01677033

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារ D381/45 & D382/43

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦១)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 09 / 20
ម៉ោង (Time/Heure): 14:39
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ: ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០២១
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់: សាធារណៈ

# សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

**សហព្រះរាជអាជ្ញា:**

ជា លាង
Brenda J. HOLLIS

**សហមេធាវីការពារក្តី យឹម ទិត្យ:**

សូ មូស្សេន្ទី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

# មាតិកា

I. ប្រវត្តិនីតិវិធី ... 2

II. ការបញ្ចូលគ្នាក្នុងសំណុំរឿងតែមួយ ... 16

III. បទដ្ឋាននៃការពិនិត្យឡើងវិញ ... 17

IV. ភាពអាចទទួលយកបាន ... 20

ភាពអាចទទួលយកបានជាផ្លូវការ ... 20

បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ... 21

បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ... 21

បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ... 22

បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី យឹម ទិត្យ ទៅលើការចេញដីកាដំណោះស្រាយពីរក្នុងសំណុំរឿង ០០៤ ... 22

បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី យឹម ទិត្យ ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ... 24

1.សារណា ... 24

2.ការពិភាក្សា ... 26

មូលដ្ឋានអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ... 31

មូលដ្ឋាន ២.២ អាចទទួលយកបាន ... 31

មូលដ្ឋាន ៣ អាចទទួលយកបាន ... 32

មូលដ្ឋានទី៤ អាចទទួលយកបាន ... 34

មូលដ្ឋានទី ៥.១, ៥.២ និង៥.៣ គឺអាចទទួលយកបាន ... 35

មូលដ្ឋានបណ្តឹងឧទ្ធរណ៍ ដែលមិនអាចទទួលយកបាន ... 36

01677035



មូលដ្ឋានទី ១.១ និង ១.២ មិនអាចទទួលយកបាន ........ 36

មូលដ្ឋានទី ២.១ និង ២.៣ គឺមិនអាចទទួលយកបាន ........ 43

V. ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាក្នុងពេលដំណាលគ្នា ........ 45

ក. ច្បាប់ជាធរមាន ........ 46

ខ. សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា ........ 51

គ. ការពិភាក្សា ........ 55

១. គោលការណ៍ជាសារវន្ត គ្រប់គ្រងលើការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ........ 57

២. ការដោះស្រាយការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ........ 59

៣. សេចក្តីសង្កេតទាក់ទងនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នា ........ 64

VI. អង្គសេចក្តី ........ 68

VII. សេចក្តីសម្រេច ........ 69

VIII. យោបល់លោកចៅក្រមប្រាក់ គឹមសាន លោកចៅក្រមន៉យ ថុល និង លោកចៅក្រម ហួត វុទ្ធី... 71

១. គោលបំណង ........ 71

២. ការប្រជុំឆ្លងសេចក្តីព្រាងច្បាប់ អ.វ.ត.ក នៅរដ្ឋសភាជាតិ ........ 73

៣. សំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ........ 73

៤. ការដឹងឮអំពីចំនួនជនដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ........ 73

៥. លក្ខណៈពិសេសរបស់ អ.វ.ត.ក ........ 74

៦. អ្នកដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុត ........ 75

៧. ការលួចលាក់ផ្តើមធ្វើការចោទប្រកាន់តាមរយៈការស៊ើបអង្កេតបឋម ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ........ 77

៨. ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិក្នុងដីកាដំណោះស្រាយ ........ 77

**IX. យោបល់ទៅក្រុមអន្តរជាតិ** ..... 79

**បណ្តឹងឧទ្ធរណ៍របស់សហមេធាវីប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ** ..... 79

**ក. អំណះអំណាង** ..... 79

១. បណ្តឹងឧទ្ធរណ៍របស់សហមេធាវីប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ ..... 79

២. ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ..... 84

*៣. ការឆ្លើយតបរបស់សហមេធាវី* ..... 90

**ខ.ការពិភាក្សា** ..... 96

*១. គ្មានការរំលោភលើវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ និងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌* ..... 96

*២. សុពលភាពនៃដីកាដំណោះស្រាយទាំងពីរ* ..... 102

ក. អត្ថន័យនៃ "ការស៊ើបអង្កេតត្រូវធ្វើបន្ត"-មាត្រា ៥ (៤) និងមាត្រា ៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ..... 102

ខ.ការសម្រេចលើសុពលភាពនៃដីកាដំណោះស្រាយទាំងពីរនេះ ..... 107

**បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី យឹម ទិត្យ ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ** ..... 108

**A. មូលដ្ឋានទី ២.២ ÷ ការចោទប្រកាន់អំពីការខកខានមិនបានកំណត់ពីធាតុផ្សំគតិយុត្តិនៃ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អង្គហេតុសំខាន់ៗ និងតំណាងជាមូលដ្ឋាន** ..... 108

ក. សារណា ..... 108

ខ. ការពិភាក្សា ..... **111**

a. *ការកំណត់អត្តសញ្ញាណនៃខ្មែរក្រោមថាជាក្រុមដែលត្រូវទទួលបានការការពារ* ..... 112

b. *ចេតនាជាក់លាក់* ..... 118

**B. មូលដ្ឋានទី ៣ ÷ ការចោទប្រកាន់អំពីការពង្រីកវិសាលភាពអង្គហេតុនៃកិច្ចស៊ើបសួរ** ..... 123

១. សារណា ..... 123

២. ការពិភាក្សា ..... 126

a. *ឧក្រិដ្ឋកម្មនៅភូមិភាគនិរតី* ..... 127

b. *ឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យ* ...... 128

c. *សេចក្តីសន្និដ្ឋាន* ...... 130

**C. មូលដ្ឋានទី ៤ ÷ ការចោទប្រកាន់អំពីកំហុសក្នុងការប្រើប្រាស់សហឧក្រិដ្ឋកម្មរួម (JCE) ដើម្បីបង្ហាញពីយុត្តាធិការបុគ្គល** ...... 130

ក. សារណា ...... 130

ខ. ការពិភាក្សា ...... 133

**D. មូលដ្ឋានទី ៥÷ ការចោទប្រកាន់អំពីកំហុសចំពោះការរកឃើញថា លោក យឹម ទិត្យ គឺជា "ជនទទួលខុសត្រូវខ្ពស់បំផុត"** ...... 141

**សេចក្តីផ្តើម** ...... 141

**ការពិចារណាលើគន្លងចំពោះមូលដ្ឋានទី ៥** ...... 142

**មូលដ្ឋានទី ៥.១ ÷ ការចោទប្រកាន់អំពីកំហុសក្នុងការសន្និដ្ឋានថា ទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយនឹង តាម៉ុក មានន័យស្មើនឹងសិទ្ធិអំណាច*តាមព្រឹត្តន័យ* នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ** ...... 149

១. សារណា ...... 149

២.ការពិភាក្សា ...... 154

*ក.សិទ្ធិអំណាចតាមព្រឹត្តន័យរបស់ យឹម ទិត្យ នៅក្នុងតំបន់ ១៣* ...... 156

*ខ. សិទ្ធិអំណាច និងការទទួលខុសត្រូវត្រួតគ្នាទាំងនៅភូមិភាគពាយ័ព្យ និងភូមិភាគនិរតី* ...... 162

**មូលដ្ឋាន ៥.២(i)÷ កំហុសដែលរងការចោទប្រកាន់ លើការសម្រេចថា យឹម ទិត្យ គឺជាអ្នកដឹកនាំស្រុកគីរីវង់** ...... 166

ក. សារណា ...... 166

ខ. ការពិភាក្សា ...... 168

**មូលដ្ឋាន ៥.២ (ii)÷ កំហុសដែលរងការចោទប្រកាន់ ក្នុងការសម្រេចថា យឹម ទិត្យ មាន "សិទ្ធិអំណាចជាក់ស្តែងច្រើន" នូវតំបន់១៣** ...... 176

**១. សារណា** ........................................................................................................................176

**២. ការពិភាក្សា** ...................................................................................................................179

**មូលដ្ឋានទី ៥.២ (iii) ÷ កំហុសដែលរងការចោទប្រកាន់លើការសម្រេចថា យឹម ទិត្យ គឺជាលេខាតំបន់ ១** ........................................................................................................................ 184

ក. សារណា ........................................................................................................................184

ខ. ការពិភាក្សា ...................................................................................................................190

*a. ការតែងតាំង យឹម ទិត្យ ជាលេខាតំបន់ ១ នៅអំឡុងខែមិថុនា ឆ្នាំ១៩៧៨*..............................191

*b. សិទ្ធិអំណាចតាមព្រឹត្តិន័យរបស់ យឹម ទិត្យ ជាលេខាតំបន់១*...............................................202

**មូលដ្ឋានទី ៥.២ (IV) ៖ កំហុសដែលរងការចោទប្រកាន់ក្នុងការសម្រេចថា យឹម ទិត្យ ..................... គឺជាលេខាតំបន់ ៣** ........................................................................................................................ 219

ក. សារណា ........................................................................................................................219

ខ. ការពិភាក្សា ...................................................................................................................221

**មូលដ្ឋានទី ៥.២ (v) ÷ កំហុសដែលរងការចោទប្រកាន់ក្នុងការសម្រេចថា យឹម ទិត្យ គឺជាលេខាតំបន់ ៤** ........................................................................................................................ 230

ក.សារណា ........................................................................................................................230

ខ. ការពិភាក្សា ...................................................................................................................232

**មូលដ្ឋាន ៥.២(vi) ការចោទប្រកាន់អំពីកំហុសក្នុងការសម្រេចថា យឹម ទិត្យ ..................... គឺជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ** ........................................................................ 235

ក. សារណា ........................................................................................................................235

ខ. ការពិភាក្សា ...................................................................................................................238

**មូលដ្ឋានទី ៥.៣ (i)÷ ការចោទប្រកាន់អំពីកំហុសក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម ក** ........................................................................................................................ 246

១. អំណះអំណាង ...............................................................................................................246

២. ការពិភាក្សា ...................................................................................................................254

*ក. ការចូលរួមចំណែករបស់ យឹម ទិត្យ ដល់ការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន* ......256

i. ការពិនិត្យមើលការដ្ឋាន និងសហករណ៍នៅក្នុងភូមិភាគពាយ័ព្យរបស់ យឹម ទិត្យ ......256

ii. ការប្រជុំ និងការណែនាំស្តីពីការសាងសង់ និងការបង្កបង្កើនផលរបស់ យឹម ទិត្យ ......263

iii. ការអនុវត្តវិន័យតឹងតែង ......267

iv. សេចក្តីសន្និដ្ឋាន ......270

*ខ. ការចូលរួមចំណែករបស់ យឹម ទិត្យ ការបោសសម្អាត និងការកំណត់គោលដៅលើក្រុមជាក់លាក់* ...270

i. ការចូលរួមរបស់ យឹម ទិត្យ ក្នុងការជ្រើសរើស បញ្ជូន និងចាត់តាំងកម្មាភិបាលភូមិភាគនិរតីទៅកាន់ ភូមិភាគពាយ័ព្យ ......270

ii. ការចូលរួមរបស់ យឹម ទិត្យ ក្នុងការស្វាគមន៍កម្មាភិបាលភូមិភាគនិរតី នៅពេលដែលពួកគេមកដល់ បាត់ដំបង ហើយចាត់តាំងពួកគេទៅជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ ......273

iii. ការចូលរួមរបស់ យឹម ទិត្យ ក្នុងការបោសសម្អាតនៅក្នុងភូមិភាគពាយ័ព្យ និងការចាប់ខ្លួន "ប្រធាន" កងវរសេនាតូចពីររូប ដែលគ្រប់គ្រងលើការដ្ឋានរោងចក្រស្ករសកំពង់គល់ ......274

*គ. ការចូលរួមរបស់ យឹម ទិត្យ ក្នុងបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍* ......277

*ឃ. សេចក្តីសន្និដ្ឋាន* ......280

**មូលដ្ឋានទី ៥.៣(ii)÷ ការចោទប្រកាន់អំពីកំហុសចំពោះការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្ម ខ** ......280

**១. អំណះអំណាង** ......280

**២. ការពិភាក្សា** ......283

**មូលដ្ឋាន ៥.៣ (iii) ÷ កំហុសដែលរងការចោទប្រកាន់ នៅក្នុងការសម្រេចថា យឹម ទិត្យ បានរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម គ** ......288

ក. សារណា ......288

ខ. ការពិភាក្សា ......294

*a. ការចុះពិនិត្យរបស់ យឹម ទិត្យ នៅវត្តព្រះធាតុ* ......294

*b. ការចូលរួមរបស់ យឹម ទិត្យ នៅក្នុងការសួរចម្លើយនៅវត្តព្រះធាតុ* ......301

*c. ការចូលរួមរបស់ យឹម ទិត្យ នៅក្នុងការសម្លាប់មនុស្ស នៅវត្តព្រះធាតុ* ......306

01677040



សេចក្តីសន្និដ្ឋាន ........................................................................................................311

E. **សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ**......313

**បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ**......................................................................313

**១. អំណះអំណាង**.................................................................................................313

**២. ការពិភាក្សា**...................................................................................................319

**បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់**..........325

**១. អំណះអំណាង**.................................................................................................325

A. មូលដ្ឋាន ក៖ កំហុសអង្គច្បាប់នៃការសន្និដ្ឋានថា ឌុច គឺជាបុគ្គលដែលទទួល "ខុសត្រូវខ្ពស់បំផុត" តែម្នាក់គត់ ........................................................................................................326

B..មូលដ្ឋាន ខ៖ កំហុសអង្គច្បាប់នៃការខកខានមិនបានផ្តល់សេចក្តីសម្រេចមានសំអាងហេតុ ពាក់ព័ន្ធនឹង ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនិងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ យឹម ទិត្យ ...........................326

C. មូលដ្ឋាន គ៖ កំហុសអង្គច្បាប់នៃការពិចារណាលើបញ្ហារបស់ថ្នាក់លើ និងការបង្ខិតបង្ខំ ..................328

D.មូលដ្ឋាន ឃ៖ កំហុសអង្គច្បាប់ក្នុងការវាយតម្លៃការចូលរួមនិងភាពកៀកកិតនឹងឧក្រិដ្ឋកម្មរបស់ យឹម ទិត្យ ........................................................................................................329

E.មូលដ្ឋាន ង៖ ការធ្វើការសន្និដ្ឋានផ្អែកអង្គហេតុដែលនាំឲ្យមានការខុសឆ្គោយរបស់តុលាការ ...............329

F.មូលដ្ឋាន ច៖ កំហុសអង្គច្បាប់ដោយផ្តល់ទម្ងន់លើអង្គហេតុដែលមានភាពពាក់ព័ន្ធតិចតួច..................330

G.អំណះអំណាងពាក់ព័ន្ធនឹងដីកាដំណោះស្រាយផ្ទុយគ្នា ........................................................331

**២. ការពិភាក្សា**...................................................................................................333

**បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**.............................................334

**១. អំណះអំណាង**.................................................................................................334

**២. ការពិភាក្សា**...................................................................................................335

**សេចក្តីសន្និដ្ឋាន**..........................................................................................................337

01677041



**១. ការយល់ឃើញនានាលើបណ្តឹងឧទ្ធរណ៍ និងអានុភាពនៃសេចក្តីពិចារណានេះ** ........ 337

**២. សេចក្តីពិចារណាចុងក្រោយ** ........ 339

*ក. កាតព្វកិច្ចក្នុងការជំនុំជម្រះ តាមអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍* ........ 339

*ខ. សេចក្តីសន្និដ្ឋានលើអានុភាពគតិយុត្តិនៃស្ថានភាពដែលបង្កដោយដីកាពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត* ........ 344

**ផ្នែកសម្រេចសេចក្តី** ........ 350

# តារាងអក្សរកាត់

| ពាក្យ | ពាក្យបំព្រួញ/អក្សរកាត់ |
|---|---|
| កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ | កិច្ចព្រមព្រៀង អ.វ.ត.ក |
| ច្បាប់ស្ដីពីការបង្កើតឱ្យមានចៅក្រមអន្តរជាតិវិសាមញ្ញក្នុងតុលាការកម្ពុជា | ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក |
| វិធានផ្ទៃក្នុងនៃចៅក្រមអន្តរជាតិវិសាមញ្ញក្នុងតុលាការកម្ពុជា | វិធានផ្ទៃក្នុង |
| កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ | កតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ |
| អនុសញ្ញាស្ដីពីការទប់ស្កាត់ និងការផ្ដន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ | អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ |
| តុលាការយុត្តិធម៌អន្តរជាតិ | តុលាការ ICJ |
| តុលាការព្រហ្មទណ្ឌអន្តរជាតិ | តុលាការ ICC |
| តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា | តុលាការ ICTR |
| តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស យូ | តុលាការ ICTY |

| | |
|---|---|
| ហ្គោស្ការី | |
| តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន | តុលាការ SCSL |
| តុលាការយុត្តិធម៌នៃសហគមន៍សេដ្ឋកិច្ចនៃបណ្តារដ្ឋនៅអាហ្វ្រិកខាងលិច | តុលាការយុត្តិធម៌នៃ ECOWAS |
| អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា | អនុសញ្ញាវីយែន |
| ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៥៦ | ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ |
| បក្សកុម្មុយនីស្តកម្ពុជា | ប.ក.ក |
| មជ្ឈមណ្ឌលឯកសារកម្ពុជា | DC-Cam |
| កម្ពុជាប្រជាធិបតេយ្យ | DK |
| សហឧក្រិដ្ឋកម្មរួម | JCE |

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទទួលបណ្ដឹងឧទ្ធរណ៍ចំនួនប្រាំប្រឆាំងនឹងដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ (ដីកាសម្រេចលើកលែងការចោទប្រកាន់)[1] និងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[2]។ បណ្ដឹងឧទ្ធរណ៍ទាំងប្រាំនេះ រួមមាន៖ -

១. បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងសំណុំរឿង ០០៤ ដែលបានដាក់នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ("បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ")[3]។

២. បណ្ដឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង ០០៤ ដែលបានដាក់នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ("បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹង (ដីកាដំណោះស្រាយពីរ)")[4]។

៣. បណ្ដឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងសំណុំរឿង ០០៤ ដែលបានដាក់នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ("បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹង (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)")[5]។

---

[1] សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤") ដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381 ("ដីកាសម្រេចលើកលែងការចោទប្រកាន់ (ឯកសារ D381)")។

[2] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382)")។

[3] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D382/4/1 ("បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D382/4/1)")។

[4] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/18 & ឯកសារ D382/21 ("បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹង (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & ឯកសារ D382/21)")។

[5] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D382/22 (ដែលបានដាក់នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩) ("បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹង (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22)")។

៤. បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ (ឯកសារ D381) ដែលបានដាក់នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ")[6]។ និង

៥. បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង ០០៤ ដែលបានដាក់នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩) ("បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី")[7]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានបញ្ជូននូវការខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង មកអង្គបុរេជំនុំជម្រះ ដោយរាយការណ៍ថា សហព្រះរាជអាជ្ញាជាតិ មិនយល់ស្របជាមួយនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋថ្មី ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីនោះឡើយ[8]។ នៅថ្ងៃដដែលនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ដែលស្នើសុំឱ្យមានការបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការ ប្រឆាំង យឹម ទិត្យ ជាផ្នែកមួយនៃសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៥៦ ("ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦")[9]។

---

[6] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ (ឯកសារ D381) ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/19 (ដែលបានដាក់នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩) ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/19)")។

[7] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០១៩ ឯកសារ D381/20 (ដែលបានដាក់នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩) ("បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/20)")។

[8] ការខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អវតក/អបជ សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ របស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីអង្គហេតុនិងសំអាងហេតុ សម្រាប់ការខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ឯកសារលេខ១ (ការិយាល័យរដ្ឋបាល បានបញ្ជូនមកអង្គបុរេជំនុំជម្រះ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨)។

[9] សំណុំរឿង ០០៤/២០-១១-២០០៨/អវតក/កសចស ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។

2. នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ដោយមិនអាចទទួលបានសម្លេងភាគច្រើនលើសលប់ដើម្បីធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នា អង្គបុរេជំនុំជម្រះបានបង្គាប់ដល់សហព្រះរាជអាជ្ញាអន្តរជាតិ ឱ្យបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី ទៅសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង[10]។

3. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ដោយស្នើដល់សហចៅក្រមស៊ើបអង្កេត ឱ្យចាប់ផ្តើមកិច្ចស៊ើបសួរតាមផ្លូវតុលាការទៅលើ យឹម ទិត្យ ជាផ្នែកនៃសំណុំរឿង ០០៤[11]។ បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន ដើម្បីពង្រីកវិសាលភាពនៃការស៊ើបសួរ អនុលោមតាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង[12]។

4. សំណុំរឿងរបស់ យឹម ទិត្យ គឺជាកម្មវត្ថុនៃការខ្វែងយោបល់គ្នាជាសម្ងាត់ជាបន្តបន្ទាប់ រវាងសហចៅក្រមស៊ើបអង្កេត (បានចុះបញ្ជីនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣,

---

[10] ការខ្វែងយោបល់គ្នា ០០១១៨/-១១-២០០៨-អវតក អបជ/សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ៤៤-៤៥។

[10] សំណុំរឿង ០០៤០៧/-០៩-២០០៩កស/អវតក/ចស ("សំណុំរឿង ០០៤"ជូនសេចក្តី (ដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1.3 ការពិចារណាទាក់ទងនឹងការខ្វែងគំនិតរបស់សហព្រះរាជអាជ្ញា (D1/1.3) ។

[11] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1។

[12] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D65 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទីមួយ (ឯកសារ D65)")។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D191 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទីពីរ (ឯកសារ D191)")។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធវត្តតាមាក់ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ D254/1។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាព នៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D272/1។

ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ និងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧)[13]។ ការថ្លែងយោបល់ទាំងអស់នេះ មិនត្រូវបានបញ្ជូនមកអង្គបុរេជំនុំជម្រះឡើយ។

5. នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ យឹម ទិត្យ ពីបទរំលោភបំពានទៅលើមាត្រា ៥០១ និង ៥០៦ (បទមនុស្សឃាតគិតទុកជាមុន) នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩[14]។ ទាំង យឹម ទិត្យ និងសហមេធាវីការពារក្ដីគាត់ សម្រេចមិនធ្វើសេចក្ដីថ្លែងណាមួយឡើយ នៅក្នុងពេលបង្ហាញខ្លួនបឋម[15]។

6. នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ តាមរយៈសំណើរបស់គាត់ សុំមតិយោបល់ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងដល់ភាគីថា គាត់មានបំណងដកចេញនូវអង្គហេតុមួយចំនួន ពីការស៊ើបអង្កេត ហើយស្នើសុំមតិរបស់ភាគីនានាអំពីបញ្ហានេះ[16]។ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ បន្ទាប់ពីទទួលបានមតិពី យឹម ទិត្យ និងសហព្រះរាជអាជ្ញាអន្តរជាតិ[17] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងដល់ភាគីថា អង្គហេតុដែលត្រូវបានចោទប្រកាន់មួយចំនួន ដែលជាលក្ខណៈបឋម ហាក់ដូចជាស្ថិតក្រោមកម្មវត្ថុ នៃវិធាន៦៦ស្ទួន នៃវិធានផ្ទៃក្នុង និងអង្គហេតុដែល

---

[13] សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ)D382) កថាខណ្ឌ ៣២១ ,៧ ,។ ដីកាសម្រេចលើកលែងចោទប្រកាន់ ឯក) សារD381) កថាខណ្ឌ ១៣។

[14] សំណុំរឿង ០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D281 (“កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ (D281)”)។

[15] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ (D281)។

[16] សំណុំរឿង ០០៤ សំណើសុំយោបល់យោបល់ ទាក់ទងនឹងការចោទប្រកាន់ អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ D302។

[17] សំណុំរឿង ០០៤ សារណារបស់ យឹម ទិត្យ ទាក់ទងនឹងការចោទប្រកាន់ អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតបន្ថែមទៀត ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ D302/1។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សុំយោបល់ទាក់ទងនឹង ការចោទប្រកាន់ពីអង្គហេតុ ដែលមិនស៊ើបអង្កេតបន្ថែម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ឯកសារ D302/2។

រងការចោទប្រកាន់ដទៃផ្សេងទៀតមួយចំនួន ហាក់ដូចជាស្ថិតក្រោមកម្មវត្ថុ នៃការលើកលែងចោទប្រកាន់ អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង[18]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចផ្អាកបណ្តោះអាសន្ន នូវការស៊ើបអង្កេតលើអង្គហេតុទាំងអស់នោះ ហើយជូនដំណឹងដល់ភាគីថា ដីកាសម្រេចលើការលើកលែងការចោទប្រកាន់មួយចំនួន យោងតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ឬការអនុវត្តវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង នឹងត្រូវធ្វើឡើងនៅពេលបញ្ចប់កិច្ចស៊ើបសួរ[19]។

7. នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧, ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ និងថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីជូនដំណឹងបន្ថែម អំពីការផ្អាកបណ្តោះអាសន្ន ហើយជូនដំណឹងដល់ភាគីអំពីចេតនារបស់គាត់ ក្នុងការបញ្ឈប់ការស៊ើបអង្កេត លើអង្គហេតុបន្ថែម ដែលជាបឋមហាក់ដូចជាស្ថិតក្រោមកម្មវត្ថុ នៃវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង[20]។

8. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមរយៈដីកាតុលាការ បានកែសម្រួលលើបទចោទប្រឆាំង យឹម ទិត្យ ហើយបានបន្ថែមទម្រង់នៃការទទួលខុសត្រូវ ពាក់ព័ន្ធឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ នាពេលកន្លងមក កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥[21]។

---

[18] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ D302/3 ("សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ (D302/3)") កថាខណ្ឌ ៨-១៦។

[19] សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ (D302/3) កថាខណ្ឌ ៣៤-៣៦។

[20] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីគោលបំណង ដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ ឯកសារ D342 ("សេចក្តីជូនដំណឹងអំពីគោលបំណង និងការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្នក្នុងសំណុំរឿង ០០៤ (D342)")។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ លើអង្គហេតុពាក់ព័ន្ធនឹង ទីតាំងឧក្រិដ្ឋកម្មចំនួន៦កន្លែង ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ឯកសារ D349 ("សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ (ទីតាំងឧក្រិដ្ឋកម្មចំនួន៦កន្លែង) ក្នុងសំណុំរឿង ០០៤ (D349)")។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងយោងតាមវិធាន ៦៦ ស្ទួន(២) នៃផ្ទៃក្នុង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D354 ("វិធាន ៦៦ ស្ទួន(២) នៃផ្ទៃក្នុងនៃសំណុំរឿង ០០៤ (D354)")។

[21] សំណុំរឿង ០០៤ ដីកាសម្រេចកែប្រែ បទចោទប្រឆាំង យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ឯកសារ D350 ("ដីកាសម្រេចកែប្រែបទចោទ (D350)") ។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យឹម ទិត្យ ឧបសម្ព័ន្ធ ១ ដីកាសម្រេចកែប្រែបទចោទ ដែលបានកែប្រែ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ឯកសារ D350។ សូមមើលផងដែរ សេចក្តីជូនដំណឹងអំពីគោលបំណង និងការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្នក្នុងសំណុំរឿង ០០៤ (D342)។

9. នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគី អំពីការបិទបញ្ចប់ការស៊ើបសួរតាមផ្លូវតុលាការប្រឆាំង យឹម ទិត្យ អនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង[22]។ នៅថ្ងៃដដែលនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកចេញនូវអង្គហេតុដែលត្រូវបានចោទប្រកាន់មួយចំនួន អនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង[23]។

10. នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានចេញការជូនដំណឹងទីពីរ អំពីការបិទបញ្ចប់ការស៊ើបអង្កេតប្រឆាំង យឹម ទិត្យ[24]។

11. នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគីនានា នៃសំណុំរឿង០០៤/២ ថា សហចៅក្រមស៊ើបអង្កេត ពិចារណាចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា ដែលជាទូទៅអាចអនុញ្ញាតបាន តាមច្បាប់ជាធរមាន[25]។ ភាគីនៃសំណុំរឿង ០០៤ ត្រូវបានជូនដំណឹងអំពីសេចក្តីសម្រេចនេះ ហើយដែលក្រោយមក សេចក្តីសម្រេចនេះត្រូវបានចាត់ចំណាត់ថ្នាក់ឡើងវិញ ជាឯកសារសាធារណៈ[26]។

---

[22] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D358។

[23] សំណុំរឿង ០០៤ ដីកាសម្រេចកាត់បន្ថយវិសាលភាព នៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D359។ សូមមើលផងដែរ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ D302/3។ សេចក្តីជូនដំណឹងអំពីគោលបំណង និងការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្នក្នុងសំណុំរឿង ០០៤ (D342)។ សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរ (ទីតាំងឧក្រិដ្ឋកម្មចំនួន៦កន្លែង) ក្នុងសំណុំរឿង ០០៤ (D349)។ វិធាន ៦៦ ស្ទួន(២) នៃផ្ទៃក្នុងនៃសំណុំរឿង ០០៤ (D354)។

[24] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងលើកទីពីរអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D368 (ការជូនដំណឹងលើកទី២ នៃការសន្និដ្ឋានសម្រាប់ការស៊ើបសួរ (D368)។

[25] សំណុំរឿង ០០៤/២/០៧-០៨-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/២" ) ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារ ដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D355/1 ("ដីកាសម្រេចលើការដាក់បង្ហាញ ពាក់ព័ន្ធការខ្វែងយោបល់ (ឯកសារ D355/1)") កថាខណ្ឌ ១៣-១៦។

[26] សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ *D*382) កថាខណ្ឌ ១៣។

12. នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេត បានបញ្ជូនសំណុំរឿង ទៅសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ដោយស្នើដល់សហព្រះរាជអាជ្ញា ឱ្យចេញដីកាសន្និដ្ឋានស្ថាពរ ក្នុងរយៈពេល ៣ ខែ[27]។

13. នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរ ស្នើសុំឱ្យលើកលែងការចោទប្រកាន់ទាំងអស់ប្រឆាំង យឹម ទិត្យ[28]។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់គាត់ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ បានស្នើសុំឱ្យបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះ (ជារួមគឺ "ដីកាសន្និដ្ឋានស្ថាពរ")[29]។ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ សហមេធាវី យឹម ទិត្យ ("សហមេធាវី") បានដាក់ចម្លើយតបចំពោះដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធសំណើលើកលែងការចោទប្រកាន់ទាំងអស់ ប្រឆាំង យឹម ទិត្យ[30]។

14. សហចៅក្រមស៊ើបអង្កេត បានចុះបញ្ជីការខ្វែងយោបល់គ្នា ពាក់ព័ន្ធការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩[31]។ ការខ្វែងយោបល់គ្នានេះមិនត្រូវបានបញ្ជូនមកអង្គបុរេជំនុំជម្រះទេ។

15. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា។ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេច លើកលែងការចោទប្រកាន់ប្រឆាំង យឹម ទិត្យ ("ដីកាសម្រេចលើកលែងការចោទប្រកាន់") ដោយលើកលែងការចោទប្រកាន់

---

[27] សំណុំរឿង ០០៤ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ យោងតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ឯកសារ D378។

[28] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានស្ថាពរ ទាក់ទងករណី យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ឯកសារ D378/1។

[29] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹង យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D378/2។

[30] សំណុំរឿង ០០៤ ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D378/5។

[31] សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ២១។ ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D381) កថាខណ្ឌ ១៣។

ទាំងអស់ប្រឆាំង យឹម ទិត្យ ផ្អែកលើមូលដ្ឋានដែលថា គាត់មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ជា "មេដឹកនាំជាន់ខ្ពស់" ឬក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[32]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ចោទប្រកាន់ យឹម ទិត្យ និងបញ្ជូនគាត់ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងសម្រេចថា យឹម ទិត្យ ស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មួយរូប សម្រាប់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម[33]។ ដីកាដំណោះស្រាយបានចេញជាភាសាខ្មែរ និងភាសាអង់គ្លេស ហើយសំណៅបកប្រែ បានចេញនៅពេលបន្ទាប់។

16. នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ បានបង្គាប់ដល់ភាគីនានា ឲ្យដាក់សេចក្ដីជូនដំណឹង ស្ដីពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីសំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរ[34]។ សំណៅបកប្រែជាភាសាខ្មែរ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណៅបកប្រែជាភាសាអង់គ្លេស នៃដីកាសម្រេចលើកលែងការចោទប្រកាន់ ត្រូវបានជូនដំណឹងនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ និងថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩។

[32] ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D381)។

[33] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) (បន្ថែមពីលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបិទកិច្ចស៊ើបសួរជាផ្លូវការ ទៅលើអង្គហេតុដែលត្រូវបានដកចេញ ក្នុងសេចក្ដីសម្រេចតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុងហើយបានចេញដីកាសម្រេចលើកលែងចោទប្រកាន់ដោយផ្អែក លើកលែងបទចោទមួយចំនួនប្រឆាំង យឹម ទិត្យ)។

[34] សំណុំរឿង ០០៤ សេចក្ដីសម្រេចលើសំណើររបស់ យឹម ទិត្យ សុំពន្យារកាលបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D381/3 & D382/3។ សូមមើលផងដែរ សំណុំរឿង ០០៤ សំណើរបស់ យឹម ទិត្យ សុំពន្យារពេលនៃកាលបរិច្ឆេទ សម្រាប់ការជូនដំណឹងអំពីការប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D381/1 & D382/1។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ យឹម ទិត្យ សុំពន្យារពេលកាលបរិច្ឆេទកំណត់ សម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ D381& D382 (ឯកសារ D381/1 & D382/1) ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D381/2 & D382/2។

17. នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិ បានដាក់សេចក្តីជូនដំណឹង ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[35]។ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ និងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេច លើកលែងការចោទប្រកាន់[36]។ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ សហមេធាវីការពារក្តី យឹម ទិត្យ បានដាក់សេចក្តីជូនដំណឹង ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំង ដីកាដំណោះស្រាយទាំងពីរ[37]។

18. នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិ បានដាក់សារណារបស់ខ្លួន ស្តីពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាភាសាខ្មែរប៉ុណ្ណោះ ដោយស្នើដល់អង្គបុរេជំនុំជម្រះ ឲ្យលើកលែងការចោទប្រកាន់ប្រឆាំង យឹម ទិត្យ ដោយសារតែមិនមានយុត្តាធិការបុគ្គល[38]។ សំណៅបកប្រែជាភាសាអង់គ្លេស នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ត្រូវបានជូនដំណឹងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨។ សហ

[35] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិ ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំង ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ឯកសារ D382/4។

[36] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំង ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (ឯកសារ D381) ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D381/4។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំង ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (ឯកសារ D381) ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D381/11។

[37] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់ យឹម ទិត្យ ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D381/7 & D382/9។

[38] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D382/4/1)។ សូមមើលផងដែរ សំណុំរឿង ០០៤ សំណើរបស់សហព្រះរាជអាជ្ញាជាតិ សុំដាក់សារណាបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាភាសាខ្មែរជាមុនសិន ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D382/7។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះសំណើរបស់សហព្រះរាជអាជ្ញាជាតិ សុំដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាភាសាខ្មែរជាមុន ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D382/8។



E.C.C.C

01677053



ព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតប ចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩[39]។ សហព្រះរាជអាជ្ញាជាតិ មិនបានដាក់ការឆ្លើយតបឡើយ។

19. នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានបង្គាប់ឲ្យមានការផ្អាក ពេលវេលាកំណត់សម្រាប់ភាគីនានា ក្នុងការដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងដីកាដំណោះស្រាយ រហូតដល់ពេលមានការជូនដំណឹងអំពីសំណៅបកប្រែជាភាសាអង់គ្លេសដែលត្រឹមត្រូវ សម្រាប់ដីកាសម្រេចលើកលែងការចោទប្រកាន់[40]។ សំណៅបកប្រែជាភាសាអង់គ្លេសដែលត្រឹមត្រូវ របស់ដីកាសម្រេចលើកលែងការចោទប្រកាន់ ត្រូវបានដាក់ និងជូនដំណឹងនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩។

20. នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ បានអនុញ្ញាតដោយផ្នែក លើសំណើរបស់ យឹម ទិត្យ ស្នើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់[41] ដោយបង្គាប់ដល់ភាគីឲ្យដាក់បណ្តឹងឧទ្ធរណ៍

---

[39] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៤ (ឯកសារ D382) ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D382/16 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16)")។

[40] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំឲ្យអង្គបុរេជំនុំជម្រះ បង្គាប់បញ្ជាបន្ទាន់ ឲ្យផ្តល់នូវការបកប្រែដោយត្រឹមត្រូវ ជាភាសាអង់គ្លេស នូវដីកាសម្រេចលើកលែងចោទប្រកាន់ចំពោះ យឹម ទិត្យ និងផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/12 & D382/13។ សូមមើលផងដែរ សំណុំរឿង ០០៤ សំណើរបស់ យឹម ទិត្យ សុំឲ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាបន្ទាន់ ឲ្យផ្តល់នូវការបកប្រែជាភាសាអង់គ្លេស នៃដីកាសម្រេចលើកលែងចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលត្រឹមត្រូវ និងផ្អាកកាលបរិច្ឆេទកំណត់ នៃបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/5 & D382/5។ សំណុំរឿង ០០៤ សារអេឡិចត្រូនិករបស់ការិយាល័យសហព្រះរាជអាជ្ញា ពាក់ព័ន្ធការកែតម្រូវដីកាសម្រេចលើកលែងចោទប្រកាន់ សំណុំរឿង ០០៤ (ឯកសារ D381) ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/6 & D382/6។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ ទាក់ទងនឹងការបកប្រែ ជាភាសាអង់គ្លេស នៃដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/9 & D382/11។

[41] សំណុំរឿង ០០៤ សំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/8 & D382/10។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមទំព័រ និងពេលវេលាកំណត់ ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/13 & D382/15។ សំណុំរឿង ០០៤ ការឆ្លើយតបរបស់ យឹម ទិត្យ ចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមទំព័រ និងពេលវេលាកំណត់ ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ឯកសារ

ដាច់ពីគ្នា ចំពោះដីកាដំណោះស្រាយនីមួយៗ ហើយអនុញ្ញាតឱ្យភាគី អាចដាក់សារណាចំនួន ១០០ទំព័រ ក្នុងរយៈពេល៤៥ថ្ងៃ គិតចាប់ពីពេលជូនដំណឹង អំពីសំណៅបកប្រែជាភាសាអង់គ្លេស ដែលត្រឹមត្រូវ នៃដីកាសម្រេចលើកលែងការចោទប្រកាន់[42]។

21. នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ សហមេធាវី បានដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងការចេញដីកាដំណោះស្រាយទាំងពីរ ("បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយទាំងពីរ)") ជាភាសាអង់គ្លេស ដោយអះអាងថា សហចៅក្រមស៊ើបអង្កេត មានកំហុសអង្គច្បាប់ ដែលចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា ហើយស្នើដោយទទូចដល់អង្គបុរេជំនុំជម្រះឱ្យបដិសេធចោលដីកាដំណោះស្រាយទាំងពីរ[43]។ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)") ជាភាសាអង់គ្លេស[44] ដោយចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការសម្រេចថា យឹម ទិត្យ ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យបដិសេធចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងប្រឆាំង យឹម ទិត្យ[45]។ សំណៅបកប្រែជាភាសាខ្មែរ នៃបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ត្រូវបានជូនដំណឹងនៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០ និងថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០។

---

D381/15 & D382/18។ សូមមើលផងដែរ សំណុំរឿង ០០៤ សំណើសុំការអនុញ្ញាតដើម្បីដាក់ ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាដំណោះស្រាយ តែមួយភាសា ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/14 & D382/17។

[42] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/16 & D382/19 (ដីកាសម្រេចលើកទី២ លើសំណើរពន្យាពេល (D381/16 & D382/19)។

[43] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយទាំងពីរ) (ឯកសារ D381/18 & D382/21)។

[44] សូមមើល សំណុំរឿង ០០៤ សំណើសុំការអនុញ្ញាត ដើម្បីដាក់បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយ តែមួយភាសា ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/17 & D382/20។

[45] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22)។

22. នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សារណារបស់ខ្លួន ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំង ដីកាសម្រេចលើកលែងការចោទប្រកាន់ ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ") ជាភាសាអង់គ្លេស ដោយលើកទឡ្ហីករណ៍ថា ដីកាសម្រេចលើកលែងការចោទប្រកាន់ មានកំហុសអង្គហេតុនិងកំហុសអង្គច្បាប់មួយចំនួន ដែលបណ្តាលឱ្យមានការសម្រេចដោយខុសឆ្គង "យ៉ាងជាក់ច្បាស់" ថា យឹម ទិត្យ មិនមែនជាកម្មវត្ថុ នៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ នៅក្នុងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យច្រានចោលដីកាសម្រេចលើកលែងការចោទប្រកាន់ ហើយបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[46]។ សំណៅបកប្រែជាភាសាខ្មែរ នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានដាក់នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ ហើយជូនដំណឹងនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០។

23. នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សារណារបស់ខ្លួន ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំង ដីកាសម្រេចលើកលែងការចោទប្រកាន់ ("បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី") ជាភាសាអង់គ្លេស និងភាសាខ្មែរ[47]។ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគេ សហមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិ មានកំហុសអង្គច្បាប់និងអង្គហេតុ ដោយសន្និដ្ឋានថា យឹម ទិត្យ មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក និងជាជម្រើសផ្សេងវិញ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចឈានដល់សេចក្តីសម្រេចដោយសម្លេងភាគច្រើនលើសលប់ ដែលក្របខណ្ឌគតិយុត្តិ អ.វ.ត.ក បានតម្រូវទេ គឺដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[48]។ មិនមានភាគីណាមួយ ដាក់ចម្លើយតបចំពោះបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

24. នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ អង្គបុរេជំនុំជម្រះ បានយល់ស្របមួយផ្នែក ទៅលើសំណើរបស់ភាគី សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់[49] ដោយអនុញ្ញាតឱ្យភាគីដាក់ឯកសារតែមួយភាសា

[46] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/19)។

[47] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/20)។

[48] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/20)។

[49] សំណុំរឿង ០០៤ សំណើបន្ទាន់របស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់ចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/21 & D382/23។ សំណុំរឿង

ដោយសំណៅបកប្រែត្រូវដាក់ជូនតាមក្រោយ ហើយអនុញ្ញាតឱ្យដាក់ចម្លើយតបចំនួន៦០ទំព័រ ក្នុងរយៈពេល ៤៥ ថ្ងៃ គិតចាប់ពីពេលជូនដំណឹង អំពីសំណៅបកប្រែនៃបណ្តឹងឧទ្ធរណ៍នីមួយៗ និងការឆ្លើយតបចំនួន៣០ទំព័រ ក្នុងរយៈពេល២៥ថ្ងៃ គិតចាប់ពីពេលជូនដំណឹង អំពីចម្លើយតបនីមួយៗ[50]។

25. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ និងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបចំពោះបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[51] និងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយទាំងពីរ)[52] ជាភាសាអង់គ្លេស និងភាសាខ្មែរ។ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ សហមេធាវីបានដាក់ចម្លើយតប ចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជាភាសាអង់គ្លេស[53]។ សំណៅបកប្រែជាភាសាខ្មែរ នៃចម្លើយតបរបស់សហមេធាវី ត្រូវបានដាក់នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ ហើយត្រូវបានជូនដំណឹងនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០។

---

០០៤ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ សម្រាប់ចម្លើយតប និងការឆ្លើយតបរបស់ខ្លួន ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/22 & D383/24។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់របស់ យឹម ទិត្យ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/23 & D382/25។

[50] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់ចម្លើយតបពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ឯកសារ D381/24 & D382/26 (ដាក់នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០)។

[51] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ រឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D382/27 (ជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០) ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27)")។

[52] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D381/25 & D382/28 (ជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០) ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 & D382/28)")។

[53] សំណុំរឿង ០០៤ ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D381/26 ("ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/26)")។

26. នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ និងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ សហមេធាវីបានឆ្លើយតប ចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[54] និងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយទាំងពីរ)[55]។ សំណៅបកប្រែជាភាសាខ្មែរនៃការឆ្លើយតប ត្រូវបានជូនដំណឹងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ និងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០។ សហព្រះរាជអាជ្ញាអន្តរជាតិ បានឆ្លើយតបចំពោះចម្លើយតបរបស់សហមេធាវី ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងដីកាសម្រេចលើកលែងការចោទប្រកាន់ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ជាភាសាអង់គ្លេស និងភាសាខ្មែរ (ជូនដំណឹងនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០)[56]។

27. នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើសុំដាក់សារណាបន្ថែម លើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងដីកាសម្រេចលើកលែងការចោទប្រកាន់ អាស្រ័យដោយមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០៤/២[57] ដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា មានផលប៉ះពាល់ដោយផ្ទាល់ ទៅលើការពិភាក្សាសម្រេចរបស់

---

[54] សំណុំរឿង ០០៤ ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ ឯកសារ D382/29 ("ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/29)")។

[55] សំណុំរឿង ០០៤ ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ ឯកសារ D381/27 & D382/30 ("ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 & D382/30)")។

[56] សំណុំរឿង ០០៤ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់គាត់ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ប្រឆាំង យឹម ទិត្យ (ឯកសារ D381) ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ឯកសារ D381/28 ("ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/28)")។

[57] សំណុំរឿង ០០៤/២/០៧-០៨-២០០៩-អវតក/អជសង/អជតក សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 (សំណុំរឿង ០០៤/២ ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ (E004/2/1/1/2)។

អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤[58]។ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ សហមេធាវីបានដាក់ចម្លើយតបថា សំណើនេះគួរត្រូវបានបដិសេធចោលភ្លាមៗ ថាមិនអាចទទួលយកបាន[59]។ នៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានចេញ "សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជាអាជ្ញាអន្តរជាតិ សុំដាក់សារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់ទៅនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ" របស់ខ្លួន ដោយសម្រេចថា សំណើនេះមិនអាចទទួលយកបានទេ[60]។

28. នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះ បានអញ្ជើញភាគីទាំងអស់នៃសំណុំរឿង ០០៤ តាមរយៈសារអេឡិចត្រូនិក ឲ្យដាក់សារណាអំពីបញ្ហាថាតើ អង្គបុរេជំនុំជម្រះគួររៀបចំសវនាការផ្ទាល់មាត់ដែរឬទេ សម្រាប់បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤[61]។ ចាប់ពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ភាគីនានាបានដាក់សារណារបស់ខ្លួន[62]។

---

[58] សំណុំរឿង ០០៤ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សារណាបន្ថែម លើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់ទៅនឹងដីកាសម្រេច លើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ ឯកសារ D381/29។

[59] សំណុំរឿង ០០៤ ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សារណាបន្ថែម លើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់ទៅនឹងដីកាសម្រេច លើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី០៧ ខែកញ្ញា២០ឆ្នាំ ២០ ឯកសារ D381/31។ សូមមើលផងដែរ សំណុំរឿង ០០៤ សំណើសុំការអនុញ្ញាតដើម្បី ដាក់ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សារណាបន្ថែម លើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់ទៅនឹងដីកាសម្រេច លើកលែងចោទប្រកាន់ យឹម ទិត្យ តែមួយភាសា ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ ឯកសារ D381/30។

[60] សំណុំរឿង ០០៤ សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជាអាជ្ញាអន្តរជាតិ សុំដាក់សារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ឯកសារ D381/44។

[61] សំណុំរឿង ០០៤ សេចក្ដីណែនាំរបស់អង្គបុរេជំនុំជម្រះ សារអេឡិចត្រូនិកថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១។

[62] សំណុំរឿង ០០៤ សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសវនាការផ្ទាល់មាត់ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ (យឹម ទិត្យ) ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/36 & D382/35។ សំណុំរឿង ០០៤ សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងសវនាការផ្ទាល់មាត់ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សារអេឡិចត្រូនិកថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/40 & D382/39។ សំណុំរឿង ០០៤ សារណារបស់ យឹម ទិត្យ ជូនអង្គបុរេជំនុំជម្រះ ស្ដីពីភាពចាំបាច់សម្រាប់ សវនាការផ្ទាល់មាត់ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/38 & D382/37។ សំណុំរឿង ០០៤ ទស្សនៈរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះសវនាការផ្ទាល់មាត់ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០២១ ឯកសារ D381/39 & D382/38។

29. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុង បានសម្រេចធ្វើការពិនិត្យសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤ ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ហើយបន្តដំណើរការនីតិវិធីដោយមិនមានសវនាការផ្ទាល់មាត់ឡើយ[63]។

## II. ការបញ្ចូលគ្នាក្នុងសំណុំរឿងតែមួយ

30. ដូចដែលបានកត់សម្គាល់ខាងលើ[64] បច្ចុប្បន្ននេះ ចៅក្រមអន្តរជាតិបានទទួលបណ្តឹងឧទ្ធរណ៍ចំនួនប្រាំ ប្រឆាំងទៅនឹងដីកាដំណោះស្រាយចំនួនពីរដែលបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤។

31. មាត្រា ១២នៃកិច្ចព្រមព្រៀង (១)[65] និងវិធាន ២ នៃវិធានផ្ទៃក្នុង ចែងថា ប្រសិនបើមានបញ្ហាណាមួយកើតមានឡើងដែលមិនមានចែងក្នុងអត្ថបទច្បាប់ អ.វ.ត.ក ចៅក្រមអន្តរជាតិត្រូវធ្វើការសម្រេចដោយអនុលោមទៅតាមច្បាប់កម្ពុជា។ ត្រង់ចំណុចនេះ ចៅក្រមអន្តរជាតិរម្លឹកថា[66]

---

[63] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសវនាការផ្ទាល់មាត់ នៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/41 & D382/40។

[64] សូមមើលខាងលើ ទំព័រ ៧។

[65] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ និងចូលជាធរមាននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ )"កិច្ចព្រមព្រៀង អ"ក.ត.វ.) មាត្រា ១២។(១)

[66] សំណុំរឿង ០០៤៦០ អបជ) ២/) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 )"សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ២/(D359/24 & D360/33)") កថាខណ្ឌ ២៥។ សំណុំរឿង ០០៣) ស.ច.ស.ក/ក.ត.វ.អ-២០០៩/០៩/០៧/"សំណុំរឿង ០០៣៣៥ អបជ) (") សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 & D267/35 កថាខណ្ឌ ៣៨ )"សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០០៣ (D266/27 & D267/35)")។

មាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "កាលណាតុលាការបានទទួលនីតិវិធីច្រើនដែលមានអង្គហេតុច្រើនជាប់ទាក់ទងគ្នា តុលាការអាចបង្គាប់ឱ្យបញ្ចូលនីតិវិធីទាំងនោះជាមួយគ្នាបាន"[67]។

32. នៅក្នុងករណីនេះ ចៅក្រមអន្តរជាតិមិនបានទទួលសំណុំរឿងច្រើនជាប់ទាក់ទងគ្នាទេ។ ផ្ទុយទៅវិញចៅក្រមអន្តរជាតិបានទទួលសំណុំរឿងចំនួនមួយ ដែលកំណត់ដោយការចេញដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរ ដែលនាំឱ្យមាននីតិវិធីបណ្តឹងឧទ្ធរណ៍ខុសគ្នា ប៉ុន្តែទាក់ទងគ្នា។ ដោយពិចារណាលើសិទ្ធិអំណាចរបស់ចៅក្រមអន្តរជាតិ ក្នុងការបង្គាប់ឱ្យបញ្ចូលគ្នានូវសំណុំរឿងច្រើនជាប់ទាក់ទងគ្នា កាតព្វកិច្ចរបស់ខ្លួនក្នុងការធានាឱ្យមានដំណើរការស្វែងរកយុត្តិធម៌ឱ្យបានត្រឹមត្រូវ និងឆាប់រហ័ស និងវិធីសាស្រ្តដែលបានប្រកាន់យកកន្លងមកក្នុងសំណុំរឿង ០០៤/០២[68] និងសំណុំរឿង ០០៣[69] ចៅក្រមអន្តរជាតិយល់ឃើញថា ការបញ្ចូលគ្នាក្នុងសំណុំរឿងតែមួយ គឺតម្រូវឱ្យមានជាចាំបាច់ក្នុងសំណុំរឿង ០០៤។

33. ហេតុដូច្នេះ ចៅក្រមអន្តរជាតិបង្គាប់ឱ្យបញ្ចូលនីតិវិធីបណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿងនេះជាមួយគ្នា ហើយនឹងដោះស្រាយជារួមទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរនៅក្នុងសេចក្តីពិចារណាទាំងនេះ។

---

ឯកសារ D266/27 & D267/35 កថាខណ្ឌ ៣៨ ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ក្នុងសំណុំ រឿង ០០០៣ (D266/27 & D267/35)")។

[67] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧) ("ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា") មាត្រា ២៩៩។

[68] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ២៤-២៧។

[69] សំណុំរឿង ការពិចារណាលើបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (D266/27 & D267/35) កថាខណ្ឌ ៣៧-៤០។

# III. មូលដ្ឋាននៃការពិនិត្យឡើងវិញ

34. ការកំណត់ថាតើ យឹម ទិត្យ ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយថាតើ គាត់ស្ថិតក្នុងយុត្តិធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណានោះ គឺជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ[70]។ ទោះជាបែបនេះក្តី អង្គបុរេជំនុំជម្រះបានសម្រេចដូចៗគ្នាថា ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការកំណត់លើចំណុចនេះ គឺជាឆន្ទានុសិទ្ធិតុលាការ និងមិនអនុញ្ញាតឱ្យបំពេញកិច្ចតាមអំពើចិត្តឡើយ ប៉ុន្តែត្រូវអនុវត្តទៅតាមគោលការណ៍ច្បាប់ដែលមានច្បាស់លាស់[71]។ ក្នុងន័យនេះ ពាក្យមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់
បំផុត គឺជាព្រំដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[72]។ ទោះបីភាពបត់បែននៃពាក្យនេះ តម្រូវ

---

[70] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35))") កថាខណ្ឌ ៤៤ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33)") កថាខណ្ឌ ២៨។ សំណុំរឿង ០០៤/១/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/១") សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 ("សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20)") កថាខណ្ឌ ២០។ សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជតក ("សំណុំរឿង ០០១") សាលក្រមលើបណ្តឹងឧទ្ធរណ៍ ០៣-កុម្ភៈ-២០១២ F28 សាលដីកាសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៦២-៧៤, ៧៩។

[71] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) កថាខណ្ឌ ៤៥។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33)") កថាខណ្ឌ ២៨ យោងទៅ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២០។ តុលាការយោធាអន្តរជាតិ សាលក្រមថ្ងៃទី០១ ខែតុលាឆ្នាំ១៩៤៦ ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៅចំពោះមុខតុលាការយោធាអន្តរជាតិ Vol. I ("សាលក្រម Nuremberg") ទំព័រ ១៧១-៣៦៧, ២៥៦។

[72] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35)) កថាខណ្ឌ ៤៥។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33)") កថាខណ្ឌ ២៨។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២០ ("កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក") មាត្រា ២(១) ច្បាប់ស្តីពីការបង្កើតឱ្យមានចៅក្រមអន្តរជាតិវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើង

ឲ្យសហចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាចមួយចំនួនក៏ដោយ តែឆន្ទានុសិទ្ធិនេះ មិនមែនគ្មានព្រំដែន និងចៀសផុតពីការត្រួតពិនិត្យរបស់ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍នោះទេ[73]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ នឹងពិនិត្យទៅលើការកំណត់របស់សហចៅក្រមស៊ើបអង្កេតដែលថា យឹម ទិត្យ ស្ថិត ឬមិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការ អនុលោមតាមបទដ្ឋាននៃការពិនិត្យឡើងវិញ ដែលអនុវត្តចំពោះសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ។

35. សេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ អាចត្រូវបានបដិសេធចោល ក្នុងករណីដែលសេចក្ដីសម្រេចនោះ (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋាន មិនបានត្រឹមត្រូវ (គឺកំហុសអង្គច្បាប់) ដែលនាំឲ្យសេចក្ដីសម្រេចនោះ គ្មានសុពលភាព (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុ មិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត (គឺកំហុសអង្គហេតុ) ដែលបណ្ដាលឲ្យមានភាពមិនយុត្តិធម៌ និង/ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុផល ដែលជាការបំពានលើឆន្ទានុសិទ្ធិ របស់សហចៅក្រមស៊ើបអង្កេត និងបង្ខំឲ្យធ្វើការសន្និដ្ឋាន ដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ឲ្យបានប្រយ័ត្នប្រយែង។ អាចនិយាយម្យ៉ាងទៀតថា ត្រូវបង្ហាញឲ្យឃើញថា សហចៅក្រមស៊ើបអង្កេត មានកំហុស ឬមានការបំពារបំពាន ដែលមានអានុភាពទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[74]។

---

នៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ (នស/រកម/១០០៤/០០៦) វិសោធនកម្មថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (“ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក”) មាត្រា ២ថ្មី។

[73] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33)”) កថាខណ្ឌ ២៨។ សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20)”) កថាខណ្ឌ ២០។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) កថាខណ្ឌ ៤៦។

[74] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33)”) កថាខណ្ឌ ២៩ យោងទៅ សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២១ យោងទៅ ផងដែរ សំណុំរឿង ០០៤ (អបជ៥២) សាលដីកាលើបណ្ដឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើ សំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាលើផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ១៥។ សូមមើលផងដែរ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35)) កថាខណ្ឌ ៤៧។

36. អង្គបុរេជំនុំជម្រះជាធម្មតានឹងបញ្ជូនសេចក្តីសម្រេចនេះឱ្យទៅសហចៅក្រមស៊ើបអង្កេត ធ្វើការពិចារណាសាជាថ្មី[75] ហើយនឹងជំនួសសេចក្តីសម្រេចរបស់ខ្លួន តែក្នុងករណីពិសេសប៉ុណ្ណោះ[76]។ នៅក្នុងករណីជាក់លាក់ នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ស្នើឡើងថា អង្គបុរេជំនុំជម្រះ មានសិទ្ធិអំណាចចេញដីកាដំណោះស្រាយថ្មីមួយ ឬចេញដីកាដំណោះស្រាយដែលបានកែប្រែរួច ដែលដីកានេះនឹងយកមកធ្វើជាមូលដ្ឋាននៃការជំនុំជម្រះ[77]។

---

[75] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33)") កថាខណ្ឌ ៣០ យោងទៅ សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") (អបជ៥២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធ សំណើសុំសម្ភាសន៍បុគ្គលដូចរាយនាម នៅក្នុងសំណើរសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D310/1/3 កថាខណ្ឌ ១៦។ សំណុំរឿង ០០២ (អបជ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការណែនាំឱ្យពិចារណាឡើងវិញ លើសំណើសុំ D153, D172, D173, D174, D178 និង D284 ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ១៩, ២៦។

[76] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33)") កថាខណ្ឌ ៣០ យោងទៅ សំណុំរឿង ០០២ (អបជ៦៧) សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូល ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D365/2/17 កថាខណ្ឌ ៦៧។ សូមមើលផងដែរ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) កថាខណ្ឌ ៤៨។

[77] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33)") កថាខណ្ឌ ៣០ យោងទៅ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២២។ សំណុំរឿង ០០១ (អបជ០២) សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 (សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ដីកាដំណោះស្រាយ) កថាខណ្ឌ ៤០។ សូមមើលផងដែរ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) កថាខណ្ឌ ៤៨។

# IV. ភាពអាចទទួលយកបាន

## ភាពអាចទទួលយកបានជាផ្លូវការ

37. ដោយកត់សម្គាល់ពីវិធាន ៧៥ នៃវិធានផ្ទៃក្នុង ដែលចែងអំពីការដាក់បណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងដោយកត់សម្គាល់ថា សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ រួមជាមួយសារណានានា ត្រូវបានដាក់តាមពេលវេលាកំណត់ តាមលក្ខខណ្ឌតម្រូវ និងអនុលោមទៅតាមសេចក្តីណែនាំ[78] អង្គជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍ទាំងប្រាំ ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ គឺអាចទទួលយកបានជាផ្លូវការ។

## បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ

38. សហព្រះរាជអាជ្ញាជាតិ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមវិធាន ៦៧(៥), ៧៣(ក) និង៧៤(២)[79] នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានជំទាស់ចំពោះភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះឡើយ[80]។

39. ដោយកត់សម្គាល់ថា សហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត[81] អង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិអាចទទួលយកបាន។

---

[78] វិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី ៩) វិសោធនកម្មនៅថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៥ ("វិធានផ្ទៃក្នុង") វិធាន ៧៥។ សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ (ឯកសារ D381/24 និង D382/26) សេចក្តីសម្រេចលើសំណើសុំ បន្ថែមចំនួនទំព័រ និងពេលវេលាកំណត់លើកទីពីរ (ឯកសារ D381/16 និង D382/19)។

[79] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D382/4/1) កថាខណ្ឌ ៥។

[80] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D382/16)។

[81] វិធាន ៦៧(៥) និង ៧៤(២) នៃវិធានផ្ទៃក្នុង។

## បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ

40. សហព្រះរាជអាជ្ញាអន្តរជាតិ បានប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចលើកលែងចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ អនុលោមតាមវិធាន ៦៧(៥) និង ៧៤(២) នៃវិធានផ្ទៃក្នុង[82]។ សហមេធាវីមិនបានជំទាស់ ចំពោះភាពអាចទទួលយកបាន នៃបណ្តឹងឧទ្ធរណ៍នេះទេ[83]។

41. អង្គជំនុំជម្រះកត់សម្គាល់ថា សហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត[84]។ អាស្រ័យហេតុនេះ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ អាចទទួលយកបាន។

## បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

42. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ដោយយោងទៅការដាក់ "សេចក្តីជូនដំណឹង អំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ" និងការណែនាំរបស់អង្គជំនុំជម្រះ[85]។

43. អនុលោមតាមវិធាន ៦៧(៥) និង ៧៤(៤)(ច) សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើសហព្រះរាជអាជ្ញា បានប្តឹងឧទ្ធរណ៍[86]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិ បានប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចលើកលែងចោទប្រកាន់[87] ដូច្នេះហើយសម្រេចថា បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលយកបាន។

---

[82] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/19) កថាខណ្ឌ ៣។

[83] ចម្លើយតបរបស់ យឹម ទិត្យ ចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/26)។

[84] វិធាន ៦៧(៥), ៧៤(២) នៃវិធានផ្ទៃក្នុង។

[85] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ៣ យោងទៅ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/4)។ សេចក្តីសម្រេចលើសំណើសុំ បន្ថែមចំនួនទំព័រ និងពេលវេលាកំណត់លើកទីពីរ (ឯកសារ D381/16 និង D382/19)។ មិនមានភាគីណាដាក់ចម្លើយតបឡើយ។

[86] វិធាន ៦៧(៥), ៧៤(៤)(ច) នៃវិធានផ្ទៃក្នុង។

[87] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/19)។

# បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី យឹម ទិត្យ នៅលើការចេញដីកាដំណោះស្រាយពីរក្នុងសំណុំរឿង ០០៤

44. សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយពីរ តាមវិធាន២១ វិធាន ៦៧(៥) និង វិធាន ៧៤ នៃវិធានផ្ទៃក្នុង[88]។ សហមេធាវីបានលើកឡើងករណីពីរ ដែលមានលក្ខណៈពាក់ព័ន្ធគ្នា ដែលគាំទ្រដល់ភាពអាចទទួលយកបាន៖ (១) ការដែលចេញដីកាដំណោះស្រាយពីរ ដែលមានវិការៈ និងពុំបានឯកភាពគ្នាលើការសម្រេចលើយុត្តាធិការបុគ្គល គឺជាបញ្ហាដែលពាក់ព័ន្ធជាសារវ័ន្តលើករណីថាតើ អ.វ.ត.ក មានយុត្តាធិការស្របច្បាប់ចំពោះលោក យឹម ទិត្យ ដែរឬទេ ហេតុដូច្នេះមូលដ្ឋាននេះ បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង និង (២) ការដែលចេញដីកាដំណោះស្រាយពីរបែបនេះ មានន័យថា សហចៅក្រមស៊ើបអង្កេត បានបង្កព្យសនកម្ម មិនអាចជួសជុលបាន ប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ដល់លោក យឹម ទិត្យ ហើយបានរំលោភវិធាន ២១ នៃវិធានផ្ទៃក្នុង និងបានរំលោភបំពានទៅលើលិខិតុបករណ៍អន្តរជាតិដទៃ[89]។ ដោយយោងទៅរកការសម្រេចជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០៤/២ ដែលថា បណ្តឹងឧទ្ធរណ៍ប្រឆាំងការចេញដីកាដំណោះស្រាយចំនួនពីរ គឺអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ដោយពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានជំទាស់ចំពោះភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះទេ[90]។

45. អង្គជំនុំជម្រះសូមបញ្ជាក់អះអាងថា ដោយសារតែ "ការចេញដីកាដំណោះស្រាយចំនួនពីរ ពុំបានប្រមើលទុកនៅក្នុងវិធានផ្ទៃក្នុង ហើយអាចតម្រូវឱ្យមានដំណោះស្រាយមួយ មុនពេលជំនុំជម្រះ

---

[88] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 និង D382/21) កថាខណ្ឌ ១២។

[89] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 និង D382/21) កថាខណ្ឌ ១៤-១៦ យោងទៅ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ 999 U.N.T.S. 171 និង 1057 U.N.T.S 407 ចូលជាធរមានថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ មាត្រា ១៤(១), (៣)(ក), (៣)(គ) ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ថ្មី (ក)(គ)។

[90] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 និង D382/28) កថាខណ្ឌ ២៤ យោងទៅ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៣៣, ១៩៩។

ដើម្បីបង្ការនូវផលប៉ះពាល់ ដែលមិនអាចជួសជុលវិញបានទៅលើសិទ្ធិទទួលការជំនុំជម្រះក្តី ដោយយុត្តិធម៌របស់ជនជាប់ចោទ” វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង គួរត្រូវបានបកស្រាយក្នុងន័យទូលាយ ដោយពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង[91]។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន តាមការបកស្រាយក្នុងន័យទូលាយ របស់វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ដោយពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង។

## បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី យឹម ទិត្យ ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ

### 1. សារណា

46. សហមេធាវីបានលើកឡើងថា បណ្តឹងឧទ្ធរណ៍របស់ខ្លួនអាចទទួលយកបាន តាមវិធាន ២១ វិធាន ៦៧(៥) និងវិធាន ៧៤ នៃវិធានផ្ទៃក្នុង[92]។ សហមេធាវីបានលើកទឡ្ហីករណ៍ថា វិធាន ៦៧(៥) និង ៧៤(៣) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យជនជាប់ចោទ ប្តឹងឧទ្ធរណ៍ចំពោះដីកា “បញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក” រួមទាំងសេចក្តីសម្រេចពាក់ព័ន្ធ យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការលើរឿងក្តី[93]។ ទោះបីជាវិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានចែងច្បាស់លាស់ពីមូលដ្ឋានសម្រាប់ការប្តឹងឧទ្ធរណ៍ក្តី តែអង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា តាមករណីជាក់ស្តែង វិធាននេះអាចពង្រីកវិសាលភាពនៃវិធាន ៧៤ នៃវិធានផ្ទៃក្នុង ដើម្បីធានាថា កិច្ចដំណើរការនីតិវិធី មានភាពយុត្តិធម៌ និងអាចតទល់គ្នាបាន[94]។ សហមេធាវីបានបញ្ចូលនូវសារណា អំពីការរំលោភបំពានទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង ទៅក្នុងមូលដ្ឋានបណ្តឹងឧទ្ធរណ៍ដែលពាក់ព័ន្ធ[95]។

47. សហមេធាវីបានលើកឡើងថា ពួកគេដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដាច់ពី បណ្តឹងឧទ្ធរណ៍ប្រឆាំង ការចេញដីកាដំណោះស្រាយពីរ ដោយសារមូលហេតុប្រសិទ្ធិភាព

[91] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៤៩។

[92] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១១។

[93] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១២។

[94] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៣។

[95] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៣។

តុលាការ និងនីតិវិធី និងដោយសារតែសារណាបណ្ដឹងឧទ្ធរណ៍ ពាក់ព័ន្ធដីកាដំណោះស្រាយពីរផ្សេងគ្នា អាចតម្រូវឱ្យមានដំណើរការនីតិវិធីផ្សេង[96]។

48. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា មូលដ្ឋាន ១, ២ និង ៣ នៃបណ្ដឹងឧទ្ធរណ៍ គឺមិនអាចទទួលយកបាន[97]។ ដំបូង សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានផ្ដល់ដោយស្វ័យប្រវត្តិ ដល់អង្គបុរេជំនុំជម្រះ នូវយុត្តាធិការបណ្ដឹងឧទ្ធរណ៍ ដើម្បីពិចារណាលើទឡ្ហីករណ៍ ផ្អែកលើការរំលោភបំពាន សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ទេ[98]។ ប៉ុន្តែភាគីម្ចាស់បណ្ដឹងឧទ្ធរណ៍ ចាំបាច់ត្រូវបង្ហាញថា កាលៈទេសៈពិសេស តម្រូវឱ្យមានកិច្ចអន្តរាគមន៍ពីអង្គជំនុំជម្រះ ដើម្បីរារាំងព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬចំពោះសិទ្ធិជាសារវន្ត ក្នុងការទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌[99]។

49. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បដិសេធថាមូលដ្ឋានទី១ គឺមិនអាចទទួលយកបានឡើយ ដោយសារតែការអះអាង អំពីការរំលោភបំពានលើ សិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ គឺជាការទាយស្មាន ហើយសហមេធាវីមិនបានបង្ហាញថា ការចោទប្រកាន់អំពីការរំលោភបំពាននេះ ធ្វើឱ្យប៉ះពាល់ដល់សុចរិតភាព នៃកិច្ចដំណើរការនីតិវិធី ក្នុងលក្ខណៈមួយដែលធ្វើឱ្យ ការជំនុំជម្រះប្រកបដោយយុត្តិធម៌ មិនអាចដំណើរការទៅបាននោះឡើយ[100]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា មូលដ្ឋានទី២ មិនអាចទទួលយកបាន ដោយសារតែការអះអាងរបស់សហមេធាវីថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានវិការៈ គឺផ្ទុយទៅនឹង

---

[96] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៤ យោងទៅ សេចក្ដីសម្រេចលើសំណើសុំ បន្ថែមចំនួនទំព័រ និងពេលវេលាកំណត់លើកទីពីរ (ឯកសារ D381/16 និង D382/19) កថាខណ្ឌ ១២។

[97] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ៥-៧។

[98] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ៤ យោងទៅ វិធាន ២១ នៃវិធានផ្ទៃក្នុង។

[99] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ៤ យោងទៅ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៤៧។

[100] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ៤-៥។

ការសម្រេចរបស់អង្គបុរេជំនុំជម្រះដែលថា វិការៈបែបនេះគឺមានលក្ខណៈ មិនមែនយុត្តាធិការឡើយ[101]។ ជាចុងក្រោយ មូលដ្ឋានទីបីមិនអាចទទួលយកបាន ដោយសារតែការអះអាងរបស់សហមេធាវីដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពង្រីកហួសពី "វិសាលភាពពេលវេលា និងភូមិសាស្ត្រនៃកិច្ចស៊ើបសួរ"[102] មិនបង្កើតបានជាការជំទាស់ ចំពោះយុត្តាធិការបុគ្គលឡើយ បើផ្អែកទៅលើការសម្រេចកន្លងមករបស់អង្គបុរេជំនុំជម្រះ[103]។

50. នៅក្នុងការឆ្លើយតប សហមេធាវីមិនបានពិភាក្សាអំពីបញ្ហា នៃភាពអាចទទួលយកបានរបស់បណ្តឹងឧទ្ធរណ៍នេះឡើយ[104]។

## 2. ការពិភាក្សា

51. នៅពេលចាប់ផ្តើម អង្គបុរេជំនុំជម្រះសង្កេតឃើញថា ជំពូក II នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក កំណត់និយមន័យនៃយុត្តាធិការពេលវេលា យុត្តាធិការបុគ្គល និងយុត្តាធិការលើរឿងក្តី របស់ អ.វ.ត.ក[105]។ អង្គជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ជនត្រូវចោទឬជនជាប់ចោទ អាចប្តឹងឧទ្ធរណ៍តែទៅលើដីកានិងសេចក្តីសម្រេច របស់សហចៅក្រមស៊ើបអង្កេត ដែលមានចែងនៅក្នុងបទប្បញ្ញត្តិនេះទេ[106]។ ជាពិសេសវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង

---

[101] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ៦ យោងទៅសំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៣៩។

[102] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ៧ យោងទៅបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៩៧។

[103] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ៧ យោងទៅសំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៥៦។

[104] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/29)។

[105] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ជំពូក II មាត្រា ២ថ្មី-៨។ សំណុំរឿង ០០២ (អបជ ១៤៥ និង១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 និង D427/3/15 ("សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) (ឯកសារ D427/2/15 និង D427/3/15)") កថាខណ្ឌ ៦៣។

[106] វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង។

បានចែងថា ដីកាឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលអាចជំទាស់បាន រួមមាន ដីកាឬសេចក្តីសម្រេចដែល "បញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក"[107]។ ក្នុងន័យនេះ អង្គបុរេជំនុំជម្រះសូមរំឭកថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ត្រូវតែអាចប្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការ ដែលសម្រេចដោយសហចៅក្រមស៊ើបអង្កេត"[108]។

52. ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺអាចទទួលយកបាន ប្រើសិនបើការនេះពាក់ព័ន្ធជាមួយ៖ (១) យុត្តាធិការលើរឿងក្តី តាមអនុវិធាន៧៤(៣)(ក) (២) យុត្តាធិការបុគ្គលតាមអនុវិធាន ៧៤(៣)(ក) និង/ឬ (៣) បញ្ហាពិសេសនៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលត្រូវត្រួតពិនិត្យ តាមករណីជាក់ស្តែង ដែលអាចតម្រូវឲ្យមានការពង្រីក សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ តាមការចែងក្នុងអនុវិធាន ៧៤(៣)(ក) ដោយពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង[109]។ ក្នុងករណីបច្ចុប្បន្ន សហមេធាវីបានលើកឡើងនូវការជំទាស់យុត្តាធិការបុគ្គល ព្រមទាំងបញ្ហាពិសេសនៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន ៧៤(៣)(ក) និងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលអង្គជំនុំជម្រះ នឹងធ្វើការពិនិត្យនៅផ្នែកខាងក្រោម។

53. ចំពោះបញ្ហាយុត្តាធិការបុគ្គល អង្គបុរេជំនុំជម្រះកត់សម្គាល់ថា យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺកម្រិតត្រឹម "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្ម[110]។

---

[107] វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

[108] សំណុំរឿង ០០២ (អបជ១០៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារឯកសារ D427/4/15 កថាខណ្ឌ ១៤ (លុបចោលជើងទំព័រ)។ សូមមើលផងដែរ សំណុំរឿង ០០២ (អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 ("សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30)") កថាខណ្ឌ ៤៤-៤៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និងអៀង ធីរិទ្ធ) (ឯកសារ D427/2/15 និង D427/3/15) កថាខណ្ឌ ៥៩-៦០។ សំណុំរឿង ០០២ (អបជ៣៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ១៩, ២១។

[109] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ៦៣។

[110] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២(១)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២ថ្មី។

បន្ថែមលើនេះ អង្គជំនុំជម្រះកត់សម្គាល់ថា ទោះបីជាពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" មិនមានកំណត់និយមន័យ ដោយកិច្ចព្រមព្រៀង ស្តីពីការបង្កើត អ.វ.ត.ក ឬច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក្តី តែគោលការណ៍ណែនាំសម្រាប់ការបកស្រាយ អាចទាញចេញតាមរយៈការពិនិត្យមើលផងដែរទៅលើយុត្តិសាស្ត្រអន្តរជាតិ ផ្អែកលើគោលដៅនិងគោលបំណងនៃលិខិតុបករណ៍បង្កើតតុលាការ[111]។ ដូចដែលអង្គជំនុំជម្រះ ជាច្រើនរបស់ អ.វ.ត.ក បានសម្រេចរួចហើយ យុត្តិសាស្ត្រអន្តរជាតិបានកំណត់ថា ការកំណត់អត្តសញ្ញាណបុគ្គលដែលត្រូវស្ថិតនៅក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" រួមមាន ការវាយតម្លៃបែបបរិមាណវិស័យ និងគុណវិស័យ ទៅលើទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម (ដែលបានចោទឡើង ឬត្រូវបានចោទប្រកាន់" និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[112]។ ហេតុដូច្នេះ នៅពេលប្រឈមជាមួយការជំទាស់ចំពោះយុត្តាធិការបុគ្គល ពាក់ព័ន្ធ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" អង្គបុរេជំនុំជម្រះត្រូវតែកម្រិតការវាយតម្លៃរបស់ខ្លួន ត្រឹមបញ្ហាដែលមានលក្ខណៈសំខាន់ចំពោះការកំណត់ និងវាយតម្លៃលើយុត្តាធិការបុគ្គល នោះគឺភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និង/ឬ កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ[113]។ អង្គបុរេជំនុំ

---

[111] សូមមើលអនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ 1155 U.N.T.S. 331 *ចូលជាធរមាននៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨០* ("អនុសញ្ញាទីក្រុងវីយ៉ែន") មាត្រា ៣១(១)(ខ) (ចែងថា ពាក្យពេចន៍នៃលិខិតុបករណ៍ ត្រូវបកស្រាយជាដំបូង ផ្អែកលើបរិបទ ដែលរួមមានផងដែរ អត្ថបទនៃលិខិតុបករណ៍ ផ្អែកលើគោលដៅ និងគោលបំណងនៃលិខិតុបករណ៍នោះ) កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១២(១) (ចែងថាក្នុងករណីមានចន្លោះប្រហោង ក្នុងច្បាប់ជាធរមាន "អាចស្វែងរកការណែនាំក្នុង បទដ្ឋាននីតិវិធីដែលបានបង្កើតឡើង ក្នុងកម្រិតអន្តរជាតិ")។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ថ្មី (ចែងថា សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំ ក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ) សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 កថាខណ្ឌ ៥៨-៦០។

[112] *សូមមើលជាឧទាហរណ៍* សំណុំរឿង ០០១ សាលក្រម ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ("សំណុំរឿង ០០១ សាលក្រមអង្គជំនុំជម្រះសាលាដំបូង (ឯកសារ E188)") កថាខណ្ឌ ២២ និងជើងទំព័រ ២៨-៣០។ សំណុំរឿង ០០១ សាលដីកា ឯកសារ F28 កថាខណ្ឌ ៧១។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការបុគ្គល និងគោលនយោបាយស៊ើបសួរ ពាក់ព័ន្ធជនសង្ស័យ មាស មុត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ ឯកសារ D48 ("សំណុំរឿង ០០៣ សេចក្តីសម្រេចលើយុត្តាធិការបុគ្គល (ឯកសារ D48)") កថាខណ្ឌ ១៥ និងជើងទំព័រ ២៥ កថាខណ្ឌ ៣២១។

[113] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៤៤។

ជម្រះសូមបញ្ជាក់ឡើងវិញថា ការជំទាស់នានា ពាក់ព័ន្ធនឹងបញ្ហា ហួសពីការកម្រិតនេះ មិនអាចបង្កើតបានជាការជំទាស់យុត្តាធិការបុគ្គលឡើយ ដូច្នេះហើយគឺមិនអាចទទួលយកបាន តាមវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ទេ។[114]។

54. ចំពោះវិការៈដូចបានលើកឡើង នៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះសូមសង្កត់ធ្ងន់ថា ការជំទាស់បែបនេះគឺ "ប្រាកដណាស់ថាគ្មានលក្ខណៈជាបណ្ដឹងជំទាស់យុត្តាធិការនោះទេ ហេតុដូច្នេះហើយមិនអាចទទួលយកបានទេ នៅដំណាក់កាលមុនការជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធី ដោយគិតដល់អត្ថន័យទាំងមូលនៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង និងជំពូក II នៃច្បាប់ អ.វ.ត.ក"[115]។ ប៉ុន្តែទឡ្ហីករណ៍ទាំងអស់នេះ អាចត្រូវបានលើកឡើង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការពិចារណាលើអង្គសេចក្ដី នៅពេលសវនាការ[116]។

55. ចំពោះបណ្ដឹងឧទ្ធរណ៍ ដែលបានដាក់តាមវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះសូមរម្លឹកថា ដើម្បីធានាអំពីភាពយុត្តិធម៌ នៃកិច្ចដំណើរការនីតិវិធី ដូចដែលមានចែងនៅក្នុង វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង[117] "នៅពេលដែលអង្គហេតុ និងកាលៈទេសៈនានា នៃបណ្ដឹងឧទ្ធរណ៍តម្រូវ អង្គបុរេ

---

[114] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៤៥។

[115] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/1/30) កថាខណ្ឌ ៤៧។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និងអៀង ធីរិទ្ធ) (ឯកសារ D427/2/15 និង D427/3/15) កថាខណ្ឌ ៦៣ យោងទៅ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* Gotovina *និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-06-90-AR72.1 សាលដីកាលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់ Ante Gotovina ប្រឆាំងដីកាសម្រេចលើសារណាជាច្រើន ជំទាស់យុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ កថាខណ្ឌ ២១, ២៤។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-04-74-AR72.1 សាលដីកាលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំ របស់ Petković ប្រឆាំងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៥ កថាខណ្ឌ ១៣។

[116] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ៤៧។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) (ឯកសារ D427/2/15 និង D427/3/15) កថាខណ្ឌ ៦៣។

[117] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ៤៩ ដកស្រង់សំណុំរឿង ០០២ (អបជ៤២) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកា

ជំនុំជម្រះ មានសមត្ថកិច្ចធ្វើការពិចារណា អំពីមូលដ្ឋាននានាដែលបានលើកឡើង ដោយ[ជនជាប់ចោទ] ដែលមិនត្រូវបានរៀបរាប់ច្បាស់លាស់ ស្របតាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង តាមរយៈការបកស្រាយ ដែលមានគំនិតច្រើន អំពីសិទ្ធិរបស់ជនត្រូវចោទ ក្នុងការប្ដឹងឧទ្ធរណ៍ស្របតាមវិធាន ២១ នៃវិធានផ្ទៃក្នុង"[118]។ ទោះបីជាបែបនេះក្ដី អង្គបុរេជំនុំជម្រះសូមបញ្ជាក់ឡើងវិញថា ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានទទួលស្គាល់[119] វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានបើកផ្លូវដោយស្វ័យប្រវត្តិ សម្រាប់ការប្ដឹងឧទ្ធរណ៍ឡើយ បើទោះបីជាបណ្ដឹងឧទ្ធរណ៍ លើកឡើងអំពីបញ្ហា សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ក្ដី[120]។ ភាគីម្ចាស់បណ្ដឹងចាំបាច់ត្រូវបង្ហាញថា កាលៈទេសៈពិសេសនៃរឿងក្ដីរបស់ខ្លួន តម្រូវឱ្យមានអន្តរាគមន៍របស់អង្គជំនុំជម្រះ នៅដំណាក់កាលដាក់បណ្ដឹងឧទ្ធរណ៍ ដើម្បីជៀសវាងពីព្យសនកម្ម ដែលមិនអាចជួសជុលបានចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ជា

---

សម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣-១៤។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និងអៀង ធីរិទ្ធ) (ឯកសារ D427/2/15 និង D427/3/15) កថាខណ្ឌ ៧១។

[118] សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ 266/27 និង D267/35) កថាខណ្ឌ ៧០។ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៤៦ យោងទៅ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ៤៩។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និងអៀង ធីរិទ្ធ) (ឯកសារ D427/2/15 និង D427/3/15) កថាខណ្ឌ ៧១។

[119] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ៤។

[120] *សូមមើលជាឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និង អៀង ធីរិទ្ធ) (ឯកសារ D427/2/15 និង D427/3/15) កថាខណ្ឌ ៧៣។ សំណុំរឿង ០០៤ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការត្រួតពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D239/1/8) ("សេចក្ដីពិចារណាលើការសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ *ដោយកំបាំងមុខ* (ឯកសារ D239/1/8)") កថាខណ្ឌ ១៧។ សំណុំរឿង ០០៣ (អបជ ២១) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ឯកសារ D128/1/9 ("សេចក្ដីពិចារណាលើការសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ *ដោយកំបាំងមុខ* (ឯកសារ D128/1/9)") កថាខណ្ឌ ២០។

សារវន្ត[121]។ ជាពិសេស អង្គជំនុំជម្រះសូមរំឭកថា នៅពេលដែលដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ដោយលើកឡើងពីបញ្ហាដែលមិនអាចកែតម្រូវ ដោយអង្គជំនុំជម្រះសាលាដំបូង ហើយការបដិសេធបណ្តឹងឧទ្ធរណ៍គឺ "បង្កការខូចខាតដែលមិនអាចជួលជុលបាន ដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌" វិធាន២១ នៃវិធានផ្ទៃក្នុងអាចតម្រូវ ឱ្យពង្រីកវិសាលភាពវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង[122]។ ហេតុដូច្នេះ អង្គជំនុំជម្រះ នឹងធ្វើការវាយតម្លៃថាតើ កាលៈទេសៈនៃករណីបច្ចុប្បន្នតម្រូវឱ្យមានការបកស្រាយដោយទូលាយទៅលើវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ដោយពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង ដែរឬទេ។

56. អង្គបុរេជំនុំជម្រះនឹងសម្រេចថាតើ បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺអាចទទួលយកបានដែរឬទេ តាមវិធាន ៧៤(៣) និងវិធាន ២១ នៃវិធានផ្ទៃក្នុង។ ជាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា សហមេធាវីបានលើកឡើងករណីជាច្រើនផ្សេងៗគ្នា ដែលអាចកំណត់ថាជា "មូលដ្ឋានរង" នៃមូលដ្ឋាន១, ២ និង៥[123]។ អង្គជំនុំជម្រះនឹងពិភាក្សាលើចំណុចទាំងអស់នេះនៅផ្នែកខាងក្រោម។

## មូលដ្ឋានអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

57. អង្គបុរេជំនុំជម្រះសម្រេចថា មូលដ្ឋាន ២.២, ៣, ៤, ៥.១, ៥.២ និង៥.៣ គឺអាចទទួលយកបាន។

---

121 *សូមមើលជាឧទាហរណ៍* សេចក្តីពិចារណាលើការសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ*ដោយកំបាំងមុខ* (ឯកសារ D239/1/8) កថាខណ្ឌ ១៧។ សេចក្តីពិចារណាលើការសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ*ដោយកំបាំងមុខ* (ឯកសារ D128/1/9) កថាខណ្ឌ ២០។ សំណុំរឿង ០០៣ (អបជ២៩) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ពីអំពើបំពារបំពានធ្ងន់ធ្ងរ នៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ឯកសារ D174/1/4 យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ១៩។

122 សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) (ឯកសារ D427/1/30) កថាខណ្ឌ ៤៨។

123 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០ -៩៤, ១២១ -២៦៥។

## មូលដ្ឋាន ២.២ អាចទទួលយកបាន

58. សហមេធាវីជំទាស់ចំពោះការណ៍ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានលើកឡើងអំពីធាតុផ្សំគតិយុត្តិ នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មូលដ្ឋានអង្គហេតុនៃបទចោទ និងភស្តុតាងគាំទ្រទាក់ទងនឹងការសម្រេចថា៖ (១) ខ្មែរក្រោមគឺជាក្រុមពិសេស និង (២) យឹម ទិត្យ មានចេតនាពិសេសដែលជាលក្ខខណ្ឌតម្រូវ[124]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានវិការៈ[125] ច្បាស់ណាស់មានលក្ខណៈមិនមែនយុត្តាធិការឡើយ[126] ហើយមិនអាចទទួលយកបាន ដូចមូលដ្ឋាន ២.១ និង ២.៣[127]។

59. ទោះជាបែបនេះក្តី អង្គជំនុំជម្រះកត់សម្គាល់ថា សហមេធាវីក៏បានអះអាងថា មូលដ្ឋានរងនៃបណ្តឹងឧទ្ធរណ៍នេះ គឺអាចទទួលយកបាន ជាការជំទាស់ចំពោះយុត្តាធិការ តាមវិធាន ៧៤(៣)(ក) ដោយសារតែការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា ការចូលរួមនិងការរៀបចំរបស់ យឹម ទិត្យ លើអំពើប្រល័យពូជសាសន៍ ខ្មែរក្រោមតែមួយនោះ ធ្វើឲ្យគាត់ "ជាប់មិនឲ្យរួចពីយុត្តាធិការបុគ្គល"[128]។ អង្គបុរេជំនុំជម្រះសូមរំឭក អំពីការសម្រេចរបស់ខ្លួន ក្នុងសំណុំរឿង ០០៤/២ ដែលអង្គជំនុំជម្រះសម្រេចថា ការជំទាស់ពាក់ព័ន្ធបញ្ហាគតិយុត្តិជាអង្គសេចក្តីដូចគ្នា[129] គឺការកំណត់អត្តសញ្ញាណ "ក្រុម" គោលដៅ និងចេតនាប្រល័យពូជសាសន៍ជាក់លាក់ បង្ហាញអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវលើឧក្រិដ្ឋកម្ម ដែលដូច្នេះហើយ "អាចទទួលយកបានជា ការជំទាស់យុត្តាធិការបុគ្គល"[130]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា មូលដ្ឋាន

---

[124] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៦៥។

[125] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៧៩។

[126] *សូមមើលខាងលើ* កថាខណ្ឌ ៥៥។

[127] *សូមមើលខាងក្រោម* កថាខណ្ឌ ៨០-៨៣។

[128] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៦៣ ដកស្រង់ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៩៩៦។

[129] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៦៣-៧៨។

[130] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៥៥។

២.២ អាចទទួលយកបាន ជាការជំទាស់ចំពោះយុត្តាធិការបុគ្គល តាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

## មូលដ្ឋាន ៣ អាចទទួលយកបាន

60. មូលដ្ឋាន ៣ ជំទាស់ចំពោះការអនុវត្តហួសវិសាលភាពអង្គហេតុនៃកិច្ចស៊ើបសួរ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយចោទប្រកាន់បញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះ ពីបទឧក្រិដ្ឋ ផ្អែកលើការចោទប្រកាន់ដែលថា ស្ថិតក្រៅវិសាលភាពពេលវេលា និងភូមិសាស្ត្រ នៃការស៊ើបអង្កេត[131]។ ជាពិសេស សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់បញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះ លើឧក្រិដ្ឋកម្ម ដោយផ្អែកលើមូលដ្ឋាន នៃសមាជិកភាពរបស់គាត់ នៅក្នុងសហឧក្រិដ្ឋកម្មរួមបី នៅក្នុងភូមិភាគនិរតី ចាប់ពី "យ៉ាងហោចណាស់ក៏ចាប់ពីខែកញ្ញា-តុលា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" និងនៅក្នុងភូមិភាគពាយ័ព្យ ចាប់ពី "យ៉ាងហោចណាស់ក៏ចាប់ពីដើមឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩"[132]។ សហមេធាវីស្នើឱ្យមានការធ្វើមោឃភាពបទចោទដែល៖ (១) ក្រោយ "ដើមឆ្នាំ១៩៧៨" សម្រាប់ឧក្រិដ្ឋកម្មភូមិភាគនិរតី (២) មុនខែមករា "ឆ្នាំ១៩៧៦" សម្រាប់ឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខ វត្តព្រះធាតុ ក្នុងភូមិភាគនិរតី និង (៣) មុន "ពាក់កណ្តាលឆ្នាំ១៩៧៧" សម្រាប់ឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យ[133]។

61. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងថា មូលដ្ឋានទី៣ បង្កើតបានជា ការជំទាស់ដែលមិនអាចទទួលយកបាន ចំពោះទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូច្នេះហើយមិនអាចបង្កើតបានជាការជំទាស់លើយុត្តាធិការបុគ្គលត្រឹមត្រូវឡើយ[134]។

---

[131] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៩៥-១០៣។

[132] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ១០១៦-១០១៧។

[133] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១០៣។

[134] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ៧ ដកស្រង់ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៥៦ ("វិការៈដែលរងការចោទប្រកាន់ មិនបានដាក់បន្ទុកដោយផ្ទាល់ លើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទ ឬការទទួលខុសត្រូវរបស់ អោ អាន ឡើយ ហេតុដូចនេះ មិនអាចបង្កើតបានជា ការជំទាស់យុត្តាធិការបុគ្គលបានឡើយ")

62. អង្គជំនុំជម្រះពិចារណាថា មូលដ្ឋានទី៣ អាចត្រូវបានចាត់ទុកថា បានដាក់តាមវិធាន ២១ វិធាន ៦៧(៥) និងវិធាន ៧៤ នៃវិធានផ្ទៃក្នុង[135]។ បន្ថែមលើនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ទោះបីជាមូលដ្ឋានទី៣ មិនអាចត្រូវបានចាត់ទុក ថាជាការជំទាស់យុត្តាធិការបុគ្គលសមស្របក្តី តែមូលដ្ឋាននេះបានលើកឡើង អំពីបញ្ហានៃសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងនីត្យានុកូលភាព នៃនីតិវិធីមុនពេលជំនុំជម្រះ របស់ អ.វ.ត.ក ដែលតម្រូវឱ្យមានការអន្តរាគមន៍ពីអង្គបុរេជំនុំជម្រះ។ ក្នុងន័យនេះ អង្គជំនុំជម្រះពិចារណាថា ការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំង យឹម ទិត្យ ទៅអង្គជំនុំជម្រះសាលាដំបូង ដោយមានបទចោទព្រហ្មទណ្ឌ ដែលហួសពីវិសាលភាពពេលវេលា នៃកិច្ចស៊ើបសួរ នឹង "បង្កព្យសនកម្មដែលមិនអាចជួសជុលបាន ទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ របស់ជនជាប់ចោទ" ដូច្នេះហើយគឺផ្តល់យុត្តិកម្មសម្រាប់ការបកស្រាយដោយទូលាយ នូវវិធាន៧៤(៣) នៃវិធានផ្ទៃក្នុង ដោយពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង[136]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា មូលដ្ឋានទី៣ អាចទទួលយកបាន តាមការបកស្រាយទូលាយនៃវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ដោយពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង។

## មូលដ្ឋានទី៤ អាចទទួលយកបាន

63. មូលដ្ឋានទី៤ ជំទាស់ទៅលើការចោទប្រកាន់ពីការណ៍ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកលើការទទួលខុសត្រូវ សហឧក្រិដ្ឋកម្មរួម ជាកត្តាសម្រាប់ការសម្រេចថា យឹម ទិត្យ ជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត"[137]។ បើផ្អែកតាមសហមេធាវី កត្តាពាក់ព័ន្ធសម្រាប់ការសម្រេច "ទទួលខុសត្រូវខ្ពស់បំផុត" ចាំបាច់ត្រូវពឹងផ្អែកលើកត្តា នៃអំពើរបស់បុគ្គល មិនមែនសមាជិកភាពនៅក្នុងសហឧក្រិដ្ឋកម្មរួម ដែលមានលក្ខណៈទូលំទូលាយខ្លាំង និងមិនយុត្តិធម៌ ដែលបង្កើតបានជា

[135] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១១-១៣។

[136] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៤៧។

[137] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១០៨-១២០។

ការរំលោភបំពាន ទៅលើឆន្ទានុសិទ្ធិ[138]។ សហមេធាវីបានលើកឡើងថា មូលដ្ឋាននេះអាចទទួលយកបាន អនុលោមទៅតាមវិធាន ៧៤(៣)(ក) និងវិធាន ២១ នៃវិធានផ្ទៃក្នុង[139]។

64. អង្គជំនុំជម្រះពិចារណាថា ការចោទប្រកាន់ពីការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើសមាជិកភាពរបស់ យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួម ជាការពិចារណាពាក់ព័ន្ធ ក្នុងការសម្រេចថា យឹម ទិត្យ ស្ថិតក្នុងចំណោមអ្នក "ទទួលខុសត្រូវខ្ពស់បំផុត"[140] គឺជាប់ពាក់ព័ន្ធដោយផ្ទាល់ ជាមួយលទ្ធភាពរបស់ អ.វ.ត.ក ក្នុងការអនុវត្តយុត្តាធិការបុគ្គលរបស់ខ្លួន។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា តាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង មូលដ្ឋានទី៤ គឺជាការជំទាស់លើយុត្តាធិការបុគ្គល ដែលអាចទទួលយកបាន។

### មូលដ្ឋានទី ៥.១, ៥.២ និង៥.៣ គឺអាចទទួលយកបាន

65. មូលដ្ឋានទី ៥ ជំទាស់ដល់ការសម្រេចដែលថា យឹម ទិត្យ គឺ "ទទួលខុសត្រូវខ្ពស់បំផុត" ដូច្នេះហើយត្រូវស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[141]។ ជាពិសេស មូលដ្ឋានទី ៥.១ ជំទាស់ចំពោះកំហុសដែលពាក់ព័ន្ធ ជាមួយចំណងគ្រួសាររបស់ យឹម ទិត្យ ជាមួយ តា ម៉ុក និងសិទ្ធិអំណាចជាក់ស្តែងនាពេលបន្ទាប់មក នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ដែលអះអាងថាជាកត្តាកំណត់ សម្រាប់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ "ទទួលខុសត្រូវខ្ពស់បំផុត"[142]។ មូលដ្ឋានទី ៥.២ ជំទាស់ការសម្រេច ពាក់ព័ន្ធតួនាទីតាមផ្លូវច្បាប់របស់ យឹម ទិត្យ និងសិទ្ធិអំណាចជាក់ស្តែង នៅក្នុងភូមិភាគនិរតី និងពាយ័ព្យ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលប៉ះពាល់ដល់ការសម្រេច លើយុត្តាធិការបុគ្គល "ទទួលខុសត្រូវខ្ពស់បំផុត"[143]។ ជាចុងក្រោយ មូលដ្ឋានទី ៥.៣ ជំទាស់ចំពោះកំហុសដែលចោទឡើង ពាក់ព័ន្ធការរួម

---

[138] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១២០។

[139] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១០៥-១០៧, ១២០។

[140] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១០៨, ១១៥ យោងទៅផងដែរ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៩៩២-៩៩៩។

[141] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១២១-២៦៥។

[142] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១២៤-១៤១។

[143] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៤២-២២០។

ចំណែករបស់ យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួមមួយចំនួន ដែលមានអានុភាពដោយផ្ទាល់ ទៅលើការសម្រេចអំពី "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[144]។

66. អង្គបុរេជំនុំជម្រះពិចារណាថា កំហុសអង្គហេតុនិងអង្គច្បាប់ដែលបានចោទឡើង ពាក់ព័ន្ធសិទ្ធិអំណាច ឋានៈ តួនាទី និងការរួមចំណែករបស់ យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួមដែលចោទឡើង នៅភូមិភាគនិរតី និងពាយ័ព្យ[145] គឺមានភាពពាក់ព័ន្ធផ្ទាល់ ក្នុងការសម្រេចលើយុត្តាធិការបុគ្គល។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា មូលដ្ឋានទី ៥ ទាំងមូល គឺអាចទទួលយកបាន ជាការជំទាស់លើយុត្តាធិការបុគ្គល តាមវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

## មូលដ្ឋានបណ្ដឹងឧទ្ធរណ៍ ដែលមិនអាចទទួលយកបាន

### មូលដ្ឋានទី ១.១ និង ១.២ មិនអាចទទួលយកបាន

67. សហមេធាវីបានលើកឡើងថា មូលដ្ឋានទី ១ ដែលលើកឡើងពីបណ្ដាការរំលោភបំពាន ទៅលើសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ គឺអាចទទួលយកបានតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[146]។ ជាពិសេស មូលដ្ឋានទី ១.១ ដែលជំទាស់នឹងអសុពលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី ដោយសារតែដីកានេះត្រូវបានដាក់ជាឯកតោភាគី ដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងមិនមានហត្ថលេខារបស់សហព្រះរាជអាជ្ញាជាតិ[147]។ សហមេធាវីយល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ ដែលដំណើរការកិច្ចស៊ើបសួរផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលគ្មានសុពលភាព[148]។

68. មូលដ្ឋាន ១.២ លើកឡើង ការរំលោភបំពានជាច្រើន លើសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌[149]។ នៅក្រោមប្រភេទនៃ "ការជ្រៀតជ្រែកយ៉ាងមានប្រសិទ្ធិភាព ទៅក្នុងកិច្ចការរដ្ឋបាល

---

[144] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២២១-២៦៥។

[145] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១២១-២៦៥។

[146] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០។

[147] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២១-២៥។

[148] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥។

[149] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦-៥៣។

01677080



តុលាការ" សហមេធាវីជំទាស់ (១) ការបែកធ្លាយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ[150] (២) ការប៉ះពាល់ដល់ការស៊ើបអង្កេត តាមរយៈភាគីខាងក្រៅ ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា[151] និង (៣) ការទទួលយកលោក យឹម ទិត្យ ទៅក្នុងសំណុំរឿង ០០៤ មានភាពយឺតយ៉ាវ[152]។ នៅក្រោមប្រភេទនៃ "ការពន្យាពេលមិនត្រឹមត្រូវ" សហមេធាវីសង្កត់ធ្ងន់លើការពន្យាពេលជាច្រើន នៅក្នុងកិច្ចស៊ើបសួរសំណុំរឿង ០០៤ និងអលទ្ធភាពក្នុងការរៀបចំ ការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដោយសារតែការកន្លងហួសផុតទៅ៤០ឆ្នាំ ក្រោយឧក្រិដ្ឋកម្ម[153]។

69. ទីមួយ ពាក់ព័ន្ធការចោទពីអសុពលភាព នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី អង្គបុរេជំនុំជម្រះសូមរំឭកអំពី សេចក្តីពិចារណារបស់អង្គជំនុំជម្រះ ពាក់ព័ន្ធការខ្វែងយោបល់គ្នា របស់សហព្រះរាជអាជ្ញា លើការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី[154]។ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថា កិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អាចអនុវត្តទៅបាន ហើយថាសហព្រះរាជអាជ្ញាអន្តរជាតិ អាចបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរ ក្នុងសំណុំរឿង ០០៤[155]។ ហេតុដូច្នេះ មូលដ្ឋានរងនេះត្រូវបដិសេធចោលភ្លាមៗ។

70. ទីពីរ ពាក់ព័ន្ធនឹងការបែកធ្លាយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីសម្ងាត់ នៅក្នុងខែឧសភា ឆ្នាំ២០១១[156] ទោះបីជាអង្គបុរេជំនុំជម្រះពិចារណាថា ជាការគួរឱ្យសោកស្តាយ ប៉ុន្តែមិនមានការបង្ហាញអំពីព្យសនកម្មជាក់លាក់ ដោយសារតែការបែកធ្លាយទៅលើសិទ្ធិរបស់ យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ទេ រួមទាំងសច្ចធារណ៍នៃនិរទោស

---

[150] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៧-២៩។

[151] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៣០-៣៥។

[152] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៣៦។

[153] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៣៧-៥៣។

[154] សេចក្តីពិចារណាពាក់ព័ន្ធការខ្វែងយោបល់របស់សហព្រះរាជអាជ្ញា (ឯកសារ D1/1.3)។

[155] សេចក្តីពិចារណាពាក់ព័ន្ធការខ្វែងយោបល់របស់សហព្រះរាជអាជ្ញា (ឯកសារ D1/1.3) កថាខណ្ឌ ៤៥។

[156] កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ D72/1.1.11 នៅត្រង់ ERN (ភាសាអង់គ្លេស) 00749869។

ឬសុចរិតភាពនៃភស្តុតាង ដូចសហមេធាវីចោទប្រកាន់ឡើយ[157] ដូច្នេះហើយ សហមេធាវីមិនបាន បំពេញគ្រប់គ្រាន់ នូវបន្ទុកសម្រាប់ផ្តល់យុត្តិកម្ម ដល់ការអន្តរាគមន៍របស់ អង្គបុរេជំនុំជម្រះ ដើម្បី រារាំងព្យសនកម្ម ដែលមិនអាចជួសជុលបាន[158] ដែលត្រូវបំពេញនូវលក្ខខណ្ឌតម្រូវជាធរមាន សម្រាប់ការទទួលយកបាន[159]។

71. ទីបី អង្គបុរេជំនុំជម្រះពិចារណាថា ទឡ្ហីករណ៍របស់សហមេធាវី ដែលថា សកម្មភាពសម្ភាសន៍ របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា នាំទៅដល់ "សក្ខីកម្មដែលអាចមានភាពប្រឡាក់ប្រឡូស"[160] គឺ មិនមានការគាំទ្រឡើយ ហើយជាការទាយស្មាន។ ជាពិសេស សហមេធាវីមិនបានបង្ហាញពី កំហុសឆ្គងជាក់លាក់ណាមួយ នៅក្នុងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើ ភាពអាចជឿជាក់បាន និងតម្លៃជាភស្តុតាងរបស់ភស្តុតាងកិច្ចសម្ភាសន៍ រួមទាំងភស្តុតាងទាំងឡាយ ដែលពឹងផ្អែកលើឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមូលដ្ឋានសម្រាប់ការសួរដេញ ដោល[161]។ បន្ថែមលើនេះ អង្គបុរេជំនុំជម្រះបានគាំទ្រការអនុវត្តការសួរដេញដោលសាក្សី ដោយ ភស្តុតាងផ្សេងទៀត ដែលមានក្នុងកំណត់ហេតុ ថាជា "ការអនុវត្តកិច្ចស៊ើបអង្កេតត្រឹមត្រូវ"[162]។ បន្ថែមលើនេះ អង្គជំនុំជម្រះកត់សម្គាល់ថា ប្រសិនបើសហមេធាវីពិចារណាថា កំណត់ហេតុស្តាប់

---

[157] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៧-២៩។

[158] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៦៣ ("អង្គជំនុំជម្រះសង្កត់ធ្ងន់ថា កិច្ចនីតិវិធីនេះ ស្ថិតក្នុងដំណាក់កាលមុនជំនុំជម្រះ ដែលមិនពាក់ព័ន្ធនឹងការកំណត់ ថា មានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពនោះទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា សច្ចធានិរទោស ត្រូវបានការពារគ្រប់គ្រាន់ ដោយ ហេតុថាអនុលោមតាមវិធាន ៩៨(៤) ការសម្រេចផ្តន្ទាទោស នៅក្នុងដំណាក់កាលជំនុំជម្រះក្តី ទាមទារឲ្យមានសំឡេងគាំទ្រយ៉ាង ហោចណាស់ ពីចៅក្រមប្អូនសម្លេង និងនៅពេលរកសម្លេងភាគច្រើន តាមតម្រូវការមិនបាន "មានន័យថា ជនជាប់ចោទត្រូវរួច ផុតពីបទចោទ")។

[159] *សូមមើលខាងលើ*កថាខណ្ឌ ៥៥។

[160] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៣៣។

[161] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៤១៩-៤២១។

[162] សំណុំរឿង ០០៤/២ សាលដីកាលើសំណើរបស់ អោ អាន សុំធ្វើមោឃភាពលើ កំណត់ហេតុស្តាប់ចម្លើយនានា ដែលធ្វើឡើង ដោយអ្នកស៊ើបអង្កេតបីរូប ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D338/1/5 កថាខណ្ឌ ២១។

ចម្លើយណាមួយ ដែល "ប្រឡាក់ប្រឡូស"[163] សហមេធាវីអាចដាក់សំណើសុំមោឃភាព តាម វិធាន ៧៦ នៃវិធានផ្ទៃក្នុង[164]។ ជាចុងក្រោយ នៅក្នុងការជំនុំជម្រះនាពេលបន្ទាប់ សហមេធាវីនឹងទទួលបានឱកាសក្នុងការសួរដេញដោលសាក្សី ដែលក្នុងពេលនោះសហមេធាវីអាចសួរដេញដោលលើភាពអាចជឿជាក់បាន ឬ "ភាពប្រឡាក់ប្រឡូស" នៃសក្ខីកម្មរបស់សាក្សី[165] ដូច្នេះហើយ ការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះ គឺមិនតម្រូវឡើយនៅដំណាក់កាលនេះ។

72. ទីបួន អង្គបុរេជំនុំជម្រះច្រានចោលភ្លាមៗ ទៅលើការចោទប្រកាន់របស់ យឹម ទិត្យ ពីការចូលពិនិត្យមើលសំណុំរឿងយឺត[166] ដោយសារតែបញ្ហាត្រូវបានជំទាស់តវ៉ា និងត្រូវបានច្រានចោល នាពេលកន្លងមកហើយ[167] ហើយ សហមេធាវីក៏មិនមានបង្ហាញអំពីមូលដ្ឋានគ្រប់គ្រាន់ សម្រាប់ការពិចារណាឡើងវិញដែរ។

73. ចំពោះការចោទប្រកាន់របស់សហមេធាវី ពាក់ព័ន្ធ "ការពន្យារពេលមិនត្រឹមត្រូវ" នៅក្នុងការបញ្ចប់កិច្ចស៊ើបសួរ និងការចេញដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤ អង្គបុរេជំនុំជម្រះកត់សម្គាល់ជាបឋមថា វិធាន ២១(៤) នៃវិធានផ្ទៃក្នុង តម្រូវឱ្យកិច្ចដំណើរការនីតិវិធី ត្រូវបិទបញ្ចប់ "ក្នុងពេលវេលាសមស្របមួយ"[168]។ ទោះបីជាវិធានផ្ទៃក្នុង មិនបានកំណត់កាលបរិច្ឆេទជាក់លាក់ សម្រាប់ការចេញដីកាដំណោះស្រាយក្តី ប៉ុន្តែសហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចចេញដីកាដំណោះស្រាយ ក្នុងពេលវេលាសមស្រប ដោយសារតែគោលការណ៍នេះ រួមជាមួយគោលការណ៍ជាដៃគូ នៅក្នុងមាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជាគោលការណ៍ជាមូលដ្ឋាន ដែលមានចែងនៅក្នុង មាត្រា១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង

---

[163] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៣០-៣៥។

[164] *សូមមើល* វិធាន ៧៦ នៃវិធានផ្ទៃក្នុង។

[165] *សូមមើល* វិធាន ៨៤, ៨៧(៤) នៃវិធានផ្ទៃក្នុង។

[166] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៣៦។

[167] សំណុំរឿង ០០៤ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេច លើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D361/4/1/10 កថាខណ្ឌ ៣០។

[168] វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

សិទ្ធិនយោបាយ[169]។ អង្គជំនុំជម្រះបញ្ជាក់អះអាងឡើងវិញ នូវការសម្រេចរបស់ខ្លួន ស្តីពីច្បាប់ពាក់ព័ន្ធការពន្យាពេល លើការចេញដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/១ និង០០៤/២[170]។

74. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងករណីបច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដូច្នេះគឺបញ្ចប់ការស៊ើបសួរនៅប្រមាណជាង ២១ខែ បន្ទាប់ពីបានចេញសេចក្តីជូនដំណឹងលើកទីពីរ តាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ដែលបញ្ចប់ការស៊ើបអង្កេត នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧[171]។ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ នៅថ្ងៃតែមួយ គឺថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨[172]។

75. អង្គបុរេជំនុំជម្រះសូមរំឭក អំពីការសម្រេចកន្លងមករបស់អង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/១ និង០០៤/២ ដែលថា ពេលវេលា១៨ខែ និង១៦ខែ សម្រាប់ការចេញដីកាដំណោះស្រាយ បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត គឺច្រើនហួសហេតុ បើប្រៀបធៀបជាពិសេសជាមួយដីកាដំណោះស្រាយដែលចេញនៅក្នុងសំណុំរឿង ០០១ និង ០០២ នៅក្នុងរយៈពេល បីខែ និង ប្រាំបីខែ[173]។ នៅក្នុងសំណុំរឿង ០០៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយ នៅជាង ១៨ខែ បន្ទាប់ពីបានបញ្ចប់ ការស៊ើបអង្កេតតាមផ្លូវតុលាការ ចំណែកសហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាដំណោះស្រាយរបស់ខ្លួន នៅថ្ងៃតែមួយ ប៉ុន្តែបានសម្រេចថា ការស៊ើបអង្កេតតាមផ្លូវតុលាការ ត្រូវបានបញ្ចប់តាំងពីជាង៧ឆ្នាំមុនមក[174]។ នៅក្នុងសំណុំរឿង ០០៣

---

[169] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(គ)។

[170] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ២៨-៣១។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៦០, ៧២។

[171] សេចក្តីជូនដំណឹងលើកទី២ អំពីការបិទកិច្ចស៊ើបសួរ ឯកសារ D368។

[172] ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D381)។

[173] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៣០ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៧១។

[174] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ 266/27 និង D267/35) កថាខណ្ឌ ១៤៥ ការពិចារណារបស់ចៅក្រម BEAUVALLET and BAIK ។

ចៅក្រមអន្តរជាតិបានសម្រេចថា សហចៅក្រមស៊ើបអង្កេត មិនបានចេញដីកាដំណោះស្រាយ នៅក្នុងពេលវេលាសមស្របឡើយ[175]។

76. បន្ទាប់ពីបានពិចារណាយ៉ាងត្រឹមត្រូវ ទៅលើភាពស្មុគ្រស្មាញនៃសំណុំរឿង០០៤ និងទំហំនៃកំណត់ត្រារបស់សំណុំរឿង បើប្រៀបធៀបទៅនឹងសំណុំរឿង ០០១ ០០២ ០០៣ ០០៤/១ និង ០០៤/២ អង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេត មិនបានចេញដីកាដំណោះស្រាយ នៅក្នុងពេលវេលាសមស្របឡើយ ក្នុងសំណុំរឿងនេះ។ បន្ថែមលើនេះ អង្គបុរេជំនុំជម្រះពិចារណាថា ភាពលំបាកដែលបានលើកឡើងនៅក្នុងឧបសម្ព័ន្ធនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[176] មិនបានផ្តល់នូវយុត្តិកម្មណាមួយ សម្រាប់ការពន្យាពេលបែបនេះឡើយ ដោយសារតែបញ្ហាពាក់ព័ន្ធនឹងបុគ្គលិក និងការបកប្រែ[177] គឺអាចប្រមើលមើលបាន តាមរយៈបទពិសោធន៍កន្លងមករបស់ពួកគេ នៅក្នុងសំណុំរឿងដទៃទៀត នៅចំពោះមុខ អ.វ.ត.ក ដូច្នេះហើយការពន្យារពេលអាចត្រូវបានកាត់បន្ថយ។

77. អង្គបុរេជំនុំជម្រះក៏សម្រេចផងដែរថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា ដាច់ដោយឡែកពីគ្នារបស់សហចៅក្រមស៊ើបអង្កេត ដែលដីកាដំណោះស្រាយនីមួយៗ មានជាង ៣០០ទំព័រ ជាមួយភាសានោះ[178] គឺមិនគ្រាន់តែរំលោភបំពានទៅលើមាត្រា ៧ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ប៉ុណ្ណោះទេ[179] ប៉ុន្តែសំខាន់ជាងនេះ គឺបានជម្រុញឱ្យមានការ

[175] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ 266/27 និង D267/35) ការពិចារណារបស់ចៅក្រម BEAUVALLET and BAIK កថាខណ្ឌ ១៤៧។

[176] សូមមើល សំណុំរឿង ០០៤ លំដាប់ពេលវេលា ផែនការបញ្ចប់ការងារ ឧបសម្ព័ន្ធ ១ នៃ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382.1 ("ឧបសម្ព័ន្ធ ១ នៃ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382.1)")។ សំណុំរឿង ០០៤ ញត្តិនិងសំណើ ដាក់ជូន [សហចៅក្រមស៊ើបអង្កេត] ឧបសម្ព័ន្ធ ២ នៃ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382.1) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382.2។

[177] *សូមមើលជាឧទាហរណ៍* ឧបសម្ព័ន្ធ ១ នៃ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382.1) ERN (ភាសាអង់គ្លេស) 01620075 កថាខណ្ឌ ២៥-២៦។

[178] សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ ជាភាសាខ្មែរតែមួយ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាភាសាអង់គ្លេសតែមួយ។

[179] *សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក* អវតក/០១/២០០៧/វ/លើកទី៨ វិសោធនកម្មថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០១២ មាត្រា ៧.១។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដើម្បីជូនដំណឹងឱ្យបានពេញលេញ នូវបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកា

ពន្យារពេលដោយមិនសមស្របបន្ថែមទៀត នៅក្នុងកិច្ចដំណើរការនីតិវិធី សំណុំរឿង ០០៤ ដែលអាចជៀសវាងបាន ដោយគោរពយ៉ាងម៉ត់ចត់ទៅតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។

78. ដោយបានពិចារណាលើការពន្យារពេលដោយមិនសមស្រប ដែលកើតឡើងក្នុងសំណុំរឿង ០០៤ អង្គបុរេជំនុំជម្រះសូមសង្កត់ធ្ងន់ថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានបើកផ្លូវដោយស្វ័យប្រវត្តិសម្រាប់ការប្តឹងឧទ្ធរណ៍ឡើយ បើទោះបីជាបណ្តឹងឧទ្ធរណ៍ លើកឡើងពីបញ្ហាសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ក្តី[180]។ ដោយមិនគិតដល់រយៈពេលនៃការពន្យារពេលហួសហេតុ ដែលអាចកាត់បន្ថយបានក្នុងសំណុំរឿងនេះ អង្គជំនុំជម្រះមិនជឿជាក់ថា ការពន្យារពេលក្នុងសំណុំរឿងនេះ "ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើភាពយុត្តិធម៌នៃកិច្ចដំណើរការនិតិវិធី ដែលត្រូវបង្ខំឱ្យដំណើរការបន្តទៅមុខ"[181] និងថា តម្រូវឱ្យពង្រីកវិសាលភាព នៃវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ដោយពិចារណាលើវិធាន ២១ នៃវិធានផ្ទៃក្នុង[182]។ ប្រហែលគ្នានេះ អង្គបុរេជំនុំជម្រះពិចារណាថា ទឡ្ហីករណ៍របស់សហមេធាវី ពាក់ព័ន្ធរយៈពេលទាំងស្រុង នៃសំណុំរឿង០០៤ រយៈពេលដែលអសកម្មដោយគ្មានយុត្តិកម្ម លទ្ធភាពនៃការខូចខាត ឬការមិនអាចស្វែងរក ភស្តុតាងសាក្សី និងបណ្តឹងតវ៉ាពាក់ព័ន្ធដទៃទៀត[183] មិនបានបង្ហាញដោយគ្រប់គ្រាន ទោះដោយឡែកឬជារួមក្តីថា សិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ ដោយអង្គជំនុំជម្រះសាលាដំបូង មិនអាចធ្វើទៅបាន ឬកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿងបច្ចុប្បន្ន គឺខូចខាតមិនអាចជួសជុលបាននោះដែរ[184]។

---

ដំណោះស្រាយ ដោយអនុលោមតាមមាត្រា ៧.១ ដែលចែងថា "គ្រប់ឯកសារទាំងអស់ ត្រូវដាក់ជាភាសាខ្មែរ រួមជាមួយភាសាអង់គ្លេស និង/ឬបារាំង" សារណាបណ្តឹងឧទ្ធរណ៍ទាំងអស់ ចម្លើយតបចំពោះសារណាទាំងនោះ និងការឆ្លើយតបចំពោះចម្លើយតបទាំងនោះ ចាំបាច់ត្រូវដាក់ជាភាសាខ្មែរ និងភាសាអង់គ្លេស ឬបារាំង។

[180] *សូមមើលជាឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ (នួន ជា និងអៀង ធីរិទ្ធ) (ឯកសារ D427/2/15 និង D427/3/15) កថាខណ្ឌ ៧៣។ សេចក្តីពិចារណាលើការសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ*ដោយកំបាំងមុខ* (ឯកសារ D239/1/8) កថាខណ្ឌ ១៧។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើការសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ*ដោយកំបាំងមុខ* (ឯកសារ D128/1/9) កថាខណ្ឌ ២០។

[181] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៥១។

[182] *សូមមើលខាងលើ*កថាខណ្ឌ ៥៥។

[183] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៤០-៤២, ៤៥-៥៣។

[184] *ផ្ទុយ* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៥៤-៥៥។

79. ជាសន្និដ្ឋាន ដោយមិនមានការបង្ហាញជាក់លាក់ណាមួយ អំពីព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌នោះ អង្គបុរេជំនុំជម្រះសម្រេចថា មូលដ្ឋានទី ១.១ និង១.២ ពាក់ព័ន្ធនឹងអានុភាពដោយឡែក ឬជារួម នៃការរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ គឺមិនអាចទទួលយកបាន។

## មូលដ្ឋានទី ២.១ និង ២.៣ គឺមិនអាចទទួលយកបាន

80. មូលដ្ឋានទី ២.១ ជំទាស់លើការចោទពីការដែល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានបង្ហាញអំពីសេចក្តីពិចារណាពាក់ព័ន្ធ មូលដ្ឋានអង្គហេតុ និងភស្តុតាងគាំទ្រ ដែលប្រើប្រាស់សម្រាប់ការសម្រេចថា យឹម ទិត្យ គឺជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត"[185]។ សហមេធាវីលើកឡើងថា នេះគឺជាវិការៈជាក់ស្តែង នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ហើយការនេះមានភាពធ្ងន់ធ្ងរខ្លាំង ដែលធ្វើឱ្យស្ថិតនៅក្នុង វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ដែលត្រូវបកស្រាយរួមជាមួយវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង ដោយសារតែវិការៈនេះធ្វើឱ្យខូចខាតដល់សិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌របស់ យឹម ទិត្យ ដែលត្រូវមានឱកាសគ្រប់គ្រាន់ដើម្បីទទួលបានព័ត៌មាន និងត្រៀមរៀបចំការការពារខ្លួន[186]។

81. មូលដ្ឋានទី ២.៣ ជំទាស់ទៅលើកំហុសអង្គច្បាប់ របស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនបានបង្ហាញអំពីសុចនាករ នៃការគ្រប់គ្រងដោយប្រសិទ្ធិភាព សម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើ និងលក្ខខណ្ឌតម្រូវនៃភស្តុតាង សម្រាប់ទំនាក់ទំនងហេតុនិងផល[187]។ ចំពោះសហមេធាវី ការទាំងនេះបណ្តាលឱ្យ មានវិការៈធ្ងន់ធ្ងរជាក់ស្តែងលើ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយរំលោភបំពានទៅលើ លក្ខខណ្ឌតម្រូវទម្រង់ជាមូលដ្ឋាន នៃវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង និងសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ផងដែរ របស់ យឹម ទិត្យ ដោយសារមិនបានបញ្ជាក់ច្បាស់លាស់គ្រប់គ្រាន់ លើអង្គហេតុ និងភស្តុតាងជាក់ស្តែង ហើយធ្វើឱ្យ

---

[185] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៥៩-៦២។

[186] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៥៨, ៦២។

[187] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៨០-៩៣។

"មិនមានលទ្ធភាព" ក្នុងការកំណត់បានពីខ្លឹមសារបទចោទ និងត្រៀមរៀបចំសម្រាប់ការជំនុំជម្រះ[188]។

82. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី ២.១ និង ២.៣ លើកឡើងនូវការអះអាងអំពីកំហុសដែលមិនអាចទទួលយកបាន នៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែល "ច្បាស់ណាស់ថាមិនមែនមានលក្ខណៈ ជាបញ្ហាយុត្តាធិការឡើយ"[189]។ លើសពីនេះទៅទៀត អង្គបុរេជំនុំជម្រះសូមរំឭកអំពីសេចក្តីសម្រេចរបស់ខ្លួន ក្នុងសំណុំរឿង ០០៤/២ ដែលអង្គជំនុំជម្រះសម្រេចថាមិនអាចទទួលយកបាន ចំពោះមូលដ្ឋានបណ្តឹងឧទ្ធរណ៍ដែល "ជំទាស់នឹងទម្រង់បទល្មើស និងទម្រង់នៃការទទួលខុសត្រូវ និងការអនុវត្តជាក់ស្តែង មិនមែនអត្ថិភាពក្នុងច្បាប់ នៅក្នុងចំណុចពេលវេលាពាក់ព័ន្ធ ទៅនឹងដីកាសម្រេចចោទប្រកាន់ឡើយ"[190]។ អង្គជំនុំជម្រះកត់សម្គាល់ថា បណ្តឹងឧទ្ធរណ៍របស់សហមេធាវី មិនបានជំទាស់ចំពោះអត្ថិភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងច្បាប់ដែលបង្ហាញអំពីសមត្ថភាពរបស់តុលាការ ក្នុងការប្រើប្រាស់យុត្តាធិការឡើយ ប៉ុន្តែជំទាស់លើបញ្ហាថាតើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រើប្រាស់នូវរាល់សូចនាករណ៍កំណត់ទាំងអស់ដែរឬអត់ អំពីការគ្រប់គ្រងដោយប្រសិទ្ធិភាព និងគាំទ្រលើចំណុចនេះ ដោយភស្តុតាងគ្រប់គ្រាន់ដែរឬទេ[191] ឬថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់ពីលក្ខខណ្ឌតម្រូវហេតុនិងផល និងបាន ផ្តល់មូលដ្ឋានភស្តុតាង សម្រាប់ទំនាក់ទំនងហេតុនិងផលនេះដែរឬទេ[192]។ អង្គបុរេជំនុំជម្រះពិចារណាថា នេះគឺជាការជំទាស់ចំពោះ "ការអនុវត្តជាក់ស្តែង" នៃការគ្រប់គ្រងដោយប្រសិទ្ធិភាព និងលក្ខខណ្ឌតម្រូវហេតុនិងផល ដែល "ត្រូវដោះស្រាយនៅក្នុងដំណាក់កាលជំនុំជម្រះ"[193]។ ចំពោះទឡ្ហីករណ៍របស់សហមេធាវី ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃមូលដ្ឋានរង

---

[188] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៩៣-៩៤។

[189] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៣៩។

[190] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៥៧។

[191] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៨៥-៨៧។

[192] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ៩២។

[193] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៣៩។ នៅក្នុងសំណុំរឿង ០០៤/២ អង្គបុរេជំនុំជម្រះ បានសម្រេចប្រហែលគ្នាលើ មូលដ្ឋានរងបណ្តឹង

01677088



ទាំងអស់នេះ តាមវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះយល់ឃើញថា ការប្រឹងប្រែងបង្កើតមូលដ្ឋានបណ្តឹងឧទ្ធរណ៍នេះ ថាជាបញ្ហាសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ គឺមិនអាចជឿជាក់បានឡើយ[194]។

83. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី ២.១ និង ២.៣ គឺ មិនអាចទទួលយកបាន។

## V. ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាក្នុងពេលដំណាលគ្នា

84. នៅក្នុងសំណុំរឿងបច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេតមិនអាចទទួលបានឯកភាពរួមគ្នាស្តីពីបញ្ហាគន្លឹះថាតើ យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា ហើយបានសម្រេចចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាក្នុងពេលដំណាលគ្នានៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។ ជំនួសការបញ្ជូនករណីខ្វែងយោបល់របស់ខ្លួនទៅអង្គបុរេជំនុំជម្រះ ឬ អនុវត្តតាមករណីរកឯកភាពរួមពុំបាន សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាសម្រេចលើកលែងចោទប្រកាន់ ដោយលើកលែងបទចោទទាំងអស់ប្រឆាំង យឹម ទិត្យ[195] រីឯសហចៅក្រមស៊ើបអង្កេតអន្តរជាតិចេញ

---

សាទុក្ខ ថាមិនអាចទទួលយកបាន "ព្រោះទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ" *សូមមើល* កថាខណ្ឌ ១៥៨ និងមូលដ្ឋានរងនៃបណ្តឹងឧទ្ធរណ៍ដទៃទៀត ដែលអះអាងអំពីអត្ថិភាពនៃធាតុផ្សំបរិបទ នៃអំពើប្រល័យពូជសាសន៍ ដូចជាភាពចាំបាច់ក្នុងការបង្ហាញ អត្ថិភាពនៃគោលនយោបាយ ឬផែនការរបស់រដ្ឋ ដែលអង្គជំនុំជម្រះពិចារណាថា ជាការដាក់បន្ទុកលើ "ទម្រង់នៃធាតុផ្សំឧក្រិដ្ឋកម្ម" និងមិនមែនជាការជំទាស់ លើយុត្តាធិការដែលអាចទទួលយកបានឡើយ។ *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៦១។

[194] ចំពោះសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទ និងត្រៀមរៀបចំសម្រាប់ការជំនុំជម្រះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានលើកឡើងយ៉ាងលម្អិតអំពីសេចក្តីពិចារណាពាក់ព័ន្ធនានា ដែលបានប្រើប្រាស់សម្រាប់សម្រេចថា យឹម ទិត្យ ស្ថិតក្នុងចំណោមអ្នក "ទទួលខុសត្រូវខ្ពស់បំផុត"។ *សូមមើលជាឧទាហរណ៍* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៩៩២-៩៩៧ (ពិភាក្សាផងដែរអំពីឋានៈ សិទ្ធិអំណាចជាក់ស្តែង ភាពធ្ងន់ធ្ងរនៃអំពើប្រព្រឹត្ត ការចូលរួមនៅក្នុងអំពើប្រល័យពូជសាសន៍ខ្មែរក្រោម និងចំនួនជនរងគ្រោះ)។ ជាពិសេស ពាក់ព័ន្ធការទទួលខុសត្រូវរបស់ថ្នាក់លើក ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏បានបង្ហាញយ៉ាងលម្អិតអំពី ការគ្រប់គ្រងដោយប្រសិទ្ធិភាពរបស់ យឹម ទិត្យ ទៅលើកូនចៅ តាមរយៈតួនាទីតាមផ្លូវច្បាប់ និងសិទ្ធិអំណាចជាក់ស្តែង នៅក្នុងភូមិភាគនិរតី និងពាយ័ព្យ។ *សូមមើលជាឧទាហរណ៍* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) ទំព័រ ១៦៧-១៩១។

[195] ដីកាសម្រេចលើកលែងចោទប្រកាន់ (D381)។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបញ្ជូនគាត់ទៅជំនុំជម្រះ[196]។ អង្គបុរេជំនុំជម្រះត្រូវសម្រេចថាតើ សកម្មភាពនៃការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាក្នុងពេលដំណាលគ្នានៅក្នុងសំណុំរឿងតែមួយត្រូវបានអនុញ្ញាត ទៅតាមក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក ឬយ៉ាងណា។ ដើម្បីសម្រេចទៅតាមគោលបំណងនេះ ចៅក្រមអន្តរជាតិនឹង (១) រម្លឹកអំពីច្បាប់ដែលចែងពាក់ព័ន្ធនឹងបញ្ហានេះ (២) វាយតម្លៃនូវសំអាងហេតុតាមផ្លូវច្បាប់ដែលបានផ្តល់ជូនដោយសហចៅក្រមស៊ើបអង្កេតក្នុងការធ្វើយុត្តិកម្មដល់ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និង (៣) ពិភាក្សាសំណុំរឿងដែលកំពុងមាននៅចំពោះមុខ។

## ក. ច្បាប់ជាធរមាន

85. ទាក់ទិននឹងច្បាប់ដែលជាទូទៅចែងពាក់ព័ន្ធនឹងបញ្ហាដែលស្ថិតក្រោមការពិចារណា ជាដំបូង អង្គបុរេជំនុំជម្រះ សូមរម្លឹកដល់សារសំខាន់នៃការទទួលខុសត្រូវរួមគ្នារបស់សហចៅក្រមស៊ើបអង្កេតពីររូប ក្នុងការបើកកិច្ចស៊ើបសួរនៅ អ.វ.ត.ក ដូចដែលមាត្រា ១៤*ថ្មី*(១) នៃច្បាប់ អ.វ.ត.ក ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា "ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបានភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន"។ ជាពិសេស មាត្រា ២៣*ថ្មី* នៃច្បាប់ អ.វ.ត.ក ចែងថា៖

> រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និង ម្នាក់ទៀតជាបរទេស [...] អនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

86. ទាក់ទិននឹងការចេញដីកាដំណោះស្រាយដោយសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះសូមរម្លឹកថា វិធាន ៦៧ នៃវិធានផ្ទៃក្នុង ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

**វិធាន ៦៧÷ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត**

[196] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382)។

១. សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ។

២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយកំហុសនីតិវិធី។

៣. សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម៖

ក-អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ។

ខ-ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ

គ-ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ។

៤. ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ។ [...]

87. ទាក់ទិននឹងករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា និង/ឬ រវាងសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះសូមរម្លឹកថា មាត្រា ៥(១), (៤) និង ៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

**មាត្រា ៥៖ ចៅក្រមស៊ើបអង្កេត**

១-មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេត ទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត។

[...]

៤-សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧។

**មាត្រា ៧៖ ការដោះស្រាយនូវការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា**

១-ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាបានធ្វើសំណើស្រប តាមមាត្រា ៥ វាក្យខណ្ឌ ៤ [...] សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាត្រូវធ្វើឯកសារវាយការណ៍ជាលាយលក្ខណ៍អក្សរពីអង្គហេតុ និងហេតុផលបញ្ជាក់ពីគោលជំហរខ្វែងគំនិតគ្នារបស់ខ្លួនដាក់ជូនការិយាល័យរដ្ឋបាល។

២-ការខ្វែងគំនិតគ្នានេះនឹងត្រូវដោះស្រាយជាបន្ទាន់ដោយអង្គបុរេជំនុំជម្រះមួយមានចៅក្រមប្រាំរូប [...]។

៣-ពេលដែលទទួលបានឯកសារវាយការណ៍ ដូចមានចែងក្នុងវាក្យខណ្ឌទី១ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះភ្លាម និងបែងចែកឯកសារវាយការណ៍នេះ ជូនសមាជិកចៅក្រមអន្តរជាតិ។

៤-ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្តឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។ ការសម្រេចសេចក្តីនេះ ត្រូវជូនប្រធានរដ្ឋបាលដែលនឹងផ្សព្វផ្សាយ ហើយចែកជូនដល់សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា។ សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា នឹងត្រូវដំណើរការភ្លាមៗស្របទៅតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើគ្មានមតិភាគច្រើន ដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្តីទេ ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត។

88. វិធាន ៧២ នៃវិធានផ្ទៃក្នុងលើកឡើងជាក់លាក់នូវនីតិវិធីក្នុងការដោះស្រាយករណីខ្វែងយោបល់គ្នាដូចខាងក្រោម៖

## វិធាន ៧២: ដំណោះស្រាយករណីខ្វែងយោបល់គ្នារវាងសហចៅក្រម ស៊ើបអង្កេត

១. ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតណាម្នាក់ឬ ទាំងពីរអាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខានិងចុះកាលបរិច្ឆេទ ដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត។

២. ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ សហចៅក្រមស៊ើបអង្កេតណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និង មូលហេតុនៃការខ្វែងយោបល់គ្នានេះទៅការិយាល័យរដ្ឋបាល ដែលត្រូវរៀបចំកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនឯកសារទាំងនេះទៅចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតម្ខាងទៀត។ [...] ឯកសារអំណះអំណាងដែលទាក់ទងនឹងអង្គហេតុ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងទេ លើកលែងតែក្នុងករណី [នៅពេលករណីខ្វែងយោបល់គ្នា ពាក់ព័ន្ធនឹងសេចក្ដីសម្រេចដែលភាគីក្នុងកិច្ចដំណើរការនីតិវិធីមានសិទ្ធិប្ដឹងឧទ្ធរណ៍ អនុលោមតាមវិធានផ្ទៃក្នុងនេះ]។ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូន សំណុំរឿងថតចម្លងមួយច្បាប់ទៅអង្គបុរេជំនុំជម្រះភ្លាម។

៣. ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា។ កិច្ច ឬ សេចក្ដីសម្រេចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះត្រូវតែអនុវត្ត លើកលែងតែបញ្ហាខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម៖

ក-សេចក្ដីសម្រេចណាមួយដែលអាចនាំឲ្យជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើបណ្ដឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

ខ-ការជូនដំណឹងអំពីបទចោទប្រកាន់។ ឬ

គ-ដីកាបង្គាប់ឱ្យចាប់ខ្លួន។

ក្នុងករណីទាំងនេះ គ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅការខ្វែងយោបល់គ្នា ត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានបង្កើតឡើង ឬរយៈពេល ៣០(សាមសិប)ថ្ងៃ បានកន្លងហួស ឬអង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ។

៤. អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដូចខាងក្រោម៖ [...]

ឃ-សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន)រូបយ៉ាងតិច។ សេចក្តីសម្រេចនេះបិទផ្លូវប្តឹងឧទ្ធរណ៍។ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកបាននូវសម្លេងគាំទ្រភាគច្រើនតាមការតម្រូវ ស្របតាមមាត្រា ២៣ថ្មីនៃច្បាប់ អ.វ.ត.ក សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រមានន័យថាដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតណាម្នាក់ ត្រូវមានសុពលភាព ឬ មានន័យថា ដីកា ឬ កិច្ចស៊ើបសួរដែលបម្រុងនឹងធ្វើដោយសហចៅក្រមស៊ើបអង្កេតម្នាក់ត្រូវតែយកមកអនុវត្ត។ [...]

89. ចុងក្រោយ អង្គបុរេជំនុំជម្រះរម្លឹកថា មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធាន ២ នៃវិធានផ្ទៃក្នុងតម្រូវថា នីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវស្របទៅនឹងច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិ។ ទាក់ទិននឹងចំណុចនេះ មាត្រា១(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងក្នុងចំណោមនោះថា ក្រមនេះ “មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ”។ មាត្រា ២០*ថ្មី*, ២៣*ថ្មី*, ៣៣*ថ្មី* និង ៣៧*ថ្មី* នៃច្បាប់ អ.វ.ត.ក បញ្ជាក់ច្បាស់ថា ស្ថាប័ននានានៅ អ.វ.ត.ក ត្រូវអនុវត្តតាមនីតិវិធីជាធរមានទាំងអស់។ ចៅក្រមអន្តរជាតិបានសម្រេចរួចហើយថា បទប្បញ្ញត្តិទាំងនេះ “មានគោលដៅធានានូវនីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធិភាពរបស់កិច្ចដំណើរ

ការនីតិវិធី
អ.វ.ត.ក"[197]។

## ខ. សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញ ដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា

90. ទាក់ទិននឹងសំអាងហេតុតាមផ្លូវច្បាប់ដែលផ្ដល់ជូនដោយសហចៅក្រមស៊ើបអង្កេត ក្នុងការធ្វើយុត្តិកម្មចំពោះការចេញដីកាដំណោះស្រាយផ្ទុយគ្នានៅក្នុងសំណុំរឿងនេះ ដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នីតិវិធីក្នុងសំណុំរឿង ០០៤ ស្ថិតក្រោមករណីខ្វែងយោបល់គ្នាសម្ងាត់ជាច្រើនរវាងសហចៅក្រមស៊ើបអង្កេត រួមទាំងករណីខ្វែងយោបល់គ្នាមួយដែលបានចុះបញ្ជីនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ "ពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា"[198]។ ពុំមានករណីខ្វែងយោបល់គ្នាណាមួយត្រូវបានដាក់ជូនអង្គជំនុំជម្រះនេះទេ តែនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីនៅក្នុងសំណុំរឿង ០០៤/២ ថា សហចៅក្រមពិចារណាដីកាដំណោះស្រាយដោយឡែកពីគ្នា និងផ្ទុយគ្នា ផ្អែកលើករណីខ្វែងយោបល់គ្នាដែលត្រូវបានអនុញ្ញាតជាគោលការណ៍អនុលោមតាមច្បាប់ជាធរមាន[199] ហើយនឹងទំនងផលវិបាកសម្រាប់ដំណើរការបណ្ដឹងសាទុក្ខ ដោយបានគូសបញ្ជាក់ថា វិធាន ៧៧(១៣) ពុំបានលើកឡើង ឬហាមឃាត់ការចេញដីកាដំណោះស្រាយដោយឡែកពីគ្នានោះទេ[200]។ ភាគីនៃសំណុំរឿង ០០៤ ត្រូវបានជូនដំណឹងអំពីសេចក្ដីសម្រេចនេះ ដែលក្រោយមកត្រូវបានចាត់ប្រភេទជា ឯកសារសាធារណៈ[201]។ អង្គជំនុំជម្រះពិចារណាឃើញថា ការដាក់ដីកាដំណោះស្រាយពីរដាច់ដោយឡែក

---

[197] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ៩៥។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) កថាខណ្ឌ ៨៣។

[198] *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ២១។ ដីកាសម្រេចលើកលែងចោទប្រកាន់ (D381) កថាខណ្ឌ ១៣។

[199] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D355/1) កថាខណ្ឌ ១៣-១៦។

[200] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D355/1) កថាខណ្ឌ ១៣-១៦។

[201] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១៣។ ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D355/1)។

ពីគ្នា និងផ្ទុយគ្នា នៅក្នុងសំណុំរឿង ០០៤ បង្ហាញពីករណីខ្វែងយោបល់គ្នាដែលមិនត្រូវបានដោះស្រាយរវាងសហចៅក្រមទាំងពីររូប យ៉ាងហោចណាស់ទៅលើបញ្ហាថាតើ យឹម ទិត្យ ត្រូវស្ថិត ឬមិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

91. សហចៅក្រមស៊ើបអង្កេតបានបែងចែកសំអាងហេតុរបស់ខ្លួន នៅពេលចេញដីកាដំណោះស្រាយដោយឡែកពីគ្នា និង ផ្ទុយគ្នានៅក្នុងសេចក្តីសម្រេចមុនៗ[202] ដោយដំបូងបានចេញនៅក្នុងសំណុំរឿង ០០៤/២ និងក្រោយមក នៅក្នុងសំណុំរឿង ០០៤[203] ឬ បានជូនដំណឹងដល់ភាគីនៃសំណុំរឿង ០០៤[204] ដោយបានសម្រេចថា (១) ការដែលសហព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពរពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាជារឿងស្របច្បាប់ ទៅតាមក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក ("ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ")[205] និង (២) ការដាក់ដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ត្រូវបានអនុញ្ញាតឱ្យធ្វើទៅបាន យោងតាមការយល់ឃើញរបស់ខ្លួន ("ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់")[206]។ អង្គជំនុំជម្រះយល់ឃើញថា ជាការពាក់ព័ន្ធដែលត្រូវលើកឡើងនូវសម្រង់អត្ថបទនៃសំអាងហេតុទាំងនេះជាច្រើន ដោយចាប់ផ្តើមពីដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់៖

> ១៤. ដើម្បីកុំឱ្យមានការតវ៉ាអំពីចំណុចនេះនាពេលអនាគត [...] និងដើម្បីចំណេញពេលវេលាសម្រាប់ភាគីទាំងអស់ យើងសូមបញ្ជាក់ថា យើងពិចារណាចេញដីកាដំណោះ

---

[202] *សូមមើល* សំណុំរឿង ០០៤/២ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ (D353/1)។ សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបញ្ជាក់បំភ្លឺ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D369 ("ដីកាសម្រេចលើសំណើរបស់ អោ អាន (D369)")។ ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D355/1)។

[203] ដីកាសម្រេចលើសំណើរបស់ អោ អាន (D369)។ *សូមមើលផងដែរ* ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ (D353/1) កថាខណ្ឌ ៤៤ (សម្រេចថា យោងតាមហេតុផលខាងលើ [សហចៅក្រមស៊ើបអង្កេត] ណែនាំក្រឡាបញ្ជី ក.ស.ច.ស ដាក់ដីកាសម្រេចនេះនៅក្នុងសំណុំរឿង ០០៤)។

[204] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D355/1) កថាខណ្ឌ ២០ (សម្រេចថា យោងតាមហេតុផលខាងលើ [សហចៅក្រមស៊ើបអង្កេត] ណែនាំក្រឡាបញ្ជី ដាក់សំណៅថតចម្លងនៃដីកាសម្រេចសម្ងាត់នៅក្នុងសំណុំរឿង ០០៤)។

[205] ដីកាសម្រេចលើសំណើរបស់ អោ អាន (D369) កថាខណ្ឌ ៣២-៣៧។

[206] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D355/1) កថាខណ្ឌ ១៣-១៦។

ស្រាយដាច់ដោយឡែកពីគ្នា និង ផ្ទុយគ្នា ដូចដែលបានអនុញ្ញាតជាទូទៅតាមច្បាប់ជាធរមាន ជាពិសេសតាមសំអាងហេតុដែលយើងបានរកឃើញពាក់ព័ន្ធនឹងដីកាសន្និដ្ឋានស្ថាពរផ្ទុយគ្នា។ [...]

១៥. យើងដឹងអំពីបញ្ហាដែលអាចនឹងកើតឡើងនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង គ្រាន់តែចែងអំពីសេណារីយ៉ូដែលមានដីកាលើកលែងចោទប្រកាន់ ឬ ក៏មានដីកាចោទប្រកាន់បញ្ជូនទៅជំនុំជម្រះរួមគ្នា ប៉ុន្តែមិនមានចែងអំពីដីកាដំណោះស្រាយ ដាច់ដោយឡែកពីគ្នាទេ។ យ៉ាងណាក៏ដោយ មិនមានយុត្តិកម្មទេ ប្រសិនបើអះអាងថា មានការហាមឃាត់មិនឱ្យមានដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា។ ផ្ទុយទៅវិញ ជាឧទាហរណ៍ នៅក្នុងសាលដីការបស់ខ្លួននៅក្នុងសំណុំរឿង ០០១ ចៅក្រមអន្តរជាតិតុលាការកំពូលបានទទួលស្គាល់យ៉ាងច្បាស់អំពីសេណារីយ៉ូរបស់ [សហចៅក្រមស៊ើបអង្កេត] មានសំអាងហេតុខ្វែងយោបល់អំពីយុត្តាធិការបុគ្គល ហើយក៏ទទួលស្គាល់យ៉ាងច្បាស់ថា នៅក្នុងបរិបទនៃនីតិវិធីខ្វែងយោបល់ កិច្ចស៊ើបសួរត្រូវបន្តទៅមុខ។

១៦. យើងយល់ឃើញថា ដំណាក់កាលស៊ើបសួរ ចប់នៅពេលចុងក្រោយបំផុតគឺនៅពេលដែល [អង្គបុរេជំនុំជម្រះ] ចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ ប្រសិនបើ [អង្គបុរេជំនុំជម្រះ] មិនមានសំឡេងភាគច្រើនគាំទ្រដីកាដំណោះស្រាយណាមួយក្នុងចំណោមដីកាដំណោះស្រាយទាំងពីរទេនោះ ដីកាដំណោះស្រាយទាំងពីរត្រូវតម្កល់ទុកជាបានការ តាមការអនុវត្តវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង [...][207]។

92. នៅក្នុងដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានលើកឡើងពាក់ព័ន្ធនឹងនីតិវិធីដោះស្រាយករណីខ្វែងយោបល់ថា៖

២៣. ដោយសារថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរ គឺជាភស្តុតាងបញ្ជាក់ពីការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ទើប បញ្ហាចោទថាតើសហព្រះរាជអាជ្ញា មានកាតព្វកិច្ចត្រូវប្រើប្រាស់ទាំងស្រុងនូវវិធានការដោះស្រាយជម្លោះដែរឬអត់ និយាយម្យ៉ាងទៀត

207 ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D355/1) កថាខណ្ឌ ១៤-១៦ (លុបចោលជើងទំព័រ)។

01677097



ថាតើយន្តការដោះស្រាយយោងតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង គឺជាលក្ខខណ្ឌតម្រូវ ឬក៏ជាឆន្ទានុសិទ្ធិ [...] គឺពិតជាបញ្ហាចោទដែលស្ថិតនៅក្នុងដែនអំណាចរបស់ [សហចៅក្រមស៊ើបអង្កេត] ពីព្រោះថា បញ្ហាចោទនេះពាក់ព័ន្ធនឹងការដែលអាចទទួលយកដីកាសន្និដ្ឋានស្ថាពរ។ [...]

២៧. [...] យើង [...] យល់ឃើញថា [...] ក៏មានការបង្ហាញឱ្យឃើញច្បាស់ថា តាមច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ការធ្វើកំណត់ហេតុករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា គឺជាបញ្ហាឆន្ទានុសិទ្ធិ។ ហេតុនេះ យើងមិនយល់ឃើញថា សហព្រះរាជអាជ្ញាមានកាតព្វកិច្ចត្រូវប្រើប្រាស់ទាំងស្រុង នូវវិធានការដោះស្រាយជម្លោះទេ [...][208]។

93. ទាក់ទិននឹងលទ្ធភាពនៃការដាក់សេចក្ដីសន្និដ្ឋានស្ថាពរជាច្រើន សហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងដីកាសម្រេចដដែលនោះថា៖

៣២. ទោះបីយើងយល់ស្រប [...] ថា ខ្លឹមសារមួយនៃវិធាន ៦៦(៥) នៃវិធានផ្ទៃក្នុង ចែងអំពីដីកាសន្និដ្ឋានស្ថាពរមួយ ប៉ុន្តែ ភាសានេះ មិន*តម្រូវឱ្យមាន*ដីកាសន្និដ្ឋានស្ថាពរមួយរួមគ្នាទេ ហើយក៏មិនបានដកចេញនូវការដាក់ដីកាសន្និដ្ឋានដាច់ដោយឡែកពីគ្នាដែរ [...]។ ទោះបីសហព្រះរាជអាជ្ញាត្រូវធ្វើការរួមគ្នាដើម្បីរៀបចំសេចក្ដីសន្និដ្ឋានចោទប្រកាន់ ប៉ុន្តែការដែលសហព្រះរាជអាជ្ញាអាចខ្វែងយោបល់គ្នាត្រូវបានទទួលស្គាល់នៅក្នុង [កិច្ចព្រមព្រៀង] ដែលតម្រូវឱ្យសហព្រះរាជអាជ្ញា "សហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការចោទប្រកាន់" ហើយពិតណាស់ មានបទប្បញ្ញត្តិអំពីយន្តការដោះស្រាយជម្លោះ ដោយ [កិច្ចព្រមព្រៀង] ចែងយ៉ាងច្បាស់ថាអាចមានករណីខ្វែងយោបល់គ្នា "ថាតើ ត្រូវបន្តការចោទប្រកាន់ដែរឬអត់"។

៣៣. ការពិចារណាថែមទៀតគឺថា [...] [សហចៅក្រមស៊ើបអង្កេត] មិនជាប់កាតព្វកិច្ចត្រូវទទួលយកខ្លឹមសារនៃដីកាសន្និដ្ឋានស្ថាពរណាមួយ [...].

៣៤. ចំពោះការអះអាងដែលថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរគឺងណ្ដើមយក "*អំណាចផ្ដាច់មុខ*" [របស់អង្គបុរេជំនុំជម្រះ] ដើម្បីដោះស្រាយជម្លោះ [...] យើងមិនយល់ឃើញ

[208] ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (D369) កថាខណ្ឌ ២៣, ២៧។

01677098



ថា ការប្ដឹង [ទៅ អ.ប.ជ] គឺជាលក្ខខណ្ឌតម្រូវចាំបាច់ទេ ហេតុនេះ មិនមានអំណាចផ្ដាច់មុខត្រូវដណ្ដើមទេ[209]។

94. តាំងពីដំបូងមក អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរដាច់ដោយឡែកពីគ្នារបស់សហព្រះរាជអាជ្ញា ដែលអង្គជំនុំជម្រះចាត់ទុកថាជាភាពមិនប្រក្រតីផ្នែកនីតិវិធីដំបូង នៅក្នុងដំណើរការបិទការស៊ើបអង្កេតនៅក្នុងសំណុំរឿងនេះ ក៏បានកើតឡើងនៅក្នុងសំណុំរឿង ០០៤/១ ដែរ ហើយមិនអាចរារាំងមិនឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយតែមួយនៅក្នុងសំណុំរឿងផ្សេងបានទេ។ អង្គជំនុំជម្រះសូមគូសបញ្ជាក់ថា នៅក្នុងចំណុចនេះ បញ្ហាបឋមគឺថា មានភាពខុសគ្នាជាមូលដ្ឋាននូវមុខងារ និងសិទ្ធិអំណាច រវាងសារណារបស់ភាគី និងសេចក្តីសម្រេចរបស់តុលាការដែលចេញដោយចៅក្រម ដូចជាដីកាដំណោះស្រាយ[210]។ ចំពោះសំណួរថាតើការដាក់សារណាសន្និដ្ឋានស្ថាពរដាក់ដោយឡែកពីគ្នារបស់សហព្រះរាជអាជ្ញា ត្រូវបានអនុញ្ញាតនៅក្នុងប្រព័ន្ធច្បាប់នៅ អ.វ.ត.ក ឬយ៉ាងណានោះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសលើអង្គច្បាប់ដ៏ធំធេង ដោយសន្និដ្ឋានថា ក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក អនុញ្ញាតឱ្យចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា។

## គ. ការពិភាក្សា

95. ដូចដែលបានកត់សម្គាល់ពីខាងលើ អង្គបុរេជំនុំជម្រះបានពិចារណាថា ការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា របស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងនេះ បានបង្ហាញពីការខ្វែងយោបល់គ្នា ដែលមិនអាចដោះស្រាយបាន រវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ ទៅលើបញ្ហាថាតើ យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬយ៉ាងណា។ អង្គជំនុំជម្រះបានសម្រេចរួចហើយ នៅក្នុងសំណុំរឿងមួយផ្សេងទៀតថា ក្របខណ្ឌគតិយុត្តិ

---

[209] ដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (D369) កថាខណ្ឌ ៣២-៣៤ (លុបជើងទំព័រ)។

[210] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១២២។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) កថាខណ្ឌ ៨៨។

របស់ អ.វ.ត.ក មិនអនុញ្ញាតឱ្យមានការចេញដីកាដំណោះស្រាយផ្ទុយគ្នាឡើយ[211]។ អង្គបុរេជំនុំជម្រះនឹងយោងទៅយុត្តិសាស្ត្ររបស់ខ្លួនក្នុងការពិចារណាចំពោះសំណុំរឿងបច្ចុប្បន្ន ដោយជាដំបូងត្រូវកែប្រែការបកស្រាយគតិយុត្តិ ដែលសហចៅក្រមស៊ើបអង្កេតបានសម្រេច ហើយជាបន្ទាប់ត្រូវបញ្ជាក់បំភ្លឺ អំពីលក្ខណៈនៃកំហុសឆ្គង ដែលសហចៅក្រមស៊ើបអង្កេតបានអនុវត្ត នៅក្នុងសំណុំរឿងនេះ។

96. ជាដំបូង អង្គបុរេជំនុំជម្រះសូមរម្លឹកថា ដូចគ្នានឹងប្រព័ន្ធគតិយុត្តិដទៃផ្សេងទៀត ច្បាប់គ្រប់គ្រង អ.វ.ត.ក មិនចាំបាច់ត្រូវតែដោះស្រាយ នូវរាល់ភាពមិនប្រាកដប្រជាផ្នែកគតិយុត្តិទាំងអស់ ដែលអាចកើតចេញពីបញ្ហានីតិវិធី និង/ឬអង្គសេចក្តីឡើយ[212]។ ទោះជាយ៉ាងនេះក្តី ច្បាប់នេះបានចែងអំពីនីតិវិធី ដែលត្រូវអនុវត្តក្នុងករណីមានភាពចន្លោះប្រហោង ក្នុងក្របខណ្ឌគតិយុត្តិ[213] ព្រមទាំងត្រៀមបម្រុងជាចំហរចំពោះការខ្វែងយោបល់គ្នាដែលអាចកើតមាន ក្នុងបរិបទចម្រុះរបស់ អ.វ.ត.ក ហើយបានចែងអំពីនីតិវិធីជាក់លាក់ក្នុងការចាត់ចែង និងដោះស្រាយ ការខ្វែងយោបល់គ្នាបែបនេះ ដើម្បីជៀសវាងការជាប់គាំងផ្នែកនីតិវិធី។ បើតាមកិច្ចព្រមព្រៀង អ.វ.ត.ក មុខងារចម្បងដែលផ្តល់ដល់អង្គបុរេជំនុំជម្រះ គឺប្រាកដណាស់ដើម្បីផ្តល់នូវយន្តការប្រកបដោយប្រសិទ្ធិភាព ដើម្បីដោះស្រាយជាស្ថាពរ នូវការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា និងរវាងសហចៅក្រមស៊ើបអង្កេត។ ដូចដែលបានសង្កត់ធ្ងន់ពីខាងលើ សហចៅក្រមស៊ើបអង្កេត បានសម្រេចដោយចេតនា ក្នុងការគេចវេសពីយន្តការនេះ ហើយបែរជាចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ទាំងដែលដឹងយ៉ាងច្បាស់អំពីបញ្ហាដែលនឹងកើតចេញពីសកម្មភាពរបស់ខ្លួន ចំពោះកិច្ចដំណើរការនីតិវិធី នៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក។

---

[211] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៨៨-១២៤។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) កថាខណ្ឌ ៨៩-១០៩។

[212] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET (D359/24 និង D360/33) កថាខណ្ឌ ១០១។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ៩០។

[213] *សូមមើល* មាត្រា ១២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធាន ២ នៃវិធានផ្ទៃក្នុង។ ជាពិសេសគឺការអនុវត្តរបស់សហចៅក្រមស៊ើបអង្កេត សូមមើលផងដែរ មាត្រា ២៣ ថ្មី នៃច្បាប់ អ.វ.ត.ក។

01677100



97. អង្គបុរេជំនុំជម្រះ ចាំបាច់ត្រូវតែសម្រេចលើបញ្ហាថាតើ សកម្មភាពទាំងនេះ គោរពទៅតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក នៅក្នុងករណីនេះដែរឬយ៉ាងណា។ សម្រាប់សំអាងហេតុដូចរៀបរាប់លម្អិត នៅផ្នែកបន្ទាប់នេះ អង្គជំនុំជម្រះសម្រេចថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នា របស់សហចៅក្រមស៊ើបអង្កេត បានរំលោភបំពានទៅលើមូលដ្ឋានស្នូល នៃប្រព័ន្ធច្បាប់ អ.វ.ត.ក។ អង្គជំនុំជម្រះនឹង (ក) អះអាងឡើងវិញនូវគោលការណ៍ជាមូលដ្ឋាន គ្រប់គ្រងលើការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត និង (ខ) រំឭកឡើងវិញនូវនីតិវិធីខុសគ្នា ដែលមានសម្រាប់ការដោះស្រាយ ការខ្វែងយោបល់គ្នារវាង សហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មក (គ) ផ្តល់នូវសេចក្តីសង្កេតរបស់អង្គជំនុំជម្រះ លើការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា ក្នុងពេលដំណាលគ្នា ដែលមិនអាចអនុញ្ញាតបាន នៅក្នុងករណីបច្ចុប្បន្ននេះ។

<u>១. គោលការណ៍ជាសារវន្ត គ្រប់គ្រងលើការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត</u>

98. ទីមួយ អង្គបុរេជំនុំជម្រះសូមរំឭកថា ការបំពេញកិច្ចស៊ើបសួររួមគ្នា ដោយសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ គឺជាគោលការណ៍គតិយុត្តិ ជាសារវន្តចម្បងនៅ អ.វ.ត.ក ដូចដែលមានចែងក្នុងមាត្រា ៥(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក "មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេត ទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត"។

99. ច្បាប់ អ.វ.ត.ក បានពង្រឹងលើគោលការណ៍ជាសារវន្តនេះ ដូចដែលចែងតម្រូវដោយ មាត្រា ១៤*ថ្មី* (១) នៃច្បាប់ដែលថា "ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឱ្យបាន ភាពឯកច្ឆ័ន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន"។ មាត្រា ២៣ ថ្មី នៃច្បាប់ អ.វ.ត.ក បានចែងលម្អិតពីវិធីសាស្ត្រ ដែលគោលការណ៍នេះត្រូវយកមកអនុវត្ត ដោយតម្រូវថា "រាល់ការស៊ើបអង្កេតគឺជាការទទួលខុសត្រូវរួមគ្នា របស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជា បរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន"។ អង្គជំនុំជម្រះបានសម្រេចថា បទប្បញ្ញត្តិនេះ ដែលដូចមាត្រា ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា ក្រមនេះ "មានគោលបំណងកំណត់អំពីវិធានទាំងឡាយ ដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់

ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសណាមួយ” ដោយកំណត់ថា សហចៅក្រមស៊ើបអង្កេតចាំបាច់ ត្រូវបំពេញកិច្ចស៊ើបសួររួមគ្នា ហើយអនុលោមទៅតាមច្បាប់ជាធរមាននៅ អ.វ.ត.ក[214]។

100. អង្គបុរេជំនុំជម្រះបានបញ្ជាក់បំភ្លឺបន្ថែមទៀតថា “សហចៅក្រមស៊ើបអង្កេត មិនមានកាតព្វកិច្ចក្នុងការជូនដំណឹងដល់អង្គបុរេជំនុំជម្រះទេ នៅពេលដែលខ្លួនមិនព្រមព្រៀងគ្នា លើបញ្ហាណាមួយដែលនៅចំពោះមុខ” ក្នុងវិសាលភាពដែលសហចៅក្រមស៊ើបអង្កេតឯកភាពលើវិធីសាស្ត្រដែល “ស្រប” ទៅនឹង “គោលជំហរស្វ័យប្រវត្តិ” ដែលបានដាក់បញ្ចូលទៅក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក គឺថា “ការស៊ើបអង្កេតត្រូវតែបន្ត”[215]។ ប្រហែលគ្នានេះ អង្គជំនុំជម្រះកត់សម្គាល់ថា មាត្រា ២៣ ថ្មី នៃច្បាប់ អ.វ.ត.ក បញ្ជាក់ច្បាស់ពីមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដោយចែងថា “ក្នុងករណីដែលមានភាពមិនយល់ស្របគ្នា រវាងសហចៅក្រម [...] ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេ ពុំបានប្ដឹងមិនសុខចិត្ត ក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយ”[216]។ វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង ដែលចែងពីការដោះស្រាយការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ដោយអង្គបុរេជំនុំជម្រះ បានគាំទ្របន្ថែមដល់គោលជំហរ ជាសារវន្តមួយនេះ ដោយចែងថា៖

៤. អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដូចខាងក្រោម ៖

ឃ- សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសម្លេងគាំទ្រពីចៅក្រម ៤(បួន) រូប យ៉ាងតិច។ សេចក្ដីសម្រេចនេះបិទផ្លូវប្ដឹងឧទ្ធរណ៍។ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចរកបាននូវសម្លេងគាំទ្រ ភាគច្រើនតាមការតម្រូវ ស្របតាមមាត្រា ២៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជានោះ សេចក្ដីសម្រេចដែលមិនមាន

---

[214] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១០៤។ សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ៨៣។

[215] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះ (D359/24 និង D360/33) កថាខណ្ឌ ១០៦ *យោងទៅ* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (D427/1/30) កថាខណ្ឌ ២៧៥។ ។ សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ៨៤។

[216] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១០៧។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) កថាខណ្ឌ ៨៤។

សម្តែងគាំទ្រមានន័យថាដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើង ដោយសហចៅក្រមស៊ើបអង្កេតណាម្នាក់ ត្រូវមានសុពលភាព ឬមានន័យថា ដីកា ឬ កិច្ចស៊ើបសួរ ដែលបម្រុងនឹងធ្វើដោយ សហចៅក្រមស៊ើបអង្កេតម្នាក់ត្រូវតែយកមកអនុវត្ត។

101. ក្នុងករណីនេះ អង្គជំនុំជម្រះត្រូវតែបញ្ជាក់ថាតើ គោលការណ៍គតិយុត្តិទាំងអស់នេះ អនុញ្ញាតិឲ្យសហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយផ្ទុយគ្នា តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ដែរឬទេ ជំនួសឲ្យការបញ្ជូនរឿងដែលពួកគាត់ខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។

## ២. ការដោះស្រាយការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត

102. ជាបញ្ហាទូទៅ អង្គបុរេជំនុំជម្រះពិចារណាថា បញ្ហាថាតើសហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចដែរឬទេ ក្នុងការបញ្ជូនការខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង គឺស្ថិតក្រោមការគ្រប់គ្រង ដោយគោលការណ៍ដែលមានអានុភាពជាងដែលថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ចាំបាច់ត្រូវតែគោរពតាមលក្ខខណ្ឌតម្រូវនីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធិភាព នៃក្របខណ្ឌគតិយុត្តិ អ.វ.ត.ក។ ក្នុងករណីនេះ អង្គជំនុំជម្រះនេះ ឲ្យតម្លៃជាពិសេសទៅលើលក្ខខណ្ឌតម្រូវនៃយុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធិភាព។

103. មធ្យោបាយមួយដែលរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ធានានូវយុត្តិធម៌ប្រកបដោយប្រសិទ្ធិភាព នៅក្នុងបរិបទ អ.វ.ត.ក គឺតាមរយៈការធានាថា នីតិវិធីដែលមានជាធរមាន មិនត្រឹមតែអាចដោះស្រាយ ការខ្វែងយោបល់គ្នាដែលកើតចេញ ក្នុងដំណើរការស៊ើបអង្កេត និងជំនុំជម្រះក្តីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានប្រសិទ្ធិភាពក្នុងការដោះស្រាយ ការខ្វែងយោបល់គ្នាបែបនេះ ដើម្បីជៀសវាងការទាល់ច្រកផ្នែកនីតិវិធី ដែលអាចបណ្តាលផងដែរឲ្យមានការប៉ះពាល់ដល់ប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ នៅដំណាក់កាលមុនពេលជំនុំជម្រះ ដំណើរការនីតិវិធីទាំងអស់នេះ ត្រូវបានគូសបញ្ជាក់ និងកំណត់ជាស្ថាពរដោយ "គោលជំហរស្វ័យប្រវត្តិ" ដែលមានចែងផងដែរដោយ មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលបញ្ជាក់យ៉ាងច្បាស់លាស់ថា នៅពេលដែល "ចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះ ត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅ

ក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំ [...] ឱ្យដោះស្រាយការខ្វែងគំនិតគ្នា" ដោយអង្គបុរេជំនុំជម្រះ។

104. ផ្អែកលើចំណុចនេះ អង្គបុរេជំនុំជម្រះបានសម្រេចថា បញ្ហាថា តើសហចៅក្រមស៊ើបអង្កេត មានបុព្វសិទ្ធិដែរឬអត់ ក្នុងការចេញដីកាដំណោះស្រាយផ្ទុយគ្នា ដោយមិនបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ អាស្រ័យលើថាតើ ការដែលសហចៅក្រមស៊ើបអង្កេត គេចវេសពីនីតិវិធីដោះស្រាយ ការខ្វែងយោបល់ដែលមានចែង ក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង គឺជាការកេងចំណេញដែរឬអត់ ទៅលើឥទ្ធិពលជាក់ស្តែងនៃគោលជំហរស្វ័យប្រវត្តិ ដែលជាធាតុសំខាន់នៃ ប្រព័ន្ធច្បាប់ អ.វ.ត.ក[217]។ ក្នុងន័យនេះ អង្គជំនុំជម្រះសង្កត់ធ្ងន់ថា គោលការណ៍ដែលមានលក្ខណៈសារវន្ត និងកំណត់សម្រេចដូចជា គោលជំហរស្វ័យប្រវត្តិនេះ គឺមិនអាចលុបចោល ឬដកចេញនូវស្ថានទម្ងន់និងអានុភាពពេញលេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយ ដែលជាការកេងចំណេញលើ ភាពមិនច្បាស់លាស់ដែលអាចមាន នៅក្នុងច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឱ្យគោលការណ៍ស្នូល នៃកិច្ចព្រមព្រៀង អ.វ.ត.ក នេះ ទៅជាអាសាឥតន័យនោះឡើយ[218]។ ការសន្និដ្ឋានផ្សេងពីនេះ នឹងនាំទៅដល់លទ្ធផលគតិយុត្តិដែលមិនមានសំអាងហេតុទាល់តែសោះ ហើយនាំឱ្យមានការរំលោភបំពាន ទាំងទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា។

105. ដោយផ្អែកលើមូលដ្ឋាននេះ អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់ នៅក្នុងសេចក្តីសម្រេចកន្លងមកអំពីបណ្តុំផ្សេងៗគ្នាជាច្រើន នៃនីតិវិធីដែលសហចៅក្រមស៊ើបអង្កេត អាចប្រើប្រាស់សម្រាប់ដោះស្រាយការខ្វែងយោបល់គ្នា ដោយគោរពទាំងស្រុងទៅតាម ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក[219]។ ក្នុងន័យនេះ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា លក្ខណៈនិងភាពធ្ងន់ធ្ងរ នៃការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវតែធ្វើឱ្យពួកគាត់ ដឹងអំពីជម្រើសរបស់ពួកគាត់ សម្រាប់

[217] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១២។ សូមមើលផងដែរ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១០-១១១ (D266/27 និង D267/35) កថាខណ្ឌ ៨៨។

[218] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១២។ សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ៨៨។

[219] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៣-១២១ សំណុំរឿង ០០៣ កថាខណ្ឌ ៩៩-១០៩។

01677104



នីតិវិធីដែលសមស្របបំផុត ដែលត្រូវអនុវត្តតាម ក្នុងករណីណាមួយក៏ដោយ[220]។ អង្គជំនុំជម្រះសូមរំលឹកថា អាស្រ័យលើកាលៈទេសៈជាក់លាក់ នៃករណីនីមួយៗ នីតិវិធីដែលសហចៅក្រមស៊ើបអង្កេតអាចជ្រើសរើស គឺមានចាប់ពីការអត់ធ្មត់ដោយស្ងៀមស្ងាត់ ចំពោះកិច្ចឬសេចក្ដីសម្រេចរបស់ចៅក្រមម្នាក់ទៀត[221] រហូតដល់ការចុះបញ្ជីការខ្វែងយោបល់គ្នា[222] ឬបញ្ជូនការខ្វែង

---

[220] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៣។ សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ៩៩។

[221] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៥ ("អង្គជំនុំជម្រះបានសម្រេចថា តាមមាត្រា ២៣ថ្មី(៣) នៃច្បាប់ អ.វ.ត.ក ដែលចែងថា "ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេ ពុំបានប្ដឹងមិនសុខចិត្ត ក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយ ដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម" សហចៅក្រមស៊ើបអង្កេតមួយរូប អាចអនុញ្ញាតដោយត្រឹមត្រូវឱ្យ សហការីរបស់គាត់ អាចអនុវត្តទៅបាន ដោយខ្លួនគាត់មិនចូលរួមពាក់ព័ន្ធ នៅក្នុងកិច្ចបែបនេះ បើទោះបីជាមិនបានចុះកំណត់ហេតុ អំពីការខ្វែងយោបល់គ្នាក្ដី ដែលធ្វើដូច្នេះគឺអនុញ្ញាតឱ្យ ការស៊ើបអង្កេតអាចបន្តទៅមុខបាន") (លុបចោលជើងទំព័រ)។ *សូមមើលផងដែរ* សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) កថាខណ្ឌ ៩៩។

[222] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៦ ("ក្នុងករណីការខ្វែងយោបល់គ្នា ពាក់ព័ន្ធបញ្ហាធ្ងន់ធ្ងរ ដូចជាបញ្ហាដែលជាចំណុចស្នូល នៃការស៊ើបអង្កេតជាដើម សហចៅក្រមស៊ើបអង្កេតមួយរូប អាចលើកការជំទាស់របស់គាត់ ប្រឆាំងនឹងកិច្ច ឬសេចក្ដីសម្រេចរបស់សហការីគាត់ ដោយការចុះកំណត់ហេតុជាផ្លូវការ លើការខ្វែងយោបល់គ្នា។ អង្គជំនុំជម្រះសម្រេចថា ការបង្ហាញជាផ្លូវការ ពីការខ្វែងយោបល់គ្នា អនុលោមតាមមាត្រា ២៣ថ្មី(៣) នៃច្បាប់ អ.វ.ត.ក និងវិធាន ៧២(១) នៃវិធានផ្ទៃក្នុង ឬការឈានទៅដល់ការឯកភាពគ្នាទៅលើបញ្ហាដែលកំពុងចោទ ត្រូវបានទទួលស្គាល់និងត្រូវបានអនុញ្ញាត នៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក។ ក្នុងករណីបែបនេះ "សហចៅក្រមស៊ើបអង្កេតណាម្នាក់ ឬទាំងពីរ អាចធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដ នៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារ នៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខានិងចុះកាលបរិច្ឆេទ ដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារ នៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជី របស់សហចៅក្រមស៊ើបអង្កេត" ដោយអនុលោមតាមវិធាន ៧២(១) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះយល់ថា បន្ទាប់មកការខ្វែងយោបល់គ្នា ត្រូវបានរក្សាទុករវាងសហចៅក្រមស៊ើបអង្កេត ហើយទៅជាការសម្ងាត់។ អង្គជំនុំជម្រះកត់សម្គាល់ទៀតថា មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២៣ថ្មី នៃ ច្បាប់ អ.វ.ត.ក និងវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង បានចែងយ៉ាងច្បាស់ថា ក្នុងករណីបែបនេះ សហចៅក្រមស៊ើបអង្កេតមួយរូប អាចបំពេញកិច្ចដោយមិនមានការយល់ព្រម ពីចៅក្រមមួយរូបទៀតបាន នៅក្នុងពេលវេលាកំណត់ជាក់ច្បាស់។ បន្ទាប់មកសហចៅក្រមស៊ើបអង្កេតរូបនេះ អាចបន្តនីតិវិធីជាមួយសេចក្ដីសម្រេច ដែលរងការជំទាស់ ពេលដែលវេលាកំណត់ដែលបានតម្រូវ បានកន្លងផុតទៅ") (លុបចោលជើងទំព័រ)។ *សូមមើលផងដែរ* សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ៩៩។

យោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ ចំពោះកិច្ចឬសេចក្តីសម្រេចដែលមានការជំទាស់ ដោយអនុលោមទៅតាម វិធាន ៧២ នៃវិធានផ្ទៃក្នុង[223]។

106. អង្គបុរេជំនុំជម្រះសូមគូសបញ្ជាក់សាជាថ្មីថា ក្នុងស្ថានភាពណាក៏ដោយ កិច្ចរបស់សហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវតែស្ថិតក្នុងសមត្ថកិច្ចផ្ទាល់របស់ពួកគាត់ ហើយបំពេញដោយស្របទៅតាមគោលការណ៍សហប្រតិបត្តិការ ដែលមានចែងក្នុងមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលឆ្លុះបញ្ចាំងពីឋានៈស្មើគ្នារបស់សហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងប្រព័ន្ធចម្រុះរបស់ អ.វ.ត.ក[224]។ អង្គជំនុំជម្រះបានបញ្ជាក់បន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេត បើតាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក មានកាតព្វកិច្ចបន្តស្វែងរកគោលជំហររួម នៅក្នុងដំណើរខ្វែងយោបល់គ្នា[225]។ ប្រព័ន្ធច្បាប់ អ.វ.ត.ក ត្រូវបានតាក់តែងឡើង និង

---

[223] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៧ (“អង្គជំនុំជម្រះកត់សម្គាល់ថា នៅពេលដែលការខ្វែងយោបល់គ្នា មានភាពធ្ងន់ធ្ងរខ្លាំង ដែលសហចៅក្រមស៊ើបអង្កេតមួយរូប ចង់បញ្ឈប់ការអនុវត្តសេចក្តីសម្រេច របស់សហការីគាត់នោះ មធ្យោបាយតាមផ្លូវច្បាប់តែមួយគត់ ដែលមានសម្រាប់ចៅក្រមរូបនោះគឺ ការបញ្ជូនការខ្វែងយោបល់គ្នា ទៅអង្គបុរេជំនុំជម្រះ ដែលជាអង្គជំនុំជម្រះទទួលបាន សិទ្ធិអំណាចជាពិសេស និងជាក់លាក់ ដើម្បីដោះស្រាយភាពខុសគ្នា រវាងសហចៅក្រមស៊ើបអង្កេត។ ដើម្បីចាប់ផ្តើមយន្តការដោះស្រាយ ការខ្វែងយោបល់គ្នាប្រកបដោយប្រសិទ្ធិភាពនេះ សហចៅក្រមស៊ើបអង្កេតចាំបាច់ ត្រូវដាក់របាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីអង្គហេតុនិងមូលហេតុ នៃការខ្វែងយោបល់គ្នា។ ច្បាប់ជាធរមានរបស់ អ.វ.ត.ក ផ្តល់ដល់អង្គបុរេជំនុំជម្រះ នូវសិទ្ធិអំណាចដែលចាំបាច់ សម្រាប់ដោះស្រាយជាស្ថាពរ លើបញ្ហាដែលមានជម្លោះរវាង សហចៅក្រមស៊ើបអង្កេតពីររូប ដែលមានសិទ្ធិអំណាចស្មើគ្នា ហើយសម្រេចថាតើ គួរ ឬមិនគួរ អនុវត្តសេចក្តីសម្រេច ដែលរងការជំទាស់។ ក្នុងករណីដែលអង្គបុរេជំនុំជម្រះមិនអាចស្វែងរកសម្លេងភាគច្រើនលើសលប់ ដើម្បីដោះស្រាយសម្រេចការខ្វែងយោបល់គ្នាទនោះ ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក បានចែងថា បញ្ហានេះនឹងត្រូវដោះស្រាយ ដោយស្ថានភាពកំណត់ដែលជាការចែងថា ការស៊ើបអង្កេតចាំបាច់ត្រូវបន្ត”) (លុបចោលជើងទំព័រ)។ *សូមមើលផងដែរ* សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D266/27 និង D267/35) កថាខណ្ឌ ៩៩។

[224] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៤ *យោងទៅ* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(១) ដែលត្រូវបកស្រាយរួមជាមួយ ច្បាប់ អ.វ.ត.ក មាត្រា ២៧ ថ្មី។ *សូមមើលផងដែរ* សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ១០០។

[225] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៨ (អង្គជំនុំជម្រះកត់សម្គាល់ថា ការប្រើប្រាស់ទម្រង់បច្ចុប្បន្ន នៅក្នុងវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង បង្ហាញយ៉ាងច្បាស់ដោយឥតមន្ទិលថា សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចបន្តស្វែងរក សំអាងហេតុផ្លូវច្បាប់រួមគ្នា ឬ

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

កំណត់ជារចនាសម្ព័ន្ធ ដើម្បីគ្រប់គ្រងលើការបំពេញកិច្ចស៊ើបសួររួមគ្នា ដោយសហចៅក្រមស៊ើបអង្កេតដែលអាចឈានដល់ការយល់ស្របគ្នា នៅដំណាក់កាលណាមួយ នៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ដែលពួកគាត់បានទទួល។ ការបញ្ជាក់បំភ្លឺទៅលើការខ្វែងយោបល់រវាងពួកគាត់ អំពីករណីបែបនេះ គឺអាចអនុញ្ញាតិទៅបាន[226] ប៉ុន្តែក្នុងករណីដែលការបញ្ជាក់បំភ្លឺនេះ គោរពទៅតាមនីតិវិធីដែលមានជាធរមាន ហើយដែលនៅតែស្របគ្នាជាមួយនឹងគោលជំហរស្វ័យប្រវត្តិដែលជាធាតុផ្សំសំខាន់នៃប្រព័ន្ធគតិយុត្តិរបស់ អ.វ.ត.ក ដែលចែងអំពីវិធីសាស្ត្រប្រកបដោយប្រសិទ្ធិភាព ក្នុងការគេចចេញពីភាពទាល់ច្រក ផ្នែកនីតិវិធីណាមួយដែលអាចកើតមាន។

107. ជាចុងក្រោយ អង្គបុរេជំនុំជម្រះសូមបញ្ជាក់ជាថ្មីថា នៅពេលដែលសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអាចយល់ស្របគ្នាលើគោលជំហររួម និងក្នុងករណីដែលបញ្ហាដែលពួកគាត់ខ្វែងយោបល់គ្នា ឬការខ្វែងយោបល់របស់ពួកគាត់ទៅលើបញ្ហាមួយ អូសបន្លាយពេលវេលា ដែលធ្វើឱ្យខូចខាតដល់ប្រសិទ្ធិភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ពេលនោះក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនអនុញ្ញាតឱ្យការខ្វែងយោបល់គ្នានេះ នៅបន្តគេចផុត ឬមិនទទួលយកដំណោះស្រាយ ប្រកបដោយប្រសិទ្ធិមួយនោះឡើយ[227]។ ហេតុដូច្នេះ អង្គជំនុំជម្រះតម្កល់ការសម្រេចនាពេលមុនថា ក្នុងករណីដែលនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា ដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង គឺជាសកម្មភាពដែលនៅសល់តែមួយគត់ សម្រាប់សហចៅក្រមស៊ើបអង្កេត ដើម្បីជៀសវាងពីការកើតឡើងវិញ នូវការជាប់គាំងផ្នែកនីតិវិធី និងដើម្បីការពារនូវនីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធភាពនៃកិច្ចស៊ើបសួរ ដែលធ្វើឡើងនៅ

---

សកម្មភាពដែលឯកភាពគ្នាជារួម នៅក្នុងអំឡុងពេលដោះស្រាយការខ្វែងយោបល់គ្នា និងថាសហចៅក្រមស៊ើបអង្កេតទាំងពីរមានកាតព្វកិច្ចទៅវិញទៅមក ក្នុងន័យនេះ បើតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក)។ *សូមមើលផងដែរ* សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ១០០។

[226] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៩ (អង្គជំនុំជម្រះទទួលស្គាល់ថា ច្បាប់ដែលអនុវត្តនៅ អ.វ.ត.ក ប្រមើលមើលថា ទោះបីជាមានការខិតខំប្រឹងប្រែងពិតប្រាកដ ក្នុងការឈានទៅរកការសម្របសម្រួល ឬស្វែងរកការឯកភាពជាឯកច្ឆន្ទក្តី សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិពីររូប ដែលមានឋានៈស្មើគ្នា អាចនៅតែមិនអាចឯកភាពគ្នា លើគោលជំហររួម)។ *សូមមើលផងដែរ* សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ១០០។

[227] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៩។ *សូមមើលផងដែរ* ក្នុងសំណុំរឿង ០០៣ (D266/27 និង D267/35)" កថាខណ្ឌ ១០១។

អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវតែប្រើប្រាស់យន្តការនីតិវិធីនេះ ដោយបញ្ជូនការខ្វែងយោបល់របស់ពួកគាត់ ទៅអង្គបុរេជំនុំជម្រះ[228]។

## ៣. សេចក្តីសង្កេតទាក់ទងនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នា

108. ដោយផ្អែកលើគោលការណ៍ដូចបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះបានរកឃើញថា ក្នុងករណីដែលការខ្វែងយោបល់គ្នា ទាក់ទងនឹងបញ្ហាដែលចាំបាច់ត្រូវសម្រេច ដោយដីកាដំណោះស្រាយ តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក អនុញ្ញាតឲ្យមានមធ្យោបាយតែពីរប៉ុណ្ណោះ ដោយអនុលោមទៅតាមមាត្រា ២៣ ថ្មី នៃច្បាប់ អ.វ.ត.ក និងវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង។ សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចក្នុងការឈានទៅរកការឯកភាពគ្នាដោយស្ងៀមស្ងាត់ ឬដោយចំហរ ទៅលើបញ្ហាទាំងអស់នេះ ឬបញ្ជូនការខ្វែងយោបល់គ្នាទៅលើបញ្ហាបែបនេះ ទៅអង្គបុរេជំនុំជម្រះ[229]។

109. លើសពីនេះទៀត អង្គជំនុំជម្រះសូមបញ្ជាក់ឡើងវិញថា អត្ថបទគតិយុត្តិរបស់ អ.វ.ត.ក ពុំមានភាពស្រពិចស្រពិលច្រើននោះទេ ក្នុងបញ្ហានេះ៖ វិធាន ៦៧(១) នៃវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា "សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ [...] ឬ លើកលែងការចោទប្រកាន់"។ សទ្ទានុក្រមនៃវិធានផ្ទៃក្នុងបន្ថែមថា "ដីកាដំណោះស្រាយសំដៅទៅលើដីកាចុងក្រោយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬចៅក្រមអន្តរជាតិ នៅពេលបញ្ចប់ដំណើរការស៊ើបសួរដែលអាចជា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់" [230]។

---

[228] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៩។ *សូមមើលផងដែរ* សំណុំរឿង ០០៣ (D266/27 និង D267/35)" កថាខណ្ឌ ១០១។

[229] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១៩។ *សូមមើលផងដែរ* សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ១០២។

[230] វិធានផ្ទៃក្នុង សទ្ទានុក្រម ទំព័រ ៨៣ (ការគូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១១២។ *សូមមើលផងដែរ* សំណុំរឿង (D266/27 និង D267/35) កថាខណ្ឌ ១០៣។

110. បទប្បញ្ញត្តិទាំងនេះបានចែងយ៉ាងច្បាស់ថា ដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតគឺជាដីកា សម្រេចតែមួយគត់។ ដូច្នេះ វិធាន ១(២) នៃវិធានផ្ទៃក្នុង ដែលបញ្ជាក់ថា នៅក្នុងវិធាន ផ្ទៃក្នុង ឯកវចនៈក៏អាចយល់ជាពហុវចនៈដែរ ហើយការយោងចំពោះពាក្យសហចៅក្រមស៊ើបអង្កេត "សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ" ពុំបានផ្តល់មូលដ្ឋានគតិយុត្តិ គ្រប់គ្រាន់ដើម្បីទាត់ចោល ឬ កាត់បន្ថយ គោលការណ៍ ស្នូល នៃកិច្ច ព្រមព្រៀង អ.វ.ត.ក ដូចជា គោលជំហរជាក់ស្តែង ហើយ វិធាន ស្តីពីការបកស្រាយ ក្នុងន័យចង្អៀតលើ ច្បាប់ ព្រហ្មទណ្ឌ បានទប់ស្កាត់បន្ថែមទៀតចំពោះការបកស្រាយតាមអំពើចិត្តណាមួយ នៅក្នុងអត្ថន័យនេះ។

111. សម្រាប់សំអាងហេតុទាំងអស់នេះ អង្គបុរេជំនុំជម្រះច្រានចោល សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីភាពអាចអនុញ្ញាតបានតាមផ្លូវច្បាប់ ក្នុងការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា។ បន្ថែមពីលើកំហុសអង្គច្បាប់យ៉ាងច្បាស់ក្រឡែត ដែលសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត បានពឹងផ្អែកទៅលើនោះ អង្គបុរេជំនុំជម្រះសូមរំឭកផងដែរថា សហចៅក្រមស៊ើបអង្កេត មានភារកិច្ចតាមផ្លូវតុលាការ ក្នុងការសម្រេចលើបញ្ហាដែលមានវិវាទ ដែលពួកគាត់បានទទួល[231]។ ក្នុងករណីដែលការខ្វែងយោបល់គ្នារបស់ពួកគាត់ រារាំងពួកគាត់មិនឱ្យឈានទៅដល់ការសម្រេចជាស្ថាពររួមគ្នា ទៅលើបញ្ហាបែបនេះ ពួកគាត់នៅតែចាំបាច់ត្រូវបញ្ចប់ ភារកិច្ចតាមផ្លូវតុលាការរួមគ្នានេះ ដោយគោរពទៅតាមនីតិវិធីជាធរមាន នៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក ដើម្បីធានាថា អាចឈានដល់ការសម្រេចជារួម ទៅលើបញ្ហាដែលស្ថិតក្នុងយុត្តាធិការរបស់ពួកគាត់[232]។

112. សរុបមក អង្គបុរេជំនុំជម្រះសូមសង្កត់ធ្ងន់ថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នា ដោយមិនបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ ឬ អនុវត្តតាមករណីដែលពុំមានជំហររួម សហចៅក្រមស៊ើបអង្កេត បានប្រព្រឹត្តកំហុសធ្ងន់ដែលធ្វើឱ្យប៉ះពាល់ទៅដល់មូលដ្ឋាននៃប្រព័ន្ធចម្រុះ និងដំណើរ

---

[231] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១២២។ *សូមមើលផងដែរ* សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ១០៥។

[232] *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១២២។ *សូមមើលផងដែរ* សំណុំរឿង ០០៣ (D266/27 និង D267/35) កថាខណ្ឌ ១០៥។

ការដោយត្រឹមត្រូវរបស់ អ.វ.ត.ក។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា ទោះបីជាលក្ខណៈជាមូលដ្ឋាន នៃបញ្ហាចោទនេះ គឺថាតើ យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬអត់នោះ ក៏ដោយ តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសំអាងហេតុតិចតួចគួរឱ្យកត់សម្គាល់លើបញ្ហានេះ ដោយលើកឡើងតែត្រឹមសេចក្តីសម្រេចមួយក្នុងចំណោមសេចក្តីសម្រេចមុនៗរបស់ខ្លួន[233]។ សហចៅក្រមស៊ើបអង្កេតជាតិពុំបានផ្តល់សំអាងហេតុ ឬ ការចង្អុលយោបនៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់នោះទេ[234]។

113. លើសពីនេះទៀត តាមរយៈសេចក្តីសម្រេចមុនៗរបស់សហចៅក្រមស៊ើបអង្កេតបង្ហាញយ៉ាងច្បាស់ថា ពួកគាត់បានដឹងថា ការបដិសេធមិនបញ្ជូនករណីខ្វែងយោបល់របស់ពួកគាត់ទៅអង្គបុរេជំនុំជម្រះ បញ្ហានានាដែលពួកគាត់មិនយល់ស្របគ្នា រួមទាំងបញ្ហាគន្លឹះថាតើ យឹម ទិត្យ ស្ថិត ឬមិនស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក នោះ នឹងត្រូវបានដោះស្រាយតែនៅក្នុងផ្នែកនៃកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍នៅចំពោះមុខចៅក្រមអន្តរជាតិនេះប៉ុណ្ណោះ មិនមែនតាមរយៈយន្តការផ្នែកនីតិវិធីដែលបានចែងជាក់លាក់ដោយក្របខណ្ឌគតិយុត្ត អ.វ.ត.ក សម្រាប់ដំណោះស្រាយតែចំពោះករណីខ្វែងយោបល់គ្នារវាងពួកគាត់នេះទេ។ សហចៅក្រមស៊ើបអង្កេតបានដឹងពីការលំបាកដែលបណ្តាលមកពីសកម្មភាពរបស់ពួកគាត់ មិនត្រឹមតែទៅលើបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ តែហួសពីដំណាក់កាលបណ្តឹងឧទ្ធរណ៍មុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុង

---

[233] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១៣ *យោងទៅ* ដីកាសម្រេចដាក់ដីកាសម្រេចពាក់ព័ន្ធ នឹងករណីខ្វែងយោបល់គ្នា (D355/1) កថាខណ្ឌ ១៣-១៦។ អង្គជំនុំជម្រះកត់សម្គាល់ថា ដីកាសម្រេចនេះ (D355/1) ដែលត្រូវបានចេញពីដំបូងដើម្បីឆ្លើយតបចំពោះសំណើរបស់ភាគី ដែលបានលើកឡើងក្នុងសំណុំរឿង ០០៤/២ ត្រូវបានជូនដំណឹងដល់ភាគីក្នុងសំណុំរឿង ០០៤ ដោយពុំបានចាត់វិធានការណាមួយនោះទេ ដូចជា ស្នើសុំឱ្យភាគីសម្រួលសេចក្តីសន្និដ្ឋានរបស់ខ្លួនដើម្បីលើកឡើងអំពីករណីឯករាជនៃករណីនេះ ដោយមិនគិតអំពីផលប៉ះពាល់ដែលជះធំធេង ដោយសារសកម្មភាពបែបនេះ។

[234] ដីកាសម្រេចលើកលែងការចោទប្រកាន់ (D381)។

សំណុំរឿង ០០៤ ទៅទៀត[235]។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ជារឿងប្លែកដែលដីកាដំណោះស្រាយផ្ទុយគ្នា ត្រូវបានចេញនៅក្នុងថ្ងៃតែមួយ ជាភាសាតែមួយ[236]។

114. ជារួម អង្គបុរេជំនុំជម្រះពិចារណាថា កំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេត បានបង្កផលប៉ះពាល់ដល់ប្រព័ន្ធទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ ក្រៅពីការរំលោភបំពានទៅលើគោលការណ៍ជាមូលដ្ឋាន នៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក អង្គជំនុំជម្រះយល់ឃើញថា ការអនុវត្តដោយខុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេត អាចបង្កើតបានជាភាពអយុត្តិធម៌ ជាពិសេសដោយសារតែអង្គជំនុំជម្រះ មិនអាចមិនពិចារណាថាពួកគាត់ប្រហែលមានចេតនា ធ្វើឱ្យបរាជ័យដល់គោលជំហរស្វ័យប្រវត្តិ ហើយរំខានដល់សិទ្ធិអំណាច របស់អង្គបុរេជំនុំជម្រះ។ អង្គជំនុំជម្រះបានកត់សម្គាល់បន្ថែមថា មិនត្រឹមតែជាឧទាហរណ៍ដាច់តែឯងប៉ុណ្ណោះទេ ប៉ុន្តែសកម្មភាពរបស់ពួកគាត់ នៅក្នុងករណីនេះ គាំទ្រនូវទម្រង់មួយដែលសហចៅក្រមស៊ើបអង្កេតបានអនុម័តយក ក្នុងការដោះស្រាយជាមួយបណ្តាសំណុំរឿងចុងក្រោយទាំងអស់ នៅក្នុងបញ្ជីសំណុំរឿងរបស់ អ.វ.ត.ក[237]។

115. ជាថ្មីម្តងទៀត អង្គជំនុំជម្រះកត់សម្គាល់ដោយការសោកស្តាយថា តាមការយល់ដឹងនិងបទពិសោធន៍របស់ខ្លួន មិនដែលធ្លាប់មានសំណុំរឿងព្រហ្មទណ្ឌណា នៅក្នុងប្រវត្តិសាស្ត្រនៃប្រព័ន្ធច្បាប់អន្តរជាតិ និងប្រព័ន្ធច្បាប់ជាតិដទៃទៀត ដែលបញ្ចប់ដោយការចេញសេចក្តីសម្រេចផ្ទុយគ្នាចំនួនពីរក្នុងពេលដំណាលគ្នា ហើយចេញដោយការិយាល័យចៅក្រមតែមួយនោះទេ។ បន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេល ១០ឆ្នាំ លើឧក្រិដ្ឋកម្មដែលស្ថិតក្នុងចំណោមឧក្រិដ្ឋកម្មដែលសាហាវ

---

235 ដីកាសម្រេចលើសំណើសុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ (D355/1) កថាខណ្ឌ ១៥-១៦។ សូមមើលផងដែរ សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅចៅក្រមអន្តរជាតិសាលាដំបូង ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឯកសារ D270/7។

236 *សូមមើល* ប្រវត្តិនីតិវិធី (នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ដីកាសម្រេចលើកលែងការចោទប្រកាន់ (D381) ត្រូវបានដាក់ជាភាសាខ្មែរតែប៉ុណ្ណោះ ចំណែកឯដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) ត្រូវបានដាក់ជាភាសាអង់គ្លេស ដោយសំណៅបកប្រែនឹងដាក់ជូនតាមក្រោយ។

237 *សូមមើល* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ៨៨-១២៤ សំណុំរឿង ០០៣ (D266/27 និង D267/35)។ ដីកាសម្រេចលើកលែងការចោទប្រកាន់ (D381)។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382)។

យង់ឃ្នងបំផុត ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងសតវត្សរ៍ទី២០ ចៅក្រមអន្តរជាតិអាចត្រឹមតែថ្កោលទោសជាថ្មីម្តងទៀត ទៅលើស្ថានការណ៍ដ៏អាក្រក់ផ្នែកផ្លូវច្បាប់ ដែលសកម្មភាពខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេតបានបង្កើតឡើង ចំពោះកិច្ចដំណើរការនីតិវិធីផ្សេងទៀតរបស់ អ.វ.ត.ក។

## VI. **អង្គសេចក្តី**

116. ទោះបីជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ និងលក្ខណៈខុសច្បាប់នៃការព្រមព្រៀងគ្នារបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញ ដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា បានបញ្ជាក់ច្បាស់នៅក្នុងកថាខណ្ឌខាងលើក្តី ក៏អង្គជំនុំជម្រះ បន្ទាប់ពីប្រជុំពិភាក្សារួច មិនអាចរកសំឡេងភាគច្រើនលើសលប់នៃសំឡេងគាំទ្រចំនួនបួនតាមការកំណត់ ដើម្បីឈានទៅដល់ការធ្វើសេចក្តីសម្រេចមួយលើអង្គសេចក្តី ផ្អែកលើសំអាងហេតុរួម បានឡើយ។ អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង មតិរបស់សមាជិកផ្សេងៗ នៃចៅក្រមអន្តរជាតិ ត្រូវបានភ្ជាប់មកជាមួយនឹងសេចក្តីពិចារណាទាំងនេះ។

# VII. សេចក្តីសម្រេច

**ដោយផ្អែកលើហេតុផលខាងលើនេះ អង្គបុរេជំនុំជម្រះ យោងតាមសំឡេងឯកច្ឆ័ន្ទ÷**

- **បង្គាប់ឲ្យដាក់**បញ្ចូលគ្នានូវបណ្តឹងឧទ្ធរណ៍ទាំងឡាយប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ
- **សម្រេចថា** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិអាចទទួលយកបាន
- **សម្រេចថា** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិអាចទទួលយកបាន
- **សម្រេចថា** បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន
- **សម្រេចថា** បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី លោក យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ អាចទទួលយកបាន
- **សម្រេច** ចំពោះបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី លោក យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅមូលដ្ឋានទី២.២ មូលដ្ឋានទី ៣ មូលដ្ឋានទី ៤ មូលដ្ឋានទី ៥.១ មូលដ្ឋានទី ៥.២ និងមូលដ្ឋានទី ៥.៣ អាចទទួលយកបាន
- **សម្រេចថា** មូលដ្ឋានផ្សេងទៀតនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី លោក យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចទទួលយកបាន
- **ប្រកាសថា** ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ដែលរំលោភបំពានទៅលើក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក
- **ប្រកាសថា** អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រពីចៅក្រម (បួន) រូប យ៉ាងតិច ដើម្បីចេញសាលដីកាមួយទៅលើអង្គសេចក្តី ដោយផ្អែកលើសំអាងហេតុរួម បានឡើយ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះត្រូវជូនដំណឹងអំពីសាលដីកានេះដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីនានា។

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០២១**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី សូមលើកឡើងនូវមតិយោបល់របស់ខ្លួនទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។

ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។

# VIII. យោបល់លោកចៅក្រមប្រាក់ គីមសាន លោកចៅក្រមន៉ី ធុល និង លោកចៅក្រម ហួត វុទ្ធី

117. សំណុំរឿង ០០៤ ដែលមាន យឹម ទិត្យ ជាជនត្រូវចោទ ជាសំណុំរឿងចុងក្រោយគេបង្អស់ ក្នុងសំណុំរឿង ០០៣-០០៤ ដែលមានឈ្មោះ អ៊ឹម ចែម, អោ អាន, មាស មុត និង យឹម ទិត្យ ជាជនត្រូវចោទ។ សំណុំរឿង ០០៣-០០៤ ចាប់ផ្តើមចេញដំណើរខុសប្លែកពីសំណុំរឿង ០០១ និង ០០២ ពោលគឺការជ្រើសរើសយកជនមួយចំនួនមកធ្វើការស៊ើបអង្កេតបឋមជាឯកតោភាគី ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដោយបិទបាំងពុំបានសហការជាមួយសហព្រះរាជអាជ្ញាជាតិ ញ៉ាំងឲ្យដំណើរការនីតិវិធីមានភាពរអាក់រអួលមិនចេះចប់មិនចេះហើយ។ ចៅក្រមជាតិនៃ អ.ប.ជ ធ្លាប់បានលើកជាយោបល់ពិស្តារអំពីភាពរអាក់រអួលនោះ ក្នុងមតិយោបល់របស់ខ្លួនក្នុងសំណុំរឿងដែលមាន អោ អាន ជាជនត្រូវចោទ។ លើកនេះទៀត ផ្អែកលើភស្តុតាងមួយចំនួនក្នុងសំណុំរឿង អោ អាន ចៅក្រមជាតិនៃ អ.ប.ជ សូមលើកជាយោបល់ថ្មីទៀត ដើម្បីបិទបញ្ចប់សំណុំរឿង ០០៤។ ក្នុងន័យនេះ យើងត្រូវពិនិត្យតាមលំដាប់លំដោយអំពី៖ គោលបំណងក្នុងការបង្កើត អ.វ.ត.ក - ការប្រជុំឆ្លងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅរដ្ឋសភាជាតិ - ការដឹងឮអំពីលទ្ធផលនៃការប្រជុំនៅរដ្ឋសភាកម្ពុជា - លក្ខណៈពិសេសរបស់ អ.វ.ត.ក - អ្នកដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ - ការបិទបាំងរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការបើកការស៊ើបអង្កេតបឋមដោយឯកតោភាគី - ការសារភាពរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ និង ការពិចារណារបស់ចៅក្រមជាតិនៃ អ.ប.ជ អំពីអនីត្យានុកូលភាពនៃកិច្ចស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលមានដូចតទៅ៖

## ១. <u>គោលបំណង</u>

118. មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះហត្ថលេខានៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣៖ "គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួល

ខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ០៦ មករា ១៩៧៩"។

119. មាត្រា ១ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ... ថៅក្រុមអន្តរជាតិវិសាមញ្ញប្រកាសឲ្យប្រើនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៤ (ច្បាប់ អ.វ.ត.ក) ដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖ "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ហើយដែលបានប្រព្រឹត្ត ក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"។

120. មាត្រា ២ នៃច្បាប់ អ.វ.ត.ក រម្លឹកឡើងវិញជាថ្មីថា ថៅក្រុមអន្តរជាតិវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបង្កើតឡើងដើម្បីជំនុំជម្រះ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម ... ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃ០៦ មករា ១៩៧៩"។

121. ផ្អែកតាមកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ជនដែលត្រូវនាំយកមកកាត់ទោសនៅចំពោះមុខ អ.វ.ត.ក គឺជនពីរប្រភេទ៖

- អ្នកដឹកនាំជាន់ខ្ពស់ និង
- អ្នកទទួលខុសត្រូវខ្ពស់បំផុត ដែលស្ថិតក្នុងយុត្តាធិការនៃ អ.វ.ត.ក។

122. ដូច្នេះ ក្នុងការជ្រើសរើសជនទាំងពីរប្រភេទនេះមកកាត់ទោស គឺត្រូវមានការសហការគ្នា ឯកភាពគ្នារវាងភាគីជាតិ និងភាគីអន្តរជាតិ ផ្ដើមធ្វើការស៊ើបអង្កេតបឋម និងចោទប្រកាន់បញ្ជូនទៅសហថៅក្រុមស៊ើបអង្កេត ដើម្បីធ្វើការស៊ើបអង្កេត ដោយគោរពអនុវត្តរាល់មាត្រាទាំងឡាយដែលមានចែងក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក រាល់វិធានទាំងឡាយដែលមានចែងក្នុងវិធានផ្ទៃក្នុង ពិសេសគោលបំណងក្នុងការបង្កើត អ.វ.ត.ក ដែលបានលាតត្រដាងជាសាធារណៈ ក្នុងឱកាសប្រជុំឆ្លងសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក នៅរដ្ឋសភាជាតិ។

01677116



## ២. ការប្រជុំឆ្លងសេចក្តីព្រាងច្បាប់ អ.វ.ត.ក នៅរដ្ឋសភាជាតិ[238]

123. កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងកម្ពុជា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ថ្វីត្បិតពុំបានបញ្ជាក់អំពីចំនួនអ្នកដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវនាំយកមកកាត់ទោសនៅចំពោះមុខ អ.វ.ត.ក ក៏ពិតមែន ប៉ុន្តែក្នុងពេលប្រជុំឆ្លងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅរដ្ឋសភាជាតិ មានការសួរដេញដោលរវាងតំណាងរាស្ត្រ និងអ្នកការពារសេចក្តីព្រាងច្បាប់គឺ ឯកឧត្តម សុខ អាន អំពីចំនួនជនដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក និងជាគោលបំណងយ៉ាងច្បាស់លាស់អំពីការព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ គឺមានចំនួនតែ បួន (៤) ទៅប្រាំ (៥) នាក់ ដែលមាននៅក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២ រួចទៅហើយ។

## ៣. សំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

124. ដើម្បីឲ្យដឹងកាន់តែច្បាស់ថែមទៀត អំពីគោលបំណងរបស់ភាគីក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក <u>សហចៅក្រមស៊ើបអង្កេតអន្តរជាតិ</u>បានស្នើសុំពីផ្នែកបណ្ណសាររបស់អង្គការ សហប្រជាជាតិនូវកំណត់ហេតុនៃការចរចារវាងអង្គការសហប្រជាជាតិ ជាមួយរដ្ឋាភិបាលកម្ពុជា ក៏ប៉ុន្តែអង្គការសហប្រជាជាតិបានបដិសេធមិនបង្ហាញឯកសារភាគច្រើនក្នុងចំណោមឯកសារដែលបានស្នើសុំទេ ដោយផ្អែកលើមូលហេតុរក្សានូវការសម្ងាត់[239]។

## ៤. ការដឹងឮអំពីចំនួនជនដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក[240]

125. ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២

---

[238] ទស្សនាវដ្តីស្វែងរកការពិត លេខ ១៣ ខែមករា ឆ្នាំ២០០១ ទំព័រ ៦៣, លេខ ១៤ ខែកុម្ភៈ ឆ្នាំ២០០១ ទំព័រ ៤៨ និងទំព័រ ៤៩។

[239] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេចដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D181/1។

[240] ឯកសារ D360/10 កថាខណ្ឌ ១១-១២ យោងទៅ "ការចរចា និងការអនុម័តកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងការចរចា និងការអនុម័តវិសោធនកម្មលើច្បាប់ស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម" សម័យប្រជុំលើកទី១ នីតិកាលទី៣ នៃ រដ្ឋសភាកម្ពុជា ថ្ងៃទី០៤-០៥ ខែតុលា ឆ្នាំ២០០៤ ឯកសារ D359/3/1.1.45។

សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា "ឯ.ឧ កែវ រ៉េមី ក្នុងឃ្លាចុងក្រោយបានលើកឡើងថា វាមិនយុត្តិធម៌ទេបើយើងកាត់ទោសតែ ៣ ឬ ៤ នាក់នោះ (ឆ្លើយតបទៅនឹង ឯ.ឧ សុខ អាន)។ នេះជាភស្តុតាងបង្ហាញថា នាពេលប្រជុំសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នៅរដ្ឋសភាកម្ពុជា ឯ.ឧ សុខ អាន បានឆ្លើយបញ្ជាក់ថា ជនដែលត្រូវនាំយកមកកាត់ទោសនៅ អ.វ.ត.ក មានចំនួនតែ ៣ ឬ ៤ នាក់ប៉ុណ្ណោះ ដូចអ្វីដែល ឯ.ឧ កែវ រ៉េមី បានលើកឡើង គឺជាគោលបំណងនៃការតាក់តែងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

126. <u>ចារីមួយចំនួនពុំត្រូវនាំយកមកកាត់ទោសទៅ អ.វ.ត.ក ទេ</u>៖ អ្នកតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានដឹងថា មានចារីដ៏ច្រើនសន្ធឹកសន្ធាប់ មិនត្រូវនាំយកមកជំនុំជម្រះនៅ អ.វ.ត.ក ទេ។

## ៥. <u>លក្ខណៈពិសេសរបស់ អ.វ.ត.ក</u>

127. ចៅក្រមជាតិនៃ អ.ប.ជ ធ្លាប់បានពិចារណាលើសេចក្តីសម្រេចក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង អ៊ឹម ចែម ថា អ.វ.ត.ក ជាតុលាការពិសេសមួយដែលអនុវត្តនីតិវិធីនៃការចោទប្រកាន់ និងការស៊ើបសួរខុសពីតុលាការជាតិ។ ការចោទប្រកាន់ និងការស៊ើបសួររបស់តុលាការជាតិគឺធ្វើឡើងតែអង្គហេតុ មានន័យថា ចៅក្រមស៊ើបអង្កេតទទួលបណ្តឹងអំពីអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា។ ផ្ទុយមកវិញ នៅ អ.វ.ត.ក ការចោទប្រកាន់អាចធ្វើទៅបាន លុះត្រាតែបំពេញបានលក្ខខណ្ឌពីរ៖

> <u>ទី១</u>៖ អង្គហេតុ "ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។
>
> <u>ទី២</u>៖ បុគ្គលដែលជាមេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជាជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ហើយដែលស្ថិតក្នុងយុត្តាធិការនៃ អ.វ.ត.ក។

## ៦. អ្នកដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុត

128. យោង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ (ឯកសារ D3)។

អ្នកដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតដែលស្ថិតក្នុងយុត្តាធិការនៃ អ.វ.ត.ក ត្រូវបាន ភាគីជាតិ និង ភាគីអន្តរជាតិទទួលស្គាល់ និង ឯកភាពគ្នានាំយកមកជំនុំជម្រះ នៅចំពោះមុខ អ.វ.ត.ក គឺ៖

១. ខៀវ សំផន

២. នួន ជា

៣. អៀង សារី

៤. អៀង ធីរិទ្ធ

៥. កាំង ហ្គេកអ៊ាវ ហៅឌុច

ចំនួនជនខាងលើនេះស្ថិតក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២ ស្របនឹងចំនួនជនដែលបាន លើកឡើងដោយ ឯ.ឧ សុខ អាន ក្នុងឱកាសប្រជុំឆ្លងសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក នៅរដ្ឋសភាជាតិ។

129. ដូច្នេះពុំមានសេសសល់ជនផ្សេងទៀត ផ្ដើមធ្វើការចោទប្រកាន់ និងនាំយកមកជំនុំជម្រះនៅចំពោះ មុខ អ.វ.ត.ក ឡើយ។

## ៧. ការលួចលាក់ផ្ដើមធ្វើការចោទប្រកាន់តាមរយៈការស៊ើបអង្កេតបឋម ដោយសហព្រះរាជអាជ្ញាអន្តរជាតិ

130. ចៅក្រមជាតិនៃអង្គជំនុំជម្រះធ្លាប់បានពិចារណាម្ដងរួចមកហើយអំពីអនីត្យានុកូលភាពនៃកិច្ច ស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង ០០៣-០០៤ កាលពីថ្ងៃទី១៨ ខែ សីហា ឆ្នាំ២០០៩ (ឯកសារ "ឧបសម្ព័ន្ធ II: សេចក្ដីដកស្រង់ការពិចារណារបស់ចៅក្រមអន្តរជាតិ

ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង”)[241]។

*យោងតាមច្បាប់ អ.វ.ត.ក ការចោទប្រកាន់មានតម្លៃអាចទទួលយកបានតាមផ្លូវច្បាប់ លុះត្រាតែសហព្រះរាជអាជ្ញាទាំងពីរ ពោលគឺសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ មានការឯកភាពគ្នា ដោយយោងលើពាក្យបណ្តឹង ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន។ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក បានបញ្ជាក់ច្បាស់ថា នៅ អ.វ.ត.ក ត្រូវមានព្រះរាជអាជ្ញាពីររូបដែលហៅថា “សហព្រះរាជអាជ្ញា” ហើយត្រូវធ្វើការសហការគ្នា ក្នុងការបំពេញការងារ។ ដូច្នេះឃើញថាភស្តុតាងនានាដែលទទួលបានពីការស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងទៅនឹងជនសង្ស័យថ្មីទាំងនោះ សហព្រះរាជអាជ្ញាជាតិពុំដែលបានចូលរួម ឬផ្តល់សិទ្ធិអំណាចដល់មន្ត្រីរបស់ខ្លួន ក្នុងការស៊ើបអង្កេតនោះទេ។*

*សហព្រះរាជអាជ្ញាជាតិ និងមន្ត្រីរបស់ខ្លួនមិនដែលបានចូលរួម និង/ឬ គាំទ្រដល់ការស៊ើបអង្កេតបឋមក្នុងការកំណត់មុខសញ្ញាជនសង្ស័យដើម្បីយកមកធ្វើការប្តឹងចោទប្រកាន់ ដូចដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ និងទី៣ ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងមន្ត្រីរបស់ខ្លួនបានចប់សព្វគ្រប់ ទើបសហព្រះរាជអាជ្ញាជាតិបានទទួលព័ត៌មានក្រៅផ្លូវការថា ខាងផ្នែកអន្តរជាតិបានធ្វើការអង្កេតបឋមទាក់ទងនឹងកិច្ចការមួយចំនួន ហើយការអង្កេតបឋមនេះក៏បានចប់សព្វគ្រប់រួចរាល់ហើយដែរ។ ពេលទទួលព័ត៌មានដូចនេះ សហព្រះរាជអាជ្ញាជាតិបានទៅសួរនាំសហព្រះរាជអាជ្ញាអន្តរជាតិ ប៉ុន្តែពេលនោះសហព្រះរាជអាជ្ញាអន្តរជាតិអវត្តមានទើបសហព្រះរាជអាជ្ញាជាតិទៅជួបជាមួយសហព្រះរាជអាជ្ញារងអន្តរជាតិគឺលោក វីល្លៀម ស្មីត។ ពេលសួរនាំករណីអង្កេតបឋមនេះ លើវីល្លៀម ស្មីត បានប្រាប់ថា ពិតជាមានការស៊ើបអង្កេតបឋមដូចដែលសហព្រះរាជអាជ្ញាជាតិទទួលបានព័ត៌មាននោះមែនហើយ លោក វីល្លៀម ស្មីត ក៏បានពោលពាក្យថា “សុំទោស” ចំពោះការធ្វើអង្កេតបឋមដោយឯកឯងនេះ ហើយសន្យាថា បើពេលក្រោយមានធ្វើអ្វីទៀត ខ្លួននឹងជូនដំណឹងដល់សហព្រះរាជអាជ្ញាជាតិ។*

*សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការសម្រេចចិត្ត ក្នុងការផ្តួចផ្តើមស៊ើបអង្កេតនេះដោយឯកឯង ដូច្នេះសហព្រះរាជអាជ្ញាជាតិមិនបានដឹងអំពីបញ្ហានេះទេ។ សហព្រះរាជអាជ្ញាជាតិ តាមចម្លើយ*

[241] សូមមើល សេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33 កថាខណ្ឌ ២៦០។

*របស់ខ្លួនចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ បានអះអាងថា៖ កិច្ចស៊ើបសួរបឋមទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកតីមួយ លើកទីពីរ និងលើកទីបី ជាគោលការណ៍ត្រូវបានឈរលើមូលដ្ឋាននៃការវិភាគឯកសារធ្វើឡើងនៅក្នុងតុលាការ ដែលប្រមូលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលបានទទួលមុនថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ មានន័យថា មុនការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីមួយ។ ភាគច្រើនបំផុតនៃការអនុញ្ញាត សម្រាប់កិច្ចស៊ើបសួរបឋមនៅពេលណាត្រូវបានផ្តល់ដោយសហព្រះរាជអាជ្ញាណាម្នាក់ ឬសហព្រះរាជអាជ្ញាក៏ដោយ គឺត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ដែលអនុញ្ញាតដោយច្បាប់។*

សំណុំរឿង ០០៤ ក៏ដូចជាសំណុំរឿងផ្សេងៗទៀត ក្នុងសំណុំរឿង ០០៣-០០៤ ត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិលាក់លៀមផ្តើមធ្វើការស៊ើបអង្កេតបឋមជាឯកតោភាគី រំលោភទៅលើកិច្ចព្រមព្រៀងរវាងកម្ពុជា និងអង្គការសហប្រជាជាតិ និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បង្កើតបានអនីត្យានុកូលភាពក្នុងសំណុំរឿងទាំងមូល។

## ៨. ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិក្នុងដីកាដំណោះស្រាយ

131. ផ្អែកតាមភស្តុតាងទាំងអស់ដូចបានលើកឡើងមកនេះ ចៅក្រមជាតិនៃ អ.ប.ជ យល់ឃើញថា ការដែលសហចៅក្រមស៊ើបអង្កេតជាតិសម្រេច ៖

- អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ ឡើយ។
- លើកលែងការប្រកាន់ប្រឆាំង យឹម ទិត្យ។

<u>គឺជាការត្រឹមត្រូវ</u>។

ប៉ុន្តែការដែលសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិសម្រេចចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺជាការខុសច្បាប់ ដោយរំលោភទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។

**ហេតុដូច្នេះ ចៅក្រមជាតិនៃ អ.ប.ជ សម្រេច៖**

បិទសំណុំរឿង ០០៤ ដែលមាន យឹម ទិត្យ ជាជនត្រូវចោទ និងបញ្ជូនទៅតម្កល់ទុកក្នុងបណ្ណសារនៃ អ.វ.ត.ក។

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០២១**

**ចៅក្រម ប្រាក់ គឹមសាន** **ចៅក្រម ន័យ ធុល** **ចៅក្រម ហួត វុទ្ធី**

# IX. យោបល់ចៅក្រម KANG JIN BAIK និងចៅក្រម OLIVIER BEAUVALLET

132. ចៅក្រមដែលបានចុះហត្ថលេខា នឹងបង្ហាញខាងក្រោមនូវមតិយោបល់របស់ខ្លួនទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ទាំង៥។

## បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ[242]

### ក. អំណះអំណាង

*១. បណ្តឹងឧទ្ធរណ៍របស់សហមេធាវីប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ*

133. បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរគឺជាការជំទាស់ទៅនឹងសុពលភាពនៃដីកាដំណោះស្រាយទាំងពីរនៅក្នុងសំណុំរឿង ០០៤។ ជាពិសេស សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតទាំងពីរមានកំហុសអង្គច្បាប់ចំពោះការចេញដីកាដំណោះស្រាយដោយឡែក និងផ្ទុយគ្នាចំនួនពីរ ដោយសារថា (i) ច្បាប់ អ.វ.ត.ក មិនអនុញ្ញាតឱ្យធ្វើដូច្នេះបានទេ ហើយ (ii) វាបានរំលោភបំពានគោលការណ៍នៃ *វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ* និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ លោក យឹម ទិត្យ។ ហេតុដូច្នេះ សហមេធាវីស្នើសុំឱ្យចៅក្រមអន្តរជាតិបដិសេធចោលដីកាដំណោះស្រាយទាំងពីរ និងលើកលែងការចោទប្រកាន់លើរឿងក្តីនេះ[243]។

---

[242] ភាគីផ្សេងទៀតក៏បានធ្វើសេចក្តីសន្និដ្ឋានជាក់លាក់អំពីដីកាដំណោះស្រាយពីរផ្ទុយគ្នា ដែលបានចេញនៅក្នុងសំណុំរឿង ០០៤ និងផលវិបាកផ្នែកច្បាប់សមស្រប ដែលចៅក្រមអន្តរជាតិគួរពិនិត្យសម្រេច។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/19) កថាខណ្ឌ ១៦៤-១៧៥។ ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/29) កថាខណ្ឌ ៨-២៧ កថាខណ្ឌ ៣៥-៤១។ ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/26) កថាខណ្ឌ ៧-២៦ កថាខណ្ឌ ៣២-៣៤។ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/28) កថាខណ្ឌ ១-៨; បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ១៣-៣៨។

[243] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ២០។

134. យោងតាមសហមេធាវី ក្របខ័ណ្ឌច្បាប់ អ.វ.ត.ក មិនអនុញ្ញាតឱ្យចេញដីកាដំណោះស្រាយចំនួនពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នានោះឡើយ។ ទីមួយ មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា សហចៅក្រមស៊ើបអង្កេតត្រូវសហការដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ ទីពីរ មាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា ការស៊ើបអង្កេតគឺជាការទទួលខុសត្រូវរួមគ្នា ពុំមែនក្នុងពេលដំណាលគ្នានោះទេ[244]។ ទីបី វិធាន ៦៧ នៃវិធានផ្ទៃក្នុងចែងបុរមើលមើលយ៉ាងច្បាស់អំពីការអនុញ្ញាតឱ្យចេញដីកាដំណោះស្រាយតែមួយ ដោយសហចៅក្រមស៊ើបអង្កេតទាំងពីរនៅពេលបញ្ចប់ការស៊ើបអង្កេត។ ពាក្យពេចន៍នៅក្នុងវិធាន ៦៧ នៃវិធានផ្ទៃក្នុង ជាការដាក់កាតព្វកិច្ច និងអនុញ្ញាត[245]ឱ្យចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់"។

135. ទី៤ វិធាន ១៤ នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតនឹងបំពេញកិច្ចរួមគ្នា និងមានអំណាចស្មើភាពគ្នា ហើយមិនអាចឱ្យចេញដីកាដំណោះស្រាយជាលក្ខណៈបុគ្គលបាននោះឡើយ។ ទោះបីជាវិធាន ១៤ (៤) នៃវិធានផ្ទៃក្នុង ចែងកំណត់អំណាចក្នុងការធ្វើប្រតិភូកម្មកិច្ចការតុលាការក៏ដោយ ក៏ស្ថានភាពដែលសហចៅក្រមស៊ើបអង្កេតអាចបំពេញកិច្ចដោយឯកឯង មិនអាចកើតឡើងដោយគ្មាន "សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររួម" នោះឡើយ ឬចំពោះសកម្មភាពណាមួយដែលត្រូវធ្វើរួមគ្នា អនុលោមតាមច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង[246]។ ចំពោះសហមេធាវី ការគ្មានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក ឬ វិធានផ្ទៃក្នុង ដែលចែងអំពីលទ្ធភាពនៃដីកាដំណោះស្រាយចំនួនពីរ ឬ លទ្ធភាពដែលសហចៅក្រមស៊ើបអង្កេត អាចបំពេញកិច្ចដោយឯកតោភាគី[247] មានន័យថា ការចេញដីកាដំណោះស្រាយ*ត្រូវតែ*ធ្វើរួមគ្នា។ ដូច្នេះ គ្មានប្រតិភូកម្មណាមួយអនុលោមតាមវិធាន ១៤(៤) នៃវិធានផ្ទៃក្នុងអាចធ្វើទៅបាននោះឡើយ ហើយទោះក្នុងករណីណាក៏ដោយ សហមេធាវីកត់សម្គាល់ថា គ្មានប្រតិភូកម្មនៃអំណាចណាមួយបានធ្វើឡើងនោះទេ[248]។

[244] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ២៣។

[245] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ២៤។

[246] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ២៧។

[247] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ២៦, ២៨។

[248] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ២៨។

136. យោងតាមហេតុផលខាងលើ សហមេធាវីអះអាងថា កិច្ចរបស់សហចៅក្រមស៊ើបអង្កេតគឺច្បាប់មិនអនុញ្ញាតនោះឡើយ[249]។ យ៉ាងហោចណាស់ សហចៅក្រមស៊ើបអង្កេតគួរតែព្យាយាមរកការបញ្ជាក់បំភ្លឺលើបញ្ហានេះពីចៅក្រមអន្តរជាតិមុនពេលចេញដីកាដាច់ដោយឡែកពីគ្នារបស់ខ្លួន[250]។

137. ម្យ៉ាងវិញទៀត សហមេធាវីជំទាស់ថា ដីកាដំណោះស្រាយផ្ទុយគ្នាទាំងពីរបានរំលោភបំពានគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងសិទ្ធិរបស់ លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ដោយសារសហចៅក្រមស៊ើបអង្កេតបានវាយតម្លៃភ័ស្តុតាងអង្គហេតុដូចគ្នា ប៉ុន្តែឈានដល់ការសន្និដ្ឋានផ្ទុយគ្នា សហមេធាវីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមាន កាតព្វកិច្ចអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ចំពោះការវាយតម្លៃភ័ស្តុតាងរបស់ពួកគេលើអង្គហេតុ ហើយត្រូវលើកលែងការចោទប្រកាន់។ បើមិនធ្វើដូច្នេះទេ សហចៅក្រមស៊ើបអង្កេត ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ លោក យឹម ទិត្យ[251]។

138. នៅពេលដកស្រង់យុត្តិសាស្ត្រពាក់ព័ន្ធ[252] សហមេធាវីបានរំលឹកអំពីកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ត្រូវរក្សាសុចរិតភាពនៃការស៊ើបអង្កេត គោរពគោលការណ៍មូលដ្ឋាន និងធានាអនុវត្តតាមនីតិវិធី[253]។ លើសពីនេះ សហមេធាវីគូសបញ្ជាក់ថា *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាធាតុសំខាន់នៃសច្ចធារណ៍និរទោស ដែលត្រូវបានធានាការពារអនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

---

[249] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣០។

[250] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ២៩។

[251] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣១។

[252] *សូមមើល ឧទា.* សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើបន្ទាប់របស់ យឹម ទិត្យ សុំឱ្យសហចៅក្រមអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ឯកសារ D229/3 កថាខណ្ឌ ២៦។ សំណុំរឿង ០០៤ ដីកាសម្រេចលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D355/9 កថាខណ្ឌ ១៧។

[253] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣២។

01677125



និងត្រូវបានទទួលស្គាល់នៅក្នុងយុត្តិសាស្ត្រ អ.វ.ត.ក និងច្បាប់អន្តរជាតិ[254]។ យោងតាមសហមេធាវី គោលការណ៍នេះកំណត់ថា វិមតិសង្ស័យនៅក្នុងការសម្រេចលើអង្គហេតុ និងការកំណត់អំពីការទទួលខុសត្រូវបុគ្គល ត្រូវបកស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ[255]។ គោលការណ៍នេះអនុវត្តនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី រួមទាំង ដំណាក់កាលមុនពេលជំនុំជម្រះផងដែរ[256]។

139. សហមេធាវីអះអាងថា ដោយសារតែចៅក្រមដែលមានសិទ្ធិស្មើគ្នាពីររូបបានធ្វើការសន្និដ្ឋានផ្ទុយគ្នាអំពីយុត្តាធិការបុគ្គលដោយផ្អែកលើភ័ស្តុតាងតែមួយ សំណុំរឿងរបស់ លោក យឹម ទិត្យ គឺ "ឧទាហរណ៍ នៃស្ថានភាពវិមតិសង្ស័យ ដែលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"[257]។ សម្រាប់សហមេធាវី "អត្ថិភាពនៃដីកាដំណោះស្រាយផ្ទុយគ្នាទាំងពីរនេះនាំឱ្យមានវិមតិសង្ស័យអំពីការសម្រេចលើអង្គហេតុ និងការវាយតម្លៃរួមលើការទទួលខុសត្រូវបុគ្គល ដូចបានចោទប្រកាន់"[258]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចលើកលែងការចោទប្រកាន់លើសំណុំរឿងនេះ ដោយត្រូវអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ក្នុងតួនាទីជាអ្នកវិនិច្ឆ័យលើអង្គហេតុ និងក្នុងនាមជាអ្នកធានាមើលការខុសត្រូវលើការស៊ើបអង្កេត[259]។

140. សហមេធាវីអះអាងបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតនៅពេលចេញដីកាដំណោះស្រាយផ្ទុយគ្នាបានបង្កើតភាពមិនច្បាស់លាស់ផ្នែកនីតិវិធី និងវិមតិសង្ស័យបន្ថែមទៀត[260]។ នេះគឺជាការរំលោភសិទ្ធិ លោក យឹម ទិត្យ ក្នុងការទទួលបានសច្ចភាពគតិយុត្តចាប់តាំងពីពេលគាត់មាន "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនបានដោះស្រាយរួចរាល់នៅតែលតោលចំពោះរូបគាត់

---

[254] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៣។

[255] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៣។

[256] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៣ ជើងទំព័រ ៣៤។

[257] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៤។

[258] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៤។

[259] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៤, ៣៦។

[260] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៥។

រហូតមកទល់ពេលនេះ”។ ម្យ៉ាងវិញទៀត នៅពេលមិនព្យាយាមស្វែងរកការបញ្ជាក់បំភ្លឺពីចៅក្រមអន្តរជាតិ “មុនពេលចាប់ផ្តើមកិច្ចមួយដោយធ្វេសប្រហែស និងមិនស្របច្បាប់” ធ្វើឱ្យ “ភាពស្មុគស្មាញប្រទាក់ប្រឡាគ្នានៃនីតិវិធីប្តឹងឧទ្ធរណ៍” អូសបន្លាយរយៈពេលនៃកិច្ចដំណើរការនីតិវិធីកាន់តែយូរមិនសមហេតុផលជាង ១៣ឆ្នាំ[261]។

141. ជារួម តាមការយល់ឃើញរបស់សហមេធាវី ដោយសារក្របខ័ណ្ឌច្បាប់ អ.វ.ត.ក មិនអនុញ្ញាតឱ្យមានដីកាដំណោះស្រាយពីរផ្ទុយគ្នា ហើយដោយសារពុំមានការធ្វើប្រតិភូអំណាច ដីកាដំណោះស្រាយទាំងពីរនេះ ត្រូវចាត់ទុកជាមោឃៈ ដោយសារវិការៈផ្នែកនីតិវិធីអនុលោមតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង[262]។ ជាលទ្ធផល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពុំមានសុពលភាព ហើយវិធាន ៧៧(១៣)(ខ) មិនអាចអនុវត្តបាន[263]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិសាលាដំបូងមិនអាចទទួលសំណុំរឿង ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលគ្មានសុពលភាពនេះដែរ លើកលែងតែចៅក្រមអន្តរជាតិអាចរកសម្លេងភាគច្រើនលើសលុបអាចចេញសេចក្តីសម្រេចបាន[264]។

142. ដូច្នេះ សហមេធាវីអះអាងថា ស្ថានភាពនេះបន្សល់ទុកនូវជម្រើសចំនួន ០៣ តែប៉ុណ្ណោះសម្រាប់អង្គបុរេជំនុំជម្រះ ពោលគឺ៖

(i) បដិសេធដីកាដំណោះស្រាយទាំងពីរទាំងស្រុងតែម្តង។ ឬ

(ii) បដិសេធដីកាដំណោះស្រាយទាំងពីរ និងបង្វិលសំណុំរឿងទៅសហចៅក្រមស៊ើបអង្កេតបង្គាប់ឱ្យចេញដីកាដំណោះស្រាយមួយរួមគ្នា ដោយកត់សម្គាល់ថា រាល់ការខ្វែងយោបល់គ្នាត្រូវតែសម្រេចជាប្រ យោជន៍ដល់ លោក យឹម ទិត្យ។ ឬ

---

[261] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៥។

[262] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៨។

[263] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៨, ៤០។

[264] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៨។

(iii) បដិសេធដីកាដំណោះស្រាយទាំងពីរ ហើយចៅក្រមអន្តរជាតិចេញដីកាដំណោះស្រាយរបស់ខ្លួន ដោយផ្អែកលើការវាយតម្លៃរបស់ខ្លួនលើសំណុំរឿង[265]។

143. សហមេធាវីនៅតែអះអាងថា វា "ពុំបានបើកលទ្ធភាព" ឱ្យចៅក្រមអន្តរជាតិច្រានចោលដីកាដំណោះស្រាយណាមួយបាននោះទេ ពីព្រោះសហចៅក្រមស៊ើបអង្កេតទាំងពីរមានឋានៈស្មើគ្នា ហើយច្បាប់ជាធរមានមិនអនុញ្ញាតឱ្យចៅក្រមអន្តរជាតិកំណត់ថា កិច្ចរបស់ចៅក្រមណាម្នាក់មានឧត្តមភាពនោះទេ[266] ។ អញ្ញត្រកម្មតែមួយគត់ គឺសច្ចធារណ៍និរទោស និងគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនចាប់ចោទ* ដែលកំណត់ថាត្រូវលើកលែងការចោទប្រកាន់លើសំណុំរឿងនេះ[267]។

## *២. ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ*

144. នៅក្នុងការឆ្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំថាច្រាន ចោលអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍របស់ លោក យឹម ទិត្យ ប្រឆាំងដីកាដំណោះស្រាយទាំងពីរ និងបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ[268]។

145. ជាបញ្ហាបឋម សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់សេចក្តីប្រកាសជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ថា *ការចេញ*ដីកាដំណោះស្រាយពីរផ្ទុយគ្នាគឺខុសច្បាប់[269]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិពុំបានជំទាស់ផ្នែកណាមួយ នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ ដែលលើកឡើងទិដ្ឋភាពច្បាប់នេះទេ ប៉ុន្តែបែរជាជំទាស់សេចក្តីសន្និដ្ឋានរបស់សហមេធាវីអំពីផលប៉ះពាល់នៃកំហុសនេះ លើស្ថានភាពស្របច្បាប់នៃដីកាដំណោះស្រាយនីមួយៗ[270]។ ទោះបីយ៉ាងណាក៏ដោយ នេះគឺជាការយល់ឃើញដ៏ស៊ីសង្វាក់គ្នារបស់

---

[265] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៣៩។

[266] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៤០។

[267] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 & D382/21) កថាខណ្ឌ ៤០។

[268] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 & D382/28) កថាខណ្ឌ ៣, ៦២។

[269] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 & D382/28) កថាខណ្ឌ ២៦។

[270] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 & D382/28) កថាខណ្ឌ ២៧។

ខ្លួនជាមួយនឹងសហព្រះរាជអាជ្ញាមុនគាត់ថា សហចៅក្រមស៊ើបអង្កេតអាចចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាបាន[271]។

146. យោងតាមអង្គសេចក្តី សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា (i) អង្គជំនុំជម្រះមិនតម្រូវឱ្យច្រានចោលដីកាដំណោះស្រាយទាំងពីរនោះឡើយ[272] (ii) មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតម្កល់ទុកជាបានការតែប៉ុណ្ណោះ អនុលោមតាមក្របខ័ណ្ឌគតិយុត្ត អ.វ.ត.ក[273] និង (iii) ប្រសិនបើអង្គជំនុំជម្រះមិនអាចរកសម្លេងភាគច្រើនលើសលប់ ដើម្បីចេញសេចក្តីសម្រេចបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[274]។

147. ទាក់ទងនឹងគោលជំហររបស់លោកស្រីដែលថា អង្គបុរេជំនុំជម្រះមិនត្រូវបានតម្រូវឱ្យបដិសេធដីកាដំណោះស្រាយទាំងពីរនេះ[275] សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា (១) វានៅតែបើកចំហរឱ្យអង្គបុរេជំនុំជម្រះបដិសេធតែដីកាដំណោះស្រាយមួយប៉ុណ្ណោះ ដែលត្រូវបានបង្ហាញដោយសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ដែលចៅក្រមនៃអង្គជំនុំជម្រះពុំបានបដិសេធដីកាដំណោះស្រាយទាំងពីរក្នុងសំណុំរឿង ០០៤/២ នេះទេ ប៉ុន្តែបានពិចារណាអំពីនីត្យានុកូលភាពនៃដីកាដំណោះស្រាយ*នីមួយៗ*[276] និង (២) ផ្ទុយទៅនឹងការអះអាងរបស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតត្រូវបានតម្រូវឱ្យចេញដីកាដំណោះស្រាយរួមគ្នាមួយ និងមិនត្រូវបានអនុញ្ញាតឱ្យបំពេញកិច្ចតែឯងនោះ អង្គបុរេជំនុំជម្រះធ្លាប់បានបញ្ជាក់ជាឯកច្ឆ័ន្ទហើយថា សហចៅក្រមស៊ើបអង្កេតមិនត្រូវបានតម្រូវឱ្យចេញដីកាសម្រេចរួមនោះទេ ហើយលើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតម្នាក់ៗអាចបំពេញកិច្ចតែឯងខ្លួន

---

[271] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 & D382/28) កថាខណ្ឌ ២៥។

[272] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 & D382/28) កថាខណ្ឌ ២៨-២៩។

[273] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 & D382/28) កថាខណ្ឌ ៣០-៤៦។

[274] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 & D382/28) កថាខណ្ឌ ៤៧-៥៨។

[275] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ២៨-២៩។

[276] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ២៨។

យ៉ាងមានសុពលភាព ជាពិសេស ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតម្នាក់បានដកខ្លួនចេញពីការបន្តការស៊ើបអង្កេត[277]។

148. ក្នុងការគាំទ្រដល់ការអះអាងរបស់លោកស្រីថា មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះអាចត្រូវបានតម្កល់ សហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញមូលហេតុថា មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះត្រូវបានចេញស្របតាមគោលជំហស្ស័យប្រវត្តិ "ជាមូលដ្ឋាន និងជាកត្តាកំណត់" ថា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត"[278]។ ជាពិសេស កាលណាសហចៅក្រមស៊ើបអង្កេតណាម្នាក់ស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសហចៅក្រមស៊ើបអង្កេតម្នាក់ទៀតមិនយល់ស្របតាមអត្ថន័យនៃថា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត" នោះគឺថា ត្រូវតែចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះដូចដែលបានស្នើឡើង ពីព្រោះដីកាសម្រេចលើកលែងចោទប្រកាន់រារាំងការស៊ើបអង្កេតមិនឱ្យដំណើរការទៅមុខទៀត[279]។ ការបកស្រាយនេះត្រូវបានគាំទ្រដោយការសម្រេចជាឯកច្ឆន្ទរបស់ចៅក្រមអន្តរជាតិក្នុងសំណុំរឿង ០០២ ដែលអះអាងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតចំពោះឧក្រិដ្ឋកម្មថ្នាក់ជាតិ គឺស្របគ្នាទៅនឹងគោលជំហរស្វ័យប្រវត្តិ ទោះបីជាខ្លួនស្ថិតនៅក្នុង "ភាពទាល់ច្រកនៃកិច្ចដំណើរការនីតិវិធី" ក៏ដោយ[280]។ ការប្រកស្រាយនេះក៏ត្រូវបានគាំតដោយយុត្តិសាស្ត្រតុលាការកំពូល[281] ហើយស្របគ្នាទៅនឹងច្បាប់ជាតិ និង អន្តរជាតិ ក៏ដូចជាកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក ផងដែរ[282]។អាស្រ័យហេតុដូច្នេះ ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលត្រូវបញ្ជូនសំណុំរឿង ០០៤ ទៅកាន់កាជំនុំជម្រះនោះគឺ "ត្រូវបានធ្វើឡើងស្របគ្នាទាំងស្រុងជាមួយនឹងគោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់" ហើយការខកខានរបស់គាត់មិនបានប្ដឹងទៅ អ.ប.ជ អំពីការ

---

277 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ២៩ ជើងទំព័រ ៥៨។

278 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៣០។

279 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៣១.

280 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៣២។

281 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៣៣។

282 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៣៤។

01677130



ខ្វែងយោបល់គ្នានេះ "មិនធ្វើឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះអស់សុពលភាពនោះទេ"[283]។ ផ្ទុយទៅវិញ ដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ត្រូវបានចេញដោយពុំមានមូលដ្ឋានច្បាប់នោះទ ពីព្រោះគាត់មានកាតព្វកិច្ចបញ្ជូនបញ្ហានេះទៅចំពោះមុខចៅក្រមអន្តរជាតិ បើសិនជាគាត់មិនយល់ស្របជាមួយនឹងដំណើរការប្រព្រឹត្តទៅ ដែលមានលក្ខណៈជាប់ទាក់ទងគ្នាជាមួយនឹងគោលជំហរស្វ័យប្រវត្តិនេះ[284]។

149. លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់តវ៉ាអំពីភាពជាប់ពាក់ព័ន្ធនៃស្ថានការណ៍នៃនិរទោស ដែលបានលើកឡើងដោយសហមេធាវីដោយការយល់ឃើញថា វានៅតែមិនប្រែប្រួលនោះទេ លុះត្រាតែ និងរហូតទាល់តែ យឹម ទិត្យ ត្រូវបានកាត់ឲ្យជាប់ទោសដោយសំឡេងភាគច្រើនលើសលុបរបស់ចៅក្រមនៃចៅក្រមអន្តរជាតិសាលាដំបូង[285]។ បន្ថែមលើនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិនៅតែយល់ឃើញថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអាចត្រូវបានយកមកអនុវត្តដើម្បីបដិសេធសំណុំរឿងនេះចោលបានទេ។ ទីមួយ អត្ថិភាពនៃគោលជំហរស្វ័យប្រវត្តិនេះផ្ទុយទៅនឹងការអះអាងថា បញ្ហាខ្វែងយោបល់ត្រូវតែឈានដល់ការលើកលែងចោទប្រកាន់[286]។ ទីពីរ ការណ៍ដែលសហចៅក្រមស៊ើបអង្កេតបានយល់ផ្សេងគ្នា នៅក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គលរបស់ខ្លួន *ដោយខ្លួនវាផ្ទាល់*មិនបង្កើតមន្ទិលទៅលើការរកឃើញអង្គហេតុជាមូលដ្ឋានរបស់ខ្លួន ឬការកំណត់អំពី យុត្តាធិការបុគ្គលខ្លួនវាឡើយ[287]។ ទោះជាយ៉ាងណា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអនុវត្តលើការរកឃើញអង្គហេតុ នៅដំណាក់កាលមុនការជំនុំជម្រះនោះទេ។ ផ្ទុយទៅវិញ *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាផ្នែកមួយនៃលក្ខខណ្ឌដែលតម្រូវថា ពិរុទ្ធភាពត្រូវតែរកឲ្យឃើញ*នៅពេលជំនុំជម្រះ*ឲ្យហួសពីវិមតិសង្ស័យ[288]។ ចុងក្រោយបំផុត តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

[283] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៣៦។

[284] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៣៧។

[285] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៣៩។

[286] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៤១។

[287] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៤២-៤៣។

[288] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៤៤។

ស្របទៅនឹងសេចក្តីសម្រេចជាឯកច្ឆន្ទរបស់ចៅក្រមអន្តរជាតិ ទៅលើនីត្យានុកូលភាពនៃការចេញដីកាដំណោះស្រាយពីរ និងគោលជំហរស្វ័យប្រវត្តិ អំណះអំណាងរបស់ យឹម ទិត្យ ទាក់ទងនឹងសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវសច្ចភាពផ្លូវច្បាប់ ភាពច្របូកច្របល់ទាក់ទងនឹងមូលដ្ឋានបទចោទ និងការរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័សដែលបានចោទប្រកាន់នោះ លែងជាការចាំបាច់ និងមិនអាចអនុវត្តបានឡើយ[289]។

150. ទាក់ទងនឹងគោលជំហររបស់គាត់ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីពុំមានសេចក្តីសម្រេចបដិសេធចោលដោយសំឡេងភាគច្រើនលើសលុបនោះទេ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ក្រោយពេលដែលដំណើរការបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០៤ ត្រូវបានបញ្ចប់ "គោលការណ៍ជាមូលដ្ឋាន និងជាកត្តាកំណត់" ចំពោះគោលជំហរស្វ័យប្រវត្តិដែលថា "ការស៊ើបអង្កេតត្រូវបន្ត" តម្រូវឱ្យសំណុំរឿងនេះបន្តទៅកាន់ការជំនុំជម្រះ ទោះបីជាចៅក្រមអន្តរជាតិខកខានមិនបានឈានដល់ការសម្រេចដោយសំឡេងភាគច្រើនលើសលុប ស្តីពីសុពលភាពនៃដីកាសម្រេចលើកលែងចោទប្រកាន់ក៏ដោយ[290]។ នេះគឺដោយសារតែគោលជំហរស្វ័យប្រវត្តិត្រូវតែគោរពនៅទូទាំងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ដោយសារចៅក្រមអន្តរជាតិបានសង្កត់ធ្ងន់ជាឯកច្ឆន្ទនៅក្នុងសំណុំរឿង ០០៤/២ រួចមកហើយ[291]។ វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុងជា*ច្បាប់គ្រប់គ្រងពិសេស* និងឆ្លុះបញ្ចាំងអំពីចេតនាច្បាស់លាស់ដើម្បីអនុវត្តគោលជំហរស្វ័យប្រវត្តិនេះ រួមទាំងវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង និងចែងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែប្តឹងទៅចៅក្រមអន្តរជាតិសាលាដំបូង[292]។

---

[289] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៤៦។

[290] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៤៧។

[291] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៤៨-៤៩ *យោងទៅ*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ១១២, ១១៧។

[292] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៥០ ជើងទំព័រ ១១១។

151. អាស្រ័យហេតុនេះ តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអាចអនុវត្តបានទេ ដោយសារតែគ្មាន "មន្ទិលសង្ស័យ"ដែលត្រូវដោះស្រាយនោះទេ[293]។ ទោះជាយ៉ាងណាក៏ដោយ គោលការណ៍នេះ មិនអាចអនុវត្តចំពោះបញ្ហានីតិវិធីបានទេ ពីព្រោះសំខាន់បំផុតនោះ គឺវាជាវិធាននៃការបង្ហាញភស្តុតាង និងមិនមែនជាការបកស្រាយច្បាប់ណាមួយនោះទេ[294]។ លើសពីនេះទៀត ទោះបីជាវាអនុវត្តចំពោះបញ្ហាអង្គច្បាប់ក៏ដោយ ក៏គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ពាក់ព័ន្ធចម្បងជាមួយនឹងការមន្ទិលសង្ស័យដែលទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌ មិនមែននីតិវិធីព្រហ្មទណ្ឌនោះទេ[295]។ សហព្រះរាជអាជ្ញាអន្តរជាតិសង្កត់ធ្ងន់ថា "ការអនុវត្តតាមន័យចង្អៀតរបស់វាចំពោះទ្វេគ្រោះនៃច្បាប់ គឺត្រូវបានកម្រិតត្រឹមតែការមន្ទិលសង្ស័យដែលនៅសេសសល់ក្រោយពី*ការបកស្រាយ* ដោយប្រើវិធានច្បាប់ស៊ីវិលសម្រាប់ការបកស្រាយ" ហើយជា "ការពិត ប្រសិនជាសេណារីយ៉ូណាមួយដែលច្បាប់មិនអាចបញ្ជាក់បានច្បាស់លាស់ វាមិនមែនបង្កើតឲ្យមាន "ការសង្ស័យ" ដែលធ្វើឲ្យចុងចោទតែងតែទទួលបានផលប្រយោជន៍នោះទេ"[296]។ តាមពិត វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថា ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យធ្វើយ៉ាងណាការពារដល់ផលប្រយោជន៍មិនមែនសម្រាប់តែជនជាប់ចោទប៉ុណ្ណោះទេ គឺទាំងជនរងគ្រោះផងដែរ ហើយការធ្វើតាមតែជនជាប់ចោទចំពោះបញ្ហាខាងនីតិវិធីនឹងធ្វើឲ្យមាន "ផលប៉ះពាល់ដ៏គួរឲ្យខ្លាចទៅលើរដ្ឋបាលរបស់ចៅក្រមអន្តរជាតិជាមិនខាន"[297]។

152. សហព្រះរាជអាជ្ញាអន្តរជាតិក៏អះអាងផងដែរថា ការរំលត់កិច្ចដំណើរការនីតិវិធីដោយស្វ័យប្រវត្តិចំពោះកិច្ចដំណើរការនីតិវិធីណាមួយ វានឹងរំលោភលើច្បាប់នីតិវិធីរបស់កម្ពុជា (និងច្បាប់នីតិវិធីបារាំង) ដ៏ដូចជាយុត្តិសាស្ត្ររបស់ អ.វ.ត.ក និងយុត្តិសាស្ត្រអន្តរជាតិ ដែលកំណត់ពីលក្ខខណ្ឌតម្រូវដ៏ខ្ពស់បំផុតសម្រាប់ការបញ្ចប់កិច្ចដំណើរការនីតិវិធី[298]។ យោងតាមបុព្វកថានៃកិច្ច

[293] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៥១។

[294] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៥២។

[295] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៥៣។

[296] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៥៤។

[297] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៥៥។

[298] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៥៧។

ព្រមព្រៀង អ.វ.ត.ក សហព្រះរាជអាជ្ញាអន្តរជាតិនៅតែយល់ឃើញថា "ការទាត់ចោលសំណុំរឿង ០០៤ នៅដំណាក់កាលនេះ គឺជាការរំលោភសិទ្ធិជាក់លាក់ដែលបានផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងក្របខណ្ឌរបស់ អ.វ.ត.ក" និង "បង្កើតបានជាការប្រមាថមួយចំពោះមនុស្សប្រុសស្រីគ្រប់រូប ដែលបានចូលខ្លួនមកបង្ហាញភ័ស្តុតាង [...] ព្រមទាំងមានតម្លៃស្មើនឹងការបរាជ័យ នៅក្នុងការផ្តល់នូវវិធានការយុត្តិធម៌ណាមួយដល់ជនរងគ្រោះរាប់ម៉ឺននាក់ដែលពួកគេកំពុងតែទន្ទឹងរង់ចាំមើលការទទួលខុសត្រូវ អស់រយៈពេលជាងបួនទសវត្សរ៍មកនេះ"[299]។

153. ហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា (១) ទោះបីជា*ការចេញ*ដីកាដំណោះស្រាយពីរដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេតមិនត្រូវបានអនុញ្ញាតក្តី ក៏ការណ៍នេះមិនធ្វើឱ្យមានការច្រានចោលដីកាដំណោះស្រាយទាំងពីរឡើយ។ ផ្ទុយទៅវិញ នៅពេលនេះ អង្គបុរេជំនុំជម្រះត្រូវតែពិចារណាទៅលើឋានៈផ្លូវច្បាប់នៃដីកាដំណោះស្រាយនីមួយៗ[300] (២) ដីកាបញ្ជូនរឿងទៅជំនុំជម្រះគួរតែត្រូវបានតម្កល់ ចំណែកដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានទុកជាមោឃៈ និងគ្មានសុពលភាពផ្លូវច្បាប់ឡើយ (ដោយសារតែមានកំហុសអង្គច្បាប់ និងអង្គហេតុជាច្រើន)[301] និង (៣) បើសិនជាចៅក្រមអន្តរជាតិខកខានមិនបានឈានដល់សេចក្តីសម្រេចមួយ ដែលមានសំឡេងភាគច្រើនលើសលុបដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ នោះត្រូវតែបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅចៅក្រមអន្តរជាតិសាលាដំបូង ស្របតាមពាក្យពេចន៍នៃវិធាន ៧៧(១៣)(ខ) និងវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង[302]។

### ៣. *ការឆ្លើយតបរបស់សហមេធាវី*

154. នៅក្នុងការឆ្លើយតបរបស់ខ្លួន សហមេធាវីស្នើសុំឱ្យចៅក្រមអន្តរជាតិច្រានចោលចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងបញ្ជាក់សាជាថ្មីអំពីសំណើរបស់ខ្លួន ដើម្បីច្រានចោលដីកាដំណោះស្រាយទាំងពីរ ដែលមានវិការៈ និង ៖ (i) លើកលែងការចោទប្រកាន់ប្រឆាំងនឹង យឹម

[299] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៥៨។

[300] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៥៩។

[301] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៦០។

[302] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយពីរ) (D381/25 & D382/28) កថាខណ្ឌ ៦១។

01677134



ទិត្យ *ឬ* (ii) បង្វិលសំណុំរឿងទៅសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីចេញដីកាដំណោះស្រាយរួមគ្នាមួយ *ឬ* (iii) វាយតម្លៃសំណុំរឿង ០០៤ រួចហើយចេញដីកាដំណោះស្រាយខ្លួនឯងផ្ទាល់ ដោយចោទប្រកាន់ យឹម ទិត្យបញ្ជូនទៅជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់ឆាំងនឹងគាត់[303]។ សហមេធាវីអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិ "បកស្រាយមិនត្រឹមត្រូវតាមការរៀបចំរបស់ខ្លួន" ទៅលើការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០៤/២[304] និងថា "ផលវិបាកជាក់ស្តែង" នៃការសម្រេចរបស់ចៅក្រមអន្តរជាតិ គឺថា ដីកាដំណោះស្រាយដែលចេញដោយខុសច្បាប់ ត្រូវបានចាត់ទុកថាមោឃៈ[305]។

155. យោងតាមសហមេធាវី គោលជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថា យឹម ទិត្យ គួរត្រូវបានជំនុំជម្រះដោយផ្អែកលើដីកាដំណោះស្រាយ (ដែលតាមទស្សនៈរបស់សហមេធាវី គឺខុសច្បាប់ និងមានវិការៈនីតិវិធី)[306] បង្ហាញថា តាមពិត សហព្រះរាជអាជ្ញាអន្តរជាតិមិនបានទទួលយកការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ ប៉ុន្តែផ្ទុយទៅវិញ ចម្លើយតបរបស់គាត់ ព្យាយាមគេចចេញ និងជំទាស់ទៅនឹងការសម្រេចជាឯកច្ឆ័ន្ទនេះ[307]។ ផ្អែកលើការបញ្ជាក់របស់សហមេធាវី ទឡ្ហីករណ៍ "បែបសន្ទុត" របស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលស្របច្បាប់មួយដែលអាចជំនុំជម្រះ យឹម ទិត្យ គឺមិនផ្អែកលើមូលដ្ឋានគតិយុត្តិ ប៉ុន្តែជា "ការបកស្រាយដោយខុស និងតាមការរៀបចំរបស់ខ្លួន" ចំពោះការសម្រេចរបស់

---

[303] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១ និងកថាខណ្ឌ ១២-១៣។

[304] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១, ៩-១៦។

[305] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១, ៩,១៧-៣០។

[306] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១០ *ដែលយោងទៅលើ* ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 និង D382/28) កថាខណ្ឌ ២៩-៣៨, ៤៣។

[307] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១១។ សហមេធាវីចាត់ទុកថា ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺជាការស្នើសុំឱ្យមានការពិចារណាឡើងវិញ ដែលគ្មានយុត្តិកម្មចំពោះការសម្រេចរបស់អង្គបុរេជំនុំជម្រះ ឬជាការព្យាយាមដែលគ្មានការអនុញ្ញាតក្នុងការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចរបស់ចៅក្រមអន្តរជាតិ ដែលត្រូវបានហាមឃាត់ដោយវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

01677135



ចៅក្រមអន្តរជាតិតាមរយៈការលើកឡើងដោយមិនត្រឹមត្រូវថា ចៅក្រមអន្តរជាតិមានជំហរថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនត្រូវបានតម្រូវឱ្យចេញដីកាដំណោះស្រាយរួមគ្នាឡើយ[308]។ គោលជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពឹងផ្អែកលើ "កត្តាគោលនយោបាយដែលមិនមានភាពពាក់ព័ន្ធ" និង "អាកប្បកិរិយាចោទប្រកាន់ដែលមិនចេះហត់នឿយ និងជាប្រចាំ" ដើម្បីបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះ ទោះជាក្នុងតម្លៃណាក៏ដោយ ទោះបីជាមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចេញដោយស្របច្បាប់ក្តី[309]។ សហមេធាវីបញ្ជាក់ថា ចៅក្រមអង្គបុរេជំនុំជម្រះបានចុះហត្ថលេខាលើផ្នែកសម្រេចសេចក្តីជាឯកច្ឆ័ន្ទលើសំណុំរឿង ០០៤/២ ដែលថា "ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់" ដូច្នេះការសម្រេចថា ដីកាដំណោះស្រាយចាំបាច់ត្រូវតែជា *សេចក្តីសម្រេចតែមួយ* ហើយថា ក្របខណ្ឌច្បាប់ អ.វ.ត.ក *មិនអនុញ្ញាតឱ្យមាន* ការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នាឡើយ និងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "បានប្រព្រឹត្តកំហុសអង្គច្បាប់ដ៏ធំធេង" ក្នុងការធ្វើដូច្នេះ[310]។

156. ពាក់ព័ន្ធនឹងគោលជំហររបស់ខ្លួន ដែលថា "ផលវិបាកជាក់ស្តែង" នៃការសម្រេចរបស់អង្គបុរេជំនុំជម្រះគឺថា ដីកាដំណោះស្រាយទាំងពីរ ត្រូវបានចាត់ទុកថាមោឃៈ ទីមួយ សហមេធាវីអះអាងថា មិនមានការញែកចេញពីគ្នាតាមផ្លូវច្បាប់រវាងការចេញដីកាដំណោះស្រាយដោយស្របច្បាប់ និងភាពស្របច្បាប់នៃដីកាដំណោះស្រាយផ្ទាល់[311]។ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទថា នៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចេញដីកាដំណោះស្រាយលើសពីមួយ សហ

[308] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១២-១៣ *ដែលយោងទៅលើ* ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 និង D382/28) កថាខណ្ឌ ២៩ *និង* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២១។

[309] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១២, ១៤, ១៦ *ដែលយោងទៅលើ* ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 និង D382/28) កថាខណ្ឌ ២៥-២៦, ២៨-៣៨ *និង* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២១ ទំព័រ ៦២។

[310] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១៥ និងជើងទំព័រ ៣១-៣៣, ៣៧។

[311] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១៨។

01677136



ចៅក្រមស៊ើបអង្កេតបានរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ហេតុដូច្នេះហើយ ដីកាដំណោះស្រាយដែលផ្ទុយគ្នា គឺខុសច្បាប់ និងមានវិការៈនីតិវិធី ដែលជាលទ្ធផល គឺមោឃៈ[312]។ សហមេធាវីទាញសំអាងហេតុថា សកម្មភាពរបស់តុលាការ អាច (i) អនុវត្តដោយអនុលោមទៅតាមច្បាប់ជាធរមាន ឬ (ii) មិនត្រូវបានអនុវត្តដោយអនុលោមទៅតាមច្បាប់ជាធរមាន ដែលក្នុងករណីនេះ គឺចៅក្រម បានធ្វើឡើងតាមអំពើចិត្ត និង*ហួសដែនសមត្ថកិច្ច* និងសេចក្តីសម្រេចដែលមានវិការៈនីតិវិធី គឺមោឃៈ និងមិនមានអានុភាពគតិយុត្តិ[313]។ តាមទស្សនៈរបស់សហមេធាវីសហព្រះរាជអាជ្ញាអន្តរជាតិ "បង្ហាញដោយមិនត្រឹមត្រូវ" និងព្យាយាមបង្ហាញការសម្រេចជាឯកច្ឆ័ន្ទ ដែលមានភាពមិនស្របច្បាប់ និងសាមញ្ញ ទៅជាការសម្រេចដែលស្មុគស្មាញទៅវិញ ប៉ុន្តែគ្មានចំណុចណាមួយក្នុងការពិចារណាជាឯកច្ឆ័ន្ទ បានបង្ហាញថា អង្គបុរេជំនុំជម្រះមានចេតនាច្រានចោលដីកាដំណោះស្រាយតែមួយ នៅក្នុងកាៈទេសៈទាំងនេះឡើយ[314]។ សហចៅក្រមស៊ើបអង្កេត *មិន*ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឆន្ទានុសិទ្ធិ ឯករាជ្យរបស់ខ្លួនឡើយ ហើយសហចៅក្រមស៊ើបអង្កេត ត្រូវបានតម្រូវឱ្យចេញដីកាដំណោះស្រាយតែមួយដែលមានន័យថា ដីកាដំណោះស្រាយទាំងពីរនេះ គឺមោឃៈ[315]។

157. ទីពីរ សហមេធាវីអះអាងថា នៅក្នុងយុត្តាធិការច្បាប់ស៊ីវិល និងច្បាប់កុំមិនឡ វាគឺជា "ច្បាប់សាមញ្ញ" ដែលថា ដីកាសម្រេចរបស់តុលាការ ដែលមិនមានមូលដ្ឋានគតិយុត្តិ គឺមោឃៈ។ ម្យ៉ាងវិញទៀត ដីកាសម្រេចដែលបានចេញដោយខុសច្បាប់ គឺមោឃៈ និងគ្មានអានុភាពគតិយុត្តិ[316]។ នៅក្នុងច្បាប់ អ.វ.ត.ក កិច្ចដែលមានវិការៈនីតិវិធី ដែលត្រូវបានធ្វើមោឃភាព ឬលុបចោល លែង

---

[312] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១៨។

[313] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ១៨។

[314] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ២០ *ដែលយោងទៅលើ* ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 និង D382/28) កថាខណ្ឌ ២៧-២៨, ៣០។

[315] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ២១ *ដែលយោងទៅលើ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២១។

[316] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ២១-២២ (ដែលដកស្រង់ចេញពីច្បាប់របស់សាធារណរដ្ឋកូរ៉េ លីប៊ី សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស)។

01677137



មានអត្ថិភាពទៀតហើយតាមវិធាន ៧៦ (៥) នៃវិធានផ្ទៃក្នុង ហើយនីតិវិធីមោឃភាពនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ២៨០ និងមាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា ១៧៤ និង មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង[317]។ លើសពីនេះទៀត សហមេធាវី យល់ឃើញថា ការបកស្រាយដោយត្រឹមត្រូវចំពោះវិធាន ៦៧ (២) នៃវិធានផ្ទៃក្នុងតម្រូវថា អានុភាពនៃការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៤/២ គឺថា ដីកាដំណោះស្រាយទាំងពីរ គឺមោឃៈ[318]។

158. ទីបី ក្នុងការជំទាស់ទៅនឹងការពឹងផ្អែករបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅលើគោលជំហរស្វ័យប្រវត្តិ ដើម្បីផ្តល់យុត្តិកម្មដល់សុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហមេធាវីអះអាងថា ការបកស្រាយតែមួយនៃ "កិច្ចស៊ើបសួរត្រូវបន្ត" ដែលស្របជាមួយនឹងក្របខណ្ឌគតិយុត្តិ និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ព្រមទាំងនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺថា អង្គបុរេជំនុំជម្រះត្រូវចេញដីកាដំណោះស្រាយផ្ទាល់របស់ខ្លួន[319]។ តាមទស្សនៈរបស់សហមេធាវី សហព្រះរាជអាជ្ញាអន្តរជាតិបានទទួលស្គាល់រួចហើយថា ឧបាស្រ័យដែលបានស្នើឡើងដោយមេធាវីការពារក្តីស្ថិតនៅក្រោមច្បាប់ ក្នុងការទទួលស្គាល់ថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ "ត្រូវធ្វើមោឃភាព"សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិដែលមានកំហុស ដោយបង្វិល ឬចេញសេចក្តីសម្រេចផ្ទាល់ ប៉ុន្តែសហព្រះរាជអាជ្ញាអន្តរជាតិ អះអាងផ្ទុយទៅវិញថា នៅពេលដែលមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត មានតែដីកាសម្រេចចោទប្រកាន់បញ្ជូនទៅជំនុំជម្រះប៉ុណ្ណោះ ដែលស្របគ្នាជាមួយគោលជំហរស្វ័យប្រវត្តិ ហេតុដូច្នេះសហព្រះរាជអាជ្ញាអន្តរ

[317] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ២២។

[318] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ២៤។

[319] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ២៣-២៤ *ដែលយោងទៅលើ* ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 និង D382/28) កថាខណ្ឌ ៣១-៣៦, ៤០, ៤១។

ជាតិអាចមើលរំលងសេចក្ដីសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០៤/០២[320]។

159. ទីបួន សហមេធាវីជំទាស់ទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអនុវត្តចំពោះការសម្រេចលើអង្គហេតុនៅដំណាក់កាលមុនពេលជំនុំជម្រះទេ ដែលជំទាស់ទៅនឹងការបកស្រាយរបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងច្បាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ[321]។ លើសពីនេះទៀត សហមេធាវីអះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិ "បង្ហាញដោយខុស និងបំផ្លើសលើគោលជំហររបស់មេធាវីការពារក្ដី"[322] "ជាន់ឈ្លីលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌" ក្រោមវិធាន ២១ នៃវិធានផ្ទៃក្នុង និងបកស្រាយដោយមិនត្រឹមត្រូវពីវិធាននេះ ដែលហាក់ដូចជាថា សហព្រះរាជអាជ្ញាអន្តរជាតិចាត់ទុកការគណនាចំពោះសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ គឺជា "ល្បែងភ្នាល់យកចាញ់ឈ្នះ" ដែលផ្ទុយទៅនឹងច្បាប់យុត្តិសាស្ត្ររបស់ចៅក្រមអន្តរជាតិ ដែលតម្កល់ថា សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មិនអាច "ជះឥទ្ធិពលផ្ទាល់ និងផ្ទុយចំពោះជំហររបស់ជនជាប់ចោទ ដូចជាថា ត្រូវយកទៅជំនុំជម្រះទោស ឬក៏អត់នោះ" [323]។ ទោះក្នុងករណីណាក៏ដោយ ចំពោះសហមេធាវី ទោះបីជាមានភាពខ្វះចន្លោះ នៅក្នុងវិធាន ៦៧ (១) នៃវិធានផ្ទៃក្នុង

---

[320] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ២៥ *ដែលយោងទៅលើ* បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/19) កថាខណ្ឌ ៨ *និង* ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/25 និង D382/28) កថាខណ្ឌ ៣១-៣២។

[321] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ២៦-២៧, ២៩។

[322] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ៣០។

[323] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ២៨ *ដែលយោងទៅលើ* សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D411/3/6 កថាខណ្ឌ ៩៧។

មិនមាន "មន្ទិលឡើយ" ថា ដីកាដំណោះស្រាយដែលចេញដោយខុសច្បាប់ក្នុងសំណុំរឿង ០០៤ គឺមោឃៈ[324]។

160. ដូច្នេះ សហមេធាវីសន្និដ្ឋានថា (i) គ្មានឯកសារដែលចេញដោយមានសុពលភាព ដែលអាចឲ្យការជំនុំជម្រះ យឹម ទិត្យ បន្តទៅមុខបានឡើយ ពីព្រោះគាត់មិនអាចត្រូវបានជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមោឃៈនោះទេ[325] និង (ii) មធ្យោបាយគតិយុត្តិតែមួយគត់ ដែលមានសម្រាប់ចៅក្រមអន្តរជាតិ គឺឧបាស្រ័យដែលបានស្នើឡើងដោយមេធាវីការពារក្តី។ តាមពិត សហមេធាវីគូសបញ្ជាក់ថា ដោយសារតែសុពលភាពនៃនីតិវិធីនៅក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ មិនអាចលើកឡើងនៅចំពោះមុខចៅក្រមអន្តរជាតិសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ដូច្នេះចៅក្រមអន្តរជាតិចាំបាច់ត្រូវតែផ្តល់ការសន្និដ្ឋានបញ្ចប់ជាក់លាក់ចំពោះកិច្ចដំណើរការនីតិវិធីទាំងអស់នេះ[326]។

## ខ.ការពិភាក្សា

### *១. គ្មានការរំលោភលើ*មតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ *និងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌*

161. ខណៈដែលចៅក្រមអន្តរជាតិយល់ស្របទៅនឹងការលើកឡើងរបស់សហមេធាវី[327] ដែលថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ តាមរយៈ*ការចេញ* ដីកាដំណោះស្រាយចំនួនពីរផ្ទុយគ្នា និងដោយឡែកពីគ្នា ព្រោះការចេញដីកាដំណោះស្រាយទាំងពីរនេះមិនអាចទទួលយកបានអនុលោមតាមច្បាប់ អ.វ.ត.ក ដូចការពន្យល់កន្លងមក[328] ចៅក្រមអន្តរជាតិមិនយល់ថា

---

[324] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ២៩។

[325] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ៣១។

[326] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 និង D382/30) កថាខណ្ឌ ៣២ *ដែលយោងទៅលើ* វិធាន ៧៦ (៧) នៃវិធានផ្ទៃក្នុង។

[327] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 និង D382/21) កថាខណ្ឌ ២១-៣០។

[328] *សូមមើលខាងលើ* [ផ្នែកទូទៅទី ៥ ការចេញដំណាលគ្នានៃដីកាដំណោះស្រាយពីរផ្ទុយគ្នា]។

សកម្មភាពនេះជាការរំលោភលើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ យឹម ទិត្យ ឡើយ[329]។

162. ទីមួយ ចៅក្រមអន្តរជាតិច្រានចោលការអះអាងថា មានការរំលោភសិទ្ធិរបស់ យឹម ទិត្យ ដែលត្រូវផ្តល់សច្ចធារណ៍និរទោស[330]។ ចៅក្រមអន្តរជាតិរំលឹកថា កិច្ចដំណើរការនីតិវិធីនេះស្ថិតក្នុងដំណាក់កាលមុនជំនុំជម្រះ ដែលមិនពាក់ព័ន្ធនឹងការកំណត់ថា មានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពនោះទេ ហើយការសន្និដ្ឋានពីមុនមករបស់អង្គបុរេជំនុំជម្រះដែលថា សច្ចធារណ៍និរទោសត្រូវបានការពារគ្រប់គ្រាន់ ដោយហេតុថា អនុលោមតាមវិធាន ៩៨ (៤) នៃវិធានផ្ទៃក្នុង ការសម្រេចផ្តន្ទាទោសនៅក្នុងដំណាក់កាលជំនុំជម្រះក្តី ទាមទារឲ្យមានសំឡេងគាំទ្រយ៉ាងហោចណាស់ពីចៅក្រមប្អូនសំឡេង និងនៅពេលរកសំឡេងភាគច្រើនតាមតម្រូវការមិនបានទេ មានន័យថា "ជនជាប់ចោទត្រូវរួចផុតពីបទចោទ"[331]។

163. ក្រៅពីនេះ ចៅក្រមអន្តរជាតិច្រានចោលការអះអាងថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* បន្ទាប់ពីចៅក្រមអន្តរជាតិបានធ្វើការវាយតម្លៃផ្ទុយគ្នាលើយុត្តាធិការបុគ្គលរបស់តុលាការចំពោះ យឹម ទិត្យ[332]។ ទីមួយ ចៅក្រមអន្តរជាតិបានសង្កត់ធ្ងន់ថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចបញ្ជូនការខ្វែងយោបល់គ្នារបស់ពួកគេទៅចៅក្រមអន្តរជាតិ ជាជាងបិទបាំងបញ្ហានេះពីអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនឯកភាពលើវិធីសាស្ត្រដែលស្របទៅនឹង

---

[329] *ផ្ទុយនឹង* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 និង D382/21) កថាខណ្ឌ ៣១-៣៦។

[330] *ផ្ទុយនឹង* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 និង D382/21) កថាខណ្ឌ ១៦, ៣៤។

[331] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១៦៣។

[332] *ផ្ទុយនឹង* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/18 និង D382/21) កថាខណ្ឌ ១៦, ៣១, ៣៤។

01677141



គោលជំហរស្វ័យប្រវត្តិ[333]។ ទីពីរ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាវិធាននៃបន្ទុកភស្តុតាង មិនមែនវិធាននៃការបកស្រាយច្បាប់ឡើយ[334]។ ដូច្នេះ ចៅក្រមអន្តរជាតិយល់ថា គ្មានការរំលោភសិទ្ធិរបស់ជនត្រូវចោទឡើយ។

164. លើសពីនេះទៀត ចៅក្រមអន្តរជាតិមិនយល់ស្របទៅនឹងទឡ្ហីករណ៍របស់សហមេធាវីដែលថា "ផលវិបាកជាក់ស្តែង" នៃការសន្និដ្ឋានរបស់ចៅក្រមអន្តរជាតិក្នុងសំណុំរឿង ០០៤/២ គឺដីកាដំណោះស្រាយដែលត្រូវបានចេញដោយខុសច្បាប់ទាំងពីរនេះ គឺមោឃៈ។ ក្នុងសំណុំរឿង ០០៤/២ អង្គបុរេជំនុំជម្រះបានប្រឆាំងជាឯកច្ឆ័ន្ទចំពោះ*ការព្រមព្រៀងគ្នា* របស់សហចៅក្រមស៊ើបអង្កេតលើការផ្តល់សិទ្ធិអំណាចដល់ខ្លួនឯង ក្នុងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា[335]។ *ការព្រមព្រៀងគ្នាដោយខុសច្បាប់*នេះ ដែលព្យាយាម "លាក់ការខ្វែងយោបល់គ្នាមិនឱ្យទទួលបានយន្តការដែលមានសម្រាប់ដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធភាពបំផុត

---

333 *សូមមើល ឧទាហរណ៍* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១១៧-១២០។

334 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) ទស្សនៈរបស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៣២៨ *ដែលយោងទៅលើ* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធក្នុងសំណុំរឿង ០០៣ (ឯកសារ D87/2/1.7/1/1/7) កថាខណ្ឌ ៦៥។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ៧៧ ("ចៅក្រមអន្តរជាតិពិចារណាថា ស្ថានភាពដែលចៅក្រមឯករាជ្យពីររូបចេញសេចក្តីសម្រេចផ្ទុយគ្នាលើបញ្ហាថាតើត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះដែរ ឬយ៉ាងណានោះ គឺមិនបណ្តាលឱ្យមានការអនុវត្តគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* ឡើយ ព្រោះគោលការណ៍នេះកើតចេញពីសច្ចធារណ៍នៃនិរទោស")។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ក្នុងសំណុំរឿង ០០២ (ឯកសារ E50/3/1/4) ("ចៅក្រមអន្តរជាតិតុលាការកំពូល បញ្ជាក់យ៉ាងមុតមាំថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* [...] មានមុខងារជាចម្បងក្នុងការបង្ហាញឱ្យឃើញនូវការយល់ដឹងជាស្វ័យប្រវត្តិក្នុងករណីពុំមានភស្តុតាងលុបបំបាត់ភាពមន្ទិលសង្ស័យ")។

335 *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) កថាខណ្ឌ ១១០។

01677142



នៅក្រោមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ដើម្បីធានានូវការជៀសផុតពីភាពទាល់ច្រកផ្នែកនីតិវិធី"[336] គឺជាការរំលោភភាពសមហេតុផលដ៏សំខាន់នៃក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ដោយពិចារណាពី *មូលហេតុ*របស់អង្គបុរេជំនុំជម្រះ[337]។ ប៉ុន្តែអង្គហេតុដែលថា *សកម្មភាពមួយចំនួន* របស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយទាំងនេះ គឺជាការខុសច្បាប់ មិនអាច "ផ្តល់ភាពសមស្រប" ក្នុងការឈានទៅរកការសន្និដ្ឋានទូទៅដោយគ្មានការបង្ហាញសមហេតុផលអំពីមូលហេតុ ដែលភាពខុសច្បាប់ផ្នែកនីតិវិធីនោះ នាំឱ្យប៉ះពាល់ទាំងស្រុងដល់ដីកាដំណោះស្រាយទាំងនោះឡើយ[338]។

165. ចៅក្រមអន្តរជាតិកត់សម្គាល់បន្ថែមទៀតថា ចៅក្រមអន្តរជាតិបានទទួលបណ្តឹងឧទ្ធរណ៍ដែលត្រូវបានដាក់ អនុលោមតាមវិធាន ៧៤ នៃវិធានផ្ទៃក្នុង ដែលខុសគ្នាពីពាក្យសុំមោឃភាពអនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង។ របបស្តីពីការលុបចោល និងបណ្តឹងឧទ្ធរណ៍មានលក្ខណៈដាច់ដោយឡែកពីគ្នា ហើយអនុវត្តចំពោះប្រភេទចំណាត់ការតាមផ្លូវច្បាប់ខុសៗគ្នា ដែល

---

336 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១២៣។

337 *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៩៩-១០០ ("ចៅក្រមអន្តរជាតិមិនអាចមិនគិតថា សហចៅក្រមស៊ើបអង្កេតប្រហែល *មានចេតនាពិតប្រាកដក្នុងការគេចវេសពីការអនុវត្តច្បាប់នៅក្នុងករណីនេះ ហើយបង្កើតភាពទាល់ច្រកផ្នែកនីតិវិធីនាពេលបច្ចុប្បន្ន*។ តាមពិតទៅ តាមរយៈដីកាសម្រេចពីខាងលើរបស់ពួកគេ ច្បាស់ណាស់ថា សហចៅក្រមស៊ើបអង្កេតព្យាយាមធានាដោយមានចេតនាថា ដំណោះស្រាយណាមួយចំពោះបញ្ហាដែលពួកគេខ្វែងយោបល់គ្នា នឹងត្រូវបានដោះស្រាយតែក្នុងផ្នែកនៃកិច្ចដំណើរការបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះតែប៉ុណ្ណោះ *មិនមែនតាមរយៈនីតិវិធីដែលបានកំណត់ជាក់លាក់ដោយក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក សម្រាប់ដោះស្រាយតែចំពោះការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតនោះទេ*។ សហចៅក្រមស៊ើបអង្កេតបានដឹងអំពីការលំបាកដែលបណ្តាលមកពីសកម្មភាពរបស់ពួកគាត់។ ប៉ុន្តែពួកគាត់ធ្វើឱ្យប្រាកដក្នុងការ *បិទបាំងការខ្វែងយោបល់ ពីយន្តការដោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព* ដែលមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះសូមប្រកាសថ្កោលទោសយ៉ាងច្បាស់លាស់ចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើប្រព័ន្ធច្បាប់របស់ អ.វ.ត.ក នេះ"។ (សេចក្តីបញ្ជាក់បន្ថែម)។

338 *សូមមើលជាទូទៅ* សាលដីកា កថាខណ្ឌ ១០០ ("ម្យ៉ាងវិញទៀត ពុំមែនកំហុសនៃកិច្ចដំណើរការនីតិវិធីទាំងអស់សុទ្ធតែនាំទៅរកការកែប្រែសាលក្រមនោះឡើយ លើកលែងតែកំហុសនោះបណ្តាលឱ្យ "មានលទ្ធផលមិនយុត្តិធម៌ទាំងស្រុងនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ"។

បំពេញឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលពាក់ព័ន្ធនឹងស្តង់ដារផ្សេងៗនៃការពិនិត្យឡើងវិញដោយតុលាការតាមរយៈចៅក្រមអន្តរជាតិ[339]។ តាមពិត វិធាន ៧៦ (៤) នៃវិធានផ្ទៃក្នុងចែងថា "ចៅក្រមអន្តរជាតិអាចប្រកាសថា ពាក្យសុំមោឃភាពនេះមិនអាចទទួលយកបាន" ប្រសិនបើ "ពាក្យសុំនេះមានពាក់ព័ន្ធជាមួយដីកាដែលត្រូវប្តឹងឧទ្ធរណ៍"។ សំខាន់បំផុត គ្មានពាក្យពេចន៍ណាមួយក្នុងវិធាន ៦៧ (២) នៃវិធានផ្ទៃក្នុង តម្រូវឱ្យធ្វើមោឃភាព ឬបដិសេធដីកាដំណោះស្រាយទាំងពីរនេះឡើយ។ វិធាន ៦៧ (២) នៃវិធានផ្ទៃក្នុង លើកឡើងពីផលវិបាកផ្លូវច្បាប់ដោយសារតែគ្មានព័ត៌មានមួយចំនួនក្នុង*ខ្លឹមសារ*នៃដីកាដំណោះស្រាយ និងមិនមែនផលវិបាកផ្លូវច្បាប់ ដោយសារការព្រមព្រៀងគ្នាចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នានោះទេ។ ដូច្នេះ ចៅក្រមអន្តរជាតិសូមច្រានចោលការអះអាងរបស់សហមេធាវីដែលថាការបកស្រាយត្រឹមត្រូវលើវិធាន ៦៧ (២) នៃវិធានផ្ទៃក្នុង អនុលោមតាមវិធាន ៧៦ (៥) នៃវិធានផ្ទៃក្នុង នឹងតម្រូវថា អានុភាពនៃការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ គឺថា ដីកាដំណោះស្រាយទាំងពីរនេះ គឺមោឃៈ។

166. ពាក់ព័ន្ធនឹងការអះអាងរបស់សហមេធាវីដែលថា នេះគឺជា "ច្បាប់ធម្មតា" ទាំងនៅក្នុងយុត្តាធិការច្បាប់ស៊ីវិល និងច្បាប់កុំមិនឡូ ដែលអនីត្យានុកូលភាពផ្នែកនីតិវិធីនៅក្នុងដំណើរការនៃការចេញដីកាសម្រេច វានាំឱ្យដីកាសម្រេចនោះទុកជាមោឃៈ[340] ចៅក្រមអន្តរជាតិមិនជឿជាក់ថា

---

[339] សំណុំរឿង ០០៣ (អបជ ០៩) សេចក្តីសម្រេចលើពាក្យសុំលុបចោល អនុលោមតាមវិធាន ៧៦ (១) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D79/1 ទស្សនៈរបស់ចៅក្រម CHUNG និង DOWNING កថាខណ្ឌ ២។

[340] ការឆ្លើយតបរបស់ យឹម ទិត្យ (ដីកាដំណោះស្រាយចំនួនពីរ) (ឯកសារ D381/27 & ឯកសារ D382/30) កថាខណ្ឌ ២១-២២ (*ដែលដកស្រង់*ច្បាប់ពីយុត្តាធិការនានា ដូចជា សាធារណរដ្ឋកូរ៉េ លីប៊ី សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស (ជើងទំព័រត្រូវបានលុបចេញ))។

វាជាគោលការណ៍ទូទៅនៃច្បាប់[341] ដែលអនីត្យានុកូលភាពផ្នែកនីតិវិធីជាស្វ័យប្រវត្តិ និងជានិច្ចកាល នាំឲ្យមានមោឃភាពនោះឡើយ[342]។

167. ជារួម ខណៈដែលចៅក្រមអន្តរជាតិសម្រេចមិនច្រានចោលដីកាដំណោះស្រាយទាំងពីរដែលផ្ទុយគ្នាប្រឆាំងនឹង យឹម ទិត្យ ដោយផ្អែកលើភាពខុសច្បាប់នៃការចេញដីកាដំណោះស្រាយទាំងនេះ

---

[341] សំណុំរឿង ០០៤ (អបជ២៩) សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍រួមរបស់ យឹម ទិត្យ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D193/91/7 កថាខណ្ឌ ៣២ ("អនុលោមតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀង, មាត្រា ២៣ថ្មីនៃច្បាប់ អ.វ.ត.ក និងវិធាន ២ នៃវិធានផ្ទៃក្នុង នៅពេលច្បាប់ជាធរមានមិនបានលើកឡើងពីបញ្ហាជាក់លាក់ណាមួយ គេអាចស្វែងរកការណែនាំនៅក្នុងវិធាននីតិវិធីដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាសារវ័ន្តដែលមានចែងនៅក្នុងវិធាន ២១ និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន")។

[342] ច្បាប់កូរ៉េដែលបានដកស្រង់នោះចែងថា នីតិវិធីសម្រាប់ផ្តើមចោទប្រកាន់អាចទុកជាមោឃៈ នៅពេលដែល*នីតិវិធីនោះផ្ទុយទៅនឹងបទប្បញ្ញត្តិទាំងនា*នៃច្បាប់នីតិវិធីព្រហ្មទណ្ឌកូរ៉េ។ វាមិនពាក់ព័ន្ធនឹងស្ថានភាពដែលបទប្បញ្ញត្តិនៃច្បាប់មិនបានលើកឡើងអំពីបញ្ហានោះឡើយ ហើយវាក៏មិនតម្រូវជាចាំបាច់ឲ្យធ្វើមោឃភាពទៅលើដីកាចោទប្រកាន់ឡើយ នៅពេលដែលមានការរំលោភលើនីតិវិធីនៅក្នុងការចេញដីកានោះ។ (សូមមើល ឧទាហរណ៍ ច្បាប់នីតិវិធីព្រហ្មទណ្ឌរបស់សាធារណរដ្ឋកូរ៉េ លេខ ៩៧៦៥ (ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩) មាត្រា ៣២៧(២) ដែលចែងថា ("ការចោទប្រកាន់ត្រូវបដិសេធចោលដោយសាលក្រម នៅក្នុងករណីដូចខាងក្រោម៖ [...] នៅពេលដែលនីតិវិធីផ្តើមចោទប្រកាន់ទុកជាមោឃៈ ដោយសារតែនីតិវិធីនេះផ្ទុយទៅនឹងបទប្បញ្ញត្តិនៃច្បាប់" (បកប្រែក្រៅផ្លូវការ")។

ចៅក្រមអន្តរជាតិកត់សម្គាល់បន្ថែមទៀតពាក់ព័ន្ធនឹងក្រមនីតិវិធីព្រហ្មទណ្ឌលីប៊ី (ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៥៣) មាត្រា ៣០៤ ("មោឃភាពត្រូវតែកើតមាន នៅពេលដែលការមិនប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ *ពាក់ព័ន្ធទៅនឹងកិច្ចជាដុំកំភួនណាមួយ*។ (សេចក្តីបញ្ជាក់បន្ថែម)) ដែលនេះមានន័យថា អនីត្យានុកូលភាពត្រូវតែ "ជាដុំកំភួន" ដើម្បីអាចឲ្យមានមោឃភាពទៅបាន ដែលចំណុចនេះហាក់ដូចជាធ្វើឲ្យបរាជ័យចំពោះការលើកឡើងដែលថា អនីត្យានុកូលភាព ជាស្វ័យប្រវត្តិ នាំឲ្យមានមោឃភាព។ ចៅក្រមអន្តរជាតិសន្និដ្ឋានបន្ថែមទៀតថា យុត្តាធិការដែលបានដកស្រង់ខាងក្រោមនេះ មិនត្រឹមត្រូវឡើយ៖ ការយោងទៅរឿងក្តី *Romito* តទល់នឹង *Maxwell* 227 N.E.2d, 223, 224 (Ohio 1967) (នៅពេលដែលការផ្តន្ទាទោសព្រហ្មទណ្ឌដែលចោទជាបញ្ហានេះ ត្រូវបានរកឃើញថាមោឃៈ ជាមុនរួចហើយ)។ រឿងក្តីរដ្ឋ តទល់នឹង *Bezak* 868 N.E.2d 961, 963 (Ohio 2007) និងរឿងក្តី រដ្ឋ តទល់នឹង *Simpkins* 884 N.E.2d 568, 575 (Ohio 2008) (នៅពេលដែល នៅក្នុងករណីទាំងពីរនេះ លក្ខខណ្ឌតម្រូវតាមច្បាប់មានអត្ថិភាព)។ រឿងក្តី *R (តាមបណ្តឹងរបស់ UNISON)* តទល់នឹង *Lord Chancellor (ចុងចម្លើយ)* [2017] UKSC 51 កថាខណ្ឌ ១១៩ និង រឿងក្តី *R (តាមបណ្តឹងរបស់ Miller)* (ដើមបណ្តឹង) តទល់នឹង នាយករដ្ឋមន្ត្រី (ចុងចម្លើយ) *Cherry* និងអ្នកផ្សេងទៀត (ចុងចម្លើយ) តទល់នឹងជំនួយការចៅក្រមប្រទេសស្កុតលេន (ដើមបណ្តឹង) (ប្រទេសស្កុតលេន) [2019] UKSC 41 កថាខណ្ឌ ៦៩ (នៅពេលដែល ក្នុងករណីទាំងពីរនេះ តុលាការកំពូលរបស់ចក្រភពអង់គ្លេស ញែកដាច់ពីគ្នានូវលក្ខណៈនៃអនីត្យានុកូលភាព និងផលវិបាកគតិយុត្តិ)។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

ចៅក្រមអន្តរជាតិបញ្ជាក់ជាថ្មីថា ទោះបីជាមានការចេញដីកាដំណោះស្រាយពីរដោយខុសច្បាប់ក្តី ក៏ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ចំណែកដីកាលើកលែងការចោទប្រកាន់គឺគ្មានសុពលភាព ដូចការលើកឡើងខាងក្រោម អនុលោមតាមគោលជំហរស្វ័យប្រវត្តិ។

## *២. សុពលភាពនៃដីកាដំណោះស្រាយទាំងពីរ*

### ក. អត្ថន័យនៃ "ការស៊ើបអង្កេតត្រូវធ្វើបន្ត"-មាត្រា ៥ (៤) និងមាត្រា ៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

168. ចៅក្រមអន្តរជាតិជាដំបូងសូមរំលឹកថា សហចៅក្រមស៊ើបអង្កេតមួយរូបអាចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបំពេញកិច្ចតែម្នាក់ឯង ដោយសុពលភាព[343]។ ចៅក្រមអន្តរជាតិកត់សម្គាល់បន្ថែមទៀតថា មាត្រា ៥ (៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៣ *ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា ក្នុងករណីមានការខ្វែងយោបល់គ្នារវាងចៅក្រមស៊ើបអង្កេត "ការស៊ើបអង្កេតត្រូវធ្វើបន្ត" លើកលែងតែសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬតែមួយរូប បានបញ្ជូនការខ្វែងយោបល់របស់ពួកគេទៅចៅក្រមអន្តរជាតិ[344]។

---

[343] *សូមមើល* វិធាន ១ (២) នៃវិធានផ្ទៃក្នុង "លើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈតំណាង")។ *សូមមើល ឧទាហរណ៍* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ១០៥។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់ចៅក្រមស៊ើបអង្កេត នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ ក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ឯកសារ D208/1/1/2 កថាខណ្ឌ ១១។ សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូងក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ A122/6.1/3 កថាខណ្ឌ ១៤។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើញត្តិសុំពិចារណាឡើងវិញ និងសុំលុបចោលដីកាកោះ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D236/1/1/8 កថាខណ្ឌ ៣០។ *សូមមើលជាទូទៅ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) យោបល់របស់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៥៥។

[344] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៥ (៤) "សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នាដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេត

169. ចៅក្រមអន្តរជាតិកត់សម្គាល់ថា គោលការណ៍នៃការបន្តការស៊ើបអង្កេតតាមផ្លូវតុលាការនេះគ្រប់គ្រងលើបញ្ហាដែលនៅចំពោះមុខពេលនេះ[345]។ ខណៈដែលនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង អាចមិនត្រូវបានអនុវត្តចំពោះនីតិវិធីទាំងនេះ *បន្ទាប់ពី*ការចេញដីកាដំណោះស្រាយមួយ ចំណុចនេះមិនរារាំងការអនុវត្តចំពោះនីតិវិធីនៃ*ការចេញ*ដីកាដំណោះស្រាយ មុនការបិទបញ្ចប់កិច្ចស៊ើបសួរនោះទេ[346]។ ដូចការលើកឡើងរបស់ចៅក្រមអន្តរជាតិក្នុងសេចក្តីសម្រេចពីមុន ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតណាម្នាក់ស្នើឱ្យចេញដីកាដំណោះស្រាយ ហើយសហចៅក្រមម្នាក់ទៀតមិនយល់ស្រប ចៅក្រមម្នាក់ ឬទាំងពីរនាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះទៅដាក់ចំពោះមុខចៅក្រមអន្តរជាតិ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង[347]។ ចៅក្រមអន្តរជាតិរំលឹកបន្ថែមទៀតថា ការសម្រេចរបស់ចៅក្រមអន្តរជាតិតុលាការកំពូលដែលថា "ប្រសិនបើ [...] អង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុស*ក្នុងការសម្រេចចេញ ឬក្នុងការស្នើ*ឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទ គឺជា ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើចៅក្រមអន្តរជាតិមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[348]។

---

ណាមួយ *ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត* លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំក្នុងរយៈពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧") (សេចក្តីបញ្ជាក់បន្ថែម)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ *ថ្មី* ("*ការស៊ើបអង្កេតត្រូវធ្វើបន្ត* ដរាបណា សហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូបក្នុងចំណោមពួកគេ ពុំបានប្តឹងមិនសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម") (សេចក្តីបញ្ជាក់បន្ថែម)។

[345] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) ទស្សនៈរបស់ចៅក្រម BEAUVALLET និង BAIK កថាខណ្ឌ ២៥៦។

[346] វិធាន ៦៧ (១) នៃវិធានផ្ទៃក្នុង "សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរដោយចេញដីកាដំណោះស្រាយ")។

[347] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៩៤, ១១៦។

[348] សាលដីកាក្នុងសំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៦៥ (សេចក្តីបញ្ជាក់បន្ថែម)។

170. ក្នុងសំណុំរឿងដែលនៅចំពោះមុខនេះ គ្មានសហចៅក្រមស៊ើបអង្កេតណាម្នាក់បាននាំយកករណីខ្វែងយោបល់គ្នានេះទៅដាក់ចំពោះមុខអង្គបុរេជំនុំជម្រះក្នុងរយៈពេល ៣០ ថ្ងៃ ឡើយ[349] ចាប់ពីការចុះករណីខ្វែងយោបល់គ្នានេះនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩។ ក្នុងស្ថានភាពជាក់លាក់នេះដែលសហចៅក្រមស៊ើបអង្កេតណាម្នាក់ស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសហចៅក្រមស៊ើបអង្កេតម្នាក់ទៀតមិនយល់ស្រប "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ" ក្នុងនាមជាគោលជំហរស្វ័យប្រវត្តិដែលអាចអនុវត្តបាន ក្នុងករណីគ្មានការដោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត។ មានន័យថា ត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ទៅតាមការស្នើឡើង[350]។

171. លើសពីនេះទៀត ក្នុងការត្រួតពិនិត្យអត្ថន័យនៃ "ការស៊ើបអង្កេតត្រូវធ្វើបន្ត" ចៅក្រមអន្តរជាតិសម្រេចថា មិនមាននរណាម្នាក់អាចបកស្រាយដោយសមហេតុផលនូវពាក្យពេចន៍នេះ ក្នុងអត្ថន័យទូទៅរបស់វា និងដោយផ្អែកលើគោលដៅ និងគោលបំណងរបស់វាដើម្បីបញ្ចូលនូវការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ឡើយ[351]។ ទីមួយ ក្នុងន័យទូទៅរបស់ពាក្យពេចន៍នេះ ការស្នើចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ដែលមានលក្ខណៈផ្ទុយទាំងស្រុងជាមួយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបញ្ជូនសំណុំរឿងទៅជំនុំជម្រះ មិនអាចត្រូវបានទទួលស្គាល់ថាជាកិច្ចស៊ើបសួរផ្សេងឡើយ។ វាគ្រាន់តែជាការកំណត់ប្រភេទផ្សេងនៃការខ្វែងយោបល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចាំបាច់ត្រូវដោះស្រាយដោយនីតិវិធីដោះស្រាយការខ្វែងយោបល់តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។ ទីពីរ គោលបំណងនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺដើម្បីនាំខ្លួនមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ

---

[349] *សូមមើល* កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៥ (៤)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ *ថ្មី*។ វិធាន ៧២ (២) នៃវិធានផ្ទៃក្នុង។

[350] កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៥ (៤) មាត្រា ៧ (៤)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ *ថ្មី*។

[351] អនុសញ្ញាទីក្រុងវីយែន មាត្រា ៣១ (១) ("សន្ធិសញ្ញាមួយគួរត្រូវបានបកស្រាយដោយចេតនាល្អ ស្របទៅតាមអត្ថន័យទូទៅដែលមានសម្រាប់ពាក្យពេចន៍នៃសន្ធិសញ្ញានោះ ក្នុងបរិបទរបស់ពួកគេ និងស្របទៅតាមគោលដៅ និងគោលបំណងរបស់សន្ធិសញ្ញានោះ")។ *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៥៨។

មកជំនុំជម្រះពីបទឧក្រិដ្ឋកម្ម[352]។ ជាការសមហេតុផលក្នុងការទាញសន្និដ្ឋានពីពាក្យពេចន៍នៃមាត្រា ៥ (៤) មាត្រា ៦ (៤) និងមាត្រា ៧ នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ២០ *ថ្មី* និង ២៣ *ថ្មី* នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធាន ១៣ (៥) វិធាន ១៤ (៧) វិធាន ៧១ និងវិធាន ៧២ នៃវិធានផ្ទៃក្នុង ថា គោលដៅជាគន្លឹះនៃយន្តការដោះស្រាយការខ្វែងយោបល់គ្នាគឺរារាំងភាពជាប់គាំងដែលបណ្ដាលឲ្យកិច្ចដំណើរការនីតិវិធីផុតចេញពីការបញ្ជូនទៅជំនុំជម្រះ[353]។

172. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសម្រេចថា ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បើទោះបីជាមានការព្រមព្រៀងគ្នាដោយខុសឆ្គងរបស់គាត់លើការចេញដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហការីគាត់ក្នុងពេលជាមួយគ្នាក្ដី គឺអនុលោមផ្នែកនីតិវិធីទៅតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ចំណែកការចេញដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ គឺមិនមានមូលដ្ឋានគតិយុត្តិឡើយ[354]។

173. ចៅក្រមអន្តរជាតិអះអាងសាជាថ្មីថា ដីកាដំណោះស្រាយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវតែជាសេចក្ដីសម្រេចតែមួយ[355]។ ចៅក្រមអន្តរជាតិគូសបញ្ជាក់ថា ក្នុង

---

[352] កិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ១។ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ១។

[353] ប្រវត្តិចរចារបស់ អ.វ.ត.ក គាំទ្រដល់ការបកស្រាយនេះ។ *សូមមើល ឧទាហរណ៍* D. SCHEFFER "ចៅក្រមអន្តរជាតិវិសាមញ្ញក្នុងតុលាការកម្ពុជា" (២០០៨) ទំព័រ ២៣១ ("នៅពេលគ្មានការបោះឆ្នោតសំឡេងភាគច្រើនលើសលប់ កិច្ចស៊ើបសួរ ឬអនុសាសន៍ក្នុងការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ នឹងបន្តទៅមុខ")។ D. CIORCIARY & A. HEINDEL យុត្តិធម៌កូនកាត់ (ការបោះពុម្ពផ្សាយលើកទី ១ សហរដ្ឋអាមេរិក The University of Michigan Press ២០១៤) ឯកសារ D297.1 ទំព័រ ៣១ ("ដើម្បីគ្រប់គ្រងហានិភ័យនៃការខ្វែងយោបល់គ្នា និងភាពជាប់គាំងរវាងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត មន្ត្រីសហរដ្ឋអាមេរិកបានជំរុញឲ្យមានការបង្កើតក្រុមតុលាការពិសេសមួយសម្រាប់គោលបំណងនោះ។ ក្រោយមកទៀត មន្ត្រីអង្គការសហប្រជាជាតិ និងមន្ត្រីកម្ពុជាបានព្រមព្រៀងបង្កើតចៅក្រមអន្តរជាតិដែលមានសមាសភាពចៅក្រមកម្ពុជា ៣ រូប និងចៅក្រមអន្តរជាតិ ២ រូប ដែលមានសិទ្ធិអំណាចក្នុងការរារាំងកិច្ចស៊ើបសួរ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយផ្អែកតាមការបោះឆ្នោតសំឡេងភាគច្រើនលើសលប់")។

[354] *សូមមើល* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) ទស្សនៈរបស់ចៅក្រម BEAUVALLET និង BAIK កថាខណ្ឌ ២៥៩។

[355] *សូមមើលកថាខណ្ឌ ១១០ ខាងលើ សូមមើលផងដែរ* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៦០។

កាលៈទេសៈបច្ចុប្បន្ន ការបញ្ជូនការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតទៅអង្គបុរេជំនុំជម្រះ គឺជាការតម្រូវចាំបាច់ខានមិនបាន ហើយថា សហចៅក្រមស៊ើបអង្កេតមិនមានមធ្យោបាយផ្សេងក្នុងការដោះស្រាយជម្លោះរបស់ពួកគេឡើយ នៅពេលដែលពួកគេមិនបានគោរពទៅតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការឈានទៅរកគោលជំហររួមមួយ ពាក់ព័ន្ធដីកាដំណោះស្រាយ[356]។ ចៅក្រមអន្តរជាតិពិចារណាថា ការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ដែលផ្ទុយគ្នាដោយសហចៅក្រមស៊ើបអង្កេតជាតិដោយមិនបញ្ជូនទៅអង្គបុរេជំនុំជម្រះ គឺជាការព្យាយាមដោយឥតអៀនខ្មាស់ក្នុងការគេចវេសទាំងស្រុងពីលក្ខខណ្ឌតម្រូវដ៏សំខាន់ និងជាចាំបាច់នេះ ដែលធ្វើឱ្យខូចខាតដល់អត្ថបទគតិយុត្តិជាមូលដ្ឋានរបស់ អ.វ.ត.ក។ ជាពិសេស មាត្រា ៥ និង មាត្រា ៧ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក បានចែងយ៉ាងច្បាស់អំពីការណែនាំស្តីពីការប្រព្រឹត្ត និងលទ្ធផលតាមការតម្រូវរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិសម្រេចថា ការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ដែលជាការព្យាយាមមួយ ដើម្បីគេចចេញពីនីតិវិធីដែលតម្រូវចាំបាច់សម្រាប់ការខ្វែងយោបល់គ្នា គឺមានកំហុសឆ្គងអង្គច្បាប់ដែលដូច្នេះហើយត្រូវចាត់ទុកថាមោឃៈ។

174. បន្ថែមលើនេះ ចៅក្រមអន្តរជាតិមានទស្សនៈថា ទឡ្ហីករណ៍អំពីចន្លោះប្រហោងដែលអាចមាននៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ពាក់ព័ន្ធនឹងផលវិបាកគតិយុត្តិនៃការចេញដីកាដំណោះស្រាយផ្ទុយគ្នា គឺមិនអាចអនុវត្តបានឡើយក្នុងសំណុំរឿងបច្ចុប្បន្ន។ បើទោះបីជាអង្គបុរេជំនុំជម្រះត្រូវទទួលស្គាល់ថា ស្ថានភាពលម្អៀងបែបនេះ គឺមិនត្រូវបានប្រមើលមើលជាមុននៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ក្តី តែភាពមិនជាក់លាក់ដែលចោទឡើង ត្រូវបានលុបបំបាត់ចោលតាមរយៈការបកស្រាយដោយសមស្របទៅលើអត្ថបទគតិយុត្តិពាក់ព័ន្ធ ជាពិសេសមាត្រា ៥ (៤) និងមាត្រា ៧ (៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២០ និង ២៣ *ថ្មី*

---

[356] *សូមមើលកថាខណ្ឌ ១០៨-១១០ ខាងលើ*។ *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៦០។

នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលតម្កល់គោលការណ៍បន្តកិច្ចស៊ើបសួរ និងការជំនុំជម្រះ[357]។ បន្ថែមលើនេះ ចៅក្រមអន្តរជាតិសូមបញ្ជាក់បំភ្លឺថា យោងតាមវិធាន ៧៧ (១៣) (ខ) នៃវិធានផ្ទៃក្នុង នៅពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានច្រានចោលទេនោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវមានសុពលភាព កិច្ចដំណើរការនីតិវិធីចាំបាច់ត្រូវបន្ត ហើយសំណុំរឿងចាំបាច់ត្រូវបញ្ជូនទៅជំនុំជម្រះ។

175. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសម្រេចថា ដីកាដំណោះស្រាយដែលចោទជាបញ្ហាទាំងពីរ គឺមិនដូចគ្នាបេះបិទឡើយ សម្រាប់អនុលោមភាពរបស់វាទៅតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក។ ចៅក្រមអន្តរជាតិសូមរំលឹកថា យោងតាមសំអាងហេតុដែលបានបញ្ជាក់ពីខាងលើ ដីកាសម្រេចលើកលែងការចោទប្រកាន់គឺមោឃៈ[358] ហើយសន្និដ្ឋានថា ការចេញដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិគឺ *ហួសដែនសមត្ថកិច្ច* ដែលដូច្នេះហើយ គឺត្រូវមោឃភាព ដោយសារនេះគឺជាការព្យាយាមធ្វើឱ្យខូចខាតគោលជំហរជាក់ស្តែង ដែលមានចែងនៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។ ផ្ទុយទៅវិញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានសុពលភាព ដោយសារតែដីកានេះនៅបន្តអនុលោមភាពរបស់ខ្លួនជាមួយគោលជំហរជាក់ស្តែងដូចបានបញ្ជាក់ខាងលើ។

ខ.ការសម្រេចលើសុពលភាពនៃដីកាដំណោះស្រាយទាំងពីរនេះ

176. ដូចដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌកន្លងមក ចៅក្រមអន្តរជាតិយល់ឃើញថា ផ្អែកលើលក្ខណៈមិនអាចអនុញ្ញាតបាន ដែលតាមរយៈលក្ខណៈនោះ ដីកាសម្រេចលើកលែងការចោទប្រកាន់ត្រូវបានចេញ[359] ទើបដីកានេះត្រូវទុកជាមោឃៈ។ សរុបសេចក្តីមក ចៅក្រមអន្តរជាតិសន្និដ្ឋានថា ទោះបីជាមានការចេញដីកាដំណោះស្រាយក្នុងពេលជាមួយគ្នាក្តី ក៏ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

---

[357] *សូមមើលកថាខណ្ឌ ៥ ខាងលើ (ការចេញដីកាដំណោះស្រាយ ពីរផ្ទុយគ្នា) សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) ទស្សនៈរបស់ចៅក្រម BEAUVALLET និង BAIK កថាខណ្ឌ ២៦១។

[358] *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៦២។

[359] *សូមមើលកថាខណ្ឌ* បណ្តឹងឧទ្ធរណ៍របស់មេធាវីលើដីកាដំណោះស្រាយពីរផ្ទុយគ្នា ផ្នែក (២)(ខ)(១) ខាងលើ។

មានអានុភាពដែរ ដោយសារតែដីកានោះមានសុពលភាពជាសារធាតុ ហើយមានអនុលោមភាពជាមួយក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក រួមទាំងគោលជំហរជាក់ស្តែងដែលអាចអនុវត្តបាន ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ហើយដែលមានគោលដៅនាំយកមកជំនុំជម្រះចំពោះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយខ្មែរក្រហម[360]។

177. អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍របស់សហមេធាវីប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ និងសំណើសុំដំណោះស្រាយដែលបានរៀបរាប់ខាងលើ។

# បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី យឹម ទិត្យ នៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ

## A. មូលដ្ឋានទី ២.២ ÷ ការចោទប្រកាន់អំពីការខកខានមិនបានកំណត់ពីធាតុផ្សំគតិយុត្តិនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អង្គហេតុសំខាន់ៗ និងភស្តុតាងជាមូលដ្ឋាន

ក. សារណា

178. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ ដោយបានចេញដីកាដំណោះស្រាយ ដែលមិនបានបំពេញលក្ខខណ្ឌជាមូលដ្ឋានសម្រាប់ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ស្របតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង[361]។ នៅពេលកំណត់មាត្រា ៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ជាអង្គច្បាប់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានលើកឡើងពីធាតុផ្សំគតិយុត្តិនៃឧក្រិដ្ឋកម្ម មូលដ្ឋានអង្គហេតុនៃបទចោទ និងភស្តុតាងគាំទ្រ ដែលទាក់ទងនឹង៖ (i) សំអាងហេតុដែលថា "ខ្មែរក្រោម" ជាក្រុមពិសេស និង (ii) ទាក់ទងនឹងសំអាងហេតុរបស់គាត់ដែលថា យឹម ទិត្យ មានចេតនាពិសេស ដែលជាលក្ខខណ្ឌសម្រាប់អំពើប្រល័យពូជសាសន៍[362]។

[360] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុង សំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៨៥។

[361] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៥៦-៥៨, ៧៩។

[362] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៦៤។

01677152



179. ទីមួយ សហមេធាវីអះអាងថា ការប្រើប្រាស់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះ "លក្ខខណ្ឌចម្រុះទៅតាមករណីជាក់ស្ដែង" ដើម្បីកំណត់ខ្មែរក្រោមជាក្រុមពិសេស គឺជាការបកស្រាយយ៉ាងទូលាយពេក ដោយមិនបានជូនដំណឹងឱ្យបានគ្រប់គ្រាន់ដល់ យឹម ទិត្យ អំពីលក្ខណៈនៃបទចោទប្រកាន់ទាំងនឹងគាត់[363]។ សហមេធាវីបញ្ជាក់ថា លក្ខណៈទូទៅនៃក្រុមដែលត្រូវទទួលបានការការពារដោយអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ ត្រូវតែបានបញ្ជាក់យ៉ាងច្បាស់ជាលក្ខណៈសត្យានុម័ត និងថា ការពឹងផ្អែកលើវិធីសាស្ត្របែបអត្តនោម័តិសុទ្ធសាធ គឺជាកំហុសឆ្គង[364]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានលើកឡើងអំពីលក្ខខណ្ឌគតិយុត្តិបន្ថែម ដូចជាភាពមិនសមស្របនៃការបង្ហាញចរិតលក្ខណៈរបស់ "ក្រុមជាតិពន្ធុ" តែមួយនៅក្នុងលក្ខខណ្ឌទូទៅ ដែលក្រុមជាច្រើនត្រូវបានកំណត់គោលដៅ[365] និងមិនបានបញ្ជាក់ពីមូលដ្ឋានអង្គហេតុ និងភ័ស្តុតាងគាំទ្រ ដែលបញ្ជាក់ពីស្ថានភាពរបស់ខ្មែរក្រោមថាជាក្រុមមួយដែលត្រូវទទួលបានការការការពារ[366]។

180. ទីពីរ សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានញែកចេញនូវ *ធាតុផ្សំអត្តនោម័តិ* នៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ពីចេតនាជាក់លាក់ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់អំពើប្រល័យពូជសាសន៍ (ដែលចារីត្រូវតែមានចេតនាបំផ្លាញក្រុមនោះ *តែម្ដង*) ដោយការរួមបញ្ចូលគ្នារវាងចេតនារើសអើង ឬការដឹងឮ ដោយមានចេតនាជាក់លាក់នៃអំពើប្រល័យពូជសាសន៍[367]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានលើកឡើងអំពីលក្ខខណ្ឌតម្រូវដែលថា អំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្ត នៅពេលដែលគោលដៅចុងក្រោយបង្អស់របស់ចារី គឺដើម្បីបំផ្លាញក្រុមនោះ និងខកខានមិនបានលើកឡើងពីលក្ខណៈពិសេសនៃធាតុផ្សំ "បែបនេះ" ក្នុងការតម្រូវឱ្យមានទំនាក់ទំនងរវាងចេតនា ដើម្បីបំផ្លាញក្រុមដែលត្រូវទទួលបានការការពារមួយ និងមូលដ្ឋានដែលត្រូវបានគេគិតគូរ ថាតើក្រុមណា ដែលត្រូវទទួលបានការការពារ

---

[363] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៦៥។

[364] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៦៦។

[365] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៦៧-៦៨ (និងភាពខុសគ្នាផ្អែកច្បាប់រវាង "ផ្នែកនៃក្រុមមួយ" និងក្រុមដែលត្រូវបានកំណត់អត្តសញ្ញាណដោយយោងទៅលើក្រុមមួយទៀត)។

[366] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៦៩-៧១។

[367] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៧២-៧៥។

01677153



[368]។ នៅចុងបញ្ចប់ សហមេធាវីបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការខកខានមិនបានលើកឡើងពីអង្គហេតុសំខាន់ៗ ដែលជាមូលដ្ឋានសម្រាប់សំអាងហេតុនៃចេតនាបុគ្គលរបស់ យឹម ទិត្យ (ដែលផ្ទុយទៅនឹងគោលនយោបាយរបស់ ប.ក.ក ក្នុងន័យទូលាយជាងនេះ)[369] ដោយសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ មិនមានភ័ស្តុតាងដោយផ្ទាល់ណាមួយ ដែលថា យឹម ទិត្យ មានចេតនាជាក់លាក់ ដើម្បីបំផ្លាញក្រុមជនជាតិភាគតិចខ្មែរក្រោមទាំងស្រុង ឬជាផ្នែកនោះឡើយ[370]។

181. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហមេធាវីខកខានមិនបានបង្ហាញពីកំហុសអង្គច្បាប់ដែលអាចពិនិត្យមើលឡើងវិញបាន នៅក្នុងវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ឬសំអាងហេតុរបស់គាត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានកំណត់អំពីធាតុផ្សំជាលក្ខខណ្ឌស្របតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង[371]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់អត្តសញ្ញាណខ្មែរក្រោមយ៉ាងត្រឹមត្រូវថាជាក្រុមមួយ ដោយផ្អែកលើជាតិពន្ធុ ពូជសាសន៍ និងសញ្ជាតិ ដោយបានលើកឡើងអំពីបុគ្គលិកលក្ខណៈជាក់លាក់របស់ក្រុម[372] និងបានបង្ហាញពីចំណុចពាក់ព័ន្ធនៃចំណងរវាងការកំណត់គោលដៅនៃខ្មែរក្រោម និងវៀតណាម[373]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្ហាញយ៉ាងត្រឹមត្រូវអំពី*ធាតុផ្សំអត្តនោម័តិ* នៃអំពើប្រល័យពូជសាសន៍[374] ដែលបានសំដៅដល់អង្គហេតុសំខាន់ៗ ដែលបញ្ជាក់អំពីចេតនារបស់ យឹម ទិត្យ និងបានញែកពីភាពខុសគ្នារវាងសំអាងហេតុដែលទាក់ទងនឹង យឹម ទិត្យ ដែលផ្ទុយទៅនឹង ប.ក.ក ដោយសន្និដ្ឋានថា យឹម ទិត្យ ទំនងជាអ្នកផ្តួចផ្តើមឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចំពោះខ្មែរក្រោម[375]។

---

[368] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៧៤-៧៥។
[369] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៧៦។
[370] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៧៦-៧៨។
[371] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៤៥-៤៦,៥០។
[372] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៥១។
[373] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៥២។
[374] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៥៣។
[375] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៥៤។

## ខ. ការពិភាក្សា

182. ចៅក្រមអន្តរជាតិរំលឹកឡើងវិញថា អនុលោមតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវមានការពិពណ៌នាអំពីអង្គហេតុសត្យានុម័ត និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត[376]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវតែកំណត់នូវអង្គហេតុសំខាន់ៗនៃសំណុំរឿង ដោយមានព័ត៌មានលម្អិតគ្រប់គ្រាន់ ដើម្បីជូនដំណឹងដល់ជនជាប់ចោទអំពីប្រភេទបទល្មើស និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនគាត់ ដើម្បីឲ្យគាត់មានលទ្ធភាពរៀបចំការការពារខ្លួនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល[377]។

183. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ យឹម ទិត្យ ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកក្រុមនៅក្នុងតំបន់ ១៣ នៃភូមិភាគនិរតី និងតំបន់ ២ និងតំបន់ ៤ នៃភូមិភាគពាយ័ព្យ ដោយផ្អែកលើមូលដ្ឋាននៃទម្រង់នៃការទទួលខុសត្រូវផ្សេងៗគ្នារួមទាំងសហឧក្រិដ្ឋកម្មរួម (JCE)[378]។ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិសង្កត់បញ្ជាក់ពីច្បាប់ជាធរមាន ដូចមានចែងក្នុងមាត្រា ៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[379] និងកំណត់ពីធាតុផ្សំគតិយុត្តិនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ថាជា "ការប្រព្រឹត្តអំពើណាមួយដែលមានចែងក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក ក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ជាពិសេស ដែលត្រូវបានកំណត់គោលដៅ"[380]។

---

[376] វិធាន ៦៧(២)នៃវិធានផ្ទៃក្នុង។ សំណុំរឿង ០០២ (អបជ៣៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/14/15 ("សាលដីកា JCE សំណុំរឿង ០០២ (ឯកសារ D97/14/15)" កថាខណ្ឌ ៣២។

[377] សាលដីកា JCE សំណុំរឿង ០០២ (ឯកសារ D97/14/15)" កថាខណ្ឌ ៣២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋកម្មតាមច្បាប់ជាតិ) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E122 កថាខណ្ឌ ១៨។

[378] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤៧៥-៤៧៦។

[379] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៥៩។

[380] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៥៩។ *សូមមើលបន្ថែមទៀត* កថាខណ្ឌ ៦០-៧២។

184. ចៅក្រមអន្តរជាតិសង្កេតឃើញថា ការជំទាស់របស់សហមេធាវី ពាក់ព័ន្ធនឹងធាតុផ្សំជាក់លាក់ចំនួនពីរ និងត្រូវបានដោះស្រាយជាបន្តបន្ទាប់៖ (i) ការកំណត់អត្តសញ្ញាណនៃក្រុមដែលត្រូវទទួលបានការការពារ (ខ្មែរក្រោម) និង (ii) ធាតុផ្សំនៃចេតនាជាក់លាក់។

*a. ការកំណត់អត្តសញ្ញាណនៃខ្មែរក្រោមថាជាក្រុមដែលត្រូវទទួលបានការការពារ*

185. មាត្រា ២ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ស្របគ្នានឹងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក ការពារក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ("ក្រុមដែលត្រូវទទួលបានការការពារ")[381]។ ចៅក្រមអន្តរជាតិសង្កេតឃើញថា ក្រុមដែលត្រូវទទួលបានការការពារទាំងបួន មិនត្រូវបានកំណត់នៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ឬច្បាប់ អ.វ.ត.ក ឡើយ និងគ្មាននិយមន័យដែលត្រូវបានទទួលយកជាទូទៅឡើយ[382]។ ក្នុងករណីពុំមាននិយមន័យបែបនេះ តុលាការ *មិនអចិន្ត្រៃយ៍*

---

[381] *អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍* ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ 78 U.N.T.S. 277 *ដែលបានចូលជាធរមាន* នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥១ ("អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍")។ អ.វ.ត.ក មានយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា II ("នៅក្នុងអនុសញ្ញាបច្ចុប្បន្ន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មានន័យថា ជាអំពើណាមួយក្នុងចំណោមអំពើទាំងឡាយខាងក្រោមនេះ ដែលប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុងក្តី ឬដោយផ្នែកក្តី ដល់ប្រជាជាតិមួយ ក្រុមជាតិពន្ធុមួយ ពូជសាសន៍មួយ ឬក្រុមសាសនាមួយ")។ *សូមមើលផងដែរ* ច្បាប់ អ.វ.ត.ក មាត្រា ៤ ("អំពើប្រល័យពូជសាសន៍ ដែលគ្មានអាជ្ញាយុកាល គឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោម ហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ")។ *សូមមើលសំណុំរឿងបន្ថែមទៀតពាក់ព័ន្ធនឹងការអនុវត្តនៃអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (រឿងក្តីប្រទេសបូស្នី និងហឺហ្ស៊ីហ្គោវី តទល់នឹងប្រទេសសៀបប៊ី និងម៉ុងតេណេហ្គ្រូ)* សាលក្រម របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ២០០៧ (ចុះថ្ងៃទី២៦ ខែកុម្ភៈ) ទំព័រ ៤៣ ("*ការអនុវត្តនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ (រឿងក្តីប្រទេសបូស្នី និងហឺហ្ស៊ីហ្គោវី តទល់នឹងប្រទេសសៀបប៊ី និងម៉ុងតេណេហ្គ្រូ)* (តុលាការយុត្តិធម៌អន្តរជាតិ)") កថាខណ្ឌ ១៩១។

[382] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា II ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៤។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Brđanin*, IT-99-36-T សាលក្រម ចៅក្រមអន្តរជាតិសាលាដំបូងទី II ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ ("សាលក្រមនៃរឿងក្តី *Brđanin* (តុលាការ ICTY)") កថាខណ្ឌ ៦៨២។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Kajelijeli*, ICTR-98-44A-T សាលក្រម និងការផ្តន្ទាទោស ចៅក្រមអន្តរជាតិសាលាដំបូងទី II ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣ ("សាលក្រមនៃរឿងក្តី *Kajelijeli* (តុលាការ ICTR)") កថាខណ្ឌ ៨១១។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Semanza*, ICTR-97-20-T សាលក្រម និងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូងទី III ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣

*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*

និងអ.វ.ត.ក បានទទួលស្គាល់ថា ក្រុមដែលត្រូវទទួលបានការការពារនីមួយៗ ចាំបាច់ត្រូវវាយតម្លៃដោយផ្អែកលើបរិបទជាក់លាក់នៃនយោបាយ សង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌[383] និងប្រើប្រាស់វិធីសាស្ត្រតាមករណីនីមួយៗ ដោយពិចារណាលើលក្ខណៈវិនិច្ឆ័យទាំងធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័តិ ក្នុងការវាយតម្លៃថាតើក្រុមជាក់លាក់មួយ នឹងទទួលបានការការពារដែរឬយ៉ាងណានោះ[384]។

186. ហេតុដូចនេះ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានកំណត់ (ឱ្យបានត្រឹមត្រូវ) ពីធាតុផ្សំគតិយុត្តិនៃអំពើប្រល័យពូជសាសន៍[385] ចៅក្រមអន្តរជាតិយល់ឃើញថា ការយោងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅនឹង "តេស្តទៅតាមករណីជាក់ស្តែង ដើម្បីកំណត់ថាជនរងគ្រោះ (ឬក្រុមដែលត្រូវបានកំណត់គោលដៅ) ស្ថិតនៅក្នុងក្រុមណាមួយដែលទទួលបានការការពារណាមួយ"[386] គឺត្រឹមត្រូវ និងស្របតាមយុត្តាធិការរបស់តុលាការ។ ទោះយ៉ាងណា ទោះបីលក្ខណៈវិនិច្ឆ័យអត្តនោម័តិ អាចត្រូវ

---

("សាលក្រមនៃរឿងក្តី *Semanza* (តុលាការ ICTR)") កថាខណ្ឌ ៣១៧។ សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ("សាលក្រមសំណុំរឿង ០០២/២ (ឯកសារ E465)") កថាខណ្ឌ ៧៩២។

[383] តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Kamuhanda*, ICTR-95-54A-T សាលក្រមសំណុំរឿង ចៅក្រមអន្តរជាតិសាលាដំបូងទី II ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ កថាខណ្ឌ ៦៣០។ សាលក្រមនៃរឿងក្តី *Kajelijeli* (តុលាការ ICTR) កថាខណ្ឌ ៨១១។ សាលក្រមនៃរឿងក្តី *Semanza* (តុលាការ ICTR) កថាខណ្ឌ ៣១៧។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង* Bagilishema, ICTR-95-1A-T សាលក្រម ចៅក្រមអន្តរជាតិសាលាដំបូងទី I ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៦៥។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Krstić*, IT-98-33-T សាលក្រម ចៅក្រមអន្តរជាតិសាលាដំបូង ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ ("សាលក្រមនៃរឿងក្តី *Krstić* (តុលាការ ICTY)") កថាខណ្ឌ ៥៥៧។ សាលក្រមសំណុំរឿង ០០២/២ ឯកសារ E465 កថាខណ្ឌ ៧៩២។

[384] តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Blagojević & Jokić*, IT-02-60-T សាលក្រម ចៅក្រមអន្តរជាតិសាលាដំបូងទី I (ផ្នែក ក) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ("សាលក្រមនៃរឿងក្តី *Blagojević & Jokić* (តុលាការ ICTY)") កថាខណ្ឌ ៦៦៧។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Gacumbtsi*, ICTR-2001-64-T សាលក្រម ចៅក្រមអន្តរជាតិសាលាដំបូងទី III ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៤ កថាខណ្ឌ ២៥៤។ សាលក្រមនៃរឿងក្តី *Brđanin* (តុលាការ ICTY) កថាខណ្ឌ ៦៨៥។ សាលក្រមនៃរឿងក្តី *Semanza* (តុលាការ ICTR) កថាខណ្ឌ ៣១៧ ។ សាលក្រមនៃរឿងក្តី *Kajelijeli* (តុលាការ ICTR) កថាខណ្ឌ ៨១១។ សាលក្រមសំណុំរឿង ០០២/២ ឯកសារ E465 កថាខណ្ឌ ៧៩២។

[385] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៦៥។

[386] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៦១-៦២។

បានពិចារណាក៏ដោយ[387] ក៏វិធីសាស្ត្រអត្តនោម័តិ*សុទ្ធសាធ* ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណនៃក្រុមដែលត្រូវទទួលបានការការពារ ត្រូវបានបដិសេធថាមិនគ្រប់គ្រាន់[388] ឬមិនស្របតាមកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដើម្បីការពារក្រុមដែលអត្ថិភាពស្ថិតស្ថេរ និងអចិន្ត្រៃយ៍[389]។

187. នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងទៅលើភាពចាំបាច់ ដើម្បីកំណត់ "លក្ខណៈសត្យានុម័តនៃបរិបទនយោបាយសង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌ដែលពាក់ព័ន្ធគ្នា"[390] និងក្នុងការកំណត់ខ្មែរក្រោមថាជា "ក្រុមជាតិពន្ធុ"[391]

---

[387] ដូចជាការមើលងាយដល់ក្រុមដែលត្រូវទទួលបានការការពារដោយផ្អែកលើចរិតលក្ខណៈជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ដោយចារី។ *សូមមើលឧទាហរណ៍* សាលក្រមនៃរឿងក្តី *Brđanin* (តុលាការ ICTY) កថាខណ្ឌ ៦៨៣។

[388] *សូមមើលឧទាហរណ៍* សាលក្រមនៃរឿងក្តី *Brđanin* (តុលាការ ICTY) កថាខណ្ឌ ៦៨៣-៦៨៤ ("ប្រការនេះគឺដោយសារលក្ខណៈវិនិច្ឆ័យនៃធាតុផ្សំអត្តនោម័តិតែមួយ អាចមិនគ្រប់គ្រាន់ដើម្បីកំណត់អត្តសញ្ញាណនៃក្រុម ដែលត្រូវបានកំណត់គោលដៅសម្រាប់ការបំផ្លិចបំផ្លាញ និងដែលត្រូវទទួលបានការការពារដោយអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដោយសារហេតុផលថា អំពើនានាដែលបានកំណត់នៅក្នុងកថាខណ្ឌកថាខណ្ឌ (ក) ដល់ (ង) នៃមាត្រា ៤(២) ជាការពិតត្រូវបានធ្វើឡើងប្រឆាំងនឹង"សមាជិកនៃក្រុមនេះ"")។

[389] *សូមមើលឧទាហរណ៍* សាលក្រមសំណុំរឿង ០០២/២ (ឯកសារ E465) កថាខណ្ឌ ៧៩៥ ("ចៅក្រមអន្តរជាតិសាលាដំបូងយល់ឃើញថា កត្តាទាំងនេះមានភាពពាក់ព័ន្ធ និងត្រូវយកមកប្រើនៅក្នុងការពិចារណា។ ទោះបីជាយ៉ាងណា ចៅក្រមអន្តរជាតិយល់ឃើញថា ធាតុផ្សំអត្តនោម័តិតែម្យ៉ាង មិនគ្រប់គ្រាន់នៅក្នុងការកំណត់សមាជិកភាពនៃក្រុមដែលត្រូវទទួលបានការការពារនោះឡើយ ហេតុដូច្នេះ ចៅក្រមអន្តរជាតិត្រូវពិនិត្យពិចារណាដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ទាំងសត្យានុម័ត និងអត្តនោម័តិ។ ការវិភាគផ្តោតលើលក្ខណៈវិនិច្ឆ័យសត្យានុម័ត ស្របតាមគោលបំណងនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ នៅក្នុងការការពារក្រុមដែលអត្ថិភាពស្ថិតស្ថេរ និងអចិន្ត្រៃយ៍")។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Musema*, ICTR-96-13-A, សាលក្រម និង ការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូងទី I ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ១៦២។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Rutaganda*, ICTR-96-3-T, សាលក្រម និងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូងទី I ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៥៧។

[390] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៦២ (ជើងទំព័រត្រូវបានលុបចោល) *ដែលយោងទៅ ជាអាទិ៍* សាលក្រមនៃរឿងក្តី *Semanza* (តុលាការ ICTR) កថាខណ្ឌ ៣១៧ ("អង្គជំនុំជម្រះសាលាដំបូងមួយចំនួននៃសាលាក្តីនេះបានរកឃើញថា ការកំណត់ថាតើក្រុមណាមួយស្ថិតនៅក្នុងដែននៃការការពារដែលត្រូវបានបង្កើតឡើងដោយមាត្រា ២ នៃលក្ខន្តិកៈនេះដែរឬយ៉ាងណានោះ គួរត្រូវបានវាយតម្លៃដោយផ្អែកលើករណីនីមួយៗ ដោយយោងទៅលើលក្ខណៈសត្យានុម័តនៃបរិបទសង្គម ឬប្រវត្តិសាស្ត្រ និងតាមរយៈទស្សនៈជាអត្តនោម័តិរបស់ចារី។ អង្គជំនុំជម្រះយល់ឃើញថា ការកំណត់ពីក្រុមដែលត្រូវទទួលបាន

ចង្អុលបង្ហាញពីកត្តាមួយចំនួនដូចជា សំនៀងនិយាយដោយឡែក សម្បុរសជ្រះ នាមត្រកូល និងប្រពៃណីរបស់ពួកគេ[392]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិសំដៅទៅលើ បរិបទសត្យានុម័ត សង្គម និងប្រវត្តិសាស្ត្រ ដែលអត្តសញ្ញាណរបស់ខ្មែរក្រោមបានលេចចេញជា រូបរាង ដោយពន្យល់*ជាអាទិ៍* ថា "ខ្មែរក្រោម ដែលមានដើមកំណើតពីជនជាតិខ្មែររស់នៅ កម្ពុជា ក្រោម តាំងពីសម័យអាណាចក្រខ្មែរ ហើយអត្តសញ្ញាណដោយឡែករបស់ពួកគេ បានលេច ចេញជារូបរាងនៅក្រោយពេលដែលតំបន់នេះស្ថិតក្រោមការត្រួតត្រា និងឥទ្ធិពលកាន់តែ ខ្លាំង របស់វៀតណាម"[393]។ បរិបទសង្គមប្រវត្តិសាស្ត្រនេះ ដោយរួមទាំងគោលនយោបាយគាបសង្កត់ របស់អាជ្ញាធរវៀតណាមខាងត្បូងប្រឆាំងនឹងខ្មែរក្រោម ដែលបានបង្ខំឲ្យពួកគេចូលទៅក្នុង សង្គមវៀតណាម ពន្យល់ពីភាពដាច់ដោយឡែកជាសត្យានុម័ត និងតាមការសន្មតរបស់ខ្មែរក្រោមពី ក្រុមដទៃទៀត[394]។

188. ក្រៅពីកត្តាសត្យានុម័តទាំងនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាលើ "ការ យល់ឃើញជាអត្តនោម័តិរបស់ជនរងគ្រោះ និងចារី"[395] ហេតុដូច្នេះ បានពឹងផ្អែកលើការកំណត់ អត្តសញ្ញាណផ្ទាល់ខ្លួនរបស់ខ្មែរក្រោម ដោយផ្អែកលើខ្សែស្រឡាយរបស់ពួកគេ[396] និងទស្សនៈ របស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការចាត់ទុកអត្តសញ្ញាណខ្មែរក្រោមថា ជាលក្ខណៈតំណពូជ

---

ការការពារ ត្រូវធ្វើឡើងដោយផ្អែកលើករណីនីមួយៗ ដោយពិចារណាទាំងលក្ខណៈវិនិច្ឆ័យធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័តិ") (ជើងទំព័រត្រូវបានលុបចោល)។ សាលក្រមនៃរឿងក្តី *Krstić* (តុលាការ ICTY) កថាខណ្ឌ ៥៥៧។

[391] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៨៧, ១០០៨-១០០៩ (ដែលនិយាយសំដៅដល់ខ្មែរក្រោមថាជា "ជនជាតិដើមភាគតិច" "ក្រុមជាតិពន្ធុ" និងបញ្ជាក់ថា "ខ្មែរក្រោមត្រូវបានកំណត់គោលដៅសម្រាប់កម្ទេចដោយសារឋានៈនៃជាតិពន្ធុរបស់ពួកគេ [...] និងថា ជាតិពន្ធុរបស់ពួកគេបានញ៉ាំងឲ្យមានការសន្មតមួយដែលមិនអាចកែប្រែបានថា ពួកគាត់គឺជាខ្មាំង" (សេចក្តីបញ្ជាក់បន្ថែម))។

[392] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៨៧,១៩៦, ២៦៧។

[393] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៨៧, ១៩៤-១៩៥។

[394] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៨៩-១៩១។

[395] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៦២។

[396] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៨៨។

ពិសេស និងចាត់ទុកថាមានភាពប្រហាក់ប្រហែលគ្នាផ្នែកជាតិសាសន៍ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយវៀតណាម[397]។

189. ដោយពិចារណាទៅលើការរៀបរាប់ខាងលើនេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសឡើយ ក្នុងការកំណត់អត្តសញ្ញាណខ្មែរក្រោមថាជាក្រុមដែលត្រូវទទួលបានការការពារស្ថិតក្រោមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដោយសារគាត់បានពឹងផ្អែកទាំងលើលក្ខណៈវិនិច្ឆ័យសត្យានុម័ត និងអត្តនោម័តិ[398]។ ទោះជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកយ៉ាងខ្លាំងលើលក្ខណៈវិនិច្ឆ័យអត្តនោម័ត ដូចជាការយល់ឃើញរបស់ ប.ក.ក ទៅលើខ្មែរក្រោមក្តី[399] ក៏ចៅក្រមអន្តរជាតិចាត់ទុកថា ការណ៍នេះមានភាពស្របគ្នាជាមួយនឹងវិធីសាស្ត្រ តាមករណីនីមួយៗដែលត្រូវបានទទួលស្គាល់។

190. ការចោទប្រកាន់ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានខកខានមិនបានកំណត់លក្ខខណ្ឌតម្រូវផ្លូវច្បាប់ *ជាអាទិ៍* "ដែលវាពុំសមស្របឡើយក្នុងការកំណត់តាមផ្លូវច្បាប់ក្នុងលក្ខខណ្ឌទូទៅ

---

[397] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៩៦។

[398] ចៅក្រមអន្តរជាតិសង្កេតឃើញថា ក្រៅពី "លក្ខណៈពិសេសជាតិពន្ធុ" សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏សំដៅផងដែរដល់អ្វីដែលអាចត្រូវបានចាត់ទុកថាជាលក្ខណៈពិសេស "ជនជាតិ" និង "ជាតិសាសន៍" ប៉ុន្តែអង្គបុរេជំនុំជម្រះយល់ឃើញថា វាមិនត្រូវបានតម្រូវឱ្យមានការបញ្ជាក់ពិសេសអំពីក្រុមដែលត្រូវទទួលបានការការពារផ្សេងៗនោះទេ។ *សូមមើល សាលក្រមនៃរឿងក្តី* *Brđanin* (តុលាការ ICTY) កថាខណ្ឌ ៦៨២ *ដែលយោងតាម សាលក្រមនៃរឿងក្តី* *Krstić* (តុលាការ ICTY) កថាខណ្ឌ ៥៥៦ ("ការងាររៀបចំអនុសញ្ញាបង្ហាញថា ការបង្កើតបញ្ជីបែបនេះត្រូវបានធ្វើឡើងកាន់តែច្រើន ដើម្បីពិពណ៌នាអំពីបាតុភូតតែមួយគត់ ដែលប្រហែលជាឆ្លើយតបទៅនឹងអ្វីដែលត្រូវបានទទួលស្គាល់ថាជា "ជនជាតិភាគតិច" មុនសង្គ្រាមលោកលើកទីពីរ ជាជាងសំដៅលើប្រភេទក្រុមមនុស្សផ្សេងៗមួយចំនួន។ ដើម្បីព្យាយាមបែងចែកឱ្យខុសគ្នានូវក្រុមដែលមានឈ្មោះនីមួយដោយឈរលើលក្ខណៈវិនិច្ឆ័យសត្យានុម័តបែបវិទ្យាសាស្ត្រ នឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលដៅ និងគោលបំណងរបស់អនុសញ្ញានេះ:")។

[399] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៩៦-២០០ ("ជាទូទៅ បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថា អត្តសញ្ញាណខ្មែរក្រោមជាលក្ខណៈតំណរពូជពិសេសដែលអាចបន្តពីឪពុកម្តាយទៅកូន [...] បក្សកុម្មុយនីស្តកម្ពុជា ហាក់ដូចជាចាត់ទុកថា ខ្មែរក្រោមគឺជាវៀតណាម ឬយ៉ាងហោចណាស់ក៏ជាក្រុមពិសេសមួយដែលមានភាពប្រហែលគ្នាខាងជាតិសាសន៍ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយវៀតណាម [...] បក្សកុម្មុយនីស្តកម្ពុជា ចាត់ទុកថា ខ្មែរក្រោមមានចិត្តគំនិតជាវៀតណាម តាមរយៈភ័ស្តុតាងនៃការប្រើប្រាស់ឃ្លាដូចជា *"ក្បាលយួន ខ្លួនខ្មែរ"* *"ខ្លួនក្បាលយួន"* [...] ដោយសារតែត្រូវបានគេមើលឃើញថា ដូចគ្នា ឬប្រហាក់ប្រហែលនឹងជនជាតិវៀតណាម ទើបខ្មែរក្រោមត្រូវទទួលរងគោលនយោបាយប្រឆាំងជនជាតិវៀតណាមរបស់បក្សកុម្មុយនីស្តកម្ពុជា")។

ថាជា "ក្រុមជាតិពន្ធ" តែមួយ" ដែលក្រុមពហុជាតិសាស្ត្រ និងក្រុមជាតិពន្ធត្រូវបានកំណត់គោលដៅ (ឧទាហរណ៍ បែបអវិជ្ជមាន) នោះ[400] ធ្វើឡើងដោយគ្មានមូលដ្ឋានឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ក្រុមដែលត្រូវបានកំណត់គោលដៅ មិនអាចត្រូវបានកំណត់តាមបែបអវិជ្ជមាននោះទេ និងថា នៅទីណាដែលមានក្រុមលើសពីមួយត្រូវបានកំណត់គោលដៅ ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ត្រូវបំពេញបានចំពោះក្រុមនីមួយៗ[401]។

191. ជាចុងក្រោយ ទាក់ទងនឹងការខកខានដែលត្រូវបានចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការកំណត់អង្គហេតុសំខាន់ៗ និងភស្តុតាងជាមូលដ្ឋាននៃស្ថានភាពរបស់ខ្មែរក្រោមថាជាក្រុមដែលត្រូវទទួលបានការការពារ[402] ចៅក្រមអន្តរជាតិជាដំបូងសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកលើសាក្សី និងឯកសារភស្តុតាងក្នុងសំអាងហេតុរបស់គាត់អំពីអត្តសញ្ញាណខ្មែរក្រោម ប្រវត្តិសាស្ត្រ និងគោលនយោបាយរបស់ ប.ក.ក ចំពោះខ្មែរក្រោម[403] និងថា "ការសន្និដ្ឋានលើអង្គច្បាប់" អំពីអំពើប្រល័យពូជសាសន៍ចំពោះខ្មែរក្រោមមានមូលដ្ឋានលើការសន្និដ្ឋានលើអង្គហេតុនៅពាសពេញដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ[404]។ ទីពីរ ដូចដែលបានបង្ហាញជូន សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំណត់អត្តសញ្ញាណតាមបែបវិជ្ជមានចំពោះខ្មែរក្រោមតាមរយៈលក្ខណៈពិសេសរបស់ពួកគេ និងការយល់ឃើញអំពីភាព

---

[400] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៦៧-៦៨ និងជើងទំព័រ ១៥០ *ដែលយោងតាម* តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Stakić*, IT-97-24-T សាលក្រម ចៅក្រមអន្តរជាតិសាលាដំបូងទី II ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៥១២។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Stakić*, IT-97-24-A, សាលក្រម អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ ("សាលដីកានៃរឿងក្តី Stakić (តុលាការ ICTY") កថាខណ្ឌ ១៩ ("ជាទីដែលក្រុមលើសពីមួយត្រូវបានកំណត់គោលដៅ [...] វាមិនសាកសមនោះទេក្នុងការកំណត់ក្រុមនេះជាទូទៅថាជា ឧទាហរណ៍ "ក្រុមមិនមែនជនជាតិស៊ែប")។

[401] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៦៣។

[402] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៦៦-៧១។

[403] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៨៦-២០៣ (ដែលយោងតាមកំណត់ហេតុនៃការស្តាប់ចម្លើយ និងសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល សៀវភៅ សេចក្តីណែនាំ និងឯកសាររបស់ ប.ក.ក និងការបោះពុម្ពផ្សាយរបស់ ក.ប.ធ)។

[404] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០០៨-១០១២។

ប្រហាក់ប្រហែលគ្នាផ្អែកជាតិសាសន៍ទៅនឹងវៀតណាម ជាជាងពឹងផ្អែកលើនិយមន័យបែប អវិជ្ជមាន (ដូចជាមិនមែនជាខ្មែរ)។

b. *ចេតនាជាក់លាក់*

192. *ធាតុផ្សំអត្តនោម័តិ* នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជា "គោលបំណងបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ដូចជា"[405]។ ដោយសំដៅថាជា ចេតនាជាក់លាក់ ឬ *ចេតនាពិសេស* អំពើជាក់លាក់ដែលមានចែងនៅក្នុងមាត្រា II នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងមាត្រា ៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវតែប្រព្រឹត្តជាមួយនឹងចេតនាជាក់លាក់ ដើម្បីបំផ្លិចបំផ្លាញក្រុមដែលទទួលបានការការពារទាំងស្រុង ឬមួយផ្នែក ដូចជា[406]។ ការប្រើប្រាស់ពាក្យថា "ដូចជា" បង្ហាញថា ការកំណត់គោលដៅលើជនរងគ្រោះដោយផ្អែកលើសមាជិកភាពរបស់ក្រុមតែមួយមុខ (ចេតនារើសអើង) មិនគ្រប់គ្រាន់ឡើយ[407]។ ផ្ទុយទៅវិញ ចេតនាបំផ្លិចបំផ្លាញក្រុមដែលត្រូវទទួលបានការការពារដែលជាអង្គភាពដាច់ដោយឡែក ត្រូវតែមាន[408]។

---

[405] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា II។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៤។

[406] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា II។ ច្បាប់ស្តីពី អ.វ.ត.ក មាត្រា ៤។ ការអនុវត្តអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ (បូស្និនិងហឺសេហ្គោវីន តទល់នឹង ស៊ែប៊ីនិងម៉ុងតេណេហ្គ្រូ) (តុលាការ ICJ) កថាខណ្ឌ ១៨៧។ *ការអនុវត្តអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (ក្រូអាស៊ី តទល់នឹង ស៊ែប៊ី)* សាលក្រម របាយការណ៍ I.C.J ឆ្នាំ២០១៥ (ថ្ងៃទី៣ ខែកុម្ភៈ) ទំព័រ៣ កថាខណ្ឌ ១៣២។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Akayesu*, ICTR- 96-4-T, សាលក្រម ចៅក្រមអន្តរជាតិសាលាដំបូងទី I ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ ("សាលក្រមនៃរឿងក្តី *Akayesu* (តុលាការ ICTR) ") កថាខណ្ឌ ៤៩៧-៤៩៨។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Karadžić*, IT-95-5/18-T, សាធារណៈសំណៅកោសលុបនៃសាលក្រមដែលចេញផ្សាយថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ចៅក្រមអន្តរជាតិសាលាដំបូង ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១៦ (សាលក្រមនៃរឿងក្តី *Karadžić* (តុលាការ ICTY) កថាខណ្ឌ ៥៤៩។ សាលក្រមសំណុំរឿង ០០២/០២ ឯកសារ E465 កថាខណ្ឌ ៧៩៧។

[407] ការអនុវត្តអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ (រឿងក្តីប្រទេសបូស្និ និងហឺហ្ស៊ីហ្គោវី តទល់នឹងប្រទេសស៊ៀបប៊ី និងម៉ុងតេណេហ្គ្រូ) (តុលាការ ICJ) កថាខណ្ឌ ១៨៧ សាលក្រមសំណុំរឿង ០០២/០២ ឯកសារ E465 កថាខណ្ឌ ៧៩៧-៧៩៨។ សាលដីការឿងក្តី Stakić (តុលាការ ICTY) កថាខណ្ឌ ១៩។

[408] សាលក្រមនៃរឿងក្តី *Blagojević & Jokić* (តុលាការ ICTY) កថាខណ្ឌ ៦៦៩-៦៧០។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Krajišnik*, IT-00-39-T, សាលក្រម ចៅក្រមអន្តរជាតិសាលាដំបូងទី I ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ ៨៥៦។

01677162



193. ទីមួយ ទាក់ទងនឹងធាតុផ្សំគតិយុត្តិ ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំណត់អំពើប្រល័យពូជសាសន៍ថាជា "ការប្រព្រឹត្តអំពើណាមួយដែលមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក ក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិសាសន៍ ជាតិពិន្ទុ ពូជសាសន៍ ឬសាសនា ជាពិសេស ដែលត្រូវបានកំណត់គោលដៅ ដូចជា"[409] និងថា "ក្រៅពីមាន *ធាតុផ្សំអត្តនោម័ត* ដូចទាមទារ ពាក់ព័ន្ធនឹងអំពើពាក់ព័ន្ធជាក់លាក់ [...] ចារីត្រូវមានចេតនាជាក់លាក់ក្នុងការបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែក *ចំពោះក្រុមពាក់ព័ន្ធដែលទទួលបានការការពារ ដូចជា* "[410]។

194. ទាក់ទងនឹងអត្ថន័យនៃពាក្យ "ដូចជា" សហចៅក្រមស៊ើបអង្កេតអន្តរជាតិបញ្ជាក់ថា ការប្រើពាក្យនេះបង្ហាញថា ជនរងគ្រោះចុងក្រោយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាក្រុមមួយ និងថា ដូច្នេះអំពើជាក់លាក់ត្រូវប្រព្រឹត្តក្នុងចេតនាបំផ្លិចបំផ្លាញក្រុមនេះ ដែលជាអង្គភាពដាច់ដោយឡែកពីជនរងគ្រោះ[411]។ ដោយសារតែ "ជនរងគ្រោះត្រូវបានកំណត់គោលដៅដោយសារពួកគេគឺជាសមាជិកនៃក្រុម [...] ការដឹងឮពីសមាជិកភាពតែមួយពុំគ្រប់គ្រាន់នោះទេ"[412]។ អាស្រ័យហេតុនេះ ការចោទប្រកាន់របស់សហមេធាវី ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានខកខានក្នុងញែកចេញនូវ*ធាតុផ្សំអត្តនោម័តិ* នៃការធ្វើទុក្ខបុកម្នេញពីចេតនាជាក់លាក់ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់អំពើប្រល័យពូជសាសន៍ ឬខកខានមិនបានលើកឡើងពីលក្ខខណ្ឌតម្រូវនៃពាក្យ "ដូចជា" គឺពុំមានមូលដ្ឋានឡើយ[413]។

---

តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Tolimir*, IT-05-88/2-T, សាលក្រម ចៅក្រមអន្តរជាតិសាលាដំបូងទី II ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ កថាខណ្ឌ ៧៤៧។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* IT-05-88-T, សាលក្រម ចៅក្រមអន្តរជាតិសាលាដំបូងទី II ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០។ ("សាលក្រមនៃរឿងក្តី Popović *និងអ្នកផ្សេងទៀត* (តុលាការ ICTY)") កថាខណ្ឌ ៨២១។ សាលក្រមនៃរឿងក្តី Akayesu (តុលាការ ICTR) កថាខណ្ឌ ៥២១។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Niyitegeka*, ICTR-96-14-A, សាលក្រម ចៅក្រមអន្តរជាតិតុលាការកំពូល ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៥៣។

[409] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៥៩ (សេចក្តីបញ្ជាក់បន្ថែម)។

[410] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៦៨ (សេចក្តីបញ្ជាក់បន្ថែម)។

[411] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៧២។

[412] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៧២។

[413] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៧២-៧៥។

195. ទីពីរ ទាក់ទងនឹងការចោទប្រកាន់អំពីការខកខានមិនបានកំណត់ពីអង្គហេតុសំខាន់ៗ និងភស្តុតាងជាមូលដ្ឋាន តាមរយៈការខកខានមិនបានញែកចេញពីគ្នារវាងអង្គហេតុដែលទាក់ទងនឹង យឹម ទិត្យ និងអង្គហេតុដែលពាក់ព័ន្ធនឹងគោលនយោបាយរបស់ ប.ក.ក[414] ចៅក្រមអន្តរជាតិសង្កេតឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ សំដៅលើផែនការទូទាំងប្រទេសក្នុងការ "កម្ទេចក្រុមជាតិពន្ធុឱ្យផុតពូជខ្មែរក្រោម ឬយ៉ាងហោចណាស់ក៏មួយផ្នែកធំនៃពួកគេ ដោយសារជាតិពន្ធុរបស់ពួកគេ"[415]។ អំណះអំណាងនេះត្រូវបានគាំទ្រ *ជាអាទិ៍* ដោយការរកឃើញក្នុងផ្នែកភស្តុតាងនៅក្នុងផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានចំណងជើងថា "គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាទៅលើខ្មែរក្រោម"[416] ដោយរួមបញ្ចូលទាំងការប្រើប្រាស់ជាទូទៅនៃពាក្យពេចន៍ប្រមាថមើលងាយរបស់ ប.ក.ក ដូចជា *"ក្បាលយួន ខ្លួនខ្មែរ"*[417] និង ប.ក.ក បានចាត់ទុកខ្មែរក្រោមថាជាក្រុមមួយ ដែលគួរឱ្យសង្ស័យខ្លាំង ជាគិញ្ចរបស់វៀតណាម និងឆាប់ចូលរួមការបះបោរ[418]។

196. នៅក្នុងផ្នែកដាច់ដោយឡែកមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានចំណងជើងថា "ការប្រព្រឹត្ត និងការចូលរួមចំណែករបស់ យឹម ទិត្យ ទៅក្នុងសហឧក្រិដ្ឋកម្មរួម ដែលប៉ុនប៉ងលុបបំបាត់ប្រជាជនខ្មែរក្រោម"[419] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានញែកចេញពីគ្នាយ៉ាងច្បាស់លាស់រវាងអង្គហេតុទាក់ទងទៅនឹងគោលនយោបាយរបស់ ប.ក.ក ជាទូទៅ និងសំអាងហេតុដែលទាក់ទងទៅនឹងសកម្មភាព និងការប្រព្រឹត្តរបស់ យឹម ទិត្យ។ ជាក់ស្តែង សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា "ពាក្យសម្តីរបស់ យឹម ទិត្យ បង្ហាញនូវការស្អប់ខ្ពើមយ៉ាងខ្លាំងក្លាចំពោះប្រជាជនវៀតណាម ដោយរួមបញ្ចូលទាំងអ្នកដែលមានដើមកំណើតជាជនជាតិវៀតណាម

---

[414] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៧៦-៧៨។

[415] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០០៨។

[416] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៨០-៨៥។

[417] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៨៦ *ដែលយោងទៅ* ភស្តុតាងរបស់ វ៉ឺន ដារ៉ា។

[418] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៩៨ *ដែលយោងទៅ ជាអាទិ៍* ភស្តុតាងរបស់ វៀល សន, ផាន់ សាវ៉ាយ, រៀម ឌី។

[419] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៩២-១៩៥។

01677164



ឬអាចមានទំនាក់ទំនងជាមួយជនជាតិវៀតណាម ដូចជាប្រជាជនខ្មែរក្រោមជាដើម"[420]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យោងដល់សេចក្តីថ្លែងការណ៍ដែល យឹម ទិត្យ បានធ្វើនៅក្នុងកិច្ចប្រជុំ[421] រួមទាំងការនិយាយសំដៅដល់ *"យួនខ្មែរ"*[422] *"វៀយួន"* *"ខ្មាំងផ្ទៃក្នុង"*[423] និងភាពចាំបាច់ក្នុងការសម្លាប់អ្នកដែលជាប់ពាក់ព័ន្ធនឹងវៀតណាម[424]។

197. លើសពីនេះទៅទៀត មានការទទួលយកជាទូទៅថា ក្នុងការវាយតម្លៃលើភស្តុតាងនៃចេតនាក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ អង្គជំនុំជម្រះត្រូវពិចារណាទៅលើថាតើ "ភស្តុតាងទាំងអស់រួមគ្នាអាចបង្ហាញពីស្ថានភាពផ្លូវចិត្តនៅក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែរឬទេ"[425]។ ក្នុងករណីដែលគ្មានភស្តុតាងផ្ទាល់ ចេតនាក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ អាចត្រូវបានទាញការសន្និដ្ឋានចេញពីអង្គហេតុ និងកាលៈទេសៈនៃឧក្រិដ្ឋកម្ម ដូចជា បរិបទទូទៅ ទំហំនៃអំពើឃោរឃៅការប្រព្រឹត្តអំពើខុសឆ្គងផ្សេងទៀត ដែលផ្តោតជាប្រព័ន្ធប្រឆាំងនឹងក្រុមដូចគ្នា ការកំណត់គោលដៅជាប្រព័ន្ធលើជនរងគ្រោះ ដោយផ្អែកលើសមាជិកភាពរបស់ពួកគេក្នុងក្រុមជាក់លាក់ ការអនុវត្តដដែលៗនូវអំពើបំផ្លិចបំផ្លាញ និងរើសអើង អត្ថិភាពនៃផែនការ ឬគោលនយោបាយ ឬការបង្ហាញចេតនាតាមរយៈសុន្ទរកថាជាសាធារណៈ ឬនៅក្នុងកិច្ចប្រជុំ[426]។ ប្រការនេះ យកឈ្នះលើការ

---

[420] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៨៧។

[421] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៨៨-៣៨៧។

[422] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៩០ *ដែលយោងទៅ* ភស្តុតាងរបស់ យូ ភ្នំ។

[423] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៩៤ *ដែលយោងទៅ* ភស្តុតាងរបស់ វី ផាន់។

[424] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៩៧ *ដែលយោងទៅ* ភស្តុតាងរបស់ ឈឹង ឈឿត។

[425] សាលដីកានៃរឿងក្តី *Karadžić* (តុលាការ ICTY) កថាខណ្ឌ ៥៥០។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Tolimir*, IT-05-88/2-A, សាលដីកា ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ ("សាលដីកានៃរឿងក្តី *Tolimir* (តុលាការICTY)") កថាខណ្ឌ ២៤៧។ Popović និងអ្នកផ្សេងទៀត សាលក្រម (តុលាការ ICTY) កថាខណ្ឌ ៨២០។

[426] តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* IT-05-88-A, សាលដីកា ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៤៦៨។ សាលក្រមនៃរឿងក្តី *Karadžić* (តុលាការ ICTY) កថាខណ្ឌ ៥៥០។ សាលដីកានៃរឿងក្តី *Tolimir* (តុលាការ ICTY) កថាខណ្ឌ ២៤៦។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Jelisić*, IT-95-10-A, សាលដីកា ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ ៤៧។ តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Munyakazi*, ICTR-97-36A-A, សាលដីកា ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៤២។ សាលក្រមនៃរឿងក្តី *Akayesu* (តុលាការ ICTR) កថាខណ្ឌ ៥២៣។ ***សូមមើលផងដែរ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

01677165



អះអាងរបស់សហមេធាវី ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយខកខាន មិនបានលើកឡើងពី "ភ័ស្តុតាងដោយផ្ទាល់ណាមួយ ដែលថា យឹម ទិត្យ មានចេតនាជាក់លាក់"[427]។

198. ក្រៅពីភ័ស្តុតាងនៃសុន្ទរកថាប្រមាថមើលងាយរបស់ យឹម ទិត្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ឃើញថា សេចក្តីថ្លែងការណ៍របស់ យឹម ទិត្យ ស្របគ្នាទាំងពេលវេលា និងភូមិសាស្ត្រទៅនឹងការសម្លាប់ជាទ្រង់ទ្រាយធំចំពោះប្រជាជនខ្មែរក្រោមរាប់រយនាក់នៅឃុំគោកព្រេច ពីចុងឆ្នាំ១៩៧៧ រហូតដល់ដើមឆ្នាំ១៩៧៨ និងនិយាយសំដៅដល់ការចុះទៅពិនិត្យមន្ទីរសន្តិសុខវត្តព្រះធាតុរបស់ យឹម ទិត្យ ជាកន្លែងដែលខ្មែរក្រោមត្រូវបានឃុំខ្លួន និងក្រោយមកសម្លាប់ និងជាកន្លែងដែលគាត់បានសួរចម្លើយ និងកំណត់អត្តសញ្ញាណអ្នកទោសថាជាខ្មាំង[428]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា យឹម ទិត្យ បានដឹងពីសកម្មភាពរបស់ ប.ក.ក ទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ តាមរយៈការប្រជុំ និងប្រព័ន្ធនៃការទំនាក់ទំនង និងការរាយការណ៍ ហើយគាត់គឺជាមនុស្សសំខាន់ម្នាក់ក្នុងចំណោមអ្នកដែលទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក នៅក្នុងតំបន់ដែលគាត់ទទួលខុសត្រូវ[429]។ លើសពីនេះទៀតការកំណត់គោលដៅជាប្រព័ន្ធទៅលើខ្មែរក្រោមនៅក្នុងតំបន់ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ[430] ការចងក្រងកំណត់ត្រាដែលកំណត់អត្តសញ្ញាណខ្មែរក្រោម[431] ការសម្លាប់ខ្មែរក្រោមជាទ្រង់ទ្រាយធំ[432] ការជម្លៀសខ្មែរក្រោមដោយបង្ខំ[433] និងគោលនយោបាយរបស់ ប.ក.ក ក្នុងការកំណត់គោលដៅលើខ្មែរក្រោម (រួមទាំងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ យឹម

---

*ការអនុវត្តអនុសញ្ញាស្តីពីអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (រឿងក្តីប្រទេសបូស្នី និងហឺហ្ស៊ីហ្គោវី តទល់នឹងប្រទេសសៀបប៊ី និងម៉ុងតេណេហ្ក្រូ)* (តុលាការយុត្តិធម៌អន្តរជាតិ) កថាខណ្ឌ ២៤២។

[427] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៧៨។

[428] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៩២។

[429] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០១៩។

[430] *សូមមើល ឧទាហរណ៍* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២១០, ២៤៣, ២៤៦, ២៥៨-២៦៥។

[431] *សូមមើល ឧទាហរណ៍* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២១០, ២៤៧-២៤៨, ២៦៧។

[432] *សូមមើល ឧទាហរណ៍* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២១២, ២៥០-២៥៦, ២៥៨-២៦០។

[433] *សូមមើល ឧទាហរណ៍* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២២២-២៣៤, ២៤៤-២៤៥, ២៤៩។

ទិត្យ)[434] គឺជាអង្គហេតុ និងកាលៈទេសៈទាំងអស់ ដែលគាំទ្រដល់សេចក្តីសន្និដ្ឋានចុងក្រោយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ មានចេតនាជាក់លាក់ដើម្បីបំផ្លិចបំផ្លាញខ្មែរក្រោម[435]។

199. សរុបសេចក្តីមក អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសក្នុងការកំណត់ពីធាតុផ្សំគតិយុត្តិនៃអំពើប្រល័យពូជសាសន៍ អង្គហេតុសំខាន់ៗ និងភ័ស្តុតាងជាមូលដ្ឋាននោះឡើយ។ អាស្រ័យហេតុនេះ សម្រេចបដិសេធមូលដ្ឋានទី ២.២។

## B. មូលដ្ឋានទី ៣ ៖ ការចោទប្រកាន់អំពីការពង្រីកវិសាលភាពអង្គហេតុនៃកិច្ចស៊ើបសួរ

### ១. សារណា

200. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ ដោយសារបានពង្រីកវិសាលភាពអង្គហេតុនៃកិច្ចស៊ើបសួរ[436]។ ទីមួយ សហមេធាវីអះអាងថា វិធាន ៥៥(២) នៃវិធានផ្ទៃក្នុង កម្រិតកិច្ចស៊ើបសួរត្រឹមតែអង្គហេតុដែលខ្លួនទទួលវិនិច្ឆ័យ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមប៉ុណ្ណោះ[437]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេត ពុំមានយុត្តាធិការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះនូវអង្គហេតុទាំងឡាយណានៅក្រៅកិច្ចស៊ើបសួរនោះឡើយ ដោយមានអញ្ញត្រកម្មតែមួយគត់ពាក់ព័ន្ធនឹងស្ថានទម្ងន់ទោសក្រោមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង[438]។ ទីពីរ សហមេធាវីបញ្ជាក់ថា ដោយអនុលោមតាមវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង មានតែអង្គហេតុដែលត្រូវបានចោទប្រកាន់ជាមុនតែប៉ុណ្ណោះ ទើបអាចយកមកពិចារណាចោទប្រកាន់បញ្ជូនទៅជំនុំជម្រះបាន[439]។ ហេតុដូចនេះ ទោះបីជាដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវផ្អែកលើការចោទប្រកាន់ពីមុនក៏ដោយ ក៏

---

[434] *សូមមើល ឧទាហរណ៍* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២១៣។

[435] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០០៨-១០២៣។

[436] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៩៥។

[437] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៩៥។

[438] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៩៥។

[439] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៩៦។

វិសាលភាពនៃអង្គហេតុដែលអាចចោទប្រកាន់បាន នៅតែបន្តស្ថិតក្រោមការកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមផងដែរ[440]។

201. ដោយឈរលើមូលដ្ឋាននៃវិធានផ្ទៃក្នុងទាំងនេះ សហមេធាវីអះអាងថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពង្រីកហួសវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលច្បាប់អនុញ្ញាត។ សហមេធាវីលើកឡើងផងដែរថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កំណត់ព្រំដែនវិសាលភាពពេលវេលា និងភូមិសាស្ត្រនៃកិច្ចស៊ើបសួរ៖ (i) ការចោទប្រកាន់នៅក្នុងភូមិភាគនិរតីចាប់ពីឆ្នាំ១៩៧៦ រហូតដល់ដើមឆ្នាំ១៩៧៨ និង (ii) ការចោទប្រកាន់នៅក្នុងភូមិភាគពាយ័ព្យ ចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៧ រហូតដល់ខែមករា ឆ្នាំ១៩៧៩[441]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបកស្រាយមិនត្រឹមត្រូវលើវិធាន ៥៥(២) និងមានកំហុសដោយបានចោទប្រកាន់បញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានាដែលបានកើតឡើងនៅក្រៅព្រំដែនកំណត់ទាំងនេះ ពោលគឺផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវរបស់គាត់ក្នុងនាមជាសមាជិកនៃ៖ (i) សហឧក្រិដ្ឋកម្មរួម ខ និងសហឧក្រិដ្ឋកម្មរួម គ *នៅក្រោយ*ដើមឆ្នាំ១៩៧៨ នៅក្នុងភូមិភាគនិរតី (ii) សហឧក្រិដ្ឋកម្មរួម គ *នៅមុន* ដំណាច់ឆ្នាំ១៩៧៥ នៅមន្ទីរសន្តិសុខវត្តព្រះធាតុនៅក្នុងភូមិភាគនិរតី និង (iii) និងសហឧក្រិដ្ឋកម្មរួម ក *នៅមុន*ពាក់កណ្ដាលឆ្នាំ១៩៧៧ នៅក្នុងភូមិភាគពាយ័ព្យ[442]។

202. សហមេធាវីសន្និដ្ឋានថា កំហុសអង្គច្បាប់នេះមាន "ភាពអយុត្តិធម៌ និងមិនសមហេតុផលខ្លាំងដែលជាការបំពានឆន្ទានុសិទ្ធិ" និងបានស្នើឲ្យចៅក្រមអន្តរជាតិធ្វើមោឃភាពការចោទប្រកាន់ទាំងអស់ដែលពឹងផ្អែកលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ[443]។

---

440 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៩៦។

441 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៩៧-៩៨ *ដែលយោងតាម* ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ឯកសារ D1 កថាខណ្ឌ ៩៣-៩៥។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី១ របស់សហព្រះរាជអាជ្ញា ឯកសារ D65 កថាខណ្ឌ ១៣។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី២ របស់សហព្រះរាជអាជ្ញា ឯកសារ D191 កថាខណ្ឌ ៨។

442 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៩៩-១០៣។

443 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១០៣។

203. ជាការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា ទឡ្ហីករណ៍របស់សហមេធាវី គឺផ្អែកលើ ការយល់ខុសអំពីដែនកំណត់ផ្នែកអង្គហេតុនៃការស៊ើបអង្កេត និងខកខានមិនបានបង្ហាញពីកំហុសអង្គច្បាប់ដែលអាចពិនិត្យឡើងវិញបាន ឬជាការបំពាន[444]។ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា ចំណុចនេះមានភាពច្បាស់លាស់ពីការសម្រេចរបស់អង្គបុរេជំនុំជម្រះដែលថា "អង្គហេតុ" ដែលសហចៅក្រមស៊ើបអង្កេតបានទទួល ពាក់ព័ន្ធនឹងអំពើព្រហ្មទណ្ឌ និងថា "កាលៈទេសៈដែលគេចោទថា ឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង ហើយនាំដល់ការកំណត់បទចោទ មិនត្រូវបានគេយល់ឃើញថាជាអង្គហេតុថ្មី ហើយកាលៈទេសៈទាំងនេះជាផ្នែកមួយនៃការស៊ើបសួរ"[445]។

204. ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា បញ្ហាដ៏សំខាន់គឺថា តើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមត្រូវបានកម្រិតពេលវេលាដែរឬទេ។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ពុំមានការកម្រិតពេលវេលាបែបនេះទេ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ[446]។ ហេតុដូចនេះ នៅក្នុង ទស្សនៈរបស់គាត់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចចោទប្រកាន់ដោយត្រឹមត្រូវចំពោះ យឹម ទិត្យ ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងភូមិភាគនិរតីពេញរបបកម្ពុជាប្រជាធិបតេយ្យ និងឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យ ចាប់តាំងពីយ៉ាងហោចណាស់ដើមឆ្នាំ១៩៧៧ រហូតដល់ខែមករា ឆ្នាំ១៩៧៨[447]។

205. លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវីបានរួមបញ្ចូលគ្នាដោយមិនត្រឹមត្រូវរវាង "អង្គហេតុ" និងទម្រង់នៃការទទួលខុសត្រូវ ដោយនិយាយយោងដល់សហឧក្រិដ្ឋកម្មរួម ដែល យឹម ទិត្យ ត្រូវបានចោទប្រកាន់[448]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិលើក

[444] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៥៧-៥៨។

[445] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៥៨ *ដែលយោងតាម* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០១ ឯកសារ D99/3/42 កថាខណ្ឌ ៣៥។ វិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង។

[446] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៥៩។

[447] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៥៩។

[448] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៦០។

ឡើងថា ការចោទប្រកាន់របស់សហមេធាវី គឺមិនទាន់ពេលវេលា និងមិនមានមូលដ្ឋាន ពីព្រោះវិសាលភាពពេលវេលានៃសហឧក្រិដ្ឋកម្មរួមទាំងបីនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានលក្ខណៈដូចគ្នា ប្រសិនបើមិនចង្អៀតជាងអ្វី ដែលត្រូវបានចោទប្រកាន់នៅក្នុងកំណត់ហេតុបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ហើយចំណុចនេះអាចត្រូវបានតវ៉ា មុនពេលដែលសហមេធាវីបានលើកឡើងនូវទឡ្ហីករណ៍នេះនៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងដីកាសន្និដ្ឋានស្ថាពរ[449]។

## ២. ការពិភាក្សា

206. តាមមូលដ្ឋានទី ៣ សហមេធាវីអះអាងថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កំណត់ព្រំដែនវិសាលភាពវេលានៃកិច្ចស៊ើបសួរប្រឆាំងនឹង យឹម ទិត្យ ដូចខាងក្រោម[450]៖

(i) សម្រាប់ភូមិភាគនិរតី៖ ចាប់ពីឆ្នាំ១៩៧៦ រហូតដល់ដើមឆ្នាំ១៩៧៨ និង

(ii) សម្រាប់ភូមិភាគពាយ័ព្យ៖ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

207. ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានចោទប្រកាន់ យឹម ទិត្យ ពីបទឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួន តាមរយៈ *ជាអាទិ៍* ការទទួលខុសត្រូវផ្នែកសហឧក្រិដ្ឋកម្មរួម ដែលតាមរយៈបទចោទនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចឲ្យ យឹម ទិត្យ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាក់លាក់មួយចំនួននៅក្នុង*ភូមិភាគនិរតី* ក្នុងនាមជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម "យ៉ាងហោចណាស់ក៏ចាប់ពីខែកញ្ញា-តុលា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩"[451] និងសម្រាប់ឧក្រិដ្ឋកម្ម

---

[449] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៦០ *ដែលយោងទៅ* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ឯកសារ D281 ត្រង់ ERN 01178414-01178415។

[450] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ៩៧។

[451] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០១៦, ១០១៧។ *សូមមើល ឧទាហរណ៍* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៤០-៩៤២ (ដែលពិពណ៌នាពីការបង្កើតសហករណ៍ និងការចាប់ខ្លួននៅក្នុងស្រុកគិរីវង់ "ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦") កថាខណ្ឌ ៩៦២ (ការគណនានៃការសម្លាប់នៅមន្ទីរសន្តិសុខវត្តព្រះធាតុ "ចាប់តាំងពីឆ្នាំ១៩៧៥")។

ផ្សេងៗទៀត នៅក្នុង*ភូមិភាគពាយ័ព្យ* ក្នុងនាមជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមចាប់ពី "ដើមឆ្នាំ១៩៧៧ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" [452]។

208. ដូចដែលចៅក្រមអន្តរជាតិបានកត់សម្គាល់ពីមុនមក វិសាលភាពនៃកិច្ចស៊ើបសួរត្រូវបានគ្រប់គ្រងដោយការចោទប្រកាន់នានា ដូចមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[453]។ ដើម្បីកំណត់ថាតើការចោទប្រកាន់ពីបទព្រហ្មទណ្ឌនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរដែរឬយ៉ាងណានោះ ជាដំបូង អង្គបុរេជំនុំជម្រះចាំបាច់ត្រូវកំណត់អង្គហេតុ ដែលបានដាក់បញ្ចូលនៅក្នុងសំណុំរឿងទទួលបាន ដែលតម្រូវឱ្យអានយ៉ាងយកចិត្តទុកដាក់នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយចំនួន ដែលត្រូវបានដាក់នៅក្នុងសំណុំរឿង ០០៤។ ទីមួយ ចៅក្រមអន្តរជាតិពិនិត្យមើលការចោទប្រកាន់នានាដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម នៅ*ភូមិភាគនិរតី*។ ទីពីរ ចៅក្រមអន្តរជាតិនឹងវាយតម្លៃលើវិសាលភាពពេលវេលានៃការចោទប្រកាន់ទាក់ទងនឹងឧក្រិដ្ឋកម្មនៅ*ភូមិភាគពាយ័ព្យ*។

### a. *ឧក្រិដ្ឋកម្មនៅភូមិភាគនិរតី*

209. នៅក្នុងការអានជារួមនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ប្រឆាំងនឹង យឹម ទិត្យ ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងឧក្រិដ្ឋកម្មនៅភូមិភាគនិរតី លាតសន្ធឹងចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី ០៦ ខែមករា ឆ្នាំ១៩៧៩។ កថាខណ្ឌផ្តើមសេចក្តីនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ រួមនឹងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ដែលត្រូវបានលើកឡើងក្នុងកថាខណ្ឌ ៨០ ដល់ ៨១ នោះ

---

[452] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០១៦, ១០១៧។ *សូមមើល ឧទាហរណ៍* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៧១៨ (ដែលពិភាក្សាពីភស្តុតាងរបស់ យឹម ទិត្យ ដែលបានចុះទៅពិនិត្យមើលគុកមន្ទីរសន្តិសុខបាណន់ "ប្រហែលនៅឆ្នាំ១៩៧៧ ប្រហែលពីរខែមុនពេលកម្មាភិបាលភូមិភាគនិរតីបានទៅដល់")។

[453] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ឯកសារ D308/3/1/20 យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ១២៨។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០១ ឯកសារ D99/3/42 កថាខណ្ឌ ៣៥-៣៧។

និងជាពិសេស កថាខណ្ឌ ១០៩ នាំឱ្យចៅក្រមអន្តរជាតិឈានដល់ការសន្និដ្ឋានដូចនេះ[454]។ ជាលទ្ធផល ដោយសារការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌទាក់ទងនឹងមន្ទីរសន្តិសុខវត្តព្រះធាតុ មិនត្រូវបានកំណត់ពេលវេលាតឹងរ៉ឹង ដូច្នេះការចោទប្រកាន់ទាំងនោះ ជាប់ទាក់ទងទៅនឹងក្របខណ្ឌទូទៅ ដូចមានចែងនៅក្នុងកថាខណ្ឌ ១០៩[455]។

210. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់លោក យឹម ទិត្យ ពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្ត នៅមន្ទីរសន្តិសុខវត្តព្រះធាតុ តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ដែលបានកើតឡើង "យ៉ាងហោចណាស់ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨"[456]។

211. ចៅក្រមអន្តរជាតិសន្និដ្ឋានថា ទាក់ទងនឹងឧក្រិដ្ឋកម្មនៅភូមិភាគនិរតី វិសាលភាពពេលវេលានៃកិច្ចស៊ើបសួរ ប្រឆាំងនឹង យឹម ទិត្យ គឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩។ ដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា សំណើរបស់សហមេធាវីសុំឱ្យធ្វើមោឃភាពនៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រាប់ឧក្រិដ្ឋកម្មនៅភូមិភាគនិរតី ដែល (i) នៅក្រោយ "ដើមឆ្នាំ១៩៧៨" និង (ii) នៅមុនខែមករា "ឆ្នាំ១៩៧៦" គួរត្រូវបានបដិសេធ។

### *b. ឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យ*

212. ទាក់ទងទៅនឹងឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យ អង្គបុរេជំនុំជម្រះយល់ឃើញថា ផ្អែកលើការអានជារួម ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម អាចត្រូវបានចាត់ទុកថាជាការចោទប្រកាន់ពីបទព្រហ្មទណ្ឌផងដែរ នៅដើមឆ្នាំ១៩៧៧ (និងមិនគ្រាន់តែនៅ

---

[454] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ឯកសារ D1 កថាខណ្ឌ ៥(២), ១៥ ("បណ្ដាញវិទ្យុទូទាំងប្រទេស ដែលបង្កើតនៅក្នុងខែតុលា ឆ្នាំ១៩៧៥"), ៨០, ៨១, ៩៣, ១០៩ ("**តា ទិត្យ** បានរៀបចំផែនការ បានញុះញង់ បានបញ្ជា បានជួយ និងជំរុញ ឬបានប្រព្រឹត្តបទល្មើសនានា ដូចមានចែងក្នុងកថាខណ្ឌទី ៥៤ ដល់កថាខណ្ឌទី ៨១ [...] ដែលបទល្មើសខាងលើ បានកើតឡើងនៅប្រទេសកម្ពុជា ក្នុងរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩...")។

[455] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ឯកសារ D1 កថាខណ្ឌ ៨០, ៨១។

[456] *សូមមើល* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ឯកសារ D281 ត្រង់ ERN 01178415-01178416។

ពាក់ កណ្តាលឆ្នាំ១៩៧៧ ដូចដែលបានចោទប្រកាន់ឡើយ)។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបំពេញកិច្ចនៅក្នុងវិសាលភាពនៃកិច្ចស៊ើបស៊ើបសួរ។

213. ជាការពិតណាស់ នៅក្នុងកថាខណ្ឌដំបូងៗនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ការចូលរួមរបស់ យឹម ទិត្យ ក្នុងការបោសសម្អាតកម្មាភិបាលដែលមានស្រាប់នៅភូមិភាគពាយ័ព្យ ត្រូវបានចោទប្រកាន់ថាបានកើតឡើង "នៅឆ្នាំ*១៩៧៧* និង១៩៧៨"[457]។ ទោះបីអង្គបុរេជំនុំជម្រះសង្កេតឃើញថា ការចោទប្រកាន់ជាច្រើនអំពីការបោសសម្អាតនេះ ពាក់ព័ន្ធនឹងរយៈពេលនៅក្រោយ "ពាក់ កណ្តាលឆ្នាំ១៩៧៧" ក៏ដោយ ក៏ការបោសសម្អាតនេះ មិនមែនជាអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងភូមិភាគពាយ័ព្យតែមួយនោះទេ។ អំពើឧក្រិដ្ឋដែលបានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មបន្ទាយអូតាក្រៃ (ឆ្នាំ១៩៧៧ ដល់ដើមឆ្នាំ១៩៧៩)[458] បន្ទាយត្រែង (ឆ្នាំ១៩៧៧ ដល់ ១៩៧៨)[459] វត្តសម្តេច (ឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨)[460] និងភ្នំទ្រយោង (នៅចន្លោះឆ្នាំ១៩៧៧ ដល់១៩៧៩)[461] មានការនិយាយសំដៅយ៉ាងច្បាស់លាស់ដល់ "ឆ្នាំ១៩៧៧"។ ចំណុចនេះត្រូវបានបំពេញបន្ថែមដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ជាឧទាហរណ៍ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ២ ការចោទប្រកាន់ពីឧក្រិដ្ឋកម្មនៅស្រុកព្រះនេត្រព្រះ ក្នុងភូមិភាគពាយ័ព្យ ត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅ "ឆ្នាំ១៩៧៧"[462]។

214. ជាការសន្និដ្ឋានចុងក្រោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសឡើយក្នុងការចោទប្រកាន់បញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះពីឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យ ចាប់ពី "យ៉ាងហោចនៅដើមឆ្នាំ១៩៧៧ រហូតដល់យ៉ាងហោចណាស់នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩"[463] ពីព្រោះ

---

[457] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ឯកសារ D1 កថាខណ្ឌ ៣ (សេចក្តីបញ្ជាក់បន្ថែម)។

[458] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ឯកសារ D1 កថាខណ្ឌ ៦២។

[459] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ឯកសារ D1 កថាខណ្ឌ ៦១។

[460] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ឯកសារ D1 កថាខណ្ឌ ៦៧។

[461] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ឯកសារ D1 កថាខណ្ឌ ៧៥។

[462] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី២ របស់សហព្រះរាជអាជ្ញា ឯកសារ D191 កថាខណ្ឌ ៩។

[463] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382 កថាខណ្ឌ ១០១៦ (i) , ១០១៧ (i)។

ការណ៍នេះស្ថិតនៅក្នុងវិសាលភាពពេលវេលានៃសំណុំរឿងទទួលបាន។ ហេតុដូច្នេះ សំណើ រ បស់សហមេធាវីទាក់ទងនឹងឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យ ត្រូវតែបដិសេធចោល។

c. *សេចក្តីសន្និដ្ឋាន*

215. សរុបសេចក្តីមក ចៅក្រមអន្តរជាតិសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹង យឹម ទិត្យ ក្នុងវិសាលភាពដែលដីកានេះស្នើឲ្យបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅភូមិភាគនិរតីមុនឆ្នាំ១៩៧៦ និងឧក្រិដ្ឋកម្មបន្ទាប់ពីដើមឆ្នាំ១៩៧៨។ ចៅក្រមអន្តរជាតិក៏តម្កល់ផងដែរនូវការចោទប្រកាន់ពីបទឧក្រិដ្ឋនៅក្នុងភូមិភាគនិរតី ដែលកើតឡើងក្នុងអំឡុងពេលដែលចោទជាបញ្ហានេះ។ លើសពីនេះទៀត អង្គជំនុំជម្រះក៏តម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងភូមិភាគពាយ័ព្យផងដែរ។

216. ហេតុដូចនេះ ចៅក្រមអន្តរជាតិសម្រេចបដិសេធមូលដ្ឋានទី ៣។

## C. មូលដ្ឋានទី ៤ ៖ ការចោទប្រកាន់អំពីកំហុសក្នុងការប្រើប្រាស់សហឧក្រិដ្ឋកម្មរួម (JCE) ដើម្បីបង្ហាញពីយុត្តាធិការបុគ្គល

ក. សារណា

217. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ដោយសារបានប្រើប្រាស់ការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម ជាមូលដ្ឋានសម្រាប់កត្តាពាក់ព័ន្ធ ដើម្បីវាយតម្លៃលើយុត្តាធិការបុគ្គល[464] ដែលបង្កឲ្យមានព្យសនកម្មមិនអាចជួសជុលបានដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ យឹម ទិត្យ និងរំលោភបំពានលើឆន្ទានុសិទ្ធិ ដែលអាចត្រូវបានដោះស្រាយតាមរយៈការធ្វើមោឃភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ[465]។ ទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានវាយតម្លៃពីយុត្តាធិការបុគ្គលលើ យឹម ទិត្យ

[464] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១០៤,១០៨។

[465] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១០៧,១២០។

01677174



ឲ្យដូចគ្នានឹងជនជាប់ចោទក្នុងសំណុំរឿង ០០៤/១[466] ដែលនៅក្នុងសំណុំរឿងនោះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងពីលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធសម្រាប់ការអនុវត្តឋានានុសិទ្ធិរបស់ពួកគេ និងពឹងផ្អែកលើការពិចារណាប្រហាក់ប្រហែលគ្នានឹងលក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើសម្រាប់គោលបំណងផ្តន្ទាទោស ពាក់ព័ន្ធនឹងការកំណត់យុត្តាធិការបុគ្គល ដែលរួមមាន៖ (i) តួនាទីផ្លូវការរបស់បុគ្គលនៅក្នុងឋានានុក្រម (ii) កម្រិតដែលជនជាប់ចោទអាចចូលរួមចំណែក ឬកំណត់គោលនយោបាយ និង/ឬការអនុវត្តវា និង (iii) ស្ថានទម្ងន់នៃអំពើផ្ទាល់របស់បុគ្គល និងផលប៉ះពាល់របស់វា[467]។

218. ទោះបីជាសហចៅក្រមស៊ើបអង្កេតជាតិ នៅតែប្រកាន់ខ្ជាប់ទៅនឹងការវិភាគរួមគ្នា ដូចបានបង្ហាញនៅក្នុងសំណុំរឿង ០០៤/១ ហើយជាលទ្ធផលបានសម្រេចថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ ដោយលើកលែងការចោទប្រកាន់ប្រឆាំងនឹងគាត់ក៏ដោយ[468] ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បែរជាមកប្រើប្រាស់ទ្រឹស្តីសហឧក្រិដ្ឋកម្មរួម "ដែលមានកំហុសជាសារវ័ន្ត" ដែលពុំបែងចែកកម្រិតនៃការទទួលខុសត្រូវ ឬក៏តម្រូវឲ្យជនជាប់ចោទបំពេញ*ធាតុផ្សំសត្យានុម័ត*

---

[466] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១០៨, ១១៩ *ដែលយោងទៅសំណុំរឿង ០០៤/០១* ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3(សំណុំរឿង ០០៤/១ដីកាដំណោះស្រាយ (សំអាងហេតុ)(D308/3) (និងខកខានមិនបានផ្តល់សំអាងហេតុចំពោះភាពខុសគ្នារបស់គាត់ពីវិធីសាស្ត្រក្នុងសំណុំរឿង ០០៤/១)។

[467] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១០៩, ១១៣, ១១៩ (សហមេធាវីបានបង្ហាញពី "អង្គហេតុទូទៅ" ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រាកដណាស់បានដឹងនៅក្នុងសំណុំរឿង ០០៤/១ ដូចជា៖ (i) ការធ្វើសេចក្តីសម្រេចនៅក្នុងកម្ពុជាប្រជាធិបតេយ្យពុំមែនជាដំណើរការប្រជាធិបតេយ្យផ្លូវការមួយនោះទេ។ សេចក្តីសម្រេចធ្វើឡើងនៅថ្នាក់លើ និងបន្ទាប់មកអនុវត្តដោយថ្នាក់ក្រោម (ii) គំនិតផ្តួចផ្តើមរបស់បុគ្គលម្នាក់នៅក្នុងកាលៈទេសៈទាំងនេះ មិនមែនជាលក្ខណៈវិនិច្ឆ័យមួយ ដែលអាចឲ្យពួកគេធ្លាក់ចូលប្រភេទជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ (iii) ការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងខ្សែបណ្តោយជាលក្ខណៈទូទៅនៅក្នុងខ្សែសង្វាក់បញ្ជា និងការសម្ងាត់ ពុំអនុញ្ញាតឲ្យអនុវត្តតាមខ្សែទទឹងដើម្បីផ្លាស់ប្តូរព័ត៌មានយុទ្ធវិធី និងប្រតិបត្តិការទៅថ្នាក់ណាដែលស្ថិតនៅក្រោមថ្នាក់កំពូលនោះទេ ហើយការពិភាក្សាជាចំហលើការណែនាំពី*អង្គការ* អាចនាំឲ្យមានផលប៉ះពាល់អវិជ្ជមានលើបុគ្គលដែលបានពិភាក្សាលើបញ្ហានេះ)។

[468] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១១៥។

ណាមួយនោះឡើយ[469]។ សហមេធាវីបញ្ជាក់ថា ជាពិសេស សហឧក្រិដ្ឋកម្មរួម មានភាពមិនសមស្របយ៉ាងខ្លាំង ក្នុងការវាយតម្លៃអំពីយុត្តាធិការបុគ្គល ក្នុងករណីដែលសហឧក្រិដ្ឋកម្មរួម ត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ដើម្បីរាប់បញ្ចូលសមាជិកជាច្រើននាក់នៅក្នុងឋានានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យ (ដូចនៅក្នុងសំណុំរឿង ០០៤) និងថា អ្នកធ្វើសេចក្តីព្រាងច្បាប់ អ.វ.ត.ក ពុំបានថែងប្រមើលមើលទុកជាមុនថា យុត្តាធិការបុគ្គលនឹងរួមបញ្ចូលចារីជាច្រើនឡើយ[470]។

219. ជាការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហមេធាវីខកខានមិនបានបង្ហាញកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន ចំពោះការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសហឧក្រិដ្ឋកម្មរួម[471]។ ទីមួយ សហមេធាវីគ្រាន់តែស្នើថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកលើសហឧក្រិដ្ឋកម្មរួម ក្នុងការវាយតម្លៃអំពីយុត្តាធិការបុគ្គល និងអះអាងដោយមិនត្រឹមត្រូវថា យុត្តាធិការបុគ្គលអាចត្រឹមតែពិចារណាលើអំពើ និងការប្រព្រឹត្ត ដែលមិននៅកៀកកិត ឬមិនមែនជាការប្រព្រឹត្តផ្ទាល់[472]។ ទីពីរ សហមេធាវីខកខានមិនបានបង្ហាញនូវកំហុសណាមួយ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកលើសហឧក្រិដ្ឋកម្មរួម ជាការអនុវត្តទម្រង់មួយនៃការទទួលខុសត្រូវនៅ អ.វ.ត.ក ដែលត្រូវបានដោះស្រាយរួចយូរណាស់មកហើយ។ សហមេធាវីពឹងផ្អែកលើសំណុំរឿង Brđanin (ICTY) តាមការជ្រើសរើស និងខកខានមិនបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកយ៉ាងច្បាស់លាស់ទៅលើការទទួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួម នៅពេលកំណត់យុត្តាធិការបុគ្គលនៅក្នុងសំណុំរឿង ០០៤/១[473]។

---

[469] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១១៥-១១៨ *ដែលយោងទៅ* សាលដីកានៃរឿងក្តី ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Brđanin* សំណុំរឿងលេខ IT-99-36-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ (សាលដីកាលើរឿងក្តី *Brđanin* (ICTY)") កថាខណ្ឌ ៤២៦-៤២៧, ៤៣១-៤៣២។

[470] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១១៨-១១៩។

[471] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)ឯកសារ D382/27 កថាខណ្ឌ ៦១ (ចំណងជើង)។

[472] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៦២។

[473] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៦៣។

220. នៅចុងបញ្ចប់ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា យឹម ទិត្យ ស្ថិតក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយសារបានដើរតួនាទីដ៏សំខាន់នៅក្នុងអំពើឃោរឃៅទាំងអស់ ក្នុងនោះរួមមាន ការរៀបចំអំពើប្រល័យពូជសាសន៍ ការធ្វើឲ្យជនស៊ីវិល និងអតីតកម្មាភិបាល ប.ក.ក ក្លាយជាជនរងគ្រោះ និងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានគាំទ្រដោយសំអាងហេតុដ៏ច្រើនអនេកអំពីការពាក់ព័ន្ធរបស់ យឹម ទិត្យ នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម[474]។

## ខ. ការពិភាក្សា

221. ចៅក្រមអន្តរជាតិ នឹងដោះស្រាយជាបន្តបន្ទាប់នូវការចោទប្រកាន់ចំនួនពីរចំណុចរបស់សហ ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (i) ខកខានមិនបានវាយតម្លៃអំពីយុត្តាធិការបុគ្គល លើ យឹម ទិត្យ ក្នុងលក្ខណៈស្មើភាពគ្នាទៅនឹងជនជាប់ចោទក្នុងសំណុំរឿង ០០៤/១ និងបែរជា (ii) ពឹងផ្អែកដោយមិនត្រឹមត្រូវលើការទទួលខុសត្រូវរបស់ យឹម ទិត្យ ដែលរងការចោទប្រកាន់ ក្នុងនាមជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ជាកត្តាពាក់ព័ន្ធ ដើម្បីសម្រេចថា យឹម ទិត្យ ជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុត"។

222. ទីមួយ ពាក់ព័ន្ធនឹងការចោទប្រកាន់ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានវាយតម្លៃអំពីយុត្តាធិការបុគ្គលលើ យឹម ទិត្យ ក្នុងលក្ខណៈស្មើគ្នានឹងជនជាប់ចោទក្នុងសំណុំរឿង ០០៤/១[475] ចៅក្រមអន្តរជាតិ បញ្ជាក់ថា ក្នុងគោលបំណងកំណត់អំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ការកំណត់អត្តសញ្ញាណ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ពាក់ព័ន្ធនឹងការវាយតម្លៃបែបបរិមាណវិស័យ និងគុណវិស័យ ទៅលើ (i) ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទ ឬដែលត្រូវបានចោទប្រកាន់ និង (ii) កម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[476]។ ក្នុងការវាយតម្លៃ

---

[474] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៦៤។

[475] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១០៩-១១៣, ១១៩។

[476] *សូមមើលឧទាហរណ៍* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៨៦។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។ សាលក្រមនៃសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ២២

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

លើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម កត្តាផ្សេងៗ ដូចជា ចំនួនជនរងគ្រោះ វិសាលភាពភូមិសាស្ត្រ និងពេលវេលា លក្ខណៈដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានលើកឡើងថាបានប្រព្រឹត្ត និងចំនួនហេតុការណ៍ដាច់ពីគ្នា អាចត្រូវបានពិចារណា[477]។ ក្នុងការកំណត់ពីកម្រិតទទួលខុសត្រូវរបស់ជនសង្ស័យ ការពិចារណានានា ដូចជា កម្រិតនៃការចូលរួមរបស់ជនសង្ស័យក្នុងបទល្មើស អាចត្រូវបានពឹងផ្អែកលើ រួមនឹងកត្តាផ្សេងៗទៀតដូចជា ឋានៈ ឬមុខតំណែងតាមឋានានុក្រម រាប់បញ្ចូលទាំងចំនួនមន្ត្រីក្រោមបង្គាប់ និងថ្នាក់លើតាមឋានានុក្រម ភាពអចិន្ត្រៃយ៍នៃមុខតំណែង និងតួនាទី និងការទទួលខុសត្រូវ *តាមព្រឹត្តន័យ* របស់ជនសង្ស័យ[478]។

223. ក្នុងករណីដែលការពិចារណាយោងតាមសំណុំរឿង ០០៤/១ ដូចជា មុខតំណែងផ្លូវការរបស់បុគ្គលនៅក្នុងឋានានុក្រម ស្ថានទម្ងន់នៃអំពើផ្ទាល់របស់បុគ្គល និងកម្រិតដែលជនជាប់ចោទអាចចូលរួមចំណែកក្នុងគោលនយោបាយ និង/ឬការអនុវត្តគោលនយោបាយទាំងនោះ[479] អាចជាផ្នែកមួយនៃការវាយតម្លៃនេះ ចៅក្រមអន្តរជាតិ បានបញ្ជាក់ជាថ្មីថា ពុំមានបញ្ជីជាក់លាក់ស្តីអំពីកត្តានានាដែលត្រូវយកមកពិចារណានោះទេ ហើយក៏ពុំមានលក្ខខណ្ឌបែបគណិតវិទ្យាចំពោះការស្លាប់

---

និងជើងទំព័រភ្ជាប់ជាមួយ។ សេចក្តីសម្រេចស្តីពីយុត្តាធិការបុគ្គលក្នុងសំណុំរឿង ០០៣ (ឯកសារ D48) កថាខណ្ឌ ១៥ និងជើងទំព័រ ២៥។

[477] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។ សាលក្រមនៃសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ២២ និងជើងទំព័រភ្ជាប់ជាមួយ។

[478] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។ សាលក្រមនៃសំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ២២ និងជើងទំព័រភ្ជាប់ជាមួយ។

[479] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១០៩-១១២ *យោងទៅ* សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ឯកសារ កថាខណ្ឌ ៣៨-៤២។

និងរបួស[480] ឬបទដ្ឋានកំហិតអំពីតួនាទីនៅក្នុងឋានានុក្រមនោះដែរ[481]។ ក៏ប៉ុន្តែ ការកំណត់ពីយុត្តាធិការបុគ្គល តម្រូវឱ្យមានការវាយតម្លៃលើករណីនីមួយៗ ដោយពិចារណាទៅលើបរិបទទូទៅ និងកាលៈទេសៈបុគ្គលរបស់ជនសង្ស័យ[482]។ ហេតុដូចនេះ ការដកចេញពីការពិចារណាដែលរងការចោទប្រកាន់ ដូចបានកំណត់ក្នុងសំណុំរឿង ០០៤/១ ឬពីសំណុំរឿងផ្សេងទៀតៗ ពុំមែនជាកំហុសអង្គច្បាប់ឡើយ ព្រោះថាការកំណត់ពីយុត្តាធិការបុគ្គល គឺជាករណីជាក់លាក់ និងមានលក្ខណៈវិនិច្ឆ័យច្រើនយ៉ាង។ លើសពីនេះទៅទៀត តាមពិត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បាន

---

[480] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២, ៥៥៥។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។

[481] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។

[482] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៨៦។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២។ *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។ *សូមមើលផងដែរ* តុលាការ SCSL *រដ្ឋអាជ្ញា តទល់នឹង Fofana* សំណុំរឿងលេខ SCSL-04-14-PT សេចក្តីសម្រេចលើសំណើបឋមរបស់មេធាវីការពារក្តីស្តីពីកង្វះយុត្តាធិការបុគ្គលដែលបានដាក់ក្នុងនាមជាជនជាប់ចោទ Fofana ចៅក្រមអន្តរជាតិសាលាដំបូង ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៤ កថាខណ្ឌ ៣៨។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ* សំណុំរឿងលេខ ICC-01/04-169 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមអន្តរជាតិ I ដែលមានចំណងជើងថា "សេចក្តីសម្រេចលើសំណើសុំដីកាចាប់ខ្លួនរបស់រដ្ឋអាជ្ញា មាត្រា ៥៨" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ៧៦។

ពិចារណាលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងសំណុំរឿង ០០៤/១ ដែលជាផ្នែកមួយនៃការវាយតម្លៃដ៏ទូលាយក្នុងការកំណត់យុត្តាធិការបុគ្គលលើ យឹម ទិត្យ[483]។

224. ទីពីរ នៅពេលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចៅក្រមអន្តរជាតិ ពុំជឿថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកដោយមិនត្រឹមត្រូវទៅលើការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់របស់ យឹម ទិត្យ ក្នុងនាមជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ក្នុងការបង្ហាញពីយុត្តាធិការបុគ្គលនោះឡើយ[484]។ ក្នុងការសម្រេចថា "យឹម ទិត្យ ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"[485] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការវាយតម្លៃតាមករណីជាក់លាក់ និងបានពឹងផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានទទួលស្គាល់ខាងលើ ដូចជា ឋានៈ និងតំណែងផ្លូវការរបស់ យឹម ទិត្យ នៅភូមិភាគ ពាយ័ព្យ និងនិរតី ក៏ដូចជា សិទ្ធិអំណាច*តាមព្រឹត្តន័យ* របស់គាត់[486] ភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តរបស់គាត់ រួមទាំងចំនួននៃទីតាំងឧក្រិដ្ឋកម្ម[487] និង "តួនាទីដ៏សំខាន់"របស់គាត់ នៅក្នុងអំពើយង់ឃ្នង និងការអនុវត្តគោលនយោបាយរបស់ ប.ក.ក នៅក្នុងតំបន់ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គាត់[488]។

225. ជាការកត់សម្គាល់ ពាក់ព័ន្ធនឹងមុខតំណែងផ្លូវការរបស់ យឹម ទិត្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាអំពីការឡើងឋានៈរបស់គាត់ពីតំណែងជា(អនុ)លេខាស្រុកគិរីវង្សនៅភូមិភាគនិរតី[489] ទៅជាអនុលេខាភូមិភាគ និង "ប្រហែលជាបានឡើងឋានៈជាលេខាភូមិភាគពេញ

---

[483] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៣-៣៤ ជើងទំព័រ ៧២-៧៣ (សេចក្តីយោងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើដីកាដំណោះស្រាយ (សំអាងហេតុ) (D308/3) ក្នុងសំណុំរឿង ០០៤/១ "សម្រាប់ចំណុចលម្អិតពាក់ព័ន្ធនឹងការ អនុវត្តឆន្ទានុសិទ្ធិនេះ")។

[484] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១០៨, ១១៦-១២០។

[485] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩២។

[486] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៣-៩៩៤។

[487] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៥។

[488] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៦-៩៩៩។

[489] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៣, ៣២៧-៣៩២។

លេញ” នៅភូមិភាគពាយ័ព្យ[490] ក៏ដូចជាការទទួលខុសត្រូវរបស់គាត់នៅតំបន់មួយចំនួនទៀត[491]។ ដោយផ្អែកលើមូលដ្ឋាននេះ (និងមិនផ្អែកលើសមាជិកភាពនៃសហឧក្រិដ្ឋកម្មរួមរបស់គាត់)[492] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា សិទ្ធិអំណាចរបស់ យឹម ទិត្យ នៅក្រោមច្បាប់របស់ ប.ក.ក “លាតសន្ធឹងយ៉ាងឆ្ងាយ ទាំងផ្នែកភូមិសាស្ត្រ និងទាំងនៅក្នុងឋានានុក្រម”[493]។ លើសពីនេះទៅទៀត ក្នុងការពិចារណាមួយក្នុងចំណោមការពិចារណាជាច្រើន សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា តាមរយៈចំណងគ្រួសារយ៉ាងជិតស្និទ្ធរបស់គាត់ និងទំនាក់ទំនងការងារក្នុងនាម*ដាក់ស្ដែង* ជាមនុស្សមានអំណាចទីពីរ ព្រមទាំងជាអនុរបស់ តាម៉ុក សិទ្ធិអំណាចជាក់ស្ដែងរបស់ យឹម ទិត្យ បានពង្រីកលើសពីសិទ្ធិអំណាចដែលគាត់មានតាមរយៈមុខតំណែងផ្លូវការរបស់គាត់[494]។

226. ដូច្នេះ នៅក្នុងការវាយតម្លៃពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់ យឹម ទិត្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាលើឧក្រិដ្ឋកម្មនៅទីតាំងជាង ២០ កន្លែង[495]

---

[490] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៣, ៣៨០-៣៨៥។

[491] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៣ (ដែលយោងដល់មុខតំណែងរបស់គាត់ជាលេខាតំបន់ ១ តំបន់ ៣ និងតំបន់ ៤ នៅក្នុងភូមិភាគពាយ័ព្យ បន្ថែមទៅនឹងតំបន់ ១៣ នៅក្នុងភូមិភាគនិរតី (*សូមមើល* កថាខណ្ឌ ៣៤៣-៣៥២, ៣៥៧-៣៧៨)។

[492] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១០៨ និងជើងទំព័រ ២៥៤។

[493] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៣។

[494] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣២៧, ៩៩៥។

[495] ដីកាដំណោះស្រាយ ឯកសារ D382, កថាខណ្ឌ ៤៣៣-៤៦៩ (មន្ទីរសន្តិសុខវត្តព្រះធាតុ), ៤៧០-៥២៦ (មន្ទីរសន្តិសុខក្រាំងតាចាន់), ៥២៧-៥៤៦ (កន្លែងសម្លាប់មនុស្សនៅភូមិព្រាល), ៥៤៧-៥៥៤ (ទីតាំងសម្លាប់វត្តអង្គុញ), ៥៥៥-៥៦៥ (ទីកន្លែងសម្លាប់នៅភូមិព្រៃស្លែង), ៥៦៦-៥៨៥ (វត្តអង្គសិរីមាលី និងកន្លែងសម្លាប់ព្រៃសុខុន), ៥៨៦-៥៩៥ (មន្ទីរសន្តិសុខគាស់ក្រឡ), ៥៩៦-៦៥១ (សហករណ៍ធិបតី - រួមមានមន្ទីរសន្តិសុខវត្តធិបតី និងមន្ទីរសន្តិសុខទួលម្ទេស និងការដ្ឋានទួលម្ទេស), ៦៥២-៧០០ (ការដ្ឋានទំនប់កង្ហត), ៧០១-៧១៩ (មន្ទីរសន្តិសុខបាណន់), ៧២០-៧៣៧ (មន្ទីរសន្តិសុខខ្នងគូ), ៧៣៨-៧៤៦ (ការដ្ឋានរោងចក្រស្ករកំពង់កុល), ៧៤៧-៧៧១ (មន្ទីរសន្តិសុខភូមិវាល), ៧៧២-៧៨៦ (មន្ទីរសន្តិសុខស្វាយជ្រុំ), ៧៨៧-៨១០ (កន្លែងសម្លាប់ទួលសេះញ៉ូវ), ៨១១-៨២៦ (កន្លែងសម្លាប់ព្រៃក្រពៅ), ៨២៩-៨៤៩ (មន្ទីរសន្តិសុខវត្តគិរីរម្យ), ៨៥០-៨៦៩ (មន្ទីរសន្តិសុខវត្តសម្ដេច), ៨៧០-៩១០, ៩១៨-៩២០, ៩៦៧-៩៧៩ (ឃុំកំពង់ព្រៀង-មន្ទីរសន្តិសុខវត្តពោធិ៍លង្ការ/កាច់រទេះ, ភូមិកាច់រទេះ, ថ្មី និងភូមិស្លាត្រាវ), ៨៩៤, ៩១១-៩២០, ៩៥០-៩៦៦ (ឃុំរាំងកេសី), ៩២១-៩៣៩ (គុកលេខ ៨), ៩៤០-៩៤៨ (ទីតាំងសម្លាប់មនុស្សវាលបាក់ចិញ្ចៀន), ៩៨០-៩៩១ ((ការរៀបការដោយបង្ខំ) នៅស្រុកសំឡូត), ១០១២-១០១៥។

ដោយរួមបញ្ចូលទាំងការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើមនុស្សឃាតក្រោមច្បាប់ជាតិ[496] តាមរយៈទម្រង់នៃការទទួលខុសត្រូវមួយចំនួន ដូចជា សហឧក្រិដ្ឋកម្មរួម ការធ្វើផែនការ ការបញ្ជា ការញុះញង់ ការទទួលខុសត្រូវរបស់ថ្នាក់លើ និងប្រព្រឹត្តកម្មដោយផ្ទាល់សម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិ និងសហប្រព្រឹត្តកម្ម ការធ្វើផែនការ និងការបញ្ជាសម្រាប់ឧក្រិដ្ឋកម្មជាតិ[497]។ ទោះបីភស្តុតាងស្តីពីចំនួនជនរងគ្រោះនៅតាមទីតាំងឧក្រិដ្ឋកម្មមួយចំនួនមិនច្បាស់លាស់ ឬ "ពុំជាក់លាក់គ្រប់គ្រាន់អាចឱ្យបង្កើតជាមូលដ្ឋានសម្រាប់ការគណនា"[498] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្តល់នូវការប៉ាន់ស្មានបែបអភិរក្សនិយមនៃចំនួនជនរងគ្រោះជាខ្មែរក្រោមរាប់ពាន់នាក់(សម្លាប់)[499] និងម៉្យាងវិញទៀតបានរកឃើញថា ជនស៊ីវិល និងអតីតកម្មាភិបាល ប.ក.ក រាប់ម៉ឺននាក់ ត្រូវបានធ្វើឱ្យក្លាយជាជនរងគ្រោះ[500]។

227. ទោះបីសហចៅក្រមស៊ើបអង្កេតអន្តរជាតិនិយាយសំដៅដល់គោលនយោបាយរបស់ ប.ក.ក នៅក្នុងរបកគំហើញផ្នែកច្បាប់ស្តីពីយុត្តាធិការបុគ្គលក៏ដោយ[501] ក៏ដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន

---

[496] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៥, ១០១២-១០១៥។

[497] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០១៦-១០៣៩។

[498] *សូមមើលឧទាហរណ៍* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៥៦៤ (ទីកន្លែងសម្លាប់នៅភូមិព្រៃស្លែង), ៥៩៩ (មន្ទីរសន្តិសុខគាស់ក្រឡ)។

[499] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៦។

[500] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៧។ *សូមមើលបន្ថែមទៀត ឧទាហរណ៍* កថាខណ្ឌ ៤៦២ (វត្តព្រះធាតុ៖ ជនរងគ្រោះ ៦៤០ នាក់ ខ្មែរក្រោម ១៤០ នាក់ (ការប៉ាន់ស្មានបែបអភិរក្ស)), ៥២៥ (ក្រាំងតាចាន់៖ ជនរងគ្រោះ ៦៤៦ នាក់ ក្នុងនោះមានខ្មែរក្រោម ២០៣ នាក់ (ការប៉ាន់ស្មានបែបអភិរក្សអប្បបរមា)), ៥៤៥ (កន្លែងសម្លាប់មនុស្សនៅភូមិព្រាល៖ ជនរងគ្រោះ ១៦ នាក់ ខ្មែរក្រោម ១០ នាក់), ៥៥៣ (ទីតាំងសម្លាប់វត្តអង្គញ៖ ជនរងគ្រោះ ៤ នាក់ ខ្មែរក្រោមទាំងអស់ (ទំនងជាមានជនរងគ្រោះច្រើនជាងនេះ)), ៥៨៣ (កន្លែងសម្លាប់ព្រៃសុខុន និងវត្តអង្គសិរីមាលី៖ ជនរងគ្រោះ ៩០ នាក់ មិនដឹងចំនួនខ្មែរក្រោម (ការប៉ាន់ស្មានបែបអភិរក្ស), ៥៩៩ (មន្ទីរសន្តិសុខគាស់ក្រឡ៖ ភស្តុតាងស្តីពីចំនួនជនរងគ្រោះ គឺមិនច្បាស់លាស់ទេ ប៉ុន្តែគេអាចសន្និដ្ឋានបានថា មានមនុស្សយ៉ាងច្រើនត្រូវបានសម្លាប់), ៦៤៩ (សហករណ៍ធិបតី- មន្ទីរសន្តិសុខវត្តធិបតី និងមន្ទីរសន្តិសុខទួលម្ទេស និងការដ្ឋានទួលម្ទេស៖ ជនរងគ្រោះ ៣៧៥ នាក់ (ចំនួនអ្នកស្លាប់អប្បបរមា)។

[501] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៦-៩៩៨ (ដែលសំដៅដល់ការកំណត់គោលដៅនៃអំពើប្រល័យពូជសាសន៍ចំពោះខ្មែរក្រោម ការកំណត់គោលដៅទៅលើជនស៊ីវិលផ្សេងទៀត និងអតីតកម្មាភិបាល ប.ក.ក ដោយផ្អែកលើទស្សនៈ

បង្ហាញយ៉ាងច្បាស់ថា គាត់បានវាយតម្លៃពីភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តរបស់ យឹម ទិត្យ តាមរយៈសម្មភាពបុគ្គល និងការចូលរួមរបស់គាត់ក្នុងគោលនយោបាយ និងឧក្រិដ្ឋកម្ម។ ជាឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានវាយតម្លៃពី "**ការចូលរួមប្រព្រឹត្ត** និង**ការរៀបចំ** របស់ យឹម ទិត្យ ក្នុងអំពើប្រល័យពូជសាសន៍ខ្មែរក្រោម នៅក្នុងតំបន់ដែលស្ថិតក្រោមការទទួលខុសត្រូវ**របស់គាត់**"[502] និងបានសន្និដ្ឋានថា ការប្រព្រឹត្ត និងការចូលរួមរបស់ យឹម ទិត្យ រួមមាន *ជាអាទិ៍* "ការនិយាយប្រឆាំងនឹងជនជាតិវៀតណាម និងអ្នកណាដែលមានទំនាក់ទំនងជាមួយវៀតណាម និងដោយការអំពាវនាវដល់គ្រប់ផ្នែកទាំងអស់នៅក្នុងសង្គម រួមទាំងកម្មាភិបាល ប.ក.ក ថ្នាក់ក្រោម ឱ្យតាមដាន និងរាយការណ៍ពីអ្នកណាដែលគេសង្ស័យថាមានខ្សែបណ្ដាញទាំងនេះ ដើម្បីយកទៅសម្លាប់"[503] និងបានរកឃើញថា យឹម ទិត្យ បានទៅពិនិត្យ សួរចម្លើយ និងកំណត់អត្តសញ្ញាណអ្នកទោសជាខ្មាំងនៅមន្ទីរសន្តិសុខវត្តព្រះធាតុ ជាកន្លែងដែលខ្មែរក្រោមត្រូវបានឃុំខ្លួននិងបន្ទាប់មកសម្លាប់[504]។

228. ស្រដៀងគ្នានេះផងដែរ ស.ច.ស.អ បានពិចារណាពីការធ្វើឱ្យក្លាយជាជនរងគ្រោះនៃ "ជនស៊ីវិលផ្សេងទៀត និងអតីតកម្មាភិបាល ប.ក.ក [...] **នៅក្រោម និងដោយ យឹម ទិត្យ**"[505] និងយល់ឃើញថា តាម៉ុក និង យឹម ទិត្យ **បានចាប់ផ្តើមរៀបចំ**ការបោសសម្អាតភូមិភាគពាយ័ព្យ[506]។ យឹម ទិត្យ បានដឹកនាំ និងចូលរួមក្នុងការប្រជុំ (ដែលផ្ដោតទៅលើការស្រាវជ្រាវរកគិញវៀតណាម និង សេ.អ៊ី.អា) កំណត់អត្តសញ្ញាណ និងចោទប្រកាន់ជនក្បត់ និងខ្មាំង បានបញ្ជាឱ្យចាប់ខ្លួន និងសម្លាប់ និងសម្របសម្រួលក្នុងការរៀបចំបណ្ដាញមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សក្នុងចំណោមការរួមចំណែកផ្សេងៗទៀត[507]។ នៅចុងបញ្ចប់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

---

នយោបាយដែលដើរខុស និងគោលនយោបាយស្ដីពីការរៀបការដោយបង្ខំ)។ *សូមមើលផងដែរ* បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១០៤ និងជើងទំព័រ ២៥៤។

[502] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩០។

[503] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៨០-៣៩៧, ១០២២។

[504] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៩២, ១០១។

[505] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៧។

[506] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤១២។

[507] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤១៣-៤២៦, ៩៩៧, ១០២២។

យល់ឃើញថា "យឹម ទិត្យ និង តាម៉ុក **បានដើរតួនាទីស្នូល**"[508] ក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក ស្តីពីការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន"[509] និងថា យឹម ទិត្យ បានចូលរួមចំណែកក្នុងគោលនយោបាយរបស់ ប.ក.ក ស្តីពីបទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍ ដោយយ៉ាងហោចណាស់បានចូលរួមនៅដំណាក់កាលរៀបចំពិធីរៀបអាពាហ៍ពិពាហ៍នៅក្នុងតំបន់ ១ និងដោយផ្តល់ការណែនាំដល់ *"អ្នករៀបការថ្មីថ្មោង"* ក្នុងរយៈពេលពីបីថ្ងៃ ក្រោយពីពិធីរៀបអាពាហ៍ពិពាហ៍ *"ឱ្យចេះស្រលាញ់គ្នា"*[510]។

229. ដូច្នេះ ទោះបីសហឧក្រិដ្ឋកម្មរួម អាចត្រូវបាន "បកស្រាយយ៉ាងទូលាយ"[511] និងរាប់បញ្ចូលមនុស្សជាច្រើន ដូចជា "កម្មាភិបាលជាទីទុកចិត្តពីភូមិភាគនិរតី"[512]ក៏ដោយ ក៏ការណ៍នេះនឹងមិនបណ្តាលឱ្យឈានដល់ការរកឃើញដោយស្វ័យប្រវត្តិលើយុត្តាធិការបុគ្គលរបស់មនុស្សទាំងអស់នោះទេ ព្រោះការវាយតម្លៃលើ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គឺផ្អែកលើកត្តាជាច្រើន ដូចបានពិពណ៌នានៅផ្នែកខាងលើ ហើយម្យ៉ាងវិញទៀត វាអាស្រ័យទៅលើប្រភេទ និងភាពធ្ងន់ធ្ងរនៃការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម។ ការវាយតម្លៃលើកត្តាផ្សេងៗគ្នាទាំងនោះ ដែលរាប់បញ្ចូល ប៉ុន្តែមិនកំណត់ចំពោះតែការទទួលខុសត្រូវរបស់ យឹម ទិត្យ ក្រោមទម្រង់ជាសហឧក្រិដ្ឋកម្មរួម (ទាក់ទងនឹងការចូលរួមចំណែកជាបុគ្គលរបស់គាត់) ដែលត្រូវបានពិចារណានៅក្នុងបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យ[513] បាននាំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា "គ្មានអ្វីដែលអាចឱ្យគេមានមន្ទិលថា យឹម ទិត្យ មិនស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក នោះទេ"[514] ហេតុដូចនេះ សម្រេចបដិសេធមូលដ្ឋានទី ៤ ។

---

[508] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៩៨។

[509] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៩៨-៤១១, ៩៩៧, ១០១៦។

[510] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤២៧, ៩៩៨, ១០២៥។

[511] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១១៨។

[512] *សូមមើលផងដែរ ឧទាហរណ៍*ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០១៦ (i)(ii)។

[513] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៣-៣៤ ជើងទំព័រ ៧២-៧៣ (ដែលគាត់ពិចារណាពីលក្ខណៈជាក់លាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ)។

[514] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩៩។

## D. មូលដ្ឋានទី ៥៖ ការចោទប្រកាន់អំពីកំហុសចំពោះការរកឃើញថា លោក យឹម ទិត្យ គឺជា "ជនទទួលខុសត្រូវខ្ពស់បំផុត"

### សេចក្ដីផ្ដើម

230. មូលដ្ឋានទី ៥ នៃបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះតវ៉ាចំពោះសេចក្ដី សន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា លោក យឹម ទិត្យ គឺជា "ជនទទួល ខុសត្រូវខ្ពស់បំផុត" ដូច្នេះ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ ជារួម សហមេធាវីលើកយក កំហុសអង្គច្បាប់ និងអង្គហេតុ ដែលភាគច្រើនទាក់ទងនឹងការវាយតម្លៃលើភ័ស្តុតាងចំពោះមុខតំណែង *តាមផ្លូវច្បាប់*របស់ លោក យឹម ទិត្យ នៅក្នុងឋានានុក្រម ប.ក.ក និងទំនួលខុសត្រូវ*ជាក់ស្ដែង*នៅ ភូមិភាគនិរតី និងពាយ័ព្យ កម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាសមាជិកភាពរបស់ លោក យឹម ទិត្យ និងការ ចូលរួមចំណែកនៅក្នុងទម្រង់ទាំងបីនៃ JCE ដែលបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

231. យោងតាមមូលដ្ឋានទី ៥[515] សហមេធាវីបានបង្កើតមូលដ្ឋានតូចៗនៃបណ្ដឹងឧទ្ធរណ៍ដែលទាក់ទងនឹងគ្នា ចំនួន ១០ ចំណុច ពោលគឺ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសចំពោះការរកឃើញថា៖ (១) ទំនាក់ទំនងគ្រួសាររបស់ លោក យឹម ទិត្យ ជាមួយតាម៉ុក "មានន័យស្មើនឹង ការសន្និដ្ឋាន អំពី សិទ្ធិអំណាច*តាមព្រឹត្តិន័យ*" (មូលដ្ឋានទី ៥.១) (២) លោក យឹម ទិត្យ ជា "មេដឹកនាំ" ស្រុកគីរីវង់ (មូលដ្ឋានទី៥.២ (i)) (៣) គាត់មាន "សិទ្ធិអំណាចជាក់ស្ដែងច្រើន" ទូទាំងតំបន់ ១៣ (មូលដ្ឋានទី ៥.២ (ii)) (៤) គាត់គឺជាលេខាតំបន់ ១ (មូលដ្ឋានទី ៥.២ )iii() (៥) គាត់គឺជាលេខាតំបន់ ៣ (មូលដ្ឋាន ទី ៥.២ )iv)) (៦) គាត់គឺជាលេខាតំបន់ ៤ (មូលដ្ឋានទី ៥.២ ) v)) និង (៧) គាត់គឺជា សមាជិកគណៈកម្មាធិការភូមិភាគពាយព្យ (មូលដ្ឋានទី ៥.២ )vi))។ សហមេធាវីក៏បានជំទាស់ ចំពោះ ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា (៨) លោក យឹម ទិត្យ បានចូលរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្មរួម ក ទាក់ទងនឹងសហករណ៍ ការដ្ឋានការងារ និងការកំណត់គោលដៅ "ខ្មាំង" និងក្រុមជាក់លាក់ និងការកំណត់បទបញ្ជានៃអាពាហ៍ពិពាហ៍នៅភូមិភាគពាយ័ព្យ (មូលដ្ឋានទី ៥.៣(i)) (៩) គាត់បានចូលរួមចំណែកដល់

[515] បណ្ដឹងឧទ្ធរណ៍របស់ លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) ទំព័រ ៨៨-១៨២។

01677185



សហឧក្រិដ្ឋកម្ម រួម ខ ទាក់ទងនឹងអំពើប្រល័យពូជសាសន៍លុបបំបាត់ខ្មែរក្រោម (មូលដ្ឋានទី ៥.៣ )ii)) និង (១០) គាត់បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម គ នៅមន្ទីរសន្តិសុខវត្តព្រះធាតុ (មូលដ្ឋានទី ៥.៣ )iii))។ មូលដ្ឋានតូចៗទាំងនេះនឹងត្រូវយកមកវាយតម្លៃម្តងមួយៗ។

## ការពិចារណាលើភស្តុតាងចំពោះមូលដ្ឋានទី ៥

232. ដូចបានរៀបរាប់ខាងលើរួចមកហើយ មូលដ្ឋានរងចំនួនដប់នៃបណ្តឹងឧទ្ធរណ៍ដែលបាន ដាក់ជូននៅក្នុងមូលដ្ឋានទី ៥ គឺ ជំទាស់ជាចម្បង ទៅនឹងការពិចារណាទៅលើភស្តុតាង និងការសំអាងទៅលើភស្តុតាង ទាក់ទងនឹងបញ្ហាយុត្តាធិការបុគ្គល របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិ នឹងកំណត់ពីបទដ្ឋាននៃការពិនិត្យឡើងវិញដែលអាចអនុវត្តបាន និងការពិចារណាទៅលើភស្តុតាងដែលត្រូវយកមកអនុវត្ត នៅក្នុងការវាយតម្លៃទៅលើមូលដ្ឋានរងនៃបណ្តឹងឧទ្ធរណ៍របស់សហាមេធាវី ដែលស្ថិតនៅក្រោមមូលដ្ឋានទី៥។

233. ចៅក្រមអន្តរជាតិ រំឮក ឡើងវិញថា "ការ ភ័ន្តច្រឡំ អង្គច្បាប់ ដែលបានលើកឡើង ត្រូវបានពិនិត្យមើលជាថ្មីដើម្បីសម្រេច ថាតើ សេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬទេ និងការភ័ន្តច្រឡំអង្គហេតុត្រូវបានពិនិត្យមើល ស្របតាមបទដ្ឋានស្តីពីភាពសមស្របដើម្បីសម្រេច ថាតើពុំមានអ្នកវិនិច្ឆ័យសេចក្តីដែលសមស្រប បានធ្វើសំអាងផ្អែកអង្គហេតុដែលបានលើកឡើងដែរឬទេ"[516]។ នៅក្នុងករណីនេះ "បន្ទុកគឺស្ថិតលើម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការបញ្ជាក់ថា មិនមានអ្នក

---

[516] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ (អៀង សារី) (D427/1/30) កថាខណ្ឌ ១១៣។ សាលដីកាសំណុំរឿង ០០២/១ (F36) កថាខណ្ឌ ៨៩-៩០។ *សូមមើលផងដែរ* តុលាការ ICTR រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង* *Rutaganda* សំណុំរឿងលេខ ICTR-96-3-A សាលដីកា ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ ("សាលដីការឿងក្តី *Rutaganda* (ICTR)") កថាខណ្ឌ ៣៥៣ ("ពិតហើយថា ដោយសារតែចៅក្រមអន្តរជាតិសាលាដំបូងនមានតួនាទីសំខាន់ ក្នុងការសង្កេតមើលសាក្សីដោយផ្ទាល់ នោះចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍នឹងធ្វើអន្តរាគមន៍តែក្នុងករណីណាដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានបង្ហាញថា ភស្តុតាងដែលត្រូវបានយកមកសំអាងនោះ មិនអាចត្រូវបានតុលាការប្រកបដោយហេតុផលណាមួយទទួលយកទេ ឬក៏ក្នុងករណីដែលការវាយតម្លៃភស្តុតាងនោះ ខុសទាំងស្រុងតែប៉ុណ្ណោះ"។ តុលាការ ICTR រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង* *Kayishema* និង *Ruzindana* សំណុំរឿងលេខ ICTR-95-1-A សាលដីកា (សំអាងហេតុ) ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១២៩។ តុលាការ SCSL រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង* *Brima* និង *និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ SCSL-2004-16-A សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ ***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

វិនិច្ឆ័យអង្គហេតុដែលមានហេតុផលណាម្នាក់ អាចធ្វើការសម្រេច និងពឹងផ្អែកទៅលើភស្តុតាងដែលត្រូវបានជំទាស់ នៅក្នុងការសម្រេចលើអង្គហេតុនោះទេ"[517]។

234. សូមរំលឹកដែរថា ការចោទប្រកាន់ដោយគ្មានមូលដ្ឋាន ដែលគ្រាន់តែបញ្ជាក់ពីការមិនយល់ស្របជាមួយសេចក្តីសន្និដ្ឋានផ្នែកអង្គហេតុដែលបានសម្រេច ឬដែលអះអាងមិនច្បាស់លាស់លើកំហុសណាមួយក្នុងលក្ខណៈពុំមានភស្តុតាងគាំទ្ររឹងមាំ អង្គជំនុំជម្រះអាចបដិសេធចោលភ្លាម[518] ដោយសារតែការចោទប្រកាន់បែបនោះពុំបញ្ជាក់ពីបន្ទុកនៃការបង្ហាញកំហុសអង្គហេតុ ឬអង្គច្បាប់ឱ្យបានច្បាស់លាស់នៅក្នុងបណ្តឹងសាទុក្ខ[519]។ ជាពិសេស ចំពោះភស្តុតាងរបស់សាក្សីវិញ វត្តមាន

("សាលដីការឿងក្តី *Brima និងជនជាប់ចោទផ្សេងទៀត* (SCSL)") កថាខណ្ឌ ១២០ "ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍នឹងគាំទ្រដល់ការយល់ឃើញរបស់ចៅក្រមអន្តរជាតិសាលាដំបូង លើបញ្ហានៃភាពគួរឱ្យជឿទុកចិត្តបាន រួមទាំងសេចក្តីសម្រេចរបស់ចៅក្រមអន្តរជាតិសាលាដំបូងទៅលើភស្តុតាងដែលមិនស៊ីសង្វាក់គ្នា ហើយនឹងសម្រេចថា កំហុសអង្គហេតុបានកើតមានឡើង នៅពេលដែលខ្លួនយល់ឃើញថា ពុំមានតុលាការប្រកបដោយហេតុផលណាមួយអាចធ្វើការសម្រេចសេចក្តីវងការជំទាស់នេះ តែប៉ុណ្ណោះ")។ *សូមមើលផងដែរ* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ២៥៩, ២៦៣, ២៨២ (ដែលអនុវត្តបទដ្ឋាននៅក្នុងការវាយតម្លៃលើកំហុសអង្គច្បាប់ និងអង្គហេតុរួមគ្នា)។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ កថាខណ្ឌ ៣៨១។

[517] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ កថាខណ្ឌ ៣៨១។ *សូមមើលផងដែរ* សាលដីកា *Rutaganda* (ICTR) កថាខណ្ឌ ៤៤២។ តុលាការ ICTR រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Setako* សំណុំរឿងលេខ ICTR-04-81-A សាលដីកា ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ៣១។ *Popović និងជនជាប់ចោទផ្សេងទៀត* សាលដីកា (ICTY) កថាខណ្ឌ ១២២៨។

[518] *សូមមើល* ("សាលដីកាសំណុំរឿង ០០២/១ (F36)" កថាខណ្ឌ ១០១-១០២ (សម្រេចថា "ចៅក្រមអន្តរជាតិពុំធ្វើការពិចារណាលើអំណះអំណាងដែលគ្រាន់តែលើកឡើងថា សេចក្តីសម្រេច ឬសំអាងហេតុរបស់ចៅក្រមអន្តរជាតិសាលាដំបូងមានកំហុស ដោយពុំបានលើកមូលដ្ឋានគាំទ្រ ថាតើមូលហេតុអ្វីបានជាសេចក្តីសម្រេច ឬសំអាងហេតុនេះមានកំហុសនោះឡើយ"។

[519] ឧទាហរណ៍ ការដែលគ្រាន់តែអះអាងថា ភស្តុតាងផ្ទុយគ្នា ឬភស្តុតាងដោះបន្ទុកត្រូវបានច្រានចោល ដោយពុំមានការចង្អុលបង្ហាញឱ្យបានជាក់លាក់ ឬពុំមានការពន្យល់ប្រកបដោយអត្ថន័យឱ្យបានពេញលេញ ថាតើកំហុសណាមួយត្រូវបានប្រព្រឹត្តឡើង គឺប្រឈមនឹងការបដិសេធចោលភ្លាម។ ដូចគ្នានេះដែរ ការប្រើប្រាស់ភាសាទូទៅគ្រួតគ្នាដដែលៗ ឧទា. "ការ

នៃភាពមិនស៊ីសង្វាក់គ្នានៃភស្តុតាងនេះ ពុំតម្រូវឱ្យអ្នកវិនិច្ឆ័យសេចក្តីដោយឥតលម្អៀងបដិសេធសក្ខីកម្មនោះថាមិនអាចឱ្យជឿជាក់បាននោះទេ[520] ដោយហេតុថា អ្នកវិនិច្ឆ័យសេចក្តីលើអង្គហេតុអាច "ទទួលយកសក្ខីកម្មរបស់សាក្សីមួយផ្នែកប្រកបដោយហេតុផល ហើយបដិសេធផ្នែកដទៃទៀត" ក្រោយពីបានពិចារណាលើសក្ខីកម្មទាំងស្រុងរួចហើយនោះ[521]។

235. ដូចដែលចៅក្រមអន្តរជាតិបានសង្កត់ធ្ងន់ដដែលៗថា "ភស្តុតាងទាំងអស់សុទ្ធតែអាចទទួលយកបាន ហើយជាទូទៅទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បានតាមផ្លូវច្បាប់ដូចគ្នា" ហើយមានតែ "លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធតែមួយគត់ គួរតែជាឥទ្ធិពលដែលខ្លឹមសារនៃភស្តុតាងនោះអាចមានទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងបញ្ហាថា តើមានភស្តុតាងគ្រប់គ្រាន់ ឬអត់ សម្រាប់ការចោទប្រកាន់នោះ"[522]។ បញ្ហានេះត្រូវបានដោះស្រាយច្បាស់លាស់រួចមកហើយថា ភស្តុតាងចចាមអារ៉ាមអាចទទួលយកបាននៅចំពោះមុខនៅចំពោះមុខ អ.វ.ត.ក និងអាចយកមកសំអាងបាន[523]។ ដូចបានបញ្ជាក់ពីមុនរួចមកហើយថា សហចៅក្រម

---

ទាញសេចក្តីសន្និដ្ឋានខុសស្រឡះ" "បណ្តាលឱ្យមានភាពអយុត្តិធម៌" ឬ "ការរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួនមិនត្រឹមត្រូវ និងពុំសមហេតុផល" ពុំបង្ហាញពីកំហុសនៅក្នុងកម្រិតបណ្តឹងឧទ្ធរណ៍នេះទេ។

[520] សាលដីការឿងក្តី *Kupreškić* ( ICTY) កថាខណ្ឌ ៣១។ *សូមមើលផងដែរ* សាលដីការឿងក្តី *Rutaganda* (ICTR) កថាខណ្ឌ ៣៥៣ ("គួរត្រូវបានបញ្ជាក់ផងដែរថា ទាក់ទងនឹងការវាយតម្លៃលើភាពឱ្យជឿជាក់បានរបស់សាក្សី និងភាពអាចជឿទុកចិត្តបាននៃសក្ខីកម្ម ចៅក្រមអន្តរជាតិសាលាដំបូងអាចទទួលយកចម្លើយសាក្សីបាន ទោះបីជាមានចម្លើយផ្ទុយគ្នាក៏ដោយ"។

[521] រឿងក្តី *Popović និងជនជាប់ចោទផ្សេងទៀត* សាលដីកា (ICTY) កថាខណ្ឌ ១៣២។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/១ (F36) កថាខណ្ឌ ៣៥៧ ("ចៅក្រមអន្តរជាតិតុលាការកំពូលពិចារណាឃើញថា ផ្អែកលើកាលៈទេសៈនៃរឿងក្តីនេះ ជាទូទៅពុំមែនជាការមិនសមហេតុផលទេ ដែលចៅក្រមអន្តរជាតិសាលាដំបូងទទួលយកសក្ខីកម្មរបស់សាក្សីមួយផ្នែក ហើយបដិសេធផ្នែកដទៃទៀត")។ តុលាការ ICTR រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Muvunyi* សំណុំរឿងលេខ ICTR-2000-55A-A សាលដីកា ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៦។

[522] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥១-៥២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៧៦-៧៧។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (D266/27 & D267/35) មតិលោកចៅក្រម BEAUVALLET and BAIK កថាខណ្ឌ ១៥៥។

[523] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៤៤។ សាលដីកាសំណុំរឿង ០០២/១ (F36) កថាខណ្ឌ ៣០២។ *សូមមើលផងដែរ* តុលាការ ICTY រឿងក្តីរវាង *រដ្ឋអាជ្ញា* ***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

ស៊ើបអង្កេតអន្តរជាតិមាន "ឆន្ទានុសិទ្ធិទូលំទូលាយ" ក្នុងការសំអាងទៅលើភស្តុតាងចចាមអារ៉ាម[524]។ សម្រាប់ភស្តុតាងគ្រប់ទម្រង់ តម្លៃជាភស្តុតាងនៃពាក្យចចាមអារ៉ាមខុសៗគ្នាអាស្រ័យលើលក្ខណៈ និងខ្លឹមសាររបស់វា និងចុងក្រោយបំផុត គឺអាស្រ័យទៅតាម "កាលៈទេសៈផ្សេងៗដែលកើតមានជុំវិញភស្តុតាងចចាមអារ៉ាមនោះ"[525]។ លើសពីនេះទៀត ពុំមានលក្ខខណ្ឌច្បាប់ដែលកំណត់ថា ភស្តុតាងរបស់សាក្សីចំពោះអង្គហេតុជាសម្ភារៈ ត្រូវស៊ីសង្វាក់គ្នាជាមួយភស្តុតាងបានមកពីប្រភពផ្សេងទៀត នៅមុនដំណាក់កាលជំនុំជម្រះនោះទេ[526]។

---

*ទល់នឹង* *Aleksovski* សំណុំរឿងលេខ IT-95-14/1-A សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ស្តីពីភាពអាចទទួលយកបាននៃភស្តុតាង ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ ("សាលដីការឿងក្តី *Aleksovski* ស្តីពីភាពអាចទទួលយកបាននៃភស្តុតាងក្នុងបណ្តឹងឧទ្ធរណ៍ (ICTY)") កថាខណ្ឌ ១៥។ សាលដីការឿងក្តី *Rutaganda* (ICTR) កថាខណ្ឌ ៣៤, ១៤៨។ តុលាការ ICC *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាមានិតកុងហ្គោ នៅក្នុងរឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង* *Mathieu Ngudjolo* សំណុំរឿងលេខ ICC-01/04-02/12-3-tENG សាលក្រម អនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ អង្គជំនុំជម្រះសាលាដំបូង II សចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៥៦។

[524] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៤៣៣។ សាលដីកាសំណុំរឿង ០០២/១ (F36) កថាខណ្ឌ ៣០២។ *សូមមើលផងដែរ* រឿងក្តី *Popović និងជនជាប់ចោទផ្សេងទៀត* សាលដីកា (ICTY) កថាខណ្ឌ ១៣០៧។ សាលដីការឿងក្តី *Rutaganda* (ICTR) កថាខណ្ឌ៣៤។ តុលាការ ICTR រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង* *Karera* សំណុំរឿងលេខ ICTR-01-74-A សាលដីកា ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៩ ("សាកដីការឿងក្តី *Karera* (ICTR)") កថាខណ្ឌ ៣៩។

[525] សាលដីកាសំណុំរឿង ០០២/១ (F36) កថាខណ្ឌ ៣០២។ សាលដីការឿងក្តី *Aleksovski* ស្តីពីភាពអាចទទួលយកបាននៃភស្តុតាងក្នុងបណ្តឹងឧទ្ធរណ៍ (ICTY) កថាខណ្ឌ ១៥។ រឿងក្តី *Popović និងជនជាប់ចោទផ្សេងទៀត* សាលដីកា (ICTY) កថាខណ្ឌ ១៣០៧។ សាកដីការឿងក្តី *Karera* (ICTR) កថាខណ្ឌ ៣៩។ តុលាការ ICC *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាមានិតកុងហ្គោ នៅក្នុងរឿងក្តីរវាង រដ្ឋអាជ្ញា ទល់នឹង* *Germain Katanga* សំណុំរឿងលេខ ICC-01/04-01/07-3436-tENG សាលក្រមសម្រេចតាមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ចៅក្រមអន្តរជាតិសាលាដំបូង II ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៤ ("សាក្រមរឿងក្តី *Katang* (ICC) កថាខណ្ឌ ៨៩។

[526] វិធាន ៦៧ នៃវិធានផ្ទៃក្នុង ពុំតម្រូវឲ្យមានភាពស៊ីសង្វាក់គ្នានៃភស្តុតាង នៅក្នុងការចេញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៤២៦។ *សូមមើលផងដែរ* សាលដីកាសំណុំរឿង ០០២/១ (F36) កថាខណ្ឌ ៤២៤ ("ពុំមានវិធានទូទៅណាមួយចែងថា ប្រសិនបើពុំមានភស្តុតាងច្រើនគាំទ្រការយល់

236. ចៅក្រមអន្តរជាតិ ក៏បានរំឭកបន្ថែមឡើងវិញនូវ "គោលការណ៍សច្ចធារណ៍ ថា សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃគ្រប់ភស្តុតាងទាំងអស់ ហើយពុំចាំបាច់លើកឡើងគ្រប់ភស្តុតាងនៅក្នុងសំណុំរឿងនោះទេ ដរាបណាពុំមានការបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបានច្រានចោលទាំងស្រុងនូវគ្រប់ភស្តុតាងទាំងអស់នោះ។ សច្ចធារណ៍នេះអាចជំទាស់តវ៉ាបាន នៅពេលភស្តុតាងដែលពាក់ព័ន្ធយ៉ាងច្បាស់នឹងការរកឃើញ ពុំបានលើកឡើងនៅក្នុងសំអាងហេតុ"[527]។ នៅក្នុងការវាយតម្លៃលើការចោទប្រកាន់របស់សហមេធាវី ពាក់ព័ន្ធនឹងការខកខានពុំបានផ្តល់ការសម្រេចប្រកបដោយសំអាងហេតុ ឬការសម្រេចលើភស្តុតាង ដូចជា ថាតើ ជាទូទៅ សាក្សីមួយចំនួនគួរឲ្យជឿទុកចិត្តបាន និងអាចត្រូវបានយកមកសំអាងប្រកបដោយហេតុផលដែរឬយ៉ាងណានោះ ចៅក្រមអន្តរជាតិ នឹងអនុវត្តវិធីសាស្ត្រដែលស៊ីសង្វាក់គ្នានេះ។

237. ជាចុងក្រោយ ចៅក្រមអន្តរជាតិ សង្កេតឃើញថា សហមេធាវីហាក់ដូចជាភាន់ច្រឡំទៅលើបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលអាចអនុវត្តបាននៅដំណាក់កាលមុនការជំនុំជម្រះ ដោយមានការច្របូកច្របល់ទាំងមិនត្រឹមត្រូវ នូវភាសាដែលត្រូវបានប្រើប្រាស់ជាធម្មតា នៅដំណាក់កាលជំនុំជម្រះ ដើម្បីបកស្រាយពីបទដ្ឋានស្តីពីភស្តុតាងដែលចងកាតព្វកិច្ចសហចៅក្រមស៊ើបអង្កេត នៅក្នុងការចេញដីកាដំណោះស្រាយ។ នៅក្នុងការលើកឡើងនូវមូលដ្ឋានទី ៥ របស់ខ្លួនដែល

---

ឃើញទេ នោះការយល់ឃើញឲ្យហួសពីវិមតិសង្ស័យមួយ ពុំអាចធ្វើឡើងដោយសមហេតុផលបានឡើយ")។ សាលដីការឿងក្តី *Taylor* (SCSL) កថាខណ្ឌ ៧៥។ តុលាការ ICTR រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Nahimana និងជនជាប់ចោទផ្សេងទៀត* សំណុំរឿងលេខ ICTR-99-52-A សាលដីកា ចៅក្រមអន្តរជាតិតុលាការកំពូល ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ("សាលដីការឿងក្តី *Nahimana និងជនជាប់ចោទផ្សេងទៀត* (ICTR)") ជើងទំព័រ ១៣១២ (ប្រមូលចងក្រងសំណុំរឿងនៅតុលាការ ICTR និង ICTY ដែលសម្រេចសេចក្តីដូចគ្នា)។

[527] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣០៦។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៤៦៨។ *សូមមើលផងដែរ* រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Zigiranyirazo* សំណុំរឿងលេខ ICTR-01-73-A សាលដីកា ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៤៥។ រឿងក្តីរ*វាង រដ្ឋអាជ្ញា ទល់នឹង Perišić* សំណុំរឿងលេខ IT-04-81-A សាលដីកា ចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ ៩២។

01677190



អះអាងថា បទដ្ឋានគតិយុត្តិដែលមិនត្រឹមត្រូវមួយត្រូវបានអនុវត្តនោះ សហមេធាវីបានអះអាងជាច្រើនដងថា៖

- "[សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] ក៏ខកខានមិនបានផ្តល់ទស្សនៈដែលមានហេតុផល ថាតើមូលហេតុអ្វីបានជាគាត់យល់ឃើញថា ភស្តុតាងបែបនេះ ពុំមានអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផល អាចឈានទៅសន្និដ្ឋានផ្សេងណាមួយ ក្នុងការអនុវត្តបទដ្ឋាន "ភវនីយភាព"នេះ នោះ[528]។

- "[សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] ខកខានមិនបាន [...] ផ្តល់ហេតុផល ថាតើមូលហេតុអ្វីបានជាគាត់យល់ឃើញថា ភស្តុតាងដែលគាត់ពឹងផ្អែកមានលក្ខណៈគួរឱ្យជឿទុកចិត្តបាន រហូតដល់អ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផល អាចធ្វើការសន្និដ្ឋានផ្សេងក្រៅពីនេះនោះ។ ហេតុនេះ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយខកខានមិនបានអនុវត្តបទដ្ឋាន 'ភវនីយភាព'" នេះ[529]។

238. ចៅក្រមអន្តរជាតិ សូមរំឭកថា ចរិតលក្ខណៈនៃសេចក្តីសម្រេច និងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះប៉ះពាល់ដល់បទដ្ឋាននៃភស្តុតាងហើយ[530]។ វិធាន ៦៧ នៃវិធានផ្ទៃក្នុង ដែលគ្របដណ្តប់លើបទដ្ឋានបង្ហាញភស្តុតាង ដែលអាចអនុវត្តបាននៅដំណាក់កាលមុនការជំនុំជម្រះ បញ្ជាក់ថាលក្ខខណ្ឌសម្រាប់ការចេញដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបអង្កេត គឺជាអត្ថិភាពនៃ "ភស្តុតាងគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសជនត្រូវចោទ"។ ដោយសារបទដ្ឋាននេះមានការលំបាកក្នុងការកំណត់ពីសនិទានកម្មឱ្យបានច្បាស់លាស់ ចៅក្រមអន្តរជាតិបានកត់សម្គាល់ស្របគ្នាថា "បទដ្ឋានផ្លូវច្បាប់ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ចេញសេចក្តីសម្រេច វិវឌ្ឍន៍ជាបន្តបន្ទាប់នៅក្នុង

---

[528] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤០ (គូសបញ្ជាក់បន្ថែម)។

[529] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៨៨ (បញ្ជាក់បន្ថែមសេចក្តី)។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១៩៧ និង ២០២ ចំពោះការចោទប្រកាន់ក្នុងទម្រង់ប្រហាក់ប្រហែលគ្នានេះ។

[530] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៨៤។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៦១។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (D266/27 & D267/35) មតិយោបល់ចៅក្រម BEAUVALLET and BAIK កថាខណ្ឌ ១៦៣។

01677191



កិច្ចដំណើរការនីតិវិធីចាប់ពី "ត្រឹមលទ្ធភាព" ឈានទៅដល់ "ភវនីយភាព" ឬ "ភាពអាចឱ្យជឿជាក់បាន" នៃពិរុទ្ធភាពនៅក្នុងពេលស៊ើបអង្កេត ដើម្បីបង្ហាញភស្តុតាងនៃពិរុទ្ធភាពបែបនេះឱ្យហួសពីវិមតិសង្ស័យ នៅដំណាក់កាលជំនុំជម្រះ"[531]។

239. ការលើកឡើងរបស់សហមេធាវី ហាក់ដូចជាតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតបង្ហាញថា វាហួសពីវិមតិសង្ស័យហើយ ដែលភស្តុតាងនេះជៀសមិនរួចពីឈានដល់កម្រិតនៃភវនីយភាព ដោយការប្រមូលផ្តុំចំណុចទាំងឡាយស្តីពីបទដ្ឋាននៃភស្តុតាង ដែលអាចអនុវត្តបាននៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ/ឧទ្ធរណ៍ រួមទាំងការដែលអាចអនុវត្តបាននៅដំណាក់កាលមុនការជំនុំជម្រះ ដូច្នេះ បង្កើតបានជាប្រភេទបទដ្ឋាននៃភស្តុតាងរវើរវាយ។ ដូចបានរំឮកឡើងវិញនៅខាងលើ ស្រាប់ "លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធតែមួយគត់" គឺ "ជំនឿស្មោះត្រង់ពិតប្រាកដរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងបញ្ហាថាតើមានភស្តុតាងគ្រប់គ្រាន់សម្រាប់ការចោទប្រកាន់" ដែរឬអត់[532]។ អាស្រ័យហេតុនេះ ការលើកឡើងរបស់សហមេធាវីពាក់ព័ន្ធនឹងបញ្ហានេះត្រូវបានបដិសេធ[533]។

240. នៅពេលនេះ ចៅក្រមអន្តរជាតិ នឹងងាកទៅធ្វើការវាយតម្លៃលើមូលដ្ឋានរងផ្សេងៗ នៅក្នុងបណ្តឹងឧទ្ធរណ៍ដែលបានបែងចែកជាប្រភេទនៅក្រោមមូលដ្ឋានទី ៥ ដែលស្របជាមួយគោលការណ៍ស្តីពីភស្តុតាងសមស្រប និងបទដ្ឋាននៃការពិនិត្យឡើងវិញ ដូចបានលើកឡើងខាងលើ។

---

[531] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៨៥។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៦២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (D266/27 & D267/35)មតិយោបល់ចៅក្រម BEAUVALLET and BAIK កថាខណ្ឌ ១៦៥។

[532] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ (D308/3/1/20) កថាខណ្ឌ ៥១-៥២។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ (D359/24 & D360/33) កថាខណ្ឌ ៧៦-៧៧។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ (D266/27 & D267/35) មតិយោបល់ចៅក្រម BEAUVALLET and BAIK កថាខណ្ឌ ១៥៥។

[533] ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាង "ភវនីយភាព" នៅក្នុងដីកាដំណោះស្រាយរបស់គាត់។ *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ២៥។

## មូលដ្ឋានទី ៥.១ ÷ ការចោទប្រកាន់អំពីកំហុសក្នុងការសន្និដ្ឋានថា ទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយនឹង តាម៉ុក មានន័យស្មើនឹងសិទ្ធិអំណាច*តាមព្រឹត្តន័យ* នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ

### ១. សារណា

241. នៅក្នុងមូលដ្ឋានទី ៥.១ សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រព្រឹត្តកំហុសក្នុងការសន្និដ្ឋានថា ទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយនឹង តាម៉ុក មានន័យស្មើនឹងសិទ្ធិអំណាច*តាមព្រឹត្តន័យ*របស់គាត់នៅក្នុងភូមិភាគពាយ័ព្យ និងភូមិភាគនិរតី ហើយគាត់ស្ថិតក្នុងចំណោមអ្នកដែល "ទទួលខុសត្រូវខ្ពស់បំផុត"[534]។

242. ទីមួយ សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបាន "បង្ហាញហួសហេតុ" ពីទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយនឹង តាម៉ុក ដើម្បីសន្និដ្ឋានថា យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ* ក្នុងតំបន់ ១៣ នៃភូមិភាគនិរតី[535]។ សហមេធាវីលើកឡើងថា ការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភស្តុតាងរបស់សាក្សី ក្នុងការបង្ហាញពីទំនាក់ទំនងជិតស្និទ្ធរវាង យឹម ទិត្យ និងតាម៉ុក គឺ "មិនមានភាពពាក់ព័ន្ធ" សម្រាប់ការវាយតម្លៃលើសិទ្ធិអំណាច*តាមព្រឹត្តន័យ* និងការបញ្ជា និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពរបស់គាត់ឡើយ[536]។ ក្រៅពីនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន ដោយពឹងផ្អែកមិនត្រឹមត្រូវ និងមិនសមហេតុផលលើផ្នែកផ្សេងៗនៃភស្តុតាង ខណៈដែលមិនយកចិត្តទុកដាក់លើផ្នែកផ្សេងៗនៃភស្តុតាងដែលមានលក្ខណៈផ្ទុយទៅនឹងសំអាងហេតុរបស់ខ្លួន
ដូចដែលបានបង្ហាញឡើងតាមរយៈ "ឧទាហរណ៍ល្អ" ដោយ រៀល សន, សាន់ ឡូន និង ណុប ងឹម[537]។

---

[534] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១២៤-១៥១។

[535] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១២៤។

[536] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១២៥។

[537] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១២៦ *ដែលយោងទៅ* ភស្តុតាងដែលរងការចោទប្រកាន់ថាផ្ទុយគ្នាទៅនឹងការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្តីពី "ទំនាក់ទំនងជិតស្និទ្ធ" រវាង តា ម៉ុក និង យឹម ទិត្យ ដោយផ្អែកតាម រៀល សន (ដែលលើកឡើងថា គាត់ពុំមានទំនាក់ទំនងជាមួយ យឹម ទិត្យ

243. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាសមស្របលើភ័ស្តុតាងរបស់សាក្សី ចាន់ វិចិត្រ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ យឹម ទិត្យ ក្នុងខេត្តតាកែវ និងជាពិសេស សក្ខីកម្មដែលសហមេធាវីលើកឡើង គឺមានភាពផ្ទុយគ្នាខាងពេលវេលាទៅនឹងភ័ស្តុតាងរបស់ ជាប់ សៅ[538]។ ជាពិសេស យោងតាមសហមេធាវី ចាន់ វិចិត្រ បានឃើញ យឹម ទិត្យ សឹងតែរាល់ថ្ងៃ ពីខែមេសា ដល់ខែកក្កដា ឆ្នាំ១៩៧៧ ក្នុងខេត្តតាកែវ ដែលនេះជាពេលវេលាតែមួយដែល ជាប់ សៅ លើកឡើងថាបានឃើញ យឹម ទិត្យ ធ្វើដំណើរពេញភូមិភាគពាយ័ព្យជាមួយតាម៉ុក[539]។ លើសពីនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាពីភ័ស្តុតាងផ្ទុយគ្នារបស់ ចាន់ វិចិត្រ និងអំណះអំណាងបញ្ជាក់ដែលពាក់ព័ន្ធនឹងឋានៈរបស់ យឹម ទិត្យ ជា "ជនទទួលខុសត្រូវខ្ពស់បំផុត"[540]។ ក្រៅពីនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបកស្រាយខុសលើភ័ស្តុតាង និងខកខានមិនបានពិចារណាលើភ័ស្តុតាងដោះបន្ទុកពី ចាន់ វិចិត្រ សម្រាប់ការសន្និដ្ឋានរបស់ខ្លួនដែលថា យឹម ទិត្យ បានចូលរួមប្រជុំជាមួយតំណាងគណៈស្រុកនៅមន្ទីរភូមិភាគនិរតី និងថា យឹម ទិត្យ បានបញ្ជាឱ្យគេអនុវត្តភារកិច្ច និងត្រួតពិនិត្យការដ្ឋានទូទាំងភូមិភាគ[541]។

---

ឡើយ ប៉ុន្តែបានជឿថា យឹម ទិត្យ បានធ្វើការនៅមន្ទីរមួយជាមួយ ប៉ុល ពត ហើយ យឹម ទិត្យ មិនសកម្មណាស់ណាទេ) សាន់ ឡូន (ដែលលើកឡើងជាច្រើនលើកច្រើនសាថា គាត់មិនដឹងអ្វីទាំងអស់អំពីទំនាក់ទំនងរបស់ តាម៉ុក ជាមួយ យឹម ទិត្យ) និង ណុប ង៉ឹម (ដែលមិនបានដឹងពីមុខតំណែងរបស់ យឹម ទិត្យ នៅក្នុងភូមភាគនិរតី)។

538 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១២៧។

539 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១២៩។

540 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៣០-១៣១ (សហមេធាវីលើកឡើងពីភ័ស្តុតាងរបស់ ចាន់ វិចិត្រ ដែលថា ៖ (១) គាត់មិនបានដឹងថា តាទិត្យ និងតាម៉ុក ជាសាច់ញាតិនឹងគ្នា និងត្រូវជាអ្វីនឹងគ្នា (២) យឹម ទិត្យ បានក្លាយជាតំណាងរបស់ តាម៉ុក លើបញ្ហាយោធាតែប៉ុណ្ណោះក្រោយពេលសង្គ្រាមចប់ទៅ (៣) ការទទួលខុសត្រូវរបស់ យឹម ទិត្យ មិននៅរងដែល (៤) យឹម ទិត្យ មិនមែនជាលេខាស្រុកទេ ប៉ុន្តែជាតំណាងឱ្យតាម៉ុកម្តងម្កាល ឬមួយភ្លែតៗតែប៉ុណ្ណោះ (៥) យឹម ទិត្យ ពុំមានតំណែងផ្លូវការទេ និង (៦) យឹម ទិត្យ មិនធ្វើការលើបញ្ហាយោធាទេ គាត់នៅជាមួយ "មូលដ្ឋាន"។ សហមេធាវីចោទប្រកាន់បន្ថែមទៀតថា ភ័ស្តុតាងនេះត្រូវបានបញ្ជាក់បន្ថែមដោយ វណ្ណ កុសល ដែលលើកឡើងថាគាត់លឺថា យឹម ទិត្យ ធ្វើការ "នៅមូលដ្ឋាន")។

541 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៣២-១៣៣។

244. ក្រៅពីនេះ សហាមេធាវីក៏ជំទាស់ផងដែរទៅនឹងការពឹងផ្អែកលើការសង្កេតរបស់ ម៉ឹង វ៉េត ដែលថា យឹម ទិត្យ មានអំណាចជាងតាផែន (ដែលត្រូវបានចោទប្រកាន់ថាជាអនុលេខាតំបន់ ១៣) ដោយសារអាយុរបស់គាត់ និងទំនាក់ទំនងសាច់ញាតិជាមួយតាម៉ុក ក្នុងផ្នែកមួយនៃការសន្និដ្ឋានថា យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ*នៅក្នុងតំបន់ ១៣[542]។ ចុងបញ្ចប់ សហាមេធាវីលើកឡើងថា គ្មានសាក្សីណាម្នាក់ដែលសហចៅក្រមស៊ើបអង្កេតយកជាសំអាង បានផ្តល់ភស្តុតាងបញ្ជាក់ពីសិទ្ធិអំណាច*តាមនីតិន័យ* និង*តាមព្រឹត្តន័យ* ត្រួតត្រារបស់ យឹម ទិត្យ ទាំងនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ *ក្រោយ*ខែមិថុនា ឆ្នាំ១៩៧៨ ឡើយ[543]។

245. ជារួម សហាមេធាវីបានលើកឡើងជាច្រើនលើកច្រើនសាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានបង្ហាញថា ទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយនឹង តាម៉ុក មានន័យស្មើនឹងសិទ្ធិអំណាច*តាមព្រឹត្តន័យ*របស់ យឹម ទិត្យ នៅក្នុងតំបន់ ១៣ ឬថា យឹម ទិត្យ គឺជាអនុរបស់តាម៉ុកនៅក្នុងភូមិភាគទាំងពីរ។ សហាមេធាវីអះអាងថាករណីយុត្តិសាស្ត្ររបស់ អ.វ.ត.ក ឬសាលាក្តីអន្តរជាតិដទៃទៀត មិនបានបង្ហាញថា ចំណងសាច់ញាតិ គឺជាការចង្អុលបង្ហាញអំពីការបញ្ជា និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពឡើយ[544]។ សហាមេធាវីអះអាងថា លក្ខណវិនិច្ឆ័យនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពគឺភាពជាម្ចាស់ជាក់ស្តែងនៃអំណាចការគ្រប់គ្រងលើសកម្មភាពរបស់អ្នកនៅក្រោមបង្គាប់ និងអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានបង្ហាញថា យឹម ទិត្យ "មានអំណាចគ្រប់គ្រងលើសកម្មភាពរបស់បុគ្គលសូម្បីតែម្នាក់"[545]។ សហាមេធាវីសន្និដ្ឋានថា "ការមមៃ" របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅនឹងទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយ តាម៉ុក បាននាំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានពិចារណាពីភស្តុតាងដោះបន្ទុក ការពិចារណាដែលមានភាពពាក់ព័ន្ធផ្លូវច្បាប់ និងភស្តុតាងដោះបន្ទុក ក្នុងចំណោមកំហុសផ្នែកភស្តុតាងផ្សេងៗទៀត[546]។

---

[542] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៣៤។

[543] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៣៥-១៣៦ (ការគូសបញ្ជាក់បន្ថែម) (ដែលជំទាស់ទៅនឹងភស្តុតាងរបស់ សាន់ ឡុន, ពេជ្រ ជឹម, សឹម ឈឿន, ប៉ាន់ សារូ និង ហ៊ុយ ក្រឹម)។

[544] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៣៧។

[545] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៣៨-១៣៩។

[546] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៤០។

01677195



246. ជាការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា មូលដ្ឋានទី ៥.១ មិនបានបង្ហាញកំហុសអង្គច្បាប់ ឬកំហុសអង្គហេតុដែលអាចពិនិត្យឡើងវិញបានក្នុងការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ* នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ និងថា យឹម ទិត្យ ស្ថិតក្នុងចំណោមអ្នកដែល "ទទួលខុសត្រូវខ្ពស់បំផុត"[547]។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ *មិនបាន* សន្និដ្ឋានថា យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ*នៅក្នុងភូមិភាគទាំងពីរ ដោយផ្អែកតែលើទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយតាម៉ុក ឡើយ[548]។

247. សហព្រះរាជអាជ្ញាអន្តរជាតិ បានបង្ហាញការជំទាស់លម្អិតទៅនឹងការជំទាស់តវ៉ារបស់សហមេធាវីលើសក្ខីកម្មរបស់សាក្សី ដោយលើកឡើងថា (១) រៀល សន បានឃើញ យឹម ទិត្យ នៅមន្ទីរពាណិជ្ជកម្មតំបន់ និងធ្វើដំណើរជាមួយតាម៉ុក[549] (២) សាន់ ឡួន ជាប់សាច់ញាតិជាមួយ យឹម ទិត្យ និងបានរ៉ាយរ៉ាប់ពីតួនាទីរបស់ យឹម ទិត្យ ក្នុងនាមជាលេខាតំបន់ ១៣ និងទំនាក់ទំនងការងារជិតស្និទ្ធរបស់ យឹម ទិត្យ ជាមួយតាម៉ុក[550] និង (៣) ណុប ង៉ឹម បានរៀបរាប់ថា យឹម ទិត្យ គឺជាមេដឹកនាំម្នាក់នៅក្នុងភូមិភាគនិរតី តាម៉ុកមានឋានៈធំជាង យឹម ទិត្យ និងថា យឹម ទិត្យ និងតាម៉ុក បានចូលរួមក្នុងពិធីរៀបការដែលគេបង្ខំគាត់ឱ្យរៀបការជាមួយ យឹម ទិត្យ និងកិច្ចប្រជុំផ្សេងៗជាមួយគ្នា[551]។ ក្រៅពីនេះ សហមេធាវី ខកខានមិនបានបង្ហាញកំហុសណាមួយនៅក្នុងការពឹងផ្អែកលើសក្ខីកម្មរបស់ ចាន់ វិចិត្រ[552] ដោយ (១) អះអាងមិនត្រឹមត្រូវថា ភ័ស្តុតាងរបស់ ចាន់ វិចិត្រ ដែលពាក់ព័ន្ធនឹង យឹម ទិត្យ នៅក្នុងភូមិភាគនិរតី ទាក់ទិននឹងរយៈពេលចាប់ពីខែមេសាដល់ខែកក្កដា ឆ្នាំ១៩៧៧ ដែលពាក់ព័ន្ធនឹងរយៈពេល ៤ ខែ នៅឆ្នាំ១៩៧៥[553] (២) ការកំណត់ដោយ

---

[547] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៦៦។

[548] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៦៧។

[549] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៦៨។

[550] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៦៩។

[551] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧០។

[552] ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិដាក់សារណាទាំងនេះក្នុងផ្នែកផ្សេងទៀតនៃចម្លើយតបរបស់គាត់ ការលើកឡើងពីសារណាទាំងនេះក្នុងផ្នែកមួយនៃមូលដ្ឋានទី ៥.១ គឺជារឿងងាយស្រួល។

[553] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៩៧។

ភាន់ច្រឡំថាភ័ស្តុតាងរបស់ ចាន់ វិចិត្រ ជាភ័ស្តុតាងដោះបន្ទុក[554] និង (៣) ការខកខានមិនបានបង្ហាញថា ភ័ស្តុតាងរបស់ ចាន់ វិចិត្រ មិនត្រូវបានយកមកពិចារណា ឬផ្ទុយគ្នា[555]។ សម្រាប់សហព្រះរាជអាជ្ញាអន្តរជាតិ អំណះអំណាងរបស់ ចាន់ វិចិត្រ ដែលពាក់ព័ន្ធនឹងតួនាទី និងសិទ្ធិអំណាចរបស់ យឹម ទិត្យ នៅក្នុងភូមិភាគនិរតី គឺច្បាស់លាស់ និងស៊ីសង្វាក់គ្នា ដោយគាំទ្រយ៉ាងខ្លាំងចំពោះសិទ្ធិអំណាច*តាមព្រឹត្តន័យ*យ៉ាងសំខាន់[556]។

248. យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមែនគ្រាន់តែយកអំពើរបស់តាម៉ុក មកទម្លាក់លើ យឹម ទិត្យ នោះទេ។ ផ្ទុយទៅវិញ វត្តមានរបស់ យឹម ទិត្យ នៅកៀកជាប់នឹង តាម៉ុក ក្នុងពេលប្រជុំនៅតំបន់ ១ បង្ហាញអំពី "ការជាប់ពាក់ព័ន្ធ និងការយល់ព្រមរបស់ យឹម ទិត្យ លើគោលនយោបាយដែលបានពិភាក្សា និងអនុវត្ត"[557]។ លើសពីនេះ ពុំមានការយោងណាមួយទៅដល់ទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយតាម៉ុក ក្នុងការសន្និដ្ឋានថា យឹម ទិត្យ ជាលេខាតំបន់ ៣ ឡើយ[558]។

249. ពាក់ព័ន្ធនឹងការសន្និដ្ឋានថា យឹម ទិត្យ មានសិទ្ធិអំណាចត្រួតគ្នានៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យស្រដៀងគ្នានឹងតាម៉ុកដែរនោះ[559] សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា (១) សាន់ ឡូន បានដឹងថា យឹម ទិត្យ ធ្វើដំណើរពីភូមិភាគមួយទៅភូមិភាគមួយ ពីព្រោះ សាន់ ឡូន ត្រូវបាន តាម៉ុក ប្រាប់ដោយផ្ទាល់[560] (២) ពេជ្រ ជឹម មិន "ប្តូរភ័ស្តុតាងរបស់គាត់ឡើយ" ដែលលើវិទ្យុផ្សាយនៅចុងឆ្នាំ១៩៧៨ ថា យឹម ទិត្យ ទទួលស្វាគមន៍ភ្ញៀវនៅមន្ទីរតំបន់ ១៣[561] (៣) ប៉ាន់ សារ៉ូ មិន "ប្តូរសក្ខីកម្មរបស់គាត់ទេ" អំពីមុខតំណែងរបស់ យឹម ទិត្យ នៅក្នុងស្រុកគិរីវង់ និងត្រូវបានដំឡើង

[554] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៩៨។
[555] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៦៣។
[556] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៦៣-១៦៥។
[557] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧១។
[558] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧១។
[559] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧២។
[560] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧៣។
[561] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧៤។

ឋានៈនៅរដ្ឋសភា[562] (៤) សឹម ឈឿន អះអាងថា គាត់ស្គាល់ថា យឹម ទិត្យ គឺជាប្រធានស្រុកគិរីវង់ រហូតទាល់តែចុងបញ្ចប់នៃរបបខ្មែរក្រហម[563] និង (៥) ភ័ស្តុតាងរបស់ ហ៊ុយ ក្រឹម មិនពាក់ព័ន្ធនឹងពេលវេលា ឬមានកម្រិតត្រឹមតែឆ្នាំ១៩៧៦ ឬ១៩៧៧[564]។

250. ជារួម សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងដដែលៗថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានសន្និដ្ឋានថា សិទ្ធិអំណាច*តាមព្រឹត្តន័យ* របស់ យឹម ទិត្យ ត្រូវបានបង្ហាញតែតាមរយៈចំណងសាច់ញាតិជាមួយ តាម៉ុក ប៉ុណ្ណោះ។ ផ្ទុយទៅវិញ អំពើ និងការប្រព្រឹត្តរបស់ យឹម ទិត្យ គឺជាមូលដ្ឋាននៃការចោទប្រកាន់លើរូបគាត់[565] ដែលផ្អែកលើភ័ស្តុតាងគ្រប់គ្រាន់របស់ យឹម ទិត្យ ដែលគ្រប់គ្រងលើថ្នាក់ក្រោមរបស់គាត់ទាំងក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ[566]។

## ២.ការពិភាក្សា

251. មូលដ្ឋានទី ៥.១ លើកឡើងពីទឡ្ហីករណ៍ប្រទាក់ក្រឡាគ្នាផ្សេងៗ ពាក់ព័ន្ធនឹងទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយនឹង តាម៉ុក ដែលទឡ្ហីករណ៍ខ្លះមានលក្ខណៈជាអង្គហេតុ និងទឡ្ហីករណ៍ខ្លះទៀតមានលក្ខណៈជាអង្គច្បាប់ និងភាគច្រើនពាក់ព័ន្ធនឹងតំបន់ ១៣ នៃភូមិភាគនិរតី។ ចៅក្រមអន្តរជាតិយល់ថា ដំបូង គួរដោះស្រាយទៅលើបញ្ហាផ្លូវច្បាប់ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ។ បន្ទាប់មកទៀត ចៅក្រមអន្តរជាតិនឹងពិនិត្យទៅលើការជំទាស់លើភ័ស្តុតាងអង្គហេតុរបស់សហមេធាវី ចំពោះសាក្សីមួយចំនួនដែលបញ្ជាក់ពី (១) សិទ្ធិអំណាច*តាមព្រឹត្តន័យ* របស់ យឹម ទិត្យ នៅក្នុងតំបន់ ១៣ និង (២) សិទ្ធិអំណាច និងការទទួលខុសត្រូវត្រួតត្រារបស់ យឹម ទិត្យ ទាំងនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។

252. ដំបូង ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហមេធាវីមិនជំទាស់ទៅនឹងអត្ថិភាពនៃទំនាក់ទំនងសាច់ញាតិជាក់ស្តែងរវាង យឹម ទិត្យ និង តាម៉ុក ឡើយ។ ផ្ទុយទៅវិញ សហមេធាវីបានជំទាស់ទៅនឹងអ្វីដែលពួកគេចាត់ទុកជាការដាក់ទម្ងន់ហួសហេតុ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ

---

[562] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧៥។
[563] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧៦។
[564] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧៧។
[565] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧៩។
[566] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ៧៨។

លើទំនាក់ទំនងសាច់ញាតិនេះ តាមរយៈការចាត់ទុកទំនាក់ទំនងនេះថា មានន័យស្មើនឹងការសន្និដ្ឋានពីសិទ្ធិអំណាច*តាមព្រឹត្តន័យ*នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ[567]។ ពាក់ព័ន្ធនឹងចំណុចនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា (១) តាម៉ុក "មានតួនាទីជាន់ខ្ពស់ជាច្រើននៅក្នុងកម្ពុជាប្រជាធិបតេយ្យ រួមទាំងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ (នៃ ប.ក.ក) ព្រមទាំងលេខភូមិភាគនិរតី លេខាភូមិភាគពាយ័ព្យ និងលេខាភូមិភាគបស្ចិម"[568] និងថា (២) នៅមុនពេលចាប់ផ្តើមរបបកម្ពុជាប្រជាធិបតេយ្យ យឹម ទិត្យ បានរៀបការជាមួយប្អូនស្រីរបស់ តាម៉ុក[569]។ ចៅក្រមអន្តរជាតិយល់ថា គ្មានហេតុផលដែលត្រូវដេញដោលទៅលើការសន្និដ្ឋានទាំងនេះឡើយ ហើយភាគីពាក់ព័ន្ធក៏មិនជំទាស់ទៅនឹងការសន្និដ្ឋានទាំងនេះដែរ។ ដូច្នេះ ចៅក្រមអន្តរជាតិកំណត់ថា អង្គហេតុទាំងនេះយកជាការបាន។

253. ចៅក្រមអន្តរជាតិយល់ថា ជាបញ្ហាអង្គច្បាប់ អ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផល អាចសន្និដ្ឋានថា ទំនាក់ទំនងផ្ទាល់ខ្លួនជិតស្និទ្ធ ផ្តល់នូវបរិបទបញ្ជាក់បន្ថែមដែលគាំទ្រដល់ភស្តុតាងផ្សេងទៀតដែលបង្ហាញពីការប្រើប្រាស់សិទ្ធិអំណាចរបស់បុគ្គលម្នាក់។ សម្រាប់គោលបំណងនៃការវាយតម្លៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ការចោទសួរពាក់ព័ន្ធគឺថា តើបុគ្គលនោះស្ថិតក្នុងចំណោម "បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត" ដែរឬទេ ដែល "តម្រូវឱ្យមានការវាយតម្លៃទៅតាមករណីជាក់ស្តែងនីមួយៗ ដោយពិចារណាទៅលើបរិបទទូទៅ និងកាលៈទេសៈផ្ទាល់ខ្លួនរបស់ជនសង្ស័យ"[570]។ ចៅក្រមអន្តរជាតិពិចារណាថា ជាបញ្ហាអង្គហេតុ ចំណុចនេះអាច

---

[567] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១២៤, ១៣៧, ១៤១។

[568] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៥៨ និងជើងទំព័រ ៣៣៥ (ដែលដកស្រង់ភស្តុតាងគាំទ្រ)។

[569] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣២៥ និងជើងទំព័រ ៨៥៧-៨៥៨ (ដែលដកស្រង់ភស្តុតាងគាំទ្រ)។

[570] *សូមមើល* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D308/3/1/20 យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១ (ដែលលើកឡើងថា ការកំណត់អត្តសញ្ញាណបុគ្គលដែលស្ថិតក្នុងចំណោម "បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត" ពាក់ព័ន្ធនឹងការវាយតម្លៃបែបបរិមាណវិស័យ និងគុណវិស័យលើ (១) ភាពធ្ងន់ធ្ងររបស់ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និង (២) កម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ និងថាពុំមានបញ្ជីជាក់លាក់ស្តីអំពីកត្តានានាដែលត្រូវយកមកពិចារណាក្នុងការពិនិត្យទៅលើចំណុចនេះទេ ហើយក៏ពុំមានបទដ្ឋានកំហិតអំពីតួនាទីនៅក្នុងឋានានុក្រមដែរ)។ *សូមមើលផងដែរ* កថាខណ្ឌ ៣២៧-៣៣៨។

បង្ហាញតាមរយៈភស្តុតាងដែលបញ្ជាក់ថា ទំនាក់ទំនងសាច់ញាតិ បានបន្ថែម ឬជួយសម្រួលដល់ការអនុវត្តការទទួលខុសត្រូវរបស់ជនសង្ស័យ[571]។ ដូច្នេះ ចៅក្រមអន្តរជាតិសូមច្រានចោលទឡ្ហីករណ៍របស់សហមេធាវីដែលថា ភស្តុតាង*ក្នុងចំណោមបញ្ហាផ្សេងទៀត*ដែលបញ្ជាក់ថា តាម៉ុក និង យឹម ទិត្យ ធ្វើដំណើរជាមួយគ្នាពាសពេញភូមិភាគនិរតីដើម្បីត្រួតពិនិត្យការដ្ឋាន និងត្រូវបានគេឃើញចូលរួមកិច្ចប្រជុំជាមួយគ្នា បង្កើតបានជា "កត្តាមិនពាក់ព័ន្ធ"[572] ដោយពិចារណាថាភស្តុតាងទាំងនេះផ្អែកដោយផ្ទាល់លើការវាយតម្លៃថាតើ យឹម ទិត្យ ផ្ទាល់បានប្រើប្រាស់សិទ្ធិអំណាច និងការគ្រប់គ្រងក្នុងការអនុវត្តជាក់ស្តែង ក្នុងតំបន់ពាក់ព័ន្ធ ឬទេ[573]។

*ក.សិទ្ធិអំណាចតាមព្រឹត្តន័យរបស់ យឹម ទិត្យ នៅក្នុងតំបន់ ១៣*

254. សម្រាប់ការអះអាងរបស់សហមេធាវីពាក់ព័ន្ធនឹងតំបន់ ១៣ នៃភូមិភាគនិរតី ចៅក្រមអន្តរជាតិមិនជឿជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិឈានដល់ការសន្និដ្ឋានពាក់ព័ន្ធនឹងសិទ្ធិអំណាច *តាមព្រឹត្តន័យ* របស់ យឹម ទិត្យ ក្នុងតំបន់នោះ ដោយផ្អែកទាំងស្រុងតែលើទំនាក់ទំនងសាច់ញាតិរបស់បុរសទាំងពីរនាក់នេះឡើយ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានគូសបញ្ជាក់ថា "ដោយសារទំនាក់ទំនងសាច់ញាតិ *និងទំនាក់ទំនងការងារជិតស្និទ្ធរបស់ យឹម ទិត្យ ជាមួយ តាម៉ុក ដែលពួកគាត់ទាំងពីរមានជាមួយគ្នានៅក្នុងភូមិភាគនិរតី* [...] ទើបធ្វើឱ្យ យឹម ទិត្យ មានសិទ្ធិអំណាចជាក់ស្តែងបន្ថែមច្រើននៅក្នុងភូមិភាគនិរតី ដែលពង្រីកសិទ្ធិអំណាច

---

[571] *សូមមើល* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D308/3/1/20 យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៣៧។

[572] *ផ្ទុយនឹង* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១២៥, ១២៦។

[573] ចៅក្រមអន្តរជាតិបានធ្វើការបដិសេធយ៉ាងខ្លីនូវទឡ្ហីករណ៍របស់សហមេធាវី ពាក់ព័ន្ធនឹងច្បាប់សម្រាប់អនុវត្តលើការទទួលខុសត្រូវរបស់បញ្ជាការ និងសូចនាករនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព ដែលត្រូវបានកំណត់រួចជាស្រេចថាមិនអាចទទួលយកបានក្រោមមូលដ្ឋានទី ២.៣។ *ផ្ទុយនឹង* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៣៨។ ក្រៅពីនេះ ចៅក្រមអន្តរជាតិ បានធ្វើការច្រានចោលភ្លាមៗនូវការចោទប្រកាន់គ្មានមូលដ្ឋានដូចមានបង្ហាញក្នុងកថាខណ្ឌ ១៣៩-១៤០ នៃបណ្តឹងឧទ្ធរណ៍នេះ។ *សូមមើល* សំណុំរឿង ០០២/០១ សាលដីកា ឯកសារ F36 កថាខណ្ឌ ១០១-១០២ (ដែលសម្រេចថា ចៅក្រមអន្តរជាតិ ពុំធ្វើការពិចារណាលើ "អំណះអំណាងដែលគ្រាន់តែលើកឡើងថាសេចក្តីសម្រេច ឬសំអាងហេតុរបស់ចៅក្រមអន្តរជាតិសាលាដំបូងមានកំហុសដោយពុំបានលើកមូលដ្ឋានគាំទ្រថាតើហេតុអ្វីបានជាសេចក្តីសម្រេច ឬសំអាងហេតុនេះ មានកំហុស")។

01677200



ដែលគាត់មាន តាមរយៈការកាន់តំណែងផ្លូវការជាក់លាក់ខ្លះ"[574]។ ចំណុចដែលពាក់ព័ន្ធបំផុតគឺ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់ ភ័ស្តុតាងដែលថា បុរសទាំងពីរនាក់នេះធ្វើការ និងចូលរួមការប្រជុំជាមួយគ្នា មន្ទីររបស់ពួកគេគឺនៅក្បែរគ្នា ហើយពួកគេរស់នៅជាមួយគ្នា នៅក្នុងបរិវេណមួយយ៉ាងធំជាទីកន្លែងដែលប្រើប្រាស់ដើម្បីទទួលភ្ញៀវ និងរៀបចំការប្រជុំ[575]។ ចៅក្រមអន្តរជាតិមិនឃើញមានកំហុសឡើយ ក្នុងការផ្តោតសំខាន់ដំណាលគ្នារបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយ តាម៉ុក បូករួមនឹងភ័ស្តុតាងដែលបញ្ជាក់ថា ពួកគេទាំងពីរនាក់បានធ្វើការនៅក្បែរគ្នាដើម្បីបំពេញ ការទទួលខុសត្រូវលើការងារក្នុងតំបន់។

255. លើសពីនេះទៀត ចៅក្រមអន្តរជាតិមិនជឿជាក់ឡើយ តាមរយៈឧទាហរណ៍ជាក់លាក់របស់ សហមេធាវី ដែលភ័ស្តុតាងផ្ទុយគ្នាត្រូវបានសន្និដ្ឋានថាមិនបានយកមកពិចារណា[576]។ ទីមួយ ពាក់ព័ន្ធនឹង រៀល សន (កម្មាភិបាលថ្នាក់ស្រុក) ខណៈដែលគាត់គ្មាន "ទំនាក់ទំនងផ្ទាល់ខ្លួន" ជាមួយ យឹម ទិត្យ ក្នុងរបប ក.ប.ធ សាក្សីរូបនេះបានពន្យល់ថា គាត់ "បានឃើញ" យឹម ទិត្យ នៅពេលដែលគាត់ទៅបើកសម្ភារៈនៅមន្ទីរពាណិជ្ជកម្មតំបន់ក្នុងខេត្តតាកែវ (ទោះបីជាពួកគេ "ពុំដែលបាននិយាយគ្នា" ក៏ដោយ)[577]។ លើសពីនេះ រៀល សន បានឃើញ យឹម ទិត្យ និងតាម៉ុក ធ្វើដំណើរជាមួយគ្នា "ម្តងម្កាល"[578]។ ទីពីរ ទោះបីជា សាន់ ឡុន (អតីតកម្មា ភិបាល ប.ក.ក) ពីដំបូងបានបដិសេធថាមិនបានដឹងអ្វីអំពី យឹម ទិត្យ ក្តី ក៏វាជារឿងយុត្តិធម៌ ឬសមហេតុផល ក្នុងការផ្អែកលើភ័ស្តុតាងរបស់ សាន់ ឡុន ស្តីពីទំនាក់ទំនងការងារជិតស្និទ្ធរបស់បុរសទាំងពីរនាក់

---

[574] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣២៧ (ការគូសបញ្ជាក់បន្ថែម)។

[575] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៥៩។

[576] *ផ្ទុយនឹង* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១២៦។

[577] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ D118/181 ERN 00975630-00975631 (ឆ.៧២, ឆ.៧៧-ឆ.៨០)។

[578] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ D118/181 ERN 00975631 (ឆ.៨៩)។

នេះ[579] ដោយពិចារណាពីការទទួលស្គាល់ដោយ សាន់ ឡូន ថា គាត់ពិតជាមានទំនាក់ទំនងជាមួយ យឹម ទិត្យ និងតាម៉ុក តាមរយៈប្រពន្ធរបស់ តាម៉ុកដែលជាបងស្រីរបស់សាក្សីរូបនេះ[580]។ ទីបី ពាក់ព័ន្ធនឹង ណុប ធឹម (អនុលេខាស្រុកសំឡូត) ទោះបីជាគាត់មិនអាចចងចាំពីតំណែងជាក់លាក់របស់ យឹម ទិត្យ ឬព័ត៌មានលម្អិតស្តីពីរចនាសម្ព័ន្ធនៃភូមិភាគនិរតីក្តី (ទោះបីជាអង្គជំនុំជម្រះកត់សម្គាល់ថា ណុប ធឹម អាចបញ្ជាក់ថា យឹម ទិត្យ គឺជា "មេដឹកនាំម្នាក់ក្នុងចំណោមអ្នកដឹកនាំនៅភូមិភាគនិរតី" ក្តី)[581] ក៏ចំណុចនេះមិនច្រានចោលសក្ខីកម្មរបស់គាត់ស្តីពីទំនាក់ទំនងការងាររវាងបុរសទាំងពីរនេះដែរ រួមទាំងការដែលពួកគេចុះពិនិត្យស្រែអំបិលនៅកែបជាមួយគ្នា "ជារៀងរាល់ខែ" នៅពាក់កណ្តាលឆ្នាំ១៩៧៧ និងមានវត្តមានជាមួយគ្នាក្នុងការប្រជុំជាមួយតំណាងមកពីស្រុក និងតំបន់[582]។ ចៅក្រមអន្តរជាតិមិនឃើញមានកំហុសឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកលើភស្តុតាងនីមួយៗរបស់សាក្សីដែលរងការជំទាស់ទាំងនេះ។

256. ចៅក្រមអន្តរជាតិយល់ថា ការជំទាស់ជាទូទៅរបស់សហមេធាវី ពាក់ព័ន្ធនឹងភស្តុតាងរបស់ ចាន់ វិចិត្រ (អតីតនិរសារដែលមានមូលដ្ឋាននៅតំបន់ ១៣ ក្នុងអំឡុងពេលមួយនៃរបប ក.ប.ធ) គឺគ្មានប្រយោជន៍។ ទីមួយ ការប្រឹងប្រែងរបស់សហមេធាវីក្នុងការស្វែងរកភាពផ្ទុយគ្នាផ្នែកពេលវេលារវាងសក្ខីកម្មរបស់ ចាន់ វិចិត្រ និងសក្ខីកម្មរបស់ សៅ ជាប់ ប្រែជាអសារបង់។ បន្ទាប់ពីការរៀបរាប់ថា យឹម ទិត្យ ធ្វើការក្នុងមន្ទីរនៅខេត្តតាកែវ នៅឆ្នាំ ១៩៧៥ ចាន់ វិចិត្រ បានប្រាប់អ្នកស៊ើបអង្កេតថា យឹម ទិត្យ បានស្នាក់នៅក្នុងទីរួមខេត្តតាកែវមួយរយៈពេលខ្លី "ប្រហែល

---

[579] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/19 ERN 01029211 (ឆ.៧៧៤), ERN 01029217 (ឆ.៨២១), ERN 01029233 (ឆ.៩៨៣) (ដែលបញ្ជាក់ថា យឹម ទិត្យ និងតាម៉ុក "តែងតែរាយការណ៍ពីនេះពីនោះរវាងគ្នា ហើយឱ្យដឹងទៅវិញទៅមក")។

[580] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/19 ERN 01029205 (ឆ.៧១១), ERN 01029218 (ឆ.៨២៧-ឆ.៨២៨)។ *ធៀបនឹង* ERN 01029156 (ឆ.១៦៦)។

[581] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008698 (ឆ.៩), ERN 01008699 (ឆ.១៨)។

[582] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008697 (ឆ.៧), ERN 01008697-01008698 (ឆ.៨-ឆ.៩, ឆ.១២), ERN 01008699 (ឆ.១៧), ERN 01008706 (ឆ.៥៥-ឆ.៥៦), ERN 01008708 (ឆ.៧៣)។

៤ ខែ" ហើយគាត់បានឃើញ យឹម ទិត្យ "សឹងតែរាល់ថ្ងៃ"[583]។ សាក្សីរូបនេះបានបញ្ជាក់បន្ថែមទៀតថា "៤ ខែហើយទៅនៅអន្លង់ទាន"[584]។ នៅពេលអានក្នុងបរិបទ សក្ខីកម្មនេះមិនគាំទ្រដល់ការលើកឡើងរបស់សហមេធាវី[585] ដែលថា ចាន់ វិចិត្រ បានឃើញ យឹម ទិត្យ ពីខែមេសា ដល់ខែកក្កដា ឆ្នាំ១៩៧៧ (ជាអំឡុងពេលដែលសាក្សីរូបនេះស្ថិតនៅអន្លង់ទាន ស្រុកកោះអណ្តែត ជាមួយនឹងអង្គភាពការពារតាមព្រំដែនវៀតណាម)[586]។ ទោះជាយ៉ាងណាក៏ដោយ សាក្សីរូបនេះបានបញ្ជាក់ថា ការប្រើប្រាស់ឃ្លា "សឹងតែរាល់ថ្ងៃ" មានន័យថា "ពេលខ្លះក៏អត់ឃើញដែរ ពេលខ្លះគាត់ដើរទៅនេះទៅនោះ ក៏អត់ឃើញដែរ"[587]។ ដូច្នេះ សក្ខីកម្មរបស់ ចាន់ វិចិត្រ ដែលបញ្ជាក់ថាបានឃើញ យឹម ទិត្យ ក្នុងខេត្តតាកែវ មិនបានច្រានចោលនូវដំណើរទស្សនកិច្ចរបស់

---

[583] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/853 ERN 01340635-36 (ឆ.១៦-ឆ.២១)។

[584] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/853 ERN 01340635 (ឆ.១៨)។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា សក្ខីកម្មរបស់ ចាន់ វិចិត្រ ដែលថា គាត់ជានិរសារកងទ័ពក្នុងវរសេនាតូច ៣១០ ហើយអង្គភាពនេះមានមូលដ្ឋាននៅវត្តត្រគៀត ឃុំទួលកី ជិតទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥។ បន្ទាប់ពីស្នាក់នៅទីនោះបាន ១ ឆ្នាំ ទាហានខ្លះស្នាក់នៅទួលកី ចំណែកទាហានផ្សេងទៀតនាំគ្នាទៅធ្វើផ្លូវរថភ្លើងនៅខេត្តតាកែវ។ ផ្អែកតាម ចាន់ វិចិត្រ គាត់បានទៅខេត្តតាកែវ ទោះបីជាមូលដ្ឋានកងទ័ពរបស់គាត់បន្តដាក់នៅទួលកីក្តី ហើយនៅពេលនោះ គាត់ "នៅជាប់ជាមួយតាភា" មេបញ្ជាការវរសេនាតូច ៣១០។ ទំនងជា ចាន់ វិចិត្រ បានស្នាក់នៅទីរួមខេត្តតាកែវរយៈពេល ៤ ខែ មុនដើមឆ្នាំ ១៩៧៧ ពីព្រោះគាត់បានបញ្ជាក់ថា គាត់បានទៅរស់នៅអន្លង់ទាន "ពីកន្លែងផ្លូវរទេះភ្លើង" ដែលលើកឡើងថា គាត់បានបន្តភារកិច្ចជាមួយអង្គភាពទ័ពនេះបន្ទាប់ពីការរស់នៅក្នុងទីរួមខេត្តតាកែវ ឬយ៉ាងហោចណាស់ បានឈប់សំចត នៅចន្លោះទីរួមខេត្តតាកែវ និងអន្លង់ទាន។ *សូមមើល* កិច្ចសម្ភាសន៍ DC-Cam ជាមួយ ចាន់ វិចិត្រ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D219/815.1 ERN 01318448-50។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/853 ERN 01340636 (ឆ.២១-ឆ.២៤)។

[585] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១២៩។

[586] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/853 ERN 01340635 (ឆ.១១)។ កិច្ចសម្ភាសន៍ DC-Cam ជាមួយ ចាន់ វិចិត្រ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D219/815.1 ERN 01318452-53, ERN 01318467-70។

[587] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/853 ERN 01340637 (ឆ.៣០)។

យឹម ទិត្យ ទៅពិនិត្យភូមិភាគពាយ័ព្យក្នុងអំឡុងពេលដូចគ្នានោះឡើយ ដូចជា ជាប់ សៅ បានជួប យឹម ទិត្យ ដើរតាមតាម៉ុក ក្នុងពេល "ការប្រជុំរៀនសូត្រ" នៅទំនប់កង្កួត នៅឆ្នាំ១៩៧៦[588]។

257. ទីពីរ សហមេធាវីបានដកស្រង់ វណ្ណ កុសល (មេបញ្ជាការអនុសេនាតូច) ជាសាក្សីបញ្ជាក់បន្ថែម ដើម្បីបង្ហាញថា យឹម ទិត្យ គ្មាន ឬមានការទទួលខុសត្រូវតិចតួចលើបញ្ហាយោធា[589]។ ទោះជាយ៉ាងណា វណ្ណ កុសល បានគូសបញ្ជាក់ដដែលៗថា គាត់មិនបានស្គាល់ យឹម ទិត្យ ឡើយ ដោយពន្យល់ថា យឹម ទិត្យ "មិនមែនជាទ័ពដូចពួកខ្ញុំទេ" និងថា "គាត់ធ្វើការខាងមូលដ្ឋាន ខាងតំបន់ខាងក្រោយ ហើយខ្ញុំធ្វើការនៅជួរមុខ អត់ដែលជួបមុខគ្នាឯណា"[590]។ ចៅក្រមអន្តរជាតិមិនចាត់ទុកថា ភស្តុតាងនេះមានតម្លៃជាភស្តុតាងខ្លាំងនោះទេ លើកលែងតែការបង្ហាញថា យឹម ទិត្យ មិនមែនជាទ័ពជួរមុខនៅពេលវេលាពាក់ព័ន្ធនេះ។ ផ្ទុយទៅវិញ តាមរយៈការពិនិត្យឡើងវិញលើភស្តុតាងរបស់ ចាន់ វិចិត្រ ទាំងស្រុង ចៅក្រមអន្តរជាតិយល់ថា អ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផល អាចសន្និដ្ឋានបានថា តាម៉ុក បានដាក់ការទទួលខុសត្រូវមួយចំនួនដល់ យឹម ទិត្យ លើបញ្ហាយោធា និងបញ្ហាសន្តិសុខផ្ទៃក្នុងមួយចំនួនក្នុងខេត្តតាកែវ [591]។

258. ទីបី ចៅក្រមអន្តរជាតិយល់ឃើញថា គ្មានកំហុសឡើយ ក្នុងការសន្និដ្ឋានថា យឹម ទិត្យ បានចូលរួមកិច្ចប្រជុំមួយជាមួយតំណាងគណៈស្រុកនៅមន្ទីរភូមិភាគនេះឡើយ ដោយពិចារណាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកស្រង់យ៉ាងជាក់លាក់នូវខ្លឹមសារដែលថា ការអះអាងរបស់សហមេធាវីមិនត្រូវបានយកមកពិចារណា[592]។ លើសពីនេះ សក្ខីកម្មដែលថា យឹម ទិត្យ បាន

---

[588] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាប់ សៅ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ឯកសារ D219/956 ERN 01425219 (ឆ.១៣-ឆ.១៨), ERN 01425220 (ឆ.២២)។

[589] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៣០, ១៣១។

[590] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វណ្ណ កុសល ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ឯកសារ D219/901 ERN 01381116 (ឆ.៣៥-ឆ.៣៩)។

[591] *សូមមើល ឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/853 ERN 01340639-01340640 (ឆ.៥១-ឆ.៥២) ("ក្រោមតាម៉ុក តែពេលអត់ តាម៉ុក ទៅ ប្រហែលជាមានប្រជុំឱ្យតាទិត្យ ជំនួស), ERN 01340640-01340641 (ឆ.៥៩) ("តាទិត្យ ទើបតំណាងពេលផុតសង្គ្រាមហើយទេ ពេលនៅសង្គ្រាមអត់ទេ"), (ឆ.៦០) ("ឃើញពេលតំណាងយោធា វ៉ៃតែម៉ុគិរីវង់ ផ្ទាល់ដាច់ ហើយ តាទិត្យ ដូចទទួលតែម៉ុគិរីវង់ ហ្នឹងទេ [...] នេះគឺយូរៗម្តង")។

[592] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 ជើងទំព័រ ៩១៤, ៩១៩។

ទទួលសាច់ញាតិរបស់គាត់ដែលមកលេងឱ្យស្នាក់នៅមួយយប់ជាច្រើនដងក្នុងបរិវេណតែមួយ មិនផ្ទុយពីភស្តុតាងរបស់ ចាន់ វិចិត្រ ដែលថា តំណាងស្រុកដែលជិះកង់ ធ្លាប់មករៀបចំកិច្ចប្រជុំម្តងជាមួយ យឹម ទិត្យ[593]។ ចៅក្រមអន្តរជាតិយល់ឃើញថា គ្មានកំហុសឡើយ នៅក្នុងការពឹងផ្អែករបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅលើសក្ខីកម្មរបស់ ចាន់ វិចិត្រ ដែលថា យឹម ទិត្យ បានបញ្ជាឱ្យប្រជាជនធ្វើកិច្ចការទូទាំងភូមិភាគនេះ[594]។

259. សំខាន់បំផុត ចៅក្រមអន្តរជាតិជឿជាក់ថា អ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផល អាចកំណត់ភស្តុតាងគ្រប់គ្រាន់ថា ទំនាក់ទំនងផ្ទាល់ខ្លួនជិតស្និទ្ធរវាង យឹម ទិត្យ និងតាម៉ុក បានផ្តល់សិទ្ធិអំណាច*តាមព្រឹត្តន័យ* ដល់ យឹម ទិត្យ លើសពីតួនាទីផ្លូវការរបស់គាត់ ដោយ ចាន់ វិចិត្រ បានបញ្ជាក់យ៉ាងខ្លី និងច្បាស់ថា "អ្នកគ្រប់គ្រងធំជាងគេគឺ តាម៉ុក និងតាទិត្យ ហើយ។ គាត់ទាំងពីរនេះគ្រប់គ្រងតាកែវទាំងមូល និងភូមិភាគទាំងមូល"[595]។

260. ចំណុចចុងក្រោយ ការជំទាស់របស់សហមេធាវីទៅលើសក្ខីកម្មរបស់ មឹង វេត ក៏មិនអាចយកជាការបានដែរ។ យោងតាមសាក្សីរូបនេះ (និរសារនៅតំបន់ ១៣) ក្នុងកិច្ចប្រជុំកម្មាភិបាលតំបន់ ១៣

---

[593] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/853 ERN 01340637-01340638 (ឆ.៣២-ឆ.៣៨), ERN 01340647 (ឆ.១០៩-ឆ.១១២), ERN 01340653 (ឆ.១៥២)។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ក ៖ គំនូសទឹកន្លែង ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/853.1, ERN 01340661។

[594] ឧទាហរណ៍ ភស្តុតាងដែលគូសបញ្ជាក់ថា អ្នកស្ថិតក្រោមបញ្ជារបស់ យឹម ទិត្យ មកពី ស្រុកអង្គរបូរី ស្រុកកោះអណ្តែត និងស្រុកព្រៃកប្បាស ត្រូវបានបញ្ជាឱ្យធ្វើព្រួលត្រី ដោយ យឹម ទិត្យ ជាអ្នកចាត់ចែងការបែងចែកត្រីងៀត។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/853 ERN 01340654 (ឆ.១៥៨)។ *សូមមើលផងដែរ* ERN 01340641-01340642 (ឆ.៦៧-ឆ.៦៩), ERN 01340643-01340644 (ឆ.៨២-ឆ.៨៣) ("និរសារភូមិភាគគឺតាទិត្យ..."), ERN 01340654 (ឆ.១៥៤) ("តាទិត្យគាត់ឱ្យអ្នកកាន់តេអូនិយាយដោយឱ្យយកក្បាលត្រីងៀតអីទៅឱ្យអ្នកកាប់ឫស្សីនៅលើភ្នំ ហើយឱ្យយកឡានដឹកឫស្សីទៅដាក់ឯណាៗអី គឺដូចជាផ្នែកសេដ្ឋកិច្ចមួយអ៊ីចឹង")។

[595] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ D219/853 ERN 01340646 (ឆ.១០១)។ *សូមមើលផងដែរ* ERN 01340641 (ឆ.៦៤) ("តាទិត្យ ប្រហែលជានៅលើថ្នាក់តំបន់ ព្រោះគាត់ជាតំណាងឱ្យតាម៉ុក"), (ឆ.៦៦) ("និយាយរួម ផ្នែកខាងលិចគឺគាត់ទៅទាំងអស់"), ERN 01340650 (ឆ.១៣១) ("តាមខ្ញុំសន្និដ្ឋាន តាទិត្យធំជាងតំបន់"), ERN 01340656 (ឆ.១៧១) ("ខ្ញុំស្មគ្រចិត្តរៀបរាប់រចនាសម្ព័ន្ធបន្ថែមអំពីថ្នាក់ដឹកនាំភូមិភាគនិរតីបញ្ជាក់ (តាម៉ុក និងតាទិត្យ)។ រចនាសម្ព័ន្ធ តាទិត្យ ជាសាខា តាម៉ុក ក្នុងរចនាសម្ព័ន្ធគឺជាស្តីទី ដោយមិនពេញសិទ្ធិរបស់តាម៉ុក នៅក្រោមបង្គាប់របស់ តាម៉ុក ប្រើសម្រាប់ធ្វើការផ្សេងៗ ដោយមិនបាច់ចេញលិខិតតែងតាំង")។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

ដែលមានរយៈពេល ១០ ថ្ងៃ នៅចុងឆ្នាំ ១៩៧៦ យឹម ទិត្យ អង្គុយនៅខាងស្ដាំដៃតាសោម ដែលក្រោយមកជាលេខាតំបន់ ១៣ នៅលើវេទិកាបែរមុខទៅរកអ្នកចូលរួម[596]។ ដូចដែល មឹង វេត ពន្យល់ យឹម ទិត្យ មិនថ្លែងសុន្ទរកថាឡើយ។ ទោះបីជាតួនាទីផ្លូវការរបស់ យឹម ទិត្យ គឺនៅថ្នាក់ស្រុកក្ដី ក៏ យឹម ទិត្យ "ឡើងទៅអង្គុយនៅវេទិកាជាមួយតាសោម" ក្នុងកិច្ចប្រជុំទាំង ១០ ថ្ងៃនោះ ហើយការរៀបចំកន្លែងអង្គុយដូច្នេះ មានន័យថា យឹម ទិត្យ "ត្រៀមឡើងហើយ" ទៅជាលេខាតំបន់។ តាមពិត នៅពេលតាសោមត្រូវបានដកពីតំណែងនៅពេលក្រោយមកទៀត យឹម ទិត្យ បានឡើងជំនួសតាសោម[597]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានប្រព្រឹត្តកំហុសឡើយ ក្នុងការពឹងផ្អែកលើសក្ខីកម្មរបស់ មឹង វេត ជាពិសេសដោយសារការពន្យល់របស់ មឹង វេត ថា តាម៉ុក "ច្រើនយកខ្សែស្រឡាយបងប្អូនគាត់ទៅកាន់កាប់ស្រុក និងតំបន់ផ្សេងៗ" និងបានបញ្ជូន យឹម ទិត្យ ទៅស្រុកគិរីវង់ទៅតាមដានកម្មាភិបាលដែលសង្ស័យ ព្រោះ យឹម ទិត្យ ជា "ប្អូនថ្លៃរបស់តាម៉ុក"[598]។

*ខ. សិទ្ធិអំណាច និងការទទួលខុសត្រូវត្រួតគ្នាទាំងនៅភូមិភាគពាយ័ព្យ និងភូមិភាគនិរតី*

261. ក្រៅពីការសន្និដ្ឋានអំពីតំបន់ ១៣ សហមេធាវីបានជំទាស់ថា សាក្សីបានផ្ដល់ភស្តុតាងស្ដីពីសិទ្ធិអំណាច*ត្រួតគ្នា*របស់ យឹម ទិត្យ ទាំងនៅភូមិភាគពាយ័ព្យ និងភូមិភាគនិរតី ក្រោយខែមិថុនា ឆ្នាំ១៩៧៨ (នៅពេល យឹម ទិត្យ ត្រូវបានតែងតាំងឱ្យកាន់មុខតំណែងនៅភូមិភាគពាយ័ព្យ យោងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ)[599]។ សហមេធាវី បានជំទាស់ទៅនឹងភស្តុតាងរបស់

---

[596] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មឹង វេត ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/488 ERN 01136710 (ឆ.៥៧- ឆ.៥៨)។

[597] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មឹង វេត ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/488, ERN 01136707 (ឆ.៣៧- ឆ.៤២), ERN 01136709 (ឆ.៥០-ឆ.៥១), ERN 01136711 (ឆ.៦២-ឆ.៦៣)។ ERN 01136716-17 (ឆ.៩០- ឆ.៩៥)។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ (មឹង វេត) ឯកសារ D219/899.1.4 ERN 01329892 ទំព័រ ៣០ បន្ទាត់ ១១-២៣។

[598] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មឹង វេត ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/488 ERN 01136715-16 (ឆ.៨៨, ឆ.៩០, ឆ.៩១)។

[599] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៣៥-១៣៦។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៥២ ជើងទំព័រ ៩២៣។

សាន់ ឡុន, ពេជ្រ ជឹម, សឹម ឈឿន, ប៉ាន់ សារូ និង ហ៊ុយ គ្រឹម។ ដំបូង ចៅក្រមអន្តរជាតិពិភាក្សា អំពីការជំទាស់ដែលចៅក្រមអន្តរជាតិយល់ថាមានអង្គសេចក្តី។

262. ទីមួយ សហមេធាវីបានកត់សម្គាល់ដោយត្រឹមត្រូវថា សឹម ឈឿន (យោធាថ្នាក់ស្រុក និងជាកម្មាភិបាលពាណិជ្ជកម្មក្នុងស្រុកគិរីវង់) បាននិយាយថា គាត់ជឿថា ក្នុងរយៈពេលពីរបីខែចុងក្រោយនៃរបប ក.ប.ធ យឹម ទិត្យ "នៅគ្រប់គ្រងស្រុកគិរីវង់ ពីព្រោះខ្ញុំមិនបានលឺអំពីការផ្លាស់ប្តូរគាត់ចេញពីស្រុកគិរីវង់"[600]។ ភស្តុតាងនេះ ដែលត្រូវបានយកជាសំអាងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហាក់មិនគាំទ្រសិទ្ធិអំណាច*ត្រួតត្រា*របស់ យឹម ទិត្យ ទាំងនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យនោះទេ ប៉ុន្តែផ្ទុយទៅវិញ យឹម ទិត្យ មិនដែលបានចាកចេញពីភូមិភាគនិរតីឡើយ[601]។

263. សហមេធាវីក៏បានលើកឡើងនូវការជំទាស់ដែលមានសុពលភាពមួយ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ ហ៊ុយ គ្រឹម ផងដែរ។ តាមរយៈការអានភស្តុតាងដែលបានដកស្រង់ក្នុងបរិបទ ហ៊ុយ គ្រឹម បានលើកឡើងថា គាត់ដឹងថា យឹម ទិត្យ "អាចឡើងចុះទៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ" ក្នុងផ្នែកមួយនៃការពិភាក្សារបស់សាក្សីរូបនេះអំពីការបានឃើញ យឹម ទិត្យ ត្រូវបានរៀបរាប់ក្នុងទស្សនាវដ្ត ក.ប.ធ នៅឆ្នាំ១៩៧៦ និង ១៩៧៧ (មុនការមកដល់នៃកម្មាភិបាលភូមិភាគនិរតី) និងក្នុងកុនមួយដែលគេបញ្ចាំងនៅចុងឆ្នាំ១៩៧៦[602]។ វាមិនច្បាស់ឡើយថា តើចម្លើយនេះទាក់ទិនជាពិសេសទៅនឹងអំឡុងពេលក្រោយខែមិថុនា ឆ្នាំ១៩៧៨ បន្ទាប់ពីការតែងតាំង យឹម ទិត្យ ជាផ្លូវការនៅភូមិភាគពាយ័ព្យ ឬយ៉ាងណានោះទេ ប៉ុន្តែបរិបទនេះនឹងបង្ហាញផ្ទុយពីនេះ[603]។

264. ពេជ្រ ជឹម (អតីតលេខាស្រុកត្រាំកក់ ដែលក្រោយមកត្រូវបានបញ្ជូនទៅភូមិភាគមជ្ឈិម) មិនបានកែប្រែភស្តុតាង របស់គាត់ ដូចការចោទប្រកាន់ដោយសហមេធាវីឡើយ។ ផ្ទុយទៅវិញ ពេជ្រ

---

600 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹម ឈឿន ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D219/189 ERN 01068052 (ឆ.២៧)។

601 *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៥២ ជើងទំព័រ ៩២៥។

602 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុយ គ្រឹម ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/75 ERN 00934370 (ឆ.២៧-ឆ.៣៤)។

603 ការកត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដោយប្រើឃ្លា *"សូមមើលផងដែរ"* ក្នុងដីកាដំណោះស្រាយនេះ ក្នុងការដកស្រង់សក្ខីកម្មរបស់ ហ៊ុយ គ្រឹម បង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិទទួលស្គាល់ភស្តុតាងនេះថាផ្តល់តែការគាំទ្រដោយប្រយោលចំពោះសេចក្តីអះអាងពាក់ព័ន្ធ។ *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 ជើងទំព័រ ៩២៥។

ជឹម បានបញ្ជាក់លើចម្លើយរបស់គាត់ថា នៅចុងឆ្នាំ១៩៧៨ គាត់បានលឺវិទ្យុផ្សព្វផ្សាយថា យឹម ទិត្យ បានទទួលភ្ញៀវនៅមន្ទីរតំបន់ ១៣ ក្នុងខេត្តតាកែវ ដោយបន្ថែមថា "ក្រោយមកទៀត និរសាររបស់ខ្ញុំបានប្រាប់ ខ្ញុំអំពីរឿងនេះទៀត"[604]។ ទោះជាយ៉ាងណា ចៅក្រមអន្តរជាតិកត់សម្គាល់ថា មាន ភាពស្រពិចស្រពិល មួយចំនួន ពាក់ព័ន្ធនឹង ក្របខណ្ឌពេលវេលានេះ ព្រោះ ពេជ្រ ជឹម បានផ្សារភ្ជាប់ទៅនឹងចម្លើយពីរបីពីដំបូងថា គាត់បានលឺរឿងនេះពីនិរសាររបស់គាត់ "ប្រហែលជាចុងឆ្នាំ១៩៧៧" ដែល យឹម ទិត្យ មកប្រចាំការនៅមន្ទីរតំបន់នេះក្នុងទីរួមខេត្តតាកែវ[605]។

265. ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិយល់ឃើញថា ការជំទាស់តវ៉ាដែលនៅសេសសល់ គឺមិនគួរឱ្យជឿជាក់ឡើយ។ ដូចបានកត់សម្គាល់ខាងលើ សាន់ ឡូន មានទំនាក់ទំនងជាមួយ យឹម ទិត្យ តាមរយៈប្រពន្ធតាម៉ុក[606]។ លើសពីនេះ សាន់ ឡូន លើកឡើងថា ទាំងតាម៉ុក និង យឹម ទិត្យ សុទ្ធតែបានធ្វើដំណើរទៅមកភូមិភាគពាយ័ព្យ និងភូមិភាគនិរតី ជាពិសេសក្នុងការពន្យល់ថា យឹម ទិត្យ "ជួនកាលធ្វើដំណើរទៅតាកែវយូរម្តងដែរ" និងការរៀបរាប់អំពីការដឹងពីរឿងនេះពី តាម៉ុក នៅពេលដែលសាក្សីរូបនេះបានទៅមន្ទីររបស់ តាម៉ុក ក្នុងខេត្តបាត់ដំបងនៅចុងរបប ក.ប.ធ[607]។ ក្រៅពីនេះ ប៉ាន់ សារូ (យោធាប្រចាំការនៅស្រុកគិរីវង់) ក៏មិនបានកែប្រែសក្ខីកម្មរបស់គាត់ ដូចដែលបានអះអាងដែរ។ យោងតាមសាក្សីរូបនេះ យឹម ទិត្យ បានធ្វើការនៅស្រុកគិរីវង់ "យូរ"

---

[604] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D118/259 ERN 00997040-41 (ឆ.១៣៥-ឆ.១៣៧)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/79, ERN 00934402 (ឆ.១៧-ឆ.១៨, ឆ.២០)។

[605] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D118/259 ERN 00997040 (ឆ.១៣១-ឆ.១៣៣)។ *សូមមើលផងដែរ* ERN 00997040 (ឆ.១២៨-ឆ.១២៩) ("តាទិត បន្តនៅជាលេខាស្រុកគិរីវង់ដដែល។ ក្រោយមកទៀតទើបខ្ញុំដឹងថា តាទិត្យ ត្រូវបានគេបញ្ជូនទៅបាត់ដំបង តែខ្ញុំមិនដឹងពេលណាទេ")។

[606] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/19 ERN 010292118 (ឆ.៨២៧-ឆ.៨២៨)។

[607] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D219/19 ERN 01029211-12 (ឆ.៧៧៦-ឆ.៧៨១) ("ស.៖ តើលោកទៅកន្លែងតាម៉ុក ហើយសួររក តាទិត្យ នេះនៅឆ្នាំណា? ឆ.៧៧៩ ៖ ឆ្នាំ១៩៧០ ប្លាយប្រហែលអំឡុង១៩៧៥-១៩៧៩។ [...] ឆ.៧៨០ ៖ កៀកឆ្នាំ១៩៧៩។ [...] ឆ.៧៨១ ៖ ហើយដល់ខ្ញុំសួររក តាទិត្យ ហើយគាត់ប្រាប់ថា តាទិត្យ ទៅខាងតាកែវ")។

ហើយបន្ទាប់មក យឹម ទិត្យ ត្រូវបានគេដំឡើងឋានៈ "ប្រហែលជាចុងរបបខ្មែរក្រហម"[608]។ ចំណុចនេះ ស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយរបស់សាក្សីដែលថា យឹម ទិត្យ ធ្វើជាគណៈស្រុកគិរីវង់ "រហូតដល់ជិតចប់របបខ្មែរក្រហម"[609]។

266. ផ្អែកតាមភ័ស្តុតាងដែលបានពិភាក្សាខាងលើ ចៅក្រមអន្តរជាតិយល់ឃើញថា មានការបញ្ជាក់បន្ថែមមួយចំនួន ចំពោះការអះអាងដែលថា យឹម ទិត្យ ប្រហែលជាបន្តប្រើប្រាស់សិទ្ធិអំណាចរដ្ឋបាល នៅភូមិភាគនិរតី នៅ អំឡុង ពេលក្រោយមកទៀតនៃរបប ក.ប.ធ ទោះបីជា មិនច្បាស់ថាតើ អំឡុងពេលនេះគ្របដណ្តប់លើអំឡុងពេលក្រោយ ខែមិថុនា ឆ្នាំ១៩៧៨ ឬយ៉ាងណាក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិ យល់ឃើញថា មិនចាំបាច់ត្រូវធ្វើការសម្រេចថា តើសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដែរឬទេពាក់ព័ន្ធនឹងបញ្ហានេះ ព្រោះចៅក្រមអន្តរជាតិយល់ឃើញថា ទោះបីជាគ្មានការពិចារណាទៅលើសិទ្ធិអំណាចរបស់ យឹម ទិត្យ នៅភូមិភាគនិរតីនៅក្រោយខែមិថុនា ឆ្នាំ១៩៧៨ ដោយផ្អែកទៅលើការសន្និដ្ឋានលើយុត្តាធិការបុគ្គលដែលត្រូវបានតម្កល់នៅក្នុងមូលដ្ឋានទី ៥.២ និង ៥.៣ ខាងក្រោមក៏ដោយ[610]ក៏ ចំណុចនេះមិនមានអានុភាពជាកត្តាកំណត់សំខាន់ ទៅលើសេចក្តីសម្រេចដោយឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា យឹម ទិត្យ ស្ថិតក្នុងចំណោមបុគ្គល "ដែលទទួលខុសត្រូវខ្ពស់បំផុត" ដូច្នេះហើយ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[611]។

267. ជារួម ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានប្រើប្រាស់ដោយមិនត្រឹមត្រូវនូវទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយនឹង តាម៉ុក សម្រាប់ជាមូលដ្ឋាន ឬជម្រើសងាយស្រួលក្នុងការចោទប្រកាន់នូវសិទ្ធិអំណាច*តាមព្រឹត្តន័យ* ឬ*តាមនីតិន័យ*

---

[608] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន់ សារ៉ូ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D118/302 ERN 01024565 (ឆ.៤៦- ឆ.៥២)។

[609] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន់ សារ៉ូ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D118/302 ERN 01024563 (ឆ.២៦) (ការគូសបញ្ជាក់បន្ថែម)។

[610] រួមបញ្ចូលការសន្និដ្ឋានពាក់ព័ន្ធនឹងការទទួលខុសត្រូវកម្រិតខ្ពស់របស់ យឹម ទិត្យ នៅភូមិភាគពាយ័ព្យ ក្រោយខែមិថុនា ឆ្នាំ១៩៧៨។

[611] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩៩២-៩៩៩។ *សូមមើលជាទូទៅ* បទដ្ឋាននៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍*ខាងលើ*។

នោះទេ។ ផ្ទុយទៅវិញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះផ្អែកលើសាក្សីផ្សេងៗ ដែលបានផ្តល់សក្ខីកម្មអំពីតួនាទី និងការទទួលខុសត្រូវរបស់ យឹម ទិត្យ ដោយផ្ទាល់ ដូចបានពិភាក្សាខាងលើ។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិសម្រេចច្រានចោលមូលដ្ឋានទី ៥.១។

## មូលដ្ឋាន ៥.២(i)÷ កំហុសដែលចោទការចោទប្រកាន់ លើការសម្រេចថា យឹម ទិត្យ គឺជាអ្នកដឹកនាំស្រុកគីរីវង់

ក. សារណា

268. សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេចថា យឹម ទិត្យ គឺជា "អ្នកដឹកនាំស្រុកគីរីវង់" នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[612]។ កំហុសនេះមោឃភាពការសម្រេចនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពាក់ព័ន្ធនឹងស្រុកគីរីវង់ និងតម្រូវឱ្យធ្វើការបដិសេធ ដើម្បីកុំឱ្យមានភាពអយុត្តិធម៌[613]។

269. ចំពោះការចោទអំពីតួនាទីតាមផ្លូវច្បាប់របស់ យឹម ទិត្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានធ្វើការសម្រេចលើកាលបរិច្ឆេទ ឬអំឡុងពេលវេលា នៃការតែងតាំងយឹម ទិត្យ ជាគណៈកម្មាការស្រុកគីរីវង់[614] និងការតែងតាំងគាត់ជាលេខាស្រុកទេ[615]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើភស្តុតាងផ្ទុយរបស់ គុប ផាន និង ម៉ុង វេតទេ[616] ហើយបានពឹងផ្អែកដោយមិនត្រឹមត្រូវទៅលើសក្ខីកម្មសាក្សីអំពីត្រឹមតែវត្តមានរបស់ យឹម ទិត្យ នៅក្នុងស្រុក

---

[612] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤២ យោងទៅរក ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣២៨-៣៤២, ៤៦៣-៤៦៩។

[613] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (D382/22) កថាខណ្ឌ ១៥១១៥២ (អះអាងថាមិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដោយសមហេតុផលណាម្នាក់ អាចនឹងធ្វើសេចក្តីសម្រេចផ្អែកលើភស្តុតាង មិនរឹងមាំ និងមិនអាចជឿជាក់បាន ដោយមិនបញ្ជាក់អំពីពេលវេលា និងចោទប្រកាន់បន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានធ្វើការពិចារណា លើភាពផ្ទុយគ្នា និងភាពមិនច្បាស់លាស់ នៅក្នុងសំណុំរឿង និងមិនបានផ្តល់សំអាងហេតុ)។

[614] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៣។

[615] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៤។

[616] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៤ (សហមេធាវីចោទប្រកាន់ថា "គុប ផាន "មិនដឹងមុខតំណែងរបស់លោក យឹម ទិត្យ" ម៉ុង វេត ថ្លែងថា "តាទិត្យ មិនធ្វើការងារស្រុកដោយផ្ទាល់ទេ"")។

គីរីវង់ នៅក្នុងឆ្នាំ ១៩៧២-១៩៧៤ ធ្វើជាភស្តុតាងថា គាត់មានតួនាទីតាមផ្លូវច្បាប់[617]។ ដោយផ្អែកលើភស្តុតាង "ដែលមិនមានលក្ខណៈគ្រប់គ្រាន់" មិនមានអ្នកវិនិច្ឆ័យលើអង្គហេតុ ប្រកបដោយហេតុផលណាម្នាក់ អាចធ្វើការសន្និដ្ឋានថា យឹម ទិត្យ មានតំណែងដឹកនាំនៅក្នុងស្រុកគីរីវង់ ដូចដែលបានគាំទ្របន្ថែមដោយសហចៅក្រមស៊ើបអង្កេតជាតិ ដែលមិនអាចឈានដល់ការសន្និដ្ឋានរឹងមាំអំពីតួនាទីរបស់ យឹម ទិត្យ នៅក្នុងស្រុក[618]។

270. ចំពោះសិទ្ធិអំណាចជាក់ស្តែងដែលចោទ ទៅលើ យឹម ទិត្យ នៅក្នុងស្រុកគីរីវង់ សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបកស្រាយដោយមិនត្រឹមត្រូវ ទៅលើភស្តុតាងរបស់សាក្សី និងមិនបានពិចារណាអំពីភស្តុតាងផ្ទុយដែលដោះបន្ទុករបស់ ទឹម ភួន, ង៉ែត ងយ និង ម៉ឹង វេត[619]។ បន្ថែមពីលើភាពមិនច្បាស់លាស់ចំពោះបញ្ហាថាតើ យឹម ទិត្យ ប្រើប្រាស់ការត្រួតត្រានៅក្នុងស្រុកគីរីវង់នៅពេលណានោះ សហមេធាវីបានលើកឡើងថា មិនមានភស្តុតាងគ្រប់គ្រាន់ថា យឹម ទិត្យ បំពេញភារកិច្ច និងការទទួលខុសត្រូវរបស់គាត់ ប្រកបដោយប្រសិទ្ធភាពឡើយ[620]។

271. ជាចម្លើយតប ចំពោះតួនាទីតាមផ្លូវច្បាប់របស់ យឹម ទិត្យ នៅក្នុងស្រុកគីរីវង់ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា យឹម ទិត្យ មិនបានបង្ហាញពីទិដ្ឋភាពត្រឹមត្រូវនៃចម្លើយរបស់សាក្សីដែលគាត់ចោទថាមានភាពផ្ទុយ ហើយលើកឡើងពីការមិនមានលើកឡើងនៅក្នុងចម្លើយដែលសំដៅទៅតួនាទី និងភារកិច្ចរបស់ យឹម ទិត្យ នៅក្នុងគណៈកម្មាការស្រុកគីរីវង់ ក្នុងឆ្នាំ ១៩៧៥[621]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា វត្តមានរបស់ យឹម ទិត្យ នៅក្នុងស្រុកត្រូវបានដកស្រង់ធ្វើជាភស្តុតាងដើម្បីគ្រាន់តែបង្ហាញអំពីភាពលេចធ្លោររបស់គាត់ នៅក្នុងតំបន់ សូម្បី

---

[617] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៥។

[618] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៦។

[619] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៧-១៥០ (សហមេធាវីយោងទៅភស្តុតាងរបស់ (១) ទឹម ភួន ដែលបញ្ជាក់ថា គាត់មិនដឹងថា យឹម ទិត្យជាគណៈស្រុកទេ និងមិនដឹងអំពីតួនាទីរបស់គាត់ឡើយ, (២) ង៉ែត ងយ ត្រូវបានលើកឡើងថាមិនដឹងអ្វីទាំងអស់អំពីលោក យឹម ទិត្យ តាមការផ្ទាល់ផ្ទាល់របស់គាត់ និង (៣) ម៉ឹង វេត ដែលភស្តុតាងរបស់គាត់ ពាក់ព័ន្ធរយៈពេលខ្លីមួយ ហើយប្រភពនៃការដឹងរបស់គាត់ គឺចេញពីម្តាយរបស់គាត់)។

[620] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥១។

[621] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)(D382/27) កថាខណ្ឌ ៨១-៨២។

តែនៅអំឡុងពេលមុនរយៈដែលចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅទៀត[622]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានបញ្ជាក់ផងដែរអំពីការយោងនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ទៅរក យឹម ទិត្យ ជាលេខាស្រុកគីរីវង់ និងអនុលេខាស្រុក នៅក្នុងឆ្នាំ១៩៧៥ ដែលផ្ទុយពីការអះអាងរបស់ យឹម ទិត្យ[623]។ ចំពោះការសម្រេចថា យឹម ទិត្យ មានសិទ្ធិអំណាចជាក់ស្តែង នៅក្នុងស្រុកគីរីវង់ សហព្រះរាជអាជ្ញាអន្តរជាតិ បានរិះគន់ការលើកឡើង "ចោះៗ" របស់ យឹម ទិត្យ ទៅលើភស្តុតាង[624]។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញពីការដកចេញមួយចំនួនទៅលើភស្តុតាងរបស់ ទឹម ភួន (ដែលអះអាងថា យឹម ទិត្យ មាន "តួនាទីធំ" និងស្ថិតក្នុង "ចំណោមអ្នកដឹកនាំ")[625] ភស្តុតាងរបស់ ង៉ែត ងយ (បានឃើញ យឹម ទិត្យ ផ្ទាល់ និងផ្តល់នូវអំឡុងពេលវេលាច្បាស់លាស់ថាគាត់ជាលេខាស្រុកនៅពេលណា)[626] និងភស្តុតាងរបស់ ម៉ឹង វេត (គាំទ្រដោយតួនាទីរបស់គាត់រយៈពេលយូរ នៅក្នុងតំបន់ ដែលត្រូវបញ្ជូនសារដោយផ្ទាល់ទៅការិយាល័យរបស់ យឹម ទិត្យ)[627]។

## ខ. ការពិភាក្សា

272. ចៅក្រមអន្តរជាតិបានសម្រេចថា សហមេធាវីមិនបានបំពេញបន្ទុកបង្ហាញភស្តុតាងថា មិនមានអ្នកវិនិច្ឆ័យអង្គហេតុប្រកបដោយហេតុផលណាម្នាក់ អាចធ្វើការសម្រេច ដូចការសម្រេចដែលរងការជំទាស់នេះឡើយ។

273. ទីមួយ ការជំទាស់របស់សហមេធាវី មិនអាចធ្វើបានទេ ដោយផ្អែកលើសាក្សីជាច្រើន ដែលផ្តល់សក្ខីកម្ម អំពីតួនាទីតាមផ្លូវច្បាប់របស់ យឹម ទិត្យ នៅក្នុងស្រុកគីរីវង់[628]។ ទោះបីជាសហចៅក្រម

---

[622] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)(D382/27) កថាខណ្ឌ ៨៣។

[623] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)(D382/27) កថាខណ្ឌ ៨៤-៨៦។

[624] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)(D382/27) កថាខណ្ឌ ៨៧។

[625] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)(D382/27) កថាខណ្ឌ ៨៨។

[626] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)(D382/27) កថាខណ្ឌ ៨៩ យោងទៅរក ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) ជើងទំព័រ ៨៦៩។

[627] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)(D382/27) កថាខណ្ឌ ៩០។

[628] ចៅក្រមអន្តរជាតិពិភាក្សាអំពី ការជំទាស់របស់សហមេធាវី ចំពោះភស្តុតាងរបស់សាក្សីជាក់លាក់ ដោយលម្អិតនៅផ្នែកខាងក្រោម ប៉ុន្តែ ទោះជាក្នុងករណីណាក្តី អង្គជំនុំជម្រះសម្រេចថា ការជំទាស់ទាំងអស់នេះ មិនអាចធ្វើឱ្យប៉ះពាល់ដល់ការសម្រេច

ស៊ើបអង្កេតអន្តរជាតិទទួលស្គាល់ថា "មានភាពមិនច្បាស់លាស់អំពីកាលបរិច្ឆេទ ដែល យឹម ទិត្យ ត្រូវបានតែងតាំងក្នុងគណៈកម្មាធិការស្រុកគីរីវង់"[629] និងមិនបានផ្តល់កាលបរិច្ឆេទ ជាក់លាក់នៃការតែងតាំងគាត់ទៅក្នុងតួនាទីជាលេខាស្រុកក្តី[630] តែចៅក្រមអន្តរជាតិកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកទៅលើភស្តុតាងរបស់សាក្សីជាច្រើនរូប ដែលបានផ្តល់សក្ខីកម្មថា យឹម ទិត្យ ស្ថិតនៅក្នុងគណៈកម្មាធិការស្រុក[631] មិនក្រោយឆ្នាំ ១៩៧៥ ឡើយ[632] ដោយពីដំបូង គាត់គឺជាអនុលេខា[633] ហើយគាត់ឡើងកាន់តំណែងជាលេខាស្រុក[634] បន្ទាប់ពីគេ

---

របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើតួនាទីតាមផ្លូវច្បាប់របស់ យឹម ទិត្យ និង/ឬសិទ្ធិអំណាចជាក់ស្តែងរបស់គាត់នៅក្នុងស្រុកគីរីវង់ដែរ។

629 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣២៨។

630 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣៣០-៣៣១។

631 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣២៨-៣៣១ យោងទៅរក *ផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ ភ្នំ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/108 នៅត្រង់ ERN 01045250 (ឆ៦) ("ខ្ញុំស្គាល់ដែលមានឈ្មោះដូចខាងក្រោមនេះ ដែលស្ថិតនៅក្នុងគណៈស្រុកគីរីវង់ ដូចជា តាតុំគឺជាគណស្រុក ឬលេខាស្រុក ... តាទិត្យ [...]។ ខ្ញុំមិនដឹងអំពីមុខងារអ្នកទាំងនេះថាអ្នកណាធ្វើស្អីនោះទេ")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ាន់ សារុ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D118/302 នៅត្រង់ ERN 01024563 (ឆ២៥) ("គណៈស្រុកគីរីវង់រួមមានឈ្មោះ តាតុំ [...] តាទិត្យ និងយាយបូ")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡាច សម្បត្តិ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/165 នៅត្រង់ ERN 00968144 (ឆ១២) ("បាទខ្ញុំស្គាល់តាទិត្យ ជាគណៈស្រុក១០៩")។

632 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣២៨ -៣៣១ យោងទៅ *ផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី លួន មល់ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/358 នៅត្រង់ ERN 01104662 (ឆ១០, ឆ១៣)("នៅឆ្នាំ១៩៧៥ ខៀវ តុំ [...] ជាចៅហ្វាយស្រុក តាទិត្យ ជាអនុ [...] តាទិត្យឡើងជាអនុស្រុកនៅ១៩៧៤")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ D119/85 នៅត្រង់ ERN 00975766-00975767 (ឆ២១ -២២) ("នៅខែកញ្ញា ឆ្នាំ១៩៧៥ ពេលដែលខ្ញុំទៅដល់ស្រុកគីរីវង់ ខ្ញុំបានឃើញគាត់នៅទីនោះរួចហើយ")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១១ ឯកសារ D13 នៅត្រង់ ERN 00687003 ("តើលោកអាចប្រាប់យើងបានទេ ថា តាទិត្យ គឺជាគណៈស្រុកមែនឬ? ឆ្លើយ៖ បាទ គាត់ជាគណៈស្រុក [...] គឺនៅប្រហែលចុងឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦")។

633 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣២៨ -៣៣១ យោងទៅរក *ផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ខឹម ស៊ន ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D118/301 នៅត្រង់ ERN 01024550 (ឆ២៧ -ឆ២៨) ("តាតុំជាប្រធានស្រុកគីរីវង់ តាទិត្យជាអនុប្រធាន ហើយយាយបូគឺបន្ទាប់ពីតាទិត្យ។ ស. តើលោកដឹងរឿងនេះដោយរបៀបណា? ឆ២៨៖ ក្រោយឆ្នាំ១៩៧៥ គេបានប្រជុំនិងប្រកាសប្រាប់ អំពីសមាសភាពទាំងអស់នេះ")។

634 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣៣១ ជើងទំព័រ ៨៦៨ យោងទៅ, *ផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ដុក ចាន់ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/86 នៅត្រង់ ERN 01040104 (ឆ៧) ("បន្ទាប់ពីតាតុំ

ដកតាតុំនៅអំឡុងចន្លោះចុងឆ្នាំ ១៩៧៦ ដល់ខែកញ្ញា ឆ្នាំ១៩៧៧[635]។ ហេតុដូច្នេះ ការចោទប្រកាន់ថា "សហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកលើសក្ខីកម្មរបស់សាក្សី អំពីត្រឹមតែវត្តមានរបស់ យឹម ទិត្យ នៅក្នុងស្រុកគីរីវង់ ក្នុងអំឡុងឆ្នាំ ១៩៧២ ១៩៧៣ និង១៩៧៤" ជាភស្តុតាងដែលថាគាត់មានតួនាទីតាមផ្លូវច្បាប់នោះ គ្មានមូលដ្ឋានទេ[636]។

274. ចំពោះការចោទពីអណត្តិការងាររយៈពេលខ្លីរបស់ យឹម ទិត្យ នៅក្នុងគណៈកម្មាធិការ និងភាពផ្ទុយគ្នាដែលអះអាង អំពីកាលបរិច្ឆេទនៃការចាកចេញពីស្រុករបស់គាត់[637] ចៅក្រមអន្តរជាតិសម្រេចថា ការសម្រេចថា យឹម ទិត្យ ចាកចេញពីស្រុកនៅក្នុងឆ្នាំ១៩៧៦ ឬឆ្នាំ១៩៧៧[638] មិនអាចសន្និដ្ឋានដោយត្រឹមត្រូវថា មានន័យសំដៅទៅខែមករា ឆ្នាំ១៩៧៦[639] ឡើយ ប្រសិនបើអានរួមគ្នាជាមួយ ការសម្រេចដែលថា តា តុំ ត្រូវបានដកចេញ "នៅពេលមួយចន្លោះចុងឆ្នាំ១៩៧៦ និងខែកញ្ញា ឆ្នាំ១៩៧៧"[640] និងភស្តុតាងដែលគាំទ្រថា យឹម ទិត្យ បានក្លាយជាលេខាស្រុកគីរីវង់បន្ទាប់ពីដកតាតុំ[641]។

---

ហើយនិងយាយបូផ្លាស់ចេញ តាទិត្យក្លាយទៅជាគណៈស្រុក ហើយយាយខឿន ក្លាយទៅជាអនុរបស់គាត់")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម ឈួន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ឯកសារ D118/45 នៅត្រង់ ERN 00905853 (ឆ៧) ("គណៈស្រុកគីរីវង់គេហៅស្រុក១០៩ គឺតាទិត្យ")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ នៅ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D118/151 នៅត្រង់ ERN (ភាសាខ្មែរ) (ឆ១៧) 00968012 ("តើតាទិត្យមានតួនាទីអ្វីជាក់លាក់? ឆ.១៧៖ ខ្ញុំឮគេនិយាយថា ដំបូងគាត់លេខាស្រុកគីរីវង់[...]")។

635 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ៣៣០។

636 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៥។

637 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៣។

638 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣៤២។

639 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៣ (សហមេធាវីចោទប្រកាន់នៅត្រង់ យឹម ទិត្យ "ចាកចេញពីស្រុកគីរីវង់តាំងពីខែមករា ឆ្នាំ១៩៧៦")។

640 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣៣០។

641 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣៣១ ជើងទំព័រ ៨០៨ យោងទៅរក *ផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ដុក ចាន់ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារD219/86 នៅត្រង់ ERN 01040104 (ឆ៧) ("បន្ទាប់ពីតាតុំហើយនឹងយាយបូផ្លាស់ចេញ តាទិត្យក្លាយទៅជាគណៈស្រុក ហើយយាយខឿន ក្លាយទៅជាអនុរបស់គាត់") កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម ឈួន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ឯកសារ D118/45 នៅត្រង់ ERN (ភាសាខ្មែរ) (ឆ៧) 00905853 ("គណៈស្រុកគីរីវង់គេហៅស្រុក១០៩ គឺតាទិត្យ")។

275. សហមេធាវីបង្ហាញពីការដែលសហចៅក្រមស៊ើបអង្កេតជាតិ មិនអាច "ធ្វើការសន្និដ្ឋានដាច់ខាត" ថា យឹម ទិត្យ មានតួនាទីតាមផ្លូវច្បាប់ នៅក្នុងស្រុកគីរីវង់[642]។ ប៉ុន្តែ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតជាតិ បានសម្រេចថា យឹម ទិត្យ គឺជាលេខាស្រុកគីរីវង់ នៅក្នុងឆ្នាំ ១៩៧៥[643] ហើយបានសម្រេចអំពីតួនាទីរបស់ យឹម ទិត្យ ជាលេខាស្រុកនៅក្នុងឆ្នាំ ១៩៧៦ និងឆ្នាំ ១៩៧៧[644]។ ទោះជាក្នុងករណីណាក្តី ចៅក្រមអន្តរជាតិសម្រេចថា កំហុសមិនអាចត្រូវបានកំណត់ដោយគ្រាន់តែសំដៅទៅការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិនោះឡើយ[645]។

276. ទីពីរ សហមេធាវីបានជំទាស់ចំពោះការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើភស្តុតាងដែលចោទថា ផ្ទុយគ្នា និងការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាទៅលើភស្តុតាងដោះបន្ទុក របស់ ម៉ឹង វេត, ង៉ែត ងយ, តុប ផន និងទឹម ភួន នៅពេលសម្រេចថា

[642] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៦ (ចោទថាសហចៅក្រមស៊ើបអង្កេតជាតិ មិនអាចឈានដល់ការសន្និដ្ឋានដាច់ខាតថាតើ យឹម ទិត្យ បានធ្វើជាលេខាស្រុកគីរីវង់ ពីខែមិថុនា ឆ្នាំ១៩៧៦ ដល់ឆ្នាំ ១៩៧៧ និងថាគាត់មិនបានសន្និដ្ឋានថា យឹម ទិត្យ អាចធ្វើជាគណៈស្រុកនោះ មុនខែមករា ឆ្នាំ១៩៧៦)។

[643] ដីកាសម្រេចលើកលែងចោទប្រកាន់ (D381) កថាខណ្ឌ ១៨៥។

[644] ដីកាសម្រេចលើកលែងចោទប្រកាន់ (D381) កថាខណ្ឌ ១៨៥, ១៨៧, ៦៨០ (សម្រេចនៅត្រង់ "តាទិត្យ ជាលេខាស្រុកនៅឆ្នាំ១៩៧៦" និងនៅត្រង់ "តាទិត្យជាលេខាស្រុកគីរីវង់នៅចន្លោះឆ្នាំ១៩៧៦ និង១៩៧៧ ដែលក្រោយមកគាត់ត្រូវបាន បញ្ជូនទៅបាត់ដំបង ប្រហែលពាក់កណ្តាលឆ្នាំ១៩៧៧" និង "យឹម ទិត្យ ទទួលឋានៈជាលេខាស្រុកគីរីវង់ និងលេខាតំបន់ ១៣ ចន្លោះឆ្នាំ ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ១៩៧៧")។

[645] តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Lukić & Lukić*, IT-98-32/1-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៣៨៦ ("អង្គជំនុំជម្រះតុលាការកំពូលរម្លឹកថា អ្នកវិនិច្ឆ័យលើអង្គហេតុដោយសមហេតុផលពីរ អាចឈានដល់ការសន្និដ្ឋានផ្សេងគ្នា ប៉ុន្តែសមហេតុដូចគ្នា នៅពេលវាយតម្លៃទៅលើ ភាពអាចជឿជាក់បានរបស់សាក្សី និងនៅពេលសម្រេចលើតម្លៃជាភស្តុតាងនៃភស្តុតាងដែលដាក់បង្ហាញ នៅពេលជំនុំជម្រះ។ កំហុសមិនត្រូវបានកំណត់ ដោយគ្រាន់តែបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងដទៃ បានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងលក្ខណៈផ្សេងនោះឡើយ), តុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Karemera & Ngirumpatse* សំណុំរឿងលេខ ICTR-98-44-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ កថាខណ្ឌ ៥២ ("អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវធ្វើការវាយតម្លៃចុងក្រោយដោយខ្លួនឯង ទៅលើភស្តុតាងដោយផ្អែកលើភស្តុតាងរួមទាំងអស់ ដែលបានដាក់បង្ហាញនៅក្នុងរឿងក្តី នៅចំពោះមុខខ្លួន។ ជាលទ្ធផល អ្នកវិនិច្ឆ័យលើអង្គហេតុដោយសមហេតុផលពីរ អាចឈានដល់ការសន្និដ្ឋានផ្សេងគ្នា ប៉ុន្តែសមហេតុដូចគ្នា នៅពេលសម្រេចលើតម្លៃជាភស្តុតាងនៃភស្តុតាងដែលដាក់បង្ហាញ នៅពេលជំនុំជម្រះ") (លុបចោលជើងទំព័រ)។

01677215



យឹម ទិត្យមានតួនាទីតាមផ្លូវច្បាប់ ឬមានសិទ្ធិអំណាចជាក់ស្តែង នៅក្នុងស្រុកគីរីវង់[646]។ ចំពោះសាក្សីទាំងអស់នេះ ចៅក្រមអន្តរជាតិជម្រះយល់ថា ភស្តុតាងដែលរងការជំទាស់ មិនមានភាពផ្ទុយគ្នា ដែលមិនតម្រូវឲ្យមាន ការពិចារណាជាក់លាក់ ឬថា ភស្តុតាងផ្ទុយនេះ ត្រូវបានពិចារណាដោយល្អិតល្អន់រួចហើយដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

277. ចំពោះភស្តុតាងរបស់ តុប ផន ចៅក្រមអន្តរជាតិយល់ថា ចម្លើយដែលថា គាត់មិនដឹងអំពីតួនាទីពិតប្រាកដរបស់ យឹម ទិត្យ មិនមែនផ្ទុយទៅនឹងភស្តុតាងដែលថា "តាទិត យាយបូរ និងតាគុំ ពួកគេសហការធ្វើការជាមួយគ្នា" ហើយក៏មិនផ្ទុយនឹងចម្លើយរបស់គាត់ដែលថា "ខ្ញុំគិតថាតាទិតមានតំណែងធំ"[647]។ ភស្តុតាងរបស់ ម៉ឹង វេត ដែលថា យឹម ទិត្យ "មិនធ្វើការងារស្រុកដោយផ្ទាល់ទេ"[648] គ្រាន់តែគាំទ្រដល់ការសម្រេចថា យឹម ទិត្យ ក៏បំពេញតួនាទីដឹកនាំ ទៅលើតាគុំ ហើយជាក់ស្តែងទៅជា "គឺជាមេដឹកនាំស្រុក សូម្បីតែនៅក្នុងអំឡុងពេលដែល យឹម ទិត្យ និងតាគុំ នៅជាមួយគ្នាក្នុង គណៈកម្មាធិការស្រុកក្តី"[649]។

278. បន្ថែមលើនេះ ការចោទប្រកាន់ថា ភស្តុតាងរបស់ ម៉ឹង វេត ពាក់ព័ន្ធ "រយៈពេលខ្លីមួយចាប់ពី "ប្រហែលចុងឆ្នាំ១៩៧៦" រហូតដល់យ៉ាងយូរបំផុត ខែ មករា ឆ្នាំ១៩៧៧" គ្មានមូលដ្ឋានឡើយ[650]។ ម៉ឹង វេត មកដល់ស្រុកគីរីវង់ស្រុកគីរីវង់ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ហើយផ្លាស់ទៅខេត្តក្រចេះ នៅក្នុងខែមីនា ឆ្នាំ១៩៧៧[651]។ បន្ទាប់ពីគាត់មកដល់ស្រុកគីរីវង់ "ខ្ញុំបានឃើញ... តា ទិត.. នៅទីនោះ"[652] ហើយគាត់ចាប់ផ្តើមរត់សំបុត្រផ្ទាល់ទៅការិយាល័យ យឹម ទិត្យ "ចន្លោះដើមឆ្នាំ៧៦

[646] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៤, ១៤៧ -១៥០។

[647] កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប ផាន ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D118/305 នៅត្រង់ ERN 01024599 (ឆ២៧-ឆ២៩)។

[648] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៤ យោងទៅរក កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/85 នៅត្រង់ ERN 00975767 (ឆ២៣ -២៤)។

[649] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣៣២។

[650] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥០។

[651] កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/85 នៅត្រង់ ERN 00975769 (ឆ៣២)។

[652] កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/85 នៅត្រង់ ERN 00975769 (ឆ៣២)។

រហូតដល់ចុងឆ្នាំ៧៦"[653]។ ចំពោះប្រភពនៃការដឹងឮរបស់ ម៉ឹង វេត ការសង្កេតរបស់គាត់ថា យឹម ទិត្យ មានតំណែងខ្ពស់ជាងតាគុំ ផ្អែកលើការកត់សម្គាល់ផ្ទាល់របស់គាត់ អំពីទីកន្លែងដែល យឹម ទិត្យ អង្គុយនៅពេលប្រជុំ[654] និងលើព័ត៌មានដែលទទួលបានពីម្តាយរបស់គាត់ដែលជាបងប្អូនជីដូនមួយតាគុំ[655]។

279. ចំពោះភស្តុតាងដោះបន្ទុក និងផ្ទុយគ្នារបស់ ទឹម ភួន[656] សហមេធាវីមិនបានបង្ហាញដោយពេញលេញ និងត្រឹមត្រូវ នូវចម្លើយរបស់ ទឹម ភួន ឡើយ។ ទោះបីជាសាក្សីរូបនេះ បានពន្យល់ថា គាត់ "មិនបានដឹង" តួនាទីរបស់ យឹម ទិត្យ[657] និង "មិនដឹងថាគាត់ មានតំណែងជាអ្វីទេ"[658] តែគាត់បាន

---

[653] កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D219/488 នៅត្រង់ ERN 01136702 (ឆ៧)។

[654] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ (ម៉ឹង វេត) ឯកសារ D219/899.1.4 នៅត្រង់ ERN 01329892 ទំព័រ ៣០ បន្ទាត់ ៨ -២៣ ("តើតាគុំ និងតាទិត្យគាត់ធ្វើអ្វីដែរ នៅស្រុកគីរីវង់នោះ? ឆ. បើតាមដែលខ្ញុំដែលខ្ញុំក្តាប់ ធ្លាប់តែចេញចូលកន្លងទៅ អ៊ំទិត្យ គាត់ពិតមែនតែនៅក្នុងគីរីវង់ គាត់ជាគណៈស្រុកគីរីវង់ តែក៏គាត់អាចមិនជាប់ជើង ក្នុងតំបន់ហ្នឹងដែរកាលជំនាន់នោះ ព្រោះទីមួយ គឺចាស់ ហើយគាត់នៅក្នុងគណៈតំបន់ហ្នឹង អាចគាត់ចូលមកក្នុងអចិន្ត្រៃយ៍តំបន់ដែរ កាលជំនាន់នោះ ព្រោះគាត់ប្រជុំអីក្នុង ជាមួយស្រុក ជាមួយអ៊ំចឹង គាត់អាចនៅខាងស្តាំ អ៊ំសោម អ៊ំចឹងទៅ។ អាហ្នឹងតាមដែលខ្ញុំមើលឃើញកាលពីជំនាន់ខ្ញុំធ្លាប់នៅអង្គរជ័យ តាមខ្ញុំក្តាប់បាន ដែលខ្ញុំដឹង។ ស. ចុះតាគុំនេះ គាត់មានតួនាទីធ្វើអ្វីដែរ នៅស្រុកគីរីវង់នោះ? ឆ. តាគុំជាលេខាស្រុកគីរីវង់។ ស. ហើយលោកបានឆ្លើយថា តាទិត្យ នេះគឺធំជាងតាគុំ ពីព្រោះគាត់ធ្វើនៅ ការនៅថ្នាក់តំបន់។ តើត្រឹមត្រូវដែរទេ? ឆ. បញ្ហាត្រឹមត្រូវ។ ដោយឡែកដែលខ្ញុំក្តាប់បាន ត្រង់ថាអ៊ំចេះ ត្រង់ថា ធម្មតាក្នុងអង្គប្រជុំអីដែលគាត់ ដែលខ្ញុំនិងនីរសា ចេញចូលក្នុងមន្ទីរ គឺចង់ប្រជុំ អ៊ំទិត្យ គាត់មានសិទ្ធិអង្គុយក្នុងជួរមុខ ជាមួយអ៊ំសោម អ៊ំចឹងទៅដល់ខាងស្រុក គឺនៅអង្គុយខាងក្រោយ ខាងមុខ។ បានន័យថា អ៊ំទិត្យ គាត់មានសិទ្ធិចាត់ចែង ព្រោះគាត់ម្យ៉ាង គាត់ជាសាច់ញាតិរបស់តា ១៥ ជាប្អូនថ្លៃបង្កើតរបស់តា"។ (ដោយគូសបញ្ជាក់បន្ថែម)។

[655] កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤ ឯកសារ D119/85 នៅត្រង់ ERN (ភាសាខ្មែរ)។ 00975767 (ឆ២៤ -ឆ២៥) ("តាទិត្យមកពីតំបន់មានឋានៈខ្ពស់ជាង [...] ស. ហេតុអ្វីបានជាលោកដឹងអំពីរឿងនេះ? ឆ. ២៥ ខ្ញុំដឹងរឿងនេះពីម្តាយរបស់ខ្ញុំ ពីព្រោះ**ម្តាយរបស់ខ្ញុំ គឺជាបងប្អូនជីដូនមួយរបស់តាគុំ**។ គាត់ប្រាប់ខ្ញុំអំពីរឿង តា គុំ ថានឹងត្រូវមានរឿងរ៉ាវហើយ មុនពេលដែលខ្ញុំចេញទៅក្រចេះម្តេះ") (គូសបញ្ជាក់បន្ថែម)។

[656] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៤៨។

[657] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/20 នៅត្រង់ ERN 00891142 (ឆ៧)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ឯកសារ D219/466 នៅត្រង់ ERN 01132108 (ឆ១០៣), សំណុំរឿង ០០៤ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១១ ឯកសារ D11 ERN 00687000។

បង្ហាញបន្ថែមថា គាត់ត្រូវបានគេបញ្ជូនឲ្យទៅរស់នៅ និងធ្វើការនៅស្រុកគីរីវង់ "នៅកន្លែងដែលតាទិតគ្រប់គ្រង"[659] ហើយបានដឹងថា យឹម ទិត្យ "មានតួនាទីធំ" "ប្រហែលជាថ្នាក់ស្រុក គឺស្រុកគីរីវង់"[660]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាយ៉ាងច្បាស់លាស់ទៅលើភស្តុតាងដែលផ្ទុយគ្នារបស់ ទឹម ភួន ដើម្បីឈានដល់ការសន្និដ្ឋានថា យឹម ទិត្យ មាន "តួនាទីធំ" នៅស្រុកគីរីវង់[661]។

280. ចំពោះ ង៉ែត ងយ ដែលត្រូវបានចោទថា "មិនដឹងអ្វីទាំងអស់អំពីលោក យឹម ទិត្យ តាមការឆ្លងកាត់ផ្ទាល់របស់គាត់"[662]នោះ អង្គជំនុំជម្រះកត់សម្គាល់ថា ង៉ែត ងយ បានឃើញ យឹម ទិត្យ ញឹកញាប់ ហើយបាននិយាយជាមួយគាត់ម្តងផង[663]។ ទោះបីជាគាត់បានដឹងអំពី "គណៈឃុំឈ្មោះ ផន និង នេន" ថា យឹម ទិត្យ និងតាគុំ គឺជាប្រធានស្រុកគីរីវង់[664] និងថា យឹម ទិត្យ មានឋានៈធំជាង តាគុំ[665] តែអង្គជំនុំជម្រះរម្លឹកថា មានការកំណត់ច្បាស់លាស់ហើយថា ភស្តុតាងចចាមអារាម អាច

---

[658] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ចុះចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/20 នៅត្រង់ ERN 00891142 (ឆ១០)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ឯកសារ D219/466 នៅត្រង់ ERN 01132108 (ឆ១០៣)។

[659] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/20 នៅត្រង់ ERN 00891141-00891142 (ឆ៤-ឆ៦) ("នៅចុងឆ្នាំ១៩៧៥ គេបញ្ជូនខ្ញុំឲ្យទៅនៅពេជ្រសារ ជិតទំលាប់ ក្នុងស្រុកគីរីវង់... នៅកន្លែងដែលតាទិតគ្រប់គ្រង")។

[660] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/20 នៅត្រង់ ERN 00891142 (ឆ១០)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទឹម ភួន ឯកសារ D219/466 នៅត្រង់ ERN 01132121 (ឆ២៤៤ -ឆ២៤៧)។

[661] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៣២ ជើងទំព័រ ៨៧១ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពិចារណាលើចម្លើយរបស់ ទឹម ភួន ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (ដែល ទឹម ភួន បាននិយាយថា យឹម ទិត្យ "ជាលេខាស្រុកគីរីវង់") និងចម្លើយបន្ទាប់មក (ដែល ទឹម ភួន ថាមិនបានដឹងថា យឹម ទិត្យ "ជាលេខាស្រុក")។

[662] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៩៩។

[663] កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ងយ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ឯកសារ D118/44 នៅត្រង់ ERN 00905848 00905848 (ឆ១២ -ឆ១៤)។

[664] កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ងយ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ឯកសារ D118/44 នៅត្រង់ ERN 00905848 (ឆ៩)។

[665] កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ងយ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ឯកសារ នៅត្រង់ ERN 00905848 (ឆ៥)។

ទទួលយកបាន ហើយមិនមានកំហុសអ្វី នៅក្នុងការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បាន ពឹងផ្អែកទៅលើភស្តុតាងនេះ ដើម្បីគាំទ្រដល់ការសម្រេចរបស់គាត់ឡើយ[666]។

281. ជាចុងក្រោយ សហមេធាវីមិនបានគាំទ្រដល់ការអះអាងដែលថា មិនមានភស្តុតាងគ្រប់គ្រាន់ថា យឹម ទិត្យ "បានអនុវត្ត ឬបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព" ឬតើតួនាទី និងការទទួលខុសត្រូវរបស់គាត់មានអ្វីខ្លះ[667]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបញ្ជាក់ច្បាស់ថា "យឹម ទិត្យ ធ្វើដំណើរគ្រប់កន្លែងក្នុងស្រុកគីរីវង់ ដើម្បីត្រួតពិនិត្យមើលការដ្ឋាន ទទួលរបាយការណ៍ និងដឹកនាំការប្រជុំទាក់ទងគោលដៅផលិត"[668]។ គាត់ចុះទៅពិនិត្យមន្ទីរសន្តិសុខវត្តព្រះធាតុជាច្រើនដង ដែលនៅទីនោះ គាត់បានសាកសួរចម្លើយសាក្សី និងកំណត់ថា ពួកគេជាខ្មាំង[669]។ សាក្សីជាច្រើនរូបបានរាយការណ៍ថា យឹម ទិត្យ ទទួលខុសត្រូវលើ "*ឃោសនាការ*" "*ពង្រឹងផ្នែកនយោបាយ*" ឬសេដ្ឋកិច្ច និងភស្តុភារ[670]។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ការសម្រេចទាំងអស់នេះត្រូវបានគាំទ្រគ្រប់គ្រាន់ ដោយភស្តុតាងរបស់សាក្សី[671] និងដោយសារតែសហមេធាវី មិនបានលើកឡើងនូវការជំទាស់ជាក់លាក់ ចំពោះភស្តុតាងដែលគាំទ្រការសម្រេចទាំងអស់នេះ ឬបង្ហាញថា ហេតុអ្វីទើបភស្តុតាងដែលបានដកស្រង់ មិនគ្រប់គ្រាន់នោះ អង្គជំនុំជម្រះត្រូវតែច្រានចោលការចោទប្រកាន់នេះ[672]។

282. អាស្រ័យហេតុនេះ សម្រេចបដិសេធមូលដ្ឋាន ៥(២)(i)។

---

[666] សូមមើល*ខាងលើ* មូលដ្ឋានទី៥ ការពិចារណាលើភស្តុតាង។

[667] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥១។

[668] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣៣៥។

[669] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣៣៦, ៣៩២, ៤៣៩, ៤៦៣-៤៦៩។

[670] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣៣៦។

[671] សូមមើលឧទាហរណ៍ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382) កថាខណ្ឌ ៣៣៦ ជើងទំព័រ ៨៧៧-៨៧៨។

[672] អង្គជំនុំជម្រះសូមរំឮកថា បន្ទុកគឺស្ថិតលើម្ចាស់បណ្តឹងឧទ្ធរណ៍ ដើម្បីបង្ហាញថា មិនមានអ្នកវិនិច្ឆ័យលើអង្គហេតុដោយសមហេតុផលណា អាចសម្រេចនិងពឹងផ្អែក លើភស្តុតាងដែលរងការជំទាស់ នៅក្នុងការសម្រេចលើអង្គហេតុ។ សូមមើលឧទាហរណ៍ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Stanišić & Župljanin*, IT-08-91-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ ២៥។ តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Gotovina & Markač*, IT-06-90-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១ 2012, កថាខណ្ឌ ១៥។

## មូលដ្ឋាន ៥.២ (ii)៖ កំហុសដែលទទួលការចោទប្រកាន់ ក្នុងការសម្រេចថា យឹម ទិត្យ មាន "សិទ្ធិអំណាចជាក់ស្តែងច្រើន" នៅតំបន់១៣

### ១. សារណា

283. សហមេធាវីជំទាស់ទៅនឹងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសិទ្ធិអំណាចតាមព្រឹត្តិន័យ និងតួនាទីតាមនីតិន័យ នៅក្នុងតំបន់ ១៣។ ទីមួយ ពាក់ព័ន្ធនឹងការសម្រេចផ្នែកនីតិន័យ សហមេធាវីបានលើកឡើងថា ការសម្រេចមិនច្បាស់លាស់ ឬផ្អែកលើភស្តុតាងមិនគ្រប់គ្រាន់។ ចំពោះការចោទពីការតែងតាំង យឹម ទិត្យ តាមនីតិន័យ ទៅក្នុងគណៈកម្មាធិការតំបន់ ១៣ សហមេធាវីបានបង្ហាញថា ការសម្រេចមិនបានបញ្ជាក់ពីតួនាទីជាក់លាក់របស់ យឹម ទិត្យ នៅក្នុងគណៈកម្មាធិការ អំពីការទទួលខុសត្រូវជាក់លាក់របស់គាត់ ឬរយៈពេលជាក់លាក់នៃការចោទពីអាណត្តិការងាររបស់គាត់[673]។ ចំពោះសហមេធាវី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏មានភស្តុតាងមិនគ្រប់គ្រាន់អំពីការតែងតាំង យឹម ទិត្យ ជាលេខាតំបន់១៣ផងដែរ[674]។

284. ទីពីរ ចំពោះសិទ្ធិអំណាចតាមព្រឹត្តិន័យ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយ (១) ពឹងផ្អែកលើការយល់ឃើញមិនត្រឹមត្រូវ អំពីទំនាក់ទំនងរវាង យឹម ទិត្យ និង តាម៉ុក ដើម្បី "ប៉ះប៉ូវ" ជាមួយនឹងភស្តុតាងមិនគ្រប់គ្រាន់ពីអំពើ និងការប្រព្រឹត្តិរបស់ យឹម ទិត្យ[675] (២) សន្និដ្ឋានថា យឹម ទិត្យ មានការប្រជុំ និងទទួលភ្ញៀវនៅមន្ទីរតំបន់១៣ជាទៀងទាត់ ដោយផ្អែកលើភស្តុតាង ដែលគ្មានការបញ្ជាក់របស់ ប៊ុច ជឹម[676] (៣) ពឹងផ្អែកលើទស្សនៈ និងភស្តុតាងចចាមអារាម ដែលគ្មានការបញ្ជាក់ និងផ្ទុយគ្នា របស់ "កម្មាភិបាលថ្នាក់ក្រោម" ម៉ឹង វេត[677]។

285. លើសពីនេះទៀត សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានធ្វើការសម្រេចអំពីសិទ្ធិអំណាចតាមព្រឹត្តិន័យ របស់បុគ្គលដទៃទៀត ដូចជា វ៉ាញ់ បិត ដែលថា ស្ថិត

---

[673] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥៤។

[674] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥៥។

[675] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥៦។

[676] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥៧។

[677] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥៨។

01677220



នៅក្នុង គណៈកម្មាធិការតំបន់១៣ និងមិនបានផ្តល់សំអាងហេតុ សម្រាប់ការសម្រេចថា សិទ្ធិអំណាចតាមព្រឹត្តិន័យរបស់ យឹម ទិត្យ ខ្លាំងជាងអ្នកដទៃឡើយ[678]។ បើតាមសហមេធាវី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនយកចិត្តទុកដាក់ទៅលើភស្តុតាងរបស់សាក្សី ៣៦ រូប ដែលរស់នៅ និងធ្វើការ នៅក្នុងតំបន់១៣ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងដែលបានបញ្ជាក់ថា ពួកគេមិនដែលឮអំពី យឹម ទិត្យ "ធ្វើឱ្យប៉ះពាល់ដល់" ការសន្និដ្ឋានរបស់ខ្លួន ថា យឹម ទិត្យ មានសិទ្ធិអំណាចធំទូទាំងតំបន់១៣[679]។

286. សហមេធាវីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសលើអង្គច្បាប់ ដោយអនុវត្តបទដ្ឋានគតិយុត្តិមិនត្រឹមត្រូវ និងមិនបានផ្តល់សំអាងហេតុ[680]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គហេតុ ដោយទាញសន្និដ្ឋាន ដែលខុសពិតប្រាកដ អំពីសិទ្ធិអំណាចតាមព្រឹត្តិន័យ របស់ យឹម ទិត្យ នៅក្នុងតំបន់ ១៣ ដែលបណ្តាលឱ្យមានភាពអយុត្តិធម៌ ដែលតម្រូវឱ្យមានការបដិសេធចោល[681]។

287. សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបថា "ការវិភាគដែលប្រាសចាកពីនិយាម" និង "ជ្រើសរើស" ភស្តុតាងរបស់ យឹម ទិត្យ មិនបានបង្ហាញអំពីកំហុសអង្គហេតុ ឬអង្គច្បាប់ណាមួយ ដែលអាចត្រួតពិនិត្យឡើងវិញបានឡើយ[682]។ ជាដំបូង ចំពោះតួនាទីតាមនីតិន័យរបស់ យឹម ទីត្យ នៅក្នុងគណៈកម្មាធិការតំបន់ ១៣ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ការពឹងផ្អែករបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅលើសាក្សីផ្ទៃក្នុង ដែលផ្តល់សក្ខីកម្មអំពីការកាន់កាប់តួនាទី ជាលេខាតំបន់១៣ នៅក្នុងឆ្នាំ១៩៧៥ ១៩៧៦ ១៩៧៧ ឬ១៩៧៨ បានបញ្ជាក់អំពី "វត្តមាន" របស់

---

678 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥៩ យោងទៅរក EN 00105142-00105143។

679 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៦០។ សំណុំរឿង ០០៤ ឧបសម្ព័ន្ធ ក នៃបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)៖ សាក្សីដែលមិនធ្លាប់ឮពីឈ្មោះ យឹម ទិត្យ ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D382/22.2។

680 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៦១-១៦៣។

681 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៦១-១៦៣។

682 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ៩១។

យឹម ទិត្យ នៅក្នុងអំឡុងពេលវេលាពាក់ព័ន្ធ[683]។ សហព្រះរាជអាជ្ញាអន្តរជាតិ ក៏បានកត់សម្គាល់ផងដែរ អំពីការសម្រេចនៅក្នុង ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលថា យឹម ទិត្យ មានតួនាទីជាលេខាតំបន់ ១៣ នៅចន្លោះឆ្នាំ ១៩៧៦ ដល់ពាក់កណ្ដាលឆ្នាំ ១៩៧៧[684]។

288. ទីពីរ ពាក់ព័ន្ធសិទ្ធិអំណាចតាមព្រឹត្តិន័យរបស់គាត់ នៅក្នុងតំបន់១៣ សហព្រះរាជអាជ្ញាអន្តរជាតិ បានជំទាស់ចំពោះសញ្ញាណដែលថា ភស្តុតាងអំពី យឹម ទិត្យ ចុះពិនិត្យការដ្ឋាន ចូលរួមការប្រជុំ និងធ្វើការនៅក្នុងមន្ទីរភូមភាគនិរតី គឺជា "កត្តាមិនពាក់ព័ន្ធ"[685]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិ បានកត់សម្គាល់ថា សហមេធាវីមិនបានយោងទៅសាក្សីគន្លឹះណាមួយ និងបង្ហាញភស្តុតាងដោយមិនត្រឹមត្រូវ ឬដោយជ្រើសរើស រួមទាំង សក្ខីកម្មរបស់ ប៊ុច ជឹម ដែលបានជួប យឹម ទិត្យ "ជាច្រើនដងណាស់" នៅមន្ទីរតំបន់ ១៣[686]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានរិះគន់ដល់ការបង្ហាញរបស់សហមេធាវី ចំពោះភស្តុតាងរបស់ ម៉ឹង វេត ដោយសន្និដ្ឋានថា មិនមានការផ្ទុយគ្នាឡើយ[687]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានវាយបកថា ការសម្រេចអំពីសិទ្ធិអំណាចតាមព្រឹត្តិន័យរបស់បុគ្គលដទៃទៀត នៅក្នុងគណៈកម្មាធិការតំបន់ ១៣ មិនពាក់ព័ន្ធឡើយ ដោយសារហេតុផលជាច្រើន ក្នុងនោះ គឺ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ធ្វើការស៊ើបអង្កេតតែទៅលើ អំពើ និងការប្រព្រឹត្តិរបស់ យឹម ទិត្យ ប៉ុណ្ណោះ មិនមែនអំពើ និងការប្រព្រឹត្តិរបស់អ្នកដទៃឡើយ[688]។ ទោះជាក្នុងករណីណាក្តី ឧទាហរណ៍ របស់ វ៉ាញ់ ប៊ិត គឺជាឧទាហរណ៍ដែល

---

[683] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ៨២ យោងទៅរក ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៤៦។

[684] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ៨២ យោងទៅរកដីកាសម្រេចលើកលែងចោទប្រកាន់ (D381), កថាខណ្ឌ ៦៦៨, ៦៨០។

[685] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ៨៣ យោងទៅរក ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៤៨-៣៥១។

[686] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ៨៤។

[687] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ៨៥។

[688] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ៨៦ យោងទៅរក វិធាន ៥៥(២) ៥៥(៤) នៃវិធានផ្ទៃក្នុង។

គ្មានការគាំទ្រ ឬធ្វើឲ្យយល់ច្រឡំ[689]។ ជាលទ្ធផល ការអះអាងរបស់សហមេធាវីដែលថា មានការអនុវត្តបទដ្ឋានគតិយុត្តិ ដែលមិនត្រឹមត្រូវនោះ គឺគ្មានមូលដ្ឋានឡើយ ដែលអាចចាត់ទុកថាជា ការផ្ទុយទៅនឹងការសន្និដ្ឋានដែលធ្វើឡើង មិនមែនជាកំហុសអង្គហេតុ ឬកំហុសអង្គច្បាប់ឡើយ[690]។

## ២. ការពិភាក្សា

289. ចៅក្រមអន្តរជាតិជាដំបូងនឹងធ្វើការពិចារណាទៅលើការជំទាស់របស់សហមេធាវី ពាក់ព័ន្ធនឹងសិទ្ធិអំណាចតាមព្រឹត្តិន័យរបស់ យឹម ទិត្យ នៅក្នុងតំបន់១៣ រួចហើយទើបបន្តទៅដោះស្រាយការជំទាស់ ពាក់ព័ន្ធតួនាទីតាមនីតិន័យរបស់គាត់។

290. ដូចដែលបានសម្រេចរួចហើយ ជាផ្នែកមួយនៃការពិភាក្សា លើមូលដ្ឋាន ៥.១ នោះ ចៅក្រមអន្តរជាតិបានសម្រេចថា មិនមានកំហុសឡើយ នៅក្នុងការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រើប្រាស់ភស្តុតាងអំពីទំនាក់ទំនងការងារ និងក្រុមគ្រួសារដ៏ជិតស្និទ្ធរបស់ យឹម ទិត្យ ជាមួយ តាម៉ុក ហើយនៅពេលត្រួតពិនិត្យឡើងវិញ លើសក្ខីកម្មដែលរងការជំទាស់ អង្គជំនុំជម្រះបានរកឃើញថា មានភស្តុតាងគ្រប់គ្រាន់សម្រាប់អ្នកវិនិច្ឆ័យអង្គហេតុ ប្រកបដោយហេតុផលម្នាក់ អាចធ្វើការសន្និដ្ឋានបានថា ទំនាក់ទំនងនេះបានផ្តល់ដល់ យឹម ទិត្យ នូវសិទ្ធិអំណាចតាមព្រឹត្តិន័យ ហួសពីតួនាទីផ្លូវការរបស់គាត់ នៅក្នុងតំបន់១៣ នៃភូមិភាគនិរតី[691]។ អង្គជំនុំជម្រះគាំទ្រចំពោះការសម្រេចទាំងអស់នេះ ពាក់ព័ន្ធនឹងកម្រិតនៃការទទួលខុសត្រូវ តាមព្រឹត្តិន័យរបស់ យឹម ទិត្យ នៅក្នុងតំបន់១៣ ដូច្នេះហើយសម្រេចបដិសេធទឡ្ហីករណ៍របស់សហមេធាវីដែលថា ចំណុចនេះបង្កើតបានជាការទាញចេញដោយមិនត្រឹមត្រូវនូវពិរុទ្ធភាពរបស់ យឹម ទិត្យ តាមរយៈទំនាក់ទំនងដ៏សាមញ្ញជាមួយ តា ម៉ុក[692]។

291. នៅក្នុងទំនាក់ទំនងនេះ ចៅក្រមអន្តរជាតិបានត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នទៅលើការជំទាស់អង្គហេតុបន្ថែមទៀតចំពោះសក្ខីកម្មសាក្សី ដែលលើកឡើងដោយសហមេធាវី នៅក្នុងមូលដ្ឋានរង

---

[689] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ៩៦ យោងទៅរកសាលក្រមសំណុំរឿង ០០២/០២ (E465) កថាខណ្ឌ ៩១០-៩១៧។

[690] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ៩៩។

[691] *សូមមើលខាងលើ* មូលដ្ឋាន ៥.១។

[692] *ផ្ទុយ* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥៦។

នេះ ក្នុងបណ្តឹងឧទ្ធរណ៍ ប៉ុន្តែ អង្គជំនុំជម្រះមិនជឿថា ការជំទាស់ទាំងអស់នេះអាចធ្វើឲ្យប៉ះពាល់ដល់ការសម្រេច របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើការទទួលខុសត្រូវ និងតួនាទីតាមព្រឹត្តិន័យរបស់ យឹម ទិត្យ នៅក្នុងតំបន់ ១៣ ឡើយ[693]។ លើសពីនេះទៀត ការកត់សម្គាល់ថា សាក្សី ៣៦ នាក់ ដែលរស់នៅក្នុងតំបន់នេះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានបញ្ជាក់ថា ពួកគេមិនដែលឮឈ្មោះ យឹម ទិត្យ មិនបានធ្វើឲ្យសហមេធាវីរួចផុតពីបន្ទុកក្នុងការកំណត់ថា មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ប្រកបដោយហេតុផលណាម្នាក់ អាចឈានដល់ការសម្រេច ពាក់ព័ន្ធនឹងសិទ្ធិអំណាចតាមព្រឹត្តិន័យ ដែលចោទជាបញ្ហានេះឡើយ[694]។ ចំណុចនេះកាន់

---

[693] ចំពោះពេជ្រ ជឹម ចៅក្រមអន្តរជាតិយល់ស្របជាមួយ សហមេធាវីថា ភស្តុតាងដែលបានដកស្រង់ មិនបានគាំទ្រជាពិសេសដល់ការសម្រេចដែលថា យឹម ទិត្យ ធ្វើការប្រជុំ និងទទួលភ្ញៀវនៅមន្ទីរតំបន់១៣ *ជាទៀងទាត់ឡើយ*។ ផ្ទុយពីការលើកឡើងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ចម្លើយរបស់ ពេជ្រ ជឹម អំពីការជួប យឹម ទិត្យ "ជាច្រើនដង" ពាក់ព័ន្ធ ជាមួយអំឡុងពេលដែល យឹម ទិត្យ ជាលេខាស្រុកគីរីវង់។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/79 នៅត្រង់ ERN 00934403 (ឆ៣១ឆ-៣២)។ សាក្សីប្រើប្រាស់ពាក្យ "ទៅ" និង "ចូលរួម" ដែលចង់បង្ហាញថា យឹម ទិត្យ ចូលរួមការប្រជុំ រួមជាមួយសមាជិកថ្នាក់ស្រុកដទៃទៀត នៅក្នុងតួនាទីកម្រិតស្រុក ហើយមិនមែនមានន័យថា ដឹកនាំការប្រជុំទាំងនោះ ក្នុងនាមជាមេដឹកនាំតាមព្រឹត្តិន័យ នៃតំបន់១៣ឡើយ។ សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D118/259 នៅត្រង់ ERN (ភាសាអង់គ្លេស) 01000670-71 (ឆ៣៦, ឆ៣៨)។ ទោះជាបែបនេះក្តី កំហុសនេះមិនបានបណ្តាល ឲ្យមានការច្រានចោលនូវ សេចក្តីសន្និដ្ឋានជារួមទៅលើ ការប្រើប្រាស់សិទ្ធិអំណាច តាមព្រឹត្តិន័យដ៏សំខាន់ របស់ យឹម ទិត្យ នៅក្នុងតំបន់១៣ដែរ។ ចំពោះ ម៉ឹង វេត សាក្សីនេះគឺជាប្រធានក្រុមនីរសា នៅស្រុកគីរីវង់ តំបន់១៣ និងស្ថិតក្នុងស្ថានភាពមួយដ៏ល្អ ក្នុងការផ្តល់ភស្តុតាង អំពីការកត់សម្គាល់ផ្ទាល់ខ្លួនរបស់គាត់ ទៅលើការរៀបចំកន្លែងអង្គុយសម្រាប់ យឹម ទិត្យ នៅក្នុងអំឡុងកិច្ចប្រជុំ កម្រិតតំបន់ រយៈពេល១០ថ្ងៃ នៅចុងឆ្នាំ១៩៧៦។ សំណុំរឿង ០០២ ប្រតិចារឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ (ម៉ឹង វេត) ឯកសារ D219/899.1.4 នៅត្រង់ ERN 01329899-01329900 ទំព័រ ៣៧ បន្ទាត់ ៨ -២៥ ទំព័រ ៣៨ បន្ទាត់ ១ -២០។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឹង វេត ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/488 នៅត្រង់ ERN 01136710 (ឆ៥៧ -ឆ៥៨)។ សាក្សីដទៃទៀតបានគាំទ្រថា បានឃើញ យឹម ទិត្យ នៅកិច្ចប្រជុំថ្នាក់តំបន់ នៅចុងឆ្នាំ១៩៧៦នេះដែរ។ *សូមមើល* កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ D118/274 នៅត្រង់ ERN 00999996 (ឆ៦៦,ឆ៦៨)។

[694] បន្ថែមលើនេះ ចៅក្រមអន្តរជាតិកត់សម្គាល់ថា សាក្សីដែលបានដកស្រង់ជាច្រើន ក៏បានបញ្ជាក់ផងដែរថា ពួកគេមិនបានដឹងអំពី រចនាសម្ព័ន្ធនយោបាយតំបន់១៣ ឬរចនាសម្ព័ន្ធនយោបាយ ខ្មែរក្រហមជាទូទៅនោះឡើយ។ *សូមមើល ជាឧទាហរណ៍* កំណត់ហេតុស្តាប់ចម្លើយសាក្សី ជាវ វ៉ាន់ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ឯកសារ D219/724 នៅត្រង់ ERN 01213621 (ឆ៧៣)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី សំ ទូច ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D219/604 នៅត្រង់ ERN 01173502 (ឆ១០៣)

01677224



តែសំខាន់ ដោយសារតែ "ភាពសម្ងាត់" ដែលបិទបាំងរចនាសម្ព័ន្ធដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា មិនឲ្យប្រជាជនកម្ពុជាទូទៅបានដឹងឮនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ[695]។

292. ចុងក្រោយ ការលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកាតព្វកិច្ចក្នុងការសម្រេចអំពីសិទ្ធិអំណាច ឬការទទួលខុសត្រូវរបស់បុគ្គលដទៃទៀត ដែលអាចថានៅក្នុងគណៈកម្មាធិការតំបន់១៣ ចាំបាច់ត្រូវតែបដិសេធចោល។ តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង មិនមានលក្ខខណ្ឌតម្រូវបែបនេះឡើយ សម្រាប់ការចេញដីកាដំណោះស្រាយ ចោទប្រកាន់ បញ្ជូនទៅជំនុំជម្រះ យឹម ទិត្យ ដែលជាជនត្រូវចោទក្នុងសំណុំរឿងនេះ[696]។ ដូចដែលបានសម្រេចកន្លងមក ទោះបីជាការវាយតម្លៃថាតើ ជនសង្ស័យស្ថិតនៅក្នុងចំណោមអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" អាចមានការប្រៀបធៀបជាមួយនឹងកម្មាភិបាលខ្មែរក្រហមដទៃទៀតក្តី តែការប្រៀបធៀបជាមួយនឹងកម្មាភិបាលខ្មែរក្រហមទាំងអស់ដែលគេស្គាល់ មិនមែនជាលក្ខខណ្ឌតម្រូវ ឬមិនមានភាពចាំបាច់ឡើយ[697]។

293. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសម្រេចបដិសេធទឡ្ហីករណ៍របស់សហមេធាវីដែលជំទាស់លើការសម្រេចលើសិទ្ធិអំណាចតាមព្រឹត្តិន័យរបស់ យឹម ទិត្យ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ នឹងធ្វើការពិភាក្សាអំពីទឡ្ហីករណនៅសល់ ដែលជំទាស់ទៅលើភាពមិនត្រឹមត្រូវ ឬភាពមិនគ្រប់គ្រាន់នៃ

("ស. កាលជំនាន់ខ្មែរក្រហម តើនរណាជាលេខាតំបន់? ឆ.១០៣ ខ្ញុំអត់ដឹង បានថាអត់ដឹង ដឹងតែធ្វើការ។ ឥឡូវចេះដឹងពីណាអង្គការអីណា"(។

[695] សាលក្រមសំណុំរឿង ០០១ (E188) កថាខណ្ឌ ៩៧ -៩៨។ សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០១ ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ("សាលក្រមសំណុំរឿង ០០២/០១ (E313)") កថាខណ្ឌ ១៩៩។

[696] សូមមើលផងដែរ វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង។

[697] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥៨។ សូមមើលផងដែរ សាលក្រមសំណុំរឿង ០០១ (E188) កថាខណ្ឌ ២៤ ("ដោយសារតែទំហំនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក មិនបានដាក់កាតព្វកិច្ច ឲ្យវិនិច្ឆ័យជនទាំងឡាយ ដែលអាចជាចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ។ [...] អង្គហេតុដែលថា បុគ្គលផ្សេងទៀត នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងអំឡុងពេលកាត់សេចក្តី អាចនឹងចូលរួមប្រព្រឹត្តបទល្មើសដូចគ្នាក៏ដោយ ក៏វាមិនបានធ្វើឲ្យជនជាប់ចោទ រួចផុតពីការចោទប្រកាន់ថា គាត់គឺជាជនម្នាក់ ក្នុងចំណោមជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតដែរ")។ (លុបចោលជើងទំព័រ)។

01677225



ភស្តុតាងដែលគាំទ្រចំពោះការសម្រេចទៅលើ តួនាទីតាមនីតិន័យរបស់ យឹម ទិត្យ នៅក្នុងតំបន់ ១៣[698]។

294. ចៅក្រមអន្តរជាតិរម្លឹកថា ក្នុងគោលបំណងដើម្បីត្រួតពិនិត្យទៅលើបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ បញ្ហាយុត្តាធិការពាក់ព័ន្ធគឺថាតើ យឹម ទិត្យ ស្ថិតក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬទេ និងជាផ្នែកមួយនៃការវាយតម្លៃនេះ បន្ថែមទៅនឹងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម កម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ ក៏ត្រូវបានយកមកពិចារណាផងដែរ[699]។ ការដេញដោលលើកម្រិតនៃការទទួលខុសត្រូវ ត្រូវបានធ្វើឡើងតាមរយៈ ការពិចារណាដែលរួមមានដូចជា ឋានានុក្រមតំណែង ឬតួនាទីរបស់ យឹម ទិត្យ និងភាពអចិន្ត្រៃយ៍នៃតួនាទីរបស់គាត់ បើទោះបីជាចាំបាច់ត្រូវរម្លឹក និងសង្កត់ធ្ងន់ថា មិនមានបទដ្ឋានសម្រាប់ចម្រាញ់លើតួនាទីនៅក្នុងឋានានុក្រមក្តី[700]។

295. ផ្អែកលើសេចក្តីពិចារណាលើអង្គច្បាប់ខាងលើ ប្រសិនបើភស្តុតាងនៅក្នុងសំណុំរឿង អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិធ្វើការសន្និដ្ឋានដោយគ្រប់គ្រាន់ថា ជនត្រូវចោទមានតួនាទីតាមនីតិន័យជាក់លាក់ នៅពេលវេលាជាក់លាក់ ដោយមានភារកិច្ចដែលកំណត់បានជាក់លាក់ ដូចដែលសហមេធាវីបានព្យាយាមដោយទទូច[701] ការធ្វើការសម្រេចបែបនេះ នឹងសម្រេចបាននូវភាពច្បាស់លាស់ ដែលចង់បាន ក្នុងការធ្វើការវិភាគលើ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។ ប៉ុន្តែកម្រិតនៃភាពច្បាស់លាស់មិនមានការតម្រូវជាចាំបាច់នោះឡើយ។

---

[698] ចៅក្រមអន្តរជាតិច្រានចោលជារួម ទៅលើការចោទប្រកាន់ជាការសន្និដ្ឋាន ដែលលើកឡើងនៅក្នុង កថាខណ្ឌ ១៦២១៦៣ នៃបណ្តឹងឧទ្ធរណ៍។

[699] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១៤១។ សូមមើលផងដែរ យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។

[700] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ១៤១។ សូមមើលផងដែរ យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៥២, ៣៥៣។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ (D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១។

[701] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ១៥៥។

296. នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា គាត់មិនអាចឈានដល់ការសម្រេចលើ "កាលបរិច្ឆេទជាក់លាក់ ឬអំពីរយៈពេល" នៃការកាន់តំណែងរបស់ យឹម ទិត្យ បើទោះបីជាគាត់អាចសន្និដ្ឋានបានថា យឹម ទិត្យ "ជាលេខាភូមិភាគ១៣ នៅពេលមួយក្នុងអំឡុង របបកម្ពុជាប្រជាធិបតេយ្យ"[702]។ អង្គបុរេជំនុំជម្រះអាចមើលឃើញថា មិនមានកំហុសនៅក្នុង ការទទួលស្គាល់ដោយស្មោះត្រង់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថាភស្តុតាងក្នុងសំណុំរឿង លើកាលបរិច្ឆេទនៃអណត្តិការងារ "ផ្ទុយគ្នា" ហើយផ្ទុយទៅវិញ ដោយបង្ហាញពីកាលបរិច្ឆេទដែលមិនស្របគ្នា ដែលសាក្សី អ៊ុល ហឿន, នុត នូវ, ម៉ឺង វេត, សាន់ ឡូន, ពេជ្រ ជឹម, វ៉ាន់ យ៉ាន់ និងណុប ណាន បានផ្តល់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្ហាញថាគាត់បានធ្វើការពិចារណាដោយប្រុងប្រយ័ត្ន ទៅលើភស្តុតាងដែលមិនស្របគ្នាទាំងនេះ។ សំខាន់បំផុតនោះ ដោយមិនគិតអំពីភាពខុសគ្នាលើកាលបរិច្ឆេទទាំងអស់នេះ ព័ត៌មានរបស់សាក្សីទាំងអស់នេះ ប្រមូលផ្តុំទៅលើចំណុចមួយដែលថា យឹម ទិត្យ គឺជាលេខាតំបន់១៣ ដែលអនុញ្ញាតឱ្យមានការសម្រេច ដែលបំពេញបានតាម លក្ខខណ្ឌតម្រូវជាធរមាននៃ "ភស្តុតាងគ្រប់គ្រាន់"។ បន្ទាប់ពីត្រួតពិនិត្យឡើងវិញ អង្គបុរេជំនុំជម្រះជឿជាក់ថា មានភស្តុតាងគ្រប់គ្រាន់ក្នុងការសម្រេចថា យឹម ទិត្យ បំពេញការងារនៅក្នុងគណៈកម្មាធិការតំបន់១៣[703]។

297. ការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអាចធ្វើការសម្រេចជាក់លាក់អំពីកាលបរិច្ឆេទ និងរយៈពេលនៃតួនាទីតាមនីតិន័យរបស់ យឹម ទិត្យ ទោះជាក្នុងករណីណាក្តី គ្រាន់តែបង្ហាញឱ្យឃើញអំពីកត្តាមួយក្នុងចំណោមកត្តាជាច្រើន នៅក្នុងការវាយតម្លៃជារួមទៅលើកម្រិតនៃការទទួល

---

[702] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៤៦។

[703] សាក្សីជាច្រើនផ្សេងគ្នា បានផ្តល់សក្ខីកម្មថា យឹម ទិត្យ នៅក្នុង "គណៈកម្មាធិការតំបន់១៣" "ឡើងទៅជាគណៈកម្មាធិការតំបន់" និង "ជាលេខាតំបន់ ១៣"។ *សូមមើលជាឧទាហរណ៍* កំណត់ហេតុស្តាប់ចម្លើយសាក្សី ខឹម វៃ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D219/636 នៅត្រង់ ERN 01184402 (ឆ៣៨)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ឺង វេត ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D219/488 នៅត្រង់ ERN 01136705 (ឆ៣១)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី នុត នូវ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/228 នៅត្រង់ ERN 01075759 (ឆ២៥)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡោ ធន ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ ឯកសារ D219/951 នៅត្រង់ ERN 01420562 (ឆ១១៩)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ដុក ចាន់ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/86 នៅត្រង់ ERN 01040104 (ឆ៧)។

ខុសត្រូវរបស់គាត់ប៉ុណ្ណោះ។ ក្នុងករណីនេះ ចៅក្រមអន្តរជាតិសម្រេចថា កត្តាទាំងអស់នេះ មិនមែនជាកត្តាកំណត់ ជាសារវ័ន្តឡើយ។

298. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា មូលដ្ឋាន ៥.២.(i) ត្រូវបដិសេធចោល។

## មូលដ្ឋានទី ៥.២ (iii) ÷ កំហុសដែលទាក់ទងការចោទប្រកាន់លើការសម្រេចថា យឹម ទិត្យ គឺជាលេខាតំបន់ ១

### ក. សារណា

299. សហមេធាវីបានជំទាស់ទៅនឹងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ គឺជាលេខាតំបន់១ តាមព្រឹត្តិន័យ និង/ឬនីតិន័យ។ ជាដំបូង សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ ត្រូវបានតែងតាំងជាលេខា តំបន់ ១ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ ហើយបានប្រើប្រាស់សិទ្ធិអំណាចរហូតដល់របបបានបញ្ចប់[704]។ សហមេធាវីបានចោទប្រកាន់ថា ការសម្រេចថា យឹម ទិត្យ មកជំនួសតាប៉ែត ក្រោយពេលគេដកតំណែងគាត់ មិនត្រឹមត្រូវទេ ហើយក៏មិនមានភស្តុតាងគាំទ្រដែរ[705] ព្រោះមិនមានសាក្សីណាម្នាក់បានផ្តល់ "ភស្តុតាងផ្ទាល់" អំពីការតែងតាំង យឹម ទិត្យ ឡើយ[706]។ សហមេធាវីបានលើកឡើងនូវទឡ្ហីករណ៍ ជាក់លាក់អំពីការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងសេចក្តីពិចារណារបស់ខ្លួន មិនបានពិចារណាទៅលើភស្តុតាងរបស់សាក្សីមួយចំនួន រួមទាំង លើបញ្ហានានា ដូចជា ការមិនស្គាល់ ឬមានទំនាក់ទំនងតិចតួចជាមួយនឹង យឹម ទិត្យ ការលើកឡើងដោយមិនត្រឹមត្រូវ ឬមិនស្របគ្នាអំពីកាលបរិច្ឆេទ មនុស្ស ឬហេតុការណ៍ផ្សេងៗ ការមិនអាចកំណត់អត្តសញ្ញាណ យឹម ទិត្យ និងការមិនមានការបញ្ជាក់ទៅលើព័ត៌មានមួយចំនួន[707]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសបន្ថែមទៀត ដោយពឹងផ្អែកទៅលើភស្តុតាង ដែលមិនមានការគាំទ្ររបស់ ឈាន ប៊ា (រួមទាំង អំពីការចោទពីការចាប់ខ្លួនតាប៉ែត)

---

[704] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៦៤។

[705] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៦៤។

[706] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៦៥។

[707] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៦៥ *យោងទៅរក* តុប សឹង លេក ពៀវ នាំ លុយ ជួន ថន វី ផាន់ ណុប ធីម ណង នី លៀស គង់ នួន មួន ឈឿន ប៊ាន។

ហើយបែរជាមិនពិចារណាទៅលើភ័ស្តុតាងដោះបន្ទុក និងផ្ទុយគ្នា ដែលផ្តល់ដោយសាក្សីដដែលនេះ សាក្សីដទៃផ្សេងៗទៀត និង/ឬឯកសារភ័ស្តុតាង[708]។

300. ទីពីរ សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេច ថា យឹម ទិត្យ ប្រើប្រាស់សិទ្ធិអំណាចនៅក្នុងតំបន់១ ក្នុងនាមជាលេខាតាមព្រឹត្តិន័យ[709]។ ដើម្បីសម្រេច ថា យឹម ទិត្យ មានសិទ្ធិអំណាច និងការគ្រប់គ្រងផ្ទាល់ទៅលើយោធាក្នុងតំបន់ ១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើភ័ស្តុតាងដែលមិនមានការគាំទ្ររបស់សាក្សីមួយរូប គឺ សឿន ម៉ាត់ ហើយមិនបានពិចារណាថា សាក្សីរូបនេះមិនដឹងថានរណាទទួលខុសត្រូវនៅក្នុងតំបន់ ១ នៅពេលនោះឡើយ ដោយគាត់គ្រាន់តែឮថា យឹម ទិត្យ ជាមេបញ្ជាការ ហើយមិនបានបញ្ជាក់ថា ក្នុងអំឡុងពេលណាឡើយ[710]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (១) មិនបានពន្យល់អំពីសញ្ញាណ នៃពាក្យថា "បញ្ជាផ្ទាល់ខ្លួន" នៅពេលសម្រេចថា យឹម ទិត្យ មានសិទ្ធិអំណាចលើ "បញ្ជាផ្ទាល់ខ្លួននៅក្នុងតំបន់" ដោយមិនមានភ័ស្តុតាងគ្រប់គ្រាន់[711] (២) មិនបានពិចារណាទៅលើភ័ស្តុតាងផ្ទុយគ្នារបស់សាក្សីជាច្រើនរូប[712] និងកត្តាពាក់ព័ន្ធដទៃទៀត នៅពេលសម្រេចថា យឹម ទិត្យ មានសិទ្ធិអំណាចលើអ្នកក្រោមបង្គាប់របស់គាត់ លើបញ្ហាសន្តិសុខ រួមទាំង លទ្ធភាពរបស់គាត់ក្នុងការណែនាំអ្នកដទៃ, ធ្វើរបាយការណ៍អំពីសកម្មភាពខ្មាំង ដឹកនាំការប្រជុំ និងផ្តល់ការណែនាំ "អប់រំ" ឬ "កម្ទេច"[713] (៣)

[708] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៦៦-១៦៩ (សហមេធាវីចោទប្រកាន់ថា ឈាន ប៊ា មិនបានឃើញការចាប់ខ្លួន តាប៉ែត ទេ ព្រោះគាត់រត់ចូលព្រៃហើយ។ លើសពីនេះទៀត វី ផាន់ បញ្ជាក់ថា យឹម ទិត្យ មកដល់ប្រហែលក្នុង ខែវិច្ឆិកា ឆ្នាំ១៩៧៨ និងថា តាប៉ែត បានប្រកាសថា តាទិត្យ មកជួយគ្រប់គ្រងតំបន់១។ លើសពីនេះ ហាន ធី បានចូលរួមការប្រជុំមួយ នៅចុងឆ្នាំ១៩៧៨ ដែលពេលនោះមានវត្តមានតាប៉ែត។ តាប៉ែតគឺជាសមាជិក គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម នៅក្នុងខែសីហា ឆ្នាំ១៩៧៨ បើតាមឯកសារ "ការរៀបចំអំណាច")។

[709] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៧០។

[710] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៧១។

[711] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៧២-១៧៣ *យោងទៅរក* ភស្តុតាងពាក់ព័ន្ធជាមួយ វី ផាន់ និងជួន ថន។

[712] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៧៤ *យោងទៅរក* ភស្តុតាងពាក់ព័ន្ធជាមួយ វី ផាន់ ជួន ថន ណុប ធីម ឈឿន ប៊ិន ត៉ឹង ឈឿត និង ណាង នី។

[713] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៧៤-១៧៥។

លើកឡើងដោយមិនត្រឹមត្រូវពីភស្តុតាងរបស់ ផា ប៉ែត ដែលមិនដឹងអំពីតួនាទីរបស់ យឹម ទិត្យ នៅពេលសន្និដ្ឋានថា យឹម ទិត្យ មានសិទ្ធិអំណាចក្នុងការការពារបុគ្គលផ្សេងៗពីការចាប់ខ្លួន និងសម្លាប់[714] និង (៤) ពឹងផ្អែកដោយមិនត្រឹមត្រូវទៅលើ សក្ខីកម្មដែលគ្មានការគាំទ្ររបស់ ឈឿង ប៊ាន ក្នុងការសម្រេចថា យឹម ទិត្យ ដោះលែងកម្មាភិបាលភូមិភាគពាយ័ព្យ (តាសាម៉ន) ហើយមិនបានពន្យល់ថា ហេតុអ្វីទើបខ្លួនមិនពិចារណាទៅលើមូលហេតុដទៃផ្សេងទៀត ចំពោះការរួចជីវិតរបស់តាសាម៉ន ក្រោយឆ្នាំ១៩៧៩[715]។

301. ចំពោះការសម្រេចថា យឹម ទិត្យ ទទួលខុសត្រូវលើសេដ្ឋកិច្ច នៅក្នុងតំបន់១ សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថាតើ “ការទទួលបន្ទុក” មានន័យដូចម្តេច នៅក្នុងន័យការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ ហើយពឹងផ្អែកទៅលើភស្តុតាង ដែលមិនអាចជឿជាក់បាន អំពីសុន្ទរកថារបស់ យឹម ទិត្យ ពាក់ព័ន្ធនឹង ធារាសាស្ត្រ និងការបង្កបង្កើនផល ព្រមទាំងការទៅពិនិត្យជាទៀងទាត់នៅទំនប់កង្ហត[716]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់សំអាងហេតុថាតើ គាត់អាចធ្វើការសម្រេចនេះដោយរបៀបណា ដោយគ្មានភស្តុតាងអំពីបញ្ហាផ្ទាល់ពី យឹម ទិត្យ ឬរបាយការណ៍បញ្ជូនទៅ យឹម ទិត្យនោះ[717]។ លើសពីនេះទៀត ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ មានសិទ្ធិអំណាចតាមព្រឹត្តិន័យ ទៅលើកម្មាភិបាលថ្នាក់ឃុំ និងថ្នាក់ស្រុក នៅតំបន់១ មិនសមហេតុផលទេ ព្រោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអាចកំណត់អំពីតួនាទី តាមនីតិន័យរបស់ យឹម ទិត្យ ដែលជាលេខាតំបន់១នោះ។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់សំអាងហេតុថា ហេតុអ្វីទើបភស្តុតាងដែលបានដកស្រង់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនបានយោងទៅការតែងតាំង យឹម ទិត្យ ជាលេខាតំបន់១ មានការពាក់ព័ន្ធជាមួយនឹងការកំណត់អំពីសិទ្ធិអំណាចតាមនីតិន័យរបស់ យឹម ទិត្យនោះ[718]។

---

[714] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៧៦-១៧៨ *យោងទៅរក* កំណត់ហេតុស្តាប់ចម្លើយសាក្សី ផា ប៉ែត ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤ ឆ៥ ERN 00990637 ឆ៩ ERN 00990638។

[715] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៧៩។

[716] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨០។

[717] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨០។

[718] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨១។

01677230



302. ជាចុងក្រោយ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានបែងចែករវាងតួនាទី និងសកម្មភាពរបស់ យឹម ទិត្យ និងតាម៉ុក នៅកិច្ចប្រជុំកម្រិតភូមិភាគ នៅបាត់ដំបង ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិចោទថា ក្នុងការប្រជុំនោះ ពួកគេចេញសេចក្តីណែនាំ និងលើកឡើងអំពីគោលដៅបង្កបង្កើនផល និងអត្រាកំណើត[719]។ នៅក្នុងការសម្រេចចំណុចខាងលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើសាក្សីតែមួយរូប គឺ ណុប ងឹម ដែលក្រោយមក បានដកវិញ នូវភ័ស្តុតាងរបស់គាត់ផ្នែកនេះ ហើយបញ្ជាក់ថា គាត់គ្រាន់តែបានចូលរួមការប្រជុំតែមួយប៉ុណ្ណោះ (នៅផ្ទះរបស់ យឹម ទិត្យ ដែលនៅទីនោះមិនមានអ្នកចូលរួមផ្សេងទេ)[720] ហើយការប្រជុំនេះអាចកើតឡើង ក្រោយខែកញ្ញា ឆ្នាំ១៩៧៨ ប៉ុណ្ណោះ នៅពេលដែលគាត់ត្រូវបានតែងតាំងជាអនុលេខាស្រុកសំឡូត[721]។ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានដោយមិនសមហេតុផលថា ការដកភ័ស្តុតាងវិញរបស់ ណុប ងឹម មិនអាចជឿជាក់បាន ដោយសារតែគាត់បានទទួលលិខិតធានា (ការពារគាត់ពីការប្រើប្រាស់ចម្លើយគាត់ប្រឆាំងនឹងខ្លួនឯង) ដូច្នេះហើយ គាត់មិនចាំបាច់ការពារតួនាទីរបស់គាត់ឡើយ[722]។ លើសពីនេះទៀត ចំពោះភ័ស្តុតាងរបស់ប្តីគាត់ គឺ ព្រាប កប សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាថា ព្រាប កប ពិការភ្នែក ធ្វើឱ្យគាត់មិនមានសម្បទាគ្រប់គ្រាន់ ជានិរសារឡើយ ថា ណុប ងឹម មិនដែលអនុញ្ញាតឱ្យ ព្រាប កប ពាក់ព័ន្ធជាមួយការងាររបស់គាត់ និងដឹងអ្វីទាល់តែសោះអំពីការងាររបស់គាត់ និងថា ណុប ងឹម មិនបានបញ្ជាក់នៅក្នុងចម្លើយណាមួយរបស់គាត់ថា ព្រាប កប ធ្លាប់ទៅចូលរួមការប្រជុំណាមួយជាមួយគាត់ ឬធ្លាប់និយាយប្រាប់ប្តីគាត់ ថាជាអនុលេខាស្រុកនោះឡើយ[723]។ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្ហាញដោយមិនត្រឹមត្រូវអំពីភ័ស្តុតាងរបស់ ណុប ងឹម សម្រេចដោយមិនត្រឹមត្រូវថា ណុប ងឹម អនុលេខាស្រុកសំឡូត បានរំឮកថា បានទទួលសេចក្តីណែនាំ សរសេរដោយដៃដោយ យឹម ទិត្យ ពីតំបន់ ប៉ុន្តែ ណុប ងឹម មិនដែលបញ្ជាក់ច្បាស់លាស់ថា សេចក្តីណែនាំនោះសរសេរដោយផ្ទាល់

[719] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨២។

[720] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨២-១៨៣។

[721] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨៥។

[722] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨៤ *យោងទៅរក* លិខិតធានារបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះលោកស្រី ណុប ងឹម ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥។

[723] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨៥។

ដៃរបស់ យឹម ទិត្យ និងការមិនចេះអក្សររបស់ ណុប ង៉ឹម ធ្វើឱ្យគាត់មិនអាចអាន ឬស្គាល់អក្សរសរសេរដៃឡើយ[724]។

303. សរុបទៅ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការសម្រេចថា យឹម ទិត្យ ជាលេខាតំបន់ ១ តាមព្រឹត្តិន័យ និងនីតិន័យ[725]។ ត្រឹមតែវត្តមានរបស់ យឹម ទិត្យ នៅក្នុងកិច្ចប្រជុំពីរបី និងចំណងទាក់ទងជាសាច់ញាត្តិរបស់ យឹម ទិត្យ ជាមួយ តាម៉ុក មិនអាចត្រូវបានចាត់ទុកថាជាការសន្និដ្ឋានអំពីសិទ្ធិអំណាចតាមព្រឹត្តិន័យជាលេខាតំបន់១ ឡើយ[726]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានវាយតម្លៃដោយត្រឹមត្រូវទៅលើចម្លើយសាក្សី មិនបានផ្តល់សំអាងហេតុ មិនបានពិចារណាលើភ័ស្តុតាងផ្ទុយ ដែលដោះបន្ទុក មិនបានអនុវត្តបទដ្ឋានភវនីយភាព និងមិនបានអនុវត្តគោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ[727] និងមិនពិចារណាលើភ័ស្តុតាងផ្ទុយ[728]។

304. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា បើតាមតុល្យភាពនៃភវនីយភាព មានភ័ស្តុតាងគ្រប់គ្រាន់ដែលថា យឹម ទិត្យ គឺជាលេខាតំបន់ ១ ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៧៨ រហូតដល់ពេលចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងថា សហមេធាវីមិនបានបង្ហាញនូវកំហុសដែលអាចត្រួតពិនិត្យបាន លើអង្គហេតុ ឬអង្គច្បាប់ឡើយ[729]។ សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ទៅនឹង ការលើកឡើងថា ភ័ស្តុតាងផ្ទាល់អំពីការតែងតាំងគឺជាការចាំបាច់ និងបានបញ្ជាក់ពីភ័ស្តុតាងរបស់ សាក្សីដែលបានដឹងអំពីតួនាទីរបស់ យឹម ទិត្យ ពីសកម្មភាព របស់គាត់ តាមរយៈមនុស្សឯទៀត ដែលមានទំនាក់ទំនងផ្ទាល់ជាមួយ យឹម ទិត្យ ឬតាមរយៈការដឹងឮទូទៅរបស់អ្នកដែលនៅក្នុងតំបន់១[730]។ សហព្រះរាជអាជ្ញាអន្តរជាតិយល់ថា ការព្យាយាមរបស់សហមេធាវីក្នុងការធ្វើឱ្យខូចខាតដល់សាក្សីសំខាន់ មិនអាចជឿជាក់បាន និង

---

[724] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨៦។

[725] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨៧។

[726] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨៧។

[727] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨៨។

[728] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ឯកសារ D382/22) កថាខណ្ឌ ១៨៨។

[729] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១០០។

[730] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១០១។

01677232



មិនមានមូលដ្ឋានឡើយ ហើយនេះជាការបង្ហាញអំពីការមិនបាន ពិនិត្យទៅលើភ័ស្តុតាងជារួម រួមទាំងភ័ស្តុតាងរបស់ លេខ ភីវ, វី ផាន, ណុប ធីម, ណាង នី, លៀស គង់ និងអ្នកដទៃទៀត[731]។

305. ចំពោះសិទ្ធិអំណាចរបស់ យឹម ទិត្យ ជាលេខាតំបន់ ១ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងប្រហាក់ប្រហែលគ្នាថា ភ័ស្តុតាងគ្រប់គ្រាន់បានបង្ហាញពីសិទ្ធិអំណាចរបស់ យឹម ទិត្យ ទៅលើអ្នកក្រោមបង្គាប់ រួមទាំង លើបញ្ហាសន្តិសុខ និងសេដ្ឋកិច្ច តាមរយៈការប្រជុំ របាយការណ៍ លិខិត និងការចុះពិនិត្យដល់ទីតាំង ហើយលើកឡើងថា មិនមានកំហុសដែលអាចត្រួតពិនិត្យឡើងវិញបាន ដូចដែលសហមេធាវីបានលើកឡើងនោះឡើយ[732]។ ជាពិសេស សហមេធាវីមិនពិចារណាទៅលើភ័ស្តុតាងពាក់ព័ន្ធនឹងការត្រួតត្រាប្រកបដោយប្រសិទ្ធភាពទៅលើអ្នកក្រោមបង្គាប់ សិទ្ធិអំណាចក្នុងការការពារកម្មាភិបាល ពីការចាប់ខ្លួន និងការសម្លាប់ សិទ្ធិអំណាចរបស់គាត់លើផ្នែកសេដ្ឋកិច្ច និងលទ្ធភាពរបស់គាត់ ក្នុងការចេញបញ្ជា និងសេចក្តីណែនាំសរសេរដោយដៃ[733]។ លើសពីនេះទៀត លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា មានភាពពាក់ព័ន្ធទៅនឹងការកំណត់អំពីការគ្រប់គ្រងតាមនីតិន័យរបស់ យឹម ទិត្យ ទៅលើអ្នកក្រោមបង្គាប់ និងភារកិច្ច និងអំណាចរបស់គាត់[734]។

306. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឡ្ហីករណ៍ទៀតថា សហមេធាវីមើលរំលងទៅលើភ័ស្តុតាងគាំទ្រ[735] និងថា ការព្យាយាមរបស់ពួកគេក្នុងការធ្វើឱ្យប៉ះពាល់ដល់សាក្សី ដែលផ្តល់សក្ខីកម្មអំពីសិទ្ធិអំណាចរបស់ យឹម ទិត្យ លើបញ្ហាសន្តិសុខ និងបុគ្គលិក ទទួលការបរាជ័យ ព្រោះថាសហមេធាវីមិនបានពន្យល់អំពីភាពពាក់ព័ន្ធនៃការជំទាស់របស់ខ្លួនចំពោះភ័ស្តុតាងសាក្សីមួយចំនួន[736]។ សម្រាប់សហព្រះរាជអាជ្ញាអន្តរជាតិ ការវាយតម្លៃមួយចំណែករបស់សហមេធាវីទៅលើភ័ស្តុតាង មិនមានភាពច្បាស់លាស់ ដូចជា អំណាចរបស់យឹម ទិត្យ ក្នុងការ

---

[731] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១០២-១០៤។

[732] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១០៥។

[733] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១០៦។

[734] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១០៧។

[735] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១០៨ ផ្ទុយពី ឯកសារ D382/22 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ កថាខណ្ឌ ១៧១។

[736] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១០៩ *យោងទៅរក* វី ផាន់ ណុប ធីម ឈឿន ប៊ាន នឹង ឈឿត និង ណាង នី។

ការពារបុគ្គលពីការចាប់ខ្លួន និងការសម្លាប់[737]។ ចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិបាន សង្កត់ធ្ងន់ថា ការព្យាយាមរបស់សហមេធាវី ក្នុងការធ្វើឱ្យប៉ះពាល់ដល់ការប្រព្រឹត្តិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើភ័ស្តុតាងរបស់ ណុប ធីម ពាក់ព័ន្ធនឹងការប្រជុំទៀងទាត់ដែល យឹម ទិត្យ បានចូលរួមនោះ មិនអាចជឿជាក់បានឡើយ[738]។

## ខ. ការពិភាក្សា

307. ដោយសារភាពស្មុគស្មាញនៃភ័ស្តុតាងដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការវាយតម្លៃ និងដោយសារសហមេធាវីមិនបានបង្ហាញអំពីកំហុសណាមួយ អង្គជំនុំជម្រះសម្រេចថា អ្នកវិនិច្ឆ័យលើអង្គហេតុប្រកបដោយហេតុផលម្នាក់ អាចធ្វើការសន្និដ្ឋានថា (១) យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់ ១ ចាប់ពីអំឡុងខែមិថុនា ឆ្នាំ១៩៧៨ រហូតដល់ចុងបញ្ចប់នៃរបបនេះ និង (២) យឹម ទិត្យ ប្រើប្រាស់សិទ្ធិអំណាចតាមព្រឹត្តិន័យនៅក្នុងតំបន់ ក្នុងពេលវេលាពាក់ព័ន្ធ[739]។

308. សហមេធាវីបានបំភ្លឺ "កំហុស" យ៉ាងច្រើនលើសលប់ ដែលជាចំណុចស្នូលនៃការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើភ័ស្តុតាងមួយចំនួនដែលពាក់ព័ន្ធ ដូចជា ការមិនមានភ័ស្តុតាងផ្ទាល់ ឬការគាំទ្រ ការវាយតម្លៃដោយមិនត្រឹមត្រូវទៅលើព័ត៌មានលម្អិតដែលសាក្សីផ្តល់ឱ្យ និងការមិនបានពិចារណាទៅលើអង្គហេតុសំខាន់ៗ ភាពមិនគ្រប់គ្រាន់ ឬមិនស្របគ្នានៅក្នុងការសម្រេច។ ទឡ្ហីករណ៍ទាំងអស់នេះគ្មានប្រសិទ្ធភាពទេ។ គោលជំហររបស់សហមេធាវីសហមេធាវី ត្រូវបានលើក ឡើងជាទូទៅដោយ (១) ការប្រើប្រាស់ដោយចង្អៀតនូវព័ត៌មានលម្អិតមួយក្នុងចំណោមភ័ស្តុតាងដ៏ច្រើនលើសលប់ (២) ការបង្ហាញពីការចោទប្រកាន់ដោយគ្មានមូលដ្ឋាន និង/ឬ (៣) ការរៀបចំឡើងនូវការអះអាង ដែលមិនពាក់ព័ន្ធ ឬមិនមានសំអាងហេតុមួយចំនួន[740]។

---

[737] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១១០ *យោងទៅរក* ផរ ប៉ែត ឈឿន ប៊ាន។

[738] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១១១។

[739] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៤-១៨៤។

[740] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៤-១៨៤។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ទឡ្ហីករណ៍របស់សហមេធាវី នៅក្នុងមូលដ្ឋាននេះ ៥.២ (iii) នាំឱ្យមានបណ្តឹងទាក់ទងនឹងការប្រើប្រាស់ទំនាក់ទំនងរវាង យឹម ទិត្យ និង តាម៉ុក (បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨៧ ចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុស "អង្គហេតុ និងអង្គច្បាប់ក្នុងការសន្និដ្ឋានថា យឹម ទិត្យ គឺជាលេខាតំបន់១ ភូមិភាគពាយ័ព្យ តាមនីតិន័យ និង/ឬព្រឹត្តន័យ នៅត្រង់ចំណុចពេលវេលា

### ខ. ការតែងតាំង យឹម ទិត្យ ជាលេខាតំបន់ ១ នៅអំឡុងខែមិថុនា ឆ្នាំ១៩៧៨

309. ចំពោះបញ្ហាទីមួយ ថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដែរឬទេ ក្នុងការសម្រេចថា យឹម ទិត្យ ជំនួស តាប៉ែត ជាលេខាតំបន់១ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨[741] ចៅក្រមអន្តរជាតិនឹងពិចារណា ទៅលើការចោទប្រកាន់របស់សហមេធាវី អំពីសាក្សីទីមួយៗ ឬភ័ស្តុតាងមួយភាគៗទៅតាមលំដាប់ លំដោយ ដូចតទៅ តុប សឹង, លេក ពៀវ, ផាំ លុយ, ជួប ថន, រី ផាន់, ណុប ងឹម, ណាង នី, លៀស គង់, នួន មួន, ឈឿង ប៊ាន, ឈាន ប៉ា, ហាន ធី និងអត្ថបទសិក្សាស្រាវជ្រាវ ដែលមានចំណងជើងថា "ការរៀបចំអំណាច"[742]។

310. ចំពោះការអះអាងថា តុប សឹង (ដែលដឹកនាំកងចល័តនៅជុំវិញការដ្ឋានទំនប់កង្កួត ក្នុងឆ្នាំ១៩៧៨)[743] "មិនស្គាល់" ឬថា អត្តសញ្ញាណរបស់ យឹម ទិត្យ បានដឹង "ពីប្រធានកងរបស់ខ្លួន" នោះ[744] អង្គជំនុំ ជម្រះសម្រេចថា ទឡ្ហីករណ៍ទាំងអស់នេះ និងការជំទាស់បន្ថែមផ្សេងទៀត ទទួលបរាជ័យ។ តុប សឹង បានឃើញ យឹម ទិត្យ ដោយផ្ទាល់ "ជាច្រើនដង"[745] នៅពេលដែលគាត់

---

ណាមួយក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិប តេយ្យ" ហើយការគាំទ្ររបស់ពួកគេ ទៅលើចំណុចមួយនេះ គឺការយោងដោយប្រយោលទៅទឡ្ហីករណ៍កន្លងមករបស់ខ្លួនដែលថា "ទំនាក់ទំនងគ្រួសារ" របស់ យឹម ទិត្យ ជាមួយ តាម៉ុក មិនអាចស្មើនឹងការសន្និដ្ឋានដែលថា លោក យឹម ទិត្យ មានសិទ្ធិអំណាចតាមព្រឹត្តន័យ ជាលេខាតំបន់ ១ ទេ")។ អង្គជំនុំជម្រះសូមរំឭកអំពីការសម្រេចកន្លងមករបស់ខ្លួន នៅក្នុងសេចក្តីពិចារណាទាំងអស់នេះថា "សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានប្រើប្រាស់ដោយមិនត្រឹមត្រូវនូវទំនាក់ទំនងគ្រួសាររវាង យឹម ទិត្យ ជាមួយ តាម៉ុក ធ្វើជាមូលដ្ឋាន ឬជាផ្លូវកាត់ ដើម្បីដាក់បន្ទុកនូវសិទ្ធិអំណាចតាមព្រឹត្តន័យ ឬតាមនីតិន័យឡើយ ប៉ុន្តែដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានពឹងផ្អែកទៅលើសាក្សីជាច្រើន ដែលផ្តល់សក្ខីកម្មអំពីតួនាទី និងការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ យឹម ទិត្យ"។ ( សូមមើល មូលដ្ឋាន ៥.១ ខាងលើ)។ ហេតុដូច្នេះ ទំនាក់ទំនងរបស់ យឹម ទិត្យ ជាមួយ តាម៉ុក នឹងមិនត្រូវបានពិភាក្សាបន្ថែមទៀតទេនៅទីនេះ។

[741] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ៣៦០-៣៦២។

[742] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥-១៦៩។

[743] កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប សឹង ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/117 នៅត្រង់ ERN 01046461-01046464 (ឆ១៥-ឆ១៩, ឆ៥៩)។

[744] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥។

[745] កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប សឹង ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារឯកសារ D219/117 នៅត្រង់ ERN 01046468 (ឆ៩១)។

បង្ហាញខ្លួន ដើម្បីត្រួតពិនិត្យទំនប់កង្កួត "ប្រហែលជាពីរដងក្នុងមួយខែ" នៅក្នុងឆ្នាំ១៩៧៨[746] ជាការទទួលខុសត្រូវ ដែលដូចគ្នានឹងការទទួលខុសត្រូវរបស់ តាប៉ែត ជាអ្នកកាន់តំណែងមុនគាត់ មុនពេល យឹម ទិត្យ មកដល់[747]។ លើសពី នេះទៀត ចៅក្រមអន្តរជាតិមិនជឿទេថា ការគ្មានការកំណត់អត្តសញ្ញាណជាមុន បង្ហាញពីកំហុសនោះ[748] ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ថា សក្ខីកម្មរបស់ គុប សឹង មិនត្រឹមតែផ្អែកលើអ្វី ដែលគាត់បានដឹងនៅពេលនោះប៉ុណ្ណោះទេ ប៉ុន្តែ វាឆ្លើយតបផងដែរចំពោះការមើលឃើញ យឹម ទិត្យ[749] ហើយ គុប សឹង បាន

[746] កំណត់ហេតុស្តាប់ចម្លើយសាក្សី គុប សឹង ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/117 នៅត្រង់ ERN 01046466-01046467 (ឆ៦៩-ឆ៧៥)។

[747] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៨១ ជើងទំព័រ ១០០៧ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី គុប សឹង ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/117 នៅត្រង់ ERN 01046465 (ឆ៥៨-ឆ៦០) (ឆ៦០ បញ្ជាក់ថា "កាលនោះ ខ្ញុំកំពុងធ្វើការលើកទំនប់ ខ្ញុំបានឃើញតាប៉ែត ជិះឡានទៅមើលការដ្ឋានលើកទំនប់ ហើយខ្ញុំឮគេនិយាយថា តាប៉ែត ជាគណៈតំបន់១ និងជាជំនួយការភូមិភាគពាយ័ព្យ")។

[748] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥។ បើទោះបីជាការកំណត់អត្តសញ្ញាណជនជាប់ចោទ នៅក្នុងពេលស៊ើបអង្កេត អាចជាឧបករណ៍ដ៏មានតម្លៃ ដែលត្រូវប្រើប្រាស់នៅក្នុង បញ្ហាព្រហ្មទណ្ឌក្តី តែអង្គជំនុំជម្រះសូមកត់សម្គាល់ថា សំណុំរឿងដែលស្មុគស្មាញខ្លាំងទាំងអស់នេះ (ពាក់ព័ន្ធផងដែរជាមួយនឹងឧក្រិដ្ឋកម្មសង្គ្រាម និងប្រល័យពូជសាសន៍) ដែលកើតឡើងរាប់ទសវត្សរ៍កន្លងមក នៅក្នុងភូមិភាគដែលមានជម្លោះ ដូច្នេះហើយអាចធ្វើឱ្យបាត់បង់នូវលទ្ធភាព តម្លៃ ឬសូម្បីតែភាពត្រឹមត្រូវ នៃឧបករណ៍ស៊ើបអង្កេតបែបនេះ។ ការចង់បានការកំណត់អត្តសញ្ញាណបែបនេះ អាចត្រូវបានពិចារណា ដោយអ្នកវិនិច្ឆ័យលើអង្គហេតុ ប្រកបដោយហេតុផលម្នាក់ នៅក្នុងភស្តុតាងរួមនៃរឿងក្តី ប៉ុន្តែ ការមិនមានការកំណត់អត្តសញ្ញាណ មិនបានធ្វើឱ្យភស្តុតាង ឬសក្ខីកម្មគ្មានសុពលភាពឡើយ។

[749] សូមមើល, ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៥៦ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី គុប សឹង ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/117 នៅត្រង់ ERN 001046466-01046467 (ឆ៧១-ឆ៧៦), ERN 01046468 (ឆ៩០), ERN 01046474 (ឆ១៤៣-ឆ១៤៦) (ស១៤៤ "តើលោកស្រីធ្លាប់ជួបនិយាយ ជាមួយតាទិត្យទេ? ឆ១៤៤ "នៅពេលដែលគាត់ជួបខ្ញុំ គាត់បានសួរសុខទុក្ខខ្ញុំ ហើយថា តើធ្វើការងារយ៉ាងម៉េចដែរ")។ *សូមមើលផងដែរ*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤០០ ជើងទំព័រ ១០៥៧ ដកស្រង់ *ផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី គុប សឹង ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/117 នៅត្រង់ ERN 01046465 - 01046468 (ឆ៥៨-ឆ៦១, ឆ៦៧-ឆ៦៨, ឆ៧៨-ឆ៧៩, ឆ៨៥, ឆ៨៧-ឆ៩០) នៅត្រង់ ERN 01046474 (ឆ១៤៣-ឆ១៤៥) នៅត្រង់ ERN 01046478 (ឆ១៨១)។ សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី គុប សឹង ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/117 នៅត្រង់ ERN 01046465 (ឆ៥៨-ឆ៦០) (ឆ៦០ បញ្ជាក់ថា "កាលនោះ ខ្ញុំកំពុងធ្វើការលើកទំនប់ ខ្ញុំបានឃើញតាប៉ែត ជិះឡានទៅមើលការដ្ឋានលើកទំនប់ ហើយខ្ញុំឮគេនិយាយថា តាប៉ែត ជាគណៈតំបន់១ និងជាជំនួយការភូមិភាគពាយ័ព្យ") កំណត់ហេតុស្តាប់ចម្លើយសាក្សី គុប សឹង ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ

សន្និដ្ឋានថា យឹម ទិត្យ គឺជា "អ្នកដឹកនាំធំជាងគេនៅកន្លែងខ្ញុំធ្វើការ [ទំនប់កង្កួត នៅក្រោមតំបន់១]"[750]។

311. សហមេធាវីអះអាងថា លោក ពៀវ "មិនដឹងប្រាកដពីតួនាទីរបស់ តាប៉ែត និងតាទិត្យ" ទេ[751] ដោយទាញចេញពីឃ្លាតែមួយ នៅចន្លោះប្រយោគពីរ ដែល លេង ពៀវ បានបញ្ជាក់ម្ខាងថា យឹម ទិត្យ "ជាគណៈតំបន់១" និងម្ខាងទៀតថា លោក ពៀវ បានឃើញជនជាប់ចោទដោយផ្ទាល់ និងបានរៀបរាប់ថា នៅពេល "តាទិត្យនិយាយនៅក្នុងអង្គប្រជុំ ខ្ញុំក៏ស្តាប់គាត់ទៅ"[752]។ ចំពោះការមិនមានការកំណត់អត្តសញ្ញាណជាមុន[753] ចៅក្រមអន្តរជាតិមិនជឿថាមានកំហុសណាមួយឡើយ ដោយសារតែភ័ស្តុតាង និងដោយសារតែសាក្សី បានឃើញជនជាប់ចោទ នៅទំនប់កង្កួត និងនៅក្នុងការប្រជុំ[754]។

312. ចំពោះ ឆាំ លុយ (ទាហានខ្មែរក្រហម នៅក្នុងតំបន់១ អំឡុងឆ្នាំ១៩៧៨)[755] ដែល "មិនដែលជួប" យឹម ទិត្យ នោះ[756] ចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមាន

---

D219/117 នៅត្រង់ ERN 01046466 (ឆ៦៧-ឆ៦៨) តុប សឹង បញ្ជាក់ច្បាស់ថា "កម្មាភិបាលទៅពីភូមិភាគនិរតីគឺឈ្មោះ តាទិត្យ ទៅជំនួសតាប៉ែត [...] "ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៨")។

[750] កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប សឹង ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/117 នៅត្រង់ ERN 01046468 (ឆ៨៧-ឆ៨៨)។

[751] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី លោក ពៀវ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/236 នៅត្រង់ ERN 01080844 (ឆ១៨)។

[752] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥។ កំណត់ហេតុស្តាប់ចម្លើយសាក្សី លោក ពៀវ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/236 នៅត្រង់ ERN 01080844 (ឆ១៦-ឆ១៨)។

[753] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥។

[754] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៥៤ ជើងទំព័រ ៩២៨ ដកស្រង់ *ផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី លោក ពៀវ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/236 នៅត្រង់ ERN 01080844 (ឆ១៧) ("សៈ តើលោកធ្លាប់បានឃើញ តាទិត្យ ឬក៏ យឹម ទិត្យ នៅការដ្ឋានទំនប់កង្កួតដែរឬទេ? ឆ១៧៖ បាទ ខ្ញុំធ្លាប់ឃើញ តាទិត្យ ពេលខ្លះ នៅក្នុងអង្គប្រជុំដែរ។ គាត់ចូលរួមប្រជុំ ប៉ុន្តែគាត់មិនស្នាក់នៅ ការដ្ឋានទំនប់កង្កួតទេ។ ការប្រជុំនោះ ពេលខ្លះ គេធ្វើឡើងនៅការដ្ឋានទំនប់កង្កួត ឬពេលខ្លះនៅវត្តព្រៃតូច។ ការប្រជុំនោះ គឺធ្វើឡើង១០ថ្ងៃម្តង")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆាំ លុយ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/243 នៅត្រង់ ERN 00990630 (ឆ១០)។

[755] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆាំ លុយ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/243 នៅត្រង់ ERN 00990629-00990630 (ឆ២-ឆ១០)។

01677237



កំហុសឡើយ ក្នុងការយល់ថា សាក្សីរូបនេះបានដឹងអំពីតួនាទីរបស់ យឹម ទិត្យ ពីប្រជាជនក្នុងភូមិ[757]។ ទោះបីជា ឆាំ លុយ បានដឹងអំពីតួនាទីរបស់ យឹម ទិត្យ នៅក្រោយពេលជាក់ស្តែងនៃការតែងតាំងនៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ ក្តី ប៉ុន្តែ តាមទស្សនៈរបស់ចៅក្រមអន្តរជាតិ មិនបានបង្ហាញអំពីកំហុសណាមួយឡើយ[758]។

313. ផ្ទុយទៅនឹងការចោទប្រកាន់របស់សហមេធាវីដែលថា ជួន ថន[759] លើកឡើងដោយមិនត្រឹមត្រូវថា "តាទិត្យគឺជាអ្នកដែលជំនួសតាវ៉ាញ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧"[760] (ដូច្នេះហើយ មិនបានរៀបរាប់ពីការជំនួសជាក់ស្តែងរបស់តាវ៉ាញ ដោយតាប៉ែត នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ និងការចាប់ខ្លួនតាប៉ែតនៅអំឡុងខែសីហា ឆ្នាំ១៩៧៨ ក្រោយពេលតែងតាំង យឹម ទិត្យ ជាលេខាតំបន់១[761]) សាក្សីដោយមិនបានលើកឡើងពីកាលបរិច្ឆេទជាក់លាក់ណាមួយនៃការជំនួសនោះ គ្រាន់តែបញ្ជាក់ថា "បន្ទាប់ពីតាណុប និងតាវ៉ាញ [ដែលទទួលខុសត្រូវតំបន់១] បានបាត់ខ្លួន ទើប

---

[756] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆាំ លុយ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/243 នៅត្រង់ ERN 00990630 (ឆ១៣)។

[757] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆាំ លុយ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/243 នៅត្រង់ ERN 00990630 (ឆ១០-ឆ១១) ( ឆាំ លុយ បានដឹងថា "តាទិត្យ មកពីនិរតី ជាអ្នកគ្រប់គ្រងតំបន់១" ពីអ្នកភូមិដែលបានឃើញជនជាប់ចោទ នៅក្នុងកិច្ចប្រជុំ និងស្គាល់ថា តាទិត្យ ជា "មនុស្សខ្លាំង" ដែលមក "បើកអង្គប្រជុំនៅតាមសហករណ៍ ហើយគាត់បានឧទ្ទេសនាមខ្លួនគាត់ថា ជាប្រធានតំបន់១")។ លើសពីនេះ ចៅក្រមអន្តរជាតិសូមរំឭកថា ដូចដែលបានតម្កល់នៅក្នុងសេចក្តីពិចារណាលើភស្តុតាង សម្រាប់មូលដ្ឋាន ៥ ខាងលើ ភស្តុតាងទាំងអស់អាចទទួលយកបាន ហើយជាទូទៅទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន តាមផ្លូវច្បាប់ដូចៗគ្នា។ លើសពីនេះទៀត ចៅក្រមអន្តរជាតិសម្រេចថា មានការកំណត់ច្បាស់លាស់ថា ភស្តុតាងចចាមអារាម អាចទទួលយកបាននៅចំពោះមុខ អ.វ.ត.ក ហើយអាចត្រូវបានពិចារណា និងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានឆន្ទានុសិទ្ធិធំទូលាយ ក្នុងការពឹងផ្អែកទៅលើភស្តុតាងចចាមអារាម"។

[758] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆាំ លុយ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/243 នៅត្រង់ ERN 00990630 (ឆ១០-ឆ១១)។

[759] ជួន ថន គឺជាកសិករដែលធ្វើការនៅកងចល័ត ស្ថិតនៅភាគខាងកើត នៃទំនប់កង្កួត អំឡុងដើមឆ្នាំ១៩៧៨។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ជួន ថន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990642 (ឆ៤)។

[760] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥។

[761] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦១-៣៦៣។

ឃើញតាទិត្យមកដល់"[762]។ ចំណុចនេះត្រូវគ្នាជាមួយនឹងលំដាប់លំដោយនៃព្រឹត្តិការណ៍នៅក្នុងការសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[763]។

314. លើសពីនេះទៀត ដោយរំឭកថា មិនមានលក្ខខណ្ឌតម្រូវថា ភស្តុតាងសាក្សីអំពីអង្គហេតុសំខាន់ចាំបាច់ត្រូវគាំទ្រដោយភស្តុតាងពីប្រភពដទៃផ្សេងទៀត នៅដំណាក់កាលមុនពេលជំនុំជម្រះនោះ[764] ចៅក្រមអន្តរជាតិមិនជឿតាម ការអះអាងរបស់សហមេធាវីដែលថា ការដែល ជួន ថន មិនអាចផ្តល់ព័ត៌មានលម្អិតពីកាលៈទេសៈខ្លះ[765] ធ្វើឲ្យប៉ះពាល់ដល់ភាពអាចជឿជាក់បានអំពីព័ត៌មានផ្ទាល់ក្នុងការចូលរួមក្នុងកិច្ចប្រជុំ ដែលដឹកនាំដោយ យឹម ទិត្យ ហើយមានអ្នកចូលរួមជាង ១០០នាក់ នៅភ្នំសំពៅ[766]។

---

[762] កំណត់ហេតុស្តាប់ចម្លើយសាក្សី ជួន ថន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990643 (ឆ៥)។

[763] សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៥៣ "តាវ៉ាញ ដែលនៅពេលនោះ ជាលេខាតំបន់១ មុនពេលដែលតាប៉ែត មកជំនួស"។ កថាខណ្ឌ ៣៦១-៣៦២ "បន្ទាប់ពីបោសសម្អាត តាវ៉ាញ អតីតលេខាតំបន់ នៅក្នុ ខែមិថុនា ឆ្នាំ១៩៧៧ [...] តាប៉ែត បានក្លាយជាលេខាតំបន់១ [...]។ បន្ទាប់ពីតាប៉ែត ត្រូវបានដកចេញពីតួនាទីរបស់គាត់ យឹម ទិត្យ បានឡើងជំនួសគាត់ [...] តាប៉ែត ត្រូវបានចាប់ខ្លួនក្រោយពេលដែល យឹម ទិត្យ មកដល់ គឺនៅក្នុងអំឡុងខែសីហា ឆ្នាំ១៩៧៨។

[764] សូមមើល សេចក្តីពិចារណាលើភស្តុតាង មូលដ្ឋាន ៥ ខាងលើ (បានសម្រេចថា "មិនមានមូលដ្ឋានផ្លូវច្បាប់ដែលថា ភស្តុតាងរបស់សាក្សីលើអង្គហេតុជាក់ស្តែង ចាំបាច់ត្រូវមានការគាំទ្រ ដោយភស្តុតាងពីប្រភពដទៃឡើយ" ដែលរៀបរាប់លម្អិតថា វិធាន ៦៧ នៃវិធានផ្ទៃក្នុង មិនតម្រូវឲ្យមានការគាំទ្រ លើភស្តុតាង នៅពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ សូមមើល តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង HARADINAJ និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-04-84-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២១៩ ("សក្ខីកម្មរបស់សាក្សីតែមួយរូប អាចទទួលយកបាន ដោយមិនចាំបាច់ការគាំទ្រ បើទោះបីជាពាក់ព័ន្ធ ជាមួយអង្គហេតុជាក់ស្តែងក្តី")។

[765] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ១៦៥ (អះអាងថា ជួន ថន បានជួបតាទិត្យ "តែម្តងគត់" "នៅក្នុងឆ្នាំ១៩៧៨" ហើយ ជួន ថន មិន "ចាំឈ្មោះអ្នកដែលណែនាំ" តាទិត្យ ឬ ជួន ថន មិនអាច "ចាំឈ្មោះអ្នកណាម្នាក់ដែលមានវត្តមាន ក្នុងកិច្ចប្រជុំនោះ" ឬ ជួន ថន ""មិនសូវដឹងច្បាស់អំពី រចនាសម្ព័ន្ធរដ្ឋបាល របស់តំបន់១ឬតំបន់ ៣ ឡើយ" ឬ "មិនដែលឃើញនរណាម្នាក់ពីគណៈភូមិភាគ" ឬ "មិនដែលចូលរួមប្រជុំណាមួយ ដែលរៀបចំឡើងដោយកម្មាភិបាលតំបន់" ឡើយ)។

[766] ទោះបីជាសហមេធាវី មិននិយាយអំពីការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទទួលស្គាល់ថា "Phnom Sampov" គឺជាការសរសេរតាមសូរសម្លេងនៃពាក្យ "Phnom Sampoeu", ( សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៨២៩ ជើងទំព័រ ២២២៥) ក្តី តែចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាដោយសមហេតុផលនូវបណ្តុំនៃភស្តុតាងប្រយោល អំពីសកម្មភាពនៃរបបខ្មែរក្រហម នៅជុំវិញ និងនៅភ្នំសំពៅ (រួមទាំងភស្តុតាងពាក់ព័ន្ធ មន្ទីរសន្តិសុខភ្នំគីរីរម្យ និងរូងភ្នំបីដែលប្រើប្រាស់ជារណ្តៅកប់សពរួម) នៅពេលវេលាប្រហែលគ្នា ជាមួយការ

315. ដូចគ្នាដែរ ចំពោះ វី ផាន់ (អនុប្រធានភូមិកំផែង ដែលធ្វើការជាមួយកម្មាភិបាលនិរតី រួមទាំង យឹម ទិត្យ ផង នៅអំឡុងឆ្នាំ ១៩៧៨)[767] គាត់បានឃើញ "តាប៉ែត" និង "តាទិត្យ" នៅក្នុងកិច្ចប្រជុំមួយ នៅទំនប់កង្កួត ដែលពេលនោះ "តាប៉ែត" ប្រកាសថា "តាទិត្យ" មកជួយគ្រប់គ្រងតំបន់ ១ នោះ ចៅក្រមអន្តរជាតិមិនជឿថា ការអះអាងដទៃទៀតតែមួយរបស់ វី ផាន់ ដែលរៀបរាប់ថា "តាទិត្យ បានមកដល់តំបន់របស់គាត់ ប្រហែលជាក្នុងខែវិច្ឆិកា" ធ្វើឲ្យសាក្សីនេះមិនអាចជឿបាន នោះទេ[768]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិនិត្យយ៉ាងលម្អិតលើភាពខុសគ្នានៃកាល បរិច្ឆេទជាក់ស្តែងនេះ ហើយបានប៉ាន់ប្រមាណដោយសមហេតុផលថា "ទោះបីជា សាក្សីអះអាងថា ការប្រជុំនេះបានកើតឡើងនៅចុងឆ្នាំ ១៩៧៨ ក៏ដោយ តែវត្តមានរបស់ តាប៉ែត ដែលត្រូវបានចាប់ខ្លួននៅខែសីហា ឆ្នាំ១៩៧៨ បង្ហាញថា ការប្រជុំប្រហែលជាបានកើតឡើង មុនកាលបរិច្ឆេទនេះ ហើយសាក្សីមានការភាន់ច្រឡំអំពីកាលបរិច្ឆេទ"[769]។

316. ការអះអាងដែលថា ណុប ងឹម (ជាអនុលេខាស្រុកសំឡូត រហូតដល់ចុងបញ្ចប់នៃរបបខ្មែរ ក្រហម"[770] គ្រាន់តែ "សន្មត" ថា យឹម ទិត្យ គឺជាគណៈតំបន់១ ក្នុងឆ្នាំ១៩៧៨ មិនមានមូលដ្ឋាន

---

ប្រជុំ ដែល ជួន ថន បានផ្តល់សក្ខីកម្មថា ដឹកនាំដោយ យឹម ទិត្យ នៅក្នុងឆ្នាំ១៩៧៨។ *សូមមើលផងដែរ*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤២០ (ii) ជើងទំព័រ ១១០៩។

[767] កំណត់ហេតុស្តាប់ចម្លើយសាក្សី វី ផាន់ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/85 ERN 01040093 (ឆ២)។

[768] លើសពីនេះទៀត ចៅក្រមអន្តរជាតិកត់សម្គាល់ថា សារណាដទៃរបស់សហមេធាវីទាក់ទង វី ផាន់ (ថាតាទិត្យ ឡើងជំនួស តាប៉ែត ឬដឹកនាំការប្រជុំផ្សព្វផ្សាយ ការឃោសនារបស់ខ្មែរក្រហម) គឺគ្រាន់តែគាំទ្រថា តាទិត្យជំនួសតាប៉ែត ប៉ុណ្ណោះ។ (សូម មើល បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥ និង កំណត់ហេតុ ស្តាប់ចម្លើយសាក្សី វី ផាន់ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/85 ERN 01040094 (ឆ៤-ឆ៥) (ដែលភស្តុតាងរបស់ វី ផាន់ បានបង្ហាញពីតួនាទីរបស់ យឹម ទិត្យ រួមទាំងថា យឹម ទិត្យ មកជំនួសតាប៉ែត និងដឹកនាំការប្រជុំ នៅក្នុងការប្រជុំនោះ យឹម ទិត្យ បានប្រកាសដោយផ្ទាល់ "លើកទឹកចិត្តយើងថា យើងជាជាតិសាសន៍មួយដ៏ខ្លាំង ខ្មែរគឺជាពូជអ្នកចំបាំង ដែល បានកសាងអង្គរវត្ត"))។

[769] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៩៤។ វី ផាន់ ក៏បានបញ្ជាក់ផងដែរថា តាទិត្យ មកជំនួសតាប៉ែត ប្រហែលមួយឆ្នាំក្រោយការចាប់ខ្លួន តាវ៉ាញ គឺនៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ (កំណត់ហេតុស្តាប់ចម្លើយសាក្សី វី ផាន់ ថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/85 ERN 01040093 (ឆ៣))។

[770] កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008701 (ឆ៣១) (ណុប ងឹម បញ្ជាក់ ស៖ តើលោកស្រីអាចបញ្ជាក់បានទេថា លោកស្រីជាកម្មាភិបាលថ្នាក់ស្រុក នៅស្រុកសំឡូត? ឆ៣១៖ នៅស្រុកសំឡូត ខ្ញុំមានតួនាទីជាអនុលេខាស្រុក")។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

ឡើយ[771]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាដោយសមហេតុផលថា ណុប ងឹម បានឃើញ យឹម ទិត្យ ដឹកនាំការប្រជុំ ហើយផ្សព្វផ្សាយការណែនាំ ដល់កម្មាភិបាល[772] ហើយបានដឹងអំពីលិខិតរបស់ស្រុក ដែលបានចេញនៅអំឡុងខែតុលា ឆ្នាំ១៩៧៨[773] ដែលជាលិខិតសរសេរដោយដៃរបស់ "អ៊ំទិត្យ"[774] រៀបរាប់លម្អិតអំពី "ផែនការកសាងមន្ទីរសន្តិសុខ ពីតំបន់"[775]។

317. សហមេធាវីបានអះអាងបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "មិនបាន" ពិចារណាទៅលើ "ភាពផ្ទុយទាំងនេះនៅក្នុងភស្តុតាងសាក្សី" ណាង នី និង លៀស គង់ ពាក់ព័ន្ធនឹង "កិច្ចប្រជុំមួយនៅបាយដំរាំ" ដែល យឹម ទិត្យ បានធ្វើការប្រកាសក្នុងពេលប្រជុំនោះ[776]។ អង្គជំនុំជម្រះមិនជឿថា សាក្សីទាំងពីរនេះបានចូលរួមកិច្ចប្រជុំតែមួយនៅបាយដំរាំទេ ព្រោះសាក្សីទាំងនេះបានរាយការណ៍ កាលបរិច្ឆេទខុសគ្នា គឺ ខែកក្កដា និងខែតុលា ឆ្នាំ១៩៧៨ ហើយការប្រជុំដែលមានលក្ខណៈបែបនេះមានច្រើនគួរសមនៅក្នុងអំឡុងពេលវេលានោះ[777]។ សហចៅក្រមស៊ើប

---

[771] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥។

[772] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤០៥ (viii) (សម្រេចថា "ឆ្នាំ១៩៧៨ តាម៉ុក និង យឹម ទិត្យ បានដឹកនាំការប្រជុំជាច្រើន នៅផ្ទះតាម៉ុក នៅខេត្តបាត់ដំបង ដែលពួកគេបានណែនាំ ឱ្យកម្មាភិបាលរាប់រយនាក់ មកពីថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ") ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008706 (ឆ៥៥-ឆ៥៦)។

[773] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤២០ (i) ជើងទំព័រ ១១០៨ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008705 (ឆ៥២)។

[774] កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008704 (ឆ៤៤)៖ "សេចក្តីណែនាំ ឬរបាយការណ៍ដែលថ្នាក់ស្រុកទទួលបាន ពីថ្នាក់តំបន់នៅពេលនោះ គឺមានឈ្មោះអ៊ំទិត្យ ដែលសរសេរដោយដៃ")។

[775] កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008705 (ឆ៥១)។

[776] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥។

[777] *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤០៥ (vii) (អង្គជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានពិចារណាផងដែរលើភស្តុតាង អំពីសកម្មភាពខ្មែរក្រហម និងការប្រជុំនានានៅក្នុងតំបន់៖ សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ២៣៩-២៤០ (ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការសម្រេចអំពី សកម្មភាពនៅតំបន់បាយដំរាំ ដូចជា ការមកដល់របស់កម្មាភិបាលភូមិភាគនិរតី និងការកាប់សម្លាប់ រួម

អង្កេតអន្តរជាតិមិនមានកំហុសឡើយដោយមិនពិចារណាទៅលើ "*ភាពខុសគ្នា*" ដែលផ្អែកលើការសន្មតថា សាក្សីទាំងអស់នោះ បានចូលរួមក្នុងកិច្ចប្រជុំតែមួយ[778]។ ទោះបីជាសហមេធាវីលើកឡើងពីការព្រួយបារម្ភ ពាក់ព័ន្ធទៅនឹងទស្សនៈមិនដូចគ្នារបស់ ណាង នី និង លៀស គង់ អំពីរូបរាងរបស់ យឹម ទិត្យ ក្តី[779] តែអង្គជំនុំជម្រះសម្រេចថា មិនមានកំហុសឡើយក្នុងករណីនេះ ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនពឹងផ្អែកទៅលើការពណ៌នាអំពីរូបរាងរបស់ យឹម ទិត្យ ដើម្បីបង្កើតសេចក្តីសន្និដ្ឋានឡើយ[780]។

318. ទោះបីជាសហមេធាវីចោទថា នួន មួន[781] បានបញ្ជាក់ថា យឹម ទិត្យ មកជំនួស តាប៉ែត ក្រោយពេលតាប៉ែត ត្រូវបានគេបញ្ជូនចេញ នៅអំឡុងខែតុលា ឬខែវិច្ឆិកា ឆ្នាំ១៩៧៨[782] ក្តី តែអង្គជំនុំ

---

ទាំង នៅអំឡុងពាក់កណ្តាលឆ្នាំ ១៩៧៨)។ កថាខណ្ឌ ៦៨៩ (*យោងទៅ* ការប្រជុំដែលរៀបរាប់ដោយ លៀស គង់ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថា "យឹម ទិត្យ ជាប្រធានអង្គប្រជុំ" នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ និង "គេស្រែកប្រាប់ទៅកាន់អ្នកធ្វើការនៅទីនោះ ថា កុំឲ្យ "*យកតម្រាប់តាមពួកគាត់*"។ ពួកគាត់ក៏បានបាត់ខ្លួន លែងឃើញមុខទៀត។ ការសន្និដ្ឋានដ៏សមហេតុផលតែមួយគត់គឺថា ពួកគាត់ត្រូវបានគេសម្លាប់ចោល")។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/368 ERN 01110186 (ឆ៩៤) ដោយ ឈឿន ប៊ាន បានផ្តល់ចម្លើយថា យឹម ទិត្យ គឺជាមនុស្សតែម្នាក់ ដែលនិយាយនៅក្នុងកិច្ចប្រជុំ ជាមួយប្រធានកង និងប្រជាជនធម្មតា នៅវត្តបាយដំរាំ ក្នុងខែកញ្ញា ឬ ខែតុលា ឆ្នាំ១៩៧៨ និងថា យឹម ទិត្យ ប្រាប់ "ប្រជាជនត្រូវផ្តោតយកចិត្តទុកដាក់ ទៅលើការបង្កបង្កើនផល")។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/538 ERN 01155829-01155830 (ឆ៥៧-ឆ៦២) (សឿន ម៉ាត់ រៀបរាប់អំពីការប្រជុំផ្សេងទៀតនៅបាយដំរាំ ដែលដឹកនាំដោយកម្មាភិបាលនារីជាន់ខ្ពស់ម្នាក់ ដែលរៀបរាប់អំពីការវាយប្រយុទ្ធជាមួយវៀតណាម)។

[778] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥។

[779] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥។

[780] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) រួមបញ្ចូល *ផងដែរ* កថាខណ្ឌ ៣៦០-៣៦៣។

[781] នួន មួន បានរៀបរាប់ខ្លួនគាត់ថាជា "ជំនួយការដើម្បីប្រមូលព័ត៌មានពីស្រុកនានារបស់តំបន់១" នៅអំឡុងឆ្នាំ១៩៧៥ ហើយនៅក្នុង ខែតុលា ឆ្នាំ១៩៧៥ គាត់បានក្លាយជា "ជំនួយការស្រុកបាត់ដំបង" ហើយនៅក្នុងពេលមួយនោះ ក៏ជាជំនួយការសហករណ៍ចម្លងគួយ នៃស្រុកបាត់ដំបង (ប្រហែលខែបីឬខែបួន ក្នុងឆ្នាំ១៩៧៦ រហូតដល់ខែមករា ឆ្នាំ១៩៧៩។ ជាចុងក្រោយ នួន មួន បានរៀបរាប់ថា គាត់ត្រូវបានគេចាប់ខ្លួន នៅពេលពួកនិរតីមកដល់ "ព្រោះគេយល់ថា ខ្ញុំគឺជាកម្មាភិបាលសហករណ៍ របស់ភូមិភាគពាយ័ព្យ" (កំណត់ហេតុស្តាប់ចម្លើយសាក្សី នួន មួន ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D118/69 ERN 00920210-00920211 (ឆ១-ឆ៧)។

[782] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី នួន មួន ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D118/69 ERN 00920212 (ឆ១១). ***សូមមើល សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

01677242



ជម្រះយល់ឃើញថា មិនមានកំហុសឡើយ ព្រោះអង្គជំនុំជម្រះមើលឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានវាយតម្លៃដោយសមហេតុផលចំពោះភាពខុសគ្នាលើកាលបរិច្ឆេទនេះ[783]។ ចំពោះ ឈឿន ប៊ាន (សមាជិកកងចល័ត ដែលធ្វើការនៅទួលម្ទេស និងកសាងទំនប់កង្គូត)[784] និងការអះអាងថា សាក្សីនេះ បានរៀបរាប់ថា យឹម ទិត្យ មកជំនួសតាព្រំ និងតាវ៉ាញ នៅអំឡុងចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ ដែលផ្ទុយនឹងការសម្រេចផ្ទាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា តាវ៉ាញត្រូវបានជំនួសដោយតាប៉ែត នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧[785] អង្គជំនុំជម្រះសម្រេចថា ការជំទាស់នេះបង្ហាញដោយត្រឹមត្រូវនូវភស្តុតាងរបស់ ឈឿន ប៊ាន ដោយប្រើប្រាស់សក្ខីកម្មតែមួយផ្នែក។ ឈឿន ប៊ាន បានបញ្ជាក់នៅក្នុងព័ត៌មានដដែលរបស់គាត់ថា "តាវ៉ាញ ត្រូវបានគេចាប់ខ្លួនប្រាំមួយ ឬប្រាំពីរខែ មុនពេលដែលតាទិត្យ មកដល់"[786] និងថា "នៅពេលដែលគេចោទតាវ៉ាញ ថាជាជនក្បត់ តាប៉ែតគឺជាអ្នកជំនួសតំណែង តាវ៉ាញ ហើយក្រោយមកទៀត តាប៉ែត ត្រូវបាន [...] ជំនួសដោយតាទិត្យ"[787]។ លើសពីនេះ ទៀត "តាទិត្យ បានគ្រប់គ្រងទៅលើទំនប់កង្គូត ក្នុងខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ១៩៧៧ ហើយគាត់គ្រប់គ្រង ទាំងស្រុងក្នុង

---

*ផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី នួន មួន ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D118/69 ERN 00920210-00920212 (ឆ១២)។

[783] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦១ ជើងទំព័រ ៩៤៣ សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី នួន មួន ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D118/69 ERN 00920212 (ឆ១១-ឆ១២) ត្រូវបានដកស្រង់ ដើម្បីគាំទ្រដល់ការសម្រេចថា "បន្ទាប់ពីតាប៉ែតត្រូវបានដកចេញ ពីតួនាទីរបស់គាត់ យឹម ទិត្យ បានឡើងជំនួសគាត់ ជាលេខាតំបន់"។ ចំពោះកាលបរិច្ឆេទនៃការចាប់ខ្លួន តាប៉ែត (ប្រហែលក្នុងខែសីហា ឆ្នាំ១៩៧៨) សាក្សីមិនត្រូវបានយោងឡើយ។

[784] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/368 ERN 01110174-01110175 (ឆ១-ឆ៧)។

[785] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/368 ERN 01110175-01110176(ឆ១០-ឆ១៧) ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦១។

[786] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/368 ERN 01110177 (ឆ២៦)។

[787] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/368 ERN 01110186ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/368 ERN 01110179 (ឆ៣៩)។

ឆ្នាំ ១៩៧៨"[788]។ អង្គជំនុំជម្រះសម្រេចថា សេចក្តីពិចារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើសាក្សីនេះ សមហេតុផល។

319. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដោយពឹងផ្អែកទៅលើ ឈាន ប៉ា (ជាអ្នកការពារ និងជានិរសាររបស់តាប៉ែត)[789] និងព័ត៌មាន "មិនស៊ីសង្វាក់" របស់គាត់ ដែលថា បានឃើញការចាប់ខ្លួន តាប៉ែត បន្ទាប់ពីមានបញ្ហាពីតាម៉ុក នៅអំឡុងខែសីហា ឆ្នាំ ១៩៧៨[790]។ អង្គជំនុំជម្រះបញ្ជាក់ឡើងវិញថា មិនមានលក្ខខណ្ឌតម្រូវអំពីការគាំទ្រឡើយ នៅពេលវាយតម្លៃភ័ស្តុតាង[791]។ លើសពីនេះទៀត អង្គជំនុំជម្រះមិនជឿថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនពិចារណាលើភ័ស្តុតាងផ្ទុយ ឬភ័ស្តុតាងដោះបន្ទុក ពាក់ព័ន្ធជាមួយ ឈាន ប៉ា នោះឡើយ[792]។ ទីមួយ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា តាប៉ែត ត្រូវបានចាប់ខ្លួននៅអំឡុងខែ សីហា ឆ្នាំ១៩៧៨ ផ្អែកលើព័ត៌មានរបស់ ឈាន ប៉ា ដែលថា ការចាប់

---

[788] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/368 ERN 01110192 (ឆ១១៦)។

[789] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៉ា ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ឯកសារ D118/136 ERN 00960662 (ឆ១, ឆ២)។ បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៦-១៦៧។

[790] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៦។ សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៉ា ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/233 ERN (ភាសាអង់គ្លេស) 01078135 (ឆ១៨) ("កាលនោះ ខ្ញុំឃើញនិរសាពីរនាក់របស់តាទិត្យ និងតាម៉ុក ជិះម៉ូតូមកប្រាប់តាប៉ែតថា "តា១រៀបចំឥវ៉ាន់ ព្រោះតាម៉ុកឱ្យដូរកន្លែង" ខ្ញុំឮដូច្នោះដឹងភ្លាមថា គាត់ច្បាស់ជាមានបញ្ហា ដែលអាចជាការយកទៅដាក់គុក ឬយកទៅសម្លាប់តែម្តង។ ដូច្នេះខ្ញុំក៏បានរត់ចូលព្រៃតែម្តងទៅ")។

[791] សូមមើលសេចក្តីពិចារណាលើភស្តុតាងមូលដ្ឋាន៥ ខាងលើ (សម្រេចថា "មិនមានលក្ខខណ្ឌតម្រូវគតិយុត្តិថា ភស្តុតាងសាក្សីអំពីអង្គហេតុជាក់ស្តែង ចាំបាច់ត្រូវមានការគាំទ្រ ដោយភស្តុតាងពីប្រភពផ្សេងឡើយ នៅដំណាក់កាលបុរេជំនុំជម្រះ") ដោយរៀបរាប់លម្អិតអំពីវិធាន ៦៧ នៃវិធានផ្ទៃក្នុង ដែលមិនតម្រូវឱ្យមានការគាំទ្រលើភស្តុតាង នៅក្នុងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះសង្កេតបន្ថែមទៀតថា សហមេធាវីបានបង្រួមហួសហេតុ នូវវិធីសាស្ត្រ ដែលធ្វើឱ្យថយចុះនូវតម្លៃនៃភស្តុតាងប្រយោល និងសាក្សី ដែលរៀបរាប់លម្អិតអំពី ការដកតំណែងនិងចាប់ខ្លួនតាប៉ែត អំឡុងខែសីហា ឆ្នាំ១៩៧៨ ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ធ្វើការពិចារណា (សូមមើល បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៦។ សូមមើលផងដែរ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦១-៣៦៣)។

[792] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៨។

ខ្លួននេះធ្វើឡើងនៅ ពីរខែបន្ទាប់ពីចាប់ខ្លួនតាញ៉ឹម[793]។ ការសន្និដ្ឋាននេះត្រូវបានគាំទ្រដោយប្រភពភស្តុតាងជាច្រើន ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការដកស្រង់[794]។ ការអះអាងរបស់សហមេធាវី ដែលដាក់កាលបរិច្ឆេទចាប់ខ្លួន តាប៉ែត នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ មិនទទួលបានជោគជ័យឡើយ[795] ព្រោះសហមេធាវីពឹងផ្អែកលើ កាលបរិច្ឆេទនៃការរត់គេចរបស់សាក្សី បន្ទាប់ពីមានការចាប់ខ្លួន[796] ឬការចងចាំមិនត្រឹមត្រូវរបស់ សាក្សី វី ផាន់ ដូចខាងលើ[797]។ ទីពីរ អង្គជំនុំជម្រះមិនជឿចំពោះទឡ្ហីករណ៍ផ្សេងទៀតដែលថា ឈាន ប៉ា "មិនស្គាល់" អ្នកការពារ និរសា ឬអ្នកបើកបររបស់ យឹម ទិត្យ, មិនបានឃើញការចាប់ខ្លួនតាប៉ែត និងរត់គេចទៅព្រៃនៅពេលដែលមានបញ្ហា ឲ្យតាប៉ែតផ្លាស់ប្តូរទៅទីកន្លែងផ្សេង និងថា ក្រោយឆ្នាំ១៩៧៩ ឈាន ប៉ា បានជួបតាប៉ែត ដែលបានប្រាប់គាត់ថា គាត់ត្រូវបានគេចាត់តាំង ឲ្យទៅកាប់ឬស្សីនៅភ្នំឱរាល់ នៅខេត្តកំពង់ស្ពឺ (មិនមែនត្រូវគេចាប់ខ្លួនទេ)[798] ដែលព័ត៌មានលម្អិតទាំងអស់នេះ មិនទាក់ទងដោយផ្ទាល់ជាមួយនឹងការសម្រេច និងមិនមែនជាព័ត៌មានផ្ទុយ ឬជាព័ត៌មានដោះបន្ទុកនោះទេ។

---

[793] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦២ ជើងទំព័រ ៩៤៥ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៉ា ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ឯកសារ D118/136 ERN 00960667 (ឆ៣៧)។ តាញ៉ឹម ត្រូវបានដកចេញពីតំណែងនៅមុនថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៨ (កាលបរិច្ឆេទនៃចម្លើយសារភាពរបស់គាត់ នៅមន្ទីរសន្តិសុខស២១)។ សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៥៨។

[794] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦២ ជើងទំព័រ ៩៤៥។

[795] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៨។

[796] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៨ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៉ា ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ឯកសារ D118/136 ERN 00960666 (ឆ២០)។

[797] កថាខណ្ឌ ៣១៥ ខាងលើ។ សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៩៤ ( ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី វី ផាន់ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/85 ERN 01040093 (ឆ៣) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា "ទោះបីសាក្សីអះអាងថា ការប្រជុំនេះបានកើតឡើង នៅចុងឆ្នាំ១៩៧៨ ក៏ដោយ តែវត្តមានរបស់តាប៉ែត ដែលត្រូវបានចាប់ខ្លួននៅខែសីហា ឆ្នាំ១៩៧៨ បង្ហាញថា ការប្រជុំប្រហែលជាបានកើតឡើង មុនកាលបរិច្ឆេទនេះ ហើយសាក្សីមានការភាន់ច្រឡំអំពីកាលបរិច្ឆេទ")។ បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៧។

[798] សូមមើល កិច្ចសម្ភាសន៍ជាមួយ ហេង ទាវ ហៅតាប៉ែត ដោយ Steve Heder ឯកសារ EN 001181104 តាប៉ែតនិយាយថា គាត់ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៨ ហើយត្រូវបានបញ្ជូនទៅភ្នំពេញ ប៉ុន្តែក្រោយមកត្រូវបានបញ្ជូនទៅកំពង់ស្ពឺ ហើយឃុំឃាំងនៅទីនោះរហូតដល់ ខែមករា ឆ្នាំ១៩៧៩។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

320. ដោយកំណត់ថា តាប៉ែត ត្រូវបានចាប់ខ្លួននៅអំឡុងខែសីហា ឆ្នាំ១៩៧៨ ដូចពីខាងលើ[799] អង្គជំនុំជម្រះ មិនអាចសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរតែធ្វើការពិចារណាទៅលើភស្តុតាងរបស់ ហាន់ ធី ដែលថា គាត់បានឃើញ តាប៉ែត នៅក្នុងកិច្ចប្រជុំមួយ នៅបីថ្ងៃមុនពេលវៀតណាមមកដល់[800]។ ប៉ុន្តែ ដោយចងចាំអំពីទម្រង់នៃភស្តុតាងនៅក្នុងសំណុំរឿងនេះ អង្គជំនុំជម្រះមិនឃើញមាន មូលដ្ឋាននៅក្នុងការលើកឡើងដែលថា អត្ថបទសិក្សាមួយមិនបានលើកឡើងអំពី យឹម ទិត្យ ថាជាសមាជិកគណៈកម្មាធិការ បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឆ្នាំ១៩៧៨ បង្ហាញពីកំហុសឆ្គងនានារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឡើយ[801]។

321. សរុបសេចក្តីទៅ ដោយបដិសេធទស្សនៈរបស់ សហមេធាវីដែលថា ត្រូវមានភស្តុតាងផ្ទាល់ ឬការគាំទ្រ ដើម្បីពង្រឹងការសម្រេចថា យឹម ទិត្យ គឺជាលេខាតំបន់១[802] និងដោយពិចារណាលើការដែលសហមេធាវីមិនបានបង្ហាញពីកំហុសណាមួយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះ អង្គជំនុំជម្រះសម្រេចថា ភស្តុតាងនៅដំណាក់កាលបុរេជំនុំជម្រះនេះ បានគាំទ្រគ្រប់គ្រាន់ថា យឹម ទិត្យ មកជំនួស តាប៉ែត និងត្រូវបានតែងតាំងជាលេខាតំបន់១ (តាមនីតិន័យ) នៅអំឡុងខែមិថុនា ឆ្នាំ១៩៧៨ រហូតដល់ពេលបញ្ចប់នៃរបបនេះ។

### *b. សិទ្ធិអំណាចតាមព្រឹត្តិន័យរបស់ យឹម ទិត្យ ជាលេខាតំបន់១*

322. ដោយងាកទៅពិនិត្យលើបញ្ហាទីពីរ ថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដែរឬទេ ក្នុងការសន្និដ្ឋានថា យឹម ទិត្យ បានប្រើប្រាស់សិទ្ធិអំណាច ជាលេខាតំបន់ ១ តាមព្រឹត្តិន័យនោះ អង្គបុរេជំនុំជម្រះពិចារណាទៅលើការសម្រេច និងភស្តុតាង ពាក់ព័ន្ធនឹងសាក្សីមួយចំនួន ដែលពួក

---

[799] កថាខណ្ឌ ៣១៩ ខាងលើ។

[800] ការិយាល័យសហព្រះរាជអាជ្ញាសួរចម្លើយរបស់ ហាន ធី ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ EN 00221584-002215845, EN 00221587។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ហាន ធី ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៨ ឯកសារ D20 ERN (ភាសាអង់គ្លេស) 00710286។ ប៉ុន្តែ ហាន ធី ភ្លេចទាំងស្រុងនូវឆ្នាំនៃការប្រជុំ នៅក្នុងការស្តាប់ចម្លើយចុងក្រោយរបស់គាត់។ សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី ហាន ធី ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ឯកសារ D105/8 ERN 00794127-00794128 (ឆ១៣-ឆ១៥)។

[801] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៩ *យោងទៅរក* ឯកសារ D1.3.15.2 អត្ថបទរបស់ Timothy Carney "ការរៀបចំអំណាច"។

[802] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៦៥។

គេខ្លះត្រូវបានលើកឡើងច្រើនដង ទាក់ទងនឹងបញ្ហាផ្សេងៗគ្នា គឺ សឿន ម៉ាត់, រី ផាន់, ជួន ថន, ណុប ងឹម, ឈឿន ប៊ាន, ណាង នី, ផន ប៉ែត និងព្រាប កប[803]។

323. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ មានសិទ្ធិអំណាច និងការគ្រប់គ្រងដោយផ្ទាល់ ទៅលើកងទ័ព ដោយពឹងផ្អែកទៅលើភ័ស្តុតាងមិនមាន ការគាំទ្ររបស់ សឿន ម៉ាត់ (សមាជិកកងចល័តដាច់ខាត ដែលធ្វើការនៅទំនប់កង្កួត)[804] និងមិនបាន ពិចារណាថា "គាត់មិនស្គាល់នរណា ទទួលបន្ទុកតំបន់១នៅពេលនោះទេ" និងថា គាត់គ្រាន់តែឮអ្នកដទៃគេលើកឡើងពីកូនទាហានរបស់ យឹម ទិត្យ ប៉ុណ្ណោះ[805]។ អង្គជំនុំជម្រះសម្រេចថា ទឡ្ហីករណ៍នេះ មិនគួរឲ្យជឿជាក់ឡើយ។ សឿន ម៉ាត់ "ស្គាល់ យឹម ទិត្យ ច្បាស់ នៅពេលដែលខ្ញុំចូលរួមប្រជុំនៅ បាណន់ ដោយសារខ្ញុំអង្គុយក្បែរគាត់ [យឹម ទិត្យ]"[806] ហើយ ម្តងទៀត សឿន ម៉ាត់ "ឃើញ យឹម ទិត្យ និយាយ" នៅក្នុងប្រជុំមួយដែល យឹម ទិត្យ "ប្រកាសអំពីការចាប់ខ្លួន[807]។ លើសពីនេះទៀត សឿន ម៉ាត់ មិនគ្រាន់តែឮពីអ្នកភូមិ ឬមេកងរបស់គាត់ អំពីកងទ័ពរបស់ យឹម ទិត្យ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានឃើញថា កងទ័ពរបស់ យឹម ទិត្យ យាមការងារតំបន់ នៅប៉ែកខាងត្បូងបាណន់ថែមទៀត[808] បានឮ យឹម ទិត្យ លើកឡើងពីការតស៊ូ ដើម្បីពង្រឹងកងទ័ពរបស់គាត់ នៅក្នុងកិច្ចប្រជុំ[809] និងបានបន្ថែមថា "ប្រជាជនគ្រប់គ្នាស្គាល់ឈ្មោះ តាទិត្យ ព្រោះគេល្បីថា តាទិត្យ ជាមេទ័ពខ្លាំង"[810]។ ព័ត៌មាននេះមានការគាំទ្រដោយភ័ស្តុតាងផ្សេង

---

[803] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧០-១៨៧។

[804] កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/538 ERN 01155822-01155823 (ឆ៩-ឆ១៧) ERN 01155828 (ឆ៤៩)។

[805] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧១។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/538 ERN 01155829 (ឆ៥៦) ("សៈ តើលោកដឹងដោយរបៀបណាថា តាទិត្យ ជាអ្នកគ្រប់គ្រងយោធា? ឆ៥៦៖ ដោយសារមេភូមិ មេកង បាននិយាយលើកឡើង អំពីកងទ័ពរបស់តាទិត្យ ដូច្នេះហើយទើបខ្ញុំដឹងថា គាត់ជាមេទ័ព")។

[806] កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/538 ERN 01155828 (ឆ៤៩)។

[807] កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/538 ERN 01155825 (ឆ៣០)។

[808] កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/538 ERN 01155830 (ឆ៦២)។

[809] កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/538 ERN 01155833 (ឆ៨៣)។

[810] កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/538 ERN 01155826 (ឆ៣៨)។

១ទៀត[811]។ ចុងក្រោយ ការអះអាងរបស់សហមេធាវី ដែលថា សឿន ម៉ាត់ "មិនបានផ្តល់ក្របខណ្ឌពេលវេលានៃភ័ស្តុតាងរបស់ខ្លួន"[812] ទទួលបរាជ័យ។ សាក្សីបានរៀបរាប់អំពីការងារ និងបទពិសោធន៍របស់គាត់ នៅក្នុងកងចល័ត ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ និងបានផ្តល់ឆ្នាំនៃហេតុការណ៍ តាមការចងចាំរបស់គាត់ នៅពេលសាកសួរឱ្យបញ្ជាក់[813]។

324. ចំពោះការជំទាស់របស់សហមេធាវី អំពីភាពមិនប្រាកដប្រជា ចំពោះសញ្ញាណនៃសិទ្ធិអំណាចរបស់ យឹម ទិត្យ ទៅលើ "បញ្ហាផ្ទាល់ខ្លួន"[814] នេះគឺជាការយល់ខុសទៅលើអ្វីដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះបានរៀបរាប់ថា "បញ្ហាកងទ័ព និងបុគ្គលិក"[815]។

---

[811] សូមមើលជាឧទាហរណ៍ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ១៨១ "តំបន់នីមួយៗ មានអង្គភាពទ័ពដែលរាយការណ៍ផ្ទាល់ទៅលេខាតំបន់"។

[812] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧១។

[813] កំណត់ហេតុស្តាប់ចម្លើយសាក្សី សឿន ម៉ាត់ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ D219/538 ERN 01155821-01155822 (ឆ៨-ឆ៩)៖ ("សៈ ខ្ញុំសូមឱ្យលោកជួយរៀបរាប់ អំពីការងាររបស់លោក តាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ តើលោកធ្វើអ្វីខ្លះ? ស៩៖ ចំពោះខ្ញុំ គេឱ្យខ្ញុំចូលក្នុងកងចល័ត។ ខ្ញុំមិននៅសមរភូមិក្រោយទេ គេឱ្យខ្ញុំនៅសមរភូមិមុខរហូត")។ ERN 01155822 (ឆ១៤) ("ឆ៖ [...] ចុងឆ្នាំ១៩៧៧ តាប៉ែតត្រូវបានគេចាប់ដាក់គុកកកោះ ហើយតាកៅ បានចាប់ខ្លួន ហើយតាទិត្យ ឡើងមកគ្រប់គ្រង។ តាទិត្យមកពីនិរតី"។ ERN 01155824 (ឆ២៤) (សៈ តើលោកនៅចាំខែ និងឆ្នាំ ដែលកិច្ចប្រជុំនៅទំនប់កង្កួត ត្រូវធ្វើឡើងដែរឬទេ? ឆ២៤៖ ខ្ញុំមិនចាំច្បាស់ទេ ប៉ុន្តែប្រហែលជាចុងឆ្នាំ ១៩៧៧")។ ERN 01155824 (ឆ២៥) (សៈ តើពួកកម្មាភិបាលនិរតីមកបានរយៈពេលប៉ុន្មាន ទើប យឹម ទិត្យ រៀបចំការប្រជុំនៅទំនប់កង្កួត? ស២៥៖ កម្មាភិបាលនិរតីមកនៅឆ្នាំ១៩៧៧។ មុនដំបូង ពួកនិរតីធ្វើការជាមួយគ្នា ជាមួយកម្មាភិបាលពាយ័ព្យ ប៉ុន្តែក្រោយមកពួកកម្មាភិបាលពាយ័ព្យ ត្រូវបានគេដកចេញ។ ខ្ញុំសូមបន្ថែមថា អ្នកដែលសម្លាប់មនុស្សច្រើនជាងគេ គឺពួកពាយ័ព្យ នៅក្នុងឆ្នាំ១៩៧៥")។ ERN 01155826 (ឆ៣៤) (សៈ មុននេះ លោកបាននិយាយថា កិច្ចប្រជុំប្រកាសអំពីការចាប់ខ្លួន តាប៉ែត និងតាកៅ នៅឆ្នាំ១៩៧៧។ តើលោកអាចបញ្ជាក់រដូវបានទេ? ស៣៤៖ ខ្ញុំមិនចាំខែទេ ពីព្រោះនៅពេលនោះ ខ្ញុំមិនបានយកចិត្តទុកដាក់ អំពីពេលវេលាទេ ដោយខ្ញុំគិតតែពីប្រឹងធ្វើការ ទាំងព្រឹក ថ្ងៃ និងយប់ ដើម្បីរស់រានមានជីវិត។ ប៉ុន្តែកិច្ចប្រជុំនោះ ធ្វើឡើងនៅក្នុងឆ្នាំ១៩៧៧")។

[814] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧២-១៧៣។

[815] ចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឡើយ ក្នុងការពិចារណាលើ វី ផាន់ និង ជួន ថន ពាក់ព័ន្ធនឹងបញ្ហា "កងទ័ព និងបុគ្គលិក"។ សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៤ (i) ជើងទំព័រ ៩៥៤ ( ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី វី ផាន់ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/85 ERN 01040094 (ឆ៥) (សៈ តើតាទិត្យ គាត់មាននិយាយអំពីរឿងខ្មាំងផ្ទៃក្នុង ប្រឆាំងនឹងអង្គការដែរឬទេ? ឆ៥៖ បាទ គាត់និយាយអំពីរឿងខ្មាំងផ្ទៃក្នុង ដែលលាក់ខ្លួនស៊ីរូងផ្ទៃក្នុង របស់ចលនាយើង ហើយក៏មានពួកសេអ៊ីអា កាហ្សេបេ យួន លាក់ខ្លួនជាមួយយើងផងដែរ។ តាទិត្យ បាននិយាយប្រាប់ពួកយើងថា យើងត្រូវតែឃ្លាំមើលពួកទាំងនេះ ហើយបើយើងបានព័ត៌មានទាក់ទងនឹង

01677248



325. ជាបន្ទាប់ សហមេធាវីបានបញ្ជាក់ អំពីកំហុសដែលប្រហែលជាប្រព្រឹត្តដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ "ខកខានមិនបានពិចារណាទៅលើភ័ស្តុតាងផ្ទុយ និងកត្តានានាដែលពាក់ព័ន្ធ" នៅពេលវាយតម្លៃលើសាក្សី ៦ រូប ដើម្បីគាំទ្រដល់សិទ្ធិអំណាចរបស់ យឹម ទិត្យ ទៅលើអ្នកក្រោមបង្គាប់របស់គាត់ លើបញ្ហាសន្តិសុខនៅក្នុងតំបន់[816]។ ចំពោះកាលបរិច្ឆេទខែវិច្ឆិកា ឆ្នាំ១៩៧៨ របស់ វី ផាន់ ដូចខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឡើយ ក្នុងការពិភាក្សាលើភាពខុសគ្នានេះ[817]។ ចំពោះ ជួន ថន វិញ អង្គជំនុំជម្រះមិនយល់ឃើញថា ភ័ស្តុតាងអំពី យឹម ទិត្យ ដឹកនាំការប្រជុំនៅក្នុងតំបន់ ២ "មិនពាក់ព័ន្ធ" នោះឡើយ ព្រោះ យឹម ទិត្យ ក៏ទទួលខុសត្រូវផងដែរ ចំពោះតំបន់៣ រួមជាមួយតំបន់ ១ និងជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យផងដែរ[818]។ លើសពីនេះ ទៀត ព័ត៌មានលម្អិតអំពីការប្រជុំនេះ ដូចជា សកម្មភាព និងការប្រព្រឹត្តិរបស់ យឹម ទិត្យ បានបង្ហាញភ័ស្តុតាងអំពីរូបភាពនៃភាពជាអ្នកដឹកនាំរបស់គាត់

---

សកម្មភាពពួកទាំងនេះ គឺយើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះ មុននឹងពួកនេះកម្ទេចពួកយើង") និង កំណត់ហេតុស្តាប់ចម្លើយសាក្សី ជួន ថន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990645 (ឆ១៧) ("ស៖ នៅពេលប្រជុំនោះ តើតាទិត្យ បាននិយាយអំពីរឿងអ្វីខ្លះ? ឆ១៧៖ តាទិត្យគឺជាអ្នកដែលនិយាយ អំពីរឿងរ៉ាវដែលខ្ញុំ បានជម្រាបអម្បាញ់មិញនេះ។ គាត់បាននិយាយថា គាត់បានទទួលព័ត៌មានជាច្រើន អំពីប្រធានសហករណ៍ ទាក់ទងនឹងអំពើចោរកម្ម ហើយ និងសកម្មភាពខ្មាំង នៅតាមមូលដ្ឋានជាច្រើន។ គាត់បានណែនាំឱ្យយើង តាមដានសកម្មភាពទាំងនេះជាប្រចាំ។ បើយើងតាមដានឃើញសកម្មភាពទាំងនេះ គឺយើងត្រូវតែយកទៅណែនាំជាមុនសិន មុននឹងយកទៅកម្ទេច ហើយរាយការណ៍ទៅថ្នាក់លើ")។

[816] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៤ (ការនេះពាក់ព័ន្ធកំហុសដែលលើកឡើង អំពី វី ផាន់ ជួន ថន ណុប ង៉ឹម ឈឿន ប៊ិន ង៉ឹង ឈឿត និង ណាង នី)។

[817] កថាខណ្ឌ ៣១៥ ខាងលើ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៩៤ ( ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី វី ផាន់ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/85 ERN 01040093 (ឆ៣) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា "ទោះបីសាក្សីអះអាងថា ការប្រជុំនេះបានកើតឡើង នៅចុងឆ្នាំ១៩៧៨ ក៏ដោយ តែវត្តមានរបស់តាប៉ែត ដែលត្រូវបានចាប់ខ្លួននៅខែសីហា ឆ្នាំ១៩៧៨ បង្ហាញថា ការប្រជុំប្រហែលជាបានកើតឡើង មុនកាលបរិច្ឆេទនេះ ហើយសាក្សីមានការភាន់ច្រឡំអំពីកាលបរិច្ឆេទ")។

[818] អង្គជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថា នៅអំឡុងឆ្នាំ១៩៧៨ យឹម ទិត្យ "បានទទួលមុខតំណែងជាលេខាតំបន់១" និងថាបណ្តាភស្តុតាងជាច្រើន បង្ហាញថា យឹម ទិត្យ "បានកាន់មុខតំណែងនេះតាំងពីដើមខែមិថុនា ឆ្នាំ១៩៧៨ ពោលគឺ ចាប់តាំងពីពេលដែលគាត់ កាន់តំណែងជាលេខាតំបន់១"។ ( សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៧២)។ *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៨០ ដែលរៀបរាប់លម្អិត អំពីសមាជិកគណៈកម្មាធិការ ភូមិភាគពាយ័ព្យ។

(ប្រហែលគ្នានឹងតំបន់ ១) រួមជាមួយនឹងតួនាទី និងកម្រិតនៃសិទ្ធិអំណាច និងការគ្រប់គ្រងរបស់ យឹម ទិត្យ នៅពេលវេលាពាក់ព័ន្ធ[819]។

326. ចំពោះ ណុប ងឹម វិញ សហមេធាវីមិនបានបង្ហាញ ថាតើការប្រជុំនៅបាត់ដំបង នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៨ "ផ្ទុយគ្នា"[820] របៀបណា ជាមួយនឹងការប្រជុំដែលធ្វើឡើង បន្ទាប់ពីការតែងតាំង យឹម ទិត្យ នៅអំឡុងខែមិថុនា ឆ្នាំ១៩៧៨[821]។ លើសពីនេះទៀត អង្គជំនុំជម្រះបដិសេធទឡ្ហីករណ៍របស់ សហ មេធាវីដែលថា ណុប ងឹម "មិនអាចចងចាំបាន" នូវអ្វីដែល យឹម ទិត្យ ពិភាក្សានៅពេលប្រជុំនេះ[822] ដែលជាការបង្ហាញដោយមិនត្រឹមត្រូវពីភ័ស្តុតាង។ ការដែល ណុប ងឹម មិនបានដឹង គឺជាចម្លើយចំពោះសំណួរ "តើលោកស្រីដឹងថា តាទិត្យ មានផ្តល់ព័ត៌មាន*ជាក់លាក់* ស្តីពីការកម្ទេចខ្មាំងទេ?"[823]។ ប៉ុន្តែ សាក្សីបានដឹងថា យឹម ទិត្យ រាយការណ៍អំពី "ស្ថានភាពទូទៅនៅក្នុងតំបន់ ដែលគាត់គ្រប់គ្រង" និងរួមគ្នាជាមួយតាម៉ុក រាយការណ៍លម្អិតពី "ស្ថានភាពខ្មាំង" និងណែនាំលម្អិតថាតើអ្នកចូលរួម "ត្រូវកម្ទេចខ្មាំងណា ដែលប្រឆាំងនឹងអង្គការ"[824]។

---

[819] កំណត់ហេតុស្តាប់ចម្លើយសាក្សី ជួន ចន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990646 (ឆ១៨) ("សៈ នៅពេលដែលប្រជុំ តើតាទិត្យ ត្រូវបានគេឧទ្ទេសនាមគាត់យ៉ាងម៉េច? ឆ១៨៖ នៅពេលនោះ គេបានឧទ្ទេសនាមគាត់ថាជាគណៈតំបន់១")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ជួន ចន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990645 (ឆ១៦)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ជួន ចន ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990645 (ឆ១៦-ឆ១៧) (ជាឧទាហរណ៍ ("សៈ នៅពេលប្រជុំនោះ តើតាទិត្យ បាននិយាយអំពីរឿងអ្វីខ្លះ? ឆ១៧៖ តាទិត្យគឺជាអ្នកដែលនិយាយអំពីរឿងរ៉ាវដែលខ្ញុំ បានជម្រាបអម្បាញ់មិញនេះ។ គាត់បាននិយាយថា គាត់បានទទួលព័ត៌មានជាច្រើនអំពីប្រធានសហករណ៍ ទាក់ទងនឹងអំពើចោរកម្ម ហើយនិងសកម្មភាពខ្មាំង នៅតាមមូលដ្ឋានជាច្រើន។ គាត់បានណែនាំឱ្យយើងតាមដានសកម្មភាពទាំងនេះជាប្រចាំ។ បើយើងតាមដានឃើញសកម្មភាពទាំងនេះ គឺយើងត្រូវតែយកទៅណែនាំជាមុនសិន មុននឹងយកទៅកម្ទេច ហើយរាយការណ៍ទៅថ្នាក់លើ")។

[820] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៥។

[821] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦០។

[822] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៥។

[823] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៤ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008711 (ឆ៨៦)។

[824] សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៤ (ii) ជើងទំព័រ ៩៥៥ (ដកស្រង់ភស្តុតាងជាច្រើនដូចជា កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008701 (ឆ៥៥-ឆ៥៦) (អង្គជំនុំជម្រះកត់សម្គាល់ថា ណុប ងឹម បានរៀបរាប់ថា តាទិត្យ និយាយអំពីស្ថានភាពទូទៅ នៅក្នុងតំបន់ ១

327. ចំពោះការតវ៉ារបស់សហមេធាវីដែលថា ភស្តុតាងរបស់ ឈឿន ប៊ាន ពាក់ព័ន្ធនឹងការប្រជុំ ដែលធ្វើឡើងនៅក្នុងខែកញ្ញា ឬតុលា ឆ្នាំ១៩៧៨ ដោយមិនមានការណែនាំអំពី យឹម ទិត្យ នោះ អង្គជំនុំជម្រះ សូមបដិសេធការជំទាស់ពាក់ព័ន្ធនឹងកាលបរិច្ឆេទនៃការប្រជុំ ព្រោះកាលបរិច្ឆេទនេះធ្វើឡើងបន្ទាប់ពីការតែងតាំង យឹម ទិត្យ ដូចខាងលើ[825]។ លើសពីនេះទៀត ការមិនមានការណែនាំអំពី យឹម ទិត្យ នៅក្នុងកិច្ចប្រជុំនេះ មិនបានបង្ហាញអំពីកំហុសណាមួយឡើយ ដោយសារតែការពន្យល់របស់សាក្សី ដែលថា គាត់ដឹងថា គឺជា យឹម ទិត្យ ព្រោះ "យើងត្រូវបានគេប្រាប់នៅមុនកិច្ចប្រជុំនោះមួយថ្ងៃថា តាទិត្យ ដែលជាគណៈតំបន់ នឹងមកធ្វើជាប្រធានកិច្ចប្រជុំ"[826]។

328. ទោះបីជា ឆឹង ឈឿត (ជាពលករនៅក្នុងរបបខ្មែរក្រហម រួមទាំងនៅទំនប់កង្កួត)[827] បានឃើញ យឹម ទិត្យ តែម្តងគត់ ហើយឱកាសរបស់គាត់ ក្នុងការមើលឃើញជនជាប់ចោទ គឺមើលឃើញពីចម្ងាយ នៅក្នុងកិច្ចប្រជុំមួយ[828]ក្តី តែអង្គជំនុំជម្រះពិចារណាថា អ្នកវិនិច្ឆ័យលើអង្គហេតុប្រកបដោយហេតុផលម្នាក់ អាចធ្វើការពិចារណាទៅក្នុងខ្លឹមសារនៃភស្តុតាង ថា ឆឹង ឈឿត បានចូលរួមក្នុងការប្រជុំ ដែល យឹម ទិត្យ បាននិយាយអំពីខ្មាំង។ សាក្សីបានរៀបរាប់អំពីការដឹងឮនៅពេលនោះថា "គេប្រាប់ថា [យឹម ទិត្យ] មកផ្លាស់តាប៉ែតហើយ"[829]។ លើសពីនេះទៀត នៅ

---

ដែលគាត់គ្រប់គ្រង និងអំពីស្ថានភាពនៅក្នុងស្រុកនានា ក្នុងតំបន់របស់គាត់។ គាត់បានណែនាំដល់អ្នកតំណាងស្រុកនានា នៅក្នុងតំបន់របស់គាត់ "សៈនៅក្នុងការប្រជុំ តើតាម៉ុក និងតាទិត្យ ដែលនិយាយអំពីរឿងកម្ទេចខ្មាំងដែរឬទេ? ឆ៥៦៖ ចាំ តាម៉ុក និងតាទិត្យ បាននិយាយអំពីស្ថានភាពខ្មាំង។ ពួកគាត់បានណែនាំយើងថា យើងត្រូវកម្ទេចខ្មាំងណា ដែលប្រឆាំងនឹងអង្គការ ពួកគាត់មិនបាននិយាយថា អ្នកណាជាខ្មាំងនោះទេ ហើយក៏មិនបាននិយាយថា ត្រូវកម្ទេចខ្មាំងនោះ តាមវិធីណាដែរ។ តាមខ្ញុំយល់ឃ្លាដែលថា "ខ្មាំងណាដែលក្បត់នឹងយើង យើងត្រូវកម្ទេច មានន័យថា ខ្មាំងនោះនឹងត្រូវបានសម្លាប់"។ អង្គជំនុំជម្រះកត់សម្គាល់ថា ការដកស្រង់ដែលនៅសល់ ដែលលើកឡើងដោយសហមេធាវី អំពីការសម្លាប់ចម្លើយដទៃទៀតរបស់ ណុប ធីម (ឯកសារ D219/285 និង ឯកសារ D219/298) មិនមានអត្ថន័យឡើយ)។

[825] សូមមើលកថាខណ្ឌ ៣១៨ ខាងលើ។

[826] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/430 ERN 01122420 (ឆ១២៨)។

[827] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆឹង ឈឿត ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ឯកសារ D219/953 ERN 01425164 (ឆ១៤)។

[828] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៤។

[829] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៤។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆឹង ឈឿត ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ឯកសារ D219/953 ERN 01425173 (ឆ៥៦) ("សៈ ពេលលោក

ក្នុងការប្រជុំ ឆឹង ឈឿត បានរៀប រាប់ថា បានឃើញថា យឹម ទិត្យ មានឃោធានៅហ៊ុំព័ទ្ធ[830] បាន ឮ "តែឈ្មោះថាគាត់ [យឹម ទិត្យ] មកៗៗ" និង "គេថាតាៗ"[831] ហើយបានឃើញ យឹម ទិត្យ ប្រកាសថា "គេថាបោសសម្អាតខ្មាំងយួន"[832] ដូចនឹងការប្រកាសដែល យឹម ទិត្យ បានផ្សព្វផ្សាយ នៅការប្រមូលផ្តុំកម្មាភិបាលដទៃទៀតដែរ[833]។

329. ចំពោះ ណាង នី (អ្នកធ្វើការនៅកងចល័ត ក្នុងតំបន់១ ចាប់ពីអំឡុងខែមេសា ឆ្នាំ១៩៧៥ រហូតដល់ ឆ្នាំ១៩៧៩ រួមទាំងនៅទំនប់កង្កួតផងដែរ)[834] អង្គជំនុំជម្រះមិនជឿថា មានកំហុសណាមួយចំពោះ ការដែលគាត់បានឃើញ យឹម ទិត្យ នៅអំឡុងខែតុលា ឆ្នាំ១៩៧៨ ឬអំពីការកំណត់អត្តសញ្ញាណ ឡើយ[835]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាដោយសមហេតុផលថា ណាង នី "ដឹងតែតាទិត្យ" និងមានភ័ស្តុតាងថា យឹម ទិត្យ បានធ្វើការប្រកាស ក្នុងការប្រជុំនៅបាយដំរាំថា ពួកពាយ័ព្យ គឺ "ក្បាលយួន ខ្លួនខ្មែរ" ហើយបានចូលរួមជាមួយវៀតណាម ហើយ "ហេតុ

---

ចាប់ឮឈ្មោះតាទិត្យ ឬ យឹម ទិត្យ ចាប់ឮដំបូងបំផុតនៅពេលណា? ឆ៥៦៖ ពេលគាត់មកប្រជុំ គេប្រាប់ថា មកផ្លាស់តាប៉ែតហើយ គាត់មកប្រជុំហ្នឹង ហើយក៏បាត់រហូតទៅ")។

[830] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆឹង ឈឿត ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ឯកសារ D219/953 ERN 01425165 (ឆ១៧)។

[831] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆឹង ឈឿត ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ឯកសារ D219/953 ERN 01425175 (ឆ៦៩)។

[832] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ 364(ii), ជើងទំព័រ 955, ( ដកស្រង់ *ផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆឹង ឈឿត ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ឯកសារ D219/953 ERN 01425176 (ឆ៧០-ឆ៧៥))។

[833] សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី វី ផាន់ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/85 ERN 01040094 (ឆ៥) (ស៖ តើតាទិត្យ គាត់មាននិយាយអំពីរឿងខ្មាំងផ្ទៃក្នុង ប្រឆាំងនឹងអង្គការដែរឬទេ? ឆ៥៖ បាទ គាត់និយាយអំពីរឿងខ្មាំងផ្ទៃក្នុង ដែលលាក់ខ្លួនស៊ីរូងផ្ទៃក្នុង របស់ចលនាយើង ហើយក៏មានពួកសេអ៊ីអា កាហ្សេបេ យួន លាក់ខ្លួនជាមួយយើងផងដែរ។ តាទិត្យ បាននិយាយប្រាប់ពួកយើងថា យើងត្រូវតែឃ្លាំមើលពួកទាំងនេះ ហើយបើយើងបានព័ត៌មានទាក់ទង នឹងសកម្មភាពពួកទាំងនេះ គឺយើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះ មុននឹងពួកនេះកម្ទេចពួកយើង") *សូមមើលផងដែរ*កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាង នី ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/77 ERN 00934388-00934390 (ឆ២៤-ឆ៣៣) (ណាង នី ដែលបានបញ្ជាក់ថា "ខ្ញុំដឹងតែតាទិត្យ" ហើយបានរៀបរាប់ថា យឹម ទិត្យ កាន់ក្បាលមេក្រូ ប្រកាស និងនិយាយថា ក្រុមពាយ័ព្យ "ក្បាលយួនខ្លួនខ្មែរ" ដោយចោទប្រកាន់ពួកពាយ័ព្យថា ចូលដៃចូលជើងជាមួយវៀតណាម "ហេតុនេះហើយទើបគេចាប់ ពួកកម្មាភិបាលពាយ័ព្យសម្លាប់ចោល")។

[834] កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាង នី ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/77 ERN 00934384 (ឆ១)។

[835] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៤។

នេះហើយទើបគេចាប់ពួកកម្មាភិបាលពាយ័ព្យសម្លាប់ចោល"[836]។ សាក្សីក៏បានផ្តល់សក្ខីកម្មផងដែរថា យឹម ទិត្យ ជិះឡានហ្សីបឃោធាមកប្រជុំ ហើយមានទាហានពីរបីនាក់ហែហម[837]។

330. ដោយពិចារណាទៅលើ ការជំទាស់របស់សហមេធាវី ចំពោះសាក្សីប្រាំមួយរូប ដែលបានគាំទ្រអំពីសិទ្ធិអំណាចរបស់ យឹម ទិត្យ ទៅលើអ្នកក្រោមបង្គាប់ អំពីបញ្ហាសន្តិសុខ គឺជាការជំទាស់មិនជោគជ័យដូចខាងលើ[838] ចៅក្រមអន្តរជាតិកត់សម្គាល់ថា ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើការបញ្ជា ការណែនាំ ឬការរាយការណ៍ រវាង យឹម ទិត្យ និងអ្នកក្រោមបង្គាប់របស់គាត់ នៅក្នុងតំបន់ ១ មានមូលដ្ឋានភស្តុតាងគ្រប់គ្រាន់[839]។ ជាពិសេសសហមេធាវីទាញយកជើងទំព័រចំនួនពីរ ពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីបង្ហាញពីការមិនមានភស្តុតាង អំពីការណែនាំរបស់ យឹម ទិត្យ ឱ្យ "អប់រំ" ឬ "កម្ទេច"[840] ប៉ុន្តែ ក្នុងនោះ សាក្សីមួយរូបដែលត្រូវបានដកស្រង់នៅក្នុងជើងទំព័រទាំងនោះ បានបញ្ជាក់ថា "តាទិត្យ និយាយអំពីខ្មាំងផ្ទៃក្នុង [...] តាទិត្យបាននិយាយប្រាប់ពួកយើងថា យើងត្រូវតែឃ្លាំមើលពួកទាំងនេះ ហើយបើយើងបានព័ត៌មាន ទាក់ទងនឹងសកម្មភាពពួកទាំងនេះ យើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះ"[841]។ លើសពីនេះទៀត អង្គជំនុំជម្រះមិនជឿថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនយកចិត្តទុកដាក់ដល់ការ "កំណត់អត្តសញ្ញាណ អ្នកនៅក្រោមបង្គាប់" ឬ "ពន្យល់ឱ្យជាក់លាក់ថា" យឹម ទិត្យ ធ្វើការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ទៅលើពួកគេដោយរបៀបណា នៅក្នុង

---

836 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៤ ជើងទំព័រ ៩៥៥ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាង នី ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/77 ERN 00934389 (ឆ២៨-ឆ៣០)។

837 កំណត់ហេតុស្តាប់ចម្លើយសាក្សី ណាង នី ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/77 ERN 00934391 (ឆ៤៦-ឆ៤៨)។ អង្គជំនុំជម្រះមិនចាត់ទុកថាមានភាពពាក់ព័ន្ធជាមួយ "លើកទីមួយ" ដែល ណាង នី បានជួបជនជាប់ចោទឡើយ។

838 កថាខណ្ឌ ៣២៥-៣២៨ ( វី ផាន់ ជួន ថន ណុប ងឹម ឈឿន ប៊ាន ឆឹង ឈឿត ណាង នី)។

839 *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៥។ សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៤-៣៦៥ ជើងទំព័រ ៩៥៣-៩៧២។

840 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៥ ដកស្រង់ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៥ ជើងទំព័រ ៩៧១-៩៧២។

841 កំណត់ហេតុស្តាប់ចម្លើយសាក្សី វី ផាន់ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/85 ERN 01040094 (ឆ៥) ដកស្រង់ នៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៥ ជើងទំព័រ ៩៧២។

តំបន់ ១[842] ព្រោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់អត្តសញ្ញាណអ្នកនៅក្រោមបង្គាប់ និងរៀបរាប់អំពីកម្រិតនៃសិទ្ធិអំណាច និងការគ្រប់គ្រងរបស់ យឹម ទិត្យ ទៅលើពួកគេ (រួមទាំង "សិទ្ធិអំណាចតាមព្រឹត្តិន័យរបស់ យឹម ទិត្យ ទៅលើកម្មាភិបាលថ្នាក់ឃុំ និងថ្នាក់ស្រុក នៅក្នុងតំបន់របស់គាត់"[843] និងការប្រព្រឹត្តិរបស់ យឹម ទិត្យ ចំពោះអ្នកក្រោមបង្គាប់[844])។

331. បន្តទៅ ផរ ប៉ែត (ទាហានដែលឈរជើងនៅស្រុកបាណន់ កង្កត ព្រៃតូច)[845] ទឡ្ហីករណ៍របស់ សហ មេធាវីដែលថា មិនមានអ្នកវិនិច្ឆ័យលើអង្គហេតុប្រកបដោយហេតុផលម្នាក់ អាចធ្វើការសន្និដ្ឋាន បន្ទាប់ពីពឹងផ្អែកទៅលើ "សាក្សីតែម្នាក់គត់" នេះ ថា យឹម ទិត្យ បញ្ជាឱ្យដោះលែងអ្នកជាប់ឃុំនោះ[846] ទទួលបរាជ័យ។ ទីមួយ សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បញ្ជាក់ដោយមិនត្រឹមត្រូវពីព័តមានរបស់ ផរ ប៉ែត អំពីការអន្តរាគមរបស់ យឹម ទិត្យ ទៅលើការដោះលែងអ្នកជាប់ឃុំ និងបានដកស្រង់នូវផ្នែកដែលពាក់ព័ន្ធនៃចម្លើយដើមរបស់

---

[842] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៥។

[843] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៤(v) លើសពីនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្ហាញអំពីការគ្រប់គ្រងរបស់ យឹម ទិត្យ ទៅលើតំបន់ ១ នៅក្នុងកថាខណ្ឌ ៣៦៤ ដោយរៀបរាប់ផងដែរថា យឹម ទិត្យ "មានសិទ្ធិអំណាច និងត្រួតត្រាផ្ទាល់ ទៅលើបញ្ហាកងទ័ព និងបុគ្គលិក នៅក្នុងតំបន់" និង "លើអ្នកក្រោមបង្គាប់ លើបញ្ហាសន្តិសុខនៅក្នុងតំបន់" និង "ខាងសេដ្ឋកិច្ច" ដូចជា ប្រព័ន្ធធារាសាស្ត្រ និងផលិតកម្មកសិកម្ម និងការចុះពិនិត្យទំនប់កង្កត។ សូមមើល តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង Karemera & Ngirumpatse*, IT-98-44-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ កថាខណ្ឌ ៣៧០។ (អង្គជំនុំជម្រះតុលាការកំពូល បានលើកមតិពាក់ព័ន្ធ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះថា "អង្គជំនុំជម្រះតុលាការកំពូល សូមរំឮកអំពីគោលការណ៍ ដែលបានកំណត់យ៉ាងច្បាស់លាស់ថា ក្នុងការសម្រេចថាតើជនជាប់ចោទបានទទួលព័ត៌មានគ្រប់គ្រាន់ដែរឬអត់ អំពីលក្ខណៈ និងមូលហេតុនៃបទចោទប្រឆាំងរូបគាត់នោះ ចាំបាច់ត្រូវពិចារណាជារួម លើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ [...] តាមកាលៈទេសៈមួយចំនួន ការយោងទៅអ្នកក្រោមបង្គាប់ ទៅតាមប្រភេទ អាចបង្កើតបានជាការជូនដំណឹងគ្រប់គ្រាន់ អំពីអត្តសញ្ញាណរបស់គាត់")។

[844] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៤-៣៧១ រួមទាំងជាពិសេស កថាខណ្ឌ ៣៦៥ (ដែលស្ថិតនៅក្នុងមូលដ្ឋានដើមនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទាញសន្និដ្ឋានអំពី យឹម ទិត្យ ចេញបញ្ជានៅកិច្ចប្រជុំ អំពីវិធីសាស្ត្រធារាសាស្ត្រ បង្កបង្កើនផល និង/ឬបញ្ហាសន្តិសុខ និងភាពចាំបាច់ដែលសមាជិកអង្គប្រជុំត្រូវរាយការណ៍ពីខ្មាំង ឬកម្មេចខ្មាំង)។

[845] កំណត់ហេតុស្តាប់ចម្លើយសាក្សី ផរ ប៉ែត ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/244 ERN 00990637 (ឆ២-ឆ៥)។

[846] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៦-១៧៨។

សាក្សី[847]។ ប៉ុន្តែ ការដកស្រង់ ផ្ទាល់ បង្ហាញថា យឹម ទិត្យ ដែលធ្វើការណែនាំខ្លួន ថាជាប្រធានតំបន់[848] បានមកទាន់ហេតុការណ៍ ពេលតាណេន ប្រុងសម្លាប់អ្នកជាប់ឃុំ និងប្រាប់ឱ្យគាត់ដោះលែងអ្នកជាប់ឃុំទាំងអស់នោះ ដោយបញ្ជាក់ថា "បើសិនណេន ឯង សម្លាប់ពួកទាំងនេះ តើមាននរណាការពារ ណេន ឯង"[849]។ ចំណុចនេះបានបង្ហាញយ៉ាងច្បាស់ អំពីសិទ្ធិអំណាចរបស់ យឹម ទិត្យ ក្នុងការការពារបុគ្គលនានា ពីការសម្លាប់។ ទីពីរ ដោយសារតែព័ត៌មានរបស់ ផរ ប៉ែត អំពីការដោះលែងកងទ័ព ដោយ យឹម ទិត្យ នេះ ការជំទាស់ផ្សេងទៀតរបស់សហមេធាវី[850] ក្លាយជាលែងពាក់ព័ន្ធ ឬមិនមានខ្លឹមសារសម្រាប់ពិចារណា។

332. អង្គជំនុំជម្រះសម្រេចថា មិនមានកំហុសឡើង ក្នុងការពិចារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើភស្តុតាងរបស់ ឈឿន ប៊ិន ដែលថា យឹម ទិត្យ បានដោះលែងតាសាម៉ន ជាកម្មាភិបាលភូមិភាគពាយ័ព្យ[851]។ ការអះអាងរបស់សហមេធាវីដែលថា ចំណុចនេះគឺផ្អែកទៅលើព័ត៌មានដែលមិនមានការគាំទ្ររបស់សាក្សី ដែលថា គាត់បានឃើញ តាសាម៉ន នៅរស់ ក្រោយឆ្នាំ ១៩៧៩[852] ទទួលបរាជ័យ។ ឈឿន ប៊ិន បានបញ្ជាក់នៅក្នុងការស្តាប់ចម្លើយដទៃទៀតថា បន្ទាប់ពីតាទិត្យមកដល់ តាសាម៉នក្លាយជាអ្នកគ្រប់គ្រងសមរភូមិកង្កួត និងទទួលបន្ទុកលើសេដ្ឋកិច្ច និង

---

[847] កំណត់ហេតុស្តាប់ចម្លើយសាក្សី ផរ ប៉ែត ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/244 ERN 00990637 (ឆ៥)។

[848] កំណត់ហេតុស្តាប់ចម្លើយសាក្សី ផរ ប៉ែត ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/244 ERN 00990638 (ឆ៦)។

[849] កំណត់ហេតុស្តាប់ចម្លើយសាក្សី ផរ ប៉ែត ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/244 ERN 00990637 (ឆ៥)។

[850] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៨ (លើកឡើងផងដែរថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "ខកខានមិនបានពិចារណាលើ ភស្តុតាងរបស់ ផរ ប៉ែត ដែលថា គាត់ជឿជា តា ណេន គឺជាគណៈស្រុកមួយ (ទោះបីជាគាត់មិនដឹងថាមួយណាក៏ដោយ) គាត់មិនដឹងថាតើ តាទិត្យ ឬតាណេន មួយណាមានឋានៈខ្ពស់ជាងឡើយគាត់មិនស្គាល់សមាជិកភូមិភាគ តំបន់ និងស្រុកទាំងអស់ គាត់មិនដែលឮឈ្មោះ តាវ៉ាញ តាញឹម ឬតាប៉ែត និងឮឈ្មោះតាម៉ុក តែម្តងគត់ ក្រោយពេលគាត់ត្រូវបានចាប់ខ្លួន។ ពុំមានអ្នកវិនិច្ឆ័យអង្គហេតុ ប្រកដោយហេតុផល អាចសន្និដ្ឋានពីភស្តុតាងនេះថា យឹម ទិត្យ "បញ្ជាឱ្យគេដោះលែងទាហានមួយចំនួន ឬមានអំណាចការពារមិនឱ្យ គេចាប់ខ្លួនឬសម្លាប់មនុស្សឡើយ")។

[851] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៩។ (ឈឿន ប៊ិន ជាសមាជិកកងចល័ត ធ្វើការនៅទួលម្ទេស និងកសាងទំនប់កង្កួត សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿន ប៊ិន ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/368 ERN 01110174 (ឆ១)។

[852] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៧៩ ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿន ប៊ិន ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/430 ERN 01122398 (ឆ២០-ឆ២១)។

ការផ្ដត់ផ្គង់ស្បៀង[853]។ ដោយបានដឹងអំពីព័ត៌មានលម្អិតពី តា យួន ដែលរស់នៅក្នុងឃុំជាមួយនឹងសាក្សីនៅពេលនោះ ឈឿន ប៊ិន បានដឹងអំពីការមកដល់កងតរបស់ តាទិត្យ មានទំនាក់ទំនងជាមួយនឹងការតែងតាំង តាសាម៉ន ទៅកាន់ការងារទាំងអស់នោះ និងថា ហេតុផលនៃការតែងតាំង តាសាម៉ន គឺថា តាទិត្យមិនស្គាល់តំបន់នោះ ហើយតាសាម៉ន គឺជាអ្នកដែលបង្ហាញផ្លូវដល់តាទិត្យ[854]។

333. គោលជំហររបស់សហមេធាវីគឺថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយមិនបាន "ផ្ដល់ការពន្យល់ណាមួយ ថាតើ "ទទួលបន្ទុក" មានន័យយ៉ាងដូចម្ដេច ក្នុងន័យការទទួលខុសត្រូវព្រហ្មទណ្ឌ" ត្រូវបានបដិសេធដោយ ភាពលម្អិតផ្នែកវិធីសាស្ត្រ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[855]។ អង្គជំនុំជម្រះយល់ថា ទស្សនៈរបស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេត

[853] កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឿន ប៊ិន ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/368 ERN 01110197 (ឆ១៤១)។

[854] កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឈឿន ប៊ិន17 ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ឯកសារ D219/465 ERN 01132080 (ឆ២៩-ឆ៣២)។

[855] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨០។ សូមមើល *ផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៩៨ សម្រេចថា "[យឹម ទិត្យ] និង តាម៉ុក បានដើតួនាទីស្នូលក្នុងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងកសិកម្មរបស់ ប.ក.ក នៅភូមិភាគពាយ័ព្យ ដែលមានគោលដៅបង្កបង្កើនផលជាតិរបស់កម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្កើតការដ្ឋាន និងសហករណ៍។ យឹម ទិត្យ បានទទួលខុសត្រូវទៅលើផលិតកម្ម និងការសាងសង់នៅក្នុងតំបន់នានា ដែលគាត់គ្រប់គ្រង ពិនិត្យទៅតាមការដ្ឋាន ដឹកនាំការប្រជុំ និងថ្លែងសុន្ទរកថាអំពី ការបង្កបង្កើនផលកសិកម្ម បណ្ដុះបណ្ដាលប្រធានអង្គភាពការងារ និងណែនាំឲ្យខិតខំប្រឹងប្រែងធ្វើការ ដើម្បីទៅតាមផែនការរបស់ ប.ក.ក")។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤០៥ សម្រេចថា "យឹម ទិត្យ បាននិយាយនៅឯកសារប្រជុំផ្សេងទៀតជាច្រើន ដែលគាត់ជំរុញការអនុវត្តគោលនយោបាយ ប.ក.ក និងផ្ដល់ការណែនាំអំពីការសាងសង់ទំនប់ និងជីកប្រឡាយ និងការអនុវត្តផ្សេងៗទៀត នៃការបង្កបង្កើនផល និងពលកម្ម")។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ១០២១ ក្រោមចំណងជើង "ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម "សហឧក្រិដ្ឋកម្មរួម" បានសន្និដ្ឋានថា "យឹម ទិត្យ បានចូលរួមចំណែកយ៉ាងច្រើនដល់គោលនយោបាយស្ដីពីការដ្ឋានការងារ និងសហករណ៍ តាមរយៈសកម្មភាព ជាអាទិ៍ ការរៀបចំការប្រជុំនានា ជាមួយអ្នកនៅក្រោមបង្គាប់របស់គាត់ និងការណែនាំពួកគេអំពីរបៀបអនុវត្តគោលនយោបាយសេដ្ឋកិច្ចរបស់ ប.ក.ក ការគ្រប់គ្រង និងការពិនិត្យការដ្ឋាន និងការមើលការខុសត្រូវ និងការតាមដានលើការកសាង និងការផលិត ការត្រួតត្រាលើកម្លាំងការងារ និងធនធានផ្សេងៗទៀត សម្រាប់ប្រតិបត្តិការនៅតាមការដ្ឋាន និងសហករណ៍ ដោយប្រកាសថា

អន្តរជាតិ ផ្អែកការសម្រេចរបស់ខ្លួនដែលថា យឹម ទិត្យ ទទួលខុសត្រូវលើសេដ្ឋកិច្ច ក្នុងតំបន់១ "ដោយគ្រាន់តែផ្អែកលើសុន្ទរកថាពីរបីដែលលោក យឹម ទិត្យ ធ្វើឡើងប៉ុន្មានខែ មុនពេលរៀត ណាមមកដល់តែប៉ុណ្ណោះ"[856] គឺជាការធ្វើឱ្យសាមញ្ញហួសហេតុទៅលើភស្តុតាង ដោយមិនគិតអំពី បរិបទទូលាយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[857]។

334. លើសពីនេះទៀត ចំពោះគោលជំហររបស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដោយមិនបាន "ផ្តល់ហេតុផលថាតើហេតុអ្វី" ទើបភស្តុតាងអំពីការតែងតាំង យឹម ទិត្យ ជាលេខាតំបន់១ ពាក់ព័ន្ធជាមួយនឹងការកំណត់អំពីសិទ្ធិអំណាចរបស់គាត់នោះ អង្គជំនុំជម្រះ សម្រេចថាមិនមានកំហុសឡើយ[858]។ ច្បាស់ណាស់ថា ការតែងតាំង យឹម ទិត្យ ជាផ្លូវការ រួម ជាមួយតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដែលអមមកជាមួយ ស្ថិតលើកម្រិតនៃការបញ្ជា ឬ

---

ប្រជាជនណាដែលមិនបានបំពេញការងាររបស់ខ្លួនគួរជាទីពេញចិត្ត នឹងត្រូវចាត់ទុកថាជាខ្មាំង ហើយតាមរយៈការឆ្លើយដាក់ ពួកគេត្រូវបានសម្លាប់ចោល"។

[856] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨០។

[857] សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៨១ ជើងទំព័រ ១០០៧ ដកស្រង់កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប សឹង ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/117 នៅត្រង់ ERN 01046465 (ឆ៥៨-ឆ៦០) (ដែល តុប សឹង រៀបរាប់ថាបានឃើញ យឹម ទិត្យ អំឡុងឆ្នាំ ១៩៧៨ (មកជំនួសតាប៉ែត) និងឃើញ យឹម ទិត្យ ទៅពិនិត្យទំនប់កង្កួត ដើម្បីតាមដានមើលការវិវឌ្ឍន៍របស់ការសាងសង់)។ លើសពីនេះទៀត អង្គជំនុំជម្រះសម្រេចថា ការចោទពីសុន្ទរកថា អំពីប្រព័ន្ធធារាសាស្ត្រ និងការបង្ករបង្កើនផល បានបង្ហាញអំពីការប្រើប្រាស់សិទ្ធិអំណាច និងឥទ្ធិពលជាក់ស្តែងរបស់ យឹម ទិត្យ (រួមទាំង យឹម ទិត្យ ដឹកនាំការប្រជុំដោយខ្លួនឯង បង្ហាញអំណាចទៅលើប្រជាជន ចេញសេចក្តីណែនាំនិងបញ្ជា ទៅកម្មាភិបាល ផ្សព្វផ្សាយយុទ្ធសាស្ត្រការងារ និងនីតិវិធីគេច)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/368 ERN 01110186-01110187 (ឆ៩៣-ឆ៩៥) ("សៈតើតាទិត្យ ណែនាំខ្លួនគាត់យ៉ាងដូចម្តេច នៅក្នុងកិច្ចប្រជុំលើកដំបូងនោះ? ឆ៩៣៖ តាទិត្យបាននិយាយអំពីគោលបំណង នៃការដឹកនាំរបស់គាត់ថា គាត់មានបំណងធ្វើឱ្យ ប្រជាជនមានភាពរីកចម្រើន ដើម្បីឱ្យប្រជាជនមានបាយហូប ជំនួសឱ្យការហូបបបរ។ ដូច្នេះ គាត់ណែនាំអំពីវិធីសាស្ត្រ កែលម្អទិន្នផលកសិផលតាមរយៈការប្រើប្រាស់ជី ដូចជា ជីអាចម៍គោ និងជីលាមកមនុស្ស។ តាទិត្យ ក៏បានប្រាប់ឱ្យប្រជាជន ជួយកែតម្រូវគាត់ផងដែរ ប្រសិនបើគាត់ដឹកនាំខុស ប៉ុន្តែគ្មានអ្នកណាហ៊ានកែតម្រូវគាត់នោះទេ ដោយយើងគ្រាន់តែនាំគ្នានិយាយថា បាទៗប៉ុណ្ណោះ។

[858] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨១។

សិទ្ធិអំណាច (តាមព្រឹត្តិន័យ និង/ឬតាមនីតិន័យ) ដែល យឹម ទិត្យ បានប្រើប្រាស់នៅក្នុងតំបន់ ១ រួមទាំងទៅលើអ្នកក្រោមបង្គាប់ផង[859]។

335. សហមេធាវីបានលើកឡើងពីការជំទាស់ជាច្រើន ចំពោះការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើ ណុប ងឹម (ដែលដកចម្លើយពីមុនរបស់គាត់ អំពីការប្រជុំប្រចាំខែជាមួយ យឹម ទិត្យ)[860]។ អង្គបុរេជំនុំជម្រះសម្រេចថា ទឡ្ហីករណ៍របស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើ "សាក្សីតែម្នាក់" គឺ ណុប ងឹម ដើម្បីគាំទ្រដល់ការប្រជុំ និងសកម្មភាពពាក់ព័ន្ធនានាគ្មានមូលដ្ឋានឡើយ ព្រោះមានភស្តុតាងជាច្រើន ដែលលើកឡើងអំពីការប្រជុំរបស់ យឹម ទិត្យ ជាមួយអ្នកក្រោមបង្គាប់ នៅក្នុងតំបន់ ១ និងកម្រិតនៃសិទ្ធិអំណាច និងការគ្រប់គ្រងរបស់គាត់ទៅលើបញ្ហាកសិកម្ម និងសន្តិសុខ និងផែនការបោសសម្អាត និងកំណត់គោលដៅទៅលើខ្មាំង[861]។ លើសពីនេះទៀត អង្គជំនុំជម្រះបដិសេធចំពោះទស្សនៈដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយ "មិនបានញែកឱ្យដាច់រវាង តួនាទី និងសកម្មភាព" របស់ យឹម

---

[859] លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកស្រង់ (ឯកសារ D1.3.20.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ១៩៧៦ ERN 00184041 មាត្រា ១២(៣) បានចែងអំពីការយល់ដឹងជាមូលដ្ឋាន អំពីសិទ្ធិអំណាចតាមនីតិន័យ ដែល យឹម ទិត្យ អាចប្រើប្រាស់ក្នុងនាមជាលេខាតំបន់)។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D427/1/30) កថាខណ្ឌ ៤៥៩ (សម្រេចផងដែរថា "លើសពីនេះទៀត ទិដ្ឋភាពទូទៅ នេះបង្ហាញថា ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានយល់ឃើញថា មិនកំណត់តែចំពោះមេបញ្ជាការយោធាប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានគ្រប់ដណ្តប់ដល់ថ្នាក់លើដែលមិនមែនជាយោធាដែរ។ ហេតុដូច្នេះ យុត្តិសាស្ត្រនេះបង្ហាញថា លក្ខណៈពិតប្រាកដនៃតួនាទី ឬមុខងាររបស់នរណាម្នាក់ ដែលជា ថ្នាក់លើ និងបញ្ហាថាតើតាមផ្លូវច្បាប់ ឬតាមហេតុការណ៍ពិត មិនសូវមានភាពសំខាន់ ស្មើកម្រិតនៃការបញ្ជា ឬការអនុញ្ញាត ដែលបានធ្វើលើអ្នកនៅក្រោមបង្គាប់ឡើយ")។

[860] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨២-១៨៦។

[861] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨២។ សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) ដូចជាកថាខណ្ឌ ៣៦៥ (សម្រេចដោយមានការដកស្រង់យ៉ាងច្រើនថា "យឹម ទិត្យ កោះហៅ និងដឹកនាំការប្រជុំ ជាមួយតំណាងមកពីស្រុក ឃុំ សហករណ៍ ដូចជាកងឈ្លប និងកងចល័ត ដែលក្នុងការប្រជុំនោះ គាត់បានណែនាំដល់អ្នកចូលរួម អំពីបញ្ហាកសិកម្ម និងសន្តិសុខ នៅតាមទីកន្លែងរៀងៗខ្លួន ហើយបានប្រាប់ពួកគេ ឱ្យរាយការណ៍អំពីសកម្មភាពខ្មាំង "រៀនសូត្រ" ឬ "កម្ទេច" (លុបចោលការដកស្រង់)។ សូមមើលផងដែរ មូលដ្ឋាន ៥.៣ (*i*) ខាងលើ។

ទិត្យ និងតាម៉ុក នៅក្នុងកិច្ចប្រជុំទាំងនោះ[862] បើទោះ បីជាភាពខុសគ្នារវាង យឹម ទិត្យ និង តាម៉ុក អាចស្តែងចេញច្បាស់ជាង នៅក្នុងផ្នែកមួយចំនួននៃសំណុំរឿង[863] ក៏អង្គជំនុំជម្រះសង្កេតឃើញថា ណុប ងឹម លើកឡើងពីអាកប្បកិរិយាទៅលើទាំង យឹម ទិត្យ និងតាម៉ុក នៅក្នុងការបរិយាយផ្ទាល់ខ្លួនរបស់គាត់ និងបានរៀបរាប់លម្អិតផងដែរ អំពីសកម្មភាព និងការប្រព្រឹត្តិរបស់ យឹម ទិត្យ ក្នុងករណីដែលអាចធ្វើបាន ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើការពិចារណាដែរ។ ជាឧទាហរណ៍ ណុប ងឹម រៀបរាប់ថា យឹម ទិត្យ និង តាម៉ុក ដឹកនាំកិច្ចប្រជុំ ហើយពួកគាត់ទាំងពីរ "បានណែនាំយើងថា យើងត្រូវកម្ទេចខ្មាំងណាដែលប្រឆាំងនឹងអង្គការ" [864]។ ណុប ងឹម បានបញ្ជាក់ថា យឹម ទិត្យ នៅក្នុងការប្រជុំដែលនោះ បាន "និយាយអំពីស្ថានភាពទូទៅ នៅក្នុងតំបន់ដែលគាត់គ្រប់គ្រង និងអំពីស្ថានភាពនៅក្នុងស្រុកនានា នៅក្នុងតំបន់របស់គាត់។ ហើយគាត់ក៏ផ្តល់ការណែនាំ ដល់អ្នកតំណាងឱ្យស្រុកនានា នៅក្នុងតំបន់របស់គាត់ដែរ"[865]។ ណុប ងឹម លើកឡើងបន្ថែមពាក់ព័ន្ធនឹង យឹម ទិត្យ ថានៅកិច្ចប្រជុំមួយ យឹម ទិត្យ "ជំរុញឱ្យពួកយើងដឹក នាំឱ្យបានរលូន រួបរួមសាមគ្គីគ្នា ហើយខិតខំប្រឹងប្រែងកសាងប្រទេសជាតិ និងការពារប្រទេសជាតិ ដើម្បីឱ្យបានរុងរឿងទៅមុខ"[866]។

---

[862] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨២។

[863] សូមមើល ជាឧទាហរណ៍កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/298 ERN 01095988 (ឆ១៦) ("សៈតើនៅក្នុងអង្គប្រជុំនោះ ធ្លាប់ដែលមានការសន្ទនាគ្នា ឬរបាយការណ៍ ឬក៏ការណែនាំដែលផ្តល់ទៅឱ្យលោកស្រី និងអ្នកចូលរួមប្រជុំដទៃទៀត ពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខ ឬក៏ពាក់ព័ន្ធទៅនឹងរបៀបថា តើត្រូវធ្វើយ៉ាងម៉េចខ្លះចំពោះអ្នកដែលមិនស្មោះត្រង់នឹងអង្គការ ហើយអ្នកដែលជាខ្មាំងនឹងអង្គការ? ឆ១៦៖ ចាស គេបាននិយាយណែនាំឱ្យយើងប្រុងប្រយ័ត្ន ឱ្យមែនទែនអំពីខ្មាំង ដែលអាចនឹងចូលមកនៅលាក់ខ្លួន នៅក្នុងជួររបស់យើង។ ពេលនោះ តាម៉ុក ហើយនិងតាទិត្យ បានប្រាប់យើងថា បើយើងឃើញមានពួកនេះ យើងត្រូវព្រមានប្រាប់គេឱ្យកែប្រែ បើពុំដូច្នេះទេ យើងនឹងចាប់ពួកគេយកទៅសម្លាប់។ នៅក្នុងអង្គប្រជុំគេក៏បាននិយាយផងដែរ អំពីស្ថិតិ និងអត្រាមនុស្សស្លាប់ និងកើត ហើយនិងអំពីលទ្ធផលបង្កបង្កើនផលដែលឃុំនីមួយៗសម្រេចបាន ។ល។ នៅក្នុងអង្គប្រជុំ ជួនកាល តាម៉ុក ជួនកាល តាទិត្យ តែងតែដាក់សំណួរមកពួកយើង ដែលជាតំណាងសង្កាត់ និងស្រុកម្នាក់ៗ ឱ្យរាយការណ៍ថា មានរឿងរ៉ាវអ្វីកើតឡើង នៅក្នុងសង្កាត់ និងស្រុករបស់ខ្លួន")។

[864] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៦ ជើងទំព័រ ៩៧៣ ( ដកស្រង់ កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008706 (ឆ៥៦))។

[865] កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008706 (ឆ៥៥)។

[866] កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ងឹម ទី៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/298 ERN 01095988 (ឆ១៥)។

336. អង្គជំនុំជម្រះយល់ថា ការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើ ណុប ង៉ឹម បើទោះបីជាគាត់ដកចម្លើយមកវិញក្តី ត្រូវបានពិភាក្សា និងផ្តល់សំអាងហេតុគ្រប់គ្រាន់[867]។ អង្គជំនុំជម្រះមិនជឿជាក់ចំពោះទឡ្ហីករណ៍របស់សហមេធាវីដែលថា ណុប ង៉ឹម បន្ទាប់ពីមានលិខិតធានា "មិនចាំបាច់ការពារ" ខ្លួនគាត់នោះទេ[868]។ ទីមួយ ហេតុផលនេះមិនត្រឹមត្រូវ ដោយពិចារណាថា លិខិតធានា ត្រូវបានចេញនៅពេលចាប់ផ្តើម គឺ នៅមុនមានចម្លើយលើកទីមួយ និងលើកទីពីររបស់ ណុប ង៉ឹម[869]។ ទីពីរ អង្គជំនុំជម្រះយល់ថា លិខិតធានាអាចការពារចំពោះលទ្ធភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅ អ.វ.ត.ក សម្រាប់ ណុប ង៉ឹម ប៉ុន្តែ មិនអាចដោះស្រាយរាល់ក្តីបារម្ភទាំងអស់ ដូចជា ផលវិបាកផ្នែកសង្គម នៅក្នុងសហគមន៍ ការភ័យខ្លាចលើសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពរបស់សមាជិកគ្រួសារជាដើម[870]។

---

[867] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៦ (ចៅក្រមអន្តរជាតិសម្រេចថា អ្នកវិនិច្ឆ័យអង្គហេតុប្រកបដោយហេតុផល អាចធ្វើការសន្និដ្ឋានប្រហែលគ្នា នឹងការសម្រេចរបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ផងដែរពាក់ព័ន្ធ ការដកចម្លើយវិញរបស់ ណុប ង៉ឹម (១) ជាចេតនាយ៉ាងច្បាស់របស់សាក្សី ក្នុងការការពារតួនាទីផ្ទាល់ខ្លួនរបស់គាត់ (២) "មិនអាចជឿជាក់បានផ្អែកលើភស្តុតាងលម្អិតរបស់គាត់កន្លងមក និង (៣) សាក្សីផ្សេងមួយរូបទៀត គឺ ប្តីរបស់ ណុប ង៉ឹម បានគាំទ្រ ណុប ង៉ឹម ដោយព័ត៌មាន ផ្ទាល់របស់គាត់ ថា គាត់បាន "រួមដំណើរជាមួយប្រពន្ធគាត់ ទៅចូលរួមការប្រជុំបែបនេះ បានប្រមាណ ៥ ទៅ ៦ ដង"។ ចៅក្រមអន្តរជាតិកត់សម្គាល់បន្ថែមទៀតថា នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានថ្លឹងថ្លែងដោយសមហេតុផលនូវតម្លៃ និងផលប៉ះពាល់នៃលិខិតធានា ដូចជាថាតើលិខិតនេះ "ពុំបានធ្វើឲ្យសាក្សី លែងមានភាពស្ទាក់ស្ទើរ ក្នុងការលើកឡើងអំពីហេតុការណ៍នោះឡើយ" និងថា ការវាយតម្លៃរបស់គាត់ទៅលើភាពអាចជឿជាក់បានរបស់សាក្សី គឺ "ផ្អែកលើខ្លឹមសារនៃសក្ខីកម្ម និងស្របតាមលទ្ធភាព ដែលអាចពាក់ព័ន្ធ នៅក្នុង អំពើឧក្រិដ្ឋដូចបានចោទប្រកាន់ [ដូចដែល ណុប ង៉ឹម អាចមានជាប់ពាក់ព័ន្ធ] បើទោះជាបានផ្តល់លិខិតធានាក៏ដោយ" (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ១៤៨)។

[868] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨៤។

[869] ចៅក្រមអន្តរជាតិកត់សម្គាល់អំពីលំដាប់លំដោយហេតុការណ៍ នៃការស៊ើបអង្កេត ដូចជា (១) នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញលិខិតធានា ជូនទៅ ណុប ង៉ឹម (២) នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ មានការស្តាប់ចម្លើយលើកទីមួយជាមួយ ណុប ង៉ឹម និង (៣) នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ការស្តាប់ចម្លើយលើកទីពីរជាមួយ ណុប ង៉ឹម បានធ្វើឡើង ដែលនៅពេលនោះ គាត់បានដកនូវផ្នែកខ្លះនៃសក្ខីកម្មពីមុនរបស់គាត់។ បើតាមហេតុផលរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ការចេញលិខិតធានា ធ្វើឲ្យចម្លើយលើកទី ១ និងលើកទី ២ របស់គាត់ (ដោយមានការដកចម្លើយ) ប្រហែលជា "អាចជឿជាក់បាន" ដែលធ្វើឲ្យទឡ្ហីករណ៍នោះ ទៅជាលែងពាក់ព័ន្ធ។

[870] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨៤។

337. ចំពោះ ព្រាប កប ដែលជាប្តីពិការភ្នែករបស់ ណុប ងឹម សហមេធាវីបានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយមិនបានពិចារណាទៅលើការពិការភ្នែក នៅពេលវាយតម្លៃលើមុខងាររបស់ ព្រាប កប ថាជានិរសា[871]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការស្ទាបស្ទង់ដោយលម្អិតទៅលើលទ្ធភាពមើលឃើញរបស់ ព្រាប កប រួមជាមួយនឹងពិធីរៀបអាពាហ៍ពិពាហ៍របស់ ព្រាប កប និង ណុប ងឹម (ដែល យឹម ទិត្យ ត្រូវបានអះ អាងថាមានវត្តមាន)[872]។ លើសពីនេះទៀត ព្រាប កប បានបង្ហាញថាតើ គាត់អាចបំពេញការងាររបស់គាត់ ដោយរបៀបណា (ក្នុងការជួយដល់ យឹម ទិត្យ ឬប្រពន្ធរបស់គាត់) ដូចជាថាតើ យឹម ទិត្យ ពេលខ្លះ "បញ្ជូននិរសាមកប្រាប់ខ្ញុំ ទៅទទួលគាត់មកផ្ទះវិញ ហើយជូនកាលគាត់ [យឹម ទិត្យ] ជិះម៉ូតូទៅកន្លែងខ្ញុំស្នាក់នៅ ហើយយើងទៅផ្ទះវិញ" និងពេលខ្លះទៀត ព្រាប កប ធ្វើដំណើរដោយឡាន ដែលជាកម្មសិទ្ធិរបស់សេដ្ឋកិច្ចស្រុក[873]។ ចំពោះភស្តុតាង "ផ្ទុយ" ដែលថា ព្រាប កប "មិនដឹងអ្វីទាំងអស់ដែលពាក់ព័ន្ធ និងការងាររបស់ប្រពន្ធ"[874] អង្គជំនុំជម្រះយល់ឃើញថា នេះជាការបំភ្លៃភស្តុតាង ព្រោះ ព្រាប កប បានរៀបរាប់ថាតើ គាត់ជួយប្រពន្ធរបស់គាត់ តាមរបៀបណា[875] និងបានទទួលស្គាល់ថា គាត់មិនដឹងអ្វី ពាក់ព័ន្ធថាតើ ណុប ងឹម ត្រូវបានបញ្ជូនឲ្យទៅធ្វើជា អនុលេខាស្រុកសំឡូតឡើយ[876]។

---

[871] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨៤។

[872] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៩៨៣ (ជាឧទាហរណ៍ ដោយពិចារណាទៅលើ សមត្ថភាពមើលឃើញ របស់សាក្សីរូបនេះ នៅក្នុងការសម្រេចថា ព្រាប កប "ចាំថា គាត់បានអានលិខិតនេះ ព្រោះគាត់បានយកលិខិតនោះ មកដាក់ក្បែរភ្នែកគាត់ ទោះបីគាត់មើលមិនសូវច្បាស់ក៏ដោយ និងត្រូវពឹងលើប្រពន្ធរបស់គាត់ ក្នុងការធ្វើដំណើរទៅណាមកណាម្តងៗ"។

[873] កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រាប កប ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/62 ERN 01037147 (ឆ៦២)។

[874] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨៤។

[875] កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រាប កប ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/62 ERN 01037147 (ឆ៦៤-ឆ៦៥) ("តែក្រោយពីរៀបការរួច គាត់នាំខ្ញុំទៅក្នុងនាមជាប្តី[...] ខ្ញុំមិនមែនជានិរសារគាត់ទេ ខ្ញុំទៅជាមួយគាត់ ដើម្បីមើលថែគាត់ ពេលគាត់មានជំងឺជាដើម")។

[876] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨៥។ សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រាប កប ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/62 ERN 01037146 (ឆ៦០)។ លើសពីនេះទៀត អង្គជំនុំជម្រះសម្រេចថា មិនមានការជំទាស់ដែលអាចត្រួតពិនិត្យវិញបានណាមួយ ទៅលើ ណុប ងឹម ដែលមិនគាំទ្រដល់តួនាទីរបស់ ព្រាប កប ដែលអមដំណើរគាត់ ឬនៅក្នុងការចោទពីការប្រជុំរវាង ណុប ងឹម និង យឹម ទិត្យ។

338. ការអះអាងរបស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "បង្ហាញដោយមិនត្រឹមត្រូវ" នូវភ័ស្តុតាង នៅពេលយោងទៅ ណុប ង៉ឹម ដែលរំឮកថា "ស្រុកទទួលការណែនាំ សរសេរដោយដៃ យឹម ទិត្យ មកពីតំបន់" ជាពិសេសនៅពេលពិចារណាអំពីការដែលគាត់មិនចេះអក្សរ[877]។ ការអះអាងនេះគ្មានមូលដ្ឋានទេ។ ណុប ង៉ឹម បានពន្យល់ថា "សេចក្តីណែនាំ ឬរបាយការណ៍ដែលស្រុកទទួលបាន ពីថ្នាក់តំបន់នៅពេលនោះ មានឈ្មោះ អ៊ំទិត្យ ដែលសរសេរដោយដៃ"[878] ហើយបន្ទាប់មកគាត់បានបញ្ជាក់ថា គាត់ដឹងថា លិខិតពាក់ព័ន្ធត្រូវបានអនុញ្ញាតដោយជនជាប់ចោទ ព្រោះ "បង ឡេង បានអានឲ្យខ្ញុំស្តាប់"[879]។

339. ជាចុងក្រោយ ផ្ទុយទៅនឹងការអះអាងដោយគ្មានការបញ្ជាក់គាំទ្ររបស់សហមេធាវី និងបានបកស្រាយបំភ្លឺពីខាងលើ[880] ចៅក្រមអន្តរជាតិមិនជឿថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិន

---

[877] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨៦ ដកស្រង់ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦៩។

[878] កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008704 (ឆ៤៤)។

[879] កំណត់ហេតុស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ថ្ងៃទី១២-១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ERN 01008710 (ឆ៨២) ("សះនៅក្នុងកិច្ចសម្ភាសន៍កាលពីម្សិលមិញ នៅសំណួរទី៤៤ និង៤៥ លោកស្រីថា បានទទួលសេចក្តី ណែនាំពីតំបន់ ១ មានឈ្មោះតាទិត្យ បើលោកស្រីមិនចេះអាន និងសរសេរផង ហេតុអ្វីបានជាលោកស្រីដឹង? ឆ៨២៖ ខ្ញុំដឹងថា សេចក្តីណែនាំមកពីតំបន់មានឈ្មោះតាទិត្យ ដោយសារលេខាស្រុកគឺបង ឡេង បានអានឲ្យខ្ញុំស្តាប់")។

[880] សូមមើល មូលដ្ឋាន ៥.១ ខាងលើ។ អង្គជំនុំជម្រះសូមរំឮក អំពីការសម្រេចកន្លងមករបស់ខ្លួន នៅក្នុងសេចក្តីពិចារណាទាំងអស់នេះថា "សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានប្រើប្រាស់ដោយមិនត្រឹមត្រូវនូវទំនាក់ទំនងគ្រួសាររវាង យឹម ទិត្យ និង តាម៉ុក ធ្វើជាមូលដ្ឋាន ឬផ្លូវកាត់ ក្នុងការដាក់បន្ទុកសិទ្ធិអំណាចតាមព្រឹត្តន័យ ឬនីតិន័យឡើយ ប៉ុន្តែដីកាបញ្ជូនរឿងទៅជំនុំជម្រះពឹងផ្អែកទៅលើសាក្សីជាច្រើន [...] ដែលផ្តល់សក្ខីកម្មអំពីតួនាទី និងការទទួលខុសត្រូវរបស់ យឹម ទិត្យ ដោយផ្ទាល់"។ សូមមើលផងដែរ សេចក្តីពិចារណាលើភស្តុតាង ក្នុងមូលដ្ឋាន ៥ ខាងលើ (កថាខណ្ឌ ៧ នៅក្នុងសេចក្តីព្រាងចុងក្រោយ មុនពេលសម្រេច នៃសេចក្តីពិចារណាលើភស្តុតាង ដែលសម្រេចថា ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី មានឥទ្ធិពលទៅលើបទដ្ឋាននៃភស្តុតាង និងថា បទដ្ឋានបង្ហាញភស្តុតាងជាធរមាន នៅក្នុងការចេញដីកាដំណោះស្រាយ "អត្ថិភាពនៃភស្តុតាងគ្រប់គ្រាន់ [...] អំពីបទចោទ"។ សូមមើលផងដែរ មូលដ្ឋាន ៥ ខាងលើ សេចក្តីពិចារណាលើភស្តុតាង ដែលបដិសេធទឡ្ហីករណ៍របស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេត ត្រូវបានតម្រូវឲ្យបង្ហាញហួសពីវិមតិសង្ស័យដែលថា ភស្តុតាងដោយមិនអាចគេចវេសបាន គឺឈានដល់កម្រិតនៃភវនីយភាព ដែលបណ្តាលមកពីការប្រមូលផ្តុំចំណុចនានានៃបទដ្ឋានបង្ហាញភស្តុតាង ដែលនៅជាធរមាន នៅដំណាក់កាល កិច្ចដំណើរការនីតិវិធីជំនុំជម្រះ ឬបណ្តឹងឧទ្ធរណ៍ ដែលអាចអនុវត្តបាននៅដំណាក់កាលបុរេជំនុំជម្រះ។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

គោរពគោលការណ៍ជាសារវ័ន្តនៃវិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ ឬថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុស ឬឈានដល់ "ការសន្និដ្ឋានមិនត្រឹមត្រូវជាក់ស្តែង" ទាំងលើអង្គច្បាប់ ឬអង្គហេតុ ដែលតម្រូវឱ្យមានកិច្ចអន្តរាគមន៍នៅកម្រិតបុរេជំនុំជម្រះឡើយ[881]។

340. ហេតុដូច្នេះ ដោយផ្អែកលើភ័ស្តុតាងទាំងអស់ជារួម និងដោយសារតែសហមេធាវីមិនបានបង្ហាញអំពីកំហុសណាមួយ អង្គជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឡើយ ក្នុងការសន្និដ្ឋានដោយសមហេតុផលថា យឹម ទិត្យ ប្រើប្រាស់សិទ្ធិអំណាច និងការគ្រប់គ្រងតាមព្រឹត្តិន័យ ទៅលើអ្នកក្រោមបង្គាប់ នៅក្នុងតំបន់ ១ នៅពេលវេលាពាក់ព័ន្ធ។ អាស្រ័យហេតុនេះ សម្រេចបដិសេធមូលដ្ឋាន ៥.២ (iii) នេះ។

## មូលដ្ឋានទី ៥.២ (IV) ៖ កំហុសដែលរងការចោទប្រកាន់ក្នុងការសម្រេចថា យឹម ទិត្យ គឺជាលេខាតំបន់ ៣

### ក. សារណា

341. សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ មានតួនាទីជាលេខាតំបន់ ៣ ក្នុងឆមាសទី ២ ក្នុងឆ្នាំ១៩៧៨ ដោយអះអាងថា គ្មានភ័ស្តុតាងណាមួយនៅក្នុងសំណុំរឿងដែលថា យឹម ទិត្យ ត្រូវបានតែងតាំងក្នុងមុខតំណែងនេះឡើយ[882]។ មូល អេង គឺជាសាក្សីតែម្នាក់គត់ដែលបានឮអំពីវត្តមានរបស់ យឹម ទិត្យ នៅក្នុងតំបន់ ៣ ហើយភ័ស្តុតាងដោះបន្ទុករបស់គាត់មិនត្រូវបានគិតគូរ ដោយគ្រាន់តែសន្មតថា យឹម ទិត្យ បានកាន់មុខតំណែងនេះ[883] ដែលធ្វើឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអាចសន្និដ្ឋានថា យឹម ទិត្យ មានសិទ្ធិអំណាច *តាមនីតិន័យ ឬតាមព្រឹត្តិន័យ* នៅក្នុងតំបន់ ៣ ឡើយ[884]។

---

[881] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ១៨៧-១៨៨។

[882] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៨៩, ១៩០។

[883] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៨៩, ១៩៥។

[884] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៨៩។

342. ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ (i) បានដឹកនាំការប្រជុំ និងបានតែងតាំងកម្មាភិបាលក្នុងតំបន់ ៣ ចាប់ពីខែមិថុនា ឆ្នាំ១៩៧៨ (ដោយបានលើកបង្ហាញដោយមិនត្រឹមត្រូវអំពីភ័ស្តុតាងរបស់ អ៊ឹម អាន់ និង កែវ ផៃ)[885] (ii) បានផ្ញើ និងទទួលលិខិតទំនាក់ទំនងជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធនឹងសន្តិសុខ និងសេដ្ឋកិច្ចនៅថ្នាក់ស្រុក (ដោយអះអាងថា គ្មានសាក្សីណាម្នាក់ ដែលត្រូវបានដកស្រង់យកមកគាំទ្រដល់ការសន្និដ្ឋាននេះទេ)[886] និង (iii) បានតែងតាំងមនុស្សឲ្យកាន់មុខតំណែងនានានៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលតំបន់ ៣ (ដោយអះអាងថា គ្មានសាក្សីណាម្នាក់ ដែលត្រូវបានដកស្រង់យកមកគាំទ្រដល់ការសន្និដ្ឋាននេះ និងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្ហាញដោយមិនត្រឹមត្រូវពីភ័ស្តុតាងរបស់ កែវ ផៃ)[887]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកលើភ័ស្តុតាងដែលមិនពាក់ព័ន្ធ និងមិនអាចជឿជាក់បានរបស់សាក្សីប្រាំនាក់ (ដែលមិនបានកំណត់អត្តសញ្ញាណរបស់ យឹម ទិត្យ ដោយត្រឹមត្រូវ មិនមានវត្តមាននៅក្នុងកិច្ចប្រជុំជាមួយ យឹម ទិត្យ ឬបានជួប យឹម ទិត្យ នៅក្នុងតំបន់ ៣ ទេ) ដែលនាំឲ្យមានការសន្និដ្ឋានខុសថា លោក យឹម ទិត្យ "បានដឹកនាំការប្រជុំដែលមានការចូលរួមពីកម្មករ និងកម្មាភិបាលថ្នាក់ស្រុកពីតំបន់ ៣"[888]។ សហមេធាវីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការសន្និដ្ឋានថា យឹម ទិត្យ បានទទួលមុខតំណែងជាលេខាតំបន់ ៣ ដោយមិនបានវាយតម្លៃយ៉ាងត្រឹមត្រូវលើចម្លើយរបស់សាក្សី និងមិនបានផ្តល់សំអាងហេតុសម្រាប់ការពឹងផ្អែករបស់គាត់ទៅលើភ័ស្តុតាងជាក់លាក់ ហេតុដូច្នេះធ្វើឲ្យមានភាពអយុត្តិធម៌ ដែលតម្រូវឲ្យអង្គបុរេជំនុំជម្រះផ្លាស់ប្តូរការសម្រេចទាំងអស់នេះ[889]។

343. ជាការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា មិនមានកំហុសដែលអាចពិនិត្យឡើងវិញបានណាមួយត្រូវបានបង្ហាញ ទាក់ទងនឹងតំណែងរបស់ យឹម ទិត្យ ជាលេខាតំបន់ ៣

---

[885] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩០។

[886] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩០-១៩២, ១៩៥។

[887] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩១, ១៩៣, ១៩៥។

[888] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៤ *ដែលយោងតាម* សាក្សី ណុប ណាន, កែវ ផៃ, ទេព សៀន និង រី ផាន់។

[889] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៧។

ដោយលើកហេតុផលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកលើភស្តុតាងស៊ីសង្វាក់ និងច្បាស់លាស់ពីអ្នកនៅក្រោមបង្គាប់របស់ យឹម ទិត្យ និងមនុស្សដទៃទៀត[890]។ លើសពីនេះទៅទៀត ថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ យោងដល់តួនាទី*តាមផ្លូវច្បាប់ ឬជាក់ស្តែង* មិនជាប់ពាក់ព័ន្ធឡើយ ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា លោក យឹម ទិត្យ បានដឹកនាំកិច្ចប្រជុំ តែងតាំងកម្មាភិបាល ទំនាក់ទំនងជាមួយបណ្តាស្រុក ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ និងសេដ្ឋកិច្ច និងបានមកពិនិត្យមន្ទីរស្រុក[891]។

344. តាមទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សហមេធាវីការពារក្តីបានជំទាស់តាមការជ្រើសរើសរបស់ខ្លួនទៅលើភស្តុតាងដែលសហព្រះរាជអាជ្ញាអន្តរជាតិបានពឹងផ្អែកលើ រួមទាំងភស្តុតាងរបស់ មូល អេង (ដោយបានលុបថា គាត់បានប្រាស្រ័យទាក់ទងជាទៀងទាត់ និងទទួលបញ្ជាពី យឹម ទិត្យ និងថា គាត់បាននិយាយថា យឹម ទិត្យ មានសិទ្ធិអំណាចក្នុងការចាប់ខ្លួន និងដោះស្រាយបញ្ហាសន្តិសុខនៅក្នុងតំបន់ និងដកកម្មាភិបាលភូមិភាគពាយ័ព្យ)[892]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានបញ្ជាក់លើភស្តុតាងរបស់ ទេព សៀន (ដែលបានបញ្ជាក់ថា យឹម ទិត្យ បានតែងតាំងកម្មាភិបាលទៅគណៈភូមិ និងគណៈឃុំ)[893] ជួន ថន (ដែលបានលើកឡើងពីការណែនាំ របស់ យឹម ទិត្យ ទាក់ទងនឹងការ "អប់រំ" និង "កម្ទេច" "ខ្មាំង" ទាំងអស់)[894] និង ឡុច អេង[895] ក្នុងការជំទាស់ទៅនឹងការអះអាងរបស់សហមេធាវីថា គ្មានភស្តុតាងបង្ហាញថា យឹម ទិត្យ ប្រើសិទ្ធិអំណាចជាលេខាតំបន់ ៣[896]។

## ខ. ការពិភាក្សា

[890] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១១២។
[891] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១១៣។
[892] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១១៤-១១៥។
[893] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១១៦។
[894] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១១៧។
[895] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កសារ D382/27 កថាខណ្ឌ ១១៩។
[896] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១១៨។

345. តាំងពីដំបូង ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានធ្វើការសន្និដ្ឋានច្បាស់លាស់ ថាតើ យឹម ទិត្យ កាន់មុខតំណែង*តាមនីតិន័យ* ឬប្រើប្រាស់សិទ្ធិអំណាច*តាមព្រឹត្តិន័យ* នៅក្នុងតំបន់ ៣ នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិមិនជឿតាមការចោទប្រកាន់របស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថាពាក្យ "បានទទួល" មានន័យដូចម្តេច ចំពោះតួនាទី និងការទទួលខុសត្រូវរបស់ យឹម ទិត្យ[897] នៅពេលដែលដីកាដំណោះស្រាយបង្ហាញភស្តុតាងគ្រប់គ្រាន់ដែលថា យឹម ទិត្យ អនុវត្តសិទ្ធិអំណាចរបស់ខ្លួន ដោយផ្តល់ការណែនាំ តែងតាំងកម្មាភិបាល និងដឹកនាំកិច្ចប្រជុំនៅក្នុងតំបន់ ៣[898]។

346. ទាក់ទងនឹងការដេញដោលផ្នែកអង្គហេតុជាក់លាក់ អង្គជំនុំជម្រះមិនជឿតាមការចោទប្រកាន់ របស់សហមេធាវីដែលថា មូល អេង គ្រាន់តែសន្មតថា យឹម ទិត្យ មានមុខតំណែងជាលេខាតំបន់ ៣[899]។ ទោះបី មូល អេង មិនឃើញដោយផ្ទាល់ផ្នែកអំពីការតែងតាំង យឹម ទិត្យ ក៏ដោយ[900] ក៏គាត់បានដឹងអំពីតួនាទីរបស់ យឹម ទិត្យ ក្នុងតួនាទីរបស់គាត់ជាលេខាស្រុកបាវិល[901] និងតាមរយៈទំនាក់ទំនងផ្ទាល់របស់ពួកគេ។ មូល អេង បានជួប យឹម ទិត្យ ក្នុងឱកាសជាច្រើន[902]

[897] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៨៩។

[898] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧២-៣៧៦។

[899] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៨៧។

[900] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095246 (ឆ.៦៨-ឆ.៧៣) ("[យឹម ទិត្យ] ចូលរួមប្រជុំ តែគេមិនទាន់ចាត់តាំងគាត់ជាអ្វីទេ"), 01095252 (ស-ឆ.១១២)។

[901] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095241-01095242 (ឆ.៤២-ឆ.៤៣) ("យឹម ទិត្យ គ្រប់គ្រងតំបន់ ៣ [...]។ ស៖ តើលោកដឹងថា យឹម ទិត្យ ហ្នឹងគាត់ជាគណៈតំបន់ ៣ ហ្នឹង ដោយសារតែតំណែងរបស់លោកជាគណៈស្រុកឬ? ឆ.៤៣៖ បាទ")។

[902] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095241 (ឆ.៤១) (" ឆ.៤១៖ [...] ហើយលើកទីពីរជាមួយគណៈតំបន់ ៣ ដែលជា តាទិត [...]។ ពីមុន ខ្ញុំនៅតំបន់ ៥។ ក្រោយមកនៅតំបន់ ៣ ព្រោះមួយផ្នែកនៃតំបន់ ៥ ត្រូវបានកាត់ទៅឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់តាទិត។ [...] គេកាត់បាវិលឲ្យមកក្រោមការត្រួតត្រារបស់ តាទិត"), ERN 01095243 (ឆ.៥៣-៥៥) (" ខ្ញុំជួប យឹម ទិត បានពីរដង។ [...] ជួបទី១ គឺពេលដែលគេកាត់ស្រុកបាវិលឲ្យស្ថិតនៅក្រោមតំបន់ ៣ ហើយជួបលើកទី២ គឺគាត់មកជួបខ្ញុំដល់កន្លែងខ្ញុំតែម្តង ដែលនៅមន្ទីរស្រុកបាវិល"), ERN 01095246 (ឆ.៧៣), ERN 01095250-01095251 (ឆ.៩៩-ឆ.១០១)។

និងផ្តល់ភ័ស្តុតាងលម្អិត និងគួរឲ្យទុកចិត្តនៃដំណើរទស្សនកិច្ចរបស់ យឹម ទិត្យ មកកាន់មន្ទីរស្រុកបាវិល ដែលគាត់បានចុះត្រួតពិនិត្យមើលវាលស្រែ និងដំណាំផ្សេងទៀត និងបានផ្តល់ការណែនាំឲ្យការពារកុំឲ្យមានខ្មាំង[903]។ បន្ទាប់ពីស្រុកបាវិលត្រូវបានកាត់ឲ្យតំបន់ ៣ មូល អេង បានរាយការណ៍ជូន យឹម ទិត្យ[904]និងបានទំនាក់ទំនងជាមួយគាត់តាមរយៈនិរសាររបស់គាត់ប្រចាំសប្តាហ៍ ឬប្រចាំខែអំពីបញ្ហាផលិតកម្ម និងទិន្នផលស្រូវ ឬដំណាំផ្សេងទៀត[905]។ គាត់បានទទួលបញ្ជាពី យឹម ទិត្យ[906] និងបានបញ្ជាក់ថា យឹម ទិត្យ មានសិទ្ធិអំណាចក្នុងការចាប់ខ្លួន និងដោះស្រាយបញ្ហាសន្តិសុខ[907]។ មូល អេង បានជួប យឹម ទិត្យលើកចុងក្រោយនៅក្នុងខែវិច្ឆិកា ឬដើមខែធ្នូ ឆ្នាំ១៩៧៨ នៅពេលពួកគេពិភាក្សាអំពីការវិវត្តនៃស្ថានការណ៍នៅភាគខាងកើតនៃប្រទេស[908]។

347. ទោះបីជា មូល អេង បង្ហាញពីភាពមិនប្រាកដប្រជាខ្លះ ចំពោះថាតើ យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់ ៣ ឬ តំបន់ ២ ក៏ដោយ[909] ក៏គាត់នៅចាំយ៉ាងច្បាស់ថា ស្រុកបាវិលត្រូវបាន

---

[903] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095247 (ឆ.៧៦, ឆ.៧៩-ឆ.៨១)។

[904] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095250 (ឆ.៩៧) ("ក្រោយមក គេកាត់ស្រុកបាវិលឲ្យស្ថិតក្រោមតំបន់ ៣ ដូច្នេះ ខ្ញុំត្រូវរាយការណ៍ឲ្យ តាទិត ព្រោះគាត់ជាគណៈតំបន់ ៣")។

[905] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095250 (ឆ.៩៨), ERN 01095260 (ឆ.១៦១-ឆ.១៦៣), ERN 01095261 (ឆ.១៦៨-ឆ.១៧១)។

[906] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095262 (ឆ.១៧៤-ឆ.១៨១)។

[907] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095263-01095264 (ឆ.១៨៩-ឆ.១៩៤)។

[908] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095250-01095251 (ឆ.៩៩-ឆ.១០១)។

[909] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095252 (ឆ.១១០) ("បន្ទាប់ពីដេកគិតឡើងវិញទៅ ខ្ញុំមិនច្បាស់ថា តា ទិត ត្រូវបានគេតែងតាំងឲ្យគ្រប់គ្រងតំបន់ ៣ ឬតំបន់ ២ ទេ"), ERN 01095260 (ឆ.១៥៨)។ *សូមមើលផងដែរ* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៨៩។

កាត់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ[910]។ ភ័ស្តុតាងបន្ថែមនៅក្នុងដីកាដំណោះស្រាយបញ្ជាក់ថាស្រុកបារិល គឺជាផ្នែកមួយនៃតំបន់ ៣ មិនមែនតំបន់ ២ នោះទេ[911]។ ដូច្នេះ ចៅក្រមអន្តរជាតិមិនបានរកឃើញកំហុសណាមួយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកលើភ័ស្តុតាងរបស់ មួល អេង ក្នុងការសម្រេចថា យឹម ទិត្យ គឺជាលេខាតំបន់ ៣ នោះឡើយ។

348. ពាក់ព័ន្ធនឹងការសម្រេចថា យឹម ទិត្យ បានដឹកនាំកិច្ចប្រជុំ ដែល តា ឆេង បានចូលរួម និងបានតែងតាំងកម្មាភិបាលក្នុងតំបន់ ៣ ចាប់ពីដើមខែមិថុនា ឆ្នាំ១៩៧៨ ចៅក្រមអន្តរជាតិមិនជឿថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកបង្ហាញដោយមិនត្រឹមត្រូវនូវភ័ស្តុតាងរបស់ អ៊ឹម អាន់ និង កែវ ផៃ ដូចដែលបានជំទាស់ឡើយ[912]។ ទោះបីភ័ស្តុតាងរបស់ពួកគេផ្តល់ការគាំទ្រតែផ្នែកខ្លះដល់ការសម្រេចនេះក៏ដោយ[913] ជាពិសេសថា តា ឆេង គឺជាគណៈស្រុកភ្នំសំពៅ (ស្ថិតនៅក្នុងតំបន់ ៣)[914] ក៏ចៅក្រមអន្តរជាតិសង្កេតឃើញថា ភ័ស្តុតាងដែលត្រូវបានដកស្រង់នៅក្នុងកថាខណ្ឌបន្ទាប់គាំទ្រថា យឹម ទិត្យ បានដឹកនាំការប្រជុំ និងចាត់តាំងកម្មាភិបាលនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលតំបន់ ៣ ចាប់ពីដើមខែមិថុនា ឆ្នាំ១៩៧៨[915]។

---

[910] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មួល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095252 (ឆ.១១០) ("តែខ្ញុំចាំច្បាស់ថា ស្រុកបារិលត្រូវបានកាត់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ យឹម ទិត"), ERN 01095259-01095260 (ឆ.១៥៧-ឆ.១៥៨) ("ស្រុកដែលខ្ញុំកាន់កាប់ បានកាត់ឱ្យស្ថិតក្រោមការត្រួតត្រារបស់ តា ទិត ព្រោះខ្ញុំមិនបានចូលរួមប្រជុំជាមួយ តា ចាយ ទៀត ទេ")។

[911] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១៦៤ ជើងទំព័រ ៣៥៨។

[912] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩០ *ដែលយោងតាម* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧២ ជើងទំព័រ ៩៩០។

[913] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧២ ជើងទំព័រ ៩៩០។

[914] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧២ ជើងទំព័រ ៩៩០ *ដែលយោងតាម* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D118/66 ERN 00920193 (ស-ឆ.១៣) ("[តា ឆាំ] នៅធ្វើជាគណៈតំបន់រហូតដល់ចុងឆ្នាំ១៩៧៧ ទើបពួកប៉ុល ពត សម្លាប់គាត់។ អាត្មាមិនដឹងថា អ្នកណាឡើងជាគណៈតំបន់ទេ ហើយអ្នកដែលឡើងធ្វើជាគណៈស្រុកកាលណោះឈ្មោះ ឆេង [...]")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ ផៃ [កែវ ភា] ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D118/94 ERN 00947270 (ឆ.១១) ("គណៈស្រុកភ្នំសំពៅមានឈ្មោះ តា ឆេង ជាប្រធាន [...]")។

[915] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧៤ (ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថា "ក្នុងនាមជាលេខាតំបន់ ៣ យឹម ទិត្យ បានតែងតាំងមនុស្សឱ្យកាន់មុខតំណែងនានានៅក្នុងរចនាសម្ព័ន្ធតំបន់ ៣" និង "បានដឹកនាំ

349. ស្រដៀងគ្នានេះដែរ ការសម្រេចថា យឹម ទិត្យ "បានផ្ញើ និងទទួលលិខិតទំនាក់ទំនងជាលាយលក្ខណ៍អក្សរ ទៅថ្នាក់ស្រុកស្តីពីបញ្ហានានា ដែលពាក់ព័ន្ធនឹងសន្តិសុខ និងសេដ្ឋកិច្ច"[916] ត្រូវបានគាំទ្រដោយផ្នែកខ្លះ តាមរយៈការដកស្រង់ជាក់លាក់ដោយភស្តុតាងរបស់ មួល អេង[917]។ ក៏ប៉ុន្តែ ការសម្រេចថា យឹម ទិត្យ "បានទាក់ទងទៅថ្នាក់ស្រុក *តាមរយៈ* លិខិតទំនាក់ទំនងជាលាយលក្ខណ៍អក្សរ" ត្រូវបានធ្វើម្តងទៀតនៅក្នុងកថាខណ្ឌបន្ទាប់ និងបានគាំទ្រដោយភស្តុតាងបន្ថែមនៅក្នុងកថាខណ្ឌនោះ[918]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ទោះបីការរៀបចំភស្តុតាងគាំទ្រនៅក្នុងផ្នែកនេះនៃដីកាដំណោះស្រាយ ខ្វះភាពត្រឹមត្រូវក៏ដោយ ក៏ការសម្រេចទាំងនេះត្រូវបានគាំទ្រដោយភស្តុតាងរបស់សាក្សីដែលបានដកស្រង់នៅពាសពេញដីកានេះ។

350. ពាក់ព័ន្ធនឹងការអះអាងរបស់សហមេធាវីដែលថា មិនមាននរណាម្នាក់ក្នុងចំណោមសាក្សីទាំងប្រាំមួយនាក់ដែលបានដកស្រង់ បញ្ជាក់ថា "យឹម ទិត្យ បានតែងតាំងមនុស្សឲ្យកាន់តំណែងនៅក្នុង

---

ការប្រជុំដែលមានការចូលរួមពីកម្មករ និងកម្មាភិបាលថ្នាក់ស្រុកពីតំបន់ ៣ រួមទាំងការប្រជុំនៅវត្តភ្នំសំពៅ"។ ការសម្រេចទាំងនេះ ត្រូវបានគាំទ្រដោយសាក្សីមួយចំនួនទៀត ក្រៅពី អ៊ុម អាន់ និង កែវ ផៃ ដូចជា ទេព សៀន និងជួន ថន។ ចៅក្រមអន្តរជាតិដោះស្រាយនូវការជំទាស់ជាក់លាក់ចំពោះសាក្សីទាំងនេះដូចខាងក្រោម)។

[916] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩១-១៩២ *ដែលយោងតាម* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧៤ និង ជើងទំព័រ ៩៩៧។

[917] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧៤ និងជើងទំព័រ ៩៩៧ *ដែលយោងតាម* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មួល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095262 (ស-ឆ.១៧៣-១៧៥) ("[យឹម ទិត្យ] បញ្ជាក់តាមក្រដាសមកថា ឲ្យធ្វើស្រូវ ៣ តោនអីជាដើម [ក្នុង១ហិកតា]។") ERN 01095263-01095264 (ឆ.១៨៣, ឆ.១៩០-១៩៤) ("ទៅសុំជំនួយពីកងទ័ពតំបន់តែម្តង។ [...] បើមានបញ្ហានៅក្នុងស្រុករបស់ខ្ញុំ ខ្ញុំនឹងទៅរកជំនួយពីទ័ពតំបន់។ [...] [លេខាតំបន់] មានសិទ្ធិលើយោធាតំបន់")។

[918] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧៦ *យោងទៅ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មួល អេង [មួល អេង] ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/294 ERN 01095260 (ស-ឆ.១៦១-១៦៤) ("តើក្នុងរបាយការណ៍របស់លោក មាននិយាយអំពីការដ្ឋាន ឬក៏ស្ថានភាពសមរភូមិពីតំបន់របស់លោកទៅថ្នាក់តំបន់ទេ? ឆ.១៦១៖ បាទ ខ្ញុំត្រូវតែរាយការណ៍ពីការដ្ឋានទាំងអស់ រួមមានទាំងការបង្កបង្កើនផល រួមទាំងស្ថានភាពសាងសង់នៅតាមការដ្ឋាននានា និងស្ថានភាពតាមសហករណ៍ទៅថ្នាក់តំបន់។ ស៖ តើលោកធ្វើរបាយការណ៍ទៅលើនោះ ដោយផ្អែកលើរបាយការណ៍ពីឃុំ និងសហករណ៍មែនឬទេ? ឆ.១៦២៖ បាទមែន ជាពិសេសគឺរបាយការណ៍ពីមេឃុំមកតែម្តង។ [...] ឆ.១៦៣៖ មានស្មៀនមួយជាអ្នកធ្វើ។ [...] ឆ.១៦៤៖ គាត់ឈ្មោះ គ្រេន")។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

វចនាសម្ព័ន្ធរដ្ឋបាលនៃតំបន់ ៣ ឡើយ"[919] ចៅក្រមអន្តរជាតិសង្កេតឃើញថា ទេព សៀន បានចងចាំពីការចូលរួមការប្រជុំ ដែល យឹម ទិត្យ បានប្រកាសថា គាត់ជាអ្នកគ្រប់គ្រងតំបន់នេះ និងបានតែងតាំងមនុស្សឱ្យទទួលខុសត្រូវក្នុងគណៈភូមិ និងឃុំ[920]។ ទោះបី ទេព សៀន មិនអាចចាំបានថាតើឃុំវត្តគរស្ថិតនៅក្នុងតំបន់ ១, តំបន់ ៣ ឬ តំបន់ ៤ នោះក៏ដោយ[921] ក៏គាត់អះអាងថា វត្តគរ ស្ថិតនៅក្រោមគណៈស្រុកឈ្មោះ តា ឆេង ដែលទទួលខុសត្រូវលើស្រុកភ្នំសំពៅក្នុងតំបន់ ៣ (ដូចដែលត្រូវបានគាំទ្រដោយ អ៊ុម អាន់ និង កែវ ផៃ)[922]។

351. ទាក់ទងនឹងការលើកឡើងថាគ្មានភ័ស្តុតាងណាមួយនៅក្នុងចម្លើយរបស់ កែវ ផៃ ដែលថា យឹម ទិត្យ បានតែងតាំងគាត់ដោយផ្ទាល់ទៅកាន់តំណែងណាមួយ[923] អង្គជំនុំជម្រះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គ្រាន់តែពឹងផ្អែកលើភ័ស្តុតាងរបស់ កែវ ផៃ សម្រាប់ខ្លឹមសារនៃអង្គប្រជុំនៅភ្នំសំពៅ មិនមែនសម្រាប់ការតែងតាំងរបស់គាត់ទៅមុខតំណែងណាមួយឡើយ[924]។

---

[919] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៣, ១៩៥។

[920] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សៀន ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ឯកសារ D118/87 ERN 00945429-00945430 (ឆ.១៥, ឆ.២០-ឆ.២៦, ឆ.២៨) ("តា ឆេង [...] ជាលេខាស្រុក [នៅក្នុងវត្តគរ] [...] សៈ ពេលនៅវត្តគរ តើលោកដឹងថា នរណាជាគណៈតំបន់? ឆ.២០៖ តា ទិត [...] មកធ្វើជាគណៈតំបន់ [...] ឆ.២២៖ ពេលខ្ញុំមកដល់ទីនេះ គេហៅប្រជុំ ហើយគេប្រកាសថា នរណាកាន់នៅខាងតំបន់ នរណានៅកាន់ខាងស្រុក។ [...] ពេលប្រជុំលើកដំបូង តា ទិត ក៏បានចូលរួមប្រជុំជាមួយគ្នាដែរ។ [...] គាត់និយាយថា គាត់កាន់ខាងតំបន់។ [...] ក្នុងអង្គប្រជុំ គាត់បានធ្វើការចាត់តាំងអ្នកណាត្រូវទៅកាន់ភូមិឃុំណា ហើយនិងនិយាយពីការធ្វើស្រែនៅតាមភូមិឃុំរៀងៗខ្លួន")។

[921] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សៀន ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ឯកសារ D118/87 ERN 00945428 (ឆ.៧)។

[922] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សៀន ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ឯកសារ D118/87 ERN 00945429 (ឆ.១៥, ឆ.២០-ឆ.២២)។

[923] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៣ *ដែលយោងតាម* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧៥។

[924] ដីកាដំណោះស្រាយ ឯកសារ D382 ជើងទំព័រ ៩៩៧ *ដែលយោងតាម* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ ផៃ [កែវ ភា] ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ឯកសារ D219/817 ERN 01323269 (ឆ.៣៥) ("គេអត់មាននិយាយអំពីខ្មាំងអីចេះអីចុះទេ គិតតែពីរឿងបង្កបង្កើនផលយ៉ាងណាឱ្យបាន ១ ហិកតា ៣ តោន ទៅ ៥ តោន និងនិយាយពីរឿងវៀតណាមចូល។ បើគេនិយាយអីទៀត ក៏គេអត់និយាយប្រាប់ដែរ ព្រោះគេសម្លាប់ពូខ្ញុំ និងក្មួយខ្ញុំ។ គេមិនសួរឱ្យចូលជិតទេ។")

*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*

352. លើសពីនេះទៀត ចៅក្រមអន្តរជាតិមិនជឿលើការអះអាងរបស់សហមេធាវី ដែលថា សាក្សី ៥ នាក់ ក្នុងចំណោមសាក្សី ៦ នាក់ ដែលត្រូវបានដកស្រង់ ដើម្បីគាំទ្រដល់ការសម្រេចថា យឹម ទិត្យ បានដឹកនាំការប្រជុំ ដែលកម្មករ និងកម្មាភិបាលថ្នាក់ស្រុកមកពីតំបន់ ៣ បានចូលរួម មិនពាក់ព័ន្ធ ឬមិនគួរឲ្យទុកចិត្តនោះទេ[925]។ ទីមួយ ការចោទប្រកាន់ដែលថា ទេព សៀន និង ជួន ថន"មិនបានកំណត់អត្តសញ្ញាណ យឹម ទិត្យ ដោយត្រឹមត្រូវ" មិនអាចជឿជាក់បានឡើយ[926]។ ទេព សៀនបានចូលរួមក្នុងការប្រជុំមួយ ដែល យឹម ទិត្យ បានណែនាំខ្លួនគាត់ និងបានប្រកាសថា គាត់ជាអ្នកគ្រប់គ្រងតំបន់នេះ។ អ្នកចូលរួមមកពីភូមិ និងឃុំផ្សេងៗគ្នាបានចូលរួម[927]។ ការពិតដែលថា ទេពសៀន មិនបានស្គាល់ យឹម ទិត្យ មុនពេលគាត់មកដល់ភូមិភាគពាយ័ព្យ និងបានជួបគាត់តែម្តងគត់[928] មិនធ្វើឲ្យប៉ះពាល់ដល់ភាពអាចទុកចិត្តបាននៃចម្លើយរបស់គាត់ស្តីពីខ្លឹមសារនៃអង្គប្រជុំ ឬសមត្ថភាពរបស់គាត់ក្នុងការកំណត់អត្តសញ្ញាណរបស់ យឹម ទិត្យ បន្ទាប់ពី គាត់ត្រូវបានណែនាំឲ្យស្គាល់នោះឡើយ។

353. ស្រដៀងគ្នានេះដែរ ជួន ថន បានពន្យល់ថា សមាជិកគណៈតំបន់ ដែលរួមមាន យឹម ទិត្យ ត្រូវបានណែនាំឲ្យស្គាល់នៅក្នុងកិច្ចប្រជុំ ហើយគាត់ក៏បានពិពណ៌នាអំពីរូបរាងរបស់ យឹម ទិត្យ ផងដែរ[929]។ ទោះបីជា ជួន ថន គ្រប់គ្រងកងចល័តនៅក្នុងតំបន់ ១ ក៏ដោយ[930] ក៏គាត់បានចងចាំពីការចូលរួមក្នុងការប្រជុំនៅវត្តភ្នំសំពៅ (តំបន់ ៣) ជាមួយនឹងប្រធានកង សហករណ៍ ឃុំ និងស្រុក

---

[925] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៥។

[926] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៥។

[927] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សៀន ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣ ឯកសារ D118/87 ERN 00945429-00945430 (ឆ.២២-ឆ.២៦) ("ស៖ តើតាទិត គាត់មានបានឧទ្ទេសនាមខ្លួនគាត់ ដែរឬទេ? ឆ.២៦៖ គាត់ថា គាត់កាន់នៅខាងតំបន់")។

[928] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៥។

[929] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990643-00990646 (ឆ.៥, ឆ.១៨-ឆ.១៩)។

[930] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990642-00990643 (ឆ.៤)។

01677271



ផ្សេងៗទៀត[931]។ នៅក្នុងកិច្ចប្រជុំនេះ ជួន ថន បានជួប យឹម ទិត្យ[932] បានពិភាក្សាលើប្រធានបទផ្សេងៗគ្នា ដូចជាសកម្មភាពរបស់ខ្មាំង[933]។ ទោះបីជា ជួន ថន បានលើកសំដៅដល់ យឹម ទិត្យ ថាជា "ប្រធានគណៈតំបន់ ១" ក៏ដោយ[934] ក៏ការពិតដែលថា យឹម ទិត្យ បានដឹកនាំការប្រជុំនេះនៅក្នុងតំបន់ ៣ និងអ្នកតំណាងមកពីតំបន់ ១ និងតំបន់ ៣ បានចូលរួម[935] បញ្ជាក់ពីការសម្រេចថា យឹម ទិត្យ មានតំណែង [ក្នុងតំបន់ ៣] [...] ក្នុងខណៈពេលដែលកំពុងបំពេញមុខងារជាលេខាតំបន់ ១"[936]។ លើសពីនេះទៀត ទោះបី កែវ ផៃ មិនបានលើកពី យឹម ទិត្យ ទាក់ទងនឹងការប្រជុំណាមួយក៏ដោយ ក៏ភស្តុតាងរបស់គាត់ស៊ីសង្វាក់គ្នានឹងតំណែងរបស់ តា ឆេង និងជាទូទៅជាងនេះទៀតនោះ គឺការប្រជុំនានាត្រូវបានធ្វើឡើងនៅភ្នំសំពៅ[937]។

354. លើសពីនេះទៀត ទោះបីភស្តុតាងរបស់ វី ផាន់ មានការពាក់ព័ន្ធនឹងកិច្ចប្រជុំមួយនៅទំនប់កង្ហតក្នុងតំបន់ ១ ក៏ដោយ[938] ក៏វត្តមានរបស់ តា ឆេង និងសេចក្តីថ្លែងការណ៍របស់គាត់ស្តីពីការ

---

[931] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990642-00990645 (ឆ.១៦)។

[932] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990642-00990643 (ឆ.៤) ("ខ្ញុំត្រូវបានគេហៅឱ្យមកប្រជុំនៅភ្នំសំពៅ។ នៅពេលនោះ គឺជាពេលដែលខ្ញុំបានជួបប្រធានគណៈតំបន់១ ឈ្មោះ តា ទិត")។

[933] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990642-00990645 (ឆ.១៦-ឆ.១៧)។

[934] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ឯកសារ D118/245 ERN 00990642-00990643 (ឆ.៤)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D118/299 ERN 01023877 (ឆ.២៤)។

[935] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D118/299 ERN 01023876 (ឆ.២២) ("តាមខ្ញុំដឹង គឺពួកគេមកពីកង សហករណ៍ ឃុំ និងស្រុក នៅក្នុងតំបន់ ១ និង តំបន់ ៣។ កិច្ចប្រជុំនោះ គឺចូលរួមដោយថ្នាក់កង ភូមិ ឃុំ និងស្រុក។ កិច្ចប្រជុំនោះ គេហៅថា កិច្ចប្រជុំរួម")។

[936] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧២។

[937] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ ផៃ [កែវ ភា] ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ឯកសារ D219/817 ERN 01323269 (ឆ.៣៣-ឆ.៣៥)។

[938] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៤។

ប្រព្រឹត្តិខុសសីលធម៌នៅឃុំវត្តគរ (តំបន់ ៣)[939] គាំទ្រថា កម្មាភិបាលតំបន់ ៣ ក៏មានវត្តមាននៅក្នុងកិច្ចប្រជុំក្នុងតំបន់ ១ ដែរ។ ចុងបញ្ចប់ អង្គជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសក្នុងការពឹងផ្អែកលើភស្តុតាងរបស់ ណុប ណាន ដែលបានស្តាប់ឮថា កិច្ចប្រជុំដែលគាត់បានចូលរួម នៅពេលគាត់មកដល់បាត់ដំបង ត្រូវបានរៀបចំឡើងតាមបញ្ជារបស់តាម៉ុក និង យឹម ទិត្យ[940]។

355. ដោយពិចារណាលើចំណុចផ្សេងៗខាងលើ ចៅក្រមអន្តរជាតិមិនជឿថា "សាក្សីតែមួយរូបដែលពាក់ព័ន្ធជាមួយហេតុការណ៍នៅតំបន់ ៣ គឺ មានតែ មូល អេង"[941]នោះទេ ឬថា ភស្តុតាងរបស់ មូល អេងដែលត្រូវបានសន្មតជាភស្តុតាងដោះបន្ទុក មិនត្រូវបានយកមកពិចារណានោះឡើយ[942]។ ចៅក្រមអន្តរជាតិយល់ឃើញថា សហមេធាវីខកខានមិនបានបង្ហាញពីកំហុសអង្គហេតុណាមួយនៅក្នុងការសម្រេច ដែលគាំទ្រដល់តំណែងរបស់ យឹម ទិត្យ ជាលេខាតំបន់ ៣ និងលើសពីនេះទៀត ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញពីអត្ថិភាពនៃភស្តុតាងបន្ថែមនៅក្នុងសំណុំរឿងនេះ[943]។ ដោយសន្និដ្ឋានថា យឹម ទិត្យ មានតួនាទីជាលេខាតំបន់ ៣ ចាប់ពីខែមិថុនា ឆ្នាំ១៩៧៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកលើសាក្សី ដូចបានពិភាក្សាក្នុងផ្នែកខាងលើ ដែលបាន

---

[939] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/85 ERN 01040093-01040095 (ឆ.៤, ឆ.៧) ("អ្នកដែលនិយាយនៅក្នុងអង្គប្រជុំនោះ គឺមាន តាទិត្យ តាប៉ែត ហើយនិងតាឆេង។ ពេលនោះ ឆេង បានរាយការណ៍ពីសកម្មភាពនានា ដែលកើតឡើងនៅក្នុងឃុំទាំង៧ ដែលគាត់គ្រប់គ្រង។ [...] ឆេង កាលពីពេលនោះ បាននិយាយអំពីរឿងខុសសីលធម៌ ផិតក្បត់គ្នា ដែលកើតមានឡើងនៅក្នុងឃុំពីរ គឺឃុំវត្តគរ [...]។ ពេលដែល ឆេង កំពុងនិយាយរៀបរាប់របាយការណ៍នេះ តាទិត្យ ហើយនិងតាប៉ែត គាត់អង្គុយចាំស្តាប់ និងកត់ត្រា")។

[940] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ណាន ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣ ឯកសារ D118/92 ERN 00947253-00947254 (ឆ.១១-ឆ.១២)។

[941] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៥។

[942] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៥។

[943] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១១៩ *ដែលយោងតាម* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D219/627 ERN 01184313-01184314 (ឆ.១២-ឆ.១៣) ("[តា ទិត្យ] ជាគណៈតំបន់បឹងព្រៃ និងភ្នំសំពៅ។ [...] ពេលដែលគាត់មកដល់ភ្នំសំពៅ គេដាក់ឱ្យទទួលខុសត្រូវតំបន់"), ERN 01184316 (ឆ.៣០) ("គាត់ទទួលខុសត្រូវរួមជាច្រើនកន្លែង មិនមែនមានតែការដ្ឋានណាមួយដែលគាត់ទទួលខុសត្រូវទេ")។

ផ្តល់សក្ខីកម្មដែលអាចជឿទុកចិត្តបានចំពោះតួនាទី និងការទទួលខុសត្រូវរបស់ យឹម ទិត្យ ដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន។ ដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានខកខានក្នុងការវាយតម្លៃលើចម្លើយរបស់សាក្សីឲ្យបានត្រឹមត្រូវ ឬផ្តល់សំអាងហេតុ ដូចការចោទប្រកាន់នោះទេ។ ដូច្នេះ មូលដ្ឋានទី ៥.២ (iv) ត្រូវបានបដិសេធចោល។

## មូលដ្ឋានទី ៥.២ (v) ÷ កំហុសដែលទាក់ទងនឹងការចោទប្រកាន់ក្នុងការសម្រេចថា យឹម ទិត្យ គឺជាលេខាតំបន់ ៤

ក.សារណា

356. សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ តាមរយៈការសម្រេចថា យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់ ៤ នៅពាក់កណ្តាលឆ្នាំ១៩៧៨[944]។ ដោយពឹងផ្អែកទាំងស្រុងទៅលើ ឡុច អេង ក្នុងការសម្រេចនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើការសម្រេចរបស់ខ្លួន និងភ័ស្តុតាងផ្ទុយគ្នា និងភ័ស្តុតាងដោះបន្ទុករបស់ ទុំ សឿន ឡើយ[945]។ ឧទាហរណ៍ ការអះអាងរបស់ ឡុច អេង ដែលថា យឹម ទិត្យ ជំនួសតំណែង តារិន ផ្ទុយស្រឡះពីភ័ស្តុតាងរបស់ ទុំ សឿន ដែលបញ្ជាក់ថា តារិន គឺជាលេខាតំបន់ ៥ រហូតដល់ពេលបញ្ចប់នៃរបបនេះ។ នៅពេលបន្ទាប់មក ឡុច អេង បានផ្លាស់ប្តូរភ័ស្តុតាងរបស់គាត់ ហើយបញ្ជាក់ថា គាត់មិនបានដឹងច្បាស់អំពីតួនាទីរបស់ យឹម ទិត្យ ទេ និងគ្រាន់តែបានចូលរួមក្នុងកិច្ចប្រជុំមួយជាមួយ យឹម ទិត្យ ប៉ុណ្ណោះ[946]។ ក្រៅពីនេះ សហមេធាវី លើកឡើង គ្មានភ័ស្តុតាងផ្សេងទៀត ដែលបញ្ជាក់ពីវត្តមានរបស់ យឹម ទិត្យ ក្នុងតំបន់ ៤ ឡើយ ហើយ យឹម ទិត្យ ក៏មិនបានប្រើប្រាស់សិទ្ធិអំណាចទៅតាមដែនសមត្ថកិច្ចរបស់គាត់ ឬបានទៅពិនិត្យទីតាំងឧក្រិដ្ឋកម្មក្នុងតំបន់នេះដែរ[947]។

[944] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៨-២០២។

[945] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៨-១៩៩។

[946] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៩។

[947] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៨-២០០។

357. ចុងបញ្ចប់ សហមេធាវីអះអាងថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការវាយតម្លៃយ៉ាងត្រឹមត្រូវលើសក្ខីកម្មរបស់សាក្សី ពិចារណាលើភស្តុតាងផ្ទុយគ្នា និង ភស្តុតាងដោះបន្ទុក អនុវត្ត បទដ្ឋានភវនីយភាព និង *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* (តាមរយៈការមិនផ្តល់សំអាងហេតុថា តើហេតុអ្វីបានជាភស្តុតាងទាំងនោះគួរឱ្យជឿជាក់ខ្លាំងដែលមិនមានអ្នកវិនិច្ឆ័យលើអង្គហេតុដែលមានហេតុផលណាម្នាក់ អាច ឈាន ដល់ការ សន្និដ្ឋានណាផ្សេងបានឡើយ) ដែលធ្វើឱ្យមានភាពអយុត្តិធម៌ និងតម្រូវឱ្យចៅក្រមអន្តរជាតិប្តូរការសម្រេចទាំងអស់នេះ[948]។

358. ជាការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហមេធាវីខកខានមិនបានបង្ហាញកំហុសដែលអាចពិនិត្យឡើងវិញបានក្នុងការសម្រេចថា យឹម ទិត្យ គឺជាលេខាតំបន់ ៤ នៅពាក់កណ្តាលឆ្នាំ១៩៧៨[949]។ ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវីមិនបានកំណត់អត្តសញ្ញាណភស្តុតាងផ្ទុយគ្នា ដោយមិនបានពន្យល់ថាហេតុអ្វីទើបចាំបាច់ត្រូវពិចារណាទៅលើភស្តុតាងរបស់ ឡុច អេង អំពីថាតើនរណាជាលេខាតំបន់ ៤ ដែលចេញទៅ[950]។ ទីពីរ យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ ឡុច អេង បានដឹងពីតួនាទីរបស់ យឹម ទិត្យ ដោយសារ យឹម ទិត្យ ដឹកនាំកិច្ចប្រជុំ ហើយនេះជាអ្វីដែលត្រូវបានគេដឹងឮជាទូទៅក្នុងតំបន់នោះ[951]។ ទីបី ឡុច អេង បានដឹងថា តួនាទីរបស់ យឹម ទិត្យ គ្របដណ្តប់ទៅលើអ្វីខ្លះ និងសិទ្ធិអំណាចអ្វីដែល យឹម ទិត្យ បានប្រើប្រាស់ ឧទាហរណ៍ តាមរយៈការបញ្ជាក់ថា យឹម ទិត្យ គ្រប់គ្រងតំបន់នោះ និងមានអំណាចបញ្ជាឱ្យកងឈ្លបតាមដានកម្មាភិបាល និងប្រជាជនសាមញ្ញ[952]។ ក្រៅពីនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ពីភស្តុតាងបន្ថែមក្នុងសំណុំរឿងនេះ ពាក់ព័ន្ធនឹងសិទ្ធិអំណាចដែល យឹម ទិត្យ ប្រើប្រាស់ក្នុងតំបន់ ៤[953]។

---

[948] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២០១-២០២។

[949] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១២០។

[950] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១២១។

[951] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១២២។

[952] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីការបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១២៣។

[953] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១២៣ *ដែលយោងតាម* សាក្សី ទូច ម៉ារី និង ឡុញ លន់។

## ខ. ការពិភាក្សា

359. ចៅក្រមអន្តរជាតិយល់ថា ក្នុងការសម្រេចថា យឹម ទិត្យ ជាលេខាតំបន់ ៤ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកលើភស្តុតាងរបស់ ឡុច អេង បន្ថែមពីលើភស្តុតាងគាំទ្រដែលបញ្ជាក់ថា តាវង់ ដែលជាអតីតលេខាតំបន់ ៤ ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ប្រហែលជានៅពាក់កណ្តាលឆ្នាំ១៩៧៨[954]។ ដំបូង ចៅក្រមអន្តរជាតិរម្លឹកឡើងវិញថា "ពុំមានលក្ខខណ្ឌតាមផ្លូវច្បាប់ដែលថា ភស្តុតាងរបស់សាក្សីស្តីពីអង្គហេតុជាក់ស្តែងចាំបាច់ ត្រូវតែមានការបញ្ជាក់បន្ថែមដោយភស្តុតាងពីប្រភពផ្សេងទៀតនោះឡើយ" ហើយ "សក្ខីកម្មរបស់សាក្សីម្នាក់ អាចបញ្ជាក់លើអង្គហេតុបាន នៅពេលដែលសក្ខីកម្មនោះមានភាពពាក់ព័ន្ធ និងតម្លៃដែលអាចជឿបាន"[955]។

360. ពាក់ព័ន្ធនឹងការដេញដោលផ្នែកអង្គហេតុ ចៅក្រមអន្តរជាតិមិនទទួលយកការចោទប្រកាន់របស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាលើភស្តុតាងផ្ទុយគ្នា និងភស្តុតាងដោះបន្ទុករបស់ ឡុច អេង ដែលរងការចោទប្រកាន់នោះ[956]។ អង្គជំនុំជម្រះយល់ឃើញថាគ្មាន ភាពផ្ទុយគ្នាសំខាន់នៅក្នុងភស្តុតាងរបស់ ឡុច អេង ឡើយ ព្រោះភស្តុតាងនោះពាក់ព័ន្ធនឹងតួនាទីរបស់ យឹម ទិត្យ ក្នុងនាមជាលេខាតំបន់ ៤ ហើយ ឡុច អេង បានផ្តល់សក្ខីកម្មស៊ីសង្វាក់គ្នាក្នុងការអះអាងថា យឹម ទិត្យ ជាប្រធានគណៈតំបន់នេះនៅឃុំបឹងព្រៃ ដែលស្ថិតក្នុងស្រុកដូនទាវ (តំបន់ ៤)[957]។

---

[954] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧៧។

[955] *សូមមើល* មូលដ្ឋានទី ៥ ៖ ការពិចារណាលើភស្តុតាង*ខាងលើ*។

[956] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៩។

[957] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D118/96 ERN 00947291 (ស.២៩-ឆ.២៩) ("ពេលលោកមកធ្វើការនៅឃុំបឹងព្រៃ តើនរណាជាគណៈតំបន់? ឆ.២៨ ៖ កាលណោះ តាទិត្យ ជាប្រធានតំបន់ ហើយខ្ញុំមិនដឹងថានរណាជាសមាជិក និងជាអនុប្រធានទេ។")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D219/627 ERN 01184313-01184315 (ឆ.១២) ("បាទ គាត់គឺជាគណៈតំបន់នៅបឹងប្រីនិងភ្នំសំពៅ") (ឆ.១៨) ("ខ្ញុំពិបាកនិយាយណាស់ថា យ៉ាងម៉េចឱ្យពិតប្រាកដ ពីព្រោះយើងទើបតែមកដល់ថ្មីៗទាំងអស់គ្នានៅកន្លែងនោះ។ ខ្ញុំគ្រាន់តែដឹងថា ពេលតាទិត្យ មកដល់ គាត់គឺក្លាយជាគណៈតំបន់ ដោយខ្ញុំធ្លាប់ចូលរួមប្រជុំជាមួយគាត់ម្តង") (ឆ.២០) ("គាត់មករៀបបើកប្រជុំនៅនឹងបឹងប្រី ពេលនោះគឺនៅចុងឆ្នាំ៧៨")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D219/884 ERN 01362501-01362502 (ស.៤-ឆ.៤, ឆ.១៣) ("លោកបាននិយាយថា

361. ឡុច អេង បានពន្យល់ថា គាត់បានស្គាល់ឈ្មោះរបស់ យឹម ទិត្យ ប្រហែលជារយៈពេលកន្លះខែ បន្ទាប់ពីគាត់បានមកដល់ឃុំបឹងព្រៃនៅខែកក្កដា ឆ្នាំ១៩៧៨ និងបានដឹងពីតួនាទីរបស់ យឹម ទិត្យ ក្នុងនាមជាលេខាតំបន់នេះ ព្រោះ យឹម ទិត្យ ធ្វើជាប្រធានកិច្ចប្រជុំដែលចូលរួមដោយគណៈស្រុក និងគណៈឃុំ និងដោយសារតែ ឡុច អេង បានចូលរួមក្នុងកិច្ចប្រជុំទាំងនោះ យ៉ាងហោចណាស់ម្តង[958]។ ឡុច អេង អះអាងថា យឹម ទិត្យ បានរៀបចំកិច្ចប្រជុំទាំងនេះនៅឃុំបឹងព្រៃ ហើយទោះបីជា យឹម ទិត្យ មិនបានឧទ្ទេសនាមអ្វីពីខ្លួនគាត់ក៏ដោយ "តែពួកខ្ញុំដឹងថា គាត់ជាប្រធានតំបន់"[959]។ ចៅក្រមអន្តរជាតិយល់ថា ការទទួលស្គាល់របស់ ឡុច អេង ថា គាត់ពិបាកនិយាយពីអ្វីដែលបានកើតឡើងឱ្យជាក់លាក់ណាស់ ព្រោះគាត់ទើបតែមកដល់ មិនកាត់បន្ថយភាពអាចជឿទុកចិត្តបាននៃភ័ស្តុតាងរបស់គាត់នោះទេ។ ផ្ទុយទៅវិញ សាក្សីរូបនេះមានឆន្ទៈចង់និយាយពីព្រឹត្តិការណ៍ដែលគាត់មិនចងចាំ ប៉ុន្តែនៅតែរក្សាចម្លើយថា គាត់បានដឹងថា យឹម ទិត្យ មានតួនាទីក្នុងគណៈតំបន់នេះ ក្នុងសក្ខីកម្មទាំងអស់របស់គាត់[960]។

362. ចំពោះភ័ស្តុតាងផ្ទុយគ្នាដែលរងការចោទប្រកាន់ពាក់ព័ន្ធនឹង តារិទ[961] អង្គជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ថា យឹម ទិត្យ បានជំនួសតំណែងរបស់តារង់[962] ដែលជា

នៅពេលលោកបានមកដល់ឃុំបឹងព្រៃ គណៈតំបន់គឺតាទិត្យ តើលោកនៅរក្សាចម្លើយនេះដែរ ឬទេ? ឆ.៤ ៖ បាទ។ ឆ.១៣ ៖ គាត់មកហ្នឹង ហើយយើងដឹងថា គាត់ជាគណៈតំបន់ គាត់គ្រប់គ្រង តែលេខតំបន់ភ្លេចអស់ហើយ។ គាត់មកគ្រប់គ្រងស្រុក")។

[958] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D118/96 ERN 00947292 (ឆ.៣១) ("ខ្ញុំដឹងថាតាទិត្យ ជាប្រធានតំបន់ ដោយសារតែគាត់ដឹកនាំប្រជុំ ដោយមានការចូលរួមពីគណៈស្រុក និងពីគណៈឃុំ។ ខ្ញុំធ្លាប់ប្រជុំជាមួយតាទិត្យម្តងម្កាល")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D219/627 ERN 01184313-01184314 (ឆ.១២, ឆ.១៨) ("ខ្ញុំគ្រាន់តែដឹងថា ពេលតាទិត្យមកដល់ គាត់គឺក្លាយជាគណៈតំបន់ ដោយខ្ញុំធ្លាប់ចូលរួមប្រជុំជាមួយគាត់ម្តង")។

[959] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D118/96 ERN 00947292 (ឆ.៣២-៣៣)។

[960] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D219/627 ERN 01184314 (ឆ.១៨) ("ខ្ញុំពិបាកនិយាយណាស់ថា យ៉ាងម៉េចឱ្យពិតប្រាកដ ពីព្រោះយើងទើបតែមកដល់ថ្មីៗទាំងអស់គ្នានៅកន្លែងនោះ។ ខ្ញុំគ្រាន់តែដឹងថា ពេលតាទិត្យមកដល់ គាត់គឺក្លាយជាគណៈតំបន់ ដោយខ្ញុំធ្លាប់ចូលរួមប្រជុំជាមួយគាត់ម្តង")។

[961] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៩។

[962] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៧៧។

អតីតលេខាតំបន់ ៤ ដូច្នេះ មិនផ្អែកលើសក្ខីកម្មរបស់ ឡុច អេង ដែលថា "ពេលតាទិត្យមកដល់ គឺគាត់ជំនួសតារិន"[963]។ ចៅក្រមអន្តរជាតិរម្លឹកឡើងវិញថា អ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផលណាម្នាក់ អាចទទួលយកផ្នែកមួយចំនួននៃសក្ខីកម្មរបស់សាក្សីម្នាក់ និងបដិសេធផ្នែកផ្សេងទៀត[964]។ ក្រៅពីនេះ ចៅក្រមអន្តរជាតិយល់ថា ថាតើ តារិន នៅបន្តតំណែងជាលេខាតំបន់ ៥ រហូតដល់ពេលបញ្ចប់នៃរបប ក.ប.ធ ឬយ៉ាងណានោះ មិនសំខាន់ចំពោះភស្តុតាងស្តីពីតួនាទីរបស់ យឹម ទិត្យ ក្នុងតំបន់ ៤ ឡើយ និងយល់ឃើញថា សហមេធាវីមានការភាន់ច្រលំក្នុងការបង្ហាញភស្តុតាងរបស់ ទុំ សឿន[965] ដែលបានមិនបានលើកឡើងថា តារិន កាន់តួនាទីជាលេខារហូតដល់ចុងបញ្ចប់នៃរបប ក.ប.ធ[966]។

363. ពាក់ព័ន្ធនឹងការចោទប្រកាន់ថា គ្មានភស្តុតាងក្នុងសំណុំរឿងនេះដែលបញ្ជាក់ថា យឹម ទិត្យ ប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ក្នុងនាមជាលេខាតំបន់ ៤[967] ចៅក្រមអន្តរជាតិយល់ឃើញថា ឡុច អេង បានផ្តល់ភស្តុតាងស្តីពីការប្រើប្រាស់សិទ្ធិអំណាចរបស់ យឹម ទិត្យ រួមទាំងភស្តុតាងដែលបញ្ជាក់ថា យឹម ទិត្យ បានដឹកនាំកិច្ចប្រជុំដែល យឹម ទិត្យ បានបញ្ជាឱ្យអ្នកក្រោមបង្គាប់របស់គាត់តាមដានកម្មាភិបាល ឬប្រជាជនទូទៅណា "ដែលមានសកម្មភាពមិនប្រក្រតី" ហើយត្រូវរាយការណ៍ទៅស្រុក[968] និងភស្តុតាងដែលបញ្ជាក់ថា យឹម ទិត្យ គ្រប់គ្រងតំបន់នោះ[969]។ ក្រៅ

---

[963] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D219/627 ERN 01184314 (ឆ.១៣) ("ទិត្យ មកដល់ភ្នំសំពៅនេះក្រោយខ្ញុំ ខ្ញុំមិនដឹងថា មុខងាររបស់គាត់កាលនៅនិរតីនោះជាអ្វីទេ ប៉ុន្តែពេលដែលគាត់មកដល់ភ្នំសំពៅ គេដាក់ទទួលត្រូវខុសតំបន់។ អ! ខ្ញុំភ្លេចនឹកឃើញតាទិត្យ ខ្ញុំទើបតែនឹកឃើញពេលតាទិត្យមកដល់ គឺគាត់ជំនួស តារិន")។

[964] *សូមមើល* មូលដ្ឋានទី ៥ ៖ ការពិចារណាលើភស្តុតាង*ខាងលើ*។

[965] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ១៩៩ *ដែលយោងតាម* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ឯកសារ D119/65 ERN 00953050 (ឆ.២២៤)។

[966] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ឯកសារ D119/65 ERN 00953050 (ឆ.២២៤) ("តាជៀលត្រូវបានជំនួសដោយតារិនដែលជាអ្នកមកពីនិរតី")។

[967] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២០០។

[968] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី៤ ខែ កញ្ញា ឆ្នាំ២០១៣ ឯកសារ D118/96 ERN 00947292 (ឆ.៣១-ឆ.៣៥)។

ពីនេះ ពាក់ព័ន្ធនឹងការចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាលើការសម្រេចរបស់ខ្លួនដែលថា គ្មានភ័ស្តុតាងក្នុងសំណុំរឿងនេះ ដែលបញ្ជាក់ថា យឹម ទិត្យ បានទៅពិនិត្យទីតាំងឧក្រិដ្ឋកម្មណាមួយក្នុងតំបន់ ៤[970] ចៅក្រមអន្តរជាតិរម្លឹកថា វត្តមានរបស់ជនជាប់ចោទណាម្នាក់នៅទីតាំងឧក្រិដ្ឋកម្ម មិនមែនជាបុរេលក្ខខណ្ឌក្នុងការកំណត់សិទ្ធិអំណាច ឬការគ្រប់គ្រងលើទីតាំងនេះឡើយ[971]។

364. សរុបសេចក្តីទៅ បើទោះជាចៅក្រមអន្តរជាតិទទួលស្គាល់ថា ភ័ស្តុតាងស្តីពីតំបន់ ៤ ពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើសក្ខីកម្មរបស់ ឡុច អេង អង្គជំនុំជម្រះសម្រេចថា ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមែនថាមិនសមហេតុផលនោះទេ។ ដូច្នេះ មូលដ្ឋានទី ៥.២ (v) មិនត្រូវបានច្រានចោល។

**មូលដ្ឋាន ៥.២(vi( ការចោទប្រកាន់អំពីកំហុសក្នុងការសម្រេចថា យឹម ទិត្យ**

**គឺជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ**

ក. សារណា

365. សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ ក្នុងការសម្រេចថា យឹម ទិត្យ គឺជាសមាជិកនៃគណៈកម្មាធិការ ភូមិភាគពាយ័ព្យ[972]។ ជាដំបូងសហមេធាវីបានអះអាងថា មិនមានភស្តុតាងនៅក្នុងសំណុំរឿង ដែលគាំទ្រការអះអាងថា យឹម ទិត្យ ធ្លាប់ត្រូវបានតែងតាំង ទៅក្នុងតួនាទីមួយនេះឡើយ[973]។ សហចៅក្រម

---

[969] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D219/884 ERN 01362502 (ស.៣-ឆ.៣, ឆ.១៣) ("គាត់មកគ្រប់គ្រងស្រុក យើងដឹងខ្លួនឯងទេ ហើយគាត់បានចុះមកអប់រំតាមការដ្ឋានម្តងម្កាល")។

[970] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២០០ *ដែលយោងតាម* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៨៦៩, ៨៩៣, ៩២០។

[971] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D359/24និង ឯកសារ D360/33 ទស្សនៈរបស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៥១៣។

[972] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៣-២១៥។

[973] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៣-២០៤។

ស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកដោយខុសទៅលើ ឈាន ប៉ា និងមិនបានពិចារណាទៅលើភស្តុតាងផ្ទុយ ដែលពាក់ព័ន្ធដទៃផ្សេងទៀត របស់សាក្សីរូបនេះ ដូចជាការទទួលស្គាល់របស់គាត់ដែលថា គាត់នៅក្មេងពេកមិនអាចយល់ដឹង អំពីតួនាទីរបស់បុគ្គលមួយចំនួនឡើយ[974]។ លើសពីនេះទៅទៀត ភស្តុតាងរបស់ លឹម ទឹម គឺផ្ទុយគ្នា ហើយត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចដោយខ្លួនឯងថា មិនអាចជឿជាក់បាន[975]។

366. ទីពីរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បកស្រាយមិនត្រឹមត្រូវនូវភស្តុតាងរបស់ ហាន់ ធី, លឹម ទឹម, ហែម មឿន, និងពៅ គឿន ដោយសារតែសាក្សីទាំងអស់នេះ មិនមានសាក្សីរូបណា ដែលគាំទ្រដល់ការសម្រេចថា យឹម ទិត្យ មានតួនាទីនៅក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ ឬថា យឹម ទិត្យ ជាក់ស្តែងគឺជាមនុស្សទីពីរ និងជាអនុប្រធានរបស់ តាម៉ុក នោះឡើយ[976]។ ទាំងភស្តុតាងអំពីទំនាក់ទំនងគ្រួសាររបស់ យឹម ទិត្យ ជាមួយតា ម៉ុក និងភស្តុតាងអំពីរចនាសម្ព័ន្ធរដ្ឋបាល របស់ភូមិភាគពាយ័ព្យ[977] មិនអាចផ្តល់ភស្តុតាង អំពីតួនាទីជាក់ស្តែង ឬតួនាទីតាមផ្លូវច្បាប់របស់ យឹម ទិត្យ ឡើយ[978]។

367. ទីបី សហមេធាវីបានចោទថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាទៅលើភស្តុតាងដោះបន្ទុកសំខាន់ ពាក់ព័ន្ធតួនាទីរបស់អនុលេខានៅក្នុងភូមិភាគពាយ័ព្យ[979]។ “សាក្សីតារា” គឺ កាំង ហ្គេកអ៊ាវ ហៅ ឌុច របស់ អ.វ.ត.ក មិនដែលបានលើកឡើងអំពី យឹម ទិត្យ នៅក្នុងឯកសារណាមួយ ដែលមាននៅក្នុងសំណុំរឿង ០០៤ តែបញ្ជាក់ផ្សេងទៅវិញថា សារុន គឺជាអនុលេខានៅក្នុងឆ្នាំ ១៩៧៩[980]។ អត្ថបទរបស់ Timothy Carney ដែលរៀបរាប់អំពីរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា មិនបានលើកឡើងពី យឹម ទិត្យ ឡើយ[981]។ ជាចុងក្រោយសហមេធាវី បាន

[974] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៥-២០៦។
[975] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៧។
[976] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៨, ២១៤។
[977] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៩។
[978] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៩, ២១៤។
[979] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៩។
[980] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២១០។
[981] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២១១-២១២។

លើកឡើងថា មិនមានភស្តុតាងអំពី យឹម ទិត្យ ប្រើប្រាស់អំណាចរបស់គាត់ នៅក្នុងតួនាទីដែលបានចោទទាំងអស់នេះទេ[982]។

368. សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបថា សហមេធាវីមិនបានបង្ហាញ កំហុសអង្គហេតុ ឬកំហុសអង្គច្បាប់ណាមួយ ដែលអាចត្រួតពិនិត្យឡើងវិញបានឡើយ នៅក្នុងការសម្រេចថា យឹម ទិត្យ គឺជាសមាជិកគណៈកម្មាធិការ ភូមិភាគពាយ័ព្យ និងជាមនុស្សមានអំណាចបំផុតទីពីរ នៅក្នុងភូមិភាគ បន្ទាប់ពី តាម៉ុក ត្រូវបានតែងតាំងជាលេខា ភូមិភាគពាយ័ព្យ[983]។ ជាដំបូង សហព្រះរាជអាជ្ញាអន្តរជាតិពិចារណាថា ការពឹងផ្អែកទៅលើភស្តុតាងរបស់ ឈាន ប៊ុា គឺមានយុត្តិកម្ម ដោយពិចារណាទៅលើការដឹងឮរបស់គាត់ អំពីការតែងតាំង យឹម ទិត្យ ដែលភស្តុតាងនេះមានការគាំទ្រ ដោយចម្លើយរបស់សាក្សី និងធាតុផ្សំតាមកាលៈទេសៈដទៃទៀត[984]។ ប្រហែលគ្នានេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានជំទាស់ចំពោះការវាយតម្លៃរបស់សហមេធាវី ទៅលើភស្តុតាងរបស់ លឹម ទឹម[985]។ ទីពីរ បើតាមយោបល់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ការពិនិត្យលើភស្តុតាង របស់សហមេធាវី គឺមានលក្ខណៈជាផ្នែកតូចៗ គឺថាសហមេធាវីមិនពិចារណាទៅលើភស្តុតាងសំខាន់របស់ ហាន់ ធី ពៅ គឿន ព្រមទាំងការចង្អុលបង្ហាញ អំពីការជ្រៀតជ្រែកទៅលើសាក្សី ហែម មឿនផង[986]។

369. ទីបី សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា ការទាញឲ្យស្របគ្នាចំពោះភស្តុតាង ពាក់ព័ន្ធតួនាទីនៅភូមិភាគពាយ័ព្យ របស់ យឹម ទិត្យ និង តាប៉ែត គឺអាចអនុញ្ញាតបាន ជាពិសេសដោយសារតែការសម្រេច ដែលមានភាពស្របគ្នានៅ អ.វ.ត.ក អំពីសមាជិកភាពរបស់គណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជា[987]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ បានចោទសួរថា តើភស្តុតាងរបស់ ឌុច រារាំងដោយរបៀបណា ចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនឲ្យពឹងផ្អែកទៅលើភស្តុតាង របស់សាក្សីជាច្រើនរូបទៀត ដែលបានឃើញ យឹម ទិត្យ នៅក្នុងភូមិ

[982] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២១៣។
[983] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១២៤។
[984] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១២៥។
[985] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១២៦។
[986] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១២៧។
[987] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១២៨។

ភាគពាយ័ព្យ និងបានទទួលព័ត៌មានថា យឹម ទិត្យ នៅក្នុងគណៈកម្មាធិការ គឺមនុស្សមានអំណាចបញ្ជាទីពីរ នៅក្នុងភូមិភាគ ឬជាអនុប្រធានរបស់តាម៉ុក[988] រួមទាំងភស្តុតាងដែលសហមេធាវី មិនបានជំទាស់ផង និងភស្តុតាងគាំទ្រដទៃទៀតផង[989]។។

## ខ. ការពិភាក្សា

370. នៅក្នុងមូលដ្ឋានទី ៥.២(vi) សហមេធាវីជំទាស់ចំពោះការណ៍ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើភស្តុតាងរបស់សាក្សីមួយចំនួន ដើម្បីសម្រេចថា យឹម ទិត្យ គឺជាសមាជិកគណៈកម្មាធិការ ភូមិភាគពាយ័ព្យ ព្រមទាំងការចោទរបស់អំពី "ការប្រកាន់ខ្ជាប់" ទៅលើចំណងញាតិរបស់ យឹម ទិត្យ ជាមួយតាម៉ុក ដែល "មានឥទ្ធិពលដោយផ្ទាល់ទៅលើការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះភស្តុតាងនានា"[990]។ អង្គបុរេជំនុំជម្រះនឹងពិភាក្សាលើបញ្ហាទាំងអស់នេះ នៅផ្នែកខាងក្រោម។

371. ទីមួយ ចំពោះការចោទអំពីការពឹងផ្អែក របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើចំណងញាតិរបស់ យឹម ទិត្យ និងតាម៉ុកនោះ អង្គបុរេជំនុំជម្រះយោងទៅរកមូលដ្ឋានទី៥.១ ខាងលើ ដែលអង្គបុរេជំនុំជម្រះបានសម្រេចថា ទំនាក់ទំនងជាបុគ្គលដែលជិតស្និទ្ធ "អាចប្រើប្រាស់ជាបរិបទគាំទ្រ ដើម្បីគាំទ្រដល់ភស្តុតាងដទៃទៀត"[991]។ ចំពោះតួនាទីរបស់ យឹម ទិត្យ នៅក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ អង្គជំនុំជម្រះមិនជឿជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិឈានដល់ការសន្និដ្ឋាន ដោយផ្អែកតែទៅលើចំណងញាតិគ្រួសារនេះ ឬថាចំណងញាតិនេះ មានឥទ្ធិពលអវិជ្ជមានដោយផ្ទាល់ ទៅលើការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះភស្តុតាងនានា" ឡើយ[992]។

---

[988] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១២៩។

[989] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១២៩ *យោងទៅរក*ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) ជើងទំព័រ ១០០៥, ១០១០។

[990] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៣។

[991] សូមមើល មូលដ្ឋានទី៥ ខាងលើ ការពិចារណាលើភស្តុតាង។

[992] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៣។

372. ចំពោះការជំទាស់ទៅលើការសម្រេចលើអង្គហេតុវិញ អង្គបុរេជំនុំជម្រះ មិនជឿជាក់ចំពោះការចោទ ប្រកាន់របស់សហមេធាវីដែលថា មិនមានភស្តុតាងនៅក្នុងសំណុំរឿងដែលថា យឹម ទិត្យ ត្រូវបានតែងតាំងជាសមាជិក គណៈកម្មាធិការភូមិភាគពាយ័ព្យ[993]។ ឈាន ប៊ា បានដឹងអំពីការតែងតាំង យឹម ទិត្យ នៅក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ តាមរយៈទំនាក់ទំនងយ៉ាងជិតស្និទ្ធិរបស់គាត់ ជាមួយតាប៉ែត (សមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ) ក្នុងនាមជាអ្នកការពារនិងនីរសា[994]។ ទោះបីជា ឈាន ប៊ា មិនបានចូលរួមការប្រជុំដោយផ្ទាល់ ជាមួយ យឹម ទិត្យ ហើយគាត់គ្រាន់តែឃើញ យឹម ទិត្យ ម្តងប៉ុណ្ណោះក្តី[995] តែការណ៍នេះមិនបានរារាំងគាត់ មិនឲ្យផ្តល់ភស្តុតាងដែលអាចជឿជាក់បាន អំពីតួនាទីរបស់ យឹម ទិត្យ នោះឡើយ។ ផ្ទុយទៅវិញ ឈាន ប៊ា បានពន្យល់ថា តាប៉ែត បានប្រាប់គាត់អំពីការតែងតាំង យឹម ទិត្យ នៅក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ នៅក្នុងកិច្ចប្រជុំមួយនៅ សាកលវិទ្យាល័យបាត់ដំបង ក្រោយពេលដែលពួកគេត្រឡប់មកពីប្រជុំនោះវិញ[996]។ ចម្លើយរបស់ ឈាន ប៊ា នៅក្នុងការស្តាប់ចម្លើយបន្ទាប់ ដែលថាគាត់មិនដឹងអំពីតួនាទីកងទ័ព របស់មេដឹកនាំដទៃទៀត (តាញឹម និងតាកើ) ដោយសារតែគាត់ "នៅក្មេង

---

[993] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៤។

[994] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៊ា ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៣ ឯកសារ D118/136 នៅត្រង់ ERN 00960662-00960663 (ឆ២-ឆ៣) ("ខ្ញុំនៅធ្វើការជាអ្នកការពារ និងជានិរសាឲ្យតាប៉ែត [...] ធ្វើជានិរសានិងជាអ្នកការពារឲ្យតាប៉ែត រហូតដល់ជិតវៀតណាមចូល")។

[995] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈាន ប៊ា ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៣ ឯកសារ D118/136 នៅត្រង់ ERN 00960664 (ឆ៩) ("ខ្ញុំមិនដែលបានចូលរួមប្រជុំជាមួយតាទិត្យ ទេ ព្រោះក្រោយពេលដែលគេចាប់តាប៉ែត ទៅ ខ្ញុំរត់ចេញមកផុតទៅហើយ")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៊ា ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ D118/271 នៅត្រង់ ERN 00998557 (ឆ២៥ -ឆ២៦) ("ខ្ញុំជាកងការពាររបស់តាប៉ែត ហើយតែងតែអមដំណើរ តាប៉ែត ទៅជួបជាមួយតាទិត្យ ពេលគាត់ត្រូវការប្រជុំនឹងគ្នា ប៉ុន្តែខ្ញុំមិនដែលចូលរួម ក្នុងប្រជុំទាំងនោះទេ។ ខ្ញុំបានជួបគាត់ផ្ទាល់តែម្តងគត់ គឺនៅសាកលវិទ្យាល័យបាត់ដំបង ហើយកាលនោះខ្ញុំនៅអមការពារតាប៉ែតដែរ"

[996] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៊ា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៣ ឯកសារ D118/136 នៅត្រង់ ERN 00960664 (ឆ១៣) ("ខ្ញុំបានឃើញគាត់ម្តង នៅពេលដលគាត់ទៅប្រជុំ នៅសាកលវិទ្យាល័យបាត់ដំបង។ តាប៉ែត គាត់ចូលរួមប្រជុំនោះ ហើយនៅពេលដែលខ្ញុំបើកឡាន ជូនគាត់ត្រឡប់មកវិញ គាត់ប្រាប់ខ្ញុំថា តា ទិត្យ មកប្រកាស និងបង្ហាញឯកសារពីមជ្ឈិម តែងតាំងឲ្យគាត់មកគ្រប់គ្រង ភូមិភាគពាយ័ព្យ ហើយតាទិត្យប្រកាសថា អ្នកដឹកនាំភូមិភាគពាយ័ព្យគឺជាជនក្បត់ ព្រោះជាប់ខ្សែររយៈឃួន")។

01677283



ពេកមិនយល់ពីបញ្ហានេះ"[997] មិនបានធ្វើឱ្យថមថយនូវភាពអាចជឿជាក់បាន នៃភស្តុតាងរបស់គាត់ពាក់ព័ន្ធតួនាទីរបស់ យឹម ទិត្យ ដែលគាត់នៅរក្សាថា ជាជំនួយការជិតស្និទ្ធិរបស់ តាម៉ុក[998]។

373. ចំពោះ "ការអះអាងប្រហែលគ្នា" របស់ លឹម ទឹម[999] ភស្តុតាងរបស់គាត់មិនមែនថា យឹម ទិត្យ ត្រូវបានគេណែនាំខ្លួន ថាជាសមាជិកគណៈកម្មាធិការ ភូមិភាគពាយ័ព្យ នៅក្នុងពេលទស្សនកិច្ចនៅរោងចក្រស្ករកំពង់គុលឡើយ[1000]។ ប៉ុន្តែ សាក្សីរូបនេះបានរក្សាចម្លើយថា យឹម ទិត្យ មិនដែលទៅរោងចក្រស្ករសឡើយ[1001] ហើយគាត់ពន្យល់ថា គាត់ដឹងអំពីតួនាទីរបស់ យឹម ទិត្យ នៅក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ ដោយសារតែគាត់ចូលរួមការប្រជុំនៅសាកលវិទ្យាល័យបាត់ដំបង ដែលនៅទីនោះ យឹម ទិត្យ ត្រូវបានគេណែនាំខ្លួនថាដូច្នេះ[1002]។

374. បន្ថែមលើនេះ សហមេធាវីបានលើកទឡ្ហីករណ៍ មិនគួរឱ្យជឿជាក់បានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "សម្រេចថា ភស្តុតាងរបស់ លឹម ទឹម មិនអាចជឿជាក់បាន"[1003] ប៉ុន្តែការ

[997] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៉ា ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ D118/271 នៅត្រង់ ERN 00998560 (ស៤៥-ឆ៤៥) ("ស៖ តើលោកដឹងថា តាញឹម និងតាគី មានតួនាទីខាងយោធាអ្វីខ្លះដែរ? ឆ៤៥៖ ខ្ញុំគ្មានយោបល់អ្វីទេ ព្រោះខ្ញុំនៅក្មេងមិនទាន់ចាប់អារម្មណ៍រឿងហ្នឹងនៅឡើយ")។

[998] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈាន ប៉ា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៣ ឯកសារ D118/136 នៅត្រង់ ERN 00960663 (ឆ៧) ("តាម៉ុកគាត់មកគ្រប់គ្រងភូមិភាគទាំងអស់ ហើយដៃស្តាំរបស់តា ម៉ុក គឺតាទិត្យ") 00960664 (ឆ១០) ("បាទ តាទិត្យ គាត់ក៏តួនាទីថ្នាក់ភូមិភាគដែរ")។

[999] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៨៤។

[1000] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៧ (សហមេធាវីចោទថា លឹម ទឹម "ផ្តល់ភស្តុតាងអំពីការប្រជុំ នៅរោងចក្រស្ក នៅពាក់កណ្តាលឆ្នាំ ១៩៧៨ដែល "តាទិត្យ" ត្រូវបានចោទថាមានវត្តមាន ហើយត្រូវបានគេណែនាំខ្លួនថា ជាគណៈកម្មាធិការភូមិភាគពាយ័ព្យ" និងថា លឹម ទឹម "នៅពេលក្រោយមកបានផ្លាស់ប្តូរចម្លើយរបស់គាត់ ហើយបាននិយាយថា "តាទិត្យ" មិនដែលទៅរោងចក្រនោះឡើយ"។

[1001] កំណត់ហេតុស្តាប់ចម្លើយសាក្សី លឹម ទឹម ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D118/108 នៅត្រង់ ERN 00951928 (ឆ១៦) ("ខ្ញុំស្គាល់តាទិត្យ គាត់នៅកាន់ខាងភូមិភាគពាយ័ព្យ។ គាត់នៅក្រុងបាត់ដំបង ហើយគាត់មិនដែលមករោងចក្រស្ករសនេះទេ មានតែតាម៉ុក ទេ ដែលមកទីនេះ")។

[1002] កំណត់ហេតុស្តាប់ចម្លើយសាក្សី លឹម ទឹម ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D118/108 នៅត្រង់ ERN 00951928 (ឆ១៧ -ឆ១៨), កំណត់ហេតុស្តាប់ចម្លើយសាក្សី លឹម ទឹម ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ឯកសារ D219/649 នៅត្រង់ ERN 01196459-01196460 (ឆ៣៧-ឆ៤០) 01196461 (ឆ៤៨) 01196462 (ឆ៥៥)។

[1003] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៧។

01677284



សម្រេចនេះ គឺពាក់ព័ន្ធតែទៅនឹងផ្នែកជាក់លាក់មួយ នៃភស្តុតាងរបស់គាត់ប៉ុណ្ណោះ។ អង្គបុរេជំនុំជម្រះសូមរំឭកថា អ្នកវិនិច្ឆ័យអង្គហេតុមួយរូប "អាចទទួលយកដោយសមហេតុផល នូវផ្នែកជាក់លាក់នៃសក្ខីកម្មរបស់សាក្សីម្នាក់ ហើយបដិសេធចោលនូវផ្នែកផ្សេងទៀត" បន្ទាប់ពីបានពិចារណាទៅលើសក្ខីកម្មទាំងស្រុងរួចហើយនោះ[1004]។ នៅទីនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថា ភស្តុតាងរបស់ លឹម ទឹម អំពីការចាប់ខ្លួនខ្មែរក្រោម និង/ឬ វៀតណាម នៅរោងចក្រស្ករកំពង់គុល "ពិតជាមិនអាចជឿបាន យកជាមូលដ្ឋានធ្វើការសន្និដ្ឋាន ជាក់លាក់ណាមួយអំពីអត្តសញ្ញាណ ឬចំនួននៃជនរងគ្រោះ ដែលបានចោទប្រកាន់នោះឡើយ"[1005] ប៉ុន្តែមិនបានសម្រេចបែបនេះ ទៅលើភស្តុតាងរបស់ លឹម ទឹម ពាក់ព័ន្ធតួនាទីរបស់ យឹម ទិត្យ នៅក្នុងគណៈកម្មាធិការ ភូមិភាគពាយ័ព្យឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏មិនបានសម្រេចថា ភស្តុតាងរបស់ លឹម ទឹម ជាទូទៅមិនអាចជឿជាក់បាននោះឡើយ។

375. សហមេធាវីបានចោទបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បកស្រាយមិនត្រឹមត្រូវនូវភស្តុតាងរបស់ ហាន់ ធី, លឹម ទឹម, ហែម មឿន, ពៅ គឿន ក្នុងការសម្រេចថា យឹម ទិត្យ មានតួនាទីនៅក្នុងគណៈកម្មាធិការ ភូមិភាគពាយ័ព្យ និងជាអ្នកមានអំណាចទីពីរជាក់ស្តែង ព្រមទាំងជាអនុប្រធានតាម៉ុក[1006]។ អង្គបុរេជំនុំជម្រះសម្រេចថា ការចោទប្រកាន់ទាំងអស់នេះ មិនគួរឱ្យជឿជាក់បាន ជាពិសេសដោយផ្អែកលើភស្តុតាងបន្ថែម ដែលមិនអាចជំទាស់បាន ដែលបានដកស្រង់នៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងនៅពេលវាយតម្លៃលើភស្តុតាង ក្នុងលក្ខណៈជារួម[1007]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះធ្វើការត្រួតពិនិត្យទៅលើការជំទាស់នីមួយៗចំពោះសាក្សីទាំងអស់នេះ នៅផ្នែកខាងក្រោម។

---

[1004] សូមមើល មូលដ្ឋាន ៥ ខាងលើ សេចក្តីពិចារណាលើភស្តុតាង។

[1005] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៧៤១។

[1006] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៨។

[1007] សូមមើល ជាឧទាហរណ៍ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៨០-៣៨២ *យោងទៅរក*ជាឧទាហរណ៍ កំណត់ហេតុស្តាប់ចម្លើយសាក្សី នួន មួន ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D118/69 នៅត្រង់ ERN 00920212-00920213 (ឆ១៤,ឆ១៦) ("ឆ១៤៖ អ្នកដែលឡើងជំនួសគាត់គឺតាម៉ុក ហើយតាទិត្យ ក្លាយជាអនុប្រធានភូមិភាគពាយ័ព្យ របស់តាម៉ុក [...] ស៖ តើហេតុអ្វីទើបលោកដឹងថា តាទិត្យ ជាអនុប្រធានភូមិភាគពាយ័ព្យ? ឆ១៦៖ ព្រោះកាលណោះអ្នកដែលធំ មកពីភូមិភាគនិរតី មានតែពីរនាក់ទេ គឺតាម៉ុក និងតាទិត្យ ហើយមិនមានអ្នកណាផ្សេងទេ"), កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ក លី ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ ឯកសារ D118/86 នៅត្រង់ ERN 00945420 (ឆ២០-ឆ២១)

376. ទីមួយ ចំពោះការប្រជុំដែល ហាន់ ធី បានចូលរួម[1008] ដែលក្នុងការប្រជុំនោះ យឹម ទិត្យ បានប្រកាសថា គាត់គឺជាប្រធានភូមិភាគពាយ័ព្យ[1009] បើទោះបីជា ហាន់ ធី កំណត់ថាការប្រជុំនោះ គឺនៅមុនពេលវៀតណាមចូលមកដល់បន្តិច[1010] ប៉ុន្តែវត្តមានរបស់តាប៉ែត ចង្អុលបង្ហាញថា ការប្រជុំនេះប្រហែលជាធ្វើឡើង នៅមុននេះ ព្រោះតាប៉ែត ត្រូវបានចាប់ខ្លួនប្រហែលជាក្នុងខែ សីហា ឆ្នាំ ១៩៧៨[1011]។ បើទោះបីជាពេលវេលាជាក់លាក់ នៃការប្រជុំនេះនៅមិនមានភាពច្បាស់លាស់ ប៉ុន្តែជាចុងក្រោយ អង្គជំនុំជម្រះពិចារណាថា ការណ៍ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើ ហាន់ ធី ចំពោះខ្លឹមសារនៃការប្រជុំ គឺសមហេតុផល ហើយជាការគាំទ្រទៅដល់ភស្តុតាងដទៃទៀត។

377. ទីពីរ ដូចដែលបានពិភាក្សាពីខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា ផ្នែកជាក់លាក់មួយនៃភស្តុតាងរបស់ លឹម ទឹម មិនអាចជឿជាក់បាន មិនមែនចម្លើយ ឬភស្តុតាងរបស់គាត់ទាំងអស់ អំពីតួនាទីរបស់ យឹម ទិត្យ ឡើយ[1012]។ ទីបី ហែម មឿន បានបញ្ជាក់ថា គាត់ឮថាតាម៉ុកធ្វើការប្រកាសថា យឹម ទិត្យ ទទួលខុសត្រូវលើភូមិភាគពាយ័ព្យ នៅពេលដែលគាត់អវត្តមាន[1013]។ នៅក្នុងចម្លើយទាំងមូលរបស់គាត់ ហែម មឿន រក្សាភាពស្របគ្នាដែលថា ខ្លួនគាត់

("ហើយក្រោយពេលគេចាប់តាគីនិងតាប៉ែត មានតែតាម៉ុក និងតាទិត្យ ដែលមកពីនិរតីជាអ្នកក្តាប់ [...] គេប្រកាសថាតាញឹមក្បត់ចូលយួន ហើយតាម៉ុកនិងតាទិត្យ ឡើងជំនួសតាញឹម ព្រោះគេចាប់កម្មាភិបាលពាយ័ព្យអស់ហើយ")។

[1008] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៨ (សហមេធាវីបានចោទថា "ហាន់ ធី បានឃើញ "តាទិត្យ" ជាលើកដំបូង នៅបីថ្ងៃមុនពេលវៀតណាមចូលមកដល់")។

[1009] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហាន់ ធី ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១១ ឯកសារ D20 នៅត្រង់ ERN 00699642-00699643 ("ខ្ញុំធ្លាប់បានជួបគាត់ [យឹម ទិត្យ] ម្តង ហើយពេលនោះគេបើកការប្តេជ្ញាវាយយួន [...] តាទិត្យថាខ្លួនគាត់គឺជាគណៈភូមិភាគពាយ័ព្យ")។

[1010] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហានិ ធី ទី២១ ខែឧសភា ឆ្នាំ២០១១ ឯកសារ D20 នៅត្រង់ ERN 00699643 ("សំណួរ៖ តើក្រោយការប្រជុំប៉ុន្មានថ្ងៃ មុនពេលដែលវៀតណាមចូល? ឆ្លើយ៖ បាទវៀតណាមចូលមែន ប៉ុន្តែមិនដឹងរយៈច្បាស់ទេ គឺប្រហែលជាបីថ្ងៃមែន")។

[1011] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៦២។

[1012] សូមមើល ខាងលើ កថាខណ្ឌ ៣៧៤។

[1013] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម មឿន ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D118/150 នៅត្រង់ ERN 00968003 (ឆ៦០-ឆ៦១) ("នៅបាត់ដំបង គឺមានតែតាទិត្យប៉ុណ្ណោះ ដែលធំជាងគេបន្ទាប់ពីតាម៉ុក។ ប្រសិនបើតាម៉ុកមិននៅ គឺតាទិត្យ ជាអ្នកទទួលខុសត្រូវភូមិភាគពាយ័ព្យ [...] ស៖ ហេតុអ្វីបានជាលោកដឹងថា តាទិត្យ ជាអ្នកទទួលខុសត្រូវ ភូមិភាគពាយ័ព្យនៅពេល

ផ្ទាល់មិនដែលបានចូលរួមការប្រជុំ ដែលមានការប្រកាសឡើយ ហើយគាត់ក៏មិនដែលបញ្ជាក់ថា គាត់មានវត្តមាននៅក្នុង ការប្រជុំណាមួយជាមួយ យឹម ទិត្យ ឡើយ[1014]។

378. ផ្ទុយពីការចោទប្រកាន់របស់សហមេធាវី[1015] ពៅ គឿន បានផ្តល់ភស្តុតាងលម្អិត អំពីតួនាទីរបស់ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ នៅពេលសាកសួរជាក់លាក់អំពី យឹម ទិត្យ ដោយគាត់បាន បញ្ជាក់ថា តាកើ បានប្រកាសថា យឹម ទិត្យ មកគ្រប់គ្រងខេត្តបាត់ដំបង[1016]។ ចម្លើយបន្ទាប់របស់ ពៅ គឿន ដែលថាគាត់មិនដឹងថានរណាដឹកនាំភូមិភាគ និងតំបន់ "ពេលពាយ័ព្យគ្រប់គ្រង"[1017] មិន បានធ្វើឱ្យចុះថយភាពអាចជឿជាក់បាន នៃភស្តុតាងកន្លងមករបស់គាត់ ពាក់ព័ន្ធតួនាទីរបស់ យឹម ទិត្យ ឡើយ។ បន្ថែមលើនេះ អង្គជំនុំជម្រះសម្រេចថា ការពិតដែលថា ពៅ គឿន មិនបានជួប យឹម

---

ដែលតាម៉ុកមិននៅ? ឆ.៦១៖ ខ្ញុំដឹងដោយសារតាម៉ុក បានប្រកាសប្រាប់យោធាថា "បើអស់ពីអញទៅ តាទិត្យ ជាអ្នកទទួល ខុសត្រូវភូមិភាគបន្ទាប់"), កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម មឿន ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៤ ឯកសារ D118/222 នៅត្រង់ ERN 00983235 (ឆ១៤) ("ខ្ញុំបានឮការប្រកាសនេះ ប្រហែលជាមួយអាទិត្យ បន្ទាប់ពីខ្ញុំបានទៅដល់ខេត្តបាត់ដំបង។ [...] គេប្រជុំនៅកន្លែងផ្សេង ពីកន្លែងខ្ញុំធ្វើការ ហើយខ្ញុំមិនបានចូលរួមទេ")។

[1014] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម មឿន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D118/150 នៅត្រង់ ERN 00968003-00968004 (ឆ៦១-ឆ៦២) ("តាទិត្យធ្លាប់បានហៅមេៗយោធា ទៅប្រជុំនៅក្នុងបាត់ដំបង នៅបរិវេណសាលា សកល។ ខ្ញុំមិនបានចូលរួមប្រជុំទេ គឺខ្ញុំជាអ្នកការពារនៅខាងក្រៅ [...]សៈ តើលោកធ្លាប់ចូលរួមប្រជុំជាមួយ តាទិត្យ ប៉ុន្មាន ដងដែរ? ឆ៦២៖ ខ្ញុំមិនធ្លាប់ចូលរួមប្រជុំទេ។")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម មឿន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ឯកសារ D118/222 នៅត្រង់ ERN 00983235 (ឆ១៤) ("ខ្ញុំមិនបានយាមនៅកន្លែងប្រជុំទេ គឺខ្ញុំនៅយាមតាមផ្លូវ [...]គេប្រជុំនៅ កន្លែងផ្សេង ពីកន្លែងខ្ញុំធ្វើការ ហើយខ្ញុំមិនបានចូលរួមទេ"), សំណុំរឿង ០០២ ប្រតិចារឹកថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១៦ (ហែម មឿន) ឯកសារ D339.1.1 នៅត្រង់ ERN (ភាសាអង់គ្លេស) 01351805 ទំព័រ ៦៤។

[1015] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ 208

[1016] កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ គឿន ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/64 នៅត្រង់ ERN (ភាសាអង់គ្លេស) 01037176 (ឆ២៧-ឆ៣១) ("ក្រោយការបោសសម្អាតកម្មាភិបាលធំៗ នៅទីនេះហើយ តាទិត្យ ក៏មកដល់ ហើយគ្រប់គ្រងនៅទីនេះ។ សៈ តើលោកដឹងថា តាទិត្យ មានមុខតំណែងអ្វីដែរឬទេ? ឆ.២៨៖ នៅពេលនោះ គាត់មានមុខតំណែងជា គណៈតំបន់ [...] ក្រោយមកទៀត តាទិត្យ ក៏គ្រប់គ្រងភូមិភាគពាយ័ព្យផងដែរ។ [...] ឆ២៩៖ មានការប្រជុំ ហើយអ្នកដែល នៅក្រោមតាទិត្យ បាននិយាយថា "មេៗនៅខេត្តបាត់ដំបង ត្រូវគេបញ្ជូនទៅរៀនសូត្រអស់ហើយ។ សមមិត្តទិត្យ ជាអ្នកមកគ្រប់ គ្រងនៅខេត្តបាត់ដំបង [...] ខ្ញុំបានចូលរួមការប្រជុំពីរបីដងដែរ ហើយតាគឺជាអ្នកប្រកាសដូច្នេះ")។

[1017] កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ គឿន ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/64 នៅត្រង់ ERN (ភាសាអង់គ្លេស) 01037174 (ឆ១៧)។

ទិត្យ ដោយផ្ទាល់ មិនបានរារាំងគាត់ក្នុងការផ្តល់ភស្តុតាងអំពីតួនាទីរបស់ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យទេ[1018]។

379. បន្ថែមលើនេះ ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហមេធាវីមិនបានគាំទ្រការចោទប្រកាន់របស់ខ្លួនដែលថា "រចនាសម្ព័ន្ធរដ្ឋបាលរបស់ភូមិភាគពាយ័ព្យ" មិនអាចអះអាងបានអំពីតួនាទីជាក់ស្តែង ឬតួនាទីតាមផ្លូវច្បាប់របស់ យឹម ទិត្យឡើយ[1019]។ ភស្តុតាងដែលថា តាប៉ែត កន្លងមកគឺជាសមាជិកគណៈកម្មាធិការភូមិភាគ និងជាលេខាតំបន់១[1020] ដោយខ្លួនឯង នឹងមិនអាចបំពេញបាន តាមបទដ្ឋាន "ភស្តុតាងគ្រប់គ្រាន់" ដើម្បីគាំទ្រការសម្រេចថា យឹម ទិត្យ ក៏កាន់តំណែងទាំងអស់នេះក្នុងពេលតែមួយនោះដែរ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្ហាញភស្តុតាងនេះគ្រាន់តែជាកត្តាមួយ រួមជាមួយចម្លើយសាក្សីនីមួយៗ ដែលអះអាងអំពីតួនាទីរបស់ យឹម ទិត្យ នៅក្នុងគណៈកម្មាធិការ ភូមិភាគពាយ័ព្យ និងជាលេខាតំបន់១[1021]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិឃើញថាមិនមានកំហុសឡើយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកទៅលើភស្តុតាង រចនាសម្ព័ន្ធរដ្ឋបាលបក្សកុម្មុយនីស្តកម្ពុជា រួមជាមួយភស្តុតាងដែលថា យឹម ទិត្យ ពិតជាកាន់តំណែងទាំងអស់នេះ។

380. ប្រហែលគ្នានេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពឹងផ្អែកដោយមិនត្រឹមត្រូវ ទៅលើចំណងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយតាម៉ុក ឬដាក់បន្ទុកអំពើរបស់តាម៉ុក ទៅលើ យឹម ទិត្យឡើយ[1022]។ ប៉ុន្តែការសម្រេចគឺផ្អែកលើភស្តុតាងរបស់សាក្សីដែលរំឭកអំពីសិទ្ធិអំណាចរបស់ យឹម ទិត្យ ដូចជាថា យឹម ទិត្យ ត្រូវបានតែងតាំងទៅក្នុង គណៈកម្មាធិការភូមិភាគពាយ័ព្យ និងថា យឹម

---

[1018] កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ គឿន ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/64 នៅត្រង់ ERN (ភាសាអង់គ្លេស) 01037176 (ឆ៣១) ("ខ្ញុំមិនធ្លាប់ជួបទេ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ តាទិត្យ បានប្រជុំជាមួយនឹង មេកម្មាភិបាលធំៗផ្សេងទៀត នៅក្រុងបាត់ដំបង។ ហើយក្រោយមកទៀត កម្មាភិបាលទាំងអស់នោះ ចេញទៅកន្លែងផ្សេងៗគ្នា។ តែខ្ញុំធ្លាប់ឮឈ្មោះតាទិត្យនេះ")។

[1019] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៩។

[1020] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៨១។

[1021] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៨០ *យោងទៅរក* កំណត់ហេតុស្តាប់ចម្លើយសាក្សី នួន មួនថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ D118/69 នៅត្រង់ ERN 00920212-00920213 (ឆ១៤-ឆ១៧)។

[1022] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៩។

ទិត្យ និងតាម៉ុក ដឹកនាំកិច្ចប្រជុំជាមួយគ្នាជាដើម[1023]។ ការចោទប្រកាន់ថា ភស្តុតាងរបស់ ពេជ្រ ជឹម ពាក់ព័ន្ធតែជាមួយភូមិភាគនិរតីនោះ គឺមិនអាចជឿជាក់បានទេ[1024] ព្រោះគាត់បានពន្យល់ថា ការងាររបស់ តាម៉ុក គឺពង្រីកទៅគ្រប់ភូមិភាគទាំងអស់[1025]។ បន្ថែមលើនេះ ចម្លើយរបស់ពេជ្រ ជឹម តែមួយ មិនមែនជាកត្តាកំណត់ សម្រាប់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើតួនាទីរបស់ យឹម ទិត្យ ឡើយ។

381. ជាចុងក្រោយ ការចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "មិនបានពិចារណាអំពីភស្តុតាងដោះបន្ទុកសំខាន់ៗ ទាក់ទងនឹងតួនាទីរបស់អនុលេខាភូមិភាគពាយ័ព្យ"[1026] គឺគ្មានមូលដ្ឋានឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាយ៉ាងច្បាស់លាស់ ទៅលើភស្តុតាងផ្ទុយគ្នាអំពីសមាជិកទីបីរបស់គណៈកម្មាធិការ ប៉ុន្តែបានសម្រេចថា ចំណុចនេះមានផលវិបាកតិចតួច សម្រាប់គោលបំណងនៃដីកាដំណោះស្រាយ[1027]។ អង្គជំនុំជម្រះសម្រេចថា ភស្តុតាងផ្ទុយគ្នាអំពីសមាជិកទីបីរបស់គណៈកម្មាធិការភូមិភាគ និងអង្គហេតុដែលថា ឌុច ឬអត្ថបទរបស់ Timothy Carney មិនបានលើកឡើងអំពី យឹម ទិត្យ[1028] នោះ មិនធ្វើឱ្យមោឃៈដល់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីតួនាទីរបស់ យឹម ទិត្យ ឡើយ។

382. ដោយផ្អែកលើការវិភាគខាងលើ ចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឡើយក្នុងការសម្រេចថា យឹម ទិត្យ គឺជាសមាជិកនៃគណៈកម្មាធិការភូមិភាគពាយ័ព្យ ចាប់ពីពាក់កណ្ដាលឆ្នាំ ១៩៧៨ និងថា គាត់ជាមនុស្សមានអំណាចទីពីរ បន្ទាប់ពីតាម៉ុក នៅក្នុងភូមិភាគនេះ។ អាស្រ័យហេតុនេះ សម្រេចបដិសេធមូលដ្ឋានទី ៥.២(vi)។

---

[1023] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៨០, ៣៨២ -៣៨៣ និង ជើងទំព័រ ១០០៤-១០០៥, ១០១១-១០១៣។

[1024] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៩ *យោងទៅរក* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៨៣។

[1025] កំណត់ហេតុស្ដាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ D118/259 នៅត្រង់ ERN 00997041-00997042 (ឆ១៤០ -ឆ១៤២)។

[1026] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២០៩-២១០។

[1027] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៨៥។

[1028] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២១០-២១១។

01677289



## មូលដ្ឋានទី ៥.៣ (i)÷ ការចោទប្រកាន់អំពីកំហុសក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម ក

### ១. អំណះអំណាង

383. សហមេធាវីការពារក្តីលើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម ក នៅភូមិភាគពាយ័ព្យ តាំងពីដើមឆ្នាំ១៩៧៦ មក ទោះបីការពិតដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានរកឃើញថា យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ ឬតាមនីតិន័យ* មុនពេលដែលគាត់ត្រូវបានតែងតាំងជាផ្លូវការនៅខែមិថុនា តាមការចោទប្រកាន់នោះក៏ដោយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ ដោយអនុវត្តហួសពីវិសាលភាពពេលវេលានៃការស៊ើបសួរ ពីព្រោះគាត់មិនបានទទួលការចោទប្រកាន់ពីអំពើឧក្រិដ្ឋរបស់ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ មុនពាក់កណ្តាលឆ្នាំ១៩៧៧ នោះឡើយ [1029]។

384. ទីមួយ ទាក់ទងនឹងការរួមចំណែករបស់ យឹម ទិត្យ ក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាននៅក្នុងភូមិភាគពាយ័ព្យ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេចថា យឹម ទិត្យ "[បាន] ពិនិត្យ" ការដ្ឋាន និងសហករណ៍ទាំងនោះ និងលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើភស្តុតាងដែលមិនមានការគាំទ្រ ហើយមិនបានពិចារណាទៅលើភស្តុតាងផ្ទុយ និងភស្តុតាងដោះបន្ទុក[1030]។ ទាក់ទិននឹងការដ្ឋានកំពីងពួយ សហចៅមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (i) មិនបានចោទប្រកាន់ យឹម ទិត្យ ពីការចូលរួមរបស់គាត់នៅក្នុង

---

[1029] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២២។

[1030] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៣ *ដែលយោងទៅ* ភស្តុតាងរបស់ សោម វណ្ណា (ដែលបានបញ្ជាក់ថា គាត់បានធ្វើការនៅការដ្ឋានទំនប់កង្កួត ប៉ុន្តែមិនដែលបានឃើញ "តាទិត្យ" មិនបានដឹងពីមុខតំណែងរបស់គាត់ មិនដែលបានឃើញគាត់ចូលរួមការប្រជុំនៅការដ្ឋានទំនប់កង្កួត និងមិនដែលបានឃើញគាត់មកការដ្ឋាននេះទេ) ឈឿង ប៊ិន (ដែលបានបញ្ជាក់ថា "តាទិត្យ" បានចាប់ផ្តើមមកការដ្ឋានទំនប់កង្កួត នៅខែឧសភា មិថុនា និងកក្កដា ឆ្នាំ១៩៧៨ ប៉ុន្តែបន្ទាប់មកបានប្តូរភស្តុតាងរបស់គាត់ ហើយបាននិយាយថា គាត់បានឃើញ "តាទិត្យ" ជាលើកដំបូងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៨ និង សៅ ជាប់ (ដែលបានអះអាងថា គាត់ស្គាល់មនុស្សពីរនាក់ឈ្មោះ "តាទិត្យ" ប៉ុន្តែគាត់មិនអាចញែកដាច់ពីគ្នារវាងមនុស្សទាំងពីរនាក់នោះបានឡើយនៅក្នុងភស្តុតាងរបស់គាត់)។

ហេតុការណ៍នៅការដ្ឋាននេះ (ii) មិនបានទទួលការចោទប្រកាន់ពីឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្ត នៅទីនោះ[1031] (iii) បានពឹងផ្អែកទៅលើភ័ស្តុតាងរបស់ ហ៊ុយ ក្រឹម ដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ស្ថិតនៅក្រៅវិសាលភាពពេលវេលានៃកិច្ចស៊ើបសួរ[1032] និង (iv) មិនបានពិចារណាទៅលើ ភ័ស្តុតាងផ្ទុយ[1033]។

385. លើសពីនេះទៀត សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុង ការសម្រេចថា យឹម ទិត្យ បានដឹកនាំការប្រជុំ និងវគ្គរៀនសូត្រនៅតាមការដ្ឋាននានា បានថ្លែង សុន្ទរកថានិងការណែនាំ និងបានបណ្តុះបណ្តាលកម្មាភិបាលថ្នាក់ក្រោមស្តីពីការសាងសង់ និង ការបង្កបង្កើនផល និង "បានជំរុញការអនុវត្តគោលនយោបាយសេដ្ឋកិច្ចរបស់ ប.ក.ក" ដោយមិន បានពិចារណាអំពី

ភ័ស្តុតាងផ្ទុយ និងភ័ស្តុតាងដោះបន្ទុក[1034]។ ស្រដៀងគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកក្នុងការជំរុញការអនុវត្តវិន័យ តឹងតែងសម្រាប់កម្មករ ជាពិសេសនៅទំនប់កង្កួត ដោយពឹងផ្អែកតែទៅលើអ្នកដាក់ពាក្យសុំតាំងខ្លួន

---

[1031] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៤។

[1032] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៤។

[1033] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៥។ (ជាឧទាហរណ៍ សហមេធាវីចង្អុលបង្ហាញអំពីចម្លើយរបស់ ធៀម របៀប (ដែលបានធ្វើការនៅការដ្ឋានកំពឹងពួយ) ថា គាត់មិនដែលបានឮ ឬបាន ឃើញ យឹម ទិត្យ ទៅពិនិត្យការដ្ឋានកំពឹងពួយឡើយ)។

[1034] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៧ *ដែលយោងទៅ* ភ័ស្តុតាង ដែលត្រូវបានចោទប្រកាន់ថាផ្ទុយទៅនឹងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ បាន ដឹកនាំការប្រជុំ និងវគ្គរៀនសូត្រនៅតាមការដ្ឋាននានា ថ្លែងសុន្ទរកថា និងការណែនាំ និងការបណ្តុះបណ្តាលដល់កម្មាភិបាល ថ្នាក់ក្រោមស្តីពីការសាងសង់ និងការបង្កបង្កើនផល ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ និងជំរុញការអនុវត្តគោលនយោបាយ សេដ្ឋកិច្ចរបស់ ប.ក.ក ពី លេខ ភីវ (ដែលមិនធ្លាប់បានកំណត់អត្តសញ្ញាណរបស់ យឹម ទិត្យ ឬ តួនាទីរបស់គាត់ ដោយត្រឹមត្រូវ ហើយ លេខ ភីវ មានវត្តមាននៅក្នុងកិច្ចប្រជុំជាមួយ "តាទិត្យ" ក្រោយរដូវវស្សា ឆ្នាំ១៩៧៨) ដុស ដឿន (ដែលភ័ស្តុតាងរបស់ គាត់ពាក់ព័ន្ធនឹងមនុស្សម្នាក់ឈ្មោះ "តាទិត្យ" ដែលជាកម្មាភិបាលភូមិភាគពាយ័ព្យ ទទួលបន្ទុកឃុំកន្ទឺមួយ ក្នុងស្រុកបាណន់) ជុច ពន្លក (ដែលបានបញ្ជាក់ថា "តាទិត្យ" ដែលគាត់ស្គាល់ "ធ្វើការដូចគេឯងដែរ" ធ្វើការជាមួយប្រជាជនសាមញ្ញ ហើយ "មិនមែន ជាមេដឹកនាំអ្វីទេ") និង ទៀប ទិត្យ (ដែលអះអាងថាបានចូលរួមការប្រជុំមួយដែល "តាទិត្យ" មានវត្តមាននៅក្នុងខែមករា ឬខែ កុម្ភៈ ឆ្នាំ១៩៧៨ ហើយមិនបានកំណត់អត្តសញ្ញាណ យឹម ទិត្យ ដោយត្រឹមត្រូវ និងប្រហែលជាច្រឡំ "តាទិត្យ" ជាមួយ តាប៉ែត )។

*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*

ជាដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា និងមិនបានពិចារណាទៅលើភ័ស្តុតាងផ្ទុយ និងភ័ស្តុតាងដោះបន្ទុករបស់សាក្សីរូបនេះឡើយ[1035]។

386. លើសពីនេះទៅទៀត ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងការចូលរួមចំណែករបស់ យឹម ទិត្យ ក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាននៅក្នុងភូមិភាគពាយ័ព្យគឺផ្ទុយពីការសម្រេចរបស់គាត់ ដែលថា យឹម ទិត្យ មិនមានវត្តមាននៅក្នុងសហករណ៍ និងការដ្ឋានចំនួន ៣ ក្នុងចំណោមសហករណ៍ និងការដ្ឋានចំនួន ៤ ដែលបានធ្វើការស៊ើបអង្កេត[1036]។ នៅចុងបញ្ចប់ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញភ័ស្តុតាង ឬពិចារណាអំពី*ធាតុផ្សំអត្តនោម័តិ* របស់ យឹម ទិត្យ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង ការដាក់ឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត[1037]។

387. ទីពីរ ទាក់ទងនឹងការចូលរួមចំណែករបស់ យឹម ទិត្យ ដែលត្រូវបានចោទប្រកាន់ក្នុងគោលនយោបាយរបស់ ប.ក.ក លើការអប់រំរៀនសូត្រ "សមាសធាតុមិនល្អ" និងការសម្លាប់ខ្មាំង សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ក្នុងការសម្រេចថា តាម៉ុក និង យឹម ទិត្យ បានជ្រើសរើស និងបញ្ជាឱ្យកម្មាភិបាលភូមិភាគនិរតីទៅត្រួតត្រាភូមិភាគពាយ័ព្យចន្លោះពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ និងបានរៀបចំការបោសសម្អាតពីឆ្នាំ១៩៧៦ រហូតដល់ពេលដួលរលំកម្ពុជាប្រជាធិបតេយ្យនៅក្នុងខែមករា ឆ្នាំ១៩៧៩[1038]។ សហមេធាវីបញ្ជាក់ថា ភ័ស្តុតាងជាឯកសារ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់ មិនបានលើកឡើងអំពី យឹម ទិត្យ ហើយក៏មិនបានបង្ហាញ ភ័ស្តុតាងនៃការចូលរួមរបស់គាត់ក្នុងការបោសសម្អាតនេះដែរ[1039]។ លើសពីនេះទៅទៀត សហមេធាវីអះអាងថា គ្មានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីដែលបានដកស្រង់មក គាំទ្រដល់ការសន្និដ្ឋានថា យឹម ទិត្យ បានចាត់តាំងកម្មាភិបាលភូមិភាគនិរតី

---

[1035] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៨។
[1036] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៩។
[1037] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣០។
[1038] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣២។
[1039] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣២-២៣៤។

01677292



មួយចំនួនតូច ឱ្យទៅបំពេញការងារជាមួយកម្មាភិបាលភូមិភាគពាយ័ព្យនៅក្នុងឆ្នាំ១៩៧៦ ទេ[1040] ឬថា នៅពាក់កណ្ដាលឆ្នាំ១៩៧៧ យឹម ទិត្យ បានស្វាគមន៍ កម្មាភិបាលភូមិភាគនិរតី នៅពេលដែលពួកគេមកដល់បាត់ដំបង ហើយចាត់តាំងពួកគេទៅជំនួសកម្មាភិបាល នៅតាមទីកន្លែងផ្សេងៗជាច្រើននៅក្នុងភូមិភាគពាយ័ព្យ[1041]។ លើសពីនេះទៀត សហមេធាវីអះអាងថា ភ័ស្តុតាងមួយចំនួនដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់ គឺទាក់ទងជាមួយនឹងឆមាសទីពីរនៃឆ្នាំ១៩៧៨[1042]។

388. បន្ថែមពីនេះទៀត សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើភ័ស្តុតាងរបស់ ហួន ជឿម ដែលមានការជាប់ពាក់ព័ន្ធ និងផ្ទុយពីភ័ស្តុតាងដែលគាត់បានពឹងផ្អែក និងមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមក្នុងការចាប់ខ្លួន "ប្រធាន"កងវរសេនាតូចពីររូប ដែលគេមិនស្គាល់ឈ្មោះ ដែលគ្រប់គ្រងលើរោងចក្រស្ករសកំពង់គល់ នៅពាក់កណ្ដាលឆ្នាំ ១៩៧៧[1043]។ ជាចុងក្រោយ សហមេធាវីអះអាងថា សហចៅក្រម

---

[1040] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៥។

[1041] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៦-២៣៧ (សហមេធាវីចង្អុលបង្ហាញពី យឹម គួញ (ដែលបានមកដល់បាត់ដំបងនៅចុងឆ្នាំ១៩៧៨) ព្រាប កប (ដែលជាជនពិការភ្នែកនៅពេលនោះ និងមិនដែលបានឃើញ ឬឮអំពី "តាទិត្យ" ទេ នៅមុនពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨ នៅពេលដែលប្រពន្ធរបស់គាត់បានប្រាប់ គាត់ថា "តាទិត្យ" បានចូលរួមពិធីរៀបអាពាហ៍ពិពាហ៍ពួកគាត់) ណុប ធីម (ដែលបានមកភូមិភាគពាយ័ព្យនៅខែ មិថុនា ឆ្នាំ១៩៧៨ ហើយបីខែក្រោយមក គាត់បានរៀបការជាមួយ ព្រាប កប នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨) និង ពៅ គឿន (ដែលជាទាហានភូមិភាគពាយ័ព្យ ឈរជើងនៅអូរតាគ្រី ពីឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៧ ហើយគាត់មិនបានស្គាល់មេដឹកនាំណាមួយដែលគ្រប់គ្រងភូមិភាគ និងតំបន់ មិនដែលបានជួប "តាទិត្យ" ទេ គឺគ្រាន់តែឮឈ្មោះគាត់ ហើយមិនដឹងថានរណាជាមេដឹកនាំភូមិភាគពាយ័ព្យទេ នៅពេលដែលកម្មាភិបាលភូមិភាគនិរតីបានមកដល់))។

[1042] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៥។

[1043] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៨ (សហមេធាវីបញ្ជាក់ពីអង្គហេតុដែលថា (i) ហួន ជឿម មិនដែលធ្លាប់ធ្វើការនៅរោងចក្រស្ករសកំពង់គល់ មិនធ្លាប់ឃើញ "តាទិត្យ" ដោយផ្ទាល់ និងមិនដែលឮពីហេតុការណ៍ណាទាក់ទងនឹង "តាទិត្យ" និង (ii) ហួន ជឿម បានផ្ដល់ចម្លើយចំនួន ៩០ ទំព័រ ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ ដែលក្នុងចម្លើយទាំងនោះ គាត់មិនបានលើកឡើងពី "តាទិត្យ" ទេ ប៉ុន្តែនៅប្រាំបីឆ្នាំក្រោយមក គឺនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣ ក្រោយពេលដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានបញ្ចេញជាសាធារណៈ ដោយខុសច្បាប់នោះ ហួន ជឿម ដែលរស់នៅ ៣៥ ឆ្នាំ បន្ទាប់ពីបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ បែរជាចងចាំភ្លាមៗថា គាត់ធ្លាប់បានឮអំពី "តាទិត្យ")។

*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*

01677293



ស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញភ័ស្តុតាង និងមិនពិចារណាអំពី*ធាតុផ្សំអត្តនោម័តិ* របស់ យឹម ទិត្យ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង អំពើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ដទៃទៀត[1044]។

389. ទីបី សហមេធាវីលើកទឡ្ហីករណ៍ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ ក្នុងនាមជាផ្នែកមួយនៃមុខតំណែងរបស់គាត់នៅក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ ជាលេខាតំបន់ ១ និងតំបន់ ៤ និងដោយសារវត្តមានរបស់គាត់នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍មួយ ដែលធ្វើឡើងនៅក្នុងខែសីហា ឆ្នាំ១៩៧៨ បានគាំទ្រ និងចូលរួមចំណែកដល់គោលនយោបាយរបស់ ប.ក.ក ក្នុងការគ្រប់គ្រងទៅលើការរៀបអាពាហ៍ពិពាហ៍ ចាប់ពីយ៉ាងហោចណាស់ឆ្នាំ១៩៧៧ រហូតដល់យ៉ាងហោចណាស់ឆ្នាំ១៩៧៩[1045]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញភ័ស្តុតាង និងមិនបានពិចារណាទៅលើ*ធាតុផ្សំអត្តនោម័តិ* របស់ យឹម ទិត្យ ក្នុងការប្រព្រឹត្ត "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍"[1046]។ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ ថាតើត្រឹមតែវត្តមានរបស់ យឹម ទិត្យ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍មួយក្នុងខែសីហា ឆ្នាំ១៩៧៨ អាចកំណត់ថាជា "ការចូលរួមចំណែកយ៉ាងចម្បង" ចំពោះគោលនយោបាយបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ដែលតម្រូវដោយច្បាប់ស្តីពីសហឧក្រិដ្ឋកម្មរួមដែរឬយ៉ាងណា[1047]។

390. សហមេធាវីសន្និដ្ឋានថា ពុំមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចថា យឹម ទិត្យ "ចាប់ពីដើមឆ្នាំ១៩៧៧ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" បានរួមចំណែកដល់៖ (i) ការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាននៅក្នុងភូមិភាគពាយ័ព្យ (ii) គោលនយោបាយរបស់ ប.ក.ក លើការអប់រំរៀនសូត្រ "សមាសធាតុមិនល្អ" និងការសម្លាប់ "ខ្មាំង" និង (iii) គោលនយោបាយរបស់ ប.ក.ក ក្នុងការគ្រប់គ្រងលើការរៀប

---

[1044] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៩។

[1045] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៤១។

[1046] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៤១។

[1047] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៤២។

01677294



អាពាហ៍ ពិពាហ៍នោះឡើយ។ សហមេធាវីបញ្ជាក់ថា ការសម្រេចទាំងនេះ មានភាពអយុត្តិធម៌ និង មិនសមហេតុផលទាល់តែសោះ ដែលនាំឱ្យមានការរំលោភបំពានទៅលើឆន្ទានុសិទ្ធិ[1048]។

391. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា សហមេធាវីមិនបានបង្ហាញពីកំហុសអង្គច្បាប់ ឬ កំហុសអង្គហេតុ ដែលអាចពិនិត្យឡើងវិញបាន ឬការរំលោភបំពានទៅលើឆន្ទានុសិទ្ធិ ក្នុងការសម្រេចថា យឹម ទិត្យ ប្រហែលជាបានចូលរួមចំណែកជាចម្បងដល់សហឧក្រិដ្ឋកម្មរួម ក[1049]។ ផ្ទុយទៅនឹងយុត្តិសាស្ត្ររបស់ អ.វ.ត.ក សហមេធាវីបានបំបែកសហឧក្រិដ្ឋកម្មរួម ក ទៅជាគោលនយោបាយដ៏សំខាន់ខុសគ្នា និងបានលើកឡើងដោយប្រយោលថា ការចូលរួមចំណែកចាំបាច់ត្រូវតែធ្វើឡើងនៅក្នុងឧក្រិដ្ឋកម្មនីមួយៗ នៅក្នុងផែនការរួម[1050]។

392. ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិលើកទឡ្ហីករណ៍ថា សហមេធាវីមិនបានប៉ះពាល់ដល់ការសម្រេច ថា យឹម ទិត្យ ប្រហែលជាបានចូលរួមចំណែកយ៉ាងសំខាន់ចំពោះឧក្រិដ្ឋកម្មរួម ក តាមរយៈការចូលរួមរបស់គាត់ នៅក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន[1051]។ ទាក់ទងនឹងការចុះត្រួតពិនិត្យរបស់ យឹម ទិត្យ នៅតាមការដ្ឋាន សហមេធាវី៖ (i) មើលរំលងថា ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ទៅលើការចោទប្រកាន់ដែលបានទទួលយក មិនកម្រិតកំណត់តាមពេលវេលា នៅក្នុងភូមិភាគពាយ័ព្យ (ii) មិនបានពិចារណាថា ភ័ស្តុតាងទាក់ទងនឹងការដ្ឋានកំពីងពួយ គឺពាក់ព័ន្ធនឹងអង្គហេតុដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[1052] (iii) មានកំហុសដោយលើកឡើងថា ចាំបាច់ត្រូវតែមានសាក្សីលើសពីម្នាក់ ដែលបានឃើញ យឹម ទិត្យ នៅការដ្ឋានក្នុងឱកាសនោះ[1053] (iv) កំណត់ប្រភេទភ័ស្តុតាងរបស់សាក្សីដោយមិនត្រឹមត្រូវ ទាក់ទងនឹងវត្តមានរបស់ យឹម ទិត្យ នៅការដ្ឋានទំនប់កង្ហត[1054] និង (v) បានធ្វើការសន្និដ្ឋានដោយគ្មានមូលដ្ឋានអំពី

---

[1048] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣១, ២៤០, ២៤៣។

[1049] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣០។

[1050] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣០។

[1051] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣១។

[1052] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣២។

[1053] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣៣។

[1054] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣៣ (សហព្រះរាជអាជ្ញាអន្តរជាតិចង្អុលបង្ហាញចំពោះភ័ស្តុតាងរបស់ សោម វណ្ណា (ដែល (i) បានឃើញ យឹម ទិត្យ ឆ្លងកាត់ផ្នែក

01677295



ភ័ស្តុតាងដែលសហមេធាវីអះអាងថា "ផ្ទុយដោយផ្ទាល់" ជាមួយនឹងភ័ស្តុតាងរបស់ ហ៊ុយ ក្រឹម ទាក់ទងនឹងការចុះពិនិត្យរបស់ យឹម ទិត្យ ទៅកាន់ការដ្ឋានផ្សេងៗគ្នាជាច្រើន ដូចជា ការដ្ឋានកំពីងពួយជាដើម[1055]។

393. លើសពីនេះទៀត ទាក់ទងនឹងការចូលរួមក្នុងការប្រជុំ និងវគ្គរៀនសូត្ររបស់ យឹម ទិត្យ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហមេធាវីខកខានមិនបានវាយតម្លៃជារួមទៅលើភ័ស្តុតាង ហើយដូច្នេះធ្វើឲ្យមានការកំណត់អត្តសញ្ញាណនៃភ័ស្តុតាងនេះដោយមិនត្រឹមត្រូវថា ជា "ភ័ស្តុតាងដោះបន្ទុក និងភ័ស្តុតាងផ្ទុយ"[1056]។ លើសពីនេះទៀត ការសម្រេចថា យឹម ទិត្យ បានចូលរួមក្នុងការអនុវត្តវិន័យតឹងតែង គឺមិនគ្រាន់តែផ្អែកទៅលើភ័ស្តុតាងរបស់ សោម វណ្ណា នោះទេ ហើយទោះជាក្នុងករណីណាក៏ដោយ ក៏គាត់បានដឹងឮគ្រប់គ្រាន់អំពីវត្តមានរបស់ យឹម ទិត្យ នៅការដ្ឋានទំនប់កង្កួតផងដែរ[1057]។

394. ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិលើកទឡ្ហីករណ៍ថា សហមេធាវីមិនបានបង្ហាញអំពីកំហុសឆ្គងណាមួយ ដែលអាចពិនិត្យឡើងវិញបាននៅក្នុងការសម្រេចថា យឹម ទិត្យ ប្រហែលជាបានចូលរួម

---

នៃការដ្ឋានទំនប់កង្កួត ដែល សោម វណ្ណា ធ្វើការ ដើម្បីទៅកាន់ផ្នែកមួយទៀតនៃការដ្ឋាន (ii) បានពិភាក្សាអំពីផលប៉ះពាល់នៃវត្តមានរបស់ យឹម ទិត្យ មកលើរូបគាត់ និងពលករដទៃទៀត និង (iii) បានចូលរួមក្នុងការប្រជុំជាមួយ យឹម ទិត្យ និងប្រធានការដ្ឋាន) និង សៅ ជាប់ (ដែល (i) បានចូលរួមក្នុងការប្រជុំជាមួយ យឹម ទិត្យ នៅទំនប់កង្កួត (ii) បានបញ្ជាក់ថា "តា ទិត្យ មួយជាប់ តាម៉ុក កាលមុនខ្ញុំដើរតាម" និង (iii) បានឃើញដោយផ្ទាល់ថា យឹម ទិត្យ គឺនៅភូមិភាគពាយ័ព្យ មុនពេលកម្មាភិបាលភូមិភាគនិរតីមកដល់))។

[1055] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣៤។

[1056] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣៥ (សហព្រះរាជអាជ្ញាអន្តរជាតិបានពិភាក្សាពីភ័ស្តុតាងរបស់ លេខ ភីវ (ដែលមិនច្បាស់អំពីតួនាទីរបស់ យឹម ទិត្យ និងតាប៉ែត នៅពេលដែលពួកគាត់បានដឹកនាំការប្រជុំរួមគ្នា ប៉ុន្តែក្រោយពេលចាប់ខ្លួន តាប៉ែត លេខ ភីវ បានដឹងច្បាស់ថា យឹម ទិត្យ បានដឹកនាំការប្រជុំ ក្នុងនាមជាលេខាតំបន់ ១ ) និង ទៀប ទិត្យ (ដែល "ប្រហែល" មិនច្រឡំថា ឃើញ យឹម ទិត្យ ថាជា តាប៉ែត ទេ នៅក្នុងកិច្ចប្រជុំមួយ នៅការដ្ឋានទំនប់កង្កួត ដោយសារតែហេតុការណ៍នេះ កើតឡើងបន្ទាប់ពី តាវ៉ាញ ត្រូវបានចាប់ខ្លួននៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ ប៉ុន្តែ នៅមុនពេលចាប់ខ្លួន តាយ៉ាន នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ហើយ ទៀប ទិត្យ បញ្ជាក់ថា គាត់គ្រាន់តែឮអំពីតាប៉ែត ប៉ុន្តែមិនដែលឃើញគាត់ឡើយ))។

[1057] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣៦។

ពាក់ព័ន្ធក្នុងការកំណត់គោលដៅខ្មាំងរបស់ ប.ក.ក[1058]។ សហមេធាវីមិនបានលើកឡើងពីការសម្រេចសំខាន់ៗ ទាក់ទងនឹងការអនុវត្តគោលនយោបាយ ប.ក.ក របស់ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ[1059] បានមើលរំលងភស្តុតាង ដែលថា យឹម ទិត្យ បានទៅភូមិភាគពាយ័ព្យជាមួយកងកម្លាំងរបស់គាត់ និង តាម៉ុក ដើម្បីគ្រប់គ្រងភូមិភាគ[1060] និងមិនបានលើកឡើងពីផ្នែកសំខាន់ៗនៃភស្តុតាងរបស់ ហួន ជឿម ពាក់ព័ន្ធនឹងការចូលរួមរបស់ យឹម ទិត្យ នៅក្នុងការចាប់ខ្លួនសមាជិកគណៈកម្មាធិការរោងចក្រស្ករសកំពង់គល់[1061]។

395. ទីបី ទាក់ទងនឹងការចូលរួមរបស់ យឹម ទិត្យ ក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ថា សហមេធាវីមិនបានពន្យល់ ថាតើភស្តុតាងនៃសេចក្តីថ្លែងការណ៍ និងការប្រព្រឹត្តរបស់ យឹម ទិត្យ ដូចជា ការចូលរួមរបស់គាត់នៅមុនពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអង្គហេតុ ដែលថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងដោយរបៀបណា បន្ទាប់ពី យឹម ទិត្យ បានក្លាយជាលេខា*ដាក់ស្តែង* មិនបានគាំទ្រដល់ការសម្រេចថា គាត់បានចូលរួមចំណែកយ៉ាងសំខាន់ចំពោះសហឧក្រិដ្ឋកម្មរួម ក[1062]។

396. ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិភាក្សាអំពី*ធាតុផ្សំអត្តនោម័តិ* របស់ យឹម ទិត្យ សម្រាប់ឧក្រិដ្ឋកម្មទាំងអស់ ដែលបានកើតឡើងពីការអនុវត្តសហឧក្រិដ្ឋកម្មរួម ក[1063]។

---

[1058] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣៧។

[1059] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣៧។

[1060] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣៨។

[1061] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣៨ (សហព្រះរាជអាជ្ញាលើកឡើងថា (i) ហួន ជឿម បានធ្វើការនៅកងទ័ពភូមិភាគពាយ័ព្យ ពីពាក់កណ្តាលឆ្នាំ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨ និងបានដឹងពីកងទ័ពភូមិភាគថា យឹម ទិត្យ "ដឹកនាំកម្លាំងរបស់គាត់ដោយផ្ទាល់" ទៅរោងចក្រ (ii) ចម្លើយរបស់ ហួន ជឿម ទាក់ទងនឹងការតែងតាំង តា យ៉ាន ត្រូវបានគាំទ្រដោយសាក្សី ដែលបានធ្វើការនៅរោងចក្រ និង (iii) មជ្ឈមណ្ឌលឯកសារកម្ពុជា មិនដែលបានសួរ ហួន ជឿម អំពីការដឹងឮជាក់លាក់របស់គាត់ពី យឹម ទិត្យ ឬរោងចក្រស្ករសឡើយ)។

[1062] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៣៩។

[1063] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/27 កថាខណ្ឌ ១៤០។

01677297



## ២. ការពិភាក្សា

397. ចៅក្រមអន្តរជាតិសង្កេតឃើញថា យឹម ទិត្យ ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ អំពើអមនុស្សធម៌ដទៃទៀត និងការធ្វើទុក្ខបុកម្នេញ ដែលជាផ្នែកមួយនៃ "សហឧក្រិដ្ឋកម្មរួម ក"។ គោលបំណងរួមរបស់សហឧក្រិដ្ឋកម្មរួម ក ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិកំណត់និយមន័យថាជាការអនុវត្តគោលនយោបាយរបស់ ប.ក.ក ទាក់ទងនឹងការបង្កើតការដ្ឋាន និងសហករណ៍ ការបោសសម្អាតប្រឆាំងនឹង "ខ្មាំង" និងការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍នៅទីតាំងជាក់លាក់មួយចំនួន នៅក្នុងភូមិភាគពាយ័ព្យនៃកម្ពុជាប្រជាធិបតេយ្យ។ ជាពិសេស ទីតាំងទាំងនោះ រួមមាន ការដ្ឋានទំនប់កង្ហត សហករណ៍ធិបតី ឃុំកំពង់ព្រៀង និង ឃុំរាំងកេសី[1064]។

398. ជាបញ្ហាបឋម ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានកំណត់យ៉ាងច្បាស់លើ*ធាតុផ្សំអត្តនោម័តិ* របស់ យឹម ទិត្យ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម ក[1065]។ ជាលទ្ធផល អង្គជំនុំជម្រះបានបដិសេធការលើកឡើងរបស់សហមេធាវី ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញភស្តុតាង ឬពិចារណាអំពី*ធាតុផ្សំអត្តនោម័តិ* របស់ យឹម ទិត្យ ក្នុងការប្រព្រឹត្ត (i) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង ការដាក់ឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត ទាក់ទងនឹងការបង្កើតការដ្ឋាន និងសហករណ៍[1066] (ii) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង អំពើមនុស្សឃាត ការសម្លាប់រង្គាល

---

[1064] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០១៦។ ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា វិសាលភាពនៃសហឧក្រិដ្ឋកម្មរួម ក ត្រូវបានកំណត់ចំពោះទីតាំងដូចខាងក្រោមនៅក្នុងភូមិភាគពាយ័ព្យ៖ មន្ទីរសន្តិសុខគាស់ក្រឡ សហករណ៍ធិបតី (រួមមានមន្ទីរសន្តិសុខវត្តធិបតី និងមន្ទីរសន្តិសុខទួលម្ទេស និងការដ្ឋានទួលម្ទេស) ការដ្ឋានទំនប់កង្ហត មន្ទីរសន្តិសុខបាណន់ មន្ទីរសន្តិសុខខ្នងគូ ការដ្ឋានរោងចក្រស្ករសកំពង់គល់ ស្រុកសំឡូត មន្ទីរសន្តិសុខភ្នំវាល មន្ទីរសន្តិសុខស្វាយជ្រុំ កន្លែងសម្លាប់ទួលសេះញ៉ូវ កន្លែងសម្លាប់ព្រៃក្របៅ មន្ទីរសន្តិសុខវត្តគិរីរម្យ មន្ទីរសន្តិសុខវត្តសម្ដេច ឃុំកំពង់ព្រៀង (រួមមានភូមិកាច់រទេះ ថ្មី និងភូមិស្លាត្រាវ និងមន្ទីរសន្តិសុខវត្តពោធិ៍លង្ការ/កាច់រទេះ) ឃុំរាំងកេសី គុកលេខ៨ ទីតាំងសម្លាប់មនុស្សវាលបាក់ចិញ្ចៀន។

[1065] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០១៩, ១០២១, ១០២២, ១០២៤, ១០៤០។

[1066] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣០។

និងអំពើអមនុស្សធម៌ដទៃទៀត ទាក់ទងនឹងការបោសសម្អាត[1067] និង (iii) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សនៃបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍[1068]។

399. ជាងនេះទៅទៀត ចៅក្រមអន្តរជាតិគាំទ្រការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើភ័ស្តុតាងស្តីពីការចូលរួមចំណែករបស់ យឹម ទិត្យ ដល់សហឧក្រិដ្ឋកម្មរួម ក មុនពេលការតែងតាំងជាផ្លូវការរបស់គាត់ ក្នុងមុខតំណែង*តាមនីតិន័យ* នៅក្នុងភូមិភាគពាយ័ព្យ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានពន្យល់ថា យឹម ទិត្យ បានស្វែងយល់ជាបណ្តើរៗអំពីភូមិសាស្ត្រនៅក្នុងភូមិភាគពាយ័ព្យ និងការទទួលខុសត្រូវរបស់គាត់ក្នុងតំណែងជាលេខាតំបន់ ១ តាមរយៈការចុះទៅពិនិត្យមើលការដ្ឋាន និងចូលរួមកិច្ចប្រជុំជាមួយលេខាតំបន់ ១ មុនពេលគាត់ត្រូវបានតែងតាំងជាផ្លូវការនៅក្នុងខែមិថុនា ឆ្នាំ១៩៧៨[1069]។ ហេតុដូច្នេះ ការចោទប្រកាន់ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានសម្រេចថា យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ* នៅក្នុងភូមិភាគពាយ័ព្យ នៅមុនខែមិថុនា ឆ្នាំ១៩៧៨ នោះ មិនមានមូលដ្ឋានឡើយ[1070]។ ផ្នែកដ៏សំខាន់នៃភ័ស្តុតាងនេះដែលថា យឹម ទិត្យ បានចូលរួមចំណែកក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន មុនពេលដែលគាត់ត្រូវបានតែងតាំងជាផ្លូវការក្នុងមុខតំណែង*តាមនីតិន័យ* នៅក្នុងភូមិភាគពាយ័ព្យ អាចត្រូវបានយកមកវាយតម្លៃ[1071]។ ជាដំបូង អង្គជំនុំជម្រះពិនិត្យមើលលើទិដ្ឋភាពនៃការចូលរួមចំណែករបស់ យឹម ទិត្យ ដល់សហឧក្រិដ្ឋកម្មរួម។ បន្ទាប់មក អង្គជំនុំជម្រះនឹងពិនិត្យមើលលើតួនាទីរបស់ យឹម ទិត្យ ក្នុងការអនុវត្តគោលនយោបាយ ប.ក.ក ពាក់ព័ន្ធនឹងការ

---

[1067] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៩។

[1068] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៤១។

[1069] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៥៣-៣៥៦ និងជើងទំព័រ ៩២៧, ៩៣១។

[1070] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២២។ *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៥៣-៣៥៦, ៦៩៤-៦៩៩, ៩៩៤។

[1071] ទាក់ទងនឹងទឡ្ហីករណ៍របស់សហមេធាវី ពាក់ព័ន្ធនឹងវិសាលភាពពេលវេលា អង្គបុរេជំនុំជម្រះរំលឹកឡើងវិញថា ដូចមាននៅក្នុងមូលដ្ឋានទី ៣ *ខាងលើ* វិសាលភាពពេលវេលានៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌរបស់ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យគឺចាប់ពីដើមឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះក៏រំលឹកផងដែរថា ភ័ស្តុតាងនៅក្រៅវិសាលភាពពេលវេលានេះ អាចត្រូវបានប្រើសម្រាប់គោលបំណងផ្តាច់មុខក្នុងការវាយតម្លៃអំពីយុត្តាធិការបុគ្គល (ទោះបីភ័ស្តុតាងនេះមិនអាចធ្វើជាមូលដ្ឋានសម្រាប់ការចោទប្រកាន់ពីបទព្រហ្មទណ្ឌសម្រាប់ការជំនុំជម្រះក្តីក៏ដោយ)។ *សូមមើល* វិធាន៦៦*ស្ទួន*(៥)នៃវិធានផ្ទៃក្នុង។

បោសសម្អាត ហើយចុងក្រោយ នឹងធ្វើការពិនិត្យមើលទៅលើបទបញ្ហានៃការរៀបអាពាហ៍ពិពាហ៍។

*ក. ការចូលរួមចំណែករបស់ យឹម ទិត្យ ដល់ការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន*

400. នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកយ៉ាងចម្បងក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន នៅក្នុងភូមិភាគពាយ័ព្យ[1072]។ សហមេធាវីជំទាស់ចំពោះការសម្រេច ដែលថា យឹម ទិត្យ បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ក តាមរយៈ (i) ការពិនិត្យមើលការដ្ឋាន និងសហករណ៍ (ii) ការដឹកនាំការប្រជុំ និងការណែនាំស្តីពីការសាងសង់ និងការបង្កបង្កើនផល និង (iii) ការចូលរួមចំណែកក្នុងការជំរុញការអនុវត្តវិន័យតឹងតែងសម្រាប់កម្មករ ជាពិសេសនៅការដ្ឋានទំនប់កង្ហូត[1073]។ អង្គបុរេជំនុំជម្រះនឹងពិនិត្យទៅលើការជំទាស់ទាំងនេះម្តងៗមួយជាបន្តបន្ទាប់។

i. ការពិនិត្យមើលការដ្ឋាន និងសហករណ៍នៅក្នុងភូមិភាគពាយ័ព្យរបស់ យឹម ទិត្យ

401. សហមេធាវីបានជំទាស់ជាពិសេសទៅនឹងភ័ស្តុតាងដែលគាំទ្រដល់ការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកដល់ការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន ដោយ "ពិនិត្យ" ទីតាំងទាំងនេះ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦[1074]។ ជាពិសេស សហមេធាវីជជែកតវ៉ាលើភ័ស្តុតាងរបស់ សោម វណ្ណា, ឈឿង ប៊ាន និង សៅ ជាប់។ នៅពេលពិនិត្យឡើងវិញ អង្គបុរេជំនុំជម្រះពុំជឿលើឧទាហរណ៍ជាក់លាក់របស់សហមេធាវីឡើយ ខណៈដែលភ័ស្តុតាងផ្ទុយ ឬដោះបន្ទុក ត្រូវបានសន្មតថាមិនត្រូវបានយកមកពិចារណា។

402. ទីមួយ ការជំទាស់របស់សហមេធាវី ដែលថា សោម វណ្ណា (ជាកម្មករនៅការដ្ឋាន) មិនដែលបានឃើញ យឹម ទិត្យ នៅការដ្ឋានទំនប់កង្ហូត មិនអាចយកជាសម្អាងបានទេ។ ផ្ទុយទៅវិញ សោម

[1072] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០២១។

[1073] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២២-២៣១។

[1074] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៣។

វណ្ណា បានបញ្ជាក់ថា "យើងត្រូវប្រឹងធ្វើការ ពេលដែលឃើញ តាទិត្យ ដើរមក"[1075] និង "ពេលដែល តាទិត្យ មកការដ្ឋាន គឺតែងតែមានយោធាបីនាក់ ដើរតាមគាត់រហូត"[1076]។ ទោះបី សោម វណ្ណា មិនដឹងពីឋានៈពិតប្រាកដរបស់ យឹម ទិត្យ ក៏ដោយ ក៏គាត់អាចយល់ថា យឹម ទិត្យ ស្ថិតក្នុងមុខតំណែងមានសិទ្ធិអំណាច ដោយសារគាត់បានឃើញ យឹម ទិត្យ ដើរឆ្លងកាត់តាមការដ្ឋានរបស់គាត់ឆ្ពោះទៅកាន់ "កន្លែងរបស់មេការដ្ឋាន"[1077]។ លើសពីនេះទៀត សោម វណ្ណា បានផ្តល់សក្ខីកម្មថា "តែបើឃើញ មុខតាទិត្យ នៅពេលថ្ងៃ យប់ឡើងគឺនឹងមាន បាត់ខ្លួនមនុស្សហើយ"[1078]។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះពុំឃើញមានកំហុសអ្វីទេនៅក្នុងការ ពឹងផ្អែករបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅលើសក្ខីកម្មរបស់ សោម វណ្ណា។

403. ទីពីរ ឈឿង ប៊ាន មិនបានប្តូរភ័ស្តុតាងរបស់គាត់ ចំពោះពេលវេលាដែលគាត់បានឃើញ យឹម ទិត្យ ជាលើកដំបូង ដូចដែលសហមេធាវីបានអះអាងនោះឡើយ។ ផ្ទុយទៅវិញ ឈឿង ប៊ាន បានបញ្ជាក់ នៅក្នុងចម្លើយរបស់គាត់ថា ដំបូងគាត់បានឃើញ យឹម ទិត្យ ចុះមកពិនិត្យការដ្ឋានទំនប់កង្កួតនៅ ក្នុងខែឧសភា មិថុនា និងកក្កដា ឆ្នាំ១៩៧៨ ជាមួយ តាប៉ែត (លេខាតំបន់ ១ ចាប់ពីពាក់កណ្តាល ឆ្នាំ១៩៧៧ រហូតដល់គាត់ត្រូវបានចាប់ខ្លួននៅពាក់កណ្តាលឆ្នាំ១៩៧៨)[1079]។ បន្ទាប់មក នៅក្នុងខែ

---

[1075] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/46 ត្រង់ ERN 01032223 (ឆ.៤៣) (សេចក្តីបញ្ជាក់បន្ថែម)។

[1076] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/46 ត្រង់ ERN 01032223 (ឆ.៤១)។

[1077] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/46 ត្រង់ ERN 01032224 (ឆ.៤៤)។

[1078] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/46 ត្រង់ ERN 01032223 (ឆ.៤១)។

[1079] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/430 ត្រង់ ERN 01122419 (ឆ.១២១) ("គាត់ចាប់ផ្តើមចុះទៅការដ្ឋាននេះ [ការដ្ឋានទំនប់កង្កួត] ចាប់ពីខែមេសា ឧសភា មិថុនា កក្កដា ឆ្នាំ១៩៧៨" ដំបូង ខ្ញុំឃើញ តា ទិត្យ ទៅជាមួយ តាប៉ែត បីដង មុនពេល តាទិត្យ ឡើងធ្វើជាគណៈតំបន់។ ក្រោយមក ខ្ញុំឃើញ តាទិត្យ ធ្វើជាប្រធានអង្គប្រជុំនៅសហករណ៍)"។

កញ្ញា ឆ្នាំ១៩៧៨[1080] នៅពេល យឹម ទិត្យ ស្ថិតនៅក្នុងគណៈកម្មាធិការតំបន់ សាក្សីបានឃើញ យឹម ទិត្យ ម្តងទៀតនៅពេលដឹកនាំការប្រជុំនៅសហករណ៍ក្រឡាពាស[1081]។ សាក្សីបានបញ្ជាក់បន្ថែមទៀតថា នៅមុនការប្រជុំមួយថ្ងៃ គាត់ត្រូវបានគេប្រាប់ថា "តាទិត្យ ដែលជាគណៈតំបន់ នឹងមកធ្វើជាប្រធានកិច្ចប្រជុំ"[1082]។ ចៅក្រមអន្តរជាតិ ពុំឃើញមានកំហុសណាមួយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលពឹងផ្អែកលើសក្ខីកម្មរបស់ ឈឿង ប៊ាន ដែលថា យឹម ទិត្យ បានមកពិនិត្យមើលការដ្ឋានទំនប់កង្កួតនៅពាក់កណ្តាលឆ្នាំ១៩៧៨ នោះឡើយ។

404. ទីបី ផ្ទុយទៅនឹងការជំទាស់របស់សហមេធាវី សៅ ជាប់ អាចធ្វើការញែកចេញពីគ្នាយ៉ាងច្បាស់លាស់រវាងមនុស្សពីរនាក់ឈ្មោះ "តាទិត្យ"។ សៅ ជាប់ បញ្ជាក់ថា មនុស្សម្នាក់គឺជា "ទ័ព គាត់ធ្វើធម្មតាដូចគេ" ខណៈដែលមនុស្សម្នាក់ទៀត ដែលគាត់ធ្វើការជាមួយជាញឹកញាប់ គឺ "ជាប់ តាម៉ុក"[1083]។ សាក្សី បានផ្តល់សក្ខីកម្មថា គាត់បានឃើញ យឹម ទិត្យ ដោយផ្ទាល់ នៅពេលមកពិនិត្យមើលការដ្ឋានទំនប់កង្កួត និងការដ្ឋានទួលម្ទេសនៅក្នុងភូមិភាគពាយ័ព្យចាប់ពីឆ្នាំ១៩៧៦ រហូតដល់ឆ្នាំ១៩៧៧[1084] ហើយបានគេចខ្លួនទៅនៅក្នុងព្រៃក្នុងឆ្នាំ១៩៧៨[1085] និងមិនមែនក្នុងឆ្នាំ

---

[1080] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/430 ត្រង់ ERN 01122414 (ឆ.៩៨) ("នៅក្នុងខែសីហា ឆ្នាំ១៩៧៨ ខ្ញុំបានត្រឡប់ទៅសហករណ៍របស់ខ្ញុំវិញ ហើយនៅក្នុងខែកញ្ញា ខ្ញុំឃើញគាត់មកធ្វើជាប្រធានអង្គប្រជុំនៅក្នុងសហករណ៍របស់ខ្ញុំ")។

[1081] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/430 ត្រង់ ERN 01122412 (ឆ.៨៨) ("ខ្ញុំឃើញគាត់មកជាមួយតាប៉ែត ប៊ីរឯង មុនពេលដែល តាទិត្យ ក្លាយជាគណៈតំបន់ ក្រោយមក ខ្ញុំឃើញតាទិត្យ ធ្វើជាប្រធានអង្គប្រជុំនៅសហករណ៍ក្រឡាពាស តែពីរដងប៉ុណ្ណោះ")។

[1082] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/430 ត្រង់ ERN 01122420 (ឆ.១២៨)។

[1083] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ឯកសារ D219/956 ត្រង់ ERN 01425218 (ឆ.១០-ឆ.១១)។

[1084] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D219/763 ត្រង់ ERN 01244127 (ឆ.៧១) ("សៈ តើលោកបានឃើញតាទិត្យនៅកង្កួតក្នុងឆ្នាំណា? ឆ.៧១៖ នៅឆ្នាំ៧៦ ៧៧ហ្នឹង។ ព្រោះអីកាលណោះ លើកទំនប់ កង្កួតហ្នឹង ហើយគាត់ដឹកនាំ លើកទំនប់កង្កួតហ្នឹង")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D219/763 ត្រង់ ERN 01244137 (ឆ.១៤៦-ឆ.១៤៧) (សៈ តើលោកបានឃើញតាទិត្យចុះមកមើលការដ្ឋានទួលម្ទេសដែរឬទេ? ឆ.១៤៦៖ មើល គាត់ចុះមកមើលដែរតើការដ្ឋាន។ សៈ នៅក្នុងឆ្នាំណា? ឆ.១៤៧៖ ក្នុងឆ្នាំ៧៦-៧៧ ហ្នឹងឯង")។

១៩៧៧ ដូចដែលសហមេធាវីបានលើកឡើងនោះឡើយ[1086]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះពុំឃើញមានកំហុសឡើយ ក្នុងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា ការចូលរួមរបស់ យឹម ទិត្យ ក្នុងការបង្កើត និងការគ្រប់គ្រងការដ្ឋាន និងសហករណ៍នៅក្នុងភូមិភាគពាយ័ព្យ បានចាប់ផ្ដើមតាំងពីដើមឆ្នាំ១៩៧៦[1087]។

405. ជាចុងក្រោយ ទោះបីថាការអះអាងបញ្ជាក់មិនត្រូវបានតម្រូវឱ្យមានក៏ដោយ[1088] តាមរយៈភស្តុតាងដែលបានពិភាក្សានៅផ្នែកខាងលើ ចៅក្រមអន្តរជាតិយល់ឃើញថា មានភស្តុតាងស៊ីសង្វាក់គ្នានៃ "ការពិនិត្យ" ការដ្ឋាន និងសហករណ៍របស់ យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ ជាពិសេសទាក់ទងនឹងសកម្មភាពរបស់គាត់នៅការដ្ឋានទំនប់កង្ហតពីឆ្នាំ១៩៧៦ រហូតដល់ពាក់កណ្ដាលឆ្នាំ១៩៧៨។

406. ទាក់ទងនឹងការជំទាស់ជាក់លាក់របស់សហមេធាវី ពាក់ព័ន្ធនឹងការដ្ឋានកំពីងពួយ ជាបញ្ហាអង្គច្បាប់ ចៅក្រមអន្តរជាតិ កត់សម្គាល់ឃើញថា យឹម ទិត្យ មិនត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មនៅការដ្ឋានកំពីងពួយ និងទីតាំងដែលត្រូវបានរួមបញ្ចូលក្នុងវិសាលភាពនៃសហឧក្រិដ្ឋកម្មរួម ក នោះឡើយ[1089]។ ទោះបីជាយ៉ាងណាក៏ដោយ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអាចពឹងផ្អែកទៅលើអង្គហេតុនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ ក្នុងកម្រិតដែលភស្តុតាង

---

[1085] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៧ ឯកសារ D219/983 ត្រង់ ERN 01477645-46 (ឆ.៥៩, ឆ.៦១)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D219/763 ត្រង់ ERN 01244123 (ឆ.៤៤)។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ឯកសារ D219/956 ត្រង់ ERN 01425228 (ឆ.៦៤)។

[1086] *ផ្ទុយពី* បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៣ ជើងទំព័រ ៦៥៨។

[1087] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤០០។ *ផ្ទុយពី* បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៣។

[1088] *ផ្ទុយពី* បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៣។ *ជាទូទៅ សូមមើល* ការពិចារណាលើភស្តុតាងក្នុងមូលដ្ឋានទី ៥ *ខាងលើ*។

[1089] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ១០១២-១០១៥។ អង្គជំនុំជម្រះកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានទទួលឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅការដ្ឋានជាក់លាក់នេះទេ។ *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ឯកសារ D1 ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨។

01677303



មានការពាក់ព័ន្ធនឹងអង្គហេតុនៅក្នុងវិសាលភាពនៃសំណុំរឿង សម្រាប់គោលបំណងជាក់លាក់នៃការវាយតម្លៃលើការទទួលខុសត្រូវរបស់ជនជាប់ចោទ ដែលជាផ្នែកមួយនៃការកំណត់យុត្តាធិការបុគ្គល (ទោះបីជាអង្គហេតុនៅក្រៅវិសាលភាពទាំងនេះ មិនអាចប្រើជាមូលដ្ឋានឯករាជ្យសម្រាប់ការចោទប្រកាន់ពីបទព្រហ្មទណ្ឌសម្រាប់ការជំនុំជម្រះក្តីក៏ដោយ)[1090]។ ហេតុដូចនេះ ភស្តុតាងដែលពាក់ព័ន្ធនឹងការដ្ឋានកំពីងពួយ អាចត្រូវបានវាយតម្លៃ ក្នុងការកំណត់ថា តើ យឹម ទិត្យ ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬយ៉ាងណា។

407. ពាក់ព័ន្ធនឹងបញ្ហាផ្នែកភស្តុតាង សហមេធាវីបានកត់សម្គាល់យ៉ាងត្រឹមត្រូវថា សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ "បានពិនិត្យ" ការដ្ឋានកំពីងពួយនៅក្នុងឆ្នាំ ១៩៧៧ គឺពឹងផ្អែកជាចម្បងលើភស្តុតាងរបស់ ហ៊ុយ ក្រឹម ដែលត្រូវបានចោទប្រកាន់ថា បានមើលខ្សែភាពយន្តរបស់ ប.ក.ក ដែលបញ្ចាំងអំពី "ការពិនិត្យ" ការដ្ឋានកំពីងពួយរបស់ យឹម ទិត្យ នៅ

[1090] អង្គបុរេជំនុំជម្រះគូសបញ្ជាក់ថា គ្រប់ភស្តុតាងទាំងអស់ដែលអាចរកបាន អាចត្រូវបានពិចារណាក្នុងការវាយតម្លៃថា យឹម ទិត្យ ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការ ដែលជាបុគ្គលម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។ វិធានផ្ទៃក្នុងបញ្ជាក់ពីការសន្និដ្ឋាននេះ។ ជាឧទាហរណ៍ វិធាន ៦៦ ស្ទួន(៥) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតបញ្ចប់កិច្ចស៊ើបសួរទាក់ទងនឹងអង្គហេតុដែលត្រូវបានដកចេញ ចែងថា អង្គហេតុដែលត្រូវបានដកចេញ "នឹងមិនត្រូវប្រើជាមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់ប្រឆាំងនឹងបុគ្គលដែលស្ថិតក្រោមការស៊ើបសួរនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ឬនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលពាក់ព័ន្ធ។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេត និងភាគី អាចប្រើភស្តុតាងដែលពាក់ព័ន្ធនឹងអង្គហេតុ ដែលត្រូវបានដកចេញពីវិសាលភាពនៃកិច្ចស៊ើបសួរក្នុងកម្រិតមួយដែលភស្តុតាងទាំងនោះមានការពាក់ព័ន្ធនឹងអង្គហេតុដែលនៅសល់ផ្សេងទៀត"។ ករណីនេះគាំទ្រដល់ទស្សនាទាន ដែលថា អង្គហេតុនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ ទោះបីជាយ៉ាងណា អាចត្រូវបានពឹងផ្អែកលើក្នុងកម្រិតមួយដែលភស្តុតាងនេះមានការពាក់ព័ន្ធនឹងការកំណត់លើការទទួលខុសត្រូវរបស់ជនជាប់ចោទសម្រាប់គោលបំណងយុត្តាធិការបុគ្គលយ៉ាងតឹងរឹង ទោះបីជាអង្គហេតុនៅក្រៅវិសាលភាពទាំងនេះ មិនអាចប្រើជាមូលដ្ឋានសម្រាប់ការចោទប្រកាន់ពីបទព្រហ្មទណ្ឌសម្រាប់ការជំនុំជម្រះក្តី។ *សូមមើលផងដែរ* កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក មាត្រា ១ (ដែលកំណត់ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយយោងទៅលើ "ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្ត *ក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩")* (សេចក្តីបញ្ជាក់បន្ថែម)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១ (ដូចគ្នាផងដែរ ដែលសំដៅដល់អំឡុងពេលទាំងមូលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩)។

*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*

ក្នុងឆ្នាំ១៩៧៦[1091]។ ក៏ប៉ុន្តែ យោងទៅលើហេតុផលដូចបានបញ្ជាក់ខាងលើ ចៅក្រមអន្តរជាតិ បដិសេធការអះអាងដែលថា សក្ខីកម្មរបស់ ហ៊ុយ គ្រីម មិនគួរយកមកពិចារណា ដោយសារអះអាងថាស្ថិតនៅក្រៅវិសាលភាពពេលវេលានៃកិច្ចស៊ើបសួរ។

408. លើសពីនេះទៀត ចៅក្រមអន្តរជាតិជឿជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសក្នុងការវាយតម្លៃភ័ស្តុតាងរបស់ ហ៊ុយ គ្រីម រួមទាំងភ័ស្តុតាងផ្ទុយរបស់សាក្សីផ្សេងទៀតឡើយ[1092]។ ទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់ថា ទោះបីជា ហ៊ុយ គ្រីម បញ្ជាក់ថា គាត់បានមើលខ្សែភាពយន្តនៅក្នុងឆ្នាំ១៩៧៦ ក៏ដោយ[1093] ក៏ខ្សែភាពយន្តនោះប្រហែលជាមិនត្រូវបានថតនៅចុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨នោះដែរ បើផ្អែកលើភ័ស្តុតាងផ្សេងទៀត[1094]។ ជាឧទាហរណ៍ អ៊ឹម អាន់ បានបញ្ជាក់ថា ការសាងសង់ការដ្ឋានកំពីងពួយបានចាប់ផ្តើមនៅ "ដើមឆ្នាំ១៩៧៧ និងបញ្ចប់នៅចុងឆ្នាំ១៩៧៧")[1095]។ ទីពីរ អង្គបុរេជំនុំជម្រះ

[1091] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុយ គ្រីម ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/75 ត្រង់ ERN 00934370 (ឆ.២៩-៣៤)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀ ងួន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ ឯកសារD219/421 ត្រង់ ERN 01118807 (ឆ.១៣)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន ម៉ឺន ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ឯកសារ D219/667 ត្រង់ ERN 01200336 (ឆ.៣៥)។ ទាក់ទិននឹងភ័ស្តុតាងរបស់ ទៀ ងួន និងភ័ស្តុតាងរបស់ ហ៊ុន ម៉ឺន អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយោងទៅលើសក្ខីកម្មទាំងនេះក្នុងគោលបំណងបង្កើតទីតាំងទំនប់កំពីងពួយ និងមិនគាំទ្រដល់ការសម្រេច ដែលថា យឹម ទិត្យ បានពិនិត្យការដ្ឋានជាក់លាក់នេះ។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀ ងួន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ D219/421 ត្រង់ ERN 01118812 (ឆ.៣៩)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន ម៉ឺន ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ឯកសារ D219/667 ត្រង់ ERN 01200337 (ឆ.៤៣)។

[1092] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៥។

[1093] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុយ គ្រីម ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/75 ត្រង់ ERN 00934370 (ឆ.៣៤) ("ខ្ញុំបានមើលកុនតែម្តងទេ នៅចុងឆ្នាំ១៩៧៦ នៅពេលដែលគេធ្វើអាងរាមគន់រួចហើយ")។

[1094] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤០១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធៀម របៀប ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D219/914 ត្រង់ ERN 01388654 (ឆ.៣៩-ឆ.៤០) ("សៈ តើកុននោះគេថតនៅឆ្នាំណា? ឆ.៤០៖ ប្រហែលជាចុង៧៧ ឬ៧៨")។

[1095] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ D6.1.165 ត្រង់ ERN 00197883។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស សារិន ចុះថ្ងៃទី៥-៦ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D219/882.1.3 ត្រង់ ERN 00482794-00482795 ("ការធ្វើទស្សនកិច្ចនេះ [...] ដល់ថ្ងៃទី១៨ ខែ១១ ឆ្នាំ១៩៧៦ ទើបចប់មក។

ពុំជឿថា ភស្តុតាងរបស់ ផៀម របៀប គឺជាភស្តុតាងផ្ទុយនោះឡើយ[1096]។ សាក្សី ដែលត្រូវបានថត នៅក្នុងខ្សែភាពយន្តនេះ និងបានធ្វើការនៅកំពីងពួយក្នុងឆ្នាំ ១៩៧៧ និងឆ្នាំ១៩៧៨ បានបញ្ជាក់ថា ទោះបីជាគាត់មិនដែលបានឃើញ យឹម ទិត្យ ចុះត្រួតពិនិត្យការដ្ឋានក៏ដោយ ក៏មានទីតាំងសាងសង់ចំនួនពីរផ្សេងគ្នានៅក្នុងការដ្ឋានកំពីងពួយ ហើយថា យឹម ទិត្យ ប្រហែលជាបានចុះត្រួតពិនិត្យការដ្ឋានទីមួយ (តាគ្រាម) ដោយសារសាក្សីកំពុងធ្វើការនៅការដ្ឋានទីពីរនៅពេលនោះ[1097]។ លើសពីនេះទៀត ផៀម របៀប បានបញ្ជាក់ថា កម្មករមិនត្រូវបានអនុញ្ញាតឱ្យទៅក្បែរកម្មាភិបាលជាន់ខ្ពស់ ដែលកំពុងរៀបចំបង្កើតក្រុមការងារថតខ្សែភាពយន្តនោះឡើយ និងថាពួកគេប្រហែលជានៅតាគ្រាម[1098]។ ដូច្នេះ សក្ខីកម្មរបស់ ផៀម របៀប មិនផ្ទុយទៅនឹងសក្ខីកម្មរបស់ ហ៊ុយ គ្រឹម ដែលថា យឹម ទិត្យ បានទៅពិនិត្យមើលការដ្ឋានកំពីងពួយនោះទេ។

409. ចុងក្រោយ សហមេធាវីចង្អុលបង្ហាញពីអវត្តមាននៃឈ្មោះ ឬរូបភាពរបស់ យឹម ទិត្យ នៅក្នុងទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យ ដែលមាននៅក្នុងសំណុំរឿង ដើម្បីបដិសេធភស្តុតាងរបស់ ហ៊ុយ គ្រឹម

---

[...] ទំនប់នឹងគេហៅថាកំពីងពួយ [...] អត់ទាន់មានដងទំនប់ទេ")។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ក្រាត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D219/784 ត្រង់ ERN 01300425 (ឆ.៤៩) ("ឆ្នាំ៧៦ ឆ្នាំ៧៧ ពួកខ្ញុំទៅលើកទំនប់កំពីងពួយ")។ ទាក់ទងនឹងភស្តុតាងរបស់ មុំ ក្រាត អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយោងទៅលើសក្ខីកម្មនេះក្នុងគោលបំណងបង្កើតរយៈពេលនៃការសាងសង់ទំនប់កំពីងពួយ និងមិនគាំទ្រដល់ការសម្រេចដែលថា យឹម ទិត្យ បានត្រួតពិនិត្យ ការដ្ឋានជាក់លាក់នេះទេ។ ហេតុដូចនេះ ការដឹងឮរបស់សាក្សីអំពី យឹម ទិត្យ (ឬកង្វះការដឹងឮនោះ) គឺគ្មានផលប៉ះពាល់អ្វីទេ។ *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៥។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ក្រាត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D219/784 ត្រង់ ERN 01300425 (ឆ.៤៨) ("ខ្ញុំមិនដែលឮទេ [...] ឈ្មោះ យឹម ទិត្យ [...]")។

[1096] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៥។

[1097] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផៀម របៀប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D219/914 ត្រង់ ERN 01388654 (ឆ.៣៨)។

[1098] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផៀម របៀប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D219/914 ត្រង់ ERN 01388654-01388655 (ឆ.៤២) ("គេមិនឱ្យយើងទៅជិតទេ ត្រៀមនៅតែឆ្ងាយ។ [...] មេគេធំៗប្រហែលជានៅតាគ្រាមនោះ ដូច្នេះខ្ញុំមិនដឹងថា ពួកគេជាខ្មែរ ឬបរទេសទេ")។

[1099]។ ទោះយ៉ាងណា អង្គជំនុំជម្រះពុំជឿថា ការខកខានមិនបានកំណត់អត្តសញ្ញាណរបស់ យឹម ទិត្យ ដែលអះអាងដោយសហមេធាវី នៅក្នុងទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យ ដែលអាចរកបាន នៅក្នុងសំណុំរឿង អាចជាការបដិសេធដែលមានសុពលភាពចំពោះចម្លើយយ៉ាងលម្អិតរបស់ ហ៊ុយ ក្រឹម នោះទេ[1100]។ ក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះពុំយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រព្រឹត្តដោយមិនសមហេតុផលក្នុងការពឹងផ្អែកលើសក្ខីកម្មរបស់ ហ៊ុយ ក្រឹម នោះឡើយ យោងទៅតាមហេតុផលដូចបានបញ្ជាក់ខាងលើ និងជាពិសេស យោងតាមសំអាងហេតុរបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពាក់ព័ន្ធនឹងភាពមិនស៊ីសង្វាក់គ្នានៃពេលវេលា[1101]។

ii. ការប្រជុំ និងការណែនាំស្ដីពីការសាងសង់ និងការបង្កបង្កើនផលរបស់ យឹម ទិត្យ

410. សហមេធាវីសង្កត់បញ្ជាក់លើភស្តុតាងផ្ទុយ និងភស្តុតាងដោះបន្ទុក ដែលត្រូវបានចោទប្រកាន់ ពីសាក្សីបួននាក់ ដែលបានដកស្រង់ក្នុងការគាំទ្រដល់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ បានដឹកនាំកិច្ចប្រជុំ ផ្ដល់ការណែនាំស្ដីពីការសាងសង់ និងការបង្កបង្កើនផល ហើយ "បាន ជំរុញការអនុវត្តគោលនយោបាយសេដ្ឋកិច្ចរបស់ ប.ក.ក" ចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៦[1102]។

---

[1099] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ុយ ក្រឹម ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/75 ត្រង់ ERN 00934370 (ឆ.២៩-ឆ.៣១) ("តើលោកចាំថា ទស្សនាវដ្ដីនោះ និយាយអំពីអ្វីទាក់ទងនឹង តាទិត ដែរឬទេ? ឆ៖២៩ គេនិយាយពីការដែល[គាត់] និងទាហាន[ចុះ]ទៅត្រួតពិនិត្យផ្លូវរថភ្លើង និងការលើកទំនប់ ប្រឡាយ និងអាងស្ដុកទឹករាមគន់")។

[1100] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ុយ ក្រឹម ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/75 ត្រង់ ERN 00934370 (ឆ.២៧) ("ខ្ញុំនិយាយដូចនេះ ដោយសារតែពួកឈ្លប ដែលមកយកទឹកត្នោតជូរនៅកន្លែងខ្ញុំ គេយកទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យឲ្យខ្ញុំមើល ហើយនៅក្នុងទស្សនាវដ្ដីនោះមានរូប តាទិត")។

[1101] អង្គបុរេជំនុំជម្រះច្រានចោលដោយសង្ខេបនូវសេចក្ដីសន្និដ្ឋានចោទប្រកាន់ដែលមាននៅក្នុងកថាខណ្ឌ ២២៦ នៃបណ្ដឹងឧទ្ធរណ៍។

[1102] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៧ *ដែលយោងទៅ* លេខ ភីវ, ឌុស ដឿន, ជុច ពន្លក និង ទៀប ទិត្យ។ សហមេធាវី ក៏បានយោងដល់ចម្លើយរបស់ សោម វណ្ណា ដែលថា គាត់មិនដែលបានឃើញ យឹម ទិត្យ ចូលរួមក្នុងការប្រជុំនៅការដ្ឋានទំនប់កង្ហតទេនៅកថាខណ្ឌខាងលើ។ *សូមមើលខាងលើនេះ* កថាខណ្ឌ ២២៣។

411. ទីមួយ ពាក់ព័ន្ធនឹងភ័ស្តុតាងដោះបន្ទុករបស់ សោម វណ្ណា ដែលបានអះអាង[1103] និងចម្លើយរបស់ ជុច ពន្លក ដែលថា យឹម ទិត្យ "បានធ្វើការដូចគេឯងដែរ" "ធ្វើការជាមួយប្រជាជនសាមញ្ញ" និង "មិនមែនជាមេដឹកនាំអ្វីទេ"[1104] ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា សាក្សីទាំងពីរនាក់ បានផ្តល់ភ័ស្តុតាងផ្សេងគ្នានៅពេលក្រោយមក នៅក្នុងការស្តាប់ចម្លើយក្រោយៗមកទៀត ដែលបានផ្តល់សក្ខីកម្មស្តីពីការចូលរួមរបស់ យឹម ទិត្យ ក្នុងការប្រជុំ និងការផ្តល់ការណែនាំស្តីពីការងារបង្កបង្កើនផល[1105]។ ចៅក្រមអន្តរជាតិពិចារណាឃើញថា ការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើចម្លើយរបស់ ជុច ពន្លក ពុំមែនមិនសមហេតុផលនោះទេ បើយោងតាមបរិបទ និងភ័ស្តុតាងទាំងមូល[1106]។

412. ទីពីរ ចៅក្រមអន្តរជាតិសង្កេតឃើញថា ទោះបី លេខ ភីវ (ដែលធ្វើការងារក្នុងមុខតំណែងជាប្រធានសហករណ៍ភ្នំធិបតីក្នុងឆ្នាំ១៩៧៧) មិនដឹងច្បាស់លាស់ពីតួនាទីពិតប្រាកដរបស់ យឹម ទិត្យ ពាក់ព័ន្ធនឹង តាប៉ែត ក៏ដោយ ក៏គាត់បានកំណត់អត្តសញ្ញាណ យ៉ាងច្បាស់ថា យឹម ទិត្យ និង

---

[1103] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/46 ត្រង់ ERN 01032224 (ឆ.៤៧) ("នៅក្នុងការប្រជុំ៤ដង ដែលលោកបានចូលរួមនៅកង្គត តើលោកធ្លាប់ឮថា តាទិត្យ បានចូលរួមក្នុងការងារប្រជុំទាំងនេះដែរឬទេ? ឆ.៤៧៖ ខ្ញុំមិនដែលឮទេ")។

[1104] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុច ពន្លក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១ ឯកសារ D22 ត្រង់ ERN 00699634-00699634។

[1105] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/239 ត្រង់ ERN 01080875 (ឆ.១៣) ("គេ [យឹម ទិត្យ និង តាស៊ួ] និយាយថា កង់បដិវត្តន៍កំពុងវិល។ បើសិនជាអ្នកណាដើរពុំទាន់កង់បដិវត្តនេះទេ វានឹងកិនបំបែកយើងជាមិនខាន។ ក្នុងការប្រជុំធំ មានគ្នាច្រើន តាទិត្យ ហើយនិង តាស៊ួ បាននិយាយអំពីរឿងទាំងនេះ ដាក់មីក្រូពីចម្ងាយ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុច ពន្លក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/76 ត្រង់ ERN 00934379 (ឆ.៤២) ("តើលោកដែលចូលរួមប្រជុំណា ដែលចូលរួមដោយតាទិត ដែរឬទេ? ឆ.៤២៖ ខ្ញុំធ្លាប់ប្រជុំជាមួយតាទិត នៅកន្លែងការដ្ឋាននៅគោកអំពិលតែម្តង [...]។ ប្រធានអង្គប្រជុំគឺប្រធានការដ្ឋានរបស់ខ្ញុំ តែគេអញ្ជើញតាទិត ឲ្យចូលរួម ហើយឲ្យគាត់និយាយបន្ថែមកន្លែងណាដែលខ្វះខាត។ គាត់និយាយថា ឲ្យយើងជួយធ្វើការងារបង្កបង្កើនផលសម្រាប់អង្គការ ហើយគាត់ជំរុញឲ្យប្រជាជនខំធ្វើការ ខ្ញុំគិតថា តាទិត គាត់អាចមានតួនាទីអ្វីផ្សេងមួយនៅកន្លែងនេះ")។

[1106] *សូមមើល* សាលដីកាសំណុំរឿង ០០២/១ ឯកសារ F36 កថាខណ្ឌ ៣៥៧ ("អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ផ្អែកលើកាលៈទេសៈនៃរឿងក្តីនេះ ជាទូទៅ ពុំមែនជាការមិនសមហេតុផលទេ ដែលអង្គជំនុំជម្រះសាលាដំបូងទទួលយកសក្ខីកម្មរបស់សាក្សីមួយផ្នែក ហើយបដិសេធផ្នែកផងទៀត")។ *ជាទូទៅ សូមមើល* ការពិចារណាលើភ័ស្តុតាងក្នុងមូលដ្ឋានទី ៥ *ខាងលើ*។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

01677308



តាប៉ែត គឺស្ថិតនៅក្នុងគណៈកម្មាធិការតំបន់ ១ ក្នុងឆ្នាំ១៩៧៧ នៅក្នុងសក្ខីកម្មរបស់គាត់[1107]។ ជាងនេះទៅទៀត លេខ ភីវ បានបញ្ជាក់ថា យឹម ទិត្យ កាន់កាប់តួនាទីរបស់ តាប៉ែត បន្ទាប់ពីការបាត់ខ្លួនរបស់ តាប៉ែត ក្នុងរដូវវស្សាឆ្នាំ១៩៧៨ និងបានក្លាយជាលេខាតំបន់ ១[1108]។ សាក្សីបានផ្តល់សក្ខីកម្មពាក់ព័ន្ធថា យឹម ទិត្យ បានដឹកនាំការប្រជុំនៅចុងឆ្នាំ១៩៧៨ និងបាននិយាយអំពី "គោលនយោបាយទាក់ទងនឹងការបង្កបង្កើនផល" និងជំរុញឲ្យមានការជឿជាក់លើ ប.ក.ក[1109]។

413. ទីបី ចៅក្រមអន្តរជាតិ ពុំជឿថា ចម្លើយរបស់ ដុស ឌឿន ដែលថា យឹម ទិត្យ គឺជាកម្មាភិបាលភូមិភាគ ពាយ័ព្យ ទទួលបន្ទុកឃុំកន្ទឺមួយ ក្នុងស្រុកបាណន់ គឺជាភ័ស្តុតាងផ្ទុយឡើយ[1110]។ ផ្ទុយទៅវិញ នៅពេលធ្វើការពិចារណាលើភ័ស្តុតាងរបស់ ដុស ឌឿន ទាំងមូល អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សាក្សីបាននិយាយសំដៅដល់ យឹម ទិត្យ យ៉ាងច្បាស់ ដោយបញ្ជាក់ថា យឹម ទិត្យ មានសិទ្ធិអំណាចក្នុងការគ្រប់គ្រងលើការដ្ឋានក្នុងតំបន់១ និងមិនត្រូវបានដកចេញទេ បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីបានមកដល់[1111]។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកដោយសមហេតុផលទៅលើសក្ខីកម្មរបស់ ដុស ឌឿន ដើម្បីបញ្ជាក់ថា យឹម ទិត្យ បាន

[1107] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/236 ត្រង់ ERN 01080844 (ឆ.១៨)។ 01080841 (ឆ.១)។

[1108] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/210 ត្រង់ ERN 01074048 (ឆ.៥-ឆ៦)។

[1109] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/210 ត្រង់ ERN 01074048 (ឆ.៤-ឆ.៨)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាម សោម ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D118/149 ត្រង់ ERN 00967985 (ឆ.២៤-ឆ.២៥)។

[1110] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុស ឌឿន ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D219/797 ត្រង់ ERN 01305017 (ឆ.២១៣)។

[1111] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុស ឌឿន ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D219/797 ត្រង់ ERN 01305017-01305018 (ឆ.២១៥-ឆ.២២០)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុស ឌឿន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D219/698 ត្រង់ ERN 01210567 (ឆ.៥៩) ("ជួនកាលគាត់ [យឹម ទិត្យ] នៅបាណន់ ជួនកាលនៅកម្ពួត គាត់ដើរទៅហើយប្រជាជនដឹកប្រឡាយ"។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុស ឌឿន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D219/698 ត្រង់ ERN 01210568 (ឆ.៥៨)។

ដឹកនាំកិច្ចប្រជុំ និងបានផ្តល់ការណែនាំស្តីពីការសាងសង់នៅស្រុកបាណន់ក្នុងឆ្នាំ១៩៧៦ ឬឆ្នាំ១៩៧៧[1112]។

414. ជាចុងក្រោយ ការអះអាងដែលថា ទៀប ទិត មានការភាន់ច្រឡំរវាង យឹម ទិត្យ និងតាប៉ែត គឺពុំមានមូលដ្ឋានឡើយ[1113]។ ទោះបីសាក្សីបានបញ្ជាក់ថា គាត់បានឃើញ យឹម ទិត្យ តែម្តងគត់នៅក្នុងសក្ខីកម្មរបស់គាត់ទាំងពីរក៏ដោយ[1114] ក៏ការវិភាគយ៉ាងយកចិត្តទុកដាក់លើចម្លើយរបស់គាត់បង្ហាញថាគាត់ពិតជាបាននិយាយសំដៅទៅលើការប្រជុំពីរផ្សេងគ្នា ដែល យឹម ទិត្យ មានវត្តមាន។ តាមពិត កិច្ចប្រជុំមួយត្រូវបានធ្វើឡើងជាមួយ តាវ៉ាញ (លេខាតំបន់ ១ ចាប់ពីឆ្នាំ១៩៧៦ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៧) ក្នុងអំឡុងកិច្ចប្រជុំមហាសន្និបាតមួយ ហើយកិច្ចប្រជុំមួយទៀតត្រូវបានធ្វើឡើងបន្ទាប់ពីការចាប់ខ្លួន តាវ៉ាញ នៅការដ្ឋានទំនប់កង្កត ក្នុងខែមិថុនា ឆ្នាំ១៩៧៧[1115] សម្រាប់របៀបវារៈផ្សេងដែល យឹម ទិត្យ បានផ្តល់"ចំណាប់អារម្មណ៍"ក្នុងអំឡុងការបើកការដ្ឋាននេះ[1116]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា តាប៉ែត បានជំនួស តាវ៉ាញ ប្រហែលនៅពាក់កណ្តាលឆ្នាំ១៩៧៧ ហើយក្រោយមកត្រូវបានចាប់ខ្លួននៅក្នុងខែសីហា ឆ្នាំ១៩៧៨[1117]។ ហេតុដូចនេះ ទៀប ទិត បានឃើញ យឹម ទិត្យ និយាយជាមួយ តាវ៉ាញ រួចហើយនៅក្នុងមហាសន្និបាត មុនពេលចាប់ខ្លួនគាត់ និងបានស្គាល់ យឹម ទិត្យ មុនពេល តាប៉ែត ក្លាយជា

---

[1112] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤០៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុស ឌឿន ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D219/698 ត្រង់ ERN 01210567-01210568 (ឆ.៥២-ឆ.៥៦) ("ការប្រជុំនោះ គេធ្វើនៅឆ្នាំណាដែរ? ឆ.៥៦៖ ឆ្នាំ ៧៦, ៧៧ គេប្រជុំ [នៅក្នុងស្រុកបាណន់]ឲ្យកាប់ប្រឡាយទឹក")។

[1113] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៧។

[1114] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ឯកសារ D219/464 ត្រង់ ERN 01132055 (ឆ.៣៤)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D118/138 ត្រង់ ERN 00960693 (ឆ.៣៧)។

[1115] បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស ឯកសារ D219/825.1.2, ERN (ភាសាអង់គ្លេស) 01222369។

[1116] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ឯកសារ D219/464 ត្រង់ ERN 01132055 (ឆ.៣៤-ឆ.៣៨) ("គេប្រជុំនៅការដ្ឋានទំនប់កង្កត [...] ជាកិច្ចប្រជុំបើកការដ្ឋាន ហើយតាទិត្យ ត្រូវបានគេអញ្ជើញឲ្យឡើងធ្វើចំណាប់អារម្មណ៍")។

[1117] បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស ឯកសារ D219/825.1.2, ERN (ភាសាអង់គ្លេស) 01222369។ ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៣៦១-៣៦២។

លេខាតំបន់ ១។ អង្គជំនុំជម្រះច្រានចោលនូវការអះអាងដែលថាទៀប ទិត "ប្រហែលជាច្រលំ" យឹម ទិត្យ ជាមួយនឹង តាប៉ែត[1118]។

415. សរុបសេចក្ដីមក អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុស ឡើយ ទាក់ទងនឹងការសម្រេចជារួមថា យឹម ទិត បានដឹកនាំការប្រជុំ និងវគ្គរៀនសូត្រនៅតាមការដ្ឋាន និងសហករណ៍ ក្នុងការជួយជ្រោមជ្រែងដល់សហឧក្រិដ្ឋកម្មរួម ក[1119]។

### iii. ការអនុវត្តវិន័យតឹងតែង

416. ទីមួយ សហមេធាវីយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកក្នុងការអនុវត្តវិន័យតឹងតែងទៅលើកម្មករ ជាពិសេស នៅការដ្ឋានទំនប់កង្ហូត ដោយពឹងផ្អែកទៅលើសាក្សីតែម្នាក់ និងមិនពិចារណាលើភ័ស្តុតាងផ្ទុយ និងភ័ស្តុតាងដោះបន្ទុក[1120]។ ចៅក្រមអន្តរជាតិច្រានចោលការអះអាងដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកតែទៅលើសក្ខីកម្មរបស់ សោម វណ្ណា[1121] ពីព្រោះគាត់ក៏បាននិយាយយោងទៅលើសក្ខីកម្មរបស់ តុប សឹង ទាក់ទងនឹងការចូលរួមចំណែករបស់ យឹម ទិត្យ ក្នុងការជំរុញការអនុវត្តវិន័យនៅការដ្ឋានទំនប់កង្ហូតផងដែរ[1122]។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះពុំជឿថាភ័ស្តុតាងរបស់ សោម វណ្ណា គឺជាភ័ស្តុតាងដោះបន្ទុក និងផ្ទុយនោះឡើយ។ ការអះអាងរបស់

---

1118 *ផ្ទុយពី* បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៧។

1119 ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤០២-៤០៥។

1120 បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៨។

1121 ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤០៧ ជើងទំព័រ ១០៧៨ និង ១០៧៩ *ដែលយោងទៅ ជាអាទិ៍* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ D219/239 ត្រង់ ERN 01080875 (ឆ.១៣) ("គេ [យឹម ទិត្យ និង តាស្ញ៉] និយាយថា កង់បដិវត្តន៍កំពុងវិល។ បើសិនជាអ្នកណាដើរពុំទាន់កង់បដិវត្តនេះទេ វានឹងកិនបំបែកយើងជាមិនខាន")។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/46 ត្រង់ ERN 01032223 (ឆ.៤១) ("តែបើឃើញមុខ តាទិត្យ នៅពេលថ្ងៃ យប់ឡើងគឺនឹងមានបាត់ខ្លួនមនុស្សហើយ")។

1122 ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤០៨ ជើងទំព័រ ១០៨០ *ដែលយោងទៅ ជាអាទិ៍* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តុប សឹង ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/117 ត្រង់ ERN 01046475 (ឆ.១៥២-ឆ.១៥៣) ("រាល់ពេលដែលតាទិត្យ មកជួបជាមួយនឹង យ៉េ ហើយយ៉េ តែងតែប្រជុំដើម្បីជំរុញឱ្យយើងធ្វើការកាន់តែខ្លាំងក្លាថែមទៀត" [...] "គាត់ក៏បាននិយាយថា បើសិនជាមនុស្សឈឺ ញឹកនោះ នឹងត្រូវចាត់ទុកថាជាសកម្មភាពមួយរបស់ខ្មាំង")។

សហមេធាវីដែលថា សាក្សីមិនដែលបានឃើញ យឹម ទិត្យ នៅការដ្ឋានទំនប់កង្កួត មិនអាចយកជាសម្អាងបានឡើយ។ ផ្ទុយទៅវិញ សោម វណ្ណា បានបញ្ជាក់ថា "យើងត្រូវប្រឹងធ្វើការ ពេលដែលឃើញតាទិត្យដើរមក"[1123] និង "ពេលដែល តាទិត្យ មកការដ្ឋាន គឺតែងតែមានឃោធាបីនាក់ដើរតាមគាត់រហូត"[1124]។ ទោះបី សោម វណ្ណា មិនដឹងពីឋានៈពិតប្រាកដ របស់ យឹម ទិត្យ ក៏ដោយ ក៏សាក្សីរូបនេះ អាចយល់ថា យឹម ទិត្យ ស្ថិតក្នុងមុខតំណែងមានសិទ្ធិអំណាច ដោយសារគាត់បានឃើញ យឹម ទិត្យ ដើរឆ្លងកាត់តាមការដ្ឋានរបស់គាត់ ឆ្ពោះទៅកាន់ "កន្លែងរបស់មេការដ្ឋាន"[1125]។ លើសពីនេះទៀត សោម វណ្ណា បានផ្តល់សក្ខីកម្មថា "តែបើឃើញមុខតាទិត្យ នៅពេលថ្ងៃ យប់ឡើងគឺនឹងមានបាត់ខ្លួនមនុស្សហើយ"[1126]។ អង្គជំនុំជម្រះពុំឃើញមានកំហុសអ្វីទេ នៅក្នុងការពឹងផ្អែករបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅលើសក្ខីកម្មរបស់ សោម វណ្ណា ដោយផ្អែកលើមូលដ្ឋាននេះ។ ជាងនេះទៅទៀត ផ្ទុយទៅនឹងការអះអាងរបស់សហមេធាវី[1127] អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿង គាំទ្រដល់ការចូលរួមរបស់ យឹម ទិត្យ ក្នុងការអនុវត្តវិន័យសម្រាប់កម្មករនៅក្នុងភូមិភាគពាយ័ព្យ[1128]។

---

[1123] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/46 ត្រង់ ERN 01032223 (ឆ.៤៣) (សេចក្តីបញ្ជាក់បន្ថែម)។

[1124] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/46 ត្រង់ ERN 01032223 (ឆ.៤១)។

[1125] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/46 ត្រង់ ERN 01032224 (ឆ.៤៥)។

[1126] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/46 ត្រង់ ERN 01032223 (ឆ.៤១)។

[1127] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២២៨។

[1128] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុស ឌឿន ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ D219/797 ត្រង់ ERN 01305018 (ឆ.២១៨-ឆ.២១៩) ("គាត់ [យឹម ទិត្យ] ដើរ និងត្រួតអ្នកធ្វើការ" [...] "បើអ្នកណាខ្ជិលច្រអូស ដឹងតែវៃចោលហើយ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/64 ត្រង់ ERN 01037176 (ឆ.៣០) ("ខ្ញុំឮគេនិយាយថា តាទិត្យ បានបញ្ជាទៅ តាគីថា "បើដាំកប្បាសមិនបាន! ដង្កូវស៊ីកប្បាស ដង្កូវនឹងស៊ីមនុស្សទៀត"។ បន្ទាប់មក តាគី ក៏ខំប្រឹងប្រែងធ្វើការខ្លាំងណាស់")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D219/689 ត្រង់ ERN 01205202 (ឆ.១៧) ("កាលហ្នឹង តាទិត្យ ចូលទៅគ្រប់គ្រងនៅហ្នឹងហើយ ពេលនោះគឺរៀនសូត្ររាល់ថ្ងៃ។ ខ្ញុំចាំឆ្នាំ១៩៧៧ តែអត់ចាំខែ")។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

417. ទីពីរ ទាក់ទងនឹងវត្តមានរបស់ យឹម ទិត្យ នៅតាមការដ្ឋានក្នុងភូមិភាគពាយ័ព្យ អង្គជំនុំជម្រះរំលឹកឡើងវិញថា វត្តមាននៅទីតាំងឧក្រិដ្ឋកម្ម មិនមែនជាលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួម ឬការរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្មរួមទេ[1129]។ លើសពីនេះទៀត ទោះបីសហមេធាវីកត់សម្គាល់យ៉ាងត្រឹមត្រូវថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអាចរកឃើញភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជាក់ថា យឹម ទិត្យ បានទៅត្រួតពិនិត្យរោងចក្រស្ករសកំពង់គល់[1130] ឃុំកំពង់ព្រៀង ឬវាំងកេសី[1131]ក៏ដោយ ក៏ការអះអាងរបស់សហមេធាវី ទាក់ទិននឹងសហករណ៍ធិបតី មិនអាចយកជាសម្អាងបានឡើយ។ ផ្ទុយទៅវិញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបញ្ជាក់យ៉ាងច្បាស់ថា "សាក្សីម្នាក់បានចូលរួមពិនិត្យទីតាំងផ្ទាល់ជាមួយ យឹម ទិត្យ នៅសហករណ៍ភ្នំធិបតី រួមមានទួលម្មេស" និង "សាក្សីម្នាក់ទៀតបញ្ជាក់ថា យឹម ទិត្យ ជួបប្រជុំនៅទួលម្មេសមួយលើក"[1132]។

418. សរុបសេចក្តីមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំមានកំហុសឡើយ ក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញឱ្យអនុវត្តវិន័យតឹងតែងចំពោះកម្មករ ជាពិសេសនៅការដ្ឋានទំនប់កង្ហត[1133]។

---

[1129] តុលាការ ICTY *រដ្ឋអាជ្ញា តទល់នឹង* *Kvočka* *និងអ្នកផ្សេងទៀត* IT-98-30/1-A សាលដីកាចៅក្រមអន្តរជាតិសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ ("សាលដីកានៃរឿងក្តី *Kvočka* (តុលាការ ICTY)") កថាខណ្ឌ ១១២ ("អង្គជំនុំជម្រះសាលាឧទ្ធរណ៍បញ្ជាក់ថា សហចារីនៅក្នុងសហឧក្រិដ្ឋកម្មរួម មិនចាំបាច់ប្រព្រឹត្តដោយផ្ទាល់នូវផ្នែកណាមួយ*នៃធាតុផ្សំអង្គនោម័តិ* នៃឧក្រិដ្ឋកម្មដែលពាក់ព័ន្ធឡើយ។ ម្យ៉ាងវិញទៀត អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ក៏មិនតម្រូវឱ្យមានវត្តមានដោយផ្ទាល់នៅពេល និងនៅទីកន្លែងដែលឧក្រិដ្ឋកម្មកំពុងត្រូវបានប្រព្រឹត្តនោះឡើយ")។

[1130] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៧៩៦។

[1131] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៩២០។

[1132] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៦៥០-៦៥១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D219/763 ត្រង់ ERN 01244136 (ឆ.១៣៩) ("សៈ នៅពេលដែលតាម៉ុកចុះមកមើលទំនប់កង្ហត សហករណ៍ភ្នំធិបតី តើតាទិត្យមកជាមួយតាម៉ុក ដែរឬទេ? ឆ.១៣៩៖ មកទាំងអស់គ្នាក្រោយពេលប្រជុំហើយ គាត់ចុះមកមើលទាំងអស់គ្នាតែម្តង")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូម លិន ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ ឯកសារ D219/943 ត្រង់ ERN 01415376-01415377 (ឆ.២៩-ឆ.៣៧) ("សៈ ម្សិលមិញលោកស្រីនិយាយថា លោកស្រីឃើញតាទិត្យ នៅក្នុងពេលប្រជុំមួយ។ តើត្រឹមត្រូវទេ? ឆ.២៩៖ ចាស ឃើញនៅកិច្ចប្រជុំមួយ។ [...] សៈ តើកិច្ចប្រជុំហ្នឹងធ្វើនៅឯណា? [...] ឆ.៣១៖ [...] គេប្រជុំនៅទួលម្មេស")។

[1133] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៥០៦។

### iv. សេចក្ដីសន្និដ្ឋាន

419. ពាក់ព័ន្ធនឹងការសម្រេចដែលថា យឹម ទិត្យ (i) បានពិនិត្យមើលការដ្ឋាន និងសហករណ៍នៅក្នុងភូមិភាគពាយ័ព្យ (ii) ដឹកនាំការប្រជុំ និងផ្ដល់ការណែនាំស្ដីពីការសាងសង់ និងការបង្កបង្កើនផល និង (iii) បានចូលរួមចំណែកក្នុងការជំរុញការអនុវត្តវិន័យតឹងតែងសម្រាប់កម្មករ ជាពិសេសនៅការដ្ឋានទំនប់កង្ហត ដូចបានរៀបរាប់ខាងលើ ចៅក្រមអន្តរជាតិសម្រេចបដិសេធការអះអាងរបស់សហមេធាវី ដែលថា មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់អាចធ្វើការសម្រេចថា យឹម ទិត្យ បានចូលរួមយ៉ាងចម្បងនៅក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាននៅក្នុងភូមិភាគពាយ័ព្យ ចាប់ពីដើមឆ្នាំ១៩៧៧ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[1134]។

### *ខ. ការចូលរួមចំណែករបស់ យឹម ទិត្យ ការបោសសម្អាត និងការកំណត់គោលដៅលើក្រុមជាក់លាក់*

420. សហមេធាវីជំទាស់នឹងការសម្រេច ដែលថា យឹម ទិត្យ បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួមក តាមរយៈ (i) ការបញ្ជាឱ្យជ្រើសរើស និងបញ្ជូនកម្មាភិបាលភូមិភាគនិរតី ចន្លោះពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ ដើម្បីត្រួតត្រាភូមិភាគពាយ័ព្យ និងចាត់តាំងកម្មាភិបាលភូមិភាគនិរតីមួយចំនួនតូចឱ្យទៅបំពេញការងារជាមួយកម្មាភិបាលភូមិភាគពាយ័ព្យនៅក្នុងឆ្នាំ១៩៧៦ (ii) នៅពាក់កណ្ដាលឆ្នាំ១៩៧៧ ការស្វាគមន៍កម្មាភិបាលភូមិភាគនិរតី នៅពេលដែលពួកគេមកដល់បាត់ដំបង ហើយចាត់តាំងពួកគេទៅជំនួសកម្មាភិបាលនៅតាមទីកន្លែងផ្សេងៗជាច្រើននៅក្នុងភូមិភាគពាយ័ព្យ និង )iii) រៀបចំការបោសសម្អាត និងការសម្លាប់នៅក្នុងភូមិភាគពាយ័ព្យ រួមទាំងការចាប់ខ្លួន "ប្រធាន" កងវរសេនាតូចពីររូប ដែលគ្រប់គ្រងលើការដ្ឋានរោងចក្រស្ករសកំពង់គល់។ អង្គបុរេជំនុំជម្រះនឹងពិនិត្យទៅលើការជំទាស់ទាំងនេះម្ដងៗមួយជាបន្តបន្ទាប់។

#### i. ការចូលរួមរបស់ យឹម ទិត្យ ក្នុងការជ្រើសរើស បញ្ជូន និងចាត់តាំងកម្មាភិបាលភូមិភាគនិរតីទៅកាន់ ភូមិភាគពាយ័ព្យ

---

[1134] *ផ្ទុយពី* បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣១។

421. *ទីមួយ* ពាក់ព័ន្ធនឹងការបញ្ជារបស់ យឹម ទិត្យ ឲ្យជ្រើសរើស និងបញ្ជូនកម្មាភិបាលភូមិភាគនិរតី[1135] ចៅក្រមអន្តរជាតិពុំឃើញមានកំហុសណាមួយនៅក្នុងការពិចារណាលើភ័ស្តុតាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទិននឹងសកម្មភាពរបស់ តាម៉ុក និង យឹម ទិត្យ នោះឡើយ[1136]។ ជាការពាក់ព័ន្ធ ហែម មឿន (ដែលត្រូវបានគេនិយាយសំដៅថាជាក្មួយប្រុសរបស់ តាម៉ុក) បានផ្តល់សក្ខីកម្មថា "តាទិត បានយកកម្លាំងទាហានរបស់ខ្លួនឯងពីតាកែវមកជាមួយ តាម៉ុក។ នៅបាត់ដំបង គឺមានតែតាទិត ប៉ុណ្ណោះ ដែលធំជាងគេបន្ទាប់ពី តាម៉ុក។ ប្រសិនបើ តាម៉ុក មិននៅ គឺ តាទិត ជាអ្នកទទួលខុសត្រូវភូមិភាគពាយ័ព្យ" ហើយគាត់បានពន្យល់ថា "ដោយសារគេមកបោសសម្អាតភូមិភាគពាយ័ព្យ ដូច្នេះហើយទើបគេឲ្យយើងមកគ្រប់គ្រងនៅភូមិភាគពាយ័ព្យវិញម្តង។ មានតែពួកកម្មាភិបាល និងយោធានិរតីទេ ដែលគេបញ្ជូនមកគ្រប់គ្រងនៅពាយ័ព្យ"[1137]។ ចៅក្រមអន្តរជាតិយល់ឃើញថា សក្ខីកម្មនេះបង្ហាញឲ្យឃើញច្បាស់ពីតួនាទីរបស់ យឹម ទិត្យ ក្នុងការបោសសម្អាត និងទំនាក់ទំនងរបស់គាត់ជាមួយ តាម៉ុក។ ម្យ៉ាងវិញទៀត កង្វះនូវការនិយាយសំដៅដល់ យឹម ទិត្យ នៅក្នុងឯកសាររបស់ ប.ក.ក ដែលត្រូវបានដកស្រង់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1138] ពុំបានបង្កើតជាកំហុសណាមួយឡើយ ពីព្រោះឯកសារទាំងនេះ ត្រូវបានយោង ដើម្បីគាំទ្រដល់ការសម្រេចស្តីពីគោលនយោបាយរបស់ ប.ក.ក ទាក់ទងនឹងការបោសសម្អាតនៅក្នុងភូមិភាគពាយ័ព្យនៅមុនការមកដល់របស់ យឹម ទិត្យ[1139]។

422. ទីពីរ ការអះអាងរបស់សហមេធាវី ដែលថា គ្មានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីដែលត្រូវបានដកស្រង់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានផ្តល់ភ័ស្តុតាងបញ្ជាក់ថា យឹម ទិត្យ បានចូលរួមក្នុងការបោសសម្អាតនោះ គឺមិនត្រឹមត្រូវឡើយ[1140]។ ទោះបីសាក្សីភាគច្រើន

---

[1135] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២៩៦។

[1136] *ជាទូទៅ សូមមើល* មូលដ្ឋានទី ៥.១ *ខាងលើ*។

[1137] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ D118/150 ត្រង់ ERN 00968003 (ឆ.៦០)។

[1138] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៣ *ដែលយោងទៅ* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២៩៥។

[1139] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២៩៥ ជើងទំព័រ ៧៥៣។

[1140] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៤។

ក្នុងចំណោមសាក្សីដែលត្រូវបានដកស្រង់ដោយសហមេធាវី (លើកលែងតែ ហែម មឿន) មិនដែលបានឮពី យឹម ទិត្យ និងមិនបានផ្តល់ភស្តុតាងពាក់ព័ន្ធនឹងការចូលរួមដែលត្រូវបានចោទប្រកាន់របស់គាត់ក្នុងការបោសសម្អាតក៏ដោយ[1141] ក៏ចៅក្រមអន្តរជាតិសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកស្រង់សាក្សីទាំងនេះនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រាប់គាំទ្រដល់ការសន្និដ្ឋានរបស់គាត់ ជាជាងចំណុចជាក់លាក់ដែលបង្ហាញពីការចូលរួមរបស់ យឹម ទិត្យ ក្នុងការបោសសម្អាត[1142]។

423. ជាចុងក្រោយ ពាក់ព័ន្ធនឹងការចាត់តាំងកម្មាភិបាលភូមិភាគនិរតីមួយចំនួនតូចឲ្យទៅបំពេញការងារជាមួយកម្មាភិបាលភូមិភាគពាយ័ព្យក្នុងឆ្នាំ១៩៧៦[1143] អង្គជំនុំជម្រះយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់សម្រាប់គាំទ្រដល់សេចក្តីសន្និដ្ឋាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ជាឧទាហរណ៍ សក្ខីកម្មរបស់ ហួន ជឿម បាននិយាយសំដៅដល់ យឹម ទិត្យ យ៉ាងច្បាស់ និងបញ្ជាក់ថា យឹម ទិត្យ គឺជាបុគ្គលម្នាក់ ក្នុងចំណោមជនដំបូងគេបំផុត ដែលបានរៀបចំក្រុមកម្មាភិបាលភូមិភាគនិរតីនៅក្នុងភូមិភាគពាយ័ព្យនៅចុងឆ្នាំ១៩៧៦[1144]។

---

[1141] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៤ ជើងទំព័រ ៦៨៨។

[1142] ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិយោងដល់ភស្តុតាងនេះ ភាគច្រើនគឺសម្រាប់គោលបំណងនៃការពិពណ៌នាអំពី (i) ការចាប់ផ្តើមនៃការបោសសម្អាតនៅក្នុងភូមិភាគពាយ័ព្យស្ថិតក្រោមសិទ្ធិអំណាចរបស់ រស់ ញឹម (លេខាភូមិភាគពាយ័ព្យពីឆ្នាំ១៩៧៥) (ii) ការជ្រើសរើស និងបញ្ជូនកម្មាភិបាលភូមិភាគនិរតីតាមបញ្ជារបស់ តាម៉ុក និង (iii) ការរៀបចំការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យដោយកម្មាភិបាលភូមិភាគនិរតីជាទូទៅ នៅក្នុងអំឡុងឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៨។ សហមេធាវីបានកម្រិតពីការជំទាស់របស់ខ្លួនត្រង់ចំណុចនេះនៅក្នុងកថាខណ្ឌ២៨៥, ២៨៦ និង៤១២ នៃដីកាដំណោះស្រាយ (ឯកសារ D382) ខណៈដែលមូលដ្ឋានផ្នែកភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រាប់ការចូលរួមរបស់ យឹម ទិត្យ ក្នុងការបោសសម្អាត ត្រូវបានពិពណ៌នាចាប់ពីកថាខណ្ឌ ៤១៣ រហូតដល់កថាខណ្ឌ ៤២៦ នៃដីកាដំណោះស្រាយ (ឯកសារ D382)។

[1143] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២៨៨។

[1144] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ជឿម ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D118/106 ត្រង់ ERN 00951904 (ឆ.១២) ("[...] ពេលពួកនិរតីចូលមកភូមិភាគពាយ័ព្យដំបូង គេមកធ្វើការជាមួយពួកពាយ័ព្យ ដោយមិនទាន់មកធ្វើការចាប់ខ្លួនអ្វីទេ គឺគេមកតាមដានពួកពាយ័ព្យ។ តាមខ្ញុំគិត តាម៉ុក និងតាទិត ជាអ្នកមករៀបចំភូមិភាគពាយ័ព្យនេះដំបូងគេ [...]")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ជឿម ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D118/106 ត្រង់ ERN 00951908 (ឆ.៣៩) ("សៈ តើពួកនិរតីដែលមកធ្វើការជាមួយពួកពាយ័ព្យដំបូងនៅក្នុងឆ្នាំណា? ឆ.៣៩ៈ

01677316



ii. ការចូលរួមរបស់ យឹម ទិត្យ ក្នុងការស្វាគមន៍កម្មាភិបាលភូមិភាគនិរតី នៅពេលដែលពួកគេមកដល់ បាត់ដំបង ហើយចាត់តាំងពួកគេទៅជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ

424. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសទាក់ទងនឹងការសម្រេចដែលថា នៅពាក់កណ្តាលឆ្នាំ១៩៧៧ មុនពេលតែងតាំងតំណែងជាផ្លូវការរបស់គាត់នៅក្នុងភូមិភាគពាយ័ព្យ យឹម ទិត្យ បានស្វាគមន៍កម្មាភិបាលភូមិភាគនិរតីនៅបាត់ដំបង និងបានចាត់តាំងពួកគេ ឱ្យទៅជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ[1145]។ ជាពិសេស អង្គជំនុំជម្រះច្រានចោលនូវការអះអាងដែលថា គ្មានសាក្សីណាម្នាក់ ក្នុងចំណោមសាក្សីទាំងបួននាក់ ដែលត្រូវបានដកស្រង់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ គាំទ្រដល់ការសម្រេច ឬជាពិសេសដែលបាននិយាយអំពីយឹម ទិត្យ ឬ *"តាទិត្យ"*។

425. ទាក់ទិននឹងតួនាទីរបស់ យឹម ទិត្យ ក្នុងការស្វាគមន៍កម្មាភិបាលភូមិភាគនិរតី និងបានចាត់តាំងពួកគេ ឱ្យទៅជំនួសកម្មាភិបាលភូមិភាគពាយ័ព្យនៅពាក់កណ្តាលឆ្នាំ១៩៧៧[1146] អង្គជំនុំជម្រះសង្កេតឃើញថា សាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងបួននាក់ ដែលត្រូវបានដកស្រង់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានគាំទ្រយ៉ាងច្បាស់លាស់ដល់ការសម្រេចនេះ។ ទោះបីជា (i) ព្រាប កប ត្រូវបានស្វាគមន៍ដោយ តាម៉ុក នៅបាត់ដំបងក្នុងខែសីហា ឆ្នាំ១៩៧៨[1147] (ii) យឹម គួញ ត្រូវបានស្វាគមន៍ដោយ យឹម ទិត្យ នៅបាត់ដំបងនៅចុងឆ្នាំ១៩៧៨[1148] និង (iii) ណុប ណាន ត្រូវបានចាត់តាំងជាមួយកម្មករភូមិភាគនិរតីផ្សេងទៀត ឱ្យទៅធ្វើការនៅក្នុងភូមិភាគពាយ័ព្យ "តាមបញ្ជារបស់ តាម៉ុក និងតាទិត" បន្ទាប់ពីគាត់បានមកដល់បាត់ដំបងនៅក្នុងខែឧសភា ឬមិថុនា

ពេលពួកនិរតីមកដំបូងគឺចុងឆ្នាំ១៩៧៦ ហើយគេប្រើល្បិចអញ្ចេះ គឺថ្នាក់ដឹកនាំគេថា គេធ្វើម្នាក់នេះដើម្បីឱ្យអប់រំផង ព្រោះគេនោះបានធ្វើខុសនៅភូមិភាគនិរតី តែតាមពិត ពួកនេះហើយគឺជាអ្នកមកស៊ើបការណ៍")។

[1145] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២៨៩។

[1146] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៦។

[1147] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/62 ត្រង់ ERN 01037142 (ឆ.៣២, ឆ.៣៥)។

[1148] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម គួញ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ឯកសារ D219/904 ត្រង់ ERN 01381133 (ឆ.៤៧) ត្រង់ ERN 01381136 (ឆ.៧០, ឆ.៧១)។

01677317



ឆ្នាំ១៩៧៨[1149] ក៏ដោយ ក៏ ពៅ គឿន បានបញ្ជាក់ថា "នៅពាក់កណ្ដាលឆ្នាំ១៩៧៧ តាទិត្យ បានប្រជុំជាមួយនឹងកម្មាភិបាលធំៗផ្សេងទៀតនៅក្រុងបាត់ដំបង ហើយក្រោយមកទៀត កម្មាភិបាលទាំងអស់នោះចេញទៅកន្លែងផ្សេងៗគ្នា។ [ខ្ញុំមិនដែលបានជួបគាត់ទេ] តែខ្ញុំធ្លាប់ឮឈ្មោះ តាទិត្យនេះ"[1150]។ លើសពីនេះទៀត ផ្ទុយទៅនឹងការអះអាងរបស់សហមេធាវី ដែលថា ពៅ គឿន មិនស្គាល់មេដឹកនាំណាម្នាក់ ដែលបានគ្រប់គ្រងភូមិភាគ និងតំបន់[1151] សាក្សីបានកំណត់អត្តសញ្ញាណរបស់ យឹម ទិត្យ យ៉ាងច្បាស់ថា គាត់ស្ថិតនៅក្នុងគណៈកម្មាធិការតំបន់ ១ បន្ទាប់ពីការបោសសម្អាតកម្មាភិបាលជាន់ខ្ពស់នៅក្នុងឆ្នាំ១៩៧៧ និងបានផ្ដល់សក្ខីកម្មថា យឹម ទិត្យ ក្រោយមក "បានគ្រប់គ្រងភូមិភាគពាយ័ព្យ"[1152]។

### iii. ការចូលរួមរបស់ យឹម ទិត្យ ក្នុងការបោសសម្អាតនៅក្នុងភូមិភាគពាយ័ព្យ និងការចាប់ខ្លួន "ប្រធាន" កងវរសេនាតូចពីររូប ដែលគ្រប់គ្រងលើការដ្ឋានរោងចក្រស្ករសកំពង់គល់

426. ចៅក្រមអន្តរជាតិយល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ ទាក់ទងនឹងការចូលរួមរបស់ យឹម ទិត្យ ក្នុងការចាប់ខ្លួន "ប្រធាន" កងវរសេនាតូចពីររូប ដែលគ្រប់គ្រងរោងចក្រស្ករសកំពង់គល់[1153]។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានធ្វើការសម្រេចច្បាស់លាស់ទេថា យឹម ទិត្យ ជាប់

[1149] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ណាន ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣ ឯកសារ D118/92 ត្រង់ ERN 00947252, 00947253 (ឆ.៣, ឆ.១១)។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីបានជំទាស់ដោយមិនត្រឹមត្រូវទៅលើកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ធីម (ប្រពន្ធរបស់ ព្រាប កប) ខណៈដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយោងដល់សក្ខីកម្មរបស់ ណុប ណាន។ *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ២៩៩ ជើងទំព័រ ៧៥៨។ បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៦ ជើងទំព័រ ៧១៣។

[1150] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពៅ គឿន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/64 ត្រង់ ERN 01037176 (ឆ.៣១)។

[1151] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៦ ជើងទំព័រ ៧១៦ *ដែលយោងតាម* កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពៅ គឿន ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D219/682 ត្រង់ ERN 01203900 (ឆ.១៧-ឆ.១៩)។

[1152] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពៅ គឿន ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/64 ត្រង់ ERN 01037176 (ឆ.២៧-ឆ.២៩)។

[1153] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៣៨។

01677318



ពាក់ព័ន្ធនឹងការបោសសម្អាតលេខាកងវរសេនាតូចទាំងពីររូបនេះ។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើកឡើងពីការអះអាងនៃសក្ខីកម្មពាក្យចចាមអារ៉ាមអនាមិករបស់ ហួន ជឿម និងបានទទួលស្គាល់នូវតម្លៃជាភស្តុតាងដ៏តិចតួចនេះ[1154]។ លើសពីនេះទៀត ការយោងទៅលើភស្តុតាងរបស់ ហួន ជឿម ទាក់ទងនឹងរោងចក្រស្ករសកំពង់គល់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនជាកត្តាសម្រេច ក្នុងការសន្និដ្ឋានលើការចូលរួមរបស់ យឹម ទិត្យ ក្នុងការបោសសម្អាតនៅភូមិភាគពាយ័ព្យនោះទេ ដោយហេតុថា យឹម ទិត្យ មិនត្រូវបានចោទប្រកាន់ពីការបោសសម្អាតនៅក្នុងការដ្ឋានរោងចក្រស្ករសកំពង់គល់ ទាក់ទងនឹង "ប្រធាន" កងវរសេនាតូចទាំងពីររូប[1155] ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់ថា មិនមានភស្តុតាងដែលអាចជឿទុកចិត្តបានដែលថា យឹម ទិត្យ បានទៅពិនិត្យមើលការដ្ឋានរោងចក្រស្ករសកំពង់គល់ ទោះបីតាម៉ុកបានទៅពិនិត្យមើលជាទៀងទាត់ក៏ដោយ[1156]។

427. ទោះបីដូចបានរៀបរាប់ពីខាងលើក៏ដោយ ក៏ចៅក្រមអន្តរជាតិអាចរកបានភស្តុតាងគ្រប់គ្រាន់ដែលគាំទ្រដល់ការចូលរួមជាចម្បងរបស់ យឹម ទិត្យ ក្នុងគោលនយោបាយរបស់ ប.ក.ក ស្តីពីការសម្លាប់ខ្មាំង ទាំងក្នុង និងទាំងក្រៅជួរបក្សកុម្មុនីស្តកម្ពុជា ក្រៅពីភស្តុតាងរបស់ ហួន ជឿម[1157]។ ទាក់ទងនឹងការបោសសម្អាតប្រជាជនភូមិភាគពាយ័ព្យនៅក្នុងជួរបក្សកុម្មុនីស្តកម្ពុជា ឈាន ហ៊ា បានបញ្ជាក់ថា ក្នុងអំឡុងកិច្ចប្រជុំមួយ យឹម ទិត្យ បានប្រកាសថា "អ្នកដឹកនាំភូមិភាគពាយ័ព្យ

---

[1154] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤១៨ ("សាក្សីនេះមិនបានលើកឡើងពីពេលដែលឧប្បត្តិហេតុនេះកើតឡើង ឬថាតើគាត់បានឮរឿងនេះពីពេលណាទេ")។

[1155] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 ទំព័រ ៧៣៧ ("ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះកម្មាភិបាលភូមិភាគពាយ័ព្យ" មិនមែនការចោទប្រកាន់ពីការដ្ឋានរោងចក្រស្ករសកំពង់គល់)។ *សូមមើលផងដែរ* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៧៤៣។

[1156] *សូមមើលផងដែរ* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៧៤៦ (សេចក្តីបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទីម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ D118/108 ត្រង់ ERN 00951928 (ឆ.១៦) ("ខ្ញុំស្គាល់តាទិត។ គាត់នៅកាន់ខាងភូមិភាគពាយ័ព្យ។ គាត់នៅក្នុងបាត់ដំបង ហើយគាត់មិនដែលមករោងចក្រស្ករសនេះទេ មានតែតាម៉ុក ទេ ដែលមកទីនេះ")។

[1157] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៤០។ *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤១៣-៤២៦។

គឺជាជនក្បត់ ព្រោះជាប់ខ្សែរបស់ យួន"[1158]។ ណាង នី (ជាកម្មករក្នុងកងចល័តនៅការដ្ឋានទំនប់កង្អួត) បានផ្តល់សក្ខីកម្មស្រដៀងគ្នាថា យឹម ទិត្យ បានបញ្ជាក់យ៉ាងច្បាស់ថា កម្មាភិបាលភូមិភាគពាយ័ព្យ មាន "ក្បាលយួន ខ្លួនខ្មែរ"[1159]។ សៅ ជាប់ ក៏បានពន្យល់ផងដែរថា យឹម ទិត្យ បានចាត់តាំងកម្មាភិបាលភូមិភាគនិរតី ជាពិសេស ឱ្យស្រាវជ្រាវរក និងចាប់ខ្លួន "ភ្នាក់ងារ សេអ៊ីអា" និងវៀតណាម នៅក្នុងក្រុមភូមិភាគពាយ័ព្យ[1160]។ ភស្តុតាងផ្សេងទៀត បញ្ជាក់ថា យឹម ទិត្យ បានចូលរួមក្នុងការបោសសម្អាត ដោយមានការចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យថ្នាក់ភូមិភាគ តំបន់ និងសហករណ៍[1161]។ ជាងនេះទៅទៀត ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា ការចូលរួមរបស់ យឹម ទិត្យ ក្នុងការបោសសម្អាត បានពង្រីកដល់ប្រជាជនទូទៅផងដែរ[1162]។ ជាឧទាហរណ៍ ណុប ងឹម (ជាអនុលេខាស្រុកសំឡូត) បានពន្យល់ថា ក្នុងអំឡុងកិច្ចប្រជុំមួយ ក្នុងឆ្នាំ១៩៧៨ យឹម ទិត្យ ជាពិសេស បានណែនាំគាត់ និងកម្មាភិបាលដទៃទៀត ឱ្យ "កម្ទេច" ខ្មាំងណាដែលប្រឆាំងនឹង

---

[1158] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៉ា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ឯកសារ D118/136 ត្រង់ ERN 00960664-00960665 (ឆ.១៣) ។

[1159] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ D118/77 ត្រង់ ERN 00934389 (ឆ.៣០) ("[តាទិត] និយាយថា ពួកពាយ័ព្យនេះ គឺ "ក្បាលយួនខ្លួនខ្មែរ"។ គេចោទថា ចូលដៃចូលជើងជាមួយវៀតណាម ហេតុនេះហើយទើបគេចាប់ពួកកម្មាភិបាលពាយ័ព្យសម្លាប់ចោល។ នៅពេលពួកនិរតីក្តោបក្តាប់តំបន់នេះទាំងស្រុងហើយ គេចាប់ពួកអតីតកម្មាភិបាលពាយ័ព្យ ដូចជា កងចល័ត ប្រធានសហករណ៍ យកទៅសម្លាប់នៅភូមិបាយដំរាំ ឃុំបាយដំរាំ")។

[1160] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ឯកសារ D219/982 ត្រង់ ERN 01477629 (ឆ.៣៣) ("តាំងពីឆ្នាំ៧៥ ៧៦ ហ្នឹងក៏សម្លាប់ ហើយ៧៧ ពួកនិរតីមក។ ហើយក្នុងឆ្នាំ៧៦ ៧៧ ហ្នឹងតាទិត្យចាត់តាំងរកខ្មាំង សេ.អ៊ី. អា យួន។ អាហ្នឹងគេស្រាវជ្រាវរកចាប់រហូត។ ការចាប់ហ្នឹងទល់ពួកនិរតីចូលមក")។

[1161] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នួន មួន ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D105/3 ត្រង់ ERN 00780638 (ឆ.៣៣-ឆ.៣៤) ("ឮគេថា តាម៉ុក មកពីនិរតី តាទិត មកពីនិរតី ហើយកម្មាភិបាលភូមិភាគពាយ័ព្យ ត្រូវគេចាប់ខ្លួនទាំងអស់ ចាប់តាំងពីថ្នាក់ភូមិភាគចុះមកថ្នាក់តំបន់ រហូតដល់ថ្នាក់សហករណ៍។ សៈ តើការចាប់នោះគឺនៅក្រោមអំណាចរបស់ តាម៉ុក និងតាទិត ឬទេ? ឆ.៣៤៖ បាទ")។

[1162] *សូមមើល* ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤២៣-៤២៦។ *សូមមើល ឧទាហរណ៍* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D219/689 ត្រង់ ERN 01205210 (ឆ.៥៤) ("សៈ តើលោកដឹងអំពីមូលហេតុដែលមនុស្សទាំងនោះត្រូវបានគេបញ្ជូនទៅរៀនដែរទេ? ឆ.៥៤៖ មូលហេតុដែលបញ្ជូនទៅ គឺអ្នកដែលធ្លាប់ធ្វើបាក់ដងរែក រហែកបង្គី បាក់ដងចប អ្នកដែលធ្លាប់តវ៉ាអីគេបន្តិចបន្តួចគេថាជាខ្មាំង ហើយត្រូវគេយកទៅរៀនសូត្រហើយ")។

*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*

01677320



របប ប.ក.ក[1163]។ លើសពីនេះទៀត យឹម ទិត្យ បានប្រាប់គាត់ដោយផ្ទាល់ថា ក្នុងករណី "ខ្មាំង" បដិសេធមិនព្រមកែប្រែ ពួកគេ "នឹងត្រូវចាប់យកទៅសម្លាប់"[1164]។

428. ហេតុដូច្នេះ ទោះបីចៅក្រមអន្តរជាតិយល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការបញ្ជាក់ថា យឹម ទិត្យ ជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួន "ប្រធាន" កងវរសេនាតូចពីររូប ដែលគ្រប់គ្រងរោងចក្រស្ករស កំពង់គល់នៅពាក់កណ្តាលឆ្នាំ១៩៧៧ ក៏ដោយ ក៏ប៉ុន្តែ អង្គជំនុំជម្រះនៅតែតម្កល់ការសម្រេច ផ្សេងទៀតអំពីការចូលរួមរបស់គាត់ក្នុងការបោសសម្អាតនៅភូមិភាគពាយ័ព្យ។ អង្គជំនុំជម្រះយល់ ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានប្រព្រឹត្តដោយមិនសមហេតុផលឡើយ ក្នុងការ សម្រេចថា យឹម ទិត្យបានគាំទ្រ និងចូលរួមជាចម្បងដល់គោលនយោបាយរបស់ ប.ក.ក ស្តីពីការ អប់រំរៀនសូត្រនៃក្រុមដែលគេហៅថា "សមាសធាតុមិនល្អ" និងការសម្លាប់ខ្មាំង ទាំងក្នុង និងក្រៅ ជួរ បក្សកុម្មុនីស្តកម្ពុជា។

*គ. ការចូលរួមរបស់ យឹម ទិត្យ ក្នុងបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍*

429. នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកជាចម្បង ក្នុងគោលនយោបាយរបស់ ប.ក.ក ស្តីពីបទបញ្ជានៃការរៀប អាពាហ៍ពិពាហ៍[1165]។ ចៅក្រមអន្តរជាតិកត់សម្គាល់ឃើញថា ការសម្រេចរបស់សហចៅក្រម ស៊ើបអង្កេតអន្តរជាតិ គឺផ្អែកលើការពិពណ៌នាអំពីអាពាហ៍ពិពាហ៍មួយដែលគាំទ្រដោយ សាក្សីជាប្តីប្រពន្ធពីររូប គឺណុប ង៉ឹម និង ព្រាប កប (ជាទាហានពិការ)។ សហមេធាវីអះអាងថា "ត្រឹមតែវត្តមាន" របស់ យឹម ទិត្យ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍មួយ នៅក្នុងស្រុកសំឡូត ខេត្ត

---

[1163] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ត្រង់ ERN 01008706 (ឆ.៥៦) ("តាម៉ុក និងតាទិត្យ បាននិយាយអំពីស្ថានភាពខ្មាំង។ ពួកគាត់បានណែនាំយើងថា យើងត្រូវកម្ទេចខ្មាំងណា ដែលប្រឆាំងនឹងអង្គការ។ [...] តាមខ្ញុំយល់ឃ្លាដែលថា "ខ្មាំងណាដែលក្បត់នឹងយើង យើងត្រូវកម្ទេច មានន័យថា ខ្មាំងនោះនឹង ត្រូវបានសម្លាប់")។

[1164] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/298 ត្រង់ ERN 01095988 (ឆ.១៦) ("តាម៉ុក ហើយនិង តាទិត បានប្រាប់យើងថា បើយើងឃើញមានពួកនេះ យើងត្រូវព្រមានប្រាប់គេឲ្យ កែប្រែ បើពុំដូច្នេះទេ យើងនឹងចាប់ពួកគេយកទៅសម្លាប់")។

[1165] ដីកាដំណោះស្រាយ ឯកសារ D382 កថាខណ្ឌ ៤២៧ និង ១០២៤។

បាត់ដំបង ក្នុងខែសីហា ឆ្នាំ១៩៧៨ មិនអាចកំណត់ថាជាការចូលរួមចំណែកយ៉ាងចម្បងចំពោះសហឧក្រិដ្ឋកម្មរួមទេ[1166]។

430. ចៅក្រមអន្តរជាតិយល់ឃើញថា ការអះអាងខាងលើ មិនអាចយកជាសម្អាងបានទេ។ តាមទស្សនៈរបស់អង្គជំនុំជម្រះ យឹម ទិត្យ មិន "ត្រឹមតែមានវត្តមាន"ទេ ប៉ុន្តែថែមទាំងបានចូលរួមចំណែកយ៉ាងសកម្មដល់ការរៀបអាពាហ៍ពិពាហ៍ក្នុងទ្រង់ទ្រាយធំ ក្នុងតួនាទីរបស់គាត់ជាលេខាតំបន់ ១[1167]។ ជាឧទាហរណ៍ យឹម ទិត្យ បានចូលរួមក្នុងការរៀបចំគ្រែ មុង និងលិខិតផ្ញើជូនប្តីប្រពន្ធថ្មោងថ្មី[1168] ហើយ ព្រាប កប បានពន្យល់ថា យឹម ទិត្យ បានឡើងថ្លែងសុន្ទរកថានៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ដែលតាមរយៈពិធីនោះ គាត់បានណែនាំដល់ប្តីប្រពន្ធដែលទើបរៀបការថ្មីៗ ឲ្យ "ចេះស្រឡាញ់គ្នា ត្រូវមានសាមគ្គីភាព"[1169]។ ចៅក្រមអន្តរជាតិក៏បានកត់សម្គាល់ឃើញផងដែរថា ពិធីនេះត្រូវបានរៀបចំឡើងសម្រាប់រៀបការប្តីប្រពន្ធ ៣៨ គូ ដែលនៅក្នុងពិធីនេះ ទាហានពិការត្រូវបានគេផ្គូផ្គងជាមួយនឹងស្ត្រីមកពីស្រែអំបិល[1170]។ លើសពីនេះទៀត រយៈពេលពីរបីថ្ងៃបន្ទាប់ពីពិធីរៀបការ យឹម ទិត្យ បានចុះសួរសុខទុក្ខដើម្បីតាមដាន និងកត់សម្គាល់នៅពេលដែលគាត់បានសួរប្តីប្រពន្ធថាតើពួកគេព្រមព្រៀងរស់នៅជាមួយគ្នា និងបាន

---

[1166] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382/22 កថាខណ្ឌ ២៤២។

[1167] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ត្រង់ ERN 01008707 (ឆ.៦៣) ("សៈ តើលោកស្រីដឹងទេថា តាទិត្យ គាត់មានតួនាទីអ្វីទៀតក្រៅពីលេខាតំបន់១? ឆ.៦៣៖ ខ្ញុំគ្រាន់តែដឹងថា គាត់ជាលេខាតំបន់ ១ តែប៉ុណ្ណោះ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី០៣ ខែវិច្ឆកា ឆ្នាំ២០១៤ ឯកសារ D219/62 ត្រង់ ERN 01037144 (ឆ.៤៦)។ *សូមមើលផងដែរ* មូលដ្ឋានទី ៥.២ (iii) *ខាងលើ* (ដែលតម្កល់ការសម្រេចថា យឹម ទិត្យ គឺជាលេខាតំបន់១)។

[1168] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆកា ឆ្នាំ២០១៤ ឯកសារ D219/62 ត្រង់ ERN 01037143 (ឆ.៤៤)។

[1169] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី៣ ខែវិច្ឆកា ឆ្នាំ២០១៤ ឯកសារ D219/62 ត្រង់ ERN 01037144 (ឆ.៤៥-ឆ.៤៦)។

[1170] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី សវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ [ណុប ធីម] ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ D219/974.1.2 ត្រង់ ERN 01382490 បន្ទាត់ ២២-២៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ D118/285 ត្រង់ ERN 01008708 (ឆ.៦៨)។

ណែនាំពួកគេ "ឱ្យធ្វើល្អ កុំឱ្យធ្វើអាក្រក់"[1171]។ ណុប ង៉ឹម ដោយគ្មានជម្រើសផ្សេងទៀត ប៉ុន្តែត្រូវតែរៀបការ ប្រសិនបើគាត់មិនចង់ឱ្យគេយកទៅសម្លាប់[1172] បានយល់ភ្លាមពីការណែនាំរបស់ យឹម ទិត្យ ថា "តែការហើយ ត្រូវដេកនៅជាមួយគ្នា"[1173]។ ជាចុងក្រោយ យឹម ទិត្យ និង តាម៉ុក បានធ្វើការត្រួតពិនិត្យទិន្នន័យអត្រាកំណើត[1174] រួមទាំងកិច្ចប្រជុំស្តីពី "ថាតើមានកូនង៉ែតកើតប៉ុន្មានក្នុងមួយខែ"[1175]។

431. ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានប្រព្រឹត្តដោយមិនសមហេតុផលឡើយ ក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកជាចម្បងដល់គោលនយោបាយរបស់ ប.ក.ក ស្តីពីបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍។

---

[1171] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី សវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ [ណុប ង៉ឹម] ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ត្រង់ ERN 01382495 បន្ទាត់ ១៣-១៥ ("ហើយការបានពីរបីថ្ងៃបាន អ៊ុំ ទិត្យ គាត់មក គាត់មកសួរណែនាំអ៊ីចឹងទៅណា គាត់មកសួរនាំអ៊ីចឹង មានអាណារត់ចោលគ្នាអ៊ីចឹងទៅណា។ ហើយអត់មាននរណារត់ចោលអ៊ីចឹងក៏គាត់ចេះតែណែនាំទៅ ណែនាំឱ្យធ្វើល្អ កុំឱ្យធ្វើអាក្រក់អ៊ីចឹងទៅណា")។

[1172] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី សវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ [ណុប ង៉ឹម] ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ត្រង់ ERN 01382488 បន្ទាត់ ២៤-២៥ ("ខ្ញុំចង់រត់ដែរ ប៉ុន្តែខ្លាចគេវៃចោល [...]") ត្រង់ ERN 01382497 បន្ទាត់ ៨-៩ ("មិនចង់យក ចង់តែរត់ចោលទេ តែធ្វើម៉េច ចេះតែទ្រាំទៅ")។

[1173] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D219/835 ត្រង់ ERN 01329405 (ឆ.១៥១-ឆ.១៥២) (ឆ.១៥១៖ [...] តែការហើយ ត្រូវដេកនៅជាមួយគ្នាហ្នឹងហើយ។ សៈ តើនោះជាអ្វីដែលលោកស្រីយល់ពីការណែនាំរបស់តាទិត្យ មែនទេ? ឆ.១៥២៖ ចាស")។

[1174] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/298 ត្រង់ ERN 01095988 (ឆ.១៦) ("នៅក្នុងអង្គប្រជុំ គេក៏បាននិយាយផងដែរអំពីស្លិត [...] និងកើត [...] ដែលឃុំនីមួយៗសម្រេចបាន។ តាម៉ុក ជួនកាលតាទិត តែងតែដាក់សំណួរមកលើពួកយើងដែលជាតំណាងសង្កាត់ និងស្រុកម្នាក់ៗឱ្យរាយការណ៍ថាមានរឿងរ៉ាវអ្វីកើតឡើងនៅក្នុងសង្កាត់ និងស្រុករបស់ខ្លួន")។

[1175] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/298 ត្រង់ ERN 01095989 (ឆ.១៨) ("សៈ តើលោកស្រីមានចាំបានដែរឬទេ ថាតើ តាទិត និងតាម៉ុក បាននិយាយអ្វីខ្លះអំពីស្ថិតិប្រជាជន? ឆ.១៨៖ នៅពេលប្រជុំ គាត់បានសួរពួកយើងអំពី ថាតើមានកូនង៉ែតកើតប៉ុន្មានក្នុងមួយខែ[...]")។

*ឃ. សេចក្តីសន្និដ្ឋាន*

432. ជាសេចក្តីសន្និដ្ឋានចុងក្រោយ ចៅក្រមអន្តរជាតិសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកជាចម្បងក្នុងការជួយជ្រោមជ្រែង ដល់សហឧក្រិដ្ឋកម្មរួម ក តាមរយៈការអនុវត្តគោលនយោបាយរបស់ ប.ក.ក ស្តីពី (i) ការបង្កើត និងការគ្រប់គ្រងសហករណ៍ និងការដ្ឋាន (ii) ការបោសសម្អាត និងការកំណត់គោលដៅទៅលើ "ខ្មាំង" និងក្រុមជាក់លាក់ផ្សេងទៀត និង (iii) បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍។ ហេតុដូចនេះ សម្រេចបដិសេធ មូលដ្ឋានទី ៥.៣(i)។

**មូលដ្ឋានទី ៥.៣(ii)÷ ការចោទប្រកាន់អំពីកំហុសចំពោះការសម្រេចថា យឹម ទិត្យ បានចូលរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្ម ខ**

**១. អំណះអំណាង**

433. នៅក្នុងការប្តឹងឧទ្ធរណ៍ចំពោះការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹង សហឧក្រិដ្ឋកម្ម ខ សហមេធាវីអះអាងអំពីកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បាន "ចូលរួមចំណែកយ៉ាងសំខាន់" ក្នុងគោលនយោបាយ ប.ក.ក ស្តីពីការលុបបំបាត់ខ្មែរក្រោមចាប់ពី "ក្នុងពេលណាមួយក្នុងឆ្នាំ១៩៧៦ រហូតដល់ពេលបញ្ចប់របប"[1176]។ សហមេធាវីលើកឡើងអំពី សុន្ទរកថាជាច្រើន ដែលចោទប្រកាន់ថា លោក យឹម ទិត្យ បានថ្លែង ការព្រមាន និងមតិមួយចំនួន ដែលអះអាងថាមានវោហាសាស្ត្រប្រឆាំងវៀតណាម ដែលទាំងអស់នេះត្រូវបានសំអាងនៅក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងនោះបានលើកទឡ្ហីករណ៍ថា សេចក្តីថ្លែងការណ៍ទាំងនេះខ្វះ "ខ្លឹមសារ បរិបទ និងកាលបរិច្ឆេទច្បាស់លាស់"[1177]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេត អន្តរជាតិខកខានមិនបានពន្យល់ថាតើ សេចក្តីថ្លែងទាំងនេះបង្កើតបាន "ការចូលរួមចំណែកយ៉ាង សំខាន់" ដោយរបៀបណា ចំពោះការសម្លាប់រង្គាលបែបប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម

[1176] បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២៤៥។

[1177] បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២៤៦-កថាខណ្ឌ ២៤៧។

ជាពិសេស ក្នុងបរិបទដែល លោក យឹម ទិត្យ ត្រូវបានចោទប្រកាន់ថាកំពុងបំពេញការងារ នៅក្រោមរបបមួយដែលកំពុងមានសង្គ្រាមជាមួយវៀតណាមនោះ[1178]។

434. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានញែកឲ្យដាច់រវាងការចូលរួមចំណែកជាលក្ខណៈបុគ្គលរបស់លោក យឹម ទិត្យ និងគោលនយោបាយទូទៅនៃ ប.ក.ក ដោយបានគូសបញ្ជាក់ថា "សហឧក្រិដ្ឋកម្មរួមមិនមែនជាទស្សនៈបើកចំហរដែលអនុញ្ញាតឲ្យមានការផ្តន្ទាទោសផ្អែកលើពិរុទ្ធភាព ដោយសារការមានទំនាក់ទំនងជាមួយឡើយ"[1179]។ ចំណុចចុងក្រោយ សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានពន្យល់ថា តើ "ភាពស្របគ្នា" នៃសេចក្តីថ្លែងការណ៍ដូចបានចោទប្រកាន់ចំពោះលោក យឹម ទិត្យ អំពីការសម្លាប់ខ្មែរក្រោមក្នុងទ្រង់ទ្រាយធំ អាចបង្ហាញដោយរបៀបណាថា លោក យឹម ទិត្យ បានចូលរួមចំណែកសំខាន់នៅក្នុងអំពើប្រល័យពូជសាសន៍ ហើយលើសពីនេះទៀត ថាតើ សេចក្តីថ្លែងការណ៍ណាមួយ នៅជិតទាំងពេលវេលា និងភូមិសាស្ត្រ ឬ ថាតើ សេចក្តីថ្លែងការណ៍ទាំងនេះ ជំរុញឲ្យមានការសម្លាប់រង្គាលដោយរបៀបណា[1180]។ សហមេធាវីសន្និដ្ឋានថា មិនមានអ្នកវិនិច្ឆ័យអង្គហេតុឥតលម្អៀងណាម្នាក់ អាចឈានដល់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលចោទជាបញ្ហានេះទេ[1181]។

435. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា សហមេធាវីខកខានមិនបានបង្ហាញនូវកំហុសណាមួយដែលអាចពិនិត្យឡើងវិញបាន ពាក់ព័ន្ធនឹងការចូលរួមចំណែកសំខាន់របស់ លោក យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួម ខ[1182]។ សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ថា សហមេធាវីបានដកស្រង់ច្បោលៗ និងកំណត់មិនត្រឹមត្រូវលើការសម្រេចយ៉ាងទូលំទូលាយចំពោះការប្រព្រឹត្តរបស់ យឹម ទិត្យ នៅភូមិភាគនិរតី និងពាយ័ព្យ[1183] ដោយបានគូសបញ្ជាក់ថា ជនរងគ្រោះខ្មែរក្រោមនៅក្នុង

---

[1178] បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២៤៧។
[1179] បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២៤៨។
[1180] បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/24) កថាខណ្ឌ ២៤៩។
[1181] បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/24) កថាខណ្ឌ ២៥០។
[1182] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ១៤១។
[1183] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ១៤២-កថាខណ្ឌ ១៤៤ (សហព្រះរាជអាជ្ញាអះអាងថា សម្រាប់ការប្រព្រឹត្តនៅក្នុងភូមិភាគនរតី ដែលនាំឲ្យមានសហឧក្រិដ្ឋកម្មរួមនេះ សហចៅក្រម

តំបន់ស្ថិតក្រោមសិទ្ធិអំណាចរបស់ លោក យឹម ទិត្យ គឺជាជនស៊ីវិល រួមទាំង កុមារផងដែរ[1184]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ថា ការលើកឡើងរបស់សហមេធាវីថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបានតម្រូវឱ្យធ្វើការពន្យល់ពីរបៀប ដែលសេចក្ដីថ្លែងការណ៍របស់លោក យឹម ទិត្យ "នៅជិតទាំងពេលវេលា និងភូមិសាស្ត្រ ឬថាតើសេចក្ដីថ្លែងទាំងនោះជំរុញឱ្យមានការសម្លាប់រង្គាល" ដោយរបៀបណានោះ គឺជាការយល់ខុសជាមូលដ្ឋានទៅលើច្បាប់ជាធរមាន ពោលគឺ ការចូលរួមចំណែករបស់ជនជាប់ចោទចំពោះសហឧក្រិដ្ឋកម្មរួម មិនចាំបាច់រហូតដល់ "មិនអាចខ្វះបាន" នោះទេ[1185]។ ក្នុងករណីណាក៏ដោយ សេចក្ដីថ្លែងការណ៍បែបនេះមានជាប់ទាក់ទងយ៉ាងច្បាស់ទៅនឹងការសម្លាប់ខ្មែរក្រោមក្នុងបរិបទនៃរចនាសម្ព័ន្ធឋានានុក្រមរបស់ ប.ក.ក និងរបៀបដែលគោលនយោបាយទាំងនេះត្រូវបានអនុវត្តដោយអ្នកមានសិទ្ធិអំណាច។ ជាចុងក្រោយ ការអះអាងរបស់សហមេធាវីថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានពន្យល់ថាតើ ការសម្រេចណាមួយ ទាក់ទងនឹងការចូលរួម

ស៊ើបអង្កេតអន្តរជាតិបានសម្រេចថា (i) យឹម ទិត្យ បានព្រមានអ្នកចូលរួមកិច្ចប្រជុំមួយនៅក្នុងស្រុកគិរីវង់ នៅពាក់កណ្ដាលឆ្នាំ១៩៧៥ ថា នរណា ដែល "រត់ចូលយួន" គឺជាខ្មាំង ហើយគេនឹងសម្លាប់ចោល។ (ii) យឹម ទិត្យ និងកម្មាភិបាលតំបន់ ១៣ ដទៃទៀត បានចូលរួមកិច្ចប្រជុំរយៈពេល ១០ថ្ងៃ នៅចុងឆ្នាំ១៩៧៦ នៅស្រុកអង្គរជ័យ ដែលនៅក្នុងការប្រជុំនោះ វៀតណាម និងអ្នកដែលមានសាច់ញាតិមកពីកម្ពុជាក្រោម ត្រូវបានចាត់ទុកថាជាខ្មាំង និង (iii) នៅក្នុងការប្រជុំជាញឹកញាប់នៅចុងឆ្នាំ១៩៧៧ ឬ ដើមឆ្នាំ១៩៧៨ នៅស្រុកគិរីវង់ ដែលចូលរួមដោយមេឃុំ និងមេស្រុក យឹម ទិត្យ បានលើកយោងទៅរក "យួនខ្មែរ" នៅពេលពិភាក្សាអំពីបញ្ហាសន្តិសុខផ្ទៃក្នុង និងបានលើកឡើងថា វៀតណាមបានជ្រៀតចូល ព្រមទាំងធ្វើជាគិញនៅគ្រប់កម្រិតទាំងអស់នៃបក្សកុម្មុយនីស្តកម្ពុជា ហើយបានអំពាវនាវដល់អ្នកចូលរួមឲ្យរាយការណ៍ពីបុគ្គលបែបនេះទៅថ្នាក់លើ។ ពាក់ព័ន្ធជាមួយការប្រព្រឹត្តិនៅក្នុងភូមិភាគពាយ័ព្យ ដែលរួមចំណែកដល់ សហឧក្រិដ្ឋកម្មនេះ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតបានសម្រេចថា (i) នៅទីតាំងមួយចំនួនក្នុងតំបន់ ១ ចាប់ពីដើមឆ្នាំ១៩៧៧ រហូតដល់យ៉ាងហោចណាស់ ពាក់កណ្ដាលឆ្នាំ១៩៧៨ យឹម ទិត្យ បានថ្លែងនៅក្នុងការប្រជុំ ដែលចូលរួមដោយកម្មាភិបាល យោធា និងស៊ីវិល អំពីថាតើវៀតណាមចង់លេបកម្ពុជាដោយរបៀបណា (ii) នៅក្នុងកិច្ចប្រជុំជាក់លាក់មួយនៅទំនប់កង្អូត មុនខែសីហា ឆ្នាំ១៩៧៨ ដែលមានមនុស្សចូលរួម ៧០០ ទៅ ៨០០នាក់ រួមមានទាំងប្រធានស្រុក និងឃុំ និងប្រជាជនទូទៅនោះ យឹម ទិត្យ បានបញ្ជាក់ថា យួន និង "ខ្មាំងផ្ទៃក្នុង" ដទៃទៀត បានលាក់បំពួនក្នុងចំណោមប្រជាជន ហើយថា អ្នកចូលរួមត្រូវត្រួតពិនិត្យ និងរាយការណ៍អំពីខ្មាំងបែបនេះ ដើម្បីឲ្យ "អង្គការ" អាចសម្លាប់ពួកគេ និង (iii) យឹម ទិត្យ បានដឹកនាំការប្រជុំមួយ នៅក្នុងឆ្នាំ១៩៧៨ ដើម្បីពិភាក្សាអំពី "ខ្មាំងយួន" ហើយគាត់បានបញ្ជាក់ថា "សម្លាប់អ្នកដែលអាចនិយាយភាសាវៀតណាម ឬ អ្នកដែលជាប់ខ្សែយួន"")។

[1184] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ១៥៤។

[1185] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ១៥៥។

ចំណែករបស់ លោក យឹម ទិត្យ ចំពោះសហឧក្រិដ្ឋកម្មរួម ហើយការសម្រេចណាមួយទាក់ទងនឹង គោលនយោបាយរបស់ ប.ក.ក គឺជាការយល់ច្រឡំចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសារការចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម ខ គឺដូចគ្នានឹងការចូលរួមចំណែកលើ គោលនយោបាយរបស់ ប.ក.ក[1186]។

## ២. ការពិភាក្សា

436. បណ្តឹងឧទ្ធរណ៍របស់សហមេធាវីទាក់ទងនឹងការចូលរួមចំណែករបស់ លោក យឹម ទិត្យ នៅក្នុង សហឧក្រិដ្ឋកម្មរួមចំពោះសហឧក្រិដ្ឋកម្មរួម ខ[1187] ពាក់ព័ន្ធនឹងការសម្លាប់រង្គាលបែបប្រល័យពូជ សាសន៍លើខ្មែរក្រោម បានចោទជាបញ្ហាមួយចំនួន ថាតើ (i) ជាបញ្ហាអង្គច្បាប់ សកម្មភាពរបស់ លោក យឹម ទិត្យ គឺជា "ការចូលរួមចំណែកសំខាន់" នៅក្នុងសហឧក្រិដ្ឋកម្មរួមដែរឬទេ និងថាតើ (ii) ជាបញ្ហាអង្គហេតុ មានភស្តុតាងគ្រប់គ្រាន់គាំទ្រដល់ការសម្រេចរបស់ចៅក្រមស៊ើបអង្កេត ដែលរងការជំទាស់ ទាក់ទិននឹងសកម្មភាពទាំងនោះ ដែរឬទេ។ ចៅក្រមអន្តរជាតិនឹងធ្វើការ ដោះស្រាយចំពោះបញ្ហាទាំងនេះម្តងមួយៗ។

437. ចៅក្រមអន្តរជាតិរំលឹកថា ដូចបានបញ្ជាក់នៅក្នុងយុត្តិសាស្ត្រស្របគ្នាពីមុនៗរបស់ អ.វ.ត.ក បទដ្ឋានគតិយុត្តិត្រឹមត្រូវដែលអាចអនុវត្តបានចំពោះការចូលរួមរបស់ជនជាប់ចោទក្នុងការអនុវត្ត គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម គឺថា ការចូលរួមចំណែករបស់ជនជាប់ចោទត្រូវតែ "សំខាន់ ប៉ុន្តែពុំមែនរហូតដល់មិនអាចខ្វះបាននោះទេ"[1188]។ ការកំណត់អំពីការចូលរួមចំណែកសំខាន់

---

[1186] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/27) កថាខណ្ឌ ១៩៦។

[1187] និយមន័យរួមលើ "សហឧក្រិដ្ឋកម្មរួម ខ" អាចពិនិត្យមើលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦(ii)។

[1188] សំណុំរឿង ០០២/១ សាលដីកា (F36) កថាខណ្ឌ ៩៨០ (សំណុំរឿង ០០២ សាលដីកាសហឧក្រិដ្ឋកម្មរួម) កថាខណ្ឌ ៣៨។ សំណុំរឿង ០០១ សាលក្រម (E188) កថាខណ្ឌ ៥០៨។ *សូមមើលផងដែរ តុលាការ ICTY* សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង *Radoslav Brđanin* សំណុំរឿងលេខ IT-99-36-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ ("សាលដីកា *Brđanin* (ICTY)") កថាខណ្ឌ ៤៣០ ("ទោះបីជាការចូលរួមចំណែកពុំមែនតែជាការចាំបាច់ ឬ ច្រើន យ៉ាងហោចណាស់វាគួរជាការចូលរួមចំណែកសំខាន់ចំពោះឧក្រិដ្ឋកម្មដែលជនជាប់ចោទ ត្រូវបានរកឃើញថាត្រូវទទួលខុសត្រូវ")។

*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*

"ជានិច្ចកាលគួរផ្អែកលើការវាយតម្លៃសកម្មភាពនានារបស់ជនជាប់ចោទ"[1189]។ ជាពិសេស ការចូលរួមចំណែករបស់ជនជាប់ចោទ "ពុំគប្បីវាយតម្លៃដាច់ដោយឡែកពីគ្នានោះទេ"[1190] ហើយ "ភាពសំខាន់នៃការចូលរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្មរួម នឹងត្រូវកំណត់ទៅតាមករណីជាក់ស្តែងនីមួយៗ ដោយពិចារណាលើកត្តាជាច្រើន រួមទាំង តួនាទីរបស់ជនជាប់ចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួម ហើយនឹងរាល់កិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់បទឧក្រិដ្ឋ"[1191]។

438. តាមការយល់ឃើញរបស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកាតព្វកិច្ចពន្យល់ថា តើសេចក្តីថ្លែងការណ៍ជាក់លាក់ណាមួយរបស់ លោក យឹម ទិត្យ "នៅជិត" ឬ "ជំរុញ" ការសម្លាប់រង្គាលខ្មែរក្រោម ដូចដែលបានស្នើឡើងដោយសហមេធាវីនោះទេ[1192]។ ការស៊ើបសួរពាក់ព័ន្ធគឺថា តើសកម្មភាពរបស់ លោក យឹម ទិត្យ ដែលត្រូវវាយតម្លៃទៅលើសកម្មភាពទាំងមូល (និងមិនមែនត្រឹមតែសេចក្តីថ្លែងកាណ៍របស់គាត់) បានបំពេញលក្ខខណ្ឌអប្បបរមា នៃការចូលរួមចំណែក "សំខាន់" ដែលផ្ទុយពីការចូលរួម "ចាំបាច់ ឬ ច្រើន"[1193] ដែរឬទេ។ ដូច្នេះ ចៅក្រមអន្តរជាតិនឹងបន្តទៅពិនិត្យមើលកត្តានានា ដែលកំណត់ដោយសហចៅក្រមស៊ើប

---

[1189] សំណុំរឿង ០០២/១ សាលដីកា (F36) កថាខណ្ឌ ៩៨៥។

[1190] សំណុំរឿង ០០២/១ សាលដីកា (F36) កថាខណ្ឌ ៩៨០ *យោងលើ* សាលដីកា *Kvočka* (ICTY) កថាខណ្ឌ ៩៥។ តុលាការ ICTY សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង* Šainović *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-87-A សាលដីកា ចៅក្រមអន្តរជាតិតុលាការកំពូល ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ៩២០។ តុលាការ ICTY សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Krajišnik* សំណុំរឿងលេខ IT-00-39-A សាលដីកា ចៅក្រមអន្តរជាតិតុលាការកំពូល ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ("សាលដីកា *Krajišnik* (ICTY)") កថាខណ្ឌ ២១៧។

[1191] សំណុំរឿង ០០២/១ សាលដីកា (F36) កថាខណ្ឌ ៩៨០ *ដកស្រង់* សំណុំរឿង ០០២/១ សាលក្រម (E313) កថាខណ្ឌ 693 *យោងទៅ* តុលាការ ICTY សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Kvočka និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-98-30/1-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០១ ("សាលក្រម *Kvočka* (ICTY)") កថាខណ្ឌ ៣១១។ *សូមមើលផងដែរ* សំណុំរឿង ០០២ សាលដីកា សហឧក្រិដ្ឋកម្មរួម (D97/14/15) កថាខណ្ឌ ៨១។

[1192] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២៤៩។ *សូមមើលជារួម* សំណុំរឿង ០០២ សាលដីកាលើសហឧក្រិដ្ឋកម្មរួម (D97/14/15) កថាខណ្ឌ ១០១។

[1193] សំណុំរឿង ០០២/១ សាលដីកា (F36) កថាខណ្ឌ ៩៨០ *ដកស្រង់* សាលក្រម *Krajišnik Kvočka* (ICTY)" កថាខណ្ឌ ២១៥។ *សូមមើលផងដែរ* សាលដីកា Kvočka (ICTY)" កថាខណ្ឌ ៩៧-៩៨។

អង្កេតអន្តរជាតិក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ បានចូលរួមចំណែកសំខាន់ ទៅតាមលក្ខខណ្ឌតម្រូវ។

439. នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា "យឹម ទិត្យ, តាម៉ុក និងកម្មាភិបាលភូមិភាគនិរតីដទៃទៀតបានចូលរួមចំណែកនៅក្នុងគោលបំណងរួម ដើម្បីអនុវត្តនៅក្នុងតំបន់ជាក់លាក់នានានៃកម្ពុជាប្រជាធិបតេយ្យ នូវផែនការទូទាំងប្រទេសមួយ ក្នុងការកម្ទេចទាំងស្រុង ឬមួយផ្នែកនៃខ្មែរក្រោម"[1194]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរកឃើញបន្ថែមទៀតថា លោក យឹម ទិត្យ "បានចូលរួមចំណែកយ៉ាងសំខាន់" ក្នុងសហឧក្រិដ្ឋកម្មរួមនេះ ដោយក្នុងនោះរួមមាន៖

> [ការ] ចូលរួមនៅក្នុងការប្រជុំនានានៅក្នុងភូមិភាគទាំងពីរ ការកំណត់អត្តសញ្ញាណ និងការថ្កោលទោសចំពោះប្រជាជននៃក្រុមទាំងនោះថាជាជនក្បត់ និងខ្មាំងដែលត្រូវបោសសម្អាត ការបញ្ជាឱ្យចាប់ខ្លួន និងសម្លាប់មនុស្ស ការរៀបចំកិច្ចប្រជុំផ្សេងៗជាមួយអ្នកក្រោមបង្គាប់របស់ខ្លួនស្តីពីប្រតិបត្តិការបោសសម្អាត និងការបញ្ជាឱ្យពួកគេប្រុងប្រយ័ត្នជានិច្ចក្នុងការចាប់ និងសម្លាប់មនុស្ស ការតាមដានការអនុវត្តការបោសសម្អាត និងការសម្របសម្រួលលើបណ្តាញមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដែលតាមរយៈនេះ អ្នកទោសត្រូវបានកំណត់អត្តសញ្ញាណ សម្រិតសម្រាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ចោលជាប្រចាំ។ អមជាមួយនឹងកសិណរបស់គាត់ដែលបញ្ជាក់យ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តរបស់គាត់ដើម្បីអនុវត្តផែនការនានារបស់*អង្គការ* ការអះអាងនេះបង្ហាញអំពីចេតនារបស់គាត់ក្នុងការអនុវត្តគោលនយោបាយដើម្បី [...] កំណត់គោលដៅ [ខ្មែរក្រោម] [1195]។

440. យោងតាមចំណុចខាងលើ ភ័ស្តុតាងបង្ហាញច្បាស់ថា ការផ្តោតមិនត្រឹមត្រូវរបស់សហមេធាវីទៅលើសុន្ទរកថា និងមតិរបស់ លោក យឹម ទិត្យ[1196] គឺជាការមិនអើពើចំពោះសកម្មភាពជាច្រើនដែលបានកំណត់យ៉ាងជាក់លាក់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលសកម្មភាព

---

[1194] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០១៦(ii)។

[1195] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០២២។

[1196] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់ លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២៤៧។

ទាំងនោះគឺជំរុញគោលបំណងរួមនៃការសម្លាប់បែបប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម។ អង្គបុរេជំនុំជម្រះសម្រេចថា សកម្មភាពទាំងនេះ នៅពេលយកមកពិចារណាជារួម អាចចាត់ទុកជាការចូលរួមចំណែកសំខាន់នៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ។ លើសពីនេះ ចៅក្រមអន្តរជាតិយល់ឃើញថា សកម្មភាពទាំងនេះគឺជាការប្រព្រឹត្តផ្ទាល់ខ្លួន និងជាលក្ខណៈបុគ្គលរបស់ លោក យឹម ទិត្យ ក្នុងទិសដៅជំរុញគោលនយោបាយ ប.ក.ក ក្នុងការលុបបំបាត់ខ្មែរក្រោម។ យោងតាមសំអាងហេតុទាំងនេះ ចៅក្រមអន្តរជាតិ មិនអាចទទួលយកការអះអាងដែលថា ការទទួលខុសត្រូវរបស់ លោក យឹម ទិត្យ ក្រោមសហឧក្រិដ្ឋកម្មរួម ខ ផ្អែកលើពិរុទ្ធភាពល្មើសច្បាប់ ដោយសារការមានទំនាក់ទំនងជាមួយនោះឡើយ ដូច្នេះ សម្រេចច្រានចោលទឡ្ហីករណ៍របស់សហមេធាវីលើករណីនេះ[1197]។

441. ចំណុចចុងក្រោយ ចៅក្រមអន្តរជាតិជឿជាក់ថា មានភស្តុតាងគ្រប់គ្រាន់ដើម្បី គាំទ្រដល់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីការចូលរួមចំណែកសំខាន់ដើម្បីឈានទៅសម្រេចសហឧក្រិដ្ឋកម្មរួម ខ។ ជាពិសេស ចៅក្រមអន្តរជាតិកត់សម្គាល់អំពីសកម្មភាព និងភស្តុតាងដូចខាងក្រោម៖

- លោក យឹម ទិត្យ បានចុះទៅពិនិត្យមន្ទីរសន្តិសុខវត្តព្រះធាតុដោយផ្ទាល់ "យ៉ាងហោចណាស់មានឱកាស ចំនួន ០៣ ដងដែរ ចន្លោះពីចុងឆ្នាំ១៩៧៦ រហូតដល់ខែមករា ឆ្នាំ១៩៧៨" ដែលជាកន្លែងខ្មែរក្រោមត្រូវបានឃុំឃាំង និងសម្លាប់ចោល ជាបន្តបន្ទាប់ និងជាកន្លែងដែលលោក យឹម ទិត្យ ធ្វើការសួរចម្លើយ និងកំណត់អត្តសញ្ញាណអ្នកទោសថាជាសត្រូវមែនឬមិនមែន[1198]។

---

[1197] ចៅក្រមអន្តរជាតិច្រានចោលភ្លាមៗនូវទឡ្ហីករណ៍ដដែលៗ ឬ គ្មានមូលដ្ឋានរបស់សហមេធាវី ដែលគ្រាន់តែយោងទៅមូលដ្ឋានផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍ ដោយពុំបានបង្ហាញនូវកំហុសជាក់លាក់ណាមួយនោះ។ *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២៤៥ កថាខណ្ឌ ២៤៩ កថាខណ្ឌ ២៥០។ *សូមមើលផងដែរ* មូលដ្ឋានទី ២.២ មូលដ្ឋានទី ៥.១ មូលដ្ឋានទី ៥.២ *ខាងលើ*។

[1198] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៩២។ *សូមមើលផងដែរ* មូលដ្ឋានទី ៥.៣(គ) ខាងក្រោម។

- យោងតាម យូ ភ្នំ[1199] លោក យឹម ទិត្យ បានលើកឡើងអំពី "យួន" ខ្មែរ ថាជាបញ្ហាសន្តិសុខផ្ទៃក្នុង ដែលបាន "តាមដាន" និង "បង្កប់ផ្ទៃក្នុង ស៊ីរូងផ្ទៃក្នុង ក្នុងបណ្ដាញកម្មាភិបាលពីថ្នាក់ឃុំ ថ្នាក់ស្រុករហូតដល់មជ្ឈិម"។ សាក្សីយល់ថា បញ្ហាចេញដោយ លោក យឹម ទិត្យ គឺធ្វើឡើង "តាមបណ្ដាញ" ហើយរចនាសម្ព័ន្ធឋានានុក្រមនេះអនុញ្ញាតឱ្យកម្មាភិបាលថ្នាក់លើ អាចប្រមូលព័ត៌មាន និងចាត់វិធានការ ដើម្បីតាមដានជនបង្កប់។

- នៅក្នុងកិច្ចប្រជុំមួយនៅការដ្ឋានទំនប់កង្គូត ដែលមានអ្នកចូលរួមប្រមាណ ៧០០ ទៅ ៨០០ នាក់លោក យឹម ទិត្យ បានលើកឡើងអំពី "វៀជាមួយយួន" ដែលស្ថិតក្នុងចំណោម "ខ្មាំងផ្ទៃក្នុង ដែលលាក់ខ្លួនស៊ីរូងផ្ទៃក្នុង" ក្នុងចំណោមប្រជាជន។ លោក យឹម ទិត្យ បានជំរុញឱ្យប្រជាជន "ឃ្លាំមើល និងរាយការណ៍" អំពីខ្មាំងទាំងនោះ "ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះមុននឹងពួកនេះកម្ទេចពួកយើ"[1200] ។

- យោងតាមលោក លឹម ទីម[1201] អតីតសន្តិសុខនៅរោងចក្រស្ករសកំពង់ក្ដុលនៅស្រុកសង្កែ ក្នុងពេលសន្និបាតមួយនៅដើមពាក់កណ្ដាលឆ្នាំ១៩៧៨ នៅសាកលវិទ្យាល័យបាត់ដំបង នៅទីនោះលោក យឹម ទិត្យត្រូវបានឧទ្ទេសនាមជាលេខាភូមិភាគពាយព្យ លោក យឹម ទិត្យ បានថ្លែងសុន្ទរកថាស្នើអ្នកចូលរួម ទប់ស្កាត់ "យួន" កុំឱ្យដុតភ្លើង ឬ វាយកំទេចរោងចក្រ។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកលើភ័ស្តុតាងនេះក៏ដោយ ចៅក្រមអន្តរជាតិសង្កេតឃើញថា គាត់បានរកឃើញផ្នែកផ្សេងមួយទៀត ដែលមិនអាចទុកចិត្តបាន នៅក្នុងសក្ខីកម្មរបស់សាក្សីទាក់ទងនឹងការចាប់ខ្លួនជាបន្តបន្ទាប់ និងការជម្លៀសកម្មករវៀតណាម និងខ្មែរ

---

[1199] កំណត់ហេតុនៃការស្ដាប់ចម្លើយ យូ ភ្នំ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ D219/406 ត្រង់ ERN (ភាសាអង់គ្លេស) 01117238-39 (ឆ.១៧៥-ឆ.១៨៥)។

[1200] កំណត់ហេតុនៃការស្ដាប់ចម្លើយ វី ផាន់ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ D219/85 ត្រង់ ERN 01040093-94 (ឆ.៣-ឆ.៥)។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៩៥។

[1201] កំណត់ហេតុនៃការស្ដាប់ចម្លើយ លឹម ទីម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ D118/108 ត្រង់ ERN (ភាសាអង់គ្លេស) 00951928 (ឆ.១៧-ឆ.១៩) ERN (ភាសាអង់គ្លេស) 00951931-32 (ឆ.៤៧-ឆ.៥៤)។ កំណត់ហេតុនៃការស្ដាប់ចម្លើយ លឹម ទីម ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ D219/649 ត្រង់ ERN (ភាសាអង់គ្លេស) 01196463-64 (ឆ.៦២ ឆ.៦៤ ឆ.៦៩) ERN (ភាសាអង់គ្លេស) 01196466-67 (ឆ.៧៩-ឆ.៨៣ ឆ.៨៦-ឆ.៨៧)។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៩៥។

ក្រោម ដោយបង្ខំ នៅរោងចក្រស្ករ[1202]។ ចៅក្រមអន្តរជាតិជឿជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាយ៉ាងត្រឹមត្រូវ នូវភាពមិនស៊ីសង្វាក់គ្នានៃភស្តុតាង និងភាពជឿជាក់ជារួមចំពោះសាក្សី ក្នុងន័យនេះ ចៅក្រមអន្តរជាតិពុំរកឃើញថាមានកំហុសនោះឡើយ[1203]។

- យោងតាមលោក ឈឹង ឈឿត[1204] នៅក្នុងការប្រជុំរវាង លោក យឹម ទិត្យ និងអ្នកក្រោមបង្គាប់របស់គាត់ លោក យឹម ទិត្យ បានលើកឡើងថា "គេថាគេបោសសម្អាតខ្មាំងយួន"។ ការប្រជុំនេះមានបំណងអំពាវនាវឱ្យកាប់សម្លាប់ "អ្នកណាជាប់ខ្សែយួន ចេះភាសាយួនបោសសម្អាតទាំងអស់"។ នៅក្នុងកិច្ចប្រជុំនោះ លោក យឹម ទិត្យ បានជំរុញលើកឡើងថា៖ "កុំឱ្យប្រឆាំងជាមួយនីរតី ឱ្យរួបរួមជាមួយគ្នាទៅ ហើយកុំឱ្យចូលជើងជាមួយយួន"។

442. ដោយមានភស្តុតាងអំពីការចូលរួមយ៉ាងក្លៀវក្លារបស់ លោក យឹម ទិត្យ ក្នុងផែនការរួមមួយដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងខ្មែរក្រោមនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់គាត់ ចៅក្រមអន្តរជាតិត្រូវតែបដិសេធចោលមូលដ្ឋានទី ៥.៣(ii)។

**មូលដ្ឋាន ៥.៣ (III) ៖ កំហុសដែលទាក់ទងការចោទប្រកាន់ នៅក្នុងការសម្រេចថា យឹម ទិត្យ បានរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម គ**

ក. សារណា

443. សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ រួមចំណែកដល់គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម គ ក្នុងការជំរុញឱ្យមាន

---

1202 *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៧៤១ កថាខណ្ឌ ៧៤៥។

1203 ដូចបានរំលឹកឡើងវិញរួចហើយ តុលាការអង្គហេតុឥតលម្អៀង អាចទទួលយកផ្នែកខ្លះនៃសក្ខីកម្មរបស់សាក្សី និងច្រានចោលផ្នែកផ្សេងទៀត ក្រោយពីបានពិចារណាលើសក្ខីកម្មទាំងមូល។ *សូមមើល* សំណុំរឿង ០០២/១ សាលដីកា (F36) កថាខណ្ឌ ៣៥៧។ *សូមមើលជាទូទៅ* មូលដ្ឋានទី៥ ការពិចារណាលើភស្តុតាង*ខាងលើ*។

1204 កំណត់ហេតុនៃការស្តាប់ចម្លើយ ឈឹង ឈឿត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ D219/953 ត្រង់ ERN 01425176-01425177 (ឆ.៧០-៧៣ ឆ.៨២) ERN 01425178 (ឆ.៨៤)។ កំណត់ហេតុនៃការស្តាប់ចម្លើយ ឈឹង ឈឿត ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧ D219/954 ត្រង់ ERN 01425185 (ឆ.៧)។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ៣៩៧។

ប្រព័ន្ធនៃការធ្វើបាបនៅមន្ទីរសន្តិសុខវត្តព្រះធាតុ ពីខែតុលា ឆ្នាំ១៩៧៥ រហូតដល់ចុងបញ្ចប់នៃរបបនេះ ដែលជាធាតុផ្សំនៃការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ១ និងសហឧក្រិដ្ឋកម្មរួម ២[1205]។

444. ជាដំបូង ពាក់ព័ន្ធនឹងការចុះទៅត្រួតពិនិត្យជាទៀងទាត់នៅវត្តព្រះធាតុ សហមេធាវីបានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទាញចេញដោយមិនត្រឹមត្រូវពីការចូលរួមរបស់ យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួម គ ដោយសារតែការចោទប្រកាន់ពីសមាជិកភាពរបស់គាត់នៅគណៈកម្មាធិការស្រុកគិរីវង់[1206]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានធ្វើការពិចារណាទៅលើ ភ័ស្តុតាងទាំងអស់ជារួមរបស់ (១) ដុក ចាន់ (ដែលភ័ស្តុតាងរបស់គាត់មានភាពផ្ទុយ និងមិនពាក់ព័ន្ធនឹងពេលវេលា) (២) យូ ភ្នំ (មិនដែលទៅក្បែរមន្ទីរសន្តិសុខ ហើយការទៅពិនិត្យផ្ទាល់របស់គាត់ នៅចោទជាបញ្ហានៅឡើយ) (៣) ទន់ ស៊ួន (ដែលនៅវត្តព្រះធាតុ ត្រឹមតែរយៈពេលខ្លីប៉ុណ្ណោះ គឺ បួនថ្ងៃ) (៤) អោក ចន (ព័ត៌មានរបស់គាត់មិនមានកាលបរិច្ឆេទច្បាស់លាស់ ហើយមិនអាចកំណត់អត្តសញ្ញាណ យឹម ទិត្យ បាន" និង (៥) ហោ យ៉ន (ផ្តល់ភ័ស្តុតាងផ្ទុយ និងមិនអាចជឿបាន ដោយបានបញ្ជាក់ថា គាត់ជាប់ឃុំឃាំងនៅក្នុងឆ្នាំ១៩៧៣ និងមិនអាចកំណត់អត្តសញ្ញាណ យឹម ទិត្យ តាមរយៈរូបថត)[1207]។

445. ទីពីរ សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមដោយផ្ទាល់ ក្នុងការសួរចម្លើយចំនួនពីរដង នៅវត្តព្រះធាតុ ដោយផ្អែកលើចម្លើយតែមួយរបស់ ទន់ ស៊ួន[1208]។ ដោយពឹងផ្អែកទៅលើ ទន់ ស៊ួន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានធ្វើការពិចារណាទៅលើភ័ស្តុតាងផ្ទុយ និងថា គាត់មិនបានលើកឡើងថា យឹម ទិត្យ បានសួរចម្លើយអ្នកទោសនៅក្នុងការស្តាប់ចម្លើយ និងការទំនាក់ទំនងពីមុនមក

[1205] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥១។

[1206] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥២។

[1207] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

[1208] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៥ *យោងទៅ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/110។

នោះទេ[1209]។ លើសពីនេះទៀត មានភាពមិនច្បាស់លាស់ថាតើ គាត់យកព័ត៌មាននេះពីបទពិសោធន៍ផ្ទាល់ ឬគាត់ទទួលឥទ្ធិពលពីការបង្ហាញជាសាធារណៈដោយខុសច្បាប់នូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ឬការទំនាក់ទំនងជាមួយអ្នកស៊ើបអង្កេត អង្គការមិនមែនរដ្ឋាភិបាល ឬតាមរយៈការពិភាក្សាជាសាធារណៈ[1210]។ ចំពោះចម្លើយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ របស់ ទន់ ស៊ួន (គាត់បានលើកឡើងជាលើកដំបូងថា យឹម ទិត្យ បានសួរចម្លើយអ្នកទោសពីរដង) សហមេធាវីបង្ហាញថា ទន់ ស៊ួន មិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងតំបន់ឃុំឃាំងអ្នកទោស ប៉ុន្តែគាត់អះអាងថា បានស្តាប់ឮ យឹម ទិត្យ សួរសំណួរជាក់លាក់ នៅក្នុងពេលសួរចម្លើយ[1211] និងថាពេលវេលានៃការលើកឡើងពីការជាប់ឃុំឃាំងរបស់គាត់ មិនច្បាស់លាស់ និងមិនអាចពឹងផ្អែកបានទេ[1212]។

446. ទីបី សហមេធាវីបានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមដោយផ្ទាល់នៅក្នុងការសម្លាប់នៅវត្តព្រះធាតុ ដោយចេញបញ្ជាឲ្យ "វះពោះអ្នកទោស"[1213]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកតែទៅលើ ហោ យ៉ន សម្រាប់ការសម្រេចនេះ ដោយភ័ស្តុតាងរបស់ ហោ យ៉ន មានភាពមិនស៊ីសង្វាក់គ្នា ហើយគាត់ត្រូវបានឃុំឃាំងនៅក្នុងឆ្នាំ១៩៧៣ និងបញ្ជាក់ថា "ខ្ញុំមិនបានឃើញមានរឿងអ្វីកើតឡើងនោះទេ"[1214]។ លើសពីនេះទៀត ភ័ស្តុតាងរបស់ ដុក ចាន់ ពាក់ព័ន្ធនឹងការប្រជុំរបស់ យឹម ទិត្យ ជាមួយតាព្រីង (ប្រធានវត្តព្រះធាតុ) មិនមានព័ត៌មានលម្អិត និងមិនច្បាស់លាស់ថាតើ គាត់បានដឹង

---

[1209] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៥ *យោងទៅ* កំណត់ហេតុស្តាប់ចម្លើយសាក្សី (ទន់ ស៊ួន) ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ឯកសារ D1.3.11.56។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D5/122។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D3/8។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១១ ឯកសារ D13។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/22។ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/122។

[1210] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៥។

[1211] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៦។

[1212] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៧។

[1213] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៩។

[1214] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦០។

ព័ត៌មានលម្អិតអំពីរចនាសម្ព័ន្ធរាយការណ៍ ដោយរបៀបណា[1215]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកដោយមិនត្រឹមត្រូវ ទៅលើឋានានុក្រមបញ្ជាការនៅក្នុងស្រុកគិរីវង់ ដោយពឹងផ្អែកទៅលើសក្ខីកម្មពីរបីជួរប៉ុណ្ណោះរបស់ ហ៊ុក (អោក) ចន និងការបកស្រាយដោយមិនត្រឹមត្រូវនូវភស្តុតាងរបស់ ហោ យ៉ន[1216]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើចម្លើយរបស់ អោក ចន ដែលរួមមានផងដែរថា យឹម ទិត្យ មិនបានចេញបញ្ជាឡើយ[1217]។

447. សហមេធាវីបានសន្និដ្ឋានថា មិនមានអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចថា យឹម ទិត្យ បានទៅពិនិត្យមន្ទីរសន្តិសុខវត្តព្រះធាតុជាទៀងទាត់ បានចូលរួមដោយផ្ទាល់ក្នុងការសួរចម្លើយអ្នកទោស និងចេញបញ្ជាឱ្យ "វះពោះអ្នកទោស"[1218]ទេ។ សហមេធាវីបានលើកឡើងថា ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនយុត្តិធម៌ មិនសមហេតុផល និងជាការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់គាត់[1219]។

448. ជាចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឡ្ហីករណ៍ថា សហមេធាវីមិនបានបង្ហាញអំពីកំហុសដែលអាចត្រួតពិនិត្យឡើងវិញណាមួយ នៅក្នុងការសម្រេច ដែលថា យឹម ទិត្យ ប្រហែលជាបានចូលរួមយ៉ាងសំខាន់ចំពោះប្រព័ន្ធនៃការធ្វើបាបនៅវត្តព្រះធាតុ[1220]។ ដោយផ្ទុយពីការអះអាងរបស់សហមេធាវី សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានទាញសន្និដ្ឋានអំពីការចូលរួមរបស់ យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួម ចេញពីការចោទពីសមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការស្រុក ឡើយ ព្រោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានលើកឡើងយ៉ាងច្រើនអំពីភស្តុតាងស្តីពី សិទ្ធិអំណាច របស់ យឹម ទិត្យ ទៅលើ និងការចូលរួមនៅក្នុង ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅវត្តព្រះធាតុ[1221]។

---

[1215] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦១។

[1216] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦២។

[1217] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦៣។

[1218] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៤, ២៥៨, ២៦៤។

[1219] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៤, ២៥៨, ២៦៤។

[1220] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៤៧។

[1221] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៤៧។

449. ជាដំបូង សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឡ្ហីករណ៍ថា សហមេធាវីមិនបានបង្ហាញអំពីកំហុសណាមួយ ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសម្រេចថា យឹម ទិត្យ ប្រហែលជាទៅពិនិត្យវត្ត ព្រះធាតុជាទៀងទាត់[1222]។ សហមេធាវីមិនបានពិចារណាទៅលើភ័ស្តុតាងគោលរបស់សាក្សី ដុក ចាន់, យូ ភ្នំ, អោក ចន និងហោ យ៉ាន[1223]។ ចំពោះសាក្សី ដុក ចាន់ សហមេធាវីមិនបានពន្យល់ពីការចោទពីភាពផ្ទុយគ្នានៅក្នុងភ័ស្តុតាងរបស់គាត់ និងកំណត់ប្រភេទដោយមិនត្រឹមត្រូវទៅលើភ័ស្តុតាងរបស់គាត់ថា មិនមានភាពទាក់ទងពេលវេលា[1224]។ ចំពោះ ហោ យ៉ានសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សហមេធាវីបានបង្ហាញដោយមិនត្រឹមត្រូវនូវភ័ស្តុតាងរបស់គាត់ និងថា ការដែលគាត់មិនអាចកំណត់អត្តសញ្ញាណ យឹម ទិត្យ នៅក្នុងរូបថតនោះ មិនបានធ្វើឲ្យប៉ះពាល់ដល់ចម្លើយរបស់គាត់ទេ ព្រោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកទៅលើភ័ស្តុតាងទាំងមូល[1225]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា សហមេធាវីបកស្រាយដោយមិនត្រឹមត្រូវទៅលើភ័ស្តុតាងរបស់ យូ ភ្នំ អំពីថាតើ គាត់ធ្លាប់ទៅវត្តព្រះធាតុដែរឬអត់នោះ[1226] និងថា ការចោទប្រកាន់ពាក់ព័ន្ធនឹង ភ័ស្តុតាងរបស់ អោក ចន ត្រូវបានលើកឡើងដោយមិនត្រឹមត្រូវ ព្រោះសាក្សីបានស្គាល់ យឹម ទិត្យ រួចទៅហើយ[1227]។

450. ទីពីរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកទឡ្ហីករណ៍ថា សហមេធាវីមិនបានបង្ហាញអំពីកំហុសដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា យឹម ទិត្យ ប្រហែលជាចូលរួមក្នុងការសួរចម្លើយនៅវត្តព្រះធាតុ[1228]។ សហមេធាវីមិនបានបញ្ជាក់ថា តើពួកគេមានន័យថាយ៉ាងដូចម្តេច នៅពេលលើកឡើងពី "ការចូលរួមដោយផ្ទាល់"[1229] នេះ ហើយការវាយតម្លៃរបស់ពួកគេទៅលើភ័ស្តុតាងរបស់ ទន់ ស៊ួន ក៏មិនត្រឹមត្រូវដែរ

[1222] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៤៨ (ចំណងជើង)។

[1223] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៤៨។

[1224] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៤៩។

[1225] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥០។

[1226] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥១។

[1227] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥២។

[1228] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥៣។

[1229] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥៣។

ហើយបានសន្និដ្ឋានដោយមិនត្រឹមត្រូវថា គាត់បានលើកឡើងជាលើកដំបូងអំពីចំណុចដែល យឹម ទិត្យ សួរចម្លើយអ្នកទោស ក្រោយពេលត្រូវបានអ្នកស៊ើបអង្កេតសាកសួរ[1230]។ ការលើកឡើងដោយប្រយោលបន្ថែមទៀត របស់សហមេធាវីដែលថា ភស្តុតាងរបស់ ទន់ ស៊ួន អាចទទួលរងឥទ្ធិពលដោយការបង្គាញដីកា សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី នៅក្នុងឆ្នាំ២០១១ គឺជាការប៉ាន់ស្មានដោយគ្មានមូលដ្ឋាន[1231]។ ភស្តុតាងបន្ថែមទៀតបានបង្ហាញអំពី ការចូលរួមរបស់ យឹម ទិត្យ នៅក្នុងការសួរចម្លើយនៅវត្តព្រះធាតុ និងការទទួលខុសត្រូវចំពោះការសួរចម្លើយនៅវត្តព្រះធាតុ[1232]។

451. ទីបី សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឡ្ហីករណ៍ថា សហមេធាវីមិនបានបង្ហាញអំពីកំហុសដែលអាចពិនិត្យឡើងវិញបាន នៅក្នុងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ ប្រហែលជាបានចូលរួមក្នុងការសម្លាប់នៅវត្តព្រះធាតុ និងថា គាត់បញ្ជាឲ្យ "វះពោះ" អ្នកទោស[1233]។ សហមេធាវីលើកឡើងថា ការសម្រេចនេះផ្អែកតែទៅលើ ភស្តុតាងរបស់ ហោ យ៉ន តែម្នាក់គត់នោះ ដែលផ្ទុយជាមួយនឹងការជំទាស់ជាបន្តបន្ទាប់របស់ពួកគេចំពោះភស្តុតាងរបស់ ដុក ចាន់[1234]។លើសពីនេះទៀត សហមេធាវីមិនបានបង្ហាញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានវិភាគទៅ លើភស្តុតាងដោយមិនត្រឹមត្រូវ ព្រោះថា ភាពមិនស្របគ្នាមួយចំនួននៅក្នុងភស្តុតាងរបស់ ហោ យ៉ន ត្រូវបានពិភាក្សាយ៉ាងច្បាស់លាស់ ហើយប្រាកដណាស់ថា គាត់បានដឹងគ្រប់គ្រាន់អំពីតួនាទី និងសិទ្ធិអំណាចរបស់ យឹម ទិត្យ[1235]។ ជាចុងក្រោយ សហមេធាវីអះអាងដោយមិនត្រឹមត្រូវថា ដុក ចាន់ មិនបានដឹងអំពីរចនាសម្ព័ន្ធ និងប្រតិបត្តិការនៅវត្តព្រះធាតុ[1236] និងបានដកស្រង់សក្ខីកម្មរបស់ អោក ចន ដោយមិនត្រឹមត្រូវ[1237]។

---

[1230] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥៤។

[1231] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥៥។

[1232] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥៦។

[1233] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥៧។

[1234] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥៧។

[1235] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៥៨-១៦០។

[1236] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៦១។

[1237] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/27) កថាខណ្ឌ ១៦២។

## ខ. ការពិភាក្សា

452. តាមមូលដ្ឋាន ៥.៣ (iii) សហមេធាវីបានជំទាស់ចំពោះការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា (១) យឹម ទិត្យទៅត្រួតពិនិត្យ វត្តព្រះធាតុជាទៀងទាត់[1238] (២) យឹម ទិត្យ ចូលរួមដោយផ្ទាល់នៅក្នុងការសួរចម្លើយនៅវត្តព្រះធាតុ និង (៣) យឹម ទិត្យ ចូលរួមដោយផ្ទាល់ក្នុងការសម្លាប់នៅវត្តព្រះធាតុ[1239]។ ការជំទាស់ទាំងអស់នេះ ពាក់ព័ន្ធនឹងការចូលរួមយ៉ាងសំខាន់របស់ យឹម ទិត្យ ចំពោះសហឧក្រិដ្ឋកម្មរួម គ ដែលត្រូវបានកំណត់ថាជាការជំរុញឱ្យមានប្រព័ន្ធនៃការធ្វើបាប នៅមន្ទីរសន្តិសុខវត្តព្រះធាតុ[1240]។

### *a. ការចុះពិនិត្យរបស់ យឹម ទិត្យ នៅវត្តព្រះធាតុ*

453. ចៅក្រមអន្តរជាតិចាត់ទុកថាមិនមានមូលដ្ឋានទេ ចំពោះការចោទប្រកាន់របស់សហមេធាវីថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកតែទៅលើ សមាជិកភាពរបស់ យឹម ទិត្យ នៅក្នុងគណៈ កម្មាធិការស្រុក[1241] ដើម្បីសន្និដ្ឋានថា យឹម ទិត្យ បានទៅត្រួតពិនិត្យមន្ទីរសន្តិសុខ

---

[1238] អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយោងទៅ "ការពិនិត្យទៀងទាត់" របស់សមាជិកគណៈកម្មាធិការស្រុកជាច្រើន គឺមិនមែនតែ យឹម ទិត្យ ម្នាក់ទេ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានលើកឡើងថា យឹម ទិត្យទៅពិនិត្យ វត្តព្រះធាតុជាច្រើនលើក និង "យ៉ាងតិចបំផុតបីដង"។ *សូមមើល* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៣៥, ៤៣៩, ៤៦៣។

[1239] អង្គជំនុំជម្រះកត់សម្គាល់ថា សហមេធាវីបានយល់ទៅ "ការចូលរួមផ្ទាល់" របស់ យឹម ទិត្យ ក្នុងការសួរចម្លើយ និងសម្លាប់ ដោយមិនមានការបញ្ជាក់បន្ថែមឡើយ។ ក្នុងន័យនេះ អង្គជំនុំជម្រះកត់សម្គាល់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានចាត់ចំណាត់ថ្នាក់ អំពើរបស់ យឹម ទិត្យ ថាជាការប្រព្រឹត្តិឧក្រិដ្ឋកម្មផ្ទាល់ឡើយ ប៉ុន្តែថាជាការប្រព្រឹត្តិ តាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម។ ការចូលរួមរបស់ យឹម ទិត្យ នៅក្នុងការសម្លាប់ និងការសួរចម្លើយ គឺជាផ្នែកនៃការរួមចំណែកយ៉ាងសំខាន់របស់គាត់ចំពោះការអនុវត្តគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម គ។

[1240] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ១០១៦ (iii)។

[1241] ចៅក្រមអន្តរជាតិសូមរំឭកថា ការសម្រេចអំពីការរួមចំណែកយ៉ាងសំខាន់របស់ជនជាប់ចោទនៅក្នុង សហឧក្រិដ្ឋកម្មរួម អាស្រ័យទៅលើកត្តាជាច្រើន ដូចជា "តួនាទីរបស់ជនជាប់ចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួម និងការខិតខំប្រឹងប្រែងនានា ក្នុងការរារាំងអំពើឧក្រិដ្ឋ" (សូមមើលមូលដ្ឋាន ៥.៣ (ii) ពាក់ព័ន្ធសហឧក្រិដ្ឋកម្មរួម គ ខាងលើ។ ហេតុដូច្នេះ តួនាទីរបស់ យឹម ទិត្យ ជាសមាជិកគណៈកម្មាធិការស្រុកគិរីវង់ ដែលគ្រប់គ្រងដោយផ្ទាល់ទៅលើ មន្ទីរសន្តិសុខវត្តព្រះធាតុ គឺជាកត្តាពាក់ព័ន្ធយ៉ាងខ្លាំង ដែលគួរត្រូវបានពិចារណា។

វត្តព្រះធាតុជាច្រើនលើក[1242]។ តាមពិតទៅ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា សមាជិកគណៈកម្មាធិការស្រុកជាច្រើន រួមទាំង យឹម ទិត្យ បានទៅត្រួតពិនិត្យទីតាំងនោះជាទៀងទាត់[1243] ថា "យឹម ទិត្យ ក៏បានចុះទៅមន្ទីរសន្តិសុខវត្តព្រះធាតុ ជាមន្ទីរសន្តិសុខថ្នាក់ស្រុក ជាច្រើនដងផងដែរ"[1244] និងថា "ចន្លោះចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៨ យឹម ទិត្យ បានចុះពិនិត្យមន្ទីរសន្តិសុខ យ៉ាងហោចណាស់បីដង"[1245]។ ដើម្បីគាំទ្រដល់ការសម្រេចទាំងអស់នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើភស្តុតាងរបស់សាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំនាក់ ដែលពួកគេម្នាក់ៗផ្តល់ចម្លើយអំពីវត្តមានរបស់ យឹម ទិត្យ នៅមន្ទីរសន្តិសុខ[1246] និងមិនមែនគ្រាន់តែអំពីភស្តុតាងថា គណៈកម្មាធិការស្រុកគិរីវង់គ្រប់គ្រងដោយផ្ទាល់ទៅលើទីតាំងឡើយ[1247]។ ការជំទាស់នីមួយៗទៅលើភស្តុតាងរបស់សាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួនប្រាំនាក់នេះ គឺ ដុក ចាន់, យូ ភ្នំ, ទន់ ស៊ួន, អោក ចន និង ហោ យ៉ន នឹងត្រូវពិភាក្សានៅផ្នែកខាងក្រោម[1248]។

454. ចំពោះការចោទប្រកាន់ពីការមិនទាក់ទងនឹងពេលវេលានៃភស្តុតាងរបស់ ដុក ចាន់[1249] បើទោះបីជាសាក្សីបានបញ្ជាក់ថា មិននៅមន្ទីរសន្តិសុខវត្តព្រះធាតុ នៅក្រោយខែមិថុនា ឆ្នាំ១៩៧៥ ក្តី (បើទោះជាឈ្មោះរបស់គាត់ នៅមានក្នុងបញ្ជីជាសមាជិកបុគ្គលិកពន្ធនាគារ រហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៧ ក្តី) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាថា ប្រយោគនេះមិនអាចជឿបានទេ

---

[1242] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥២។

[1243] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៣៩។

[1244] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៣៥។

[1245] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៣៦។ *សូមមើលផងដែរ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៣៩២។

[1246] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៦៤-៤៦៩ (បញ្ជាក់ថា "សាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥ នាក់ រួមទាំង អតីតអ្នកជាប់ឃុំ ចំនួនបីនាក់ ផ្តល់ភស្តុតាងអំពីការចុះពិនិត្យ ទីតាំងឧក្រិដ្ឋកម្មរបស់ យឹម ទិត្យ និង *យោងទៅកា*ភស្តុតាងរបស់ ដុក ចាន់ យូ ភ្នំ ទន់ ស៊ួន អោក ចន និង ហោ យ៉ន)។

[1247] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥២ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៣៩។

[1248] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

[1249] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

"ដោយសារគាត់ត្រូវបានកំណត់អត្តសញ្ញាណ ដែលគួរឲ្យជឿជាក់បាន និងទទួលយកបាន ថា "*ចាន់*" ដោយសាក្សីពីរនាក់ ដែលជាប់ឃុំនៅមន្ទីរសន្តិសុខវត្តព្រះធាតុ នៅឆ្នាំ១៩៧៧" និងដោយសារតែ "ប្អូនប្រុស គាត់ឈ្មោះ យូ ភ្នំ បានលើកឡើងថា គាត់បានទៅលេង ដុក ចាន់ ជាទៀងទាត់ នៅមន្ទីរសន្តិសុខនោះ នៅចន្លោះរដូវវស្សា ឆ្នាំ១៩៧៦ រហូតដល់របបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបញ្ចប់"[1250]។ នៅក្នុងពេលទៅលេងទាំងអស់នោះ យូ ភ្នំ ក៏បានឃើញ យឹម ទិត្យ ទៅត្រួតពិនិត្យនៅមន្ទីរសន្តិសុខផងដែរ[1251]។ អង្គជំនុំជម្រះសូមរំឭកថា អ្នកវិនិច្ឆ័យលើអង្គហេតុ អាច "ទទួលយកដោយសមហេតុផល នូវផ្នែកខ្លះនៃសក្ខីកម្មរបស់សាក្សី ហើយបដិសេធចោលផ្នែកខ្លះទៀត" បន្ទាប់ពីបានពិចារណាទៅលើភ័ស្តុតាងទាំងស្រុង[1252] ដូច្នេះហើយ អង្គជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុសឡើយ ក្នុងការពឹងផ្អែកដោយសមហេតុផលទៅលើសក្ខីកម្មរបស់ ដុក ចាន់ ពាក់ព័ន្ធនឹង រចនាសម្ព័ន្ធ និងបុគ្គលិករបស់មន្ទីរសន្តិសុខ និងការចូលរួមពាក់ព័ន្ធរបស់ យឹម ទិត្យ នៅទីនោះ។

455. លើសពីនេះនេះ អង្គជំនុំជម្រះមិនជឿទៅលើការចោទប្រកាន់របស់សហមេធាវី ពាក់ព័ន្ធនឹងភ័ស្តុតាងផ្ទុយគ្នារបស់ ហោ យ៉ន អំពីចំនួនដងដែលគាត់បានឃើញ យឹម ទិត្យ នៅវត្តព្រះធាតុ[1253]។ ហោ យ៉ន បានយោងទៅ "ទំនាក់ទំនង" ជាច្រើនរបស់គាត់ជាមួយ យឹម ទិត្យ រួមទាំង ពេលវេលា

[1250] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៣៨ (លុបចោលជើងទំព័រ)។

[1251] កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ ភ្នំ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/108 នៅត្រង់ ERN 01045249 (ឆ៣) ("ខ្ញុំមានបងប្រុសម្នាក់ឈ្មោះ ដុក ចាន់ [...] ដែលជាអ្នកគ្រប់គ្រងអ្នកទោស នៅមន្ទីរសន្តិសុខវត្តព្រះធាតុ។ ខ្ញុំធ្លាប់ទៅលេងគាត់") 01045250 (ស៨ -ឆ៨) ("ស៖ តើលោកធ្លាប់ឃើញ តាទិត្យ និងតាតុម មកមើលមន្ទីរសន្តិសុខវត្តព្រះធាតុញឹកញាប់ដែរទេ? ឆ៨៖ បាទ ខ្ញុំបានឃើញតាទិត្យ និងតាតុម មកមើលមន្ទីរសន្តិសុខវត្តព្រះធាតុ ញឹកញាប់ដែរ ប៉ុន្តែខ្ញុំមិនដឹងថា គាត់មកធ្វើអីទេ។ [...] ខ្ញុំមិនធ្លាប់ឃើញតាទិត្យ និងតាតុម និយាយជាមួយនឹងអ្នកទោសទេ។ ខ្ញុំធ្លាប់ឃើញពួកគាត់ជួបនិយាយ ជាមួយតែនឹងបុគ្គលិកមន្ទីរសន្តិសុខតែប៉ុណ្ណោះ"។ កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ ភ្នំ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/109 នៅត្រង់ ERN 01045256 (ស១២-ឆ១២) ("ស៖ហេតុអ្វីបានជាលោក មានសិទ្ធិចេញចូល និងធ្វើដំណើរនៅក្នុងបរិវេណមន្ទីរសន្តិសុខ វត្តព្រះធាតុ? ឆ១២៖ ដោយសារតែបងប្រុសខ្ញុំ ជាបុគ្គលិកនៅក្នុងមន្ទីរសន្តិសុខនោះ រួចហើយការិយាល័យសិក្សារបស់ខ្ញុំ ក៏ស្ថិតនៅជិតមន្ទីរនោះដែរ")។

[1252] សូមមើល សេចក្តីពិចារណាលើភស្តុតាង មូលដ្ឋាន ៥ ខាងលើ។

[1253] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

ដែលគាត់ឃើញ យឹម ទិត្យ[1254] បានជួប យឹម ទិត្យ[1255] និងចំនួនដងដែល យឹម ទិត្យ មកវត្តព្រះធាតុ ដើម្បីប្រមូលយកប្រម៉ាត់[1256]។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែកទៅលើភ័ស្តុតាងរបស់ ហោ យ៉ន ដោយប្រុងប្រយ័ត្ន ដោយបញ្ជាក់ថា ហោ យ៉ន ចាំថាបានឃើញ យឹម ទិត្យ នៅមន្ទីរសន្តិសុខ វត្តព្រះធាតុ យ៉ាងហោចណាស់ម្តងដែរ[1257]។ អង្គជំនុំជម្រះពិចារណាថា ចំណុចនេះ សមហេតុផល និងមិនមានកំហុសឡើយ។

456. ចំពោះការចោទប្រកាន់ថា មានភាពមិនច្បាស់លាស់ ថាតើ ហោ យ៉ន ដែលជាអ្នកទោស អាចដឹងថា យឹម ទិត្យ គឺជានរណា ឬគាត់មានតួនាទីអ្វីខ្លះ ដោយរបៀបណានោះ[1258] ហោ យ៉ន បានពន្យល់ថា គាត់ស្គាល់ យឹម ទិត្យ ហើយទទួលបានដំណឹងអំពី ការចុះត្រួតពិនិត្យរបស់ យឹម ទិត្យ ជាមុន[1259]។ លើសពីនេះទៀត ចំពោះការចោទប្រកាន់ថា ហោ យ៉ន ស្ថិតនៅវត្តព្រះធាតុនៅក្នុងឆ្នាំ ១៩៧៣ មិនមែននៅក្នុងឆ្នាំ ១៩៧៨ នោះ[1260] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់ និងពិចារណាដោយប្រុង ប្រយ័ត្នទៅលើ ភាពមិនស្របគ្នានៅក្នុងចម្លើយរបស់ ហោ យ៉ន ពាក់

[1254] កិច្ចសម្ភាសរវាង SOAS/HRW និង ហោ យ៉ន [ហោ យ៉ន] ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៥ ឯកសារ D1.3.11.18 នៅត្រង់ ERN (ភាសាអង់គ្លេស) 00217607 (បញ្ជាក់ថា "ទិត្យមកម្តងម្កាល" ប៉ុន្តែមិនច្បាស់ថាតើ ហោ យ៉ន បានឃើញគាត់ដោយផ្ទាល់ ដែរឬយ៉ាងណា)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោ យ៉ន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ឯកសារ D105/6 នៅត្រង់ ERN 00788831 (ឆ២២) ("ខ្ញុំបានឃើញគាត់មកទីនេះ ប្រហែលជាជាង១០ដង")។

[1255] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោ យ៉ន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/155 នៅត្រង់ ERN 00968073 (ឆ៤៨) ("ខ្ញុំជួបគាត់មិនជាញឹកញាប់ទេ។ ខ្ញុំជួបគាត់២ដង")។

[1256] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោ យ៉ន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/55 នៅត្រង់ ERN 01034062 (ស១០-ឆ១០) (តើលោកឃើញ តាទិត្យ ទៅទីនោះប៉ុន្មានដង ពេលដែលគេយកអ្នកទោស ទៅសម្លាប់យកប្រម៉ាត់? ឆ១០៖ តាទិត្យ មកតែម្តងទេ គឺនៅពេលដែលអ្នកទោស៣០នាក់ ត្រូវបានគេវះពោះយកប្រម៉ាត់") 01034064 (ឆ២០) ("ខ្ញុំចង់បញ្ជាក់ថា តាទិត្យ មកយកប្រម៉ាត់ពីគុកតែម្តងទេ")។

[1257] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៦៩។

[1258] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

[1259] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោ យ៉ន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/155 នៅត្រង់ ERN 00968073 (ស៤៦ -ឆ៤៧) 00968082 (ឆ១១៩)។

[1260] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

ព័ន្ធនឹងពេលវេលានៃការជាប់ពន្ធនាគាររបស់គាត់ ហើយជាចុងក្រោយ បានសម្រេចថា គាត់ប្រហែលជាស្ថិតនៅវត្តព្រះធាតុ ចាប់ពីឆ្នាំ ១៩៧៧ រហូតដល់ឆ្នាំ១៩៧៨[1261]។

457. ចំពោះចម្លើយរបស់ យូ ភ្នំ ដែលថា គាត់មិនហ៊ានទៅជិតមន្ទីរសន្តិសុខនោះ[1262] អង្គជំនុំជម្រះកត់សម្គាល់ថា ចម្លើយជាក់លាក់មួយនេះ គឺជាការយោងយ៉ាងច្បាស់លាស់ទៅអគារឃុំឃាំង (អតីតសាលាឆាន់របស់លោកសង្ឃ) នៅក្នុងបរិវេណមន្ទីរសន្តិសុខវត្តព្រះធាតុ[1263]។ ភស្តុតាងរបស់ យូ ភ្នំ ដែលថា គាត់បានឃើញ យឹម ទិត្យ នៅវត្តព្រះធាតុ នៅពេលដែលគាត់ទៅលេងបងប្រុសឈ្មោះ ដុក ចាន់ គឺជាការគាំទ្រយ៉ាងច្បាស់ចំពោះការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា យឹម ទិត្យទៅ ពិនិត្យវត្តព្រះធាតុ[1264]។ ចំពោះ ទន់ ស៊ួន អង្គជំនុំជម្រះមិនជឿទៅលើការចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "បំប៉ោង" នៅក្នុងការសម្រេចរបស់គាត់ ដោយផ្អែកលើមូលដ្ឋាននៃការជាប់ឃុំ ឃាំង រយៈពេលបួនថ្ងៃរបស់ ទន់ ស៊ួន [1265]។

---

[1261] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៥៥ ("ដោយហេតុថា គាត់បានជាប់ឃុំរយៈពេល ៨ ខែ នៅពេលកងទ័ពវៀតណាមបានវាយប្រហារ លើកដំបូងទៅលើស្រុកគិរីវង់ ហើយនៅពេលដែល យឹម ទិត្យ បានទៅពិនិត្យមើលមន្ទីរសន្តិសុខនោះ សាក្សី ហោ យ៉ន ទំនងជាជាប់ឃុំនៅវត្តព្រះធាតុ ក្នុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨")។ ការនេះត្រូវបានគាំទ្របន្ថែមដោយភស្តុតាងដែលថា មន្ទីរសន្តិសុខចាប់ផ្តើមប្រតិបត្តិការ នៅវត្តព្រះធាតុ នៅដើមឆ្នាំ១៩៧៥។ សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៣៤ និង ជើងទំព័រ ១១៥៤។

[1262] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

[1263] កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ ភ្នំ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/108 នៅត្រង់ ERN 01045251 (ឆ៩) ("ពេលដែលខ្ញុំទៅលេងនឹងបងប្រុសរបស់ខ្ញុំ គឺខ្ញុំនៅជាមួយគាត់ នៅកន្លែងគាត់ប៉ុណ្ណោះ។ ខ្ញុំឃើញមានសាលាមួយនៅក្បែរហ្នឹង ហើយខ្ញុំដឹងថា មានអ្នកទោសដែលគេឃុំឃាំង នៅក្នុងសាលានោះ។ សាលានោះ ពីដើមមកគឺជាសាលាឆាន់ របស់លោកសង្ឃ")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ ភ្នំ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/109 នៅត្រង់ ERN 01045255 (ស៩ - ឆ៩) ("ស៖ នៅពេលដែលលោកទៅលេង បងរបស់លោកនៅវត្តព្រះធាតុ តើលោកឃើញមានអ្នកទោស ជាប់ក្នុងមន្ទីរសន្តិសុខវត្តព្រះធាតុ ចំនួនប៉ុន្មាននាក់ដែរ? ឆ៩៖ ខ្ញុំមិនអាចស្មានពីចំនួនប៉ុន្មាននាក់បានទេ ពីព្រោះខ្ញុំមិនហ៊ានចូលជិត មើលនៅក្នុងមន្ទីរឃុំឃាំងនោះទេ")។

[1264] កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ ភ្នំ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/108 នៅត្រង់ ERN 01045250 (ស៨ - ឆ៨) ("ស៖តើលោកធ្លាប់ឃើញតាទិត្យ មកពិនិត្យមន្ទីរសន្តិសុខ នៅវត្តព្រះធាតុដែរទេ? ឆ៨៖ បានខ្ញុំបានឃើញ តាទិត្យ និងតាគុម មកមើលមន្ទីរសន្តិសុខវត្តព្រះធាតុញឹកញាប់ដែរ ប៉ុន្តែខ្ញុំមិនដឹងថាគាត់មកធ្វើអីទេ។ [...] ខ្ញុំមិនធ្លាប់ឃើញតាទិត្យ និងតាគុមនិយាយជាមួយនឹងអ្នកទោសទេ។ ខ្ញុំធ្លាប់ឃើញពួកគាត់ជួបនិយាយ ជាមួយតែនឹងបុគ្គលិកមន្ទីរសន្តិសុខតែប៉ុណ្ណោះ"។

[1265] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

ទោះបីជា ទន់ ស៊ូន ត្រូវបានឃុំឃាំងនៅវត្តព្រះធាតុ រយៈពេលខ្លីក្តី តែចំណុចនេះមិនបានប៉ះពាល់ទៅលើតម្លៃជាភស្តុតាងនៃចម្លើយដ៏ច្បាស់លាស់របស់គាត់ដែលថា គាត់បានឃើញ យឹម ទិត្យ ពីរដង នៅក្នុងពេលដែលគាត់ជាប់ឃុំឃាំង នៅមន្ទីរសន្តិសុខនោះ[1266] ឬរារាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនឱ្យពឹងផ្អែកទៅលើ ទន់ ស៊ូន ឡើយ[1267]។ ការជំទាស់ផ្សេងទៀតចំពោះភស្តុតាងរបស់ ទន់ ស៊ូន នឹងត្រូវពិភាក្សាលម្អិតនៅផ្នែកខាងក្រោម[1268]។

458. លើសពីនេះទៀត ការអះអាងដែលថា ព័ត៌មានរបស់ អោក ចន មិនមានកាលបរិច្ឆេទច្បាស់លាស់ និងយោងទៅពាក្យទូទៅ គឺ រយៈពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មិនមានមូលដ្ឋានឡើយ[1269]។ អោក ចន បានបញ្ជាក់ថា គាត់ជាប់ឃុំនៅវត្តព្រះធាតុ ប្រហែលជាបីខែ នៅក្នុងឆ្នាំ១៩៧៧[1270]។ ប៉ុន្តែ អោក ចន មិនមានភាពស្របគ្នាចំពោះចំនួនដង ដែល យឹម ទិត្យទៅវត្តព្រះធាតុ[1271]។ នៅពេលសួរដេញដោល គាត់បានបញ្ជាក់ថា គាត់ជួប យឹម ទិត្យ ញឹកញាប់នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែ គាត់ឃើញ យឹម ទិត្យ ដោយផ្ទាល់តែពីរដងប៉ុណ្ណោះ នៅក្នុងពេលដែលគាត់ជាប់ឃុំ

---

[1266] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/346 នៅត្រង់ ERN 01102937 (ឆ៤៨)។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/110 នៅត្រង់ ERN 01045262 (ឆ១-ឆ៣)។

[1267] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៥៦៤។

[1268] ការជំទាស់បន្ថែមទៅលើ ភស្តុតាងរបស់ ទន់ ស៊ូន នឹងត្រូវធ្វើការពិចារណា នៅក្នុងផ្នែកស្តីពីការចូលរួមរបស់ យឹម ទិត្យ នៅក្នុងការសួរចម្លើយអ្នកទោស នៅវត្តព្រះធាតុ *ខាងក្រោម កថាខណ្ឌ ៤៦១-៤៦៥*

[1269] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

[1270] កំណត់ហេតុស្តាប់ចម្លើយសាក្សី អោក ចន ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១២ ឯកសារ D105/5 នៅត្រង់ ERN 00788849 (ឆ៧១-ឆ៧៣)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី អោក ចន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/369 នៅត្រង់ ERN 01110212 (ឆ៨០)។ កំណត់ហេតុនៃកិច្ចសម្ភាសន៍ អោក ចន ដោយការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ឯកសារ D1.3.11.2 នៅត្រង់ ERN 00827883។

[1271] កំណត់ហេតុនៃកិច្ចសម្ភាសន៍ អោក ចន ដោយការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ឯកសារ D1.3.11.2 នៅត្រង់ ERN 00827884 ("គាត់បញ្ជាក់ថា តាទិត្យមកគុកម្តងក្នុងមួយសប្តាហ៍") ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី អោក ចន ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១២ ឯកសារ D105/5 នៅត្រង់ ERN 00788851 (ឆ៩៨) ("ខ្ញុំឃើញគាត់មកគុកនេះប្រហែលជាពីរដង។ ខ្ញុំមិនដឹងថា គាត់មកញឹកញាប់ឬអត់ទេ ព្រោះខ្ញុំនៅជាប់ក្នុងគុក")។

ឃាំង[1272]។ អង្គជំនុំជម្រះពិចារណាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានកំហុសឡើយ ក្នុងការពឹងផ្អែកទៅលើ ការបញ្ជាក់របស់ អោក ចន ពាក់ព័ន្ធនឹងការទៅពិនិត្យវត្តព្រះធាតុ របស់ យឹម ទិត្យ[1273]។

459. លើសពីនេះទៀត អោក ចន បានបញ្ជាក់ថា អគារដែលគាត់ជាប់ឃុំឃាំង មិនមានបង្អួចឡើយ (ជាអតីតសាលាឆាន់របស់ព្រះសង្ឃ) ហើយគាត់មិនអាចមើលឃើញអ្វីៗនៅខាងក្រៅឡើយ[1274]។ ប៉ុន្តែ ផ្ទុយពីការអះអាងរបស់សហមេធាវីដែលថា មានភាពមិនច្បាស់លាស់ថាតើ គាត់ដឹងថា យឹម ទិត្យ មកពិនិត្យគុកដោយរបៀបណា បើស្ថិតក្នុងស្ថានភាពបែបនេះ[1275] អោក ចន បានពន្យល់គួរឱ្យជឿជាក់ថា គាត់ស្គាល់ យឹម ទិត្យ តាំងពីមុនពេលគាត់មកពិនិត្យទីនេះម្ល៉េះ ដោយគាត់ធ្លាប់ធ្វើការនៅកងផលិតស្រុក ហើយថា យឹម ទិត្យ ចូលអគារឃុំឃាំង និងដើរតាមបន្ទប់ឃុំឃាំង ដើម្បីពិនិត្យមើលអ្នកទោស ហើយថាបន្ទប់ឃុំឃាំងងងឹតតែនៅពេលយប់ប៉ុណ្ណោះ[1276]។ អង្គជំនុំ

[1272] កំណត់ហេតុស្តាប់ចម្លើយសាក្សី អោក ចន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/156 នៅត្រង់ ERN 00968096 (ស៧៥ -ឆ៧៨). ("ស៖ ក្នុងឯកសារសម្ភាសរបស់លោក ជាមួយនិងការិយាល័យ សហព្រះរាជអាជ្ញា នៅឆ្នាំ២០០៨ [...] លោកបាននិយាយថា "តាទិតមកគុកវត្តព្រះធាតុ ក្នុងមួយអាទិត្យម្តង។ ចំណែកក្នុងឯកសារសម្ភាសរបស់លោក ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត [...] លោកនិយាយថា "លោកធ្លាប់ឃើញ តាទិត ពីរដងប៉ុណ្ណោះ"។ តើលោកអាចបញ្ជាក់ អំពីរឿងនេះបានដែរឬទេ? ឆ៧៥៖ ខ្ញុំធ្លាប់ឃើញ តាទិត ពីរដងប៉ុណ្ណោះ ក្នុងរយៈពេល៣ខែ ដែលខ្ញុំជាប់ឃុំ")។

[1273] ចៅក្រមអន្តរជាតិកត់សម្គាល់ថា នៅក្នុងចម្លើយនាពេលក្រោយរបស់គាត់ អោក ចន បានបញ្ជាក់ថា គាត់បានឃើញ យឹម ទិត្យ តែម្តងប៉ុន្តែគាត់ក៏បាននិយាយថា គាត់មិនចាំថាប៉ុន្មានដងដែល យឹម ទិត្យ មកគុក។ សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី អោក ចន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/369 នៅត្រង់ ERN 01110213 (ស៨៣-ឆ៨៨) ជាពិសេស (ស៨៦) ("តើលោកឃើញគាត់តែម្តង ឬច្រើនដង? ឆ៨៦៖ ខ្ញុំឃើញគាត់តែម្តងទេ")។ ចៅក្រមអន្តរជាតិពិចារណាថា ដោយផ្អែកលើភស្តុតាងសាក្សីទាំងស្រុង ការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើភស្តុតាងកន្លងមករបស់គាត់ នៅពេលមានការសួរដេញដោល ដែល អោក ចន បានបញ្ជាក់បំភ្លឺថា គាត់បានឃើញ យឹម ទិត្យ ពីរដង នៅក្នុងពេលគាត់ជាប់ឃុំឃាំងនោះ មិនមែនមិនសមហេតុផលនោះឡើយ។

[1274] កំណត់ហេតុស្តាប់ចម្លើយសាក្សី អោក ចន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/156 នៅត្រង់ ERN 00968088 (ស៩ -ឆ១២)។

[1275] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

[1276] កំណត់ហេតុស្តាប់ចម្លើយសាក្សី អោក ចន ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១២ ឯកសារ D105/5 នៅត្រង់ ERN 00788851-00788852 (ឆ៩៨-ឆ១០០) ("[...] ខ្ញុំនៅជាប់ក្នុងគុក [...] គាត់គ្រាន់តែដើរមើលអ្នកទោស ហើយគាត់ចេញទៅវិញហើយ។ ស៖ គាត់ចូលទៅក្នុងមន្ទីរឃុំឃាំងមែនឬទេ? ឆ១០០៖ បាទ កន្លែងមន្ទីរឃុំឃាំង មន្ទីរឃុំឃាំងគឺមានបីបន្ទប់")។ កំណត់ហេតុ

ជម្រះពិចារណាបន្ថែមថា ចម្លើយមិន ស្របគ្នារបស់ អោក ចន ពាក់ព័ន្ធនឹងវត្តស្លែង ដែលជាគុក មួយផ្សេងទៀតនោះ[1277] មិនពាក់ព័ន្ធជាមួយ នឹងភាពអាចជឿជាក់បាននៃភស្តុតាងអំពីការត្រួតពិនិត្យរបស់ យឹម ទិត្យ នៅវត្តព្រះធាតុឡើយ។

460. ជាចុងក្រោយ អង្គជំនុំជម្រះសម្រេចថា ការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើការដែល ហោ យ៉ន និង អោក ចន មិនអាចកំណត់ថាជា យឹម ទិត្យ ដោយមើលរូបថតកាលពីខែមករា ឆ្នាំ២០១១ នោះ[1278] ដោយកត់សម្គាល់ពី "ពេលវេលាកន្លងផុតរវាងហេតុការណ៍ និងកាល បរិច្ឆេទរូបថត ពុំអាចឱ្យសាក្សីសម្គាល់ យឹម ទិត្យ" និងថា ចំណុចនេះមិនប៉ះពាល់ពិតប្រាកដទៅលើភាពអាចទុកចិត្តបាននៃភស្តុតាងរបស់សាក្សីនោះ គឺជាការសមហេតុផល[1279]។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា សាក្សីទាំងពីរបានពន្យល់យ៉ាងច្បាស់ ថាតើពួកគាត់អាចកំណត់អត្តសញ្ញាណ យឹម ទិត្យ បានដោយរបៀបណា នៅពេលដែលគាត់ទៅត្រួតពិនិត្យនៅវត្តព្រះធាតុ គឺដោយពួកគាត់បានស្គាល់ យឹម ទិត្យ តាំងពីមុន[1280] ឬដោយសារតែការប្រកាសជាមុនអំពីការចុះពិនិត្យរបស់ យឹម ទិត្យ[1281]។

### *b. ការចូលរួមរបស់ យឹម ទិត្យ នៅក្នុងការសួរចម្លើយនៅវត្តព្រះធាតុ*

---

ស្តាប់ចម្លើយសាក្សី អោក ចន ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/156 នៅត្រង់ ERN 00968094 (ឆ៦១-ឆ៦៤) (" យឹម ទិត្យ ដើរមើលអ្នកទោស តាមបន្ទប់ឃុំឃាំងអ្នកទោសតែម្តង") 00968096 (ស៧៦ -ឆ៧៦) ("លោកនិយាយថា បន្ទប់ឃុំឃាំងអ្នកទោស គ្មានបង្អួចទេ ហេតុអ្វីបានជាលោកដឹងថា អ្នកដែលចូលទៅមើលអ្នកទោសនោះជា តាទិត? ឆ៧៦៖ ពេលដែលខ្ញុំនៅកន្លែងផលិតស្រុក គឺខ្ញុំស្គាល់គាត់ហើយ។ នៅក្នុងបន្ទប់ឃុំឃាំងពេលថ្ងៃ មិនងងឹតនោះទេ គឺងងឹតតែយប់ប៉ុណ្ណោះ")។

[1277] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។

[1278] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៦៨-៤៦៩ និង ជើងទំព័រ ១២៧២,១២៧៧។

[1279] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៦៨-៤៦៩។ រូបថតមិនត្រូវបានផ្ទៀងផ្ទាត់ជាផ្លូវការ ថាជា យឹម ទិត្យឡើយ។ សូមមើល បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៣។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) ជើងទំព័រ ១២៧៧។

[1280] កំណត់ហេតុស្តាប់ចម្លើយសាក្សី អោក ចន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/156 នៅត្រង់ ERN 00968096 (ឆ៧៦) ("ពេលដែលខ្ញុំនៅកន្លែងផលិតស្រុក គឺខ្ញុំស្គាល់គាត់ហើយ។ នៅក្នុងបន្ទប់ឃុំឃាំងពេលថ្ងៃ មិនងងឹតនោះទេ គឺងងឹតតែយប់ប៉ុណ្ណោះ")។

[1281] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោ យ៉ន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/155 នៅត្រង់ ERN 00968073 (ស៤៦ -ឆ៤៧) 00968082 (ឆ១១៩)។

461. សហមេធាវីជំទាស់ចំពោះការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលផ្អែកទៅលើចម្លើយរបស់ ទន់ ស៊ួន កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤[1282] ថា យឹម ទិត្យ សួរចម្លើយអ្នកជាប់ឃុំឃាំង នៅវត្តព្រះធាតុចំនួនពីរដង[1283]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ទោះបីជា ទន់ ស៊ួន បានបញ្ជាក់នៅក្នុង ការស្តាប់ចម្លើយកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ របស់គាត់ថា គាត់ជាប់ឃុំរយៈពេលបួនថ្ងៃ នៅវត្តព្រះធាតុ និងបានឃើញ យឹម ទិត្យ សួរចម្លើយអ្នកជាប់ឃុំនៅទីនោះក្តី[1284] តែគាត់មិនបានផ្តល់ព័ត៌មានលម្អិតអំពីបទពិសោធន៍ផ្ទាល់របស់គាត់ នៅវត្តព្រះធាតុឡើយ នៅក្នុងការស្តាប់ចម្លើយកន្លងមករបស់គាត[1285]។ ទោះជាបែបនេះក្តី ចៅក្រមអន្តរជាតិមិនជឿទៅលើការចោទប្រកាន់ថា ភស្តុតាងរបស់ ទន់ ស៊ួន ផ្ទុយគ្នា និងមិនអាចជឿបាន ព្រោះគាត់មិនបានលើកឡើងពី យឹម ទិត្យ ពាក់ព័ន្ធនឹងការសួរចម្លើយអ្នកទោស នៅក្នុងចម្លើយមុនៗរបស់គាត់នោះ[1286]។

462. ចំពោះការស្តាប់ចម្លើយថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ របស់គាត់ ជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា នៅក្នុងពេលស៊ើបអង្កេតបឋម[1287] អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា ទន់ ស៊ួន "មិនបានដឹងឮផ្ទាល់អំពីវត្តព្រះធាតុ" ដូចការចោទប្រកាន់នោះឡើយ[1288] ដោយសារតែមានព័ត៌មានតិច

[1282] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/110។

[1283] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៥ *យោងទៅរក* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៦៣, ៤៦៧ ជើងទំព័រ ១២៦៤-១២៦៦។

[1284] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/110 នៅត្រង់ ERN 01045262 (ឆ១-ឆ៣). *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/346 នៅត្រង់ ERN 01102937-01102938 (ឆ៥៣-ឆ៦២)។

[1285] កំណត់ហេតុស្តាប់ចម្លើយសាក្សី (ទន់ ស៊ួន) ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ឯកសារ D1.3.11.56។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D5/122។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D3/8។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១១ ឯកសារ D13។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/22។

[1286] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៥។

[1287] កំណត់ហេតុស្តាប់ចម្លើយសាក្សី (ទន់ ស៊ួន) ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ឯកសារ D1.3.11.56។

[1288] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៥ *យោងទៅរក* កំណត់ហេតុស្តាប់ចម្លើយសាក្សី (ទន់ ស៊ួន) ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ឯកសារ D1.3.11.56 នៅត្រង់ ERN (ភាសាអង់គ្លេស) 00219281។

តូច នៅក្នុងកំណត់ត្រាស្តាប់ចម្លើយ[1289]។ លើសពីនេះទៀត ការស្តាប់ចម្លើយថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០១០ ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវបានធ្វើឡើងក្នុងគោលបំណងបញ្ជាក់ ឬកែតម្រូវការស្តាប់ចម្លើយរបស់គាត់ កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ហើយគាត់មិនត្រូវបានសាកសួរបន្ថែម អំពីវត្តព្រះធាតុឡើយ[1290]។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន មិនបានលើកឡើងអំពី ការជាប់ឃុំឃាំងរយៈពេលខ្លីរបស់គាត់ ឬការរៀនសូត្រនៅវត្តព្រះធាតុឡើយ ដោយគាត់គ្រាន់តែបញ្ជាក់ថា គាត់ទទួលព័ត៌មានមួយចំនួន ពីអ្នកទោស ដូចជាថា ពួកគេត្រូវដាក់ឃ្នាងជើង ជាដើម[1291]។ ចំណុចនេះមិនមែនមិនស្របគ្នាជាមួយនឹងការស្តាប់ចម្លើយក្រោយមករបស់គាត់ ដែលគាត់បន្តអះអាងថា គាត់ត្រូវបានគេបញ្ជូនទៅវត្តព្រះធាតុ ដើម្បីអប់រំ ឬរៀនសូត្រ[1292] ហើយគាត់ត្រូវបានឃុំឃាំងនៅកុដ្ឋព្រះសង្ឃ[1293] និងមិនដែលបានចូលអគារឃុំឃាំងឡើយ (ទីដែលដាក់អ្នកទោសជាប់ឃ្នាង)[1294]។

---

[1289] អង្គជំនុំជម្រះកត់សម្គាល់ថា កំណត់ហេតុស្តាប់ចម្លើយសាក្សី របស់ការិយាល័យសហព្រះរាជអាជ្ញា គឺមិនមែនជាប្រតិចារឹកពេញលេញ នៃការស្តាប់ចម្លើយឡើយ ប៉ុន្តែជាសេចក្តីសង្ខេប នៃព័ត៌មានដែលសាក្សីបានផ្តល់។ កំណត់ត្រាទាំងអស់នេះ មិនបានបញ្ចូលនូវសំណួរ ដែលអ្នកស៊ើបសួរបានសួរឡើយ។ ទោះបីជាកំណត់ហេតុស្តាប់ចម្លើយសាក្សីលើកឡើងថា "សាក្សីបញ្ជាក់ថា គុកគឺជាកន្លែងហាមឃាត់ ហើយពួកគាត់មិនត្រូវបានអនុញ្ញាតឱ្យទៅកន្លែងនោះឡើយ" និង "គាត់បានបញ្ជាក់ថា មានការហាមឃាត់មិនឱ្យចូលរួមទៅក្នុង បើហ៊ានចូលគឺត្រូវចាប់ខ្លួន" តែវាមិនច្បាស់លាស់ថាតើ ទន់ ស៊ួន បញ្ជាក់ថា គាត់មិនដែលចូលក្នុងបរិវេណដោយផ្ទាល់ ឬថាទីនោះ ជា ទូទៅ គឺជាកន្លែងហាមឃាត់ សម្រាប់អ្នកដែលមិនជាប់ឃុំឃាំង។ នៅក្នុងចម្លើយក្រោយរបស់គាត់ ទន់ ស៊ួន ក៏បានបញ្ជាក់ថា គាត់មិនបានដឹង ឬបានឃើញរឿងរ៉ាវមួយចំនួន ព្រោះគាត់ "ត្រូវបានហាមមិនឱ្យចូលទៅរង្វង់១០០ម៉ែត្រ ពីរបបវត្តព្រះធាតុ" ប៉ុន្តែគាត់បានបញ្ជាក់ថា គាត់ត្រូវ "រៀនសូត្រនៅគុកវត្តព្រះធាតុ" និងថាគាត់ "ចូលក្នុងបរិវេណវត្ត"។ សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/22 នៅត្រង់ ERN 0089154, 00891155, 00891157 (ឆ១២, ឆ១៥, ឆ៣៣)។

[1290] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D3/8។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា ទន់ ស៊ួន គ្រាន់តែបានអាន ការស្តាប់ចម្លើយថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ របស់ការិយាល័យសហព្រះរាជអាជ្ញា ហើយត្រូវបានសួរថា គាត់ចង់ធ្វើការផ្លាស់ប្តូរ ឬកែប្រែអ្វីទេ ចំពោះព័ត៌មានដែលបានផ្តល់ នៅក្នុងការស្តាប់ចម្លើយនោះ។ អ្នកស៊ើបអង្កេតបានបញ្ជាក់ច្បាស់ថា គាត់អាចត្រឡប់មកវិញម្តងទៀត ដើម្បីឆ្លើយសំណួរដែលលម្អិតជាងនេះ។

[1291] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D5/122 នៅត្រង់ ERN 00491809។ ចៅក្រមអន្តរជាតិកត់សម្គាល់បន្ថែមថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានទាញចេញពីទម្រង់រៀបរាប់ ហើយមានគោលបំណងផ្សេងពីការស្តាប់ចម្លើយសាក្សីទូទៅ។

[1292] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១១ ឯកសារ D13 នៅត្រង់ ERN 00687004។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/22 នៅត្រង់ ERN 0089154 (ឆ១២)។

463. លើសពីនេះទៀត ទន់ ស៊ូន បានបញ្ជាក់ថា គាត់ត្រូវបានបញ្ជូនទៅ "រៀនសូត្រ" នៅវត្តព្រះធាតុ នៅក្នុងការស្តាប់ចម្លើយថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១១ របស់គាត់[1295] មុនពេលមានការបង្ហាញដីកាបញ្ជូនរឿងទៅជំនុំជម្រះលើកទីបី[1296]។ លើសពីនេះទៀត ផ្ទុយពីការចោទប្រកាន់របស់សហមេធាវី[1297] ជាដំបូង ទន់ ស៊ូន បានលើកឡើងអំពី យឹម ទិត្យ សួរចម្លើយអ្នកទោសនៅវត្តព្រះធាតុ នៅក្នុងចម្លើយថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ (បើទោះជាមិនលើកឡើងថាពីរដងក្តី)[1298]។ អង្គជំនុំជម្រះសម្រេចថា ការមិនបានយោងជាដំបូងទៅការពាក់ព័ន្ធរបស់ យឹម ទិត្យ នៅក្នុងការសួរចម្លើយអ្នកទោស នៅវត្តព្រះធាតុ នៅក្នុងភ័ស្តុតាងរបស់ ទន់ ស៊ូន មិនបានចោទជាបញ្ហាគ្រប់គ្រាន់ទៅលើភាពអាចជឿជាក់បាននៃចម្លើយនាពេលក្រោយរបស់គាត់ឡើយ[1299]។

---

[1293] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/346 នៅត្រង់ ERN 01102933 (ឆ១០)។

[1294] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/22 នៅត្រង់ ERN 0089155, 00891157 (ឆ១៥, ឆ៣៤)។

[1295] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១១ ឯកសារ D13 នៅត្រង់ ERN 00687004 ("ខ្ញុំត្រូវបានគេបញ្ជូនទៅរៀនសូត្រ៣ឬ៤ថ្ងៃប៉ុណ្ណោះ")។

[1296] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៥។

[1297] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៦។

[1298] កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/22 នៅត្រង់ ERN 0089153-00891154 (ឆ៤-ឆ៦) 00891154 (ឆ១២) ("កម្មាភិបាលស្រុកគិរីវង់ យកខ្ញុំទៅអប់រំ២ទៅ៣ថ្ងៃ នៅគុកវត្តព្រះធាតុនោះ"( 00891155 (ឆ១៦) ("ខ្ញុំដឹងរឿងនេះដោយសារ ខ្ញុំបានឮពួកឈ្លប និងតាទិត សួរចម្លើយអ្នកទោស")។

[1299] អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា ទន់ ស៊ូន ត្រូវបានសួរថា "នៅក្នុងកិច្ចសម្ភាសន៍ ក្នុងឯកសារកត់ត្រាសួរចម្លើយដែលមានលេខ D13 (ERN00698808-00698810) លោកបាននិយាយប្រាប់ ចៅក្រមស៊ើបអន្តរជាតិ Blunk ថា លោកដឹងថា តាទិត្យ គឺជាគណៈស្រុកគិរីវង់ ប៉ុន្តែនៅពេលដែលចៅក្រមសួរលោក ថាតើលោកដឹងរឿងអ្វីខ្លះទៀត អំពីតាទិត្យ លោកថា លោកមិនដឹងទេ។ សូមលោកបញ្ជាក់អំពីចំណុចនេះ ដល់យើងក្នុងពេលនេះបានដែរឬទេ" និង "តើដែលមាននរណាម្នាក់ មកដាក់ឥទ្ធិពលលើលោក ដើម្បីឱ្យលោកឆ្លើយនឹងសំណួរផ្សេងៗ ដែលសួរដោយអ្នកមកពី អ.វ.ត.ក ដែរឬទេ?"។ ទន់ ស៊ូន បញ្ជាក់ថា គាត់មិនចាំថាគាត់និយាយអ្វី ជាមួយចៅក្រម Blunk ព្រោះ "រឿងនេះវាយូរណាស់ហើយ" និងថាមិនមាននរណាម្នាក់ ដាក់សម្ពាធលើចម្លើយរបស់គាត់ឡើយ។ សូមមើល កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/110 នៅត្រង់ ERN 01045264 (ស៩-ឆ១០)។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

464. សហមេធាវីមិនបានផ្តល់ការគាំទ្រខ្លាំងចំពោះការចោទប្រកាន់ថា ចម្លើយរបស់ ទន់ ស៊ូន អាចទទួលរងឥទ្ធិពល ដោយការបង្ហាញជាសាធារណៈនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីកាលពីឆ្នាំ២០១១ ឬតាមរយៈទំនាក់ទំនងរបស់គាត់ជាមួយអ្នកស៊ើបអង្កេត និង/ឬអង្គការមិនមែនរដ្ឋាភិបាលនោះ[1300]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់ថា ការស្តាប់ចម្លើយ ទន់ ស៊ូន នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ មិនបានកំណត់ថាតើ ព័ត៌មានពាក់ព័ន្ធនឹងការចូលរួមរបស់ យឹម ទិត្យ ក្នុងការសួរចម្លើយអ្នកទោស ចេញពីបទពិសោធន៍ផ្ទាល់របស់ ទន់ ស៊ូន ដែរឬយ៉ាងណាទេ[1301]។ ការស្តាប់ចម្លើយ និងកិច្ចស៊ើបសួរបន្តបន្ទាប់មកទៀត[1302] ត្រូវបានធ្វើឡើងក្នុងគោលបំណងបញ្ជាក់ទៅលើបញ្ហានេះ។ អង្គជំនុំជម្រះយល់ឃើញថា មិនមានកិច្ចមិនសមស្របណាមួយរបស់អ្នកស៊ើបអង្កេត ដូចការចោទប្រកាន់ឡើយ[1303]។

465. ចំពោះការជំទាស់ជាក់លាក់ ពាក់ព័ន្ធនឹងចម្លើយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ របស់ ទន់ ស៊ូន អង្គជំនុំជម្រះកត់សម្គាល់ថា សហមេធាវីមិនបានបង្ហាញដោយពេញលេញ និងដោយត្រឹមត្រូវ នូវភ័ស្តុតាងរបស់ ទន់ ស៊ូន ឡើយ។ ឧទាហរណ៍ សហមេធាវីចោទថា ទន់ ស៊ូន មិនអាចស្តាប់ឮសំណួរជាក់លាក់ ដែល យឹម ទិត្យ សួរឡើយ ព្រោះគាត់ "មិនត្រូវបានអនុញ្ញាតឱ្យចូលតំបន់ឃុំ

---

[1300] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៥។

[1301] កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ D219/122 នៅត្រង់ ERN 01363998 ("នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ ក្រុមការងារបានធ្វើដំណើរ [...] ស្វែងរកលោក ទន់ ស៊ូន។ មូលហេតុដែលយើងដាក់បញ្ចូលរូបគាត់ គឺដើម្បីបញ្ជាក់បំភ្លឺអំពីសក្ខីកម្មដែលគាត់បានផ្តល់ [...] ក្នុង [កំណត់ហេតុនៃការស្តាប់ចម្លើយមួយ] D118/22 ដែលក្នុងនោះសាក្សីបាននិយាយថា តាទិត្យ បានសួរចម្លើយអ្នកទោស ហើយពុំមានភាពជាក់លាក់ ថាតើនេះជាព័ត៌មានចចាមអារាម ដែរឬយ៉ាងណា [...] នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ ក្រុមការងារបានវិលត្រឡប់ [...] ដើម្បីស្តាប់ចម្លើយ ទន់ ស៊ូន។ គាត់បានផ្តល់ [របាយការណ៍ស្តាប់ចម្លើយ] របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយ ដែលក្នុងនោះគាត់បានផ្តល់សេចក្តីលម្អិត អំពីហេតុការណ៍ចំនួនពីរ ក្នុងចុងឆ្នាំ១៩៧៦ ដែលនៅពេលនោះ តាទិត្យ បានមានវត្តមាន នៅ [មន្ទីរសន្តិសុខ] វត្តព្រះធាតុ និងបានសួរចម្លើយអ្នកជាប់ឃុំឃាំង")។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D118/22 នៅត្រង់ ERN 0089155 (ឆ១៦)។

[1302] កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/122 (ពាក់ព័ន្ធការជួបជាមួយ ទន់ ស៊ូន នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤)។

[1303] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៥។

ឃុំឃាំងអ្នកទោស"[1304]។ ប៉ុន្តែ ទន់ ស៊ូន បានបញ្ជាក់ថា អ្នកទោសត្រូវបានគេយកចេញក្រៅតំបន់ឃុំឃាំង ហើយយកទៅសួរចម្លើយ នៅ ក្រោមកុដិព្រះសង្ឃ ដែលមានចម្ងាយមិនឆ្ងាយពីគាត់[1305]។ ប្រហែលគ្នានេះដែរ ការអះអាងដែលថា ទន់ ស៊ូន មិនប្រាកដថាតើ យឹម ទិត្យ បាននិយាយជាមួយអ្នកទោស ឬជាមួយបុគ្គលិករបស់គុក[1306] គឺជាការអះអាងមិនត្រឹមត្រូវទេ។ ភ័ស្តុតាងរបស់ ទន់ ស៊ូន គឺថា គាត់បានឮ យឹម ទិត្យ សួរអ្នកជាប់ឃុំនូវសំណួរមួយចំនួន ប៉ុន្តែ គាត់មិនឮ យឹម ទិត្យ និយាយជាមួយបុគ្គលិករបស់គុកទេ[1307]។ ជាចុងក្រោយ ភាពមិនស្របគ្នាពាក់ព័ន្ធនឹងរយៈពេលនៃការជាប់ឃុំរបស់ ទន់ ស៊ូន[1308] ត្រូវបានទទួលស្គាល់ និងពិភាក្សាដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលសម្រេចថា ភ័ស្តុតាងរបស់គាត់ ប្រហែលជាពាក់ព័ន្ធជាមួយនឹងឆ្នាំ ១៩៧៧ និងថា បើទោះបីជាមានភាពមិនស៊ីសង្វាក់គ្នាក្តី តែសាក្សីបានផ្តល់ព័ត៌មានច្បាស់លាស់អំពីហេតុការណ៍នេះ[1309]។

### *c. ការចូលរួមរបស់ យឹម ទិត្យ នៅក្នុងការសម្លាប់មនុស្ស នៅវត្តព្រះធាតុ*

466. សហមេធាវីបានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា "[យឹម ទិត្យ] បានបញ្ជា និងបានបញ្ជូនបញ្ជាបន្ត ឬយ៉ាងហោចណាស់យល់ព្រមឱ្យ [...] សម្លាប់

---

1304 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៦ និង ជើងទំព័រ ៨១៧។

1305 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D219/110 នៅត្រង់ ERN 01045262 (ឆ៤) ("ខ្ញុំបានឃើញតាទិត្យ ហើយនឹងយាយបូ ហៅអ្នកទោសម្នាក់ចេញពី កន្លែងឃុំឃាំង ទៅក្រោមកុដិលោកមួយដែលនៅក្បែរនោះ ហើយខ្ញុំឃើញពួកគាត់ឈរនិយាយ ជាមួយអ្នកទោសនោះ") ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/346 នៅត្រង់ ERN 01102937-01102938 (ឆ៥៧-ឆ៥៩)។

1306 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៦ និង ជើងទំព័រ ៨១៩។

1307 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ D219/346 នៅត្រង់ ERN 01102937 (ឆ៥២-ឆ៥៧) ("សៈ តើលោកមានធ្លាប់ឮតាទិត្យ និយាយទៅកាន់បុគ្គលិកគុកទេ? ឆ៥២ៈ មិនធ្លាប់ឮទេ" "ឆ៥៧ៈគាត់ [យឹម ទិត្យ] សួរសំណួរអ្នកទោសនោះថា [...]")។

1308 បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៧។

1309 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៦៧ និង ជើងទំព័រ ១២៦៩។

01677350



អ្នកទោស"[1310] និងថា យឹម ទិត្យ បានចូលរួមក្នុងការសម្លាប់មនុស្សនៅវត្តព្រះធាតុ ដោយចេញបញ្ជាឱ្យ "វះពោះ" អ្នកទោស[1311] ដោយផ្អែកលើភ័ស្តុតាងរបស់ ហោ យ៉ន តែមួយគត់[1312]។

467. ចំពោះ ហោ យ៉ន[1313] អង្គជំនុំជម្រះអះអាងថា អ្នកវិនិច្ឆ័យអង្គហេតុ "ទទួលយកដោយសមហេតុផល នូវផ្នែកខ្លះនៃសក្ខីកម្មរបស់សាក្សី ហើយបដិសេធចោលផ្នែកខ្លះទៀត" បន្ទាប់ពីបានពិចារណាទៅលើភ័ស្តុតាងទាំងស្រុង[1314]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាទៅលើភាពផ្ទុយគ្នាខ្លះៗ នៅក្នុងភ័ស្តុតាងរបស់ ហោ យ៉ន រួមទាំង ចម្លើយរបស់គាត់ដែលថា គាត់ជាប់ឃុំឃាំងនៅក្នុងឆ្នាំ ១៩៧៣[1315] និងមិនបានឃើញថាមានអ្វីកើតឡើងនោះទេ ក្រោយពេលដែលគេយកអ្នកទោសចេញទៅ[1316]។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា ប្រាកដណាស់ ដោយសារតែភាពមិនស្របគ្នាទាំងអស់នេះ ទើបសហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចមិនពឹងផ្អែកទៅលើចម្លើយមួយចំនួនរបស់ ហោ យ៉ន ដោយសម្រេចថា "ពុំអាចសន្និដ្ឋានឱ្យច្បាស់លាស់ចាំបាច់ថា

---

[1310] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦៤ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៦៣។

[1311] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៥៩ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៥៦-៤៥៧។

[1312] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦០។

[1313] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦០។

[1314] សូមមើល សេចក្តីពិចារណាលើភស្តុតាង មូលដ្ឋាន ៥ ខាងលើ។

[1315] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៥៥ ("អតីតអ្នកទោសម្នាក់ឈ្មោះ ហោ យ៉ន បានឆ្លើយនៅក្នុងការស្តាប់ចម្លើយមួយថា គាត់បានជាប់ឃុំនៅវត្តព្រះធាតុ ក្នុងឆ្នាំ១៩៧៣។ ទោះជាយ៉ាងណាក្តី គាត់បានផ្តល់ចម្លើយមិនស៊ីចង្វាក់គ្នាជាច្រើន ទាក់ទិននឹងពេលវេលាដែលគាត់ជាប់ឃុំ។ ដោយហេតុថា គាត់បានជាប់ឃុំរយៈពេល៨ខែ នៅពេលកងទ័ពវៀតណាមបានវាយប្រហារលើកដំបូងទៅលើស្រុកគិរីវង់ ហើយនៅពេលដែល យឹម ទិត្យ បានទៅពិនិត្យមើលមន្ទីរសន្តិសុខនោះ សាក្សី ហោ យ៉ន ទំនងជាជាប់ឃុំនៅវត្តព្រះធាតុ ក្នុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨") (លុបចោលជើងទំព័រ)។ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា ហោ យ៉ន ប្រហែលជានៅវត្តព្រះធាតុ ក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ មិនមែនក្នុងឆ្នាំ ១៩៧៣ នោះ ត្រូវបានគាំទ្របន្ថែមទៀតដោយភស្តុតាងដែលថា វត្តព្រះធាតុចាប់ផ្តើមដំណើរការនៅដើមឆ្នាំ១៩៧៥។ សូមមើល ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៣៤ និង ជើងទំព័រ ១១៥៤។

[1316] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៥៧ ("ទោះជាយ៉ាងណាក្តី សាក្សី ហោ យ៉ន បានផ្លាស់ប្តូរសាច់រឿងរបស់ខ្លួន នៅក្នុងការស្តាប់ចម្លើយពេលក្រោយ នៅឆ្នាំ២០១៤ ដោយលើកឡើងថា "*គាត់មិនបានឃើញមានរឿងអ្វីកើតឡើងនោះទេ*" នៅពេលគេយកអ្នកទោសចេញទៅវាលស្រែ")។

***សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ***

01677351



យឹម ទិត្យ ពិតជាមានវត្តមានដោយផ្ទាល់ នៅកន្លែងដែលគេវះពោះអ្នកទោសយកប្រម៉ាត់ រួចសម្លាប់ពួកគេនោះទេ”[1317]។

468. ចំពោះការចោទប្រកាន់ពីភាពផ្ទុយគ្នាផ្សេងទៀត[1318] អង្គជំនុំជម្រះកត់សម្គាល់ថា ចម្លើយរបស់ ហោ យ៉ន ដែលថា គាត់មិនដឹងអំពីតួនាទីរបស់ យឹម ទិត្យនៅក្នុងស្រុកគិរីវង់ មិនមែនផ្ទុយគ្នាទាំងស្រុងជាមួយនឹងភ័ស្តុតាងរបស់គាត់ដែលថា យឹម ទិត្យ នៅក្នុងគណៈកម្មាធិការស្រុកគិរីវង់ឡើយ[1319]។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមថា ហោ យ៉ន រក្សាភាពស្របគ្នានៅក្នុងការបញ្ជាក់ថា យឹម ទិត្យនៅស្រុកគិរីវង់[1320] គ្រប់គ្នានៅក្នុងស្រុកស្គាល់គាត់[1321] និងថា វត្តព្រះធាតុគឺជាមន្ទីរសន្តិសុខថ្នាក់ ស្រុក[1322]។ អង្គជំនុំជម្រះយល់ថា ចម្លើយទាំងអស់នេះបានពន្យល់គ្រប់គ្រាន់

---

[1317] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៥៧។

[1318] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦០ និង ជើងទំព័រ ៨៣២។ ការចោទពីភាពមិនស៊ីចង្វាក់គ្នា ពាក់ព័ន្ធចំនួនដងដែល ហោ យ៉ន បាន “ឃើញ” ឬជួបទាក់ទងជាមួយ យឹម ទិត្យ នៅវត្តព្រះធាតុ ត្រូវបានពិភាក្សានាពេលកន្លងមក នៅក្នុងផ្នែកពាក់ព័ន្ធ ការត្រួតពិនិត្យរបស់ យឹម ទិត្យ នៅវត្តព្រះធាតុ។

[1319] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោ យ៉ន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ឯកសារ D105/6 នៅត្រង់ ERN 00788829 (ឆ១១-ឆ១២) (“លោកចាំទេថា តើ តាទិត្យ មានតួនាទីអ្វីនៅក្នុងស្រុកគិរីវង់នេះដែរទេ? ឆ១២៖ ខ្ញុំមិនដឹងទេ ព្រោះខ្ញុំមិនបានចូលរួមជាមួយគេទេ”) អង្គជំនុំជម្រះកត់សម្គាល់ថា សំណួរនេះមានភាពច្បាស់លាស់ ហើយពិចារណាថា ចម្លើយរបស់ ហោ យ៉ន ដែលថា គាត់មិនដឹងពីតួនាទីរបស់ យឹម ទិត្យ នៅក្នុងស្រុកគិរីវង់ អាចសំដៅទៅរកមុខងារជាក់លាក់នៅក្នុងគណៈកម្មាធិការស្រុកគិរីវង់។

[1320] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោ យ៉ន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/55 នៅត្រង់ ERN 01034060 (ឆ១) (“គណៈស្រុកគិរីវង់កាលនោះ គឺតាទិត្យ តាណាំ និងយាយបូ”) 01034063 (ឆ១៥)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោ យ៉ន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/155 នៅត្រង់ ERN 00968069 (ឆ១៤) (“តាទិត្យ និងតាណាំ សុទ្ធតែជាគណៈស្រុក”)។ សូមមើលបន្ថែម កិច្ចសម្ភាសរវាង SOAS/HRW និង ហោ យ៉ន ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៥ ឯកសារ D1.3.11.18 នៅត្រង់ ERN (ភាសាអង់គ្លេស) 00217607 (“គណៈកម្មាធិការស្រុកគឺមាន៖ ទិត្យ”(។

[1321] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោ យ៉ន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/155 នៅត្រង់ ERN 00968082 (ឆ១១៩)។

[1322] កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោ យ៉ន ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ D219/55 នៅត្រង់ ERN 01034069 (ឆ៤៣) (“ត្រឹមត្រូវហើយ ជាមន្ទីរសន្តិសុខថ្នាក់ស្រុក”)។

ថាតើ ហោ យ៉ន បានដឹងថា យឹម ទិត្យ និងមេដឹកនាំស្រុកដទៃទៀត ស្ថិតនៅលើវត្តព្រះធាតុដោយរបៀបណា បើតាមឋានានុក្រមនោះ[1323]។

469. ដោយបានពិចារណាទៅលើ ភាពមិនស្របគ្នាមួយចំនួន នៅក្នុងភស្តុតាងរបស់ ហោ យ៉ន សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចជាចុងក្រោយថា "មានភាពច្បាស់លាស់គ្រប់គ្រាន់ថា គាត់បានចេញបញ្ជាឲ្យ "វះពោះ" អ្នកទោស ហើយថា គាត់បានឃើញគេយកប្រម៉ាត់ ដាក់ក្នុងធុងមួយ ហើយគាត់បានទទួលប្រមាត់ទាំងនោះជាមួយ តាណាំ មែន"[1324]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានត្រួតពិនិត្យដោយប្រុងប្រយ័ត្នទៅលើភស្តុតាងទាំងស្រុងរបស់ ហោ យ៉ន។ ដូច្នេះ អង្គជំនុំជម្រះបានសម្រេចថា ការសម្រេចខាងលើមិនមែនមិនសមហេតុផលនោះទេ។

470. សហមេធាវីបានជំទាស់បន្ថែមចំពោះការសម្រេចទាក់ទងនឹង រចនាសម្ព័ន្ធរាយការណ៍ និងឋានានុក្រមបញ្ជាការ នៅក្នុងស្រុកគិរីវង់ ទៅលើវត្តព្រះធាតុ[1325]។ ពិសេសជាងនេះទៅទៀត ការជំទាស់របស់សហមេធាវី ពាក់ព័ន្ធទៅនឹងការពឹងផ្អែករបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើភស្តុតាងរបស់ ដុក ចាន់ នៅក្នុងការសម្រេចថា យឹម ទិត្យ បានចូលរួមការប្រជុំថ្នាក់ស្រុកជាមួយ តាព្រីង ប្រធានវត្តព្រះធាតុ[1326] និងភស្តុតាងរបស់ អោក ចន ទាក់ទងនឹងសិទ្ធិអំណាចរបស់ យឹម ទិត្យ ក្នុងការចេញបញ្ជា[1327]។

---

[1323] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦០។ សហមេធាវីចោទថា ប្រភពនៃភស្តុតាងរបស់គាត់ដែលថា "ទិត តុម ឬ នៅពីលើវត្តព្រះធាតុ" មិនច្បាស់លាស់"។

[1324] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៥៧។

[1325] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦១-២៦៣។

[1326] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦១ *យោងទៅ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៤៣៩។

[1327] បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦៣ និង ជើងទំព័រ ៨៤១។

01677353



471. ទោះបីជា ឌុក ចាន់ មិនបានផ្តល់ភ័ស្តុតាងអំពីខ្លឹមសារនៃរបាយការណ៍របស់ ព្រីង ឬទម្រង់នៃរបាយការណ៍ ដូចការចោទក្តី[1328] តែចៅក្រមអន្តរជាតិមិនជឿថា ចាំបាច់តម្រូវឱ្យមានព័ត៌មានលម្អិតកម្រិតនេះ ដើម្បីធ្វើការសម្រេចទៅលើវចនាសម្ព័ន្ធរាយការណ៍ និងឋានានុក្រមបញ្ជាការនៅក្នុងស្រុកគិរីវង់ឡើយ។ អង្គជំនុំជម្រះបានកត់សម្គាល់បន្ថែមថា ឌុក ចាន់ ខ្លួនគាត់ផ្ទាល់ គឺជាបុគ្គលិកនៅវត្តព្រះធាតុ ហើយគាត់ដឹងអំពីវចនាសម្ព័ន្ធរដ្ឋបាលរបស់មន្ទីរសន្តិសុខ រួមទាំង តួនាទីរបស់ព្រីង ជាប្រធានមន្ទីរសន្តិសុខ[1329]។ ឌុក ចាន់ បានបញ្ជាក់ថា វត្តព្រះធាតុ គឺជាគុកស្រុក[1330] ដែលព្រីង រាយការណ៍ទៅស្រុក១០៩ និង ថា យឹម ទិត្យ ក្លាយជាលេខាស្រុក ក្រោយពេលផ្ទេរតាត[1331]។ គាត់បានពន្យល់ថា ប្រជាជនធម្មតាស្គាល់ឈ្មោះ និងតួនាទី យឹម ទិត្យ ព្រោះតួនាទីរបស់គាត់ ត្រូវបានគេប្រកាសរាល់ពេលចូលរួមប្រជុំទាំងអស់ ហើយគាត់ចូលរួមដោយផ្ទាល់ជាទៀងទាត់[1332]។ ហេតុដូច្នេះ ការចោទថា ឌុក ចាន់ មិនអាចដឹងអំពីវចនាសម្ព័ន្ធរាយការណ៍ ឬថាគាត់មិនបានផ្តល់ភ័ស្តុតាង អំពីតួនាទីរបស់ យឹម ទិត្យ មិនអាចជឿជាក់បានឡើយ[1333]។

472. ជាចុងក្រោយ អោក ចន បានបញ្ជាក់ថា បើតាមច្បាប់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ បញ្ជាសម្លាប់គឺចេញពីថ្នាក់តំបន់ ប៉ុន្តែ ថាថ្នាក់ស្រុក (យឹម ទិត្យ) បញ្ជូនបញ្ជាសម្លាប់ទៅមេគុក[1334]

---

[1328] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦១ និង ជើងទំព័រ ៨៣៦។

[1329] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឌុក ចាន់ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/86 នៅត្រង់ ERN 01040103 (ឆ៣-ឆ៤)។

[1330] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឌុក ចាន់ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/86 នៅត្រង់ ERN 01040104 (ឆ៦) ("បាទ វត្តព្រះធាតុ គឺជាគុករបស់ស្រុក")។

[1331] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឌុក ចាន់ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/86 នៅត្រង់ ERN 01040104 (ស៧-ឆ៧)។

[1332] កំណត់ហេតុស្តាប់ចម្លើយសាក្សី ឌុក ចាន់ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D219/87 នៅត្រង់ ERN 01040114 (ឆ១៦-ឆ១៧)។

[1333] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦១។

[1334] កំណត់ហេតុស្តាប់ចម្លើយសាក្សី អោក ចន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ D118/156 នៅត្រង់ ERN 00968094 (ឆ៥៨-ឆ៦០) ("ពីព្រោះច្បាប់នៅក្នុងសម័យខ្មែរក្រហមគឺគត្ថា លុះត្រាមានបញ្ជាពីថ្នាក់តំបន់ ទើបថ្នាក់ស្រុកសម្លាប់។ [...] មេគុកទទួលបញ្ជាពីថ្នាក់លើ ទើបមេគុកបញ្ជា ឱ្យសម្លាប់អ្នកទោស។ ស៖ [...] តើអ្នកណាជាអ្នកបញ្ជា ឱ្យមេគុកសម្លាប់អ្នកទោស? ឆ៦០៖គឺមានមនុស្សមកពីខាងស្រុក ហើយយកបញ្ជាឱ្យមេគុកសម្លាប់មនុស្ស")។ សូមមើលបន្ថែម កំណត់ហេតុស្តាប់

01677354



ហើយក្រោយមកបញ្ជាក់ថា បញ្ជាសម្លាប់គឺចេញដោយសមាជិកគណៈកម្មាធិការស្រុក[1335]។ ចំពោះការដោះលែងរូបគាត់ផ្ទាល់[1336] លោក ចន បានពន្យល់ថា គាត់មិនបានឮ យឹម ទិត្យ ចេញបញ្ជាឱ្យដោះ លែងទេ ប៉ុន្តែគាត់ជឿថា បញ្ជានេះចេញពី យឹម ទិត្យ ព្រោះគាត់ត្រូវបានដោះលែងបន្ទាប់ពី យឹម ទិត្យមកត្រួតពិនិត្យគុក[1337]។ ទោះបីជាចៅក្រមអន្តរជាតិកត់សម្គាល់ថា លោក ចន មិនបានឮដោយផ្ទាល់ យឹម ទិត្យ ចេញបញ្ជាណាមួយក្តី តែភស្តុតាងរបស់គាត់មានការគាំទ្រចំពោះការសម្រេចថា យឹម ទិត្យ ចេញបញ្ជា ឬបញ្ជូនបញ្ជាសម្លាប់អ្នកទោសនៅវត្តព្រះធាតុ។

473. សរុបមក អង្គបុរេជំនុំជម្រះសម្រេចថា សហមេធាវីមិនបានបង្ហាញអំពីកំហុសណាមួយនៅក្នុងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា យឹម ទិត្យ ទៅត្រួតពិនិត្យវត្តព្រះធាតុ សួរចម្លើយអ្នកទោស និងចេញបញ្ជា ឬបញ្ជូនបញ្ជាសម្លាប់អ្នកទោស។ អង្គជំនុំជម្រះជឿថា មានភស្តុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការសម្រេចអំពីការចូលរួមដ៏សំខាន់របស់ យឹម ទិត្យ នៅក្នុងការអនុវត្តសហឧក្រិដ្ឋកម្មរួម។ អាស្រ័យហេតុនេះ មូលដ្ឋាន ៥.៣ (iii) ត្រូវបានសម្រេចថា ត្រូវបានបដិសេធចោល។

## សេចក្តីសន្និដ្ឋាន

474. បន្ទាប់ពីបានពិនិត្យឡើងវិញនូវមូលដ្ឋានតូចៗចំនួន ១០ នៅក្នុងបណ្តឹងឧទ្ធរណ៍ដែលសហមេធាវីបានដាក់រួចមក ចៅក្រមអន្តរជាតិសន្និដ្ឋានថា ទឡ្ហីករណ៍របស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសជាប្រព័ន្ធក្នុងការវាយតំលៃលើភស្តុតាងនោះ ពុំមានមូលដ្ឋានឡើយ។ ពាក់ព័ន្ធនឹងបញ្ហានេះ ចៅក្រមអន្តរជាតិបដិសេធសេចក្តីសន្និដ្ឋានដែលថា សហ

ចម្លើយសាក្សី លោក ចន ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១២ ឯកសារ D105/5 នៅត្រង់ ERN 00788847 (ឆ៥៥) ("ឧបមាថា គណៈស្រុកទី១ ទី២ ទី៣ អញ្ជើង បើមានផែនការពីលើមកថាឱ្យសម្លាប់ គឺត្រូវសម្លាប់តែម្តង") 00788851 (ឆ៩៥) ("[យឹម ទិត្យ] មកដូចជាថា នាំយកបទបញ្ជាពីតំបន់ថា តើអ្នកទោសណាត្រូវសម្លាប់")។

[1335] កំណត់ហេតុស្តាប់ចម្លើយសាក្សី លោក ចន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/369 នៅត្រង់ ERN 01110214 (ឆ១០១)។

[1336] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D382/22) កថាខណ្ឌ ២៦៣ និងជើងទំព័រ ៨៤២។

[1337] កំណត់ហេតុស្តាប់ចម្លើយសាក្សី លោក ចន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D219/369 នៅត្រង់ ERN 01110214-01120215 (ឆ១០៤-ឆ១១២)។

ចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានជាប្រព័ន្ធមិនបានពិចារណាភស្តុតាងផ្ទុយ និងភស្តុតាងដោះបន្ទុក មិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់ចំពោះការរកឃើញរបស់ខ្លួន ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្តមិនត្រឹមត្រូវចំពោះបទដ្ឋាននៃការបង្ហាញភស្តុតាង ក្នុងការសន្និដ្ឋានអំពីមុខតំណែង*តាមផ្លូវច្បាប់* និងសិទ្ធិអំណាច*តាមព្រឹត្តន័យ*របស់ លោក យឹម ទិត្យ នៅភូមិភាគពាយ័ព្យ និងនិរតី[1338]។

475. ចៅក្រមអន្តរជាតិពិចារណាបន្ថែមទៀតថា ភស្តុតាងបង្ហាញយ៉ាងរឹងមាំអំពីសមាជិកភាពរបស់លោក យឹម ទិត្យ និងការចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងសហឧក្រិដ្ឋកម្មរួម ក ខ និង គ[1339]។ ម្យ៉ាងវិញទៀត ករណីដែលថា លោក យឹម ទិត្យ ពុំមែនជាសមាជិកគណៈកម្មាធិការមជ្ឈិម ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយគាត់ពុំបានបង្កើតគោលនយោបាយ ប.ក.ក នោះ វាមិនគ្រប់គ្រាន់ក្នុងការរារាំងដល់ការរកឃើញថា លោក យឹម ទិត្យ ស្ថិតនៅក្នុងចំណោមជនទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះឡើយ[1340]។

476. ចៅក្រមអន្តរជាតិតម្កល់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកតាមឆន្ទានុសិទ្ធិយ៉ាងសមហេតុផលដែលថា លោក យឹម ទិត្យ ស្ថិតក្នុងចំណោមជនទាំងឡាយ "ដែល

---

[1338] *ខុសភើបណ្តឹងឧទ្ធរណ៍*របស់ លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២១៨ កថាខណ្ឌ ២២០ កថាខណ្ឌ ២៦៦។

[1339] *ខុសភើបណ្តឹងឧទ្ធរណ៍*របស់ លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២១៩។

[1340] *ខុសភើបណ្តឹងឧទ្ធរណ៍*របស់ លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២១៧ កថាខណ្ឌ ២១៩។ *សូមមើលជារួម* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 & D360/33) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៤៤១។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D308/3/1/20) មតិយោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២១ កថាខណ្ឌ ៣៣៤ ("ពីដំបូង ចៅក្រមទទួលបន្ទុកលើរឿងក្តីសង្កេតឃើញថា "ផលវិបាកជាក់ស្តែងដំបូង" ដែលតួនាទីផ្លូវការរបស់បុគ្គលម្នាក់មាននៅក្នុងឋានានុក្រម ដូចដែលបានអនុវត្តដោយសហចៅក្រមស៊ើបអង្កេត មិនគួរមិនរាប់បញ្ចូលដោយស្វ័យប្រវត្តិបុគ្គលនៅថ្នាក់ទាបៗ ដែលពាក់ព័ន្ធដោយផ្ទាល់នៅក្នុងអំពើឃោរឃៅដ៏ធ្ងន់ធ្ងរបំផុតនោះឡើយ")។

ទទួលខុសត្រូវខ្ពស់បំផុត" ជាហេតុធ្វើឱ្យគាត់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អក.ត.វ.[1341]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិបដិសេធមូលដ្ឋានទី ៥។

## E. សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

477. យោងតាមសំអាងហេតុទាំងអស់ដែលបានលើកឡើងខាងលើ ចៅក្រមអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានប្រព្រឹត្តកំហុស ឬការបំពានដែលជាកត្តាកំណត់យ៉ាងសំខាន់នៃការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសន្និដ្ឋានថា យឹម ទិត្យ ស្ថិតក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងរយៈកាលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិ តម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមអន្តរជាតិ និងសន្និដ្ឋានថា យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

478. មិនតែប៉ុណ្ណោះ ចៅក្រមអន្តរជាតិតម្កល់បទចោទនានា ដូចបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ អាស្រ័យហេតុនេះ យឹម ទិត្យ ត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខចៅក្រមអន្តរជាតិសាលាដំបូង។

## បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ

### ១. អំណះអំណាង

479. សហព្រះរាជអាជ្ញាជាតិលើកឡើងថា សំណុំរឿងប្រឆាំងនឹង យឹម ទិត្យ គួរត្រូវបានបដិសេធចោលដោយហេតុថា (១) គាត់ "រួចផុតពីការទទួលសុខត្រូវ" និង (២) គាត់មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ[1342]។

---

[1341] *ខុសពី*បណ្តឹងឧទ្ធរណ៍របស់ លោក យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D382/22) កថាខណ្ឌ ២៦៥ កថាខណ្ឌ ២៦៧។

[1342] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ )D382/4/1៥៣ កថាខណ្ឌ (-៧៦។

01677357



480. ទីមួយ សហព្រះរាជអាជ្ញាជាតិជំទាស់ថា យ៉ឹម ទិត្យ ពុំទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងនោះទេ ពីព្រោះថា គណៈកម្មាធិការអចិន្ត្រៃយ៍នៃ ប.ក.ក ដែលមានសមាសភាពចំនួនប្រាំពីររូប រួមទាំង ប៉ុល ពត និង នួន ជា ដែលមានអំណាចលើការសម្រេចនានា និងបានដាក់ចេញនូវគោលនយោបាយបោសនៃការបោសសម្អាត និងការបង្ក្រាប[1343]។ សហព្រះរាជអាជ្ញាជាតិអះអាងថា គោលនយោបាយបោសសម្អាតត្រូវបានស្តែងឡើងតាមរយៈសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមបក្ស ប.ក.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលបានកំណត់យ៉ាងច្បាស់លាស់ថា ការបោសសម្អាតនៅក្នុងភូមិភាគ ត្រូវអចិន្ត្រៃយ៍ភូមិភាគសម្រេច[1344] និងអះអាងបន្ថែមថា គោលនយោបាយបង្ក្រាបកាន់តែរាលដាលលាតសន្ធឹងទូទាំងប្រទេសក្រោយពីមានសេចក្តីសម្រេចនេះមក[1345]។

481. ទីពីរ សហព្រះរាជអាជ្ញាជាតិអះអាងថា យ៉ឹម ទិត្យ គ្មានសិទ្ធិអំណាចអ្វី ក្រៅតែពីការគោរពតាមមាគ៌ាបក្សនោះទេ ហើយហេតុដូច្នេះ គាត់មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដូចបានកំណត់ក្នុងមាត្រា ១ នៃ ច្បាប់ អ.វ.ត.ក នោះឡើយ[1346]។ សហព្រះរាជអាជ្ញាជាតិបញ្ជាក់ថា សម្រាប់ការកម្រិតលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺរាជរដ្ឋាភិបាលកម្ពុជា "កំពុងតែដើរតួដូចក្រុមប្រឹក្សាសន្តិសុខ [អង្គការសហប្រជាជាតិ] ដែលក្រុមប្រឹក្សានេះបានអនុវត្តចំពោះតុលាការ ICTY, ICTR និង SCSL អញ្ចឹងដែរ" [1347]។ លោកស្រីជំទាស់ថា "ស្ថាបនិកតុលាការអន្តរជាតិ" អាចមាន "ឥទ្ធិពលលើវិសាលភាពយុត្តាធិការបុគ្គល និងកិច្ចការរបស់តុលាការ ដោយមិនធ្វើឲ្យប៉ះពាល់ដល់អនាគតិ និងឯករាជ្យភាពរបស់តុលាការឡើយ"[1348]។

482. សហព្រះរាជអាជ្ញាជាតិអះអាងថា តាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា និងស្មារតីនៃច្បាប់ អ.វ.ត.ក តម្រូវឲ្យតុលាការនេះធ្វើការស៊ើបអង្កេត និងនាំខ្លួនមកវិនិច្ឆ័យទោសចំពោះតែមេដឹកនាំ

---

[1343] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៥៣-៥៨។
[1344] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៥៣-៥៤។
[1345] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៥៨។
[1346] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៥៩-៧៥។
[1347] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៥៩-៦៥។
[1348] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៦៥។

ជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត នៃរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ[1349]។ យោងតាមសហព្រះរាជអាជ្ញាជាតិ គោលគំនិតរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើតចៅក្រមអន្តរជាតិសាមញ្ញក្នុងតុលាការកម្ពុជា គឺដើម្បីសម្រិតសម្រាំងតែទៅលើ "មេដឹកនាំជាន់ខ្ពស់" មួយចំនួនតូចដែលស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក *ពោលគឺ* ចង់សំដៅតែទៅលើសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស និងសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សតែប៉ុណ្ណោះ[1350]។ តាមការយល់ឃើញរបស់លោកស្រី "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គឺសំដៅតែ កាំង ហ្គេចអ៊ាវ *ហៅ* ឌុច ដែលជាប្រធានមន្ទីរសន្តិសុខ ស-២១ តែម្នាក់គត់ ដោយសារតែ ឌុច បានដើរតួនាទីសំខាន់នៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ មានស្វ័យភាពក្នុងការងារ និងមានអំណាចអនុវត្ត*ដាក់ស្តែង*តែម្តង[1351]។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាជាតិកត់សម្គាល់ថា ឈ្មោះរបស់ យឹម ទិត្យ មិនមាននៅក្នុងឯកសារសហកាលនាសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ ហើយគាត់អះអាងថា ការចោទប្រកាន់ពីសំណាក់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង យឹម ទិត្យ គឺធ្វើឡើងតាមទំនើងចិត្ត និងមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ពីតួនាទីរបស់ យឹម ទិត្យ នៅក្នុងជួរកងទ័ព ឬថាតើគាត់ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សនៃ ប.ក.ក ដែរឬអត់នោះទេ[1352]។

483. តាមរយៈបុព្វកថានៃកិច្ចព្រមព្រៀង អ.វ.ត.ក សហព្រះរាជអាជ្ញាជាតិអះអាងបន្ថែមទៀតថា ជាមួយនឹងការទទួលស្គាល់របស់អង្គការសហប្រជាជាតិចំពោះរាជរដ្ឋាភិបាល និងការព្រួយបារម្ភពេញច្បាប់របស់ប្រជាជនកម្ពុជា គឺត្រូវតែថ្លឹងថ្លែងរវាង "យុត្តិធម៌" និង "ការផ្សះផ្សាជាតិ"។ ដូចបានលើកឡើងខាងលើ ច្បាប់ និង កិច្ចព្រមព្រៀង អ.វ.ត.ក គឺសំដៅតែទៅលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ប៉ុណ្ណោះដែលត្រូវនាំខ្លួនមកវិនិច្ឆ័យទោស[1353]។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាជាតិកត់សម្គាល់ថា ការពង្រីកវិសាលភាពនៃយុត្តាធិការបុគ្គលមកលើ យឹម ទិត្យ ហួសពីវិសាលភាពនៃសំណុំរឿង ០០១ និង ០០២ នឹងខាត

[1349] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៥៩-៧៣។
[1350] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៦៦-៦៨។
[1351] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៦៦។
[1352] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៧៤។
[1353] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៧០-៧១។

បង់ពេលវេលា ព្រមទាំងចំណាយថវិកាដោយមិនចាំបាច់ ជាពិសេស ដោយសារតែជនរងគ្រោះបានទទួលយុត្តិធម៌ តាមរយៈការជំនុំជម្រះលើសំណុំរឿង ០០១ និង ០០២ រួចមកហើយ[1354]។

484. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ៖ (១) មិនត្រូវតាមបទដ្ឋាននៃការត្រួតពិនិត្យលើបណ្ដឹងឧទ្ធរណ៍ទេ (២) តវ៉ាទៅលើនិយមន័យនៃយុត្តាធិការបុគ្គល ដែលមិនគោរពតាមចេតនាដែលបានបញ្ជាក់យ៉ាងច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (៣) ខកខានមិនបានបកស្រាយបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាមានអំណាចកម្រិតជាឯកតោភាគីលើយុត្តាធិការបុគ្គល ដោយមិនបាច់ធ្វើវិសោធនកម្មតាមផ្លូវច្បាប់លើកិច្ចព្រមព្រៀង អ.វ.ត.ក នោះទេ និង (៤) អះអាងដោយមិនគួរឱ្យជឿបានថា សំណុំរឿង ០០១ និង ០០២ បាននាំមកនូវវិធានការយុត្តិធម៌គ្រប់គ្រាន់ និងជាការរួមចំណែកដល់ការផ្សះផ្សាជាតិផងដែរ[1355]។

485. ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិគួរត្រូវបានបដិសេធចោល ដោយសារបណ្ដឹងនេះមិនបានលើកឡើងពីមូលដ្ឋានបណ្ដឹងឧទ្ធរណ៍ច្បាស់លាស់ណាមួយនោះទេ[1356]។ បណ្ដឹងឧទ្ធរណ៍នេះខកខានពុំបានបង្ហាញកំហុសផ្នែកអង្គហេតុ[1357] ឬអង្គច្បាប់[1358] ឬបង្ហាញឱ្យឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរំលោភបំពានឆន្ទានុសិទ្ធិរបស់គាត់នោះទេ[1359]។ ផ្ទុយទៅវិញ បណ្ដឹងឧទ្ធរណ៍នេះគ្រាន់តែធ្វើសេចក្ដីសន្និដ្ឋាន

---

[1354] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៧២។

[1355] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ២-៣៥។

[1356] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ៥។

[1357] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ៤-៥។

[1358] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ៤, ៦។

[1359] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ៤, ៧។

ជាទូទៅ ដែលពុំមានទំនាក់ទំនងដោយផ្ទាល់ ឬច្បាស់លាស់ទាល់តែសោះ ជាមួយនឹងការសម្រេចលើអង្គច្បាប់ ឬអង្គហេតុនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1360]។

486. ទីពីរ និយមន័យនៃយុត្តាធិការបុគ្គលរបស់សហព្រះរាជអាជ្ញាជាតិ មិនគោរពតាមចេតនារបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដែលបានបញ្ជាក់យ៉ាងច្បាស់លាស់ ដោយបានអះអាងមិនត្រឹមត្រូវថា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គឺសំដៅតែ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច តែម្នាក់គត់[1361]។ លិខិតុបករណ៍ទាំងមូលនៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់បង្កើត អ.វ.ត.ក ចែងបញ្ជាក់ច្បាស់លាស់ពីប្រភេទនៃក្រុមមនុស្ស គឺមិនមែនមនុស្សតែម្នាក់នោះទេ[1362] ហើយប្រវត្តិនៃការចរចារបង្កើត អ.វ.ត.ក បង្ហាញថា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ មានចេតនាថា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គឺជាប្រភេទមួយបើកចំហ ដោយសមាជិកភាពរបស់ពួកគេនឹងត្រូវបានកំណត់ដោយសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត[1363] ផ្អែកទៅលើភ័ស្តុតាងទាំងមូល និងបំពេញកិច្ចដោយឯករាជ្យមិនស្ថិតក្រោមការណែនាំណាមួយឡើយ[1364]។

---

[1360] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ៤ *ដែលសំអាងទៅលើ*បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៧៥។

[1361] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ៨ *ដែលសំអាងទៅលើ*បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៦៦, ៧២។

[1362] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ៩ *ដែលសំអាងទៅលើ*កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១។ ច្បាប់ អ.វ.ត.ក មាត្រា ១ និង ២ *ថ្មី*។

[1363] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ១០-១៦។ "ការពិភាក្សា និងយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងការពិភាក្សា និងយល់ព្រមចំពោះវិសោធនកម្មលើច្បាប់ស្តីពីការជំនុំជម្រះលើមេដឹកនាំខ្មែរក្រហម" នីតិកាលទីមួយ អាណត្តិទីបីនៃរដ្ឋសភាជាតិកម្ពុជា ចាប់ពីថ្ងៃទី ៤-៥ ប្រតិចារឹកផ្នែកខ្លះនៃបានបោះពុម្ពផ្សាយនៅក្នុង*ទស្សនាវដ្តីស្វែងរកការពិត* (មជ្ឈមណ្ឌលឯកសារកម្ពុជា [ឬហៅថា *DC-Cam*] ការបោះពុម្ពផ្សាយពិសេសជាភាសាអង់គ្លេស (ត្រីមាសទីបី ឆ្នាំ២០០៤) ឯកសារ D378/5.1.2 ERN (ភាសាអង់គ្លេស) 01593392-01593393។ *របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបានបង្កើតឡើងស្របតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ 52/135* ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ ឯកសារ អ.ស.ប លេខ A/53/850 និង S/1999/231 និងឯកសារ D324.15 កថាខណ្ឌ ១១០។

[1364] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ១៦។

487. ទីបី រាជរដ្ឋាភិបាលកម្ពុជាពុំមានអំណាចកម្រិតដោយឯកតោភាគីទៅលើយុត្តាធិការបុគ្គល ដោយមិនមានការធ្វើវិសោធនកម្មជាផ្លូវការចំពោះកិច្ចព្រមព្រៀង អ.វ.ត.ក បានឡើយ[1365]។ ការប្រៀបធៀបរបស់សហព្រះរាជអាជ្ញាជាតិចំពោះ "ឥទ្ធិពល" របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទៅលើតុលាការ ICTR និង ICTY តាមរយៈសេចក្តីសម្រេច ១៥០៣ និង ១៥៣៤ គឺមិនសមស្របនោះទេ[1366] ហើយការកែប្រែណាមួយទៅលើគោលនយោបាយពាក់ព័ន្ធនឹងបញ្ហានានាដូចដែលបានលើកឡើងក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក រួមទាំងបញ្ហាយុត្តាធិការបុគ្គលផងនោះត្រូវតែអនុម័តដោយភាគីទាំងពីរ។ មកទល់នឹងពេលនេះ ពុំមានភាគីណាមួយបានស្នើឱ្យមានការធ្វើវិសោធនកម្មបទប្បញ្ញត្តិ ទាក់ទងនឹងយុត្តាធិការបុគ្គលនៅឡើយ ទេ[1367]។ លើសពីនេះទៀត វិធានជាសារវ័ន្តនៃគោលការណ៍ច្បាប់ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ ដែលមានចែងក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់បង្កើត អ.វ.ត.ក រដ្ឋធម្មនុញ្ញកម្ពុជា និងលិខិតុបករណ៍សិទ្ធិមនុស្សជាច្រើនដាក់កំហិតភារកិច្ចចំពោះរដ្ឋាភិបាល ក៏ដូចជាស្ថាប័នដទៃទៀតឱ្យដកខ្លួនចេញពីការប្រើប្រាស់ការគាបសង្កត់តាមទម្រង់ណាមួយទៅលើចៅក្រម ដោយហេតុថា ពួកគាត់ត្រូវចេញសេចក្តីសម្រេចផ្តាច់មុខដោយសំអាងលើមូលដ្ឋានច្បាប់ ភ័ស្តុតាង សេចក្តីសម្រេច និងសម្បជញ្ញៈផ្ទាល់ខ្លួន[1368]។

---

[1365] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ២, ១៧-២៦។

[1366] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ១៩, ២០-២៣។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥០៣ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣, ឯកសារ អ.ស.ប លេខ S/RES/1503 (ឆ្នាំ២០០៣) ឯកសារ D378/5.1.12។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥៣៤ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤, ឯកសារ អ.ស.ប លេខ S/RES/1534 (ឆ្នាំ២០០៤) ឯកសារ D378/5.1.13។.

[1367] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ២០ *ដែលសំអាងទៅលើ*កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២(៣)។

[1368] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ២៥-២៦ *ដែលសំអាងទៅលើរដ្ឋធម្មនុញ្ញកម្ពុជា* (ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងស្តីពីគោលការណ៍ឯករាជ្យភាពរបស់តុលាការនៅក្នុងតំបន់ Lawasia សមាគមច្បាប់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៧។ គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ ដែលបានអនុម័តដោយសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៤០/៣២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និងលេខ ៤០/១៤៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥។ ក្រមទីក្រុងញូវដេលីស្តីពីបទដ្ឋានអប្បរមានៃឯករាជ្យភាពរបស់តុលាការ គណៈមេធាវីអន្តរជាតិ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៨២។

488. ចុងបញ្ចប់ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ដំណោះស្រាយតាមផ្លូវតុលាការដោយឯករាជ្យចំពោះសំណុំរឿង ០០៣, ០០៤ និង ០០៤/២ នឹងលើកកម្ពស់ទាំងយុត្តិធម៌ និងការផ្សះផ្សា ជាជាងធ្វើឱ្យវាអន្តរាយទៅវិញទេ[1369]។ ពុំមានការបញ្ជាក់ថា ដំណោះស្រាយលើសំណុំរឿងទាំងនេះនឹងគំរាមកំហែងដល់សន្តិភាព និងសន្តិសុខនៅក្នុងប្រទេសកម្ពុជានោះឡើយ[1370]។ លើសពីនេះទៀត ដោយការយល់ឃើញថា សំណុំរឿង ០០៣, ០០៤ និង ០០៤/២ រួមទាំងបញ្ហានានា និងទីតាំងឧក្រិដ្ឋកម្មដែលមិនត្រូវបានដោះស្រាយក្នុងសំណុំរឿង ០០១ និង ០០២ ជនរងគ្រោះ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនមានចំណាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងការស្តាប់អំពីការពិត និងពុំយល់ឃើញថា យុត្តិធម៌ត្រូវបានផ្តល់ជូនរួចហើយ តាមរយៈសំណុំរឿង ០០១ និង ០០២ នោះទេ[1371]។

489. សហព្រះរាជអាជ្ញាជាតិពុំបានដាក់ការឆ្លើយតបទេ។

## ២. ការពិភាក្សា

490. ជាការកត់សម្គាល់បឋម ចៅក្រមអន្តរជាតិសង្កេតឃើញថា សហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[1372] ហើយបានបញ្ជាក់ជាថ្មីថា បណ្តឹង

[1369] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ២, ២៧-៣៥។

[1370] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ២៩។

[1371] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/16) កថាខណ្ឌ ៣០-៣៤ ដែលយោងទៅអត្ថបទរបស់ T. WILLIAMS *និងអ្នកផ្សេងទៀត, យុត្តិធម៌ និងការផ្សះផ្សាសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម? ការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការយុត្តិធម៌ឆ្លងសម័យដែនជាតិ* (Marburg:សមជ្ឈមណ្ឌលសម្រាប់ការសិក្សាអំពីជម្លោះ ភ្នំពេញ: មជ្ឈមណ្ឌលសម្រាប់ការសិក្សាអំពីមនុស្សធម៌ Bern: Swisspeace ចុះខែវិច្ឆិកា ឆ្នាំ២០១៨)។ H. RYAN និង L. MCGREW *ការសំដែង និងទស្សនទាន: ផលប៉ះពាល់របស់ចៅក្រមអន្តរជាតិវិសាមញ្ញក្នុងតុលាការកម្ពុជា* (ទីក្រុងញូវយ៉ក: អង្គការ Open Society Justice Initiative ឆ្នាំ២០១៦)។ P. PHAM *និងអ្នកផ្សេងទៀត, បន្ទាប់ពីការជំនុំជម្រះលើកទីមួយ: ការសិក្សាស្រាវជ្រាវផ្តោតទៅលើប្រជាជនស្តីពីការយល់ដឹង និងការយល់ឃើញចំពោះយុត្តិធម៌ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* (មជ្ឈមណ្ឌលសិទ្ធិមនុស្ស សាកលវិទ្យាល័យកាលីហ្វ័រនីញ៉ា សាលាច្បាប់ Berkley ចុះខែមិថុនា ឆ្នាំ២០១១)។

[1372] វិធាន ៧៤(២) នៃវិធានផ្ទៃក្នុង។

ខន្ទរណ៍របស់សហព្រះរាជអាជ្ញាជាតិអាចទទួលយកបាន[1373]។ ទោះជាយ៉ាងនេះក្តី ចៅក្រមអន្តរជាតិ សូមរំលឹកថា អំណះអំណាងរបស់ភាគីមួយដែលមិនអាចនាំឱ្យបដិសេធ ឬ កែប្រែសេចក្តីសម្រេចដែលរងការជំទាស់ អាចត្រូវបានច្រានចោលដោយពុំចាំបាច់វិភាគលើខ្លឹមសារនោះទេ[1374]។ ចៅក្រមអន្តរជាតិបញ្ជាក់បន្ថែមទៀតថា ចៅក្រមអន្តរជាតិនឹងមិនពិចារណាលម្អិតលើការចោទប្រកាន់ដែលមានភាពមិនច្បាស់លាស់ ស្រពិចស្រពិល ឬមិនមានលក្ខណៈគ្រប់គ្រាន់ជាផ្លូវការ និងជាក់ស្តែងផ្សេងទៀតនោះឡើយ[1375]។

491. ចៅក្រមអន្តរជាតិសង្កេតឃើញថា សហព្រះរាជអាជ្ញាជាតិធ្វើសេចក្តីសន្និដ្ឋានស្តីពីបរិបទប្រវត្តិសាស្ត្រ និងសាវតាររបស់ លោក យឹម ទិត្យ ដោយមិនបានបង្ហាញកំហុសជាក់លាក់ប្រព្រឹត្តដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[1376]។ លោកស្រីត្រឹមតែអះអាងបន្ថែមអំពីការបកស្រាយរបស់លោកស្រីអំពី "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ" និង "អ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងយុត្តាធិការបុគ្គល របស់អ.វ.ត.ក[1377]។ ដើម្បីគាំទ្រជំហររបស់លោក

---

[1373] សូមមើល កថាខណ្ឌ ៣៩ ខាងលើ។

[1374] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងខន្ទរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៦៤៩។ សំណុំរឿង ០០២ សាលដីកាលើសេចក្តីសម្រេចលើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 ("សំណុំរឿង ០០២ សាលដីកាលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D250/3/2/1/5)") កថាខណ្ឌ ២២ *យោងលើ* សាលដីកា *Rutaganda* (តុលាការ ICTR) កថាខណ្ឌ ១៨។ តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blaškić* សំណុំរឿងលេខ IT-95-14-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៣។

[1375] ដីកាសម្រេចក្នុងសំណុំរឿង ០០២ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D250/3/2/1/5) កថាខណ្ឌ ២២។

[1376] បណ្តឹងខន្ទរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ១៩-៥១ (លើកឡើងអំពីប្រវត្តិ ប.ក.ក វចនាសម្ព័ន្ធ និងជួរដឹកនាំ វចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យព្រមទាំងសាវតារបុគ្គលរបស់ យឹម ទិត្យ និងតួនាទីនៅក្នុងភូមិភាគពាយ័ព្យ)។

[1377] បណ្តឹងខន្ទរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៥៩-៧៥។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ទោះបីសញ្ញាណនៃអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត មិនត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀង ឬ ច្បាប់ អ.វ.ត.ក ក៏ដោយ យើងចាំបាច់ពិនិត្យមើលប្រវត្តិនៃការចរចានៅពេលណាដែលការអនុវត្តវិធានទូទៅស្តីពីការបកស្រាយពុំមានប្រសិទ្ធិភាព ពោលគឺពាក្យពេចន៍ត្រូវបកស្រាយក្នុងបរិបទ និងដោយផ្អែកលើគោលបំណង និងកម្មវត្ថុនៃឯកសារបង្កើតតុលាការ ដោយត្រូវពិចារណា

ស្រី សហព្រះរាជអាជ្ញាជាតិមិនបានផ្តល់នូវឯកសារយោងច្បាស់លាស់ណាមួយ ចំពោះការរកឃើញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានជំទាស់តវ៉ានោះទេ[1378]។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិខកខានមិនបានកំណត់ និងបញ្ជាក់អំពីកំហុសឆ្គងដែលអាចយកមកពិនិត្យឡើងវិញបាន នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[1379]។ ដូច្នេះ ចៅក្រមអន្តរជាតិយល់ឃើញថា សេចក្តីសន្និដ្ឋានបច្ចុប្បន្ននេះ មិនមានអានុភាពនាំឲ្យមានការច្រានចោល ឬកែប្រែសេចក្តីសម្រេចដែលរងការជំទាស់ឡើយ ដូច្នេះ អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍នេះទាំងស្រុងតែម្តង។

492. ទោះបីជាសម្រេចបដិសេធចោលភ្លាមៗក្តី ចៅក្រមអន្តរជាតិបញ្ជាក់ជាថ្មីនូវអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេចលើបញ្ហាទាំងឡាយ ដែលមានសារសំខាន់ជាទូទៅចំពោះយុត្តិសាស្ត្រ និងកេរ្តិ៍ដំណែលរបស់ អ.វ.ត.ក[1380]។ អាស្រ័យដូចនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ជាការសមហេតុផលក្នុងការបញ្ជាក់បំភ្លឺលើបញ្ហាចំនួនពីរដែលសហព្រះរាជអាជ្ញាជាតិបានលើកឡើង គឺ (i) ជំហរ និងសិទ្ធិអំណាចរបស់រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងយុត្តាធិការបុគ្គលរបស់

---

លើច្បាប់អន្តរជាតិជាធរមាន។ ចៅក្រមអន្តរជាតិយល់ឃើញថា ចំពោះករណីនេះ វាមិនមែនដូច្នោះនោះទេហើយអត្ថន័យនៃអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតអាចត្រូវបានកំណត់ ដោយការពិនិត្យលើយុត្តិសាស្ត្រច្បាប់អន្តរជាតិពាក់ព័ន្ធ។ *សូមមើល អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា* ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ 1155 U.N.T.S. 331 ចូលជាធរមាននៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨០ ("អនុសញ្ញាទីក្រុងវីយែន") មាត្រា ៣១-៣២។

[1378] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ១៩-៧៦។

[1379] *សូមមើល* សំណុំរឿង ០០៣ សេចក្តីពិចារណាលើដីកាដំណោះស្រាយ កថាខណ្ឌ ១៩១។

[1380] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ៣២-៣៣។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើដីកាដំណោះស្រាយ (D266/27 & D267/35) កថាខណ្ឌ ១៩៣។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៧៣ *យោងទៅ* តុលាការ ICTR *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-A សាលដីកា ចៅក្រមអន្តរជាតិតុលាការកំពូល ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០១ ("សាលដីកា*Akayesu* (តុលាការ ICTR)") កថាខណ្ឌ ១៩ កថាខណ្ឌ ២៣-២៤។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-A សាលដីកា ចៅក្រមអន្តរជាតិតុលាការកំពូល ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ("សាកដីកា *Tadić* (តុលាការ ICTY)") កថាខណ្ឌ ២៤៧ កថាខណ្ឌ ២៨១ កថាខណ្ឌ ៣១៦។ តុលាការ ICTY *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Mucić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-21-A សាលដីកា ចៅក្រមអន្តរជាតិតុលាការកំពូល ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២២១។

អ.វ.ត.ក[1381] និង (ii) "ការចោទប្រកាន់អំពីតុល្យភាពរវាងយុត្តិធម៌ និងការផ្សះផ្សាជាតិ" សម្រាប់ជនរងគ្រោះក្នុងសំណុំរឿង ០០៤[1382]។

493. ទីមួយ ចៅក្រមអន្តរជាតិយល់ឃើញថា ការអះអាងរបស់សហព្រះរាជអាជ្ញាជាតិដែលថារាជរដ្ឋាភិបាលកម្ពុជា ស្រដៀងនឹងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ហើយអាចមានឥទ្ធិពលលើការប្រព្រឹត្តទៅរបស់ អ.វ.ត.ក[1383] គឺមានកំហុស និងច្រានចោលទាំងស្រុងតែម្តង។ ក្នុងន័យនេះ ចៅក្រមអន្តរជាតិសង្កេតឃើញថាកិច្ចព្រមព្រៀង អ.វ.ត.ក ត្រូវបានចែង និងអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបន្ទាប់ពីមានការចរចារវាងភាគីទាំងពីរ។ ដូច្នេះ ក្នុងនាមជាភាគីនៃកិច្ចព្រមព្រៀង អ.វ.ត.ក រាជរដ្ឋាភិបាលកម្ពុជាត្រូវគោរពតាមលក្ខខណ្ឌ ហើយត្រូវតែអនុវត្តដោយស្មោះត្រង់[1384]។ ទាំងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ជាធរមានផ្សេងទៀត ពុំបានចែងថារាជរដ្ឋាភិបាលកម្ពុជាមានអំណាចឯកតោភាគីដើម្បី "មានឥទ្ធិពលលើវិសាលភាពនៃយុត្តាធិការបុគ្គលនិងកិច្ចការតុលាការ" [1385] របស់តុលាការនោះទេ។ ផ្ទុយមកវិញ គោលការណ៍ឯករាជ្យភាពរបស់តុលាការ ដែលបានកំណត់ដោយកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ចងកាតព្វកិច្ចឱ្យគោរព និងអនុវត្តឯករាជ្យភាពនៃតុលាការនៅពេលបំពេញមុខងារ[1386]។ ចៅក្រមអន្តរជាតិយល់ឃើញថា ទស្សនៈរបស់សហព្រះរាជអាជ្ញាជាតិស្តីពីប្រវត្តិចរចារបស់ អ.វ.ត.ក ដែលបង្ហាញអំពីតែ "ទស្សនៈរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះកិច្ចព្រមព្រៀង អ.វ.ត.ក"[1387] មិនបានផ្តល់នូវមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការបកស្រាយកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ទាក់ទងនឹងយុត្តាធិការបុគ្គលនោះឡើយ។

494. ទីពីរ ចៅក្រមអន្តរជាតិកត់សម្គាល់ថា បុព្វកថានៃកិច្ចព្រមព្រៀង អ.វ.ត.ក បញ្ជាក់ការទទួលស្គាល់របស់មហាសន្និបាតអង្គការសហប្រជាជាតិអំពី "ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និង

---

[1381] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៥៩-៦៨។

[1382] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៧០-៧២។

[1383] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៦៥។

[1384] *សូមមើល* អនុសញ្ញាទីក្រុងវីយែន មាត្រា ២៦។

[1385] *ផ្ទុយពី* បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៦៥។

[1386] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៣(៣) និងច្បាប់ អ.វ.ត.ក មាត្រា ១០ថ្មី។

[1387] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៦៦-៦៨។

01677366



សន្តិសុខ"[1388]។ ចៅក្រមអន្តរជាតិយល់ឃើញថា ការអះអាងរបស់សហព្រះរាជអាជ្ញាជាតិដែលថា "ការថ្លឹងថ្លែងរវាង "យុត្តិធម៌" និង "ការផ្សះផ្សាជាតិ" គឺស្មើនឹងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះក្នុងសំណុំរឿង ០០៤ តាមរយៈការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០១ និង ០០២ គឺជាការភាន់ច្រឡំ[1389]។ ដោយពិចារណាលើគោលបំណងរបស់កិច្ចព្រមព្រៀង អ.វ.ត.ក ដូចមានចែងក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក រួមជាមួយនឹងបុព្វកថានោះ[1390] អង្គជំនុំជម្រះយល់ឃើញថា "ការផ្សះផ្សារជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ" ត្រូវបានធានាតាមរយៈ "យុត្តិធម៌" ដោយនាំយកមកកាត់ទោសនូវមេដឹកនាំជាន់ខ្ពស់ នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ ដោយកត់សម្គាល់អំពីសារសំខាន់នៃយុត្តិធម៌ចំពោះដំណើរការផ្សះផ្សា អង្គជំនុំជម្រះកត់សម្គាល់ថា និទណ្ឌភាពនោះទេដែលអាចប៉ះពាល់ដល់ដំណើរការផ្សះផ្សាសម្រាប់ជនរងគ្រោះ[1391]។

495. លើសពីនេះទៀត ជនរងគ្រោះដែលចូលរួមក្នុងនាមជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ចាំបាច់ត្រូវបង្កើតការផ្សារភ្ជាប់ទៅនឹងឧក្រិដ្ឋកម្មជាក់លាក់ណាមួយរបស់ជនជាប់ចោទ[1392]។ ដូច្នេះ អំណះអំណាងរបស់សហព្រះរាជអាជ្ញាជាតិ ដែលថា "យុត្តិធម៌ត្រូវបាននាំមកជូន [ជនរងគ្រោះ] តាមរយៈការជំនុំជម្រះក្តីលើសំណុំរឿង ០០១ និង ០០២"[1393] គឺមិនអាចជឿជាក់បានឡើយ ពីព្រោះសំណុំរឿង ០០១ និងសំណុំរឿង ០០២ មិនអាចរាប់បញ្ចូលជនរងគ្រោះទាំងអស់នៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឱ្យបានសមហេតុផលនោះទេ។ សហចៅក្រមស៊ើបអង្កេតជាតិ នៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់ក្នុងសំណុំរឿង ០០៤ បានប៉ាន់ស្មានចំនួនជនរងគ្រោះមានរាប់

[1388] កិច្ចព្រមព្រៀង អ.វ.ត.ក បុព្វកថា។

[1389] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៧០-៧២។

[1390] កិច្ចព្រមព្រៀង អ.វ.ត.ក បុព្វកថា មាត្រា ១។

[1391] *សូមមើលផងដែរ* សេចក្តីពិចារណាលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឯកសារ D1/1.3 កថាខណ្ឌ ៣៣-៣៦ កថាខណ្ឌ ៤៥ (ដែលសហព្រះរាជអាជ្ញាជាតិចោទប្រកាន់ស្រដៀងគ្នាថា ការផ្តួចផ្តើមការចោទប្រកាន់ថ្មីអាចរាំងស្ទះដល់ដំណើរការផ្សះផ្សាជាតិ។ ទោះបីជាចៅក្រមអន្តរជាតិពុំអាចរកសម្លេងភាគច្រើនលើសលប់ ដើម្បីចេញសេចក្តីសម្រេចលើអង្គសេចក្តីក៏ដោយ រឿងក្តីត្រូវបន្តទៅដំណាក់កាលស៊ើបសួរ)។

[1392] វិធាន ២៣*ស្ទួន*(១)(ខ)។

[1393] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៧២។

01677367



ពាន់នាក់នៅតាមទីតាំងឧក្រិដ្ឋកម្មចំនួន ២៤ ក្រោមការស៊ើបអង្កេតរបស់ខ្លួន[1394]។ នៅក្នុងសំណុំរឿង ០០៤ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានប្រមាណ ២.០០០ នាក់ បានស្នើសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដោយក្នុងនោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១.០៦៤ នាក់ ត្រូវបានប្រកាសទទួលយកដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[1395]។ លើសពីនេះទៀត ចៅក្រមអន្តរជាតិកត់សម្គាល់យ៉ាងត្រឹមត្រូវថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រមាណ ៩០០ នាក់ ដែលពាក្យសុំរបស់ពួកគេត្រូវបានច្រានចោលដោយដីកាសម្រេចស្តីពីភាពអាចទទួលយកបាន កំពុងប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[1396]។

496. លោក យឹម ទិត្យ ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ដែល "តាមលក្ខណៈរបស់វា បណ្តាលឱ្យមានការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ជនរងគ្រោះ[...]" និងជំរុញឱ្យរដ្ឋមានកាតព្វកិច្ចធ្វើការចោទប្រកាន់ ដែលជាផ្នែកមួយនៃការផ្តល់សំណងដ៏មានប្រសិទ្ធិភាពដល់ជនរងគ្រោះ ស្របតាមមាត្រា ២(៣) នៃ ICCPR[1397]។ អង្គបុរេជំនុំជម្រះពុំជឿជាក់ថា

---

[1394] ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D381) កថាខណ្ឌ ៥៨៩, កថាខណ្ឌ ៦៨០ (រកឃើញថា ប្រជាជនប្រហែល ៥៣.០៥០ ត្រូវបានសម្លាប់នៅតាមទីតាំងឧក្រិដ្ឋកម្មចំនួន ២៤ នៅភូមិភាគពាយ័ព្យ និងភូមិភាគនិរតី) សូមមើលផងដែរ កថាខណ្ឌ ២១២ (ដោយរកឃើញថា ប្រជាជនជាង ១០០នាក់ បានស្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់) កថាខណ្ឌ ២២០ (ដែលប៉ាន់ស្មានថា ប្រជាជនខ្មែរក្រោមជាង ១.០០០នាក់ ត្រូវបានសម្លាប់នៅទីតាំងកាប់សម្លាប់ភូមិព្រាល) កថាខណ្ឌ ២៦០-២៦២ (ដែលពិចារណាឃើញថា ជនរងគ្រោះរាប់រយនាក់បានស្លាប់នៅមន្ទីរសន្តិសុខវត្តគាស់ក្រឡ) កថាខណ្ឌ ៣៦៧ (រកឃើញថា សាកសពប្រហែល ៣០០ ត្រូវបានរកឃើញនៅទីតាំងកាប់សម្លាប់ព្រៃក្របៅ) និងកថាខណ្ឌ ៤១៦ (វាយតម្លៃថា ប្រជាជនរាប់ពាន់នាក់បានស្លាប់នៅគុកលេខ ៨)។

[1395] *សូមមើល សំណុំរឿង ០០៤ ឧបសម្ព័ន្ធ ក បញ្ជីឈ្មោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលយក ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384.1*។ សំណុំរឿង ០០៤ ឧបសម្ព័ន្ធ ខ បញ្ជីឈ្មោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលយក ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384.2។

[1396] សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D384/5 កថាខណ្ឌ ២-៣។

[1397] សំណុំរឿង ០០២ (អបជ ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 & ឯកសារ D427/3/15 កថាខណ្ឌ ១១៨ ។

ការអនុវត្តយុត្តាធិការបុគ្គលលើ យឹម ទិត្យ "នឹងអូសបន្លាយពេលវេលា និងចំណាយថវិកាដោយមិនចាំបាច់"[1398] នោះឡើយ។ ការបន្តស្វែងរកការផ្សះផ្សាដោយមិនផ្តល់យុត្តិធម៌សម្រាប់ជនរងគ្រោះទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំង អ្នកទាំងឡាយនៅក្នុងសំណុំរឿង ០០៤ នឹងផ្ទុយទៅនឹងសិទ្ធិរបស់ពួកគេក្នុងការទទួលបានយុត្តិធម៌ និងសំណង[1399] ហើយអាចរាំងរាល់ការសម្របសម្រួលដល់ដំណើរការផ្សះផ្សាផ្ទាល់ផងដែរ។

497. ជារួម ចៅក្រមអន្តរជាតិយល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ មិនបានបង្ហាញនូវកំហុសឆ្គងដែលអាចបញ្ជាក់បាន ឬមានមូលដ្ឋាន នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលរងការជំទាស់នោះឡើយ។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍នេះទាំងស្រុងតែម្តង។

## បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់

### ១. អំណះអំណាង

498. សហព្រះរាជអាជ្ញាអន្តរជាតិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ និងស្នើសុំឱ្យចៅក្រមអន្តរជាតិ៖ (i) បដិសេធការសន្និដ្ឋាននៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា យឹម ទិត្យ មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដូច្នេះ មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក (ii) បង្គាប់ឱ្យបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1400]។

499. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសអង្គហេតុនិងអង្គច្បាប់មួយចំនួន ដែលនាំឱ្យគាត់សន្និដ្ឋានខុសថា យឹម ទិត្យ មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់

---

[1398] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (D382/4/1) កថាខណ្ឌ ៧២។

[1399] *សេចក្តីប្រកាសស្តីពីសិទ្ធិមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការបំពានអំណាច សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៤០/៣៤ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ លេខ A/RES/40/34 កថាខណ្ឌ ៤។ វិធាន ២១(១)(គ)*។

[1400] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ២-៣, ១៧៦-១៧៧។

អ.វ.ត.ក និងបណ្តាលឲ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព[1401] ដូចដែលបានលើកឡើង នៅក្នុងមូលដ្ឋាន ក-ឆ ខាងក្រោម។ បន្ថែមលើមូលដ្ឋានបណ្តឹងឧទ្ធរណ៍ គាត់ក៏បានធ្វើសេចក្តីសន្និដ្ឋានអំពីផលវិបាកនៃដីកាដំណោះស្រាយផ្ទុយគ្នាផងដែរ[1402]។

### A. មូលដ្ឋាន ក៖ កំហុសអង្គច្បាប់នៃការសន្និដ្ឋានថា ឌុច គឺជាបុគ្គលដែលទទួល "ខុសត្រូវខ្ពស់បំផុត" តែម្នាក់គត់

500. សហព្រះរាជព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយសន្និដ្ឋានថា "ប្រភេទ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត អាចអនុវត្តតែចំពោះ ឌុច ម្នាក់ប៉ុណ្ណោះ"[1403] ដោយអះអាងថាការសន្និដ្ឋាននេះផ្ទុយទៅនឹង (i) ការសម្រេចកន្លងមកក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០១ និងដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងសំណុំរឿង ០០៤/០២[1404] (ii) ភាសាច្បាស់ក្រឡែតនៃកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក[1405] និង (iii) "ការយល់ឃើញយ៉ាងច្បាស់លាស់ទៅលើយុត្តាធិការបុគ្គល នៅពេលបង្កើត អ.វ.ត.ក" របស់រាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ[1406]។

### B. មូលដ្ឋាន ខ៖ កំហុសអង្គច្បាប់នៃការខកខានមិនបានផ្តល់សេចក្តីសម្រេចមានសំអាងហេតុពាក់ព័ន្ធនឹង ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនិងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ យឹម ទិត្យ

501. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតជាតិខកខាន "ក្នុងការចេញសេចក្តីសម្រេចដែលមានសំអាងហេតុលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងលទ្ធភាពនៃការទទួលខុសត្រូវ

[1401] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៩។

[1402] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៦៤-១៧៥។

[1403] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ២០-២១។

[1404] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ២២ *យោងទៅ* សំណុំរឿង ០០៤/២ ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 កថាខណ្ឌ ៤៦១, សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) (D308/3) កថាខណ្ឌ ៣៧។

[1405] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ២៣-២៤។

[1406] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ២៥-៣៦។

01677370



ផ្នែកព្រហ្មទណ្ឌរបស់ យឹម ទិត្យ[1407]។ ទីមួយ យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ ដីកាសម្រេចលើកលែងចោទប្រកាន់ពុំមានសំអាងច្បាប់ ដែលចាំបាច់សម្រាប់សេចក្តីសម្រេចដែលមានសំអាងហេតុ[1408]។ទោះបីជាការសន្និដ្ឋានផ្នែកអង្គហេតុមួយចំនួននៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់បានទទួលស្គាល់យ៉ាងច្បាស់អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនិងការទទួលខុសត្រូវរបស់ យឹម ទិត្យ ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតជាតិខកខានមិនបានកំណត់តាមផ្លូវច្បាប់អំពីការប្រព្រឹត្តិដែលត្រូវបានចាត់ទុកជាបទឧក្រិដ្ឋ និងធ្វើការកំណត់ប្រភេទនៃការទទួល ខុសត្រូវរបស់ យឹម ទិត្យ ចំពោះការប្រព្រឹត្តនោះដែរ[1409]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថាប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់បានធ្វើការសន្និដ្ឋានតាមផ្លូវច្បាប់តាមការចាំបាច់ ម្ល៉េះសមមាន“សេចក្តីពន្យល់ជាមួយនឹងសំអាងហេតុទាក់ទងនឹងមូលហេតុដែល យឹម ទិត្យ មិនស្ថិតនៅក្នុងចំណោម អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត”[1410]។ ជាងនេះទៀត សហព្រះ រាជអាជ្ញាអន្តរជាតិលើកឡើងថាដីកាដែលរងការជំទាស់បានជ្រើសរើសវិធីសាស្ត្រមួយដែលវាយតម្លៃ លើផ្នែកមួយនៃភស្តុតាង និងខកខានក្នុងការផ្តល់សេចក្តីសន្និដ្ឋានដែល មានសំអាងច្បាប់ចាំបាច់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ យឹម ទិត្យ លើឧក្រិដ្ឋកម្មជាក់លាក់នានា[1411]។

502. ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតជាតិខកខានក្នុងការវាយតម្លៃភស្តុតាងឲ្យបានត្រឹមត្រូវ និងធ្វើការសន្និដ្ឋានពាក់ព័ន្ធនឹងតួនាទីនិងអំណាចតាមព្រឹត្តិហេតុដែលជា “ទិដ្ឋភាពដ៏សំខាន់បំផុតនៃការទទួលខុសត្រូវរបស់ [យឹម] ទិត្យ”[1412]។ ទីបី សហព្រះរាជអាជ្ញាអន្តរជាតិលើកទឡ្ហីករណ៍ថា ដីកាសម្រេចលើកលែងចោទប្រកាន់ដកចេញដោយមិនត្រឹមត្រូវនូវទីតាំងទួលម្ទេស ទួលអណ្តែត អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងឃុំកំពង់ព្រៀងពីការពិចារណា

[1407] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៣៧-៦៩។
[1408] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៣៨-៤៣។
[1409] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៣៩-៤២។
[1410] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៤៣។
[1411] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៤៣។
[1412] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៤៤-៥៤។

ដោយគ្មានសំអាងហេតុគ្រប់គ្រាន់[1413]។ ជាងនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានក្នុងការពិចារណាលើ "លទ្ធភាពនៃការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍លើខ្មែរក្រោម"របស់ យឹម ទិត្យ នៅក្នុងការវាយតម្លៃយុត្តាធិការបុគ្គល ទោះបីជាធ្វើការសន្និដ្ឋានអង្គហេតុដ៏ច្រើនលើការកំណត់មុខសញ្ញានិង សម្លាប់ខ្មែរក្រោម និង ចេតនាជាក់លាក់របស់ យឹម ទិត្យ ក្នុងការកម្ទេចប្រជាជនខ្មែរក្រោមក៏ដោយ[1414]។ ចំណុចចុងក្រោយ នៅក្នុងការវាយតម្លៃរបស់ខ្លួនទៅលើយុត្តាធិការបុគ្គល សហចៅក្រមស៊ើបអង្កេតជាតិខកខានក្នុងការពិចារណាទៅលើការឈឺចាប់របស់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម ជាអាទិ៍ ការដាក់ក្នុងមន្ទីរឃុំឃាំង ទារុណកម្ម ការធ្វើឱ្យទៅជាទាសករ និងអាពាហ៍ពិពាហ៍ដោយបង្ខំ និងបានពិចារណាតែទៅលើជនរងគ្រោះដែលត្រូវបានសម្លាប់ប៉ុណ្ណោះ[1415]។

C. មូលដ្ឋាន គ៖ កំហុសអង្គច្បាប់នៃការពិចារណាលើបញ្ហារបស់ថ្នាក់លើ និងការបង្ខិតបង្ខំ

503. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសអង្គច្បាប់ដោយផ្អែកយ៉ាងច្រើនលើបញ្ហារបស់ថ្នាក់លើ និងការបង្ខិតបង្ខំក្នុងការកំណត់យុត្តាធិការបុគ្គលលើ យឹម ទិត្យ[1416]។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់លើចំណុច (i) ការសង្កត់ធ្ងន់លើ "បញ្ហារបស់ថ្នាក់លើក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល" និងការ សន្និដ្ឋានថា "យឹម ទិត្យ ត្រូវទទួលបញ្ជាថ្នាក់លើ"[1417] (ii) ផ្អែកលើការបង្ខិតបង្ខំដែលពុំបានបង្ហាញនៅក្នុងករណីនេះ ពីព្រោះ យឹម ទិត្យ ចូលរួម "ដោយសកម្ម និងស្ម័គ្រចិត្តនៅក្នុងផែនការឧក្រិដ្ឋកម្មរួមដោយគ្មាន "ការភ័យខ្លាចការដាក់ទោសទណ្ឌឡើយ"[1418] និង (iii) ការប្រព្រឹត្តខុសគ្នាដោយអំពើចិត្តលើបញ្ហារបស់ថ្នាក់លើនិងការបង្ខិតបង្ខំក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង

[1413] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៥៥-៥៨ *យោងទៅ* ក្នុងចំណោមនោះ វិធានផ្ទៃក្នុង វិធាន ៦៦ស្ទួន, ៧៦, ៦៧។

[1414] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៥៩-៦៧។

[1415] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៦៨។

[1416] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៧០-៩៥។

[1417] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៧១-៧៧។

[1418] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៧៨-៨៨។

០០១ និង សំណុំរឿង០០៤ ទោះបីជាតាមការពិត យឹម ទិត្យ "មានឆន្ទានុសិទ្ធិច្រើនខ្លាំង" ក្នុងការអនុវត្តបញ្ជាជាង ឌុច យ៉ាងណាក្តី[1419]។

D. មូលដ្ឋាន ឃ៖ កំហុសអង្គច្បាប់ក្នុងការវាយតម្លៃការចូលរួមនិងភាពកៀកកិតនឹងឧក្រិដ្ឋកម្មរបស់ យឹម ទិត្យ

504. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសក្នុងការវាយតម្លៃទៅលើការចូលរួម និងភាពកៀកកិតរបស់ យឹម ទិត្យ ទៅនឹងឧក្រិដ្ឋកម្មក្នុងការកំណត់កម្រិតនៃការទទួលខុសត្រូវរបស់គាត់[1420]។ យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ កំហុសទាំងនោះរួមមាន (i) ការផ្តោតតែទៅលើ "ការចូលរួមដោយផ្ទាល់" ដែលត្រូវបានកំណត់ដោយខុសឆ្គងថាជាការប្រព្រឹត្តឧក្រិដ្ឋកម្ម និង "មិនបញ្ចូលដោយចេតនា" នូវការពិចារណាទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត[1421] និង (ii) ការខកខានក្នុងការ "ពិចារណាការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម" ក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល[1422]។ មិនតែប៉ុណ្ណោះសហព្រះរាជអាជ្ញាអន្តរជាតិតវ៉ាថាការសន្និដ្ឋានជាច្រើននៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ បង្ហាញភវនីយភាពនៃការចូលរួមរបស់ យឹម ទិត្យ និងការចូលរួមដ៏សំខាន់ទៅក្នុងគោលបំណងឧក្រិដ្ឋកម្មរួម ព្រមទាំងចេតនា និងការដឹងរបស់គាត់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំ ការធ្វើការដោយបង្ខំ ការកំណត់គោលដៅក្រុមនិងការសម្លាប់ខ្មាំង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការហាមឃាត់ការប្រតិបត្តិសាសនា។[1423]

E. មូលដ្ឋាន ង៖ ការធ្វើការសន្និដ្ឋានផ្នែកអង្គហេតុដែលនាំឲ្យមានការខុសឆ្គងរបស់តុលាការ

505. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ការខុសឆ្គងរបស់តុលាការត្រូវបានបង្កើតឡើងដោយមូលហេតុនៃការសន្និដ្ឋានផ្នែកអង្គហេតុដែលមានកំហុសដែលធ្វើឡើងនៅក្នុងដីកាសម្រេចលើក

---

[1419] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៨៩-៩៥។

[1420] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៩០-១២៥។

[1421] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ៩៧-១០៥។

[1422] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១០៥-១២៥។

[1423] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១១៣-១២២។

លែងចោទប្រកាន់[1424]។ ក្នុងចំណោមកំហុសផ្នែកអង្គហេតុដែលបានលើកឡើងទាំងនោះ សហព្រះរាជអាជ្ញាអន្តរជាតិតវ៉ាការសន្និដ្ឋាននៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ថា (i) មានមនុស្សប្រហែល១៣រូប ក្នុងនោះមានលេខាភូមិភាគដូចជា តាម៉ុក ជាដើម បានធ្វើការសម្រេចទាំងអស់អំពីអ្នកដែលត្រូវសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងថា យឹម ទិត្យ មិនស្ថិតក្នុងចំណោមបុគ្គលជាង ១៣ រូបនោះ ដែលជាការផាត់គាត់ចេញពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[1425] (ii) មានតែកម្មាភិបាលឃោធាតែប៉ុណ្ណោះដែលមានសិទ្ធិសម្លាប់មនុស្ស ដែលជាការអនុញ្ញាតឱ្យការទទួលខុសត្រូវរបស់ យឹម ទិត្យ ក្នុងនាមជាកម្មាភិបាលស៊ីវិល ត្រូវបានវាយតម្លៃទាប[1426] (iii) យឹម ទិត្យ មិនអាចបានកាន់មុខតំណែងចំនួនពីរនៅក្នុងភូមិភាគពាយ័ព្យផង និង ភូមិភាគនិរតីផងនៅពេលជាមួយគ្នា[1427] (iv) តួនាទីរបស់ យឹម ទិត្យ នៅថ្នាក់ភូមិភាគពាយ័ព្យគឺជាសមាជិក មិនមែនជាអនុលេខាភូមិភាគពាយ័ព្យឡើយ[1428] (v) យឹម ទិត្យ ពុំមានអ្នកនៅក្រោមបង្គាប់ ដែលជាការផ្ទុយនឹងភស្តុតាងពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យនិងការសន្និដ្ឋានរបស់ខ្លួននៅក្នុងដីកាដែលរងការជំទាស់[1429] និង (vi) "ការសម្លាប់មានការថយចុះក្រោយពីការប្រកាសរបស់ ខៀវ សំផន នៅពាក់កណ្តាលឆ្នាំ១៩៧៨[1430]។

F. មូលដ្ឋាន ចៈ កំហុសអង្គច្បាប់ដោយផ្តល់ទម្ងន់លើអង្គហេតុដែលមានភាពពាក់ព័ន្ធតិចតួច

506. សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតជាតិ "មានកំហុសអង្គច្បាប់ដោយផ្តល់ទម្ងន់លើអង្គហេតុដែលមានភាពពាក់ព័ន្ធតិចតួច ក្នុងការវិភាគលើយុត្តាធិការបុគ្គល[1431]។ តាមទស្សនៈរបស់ព្រះរាជអាជ្ញាអន្តរជាតិ កំហុសទាំងនោះរួមមានៈ (i) ការផ្តល់ទម្ងន់លើ "ការសន្និដ្ឋានថា យឹម ទិត្យ ពុំមែនជាសមាជិកនៃសភាតំណាងប្រជាជន" ទោះបីជាខ្វះអំណាច

[1424] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១២៥-១៥១។
[1425] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១២៦-១៣៥។
[1426] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៣៦-១៣៧។
[1427] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៣៨។
[1428] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៣៩។
[1429] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៤០-១៤៥។
[1430] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៤៦-១៥០។
[1431] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៥២-១៦៣។

នៃស្ថាប័ននេះដូចដែលបានទទួលស្គាល់នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ក៏ដោយ[1432] (ii) ទម្ងន់ហួសហេតុទៅលើការសន្និដ្ឋានថា យឹម ទិត្យ មានតួនាទីនៅក្នុងកងទ័ព[1433] (iii) ការផ្តោតលើ "ការសន្និដ្ឋានរបស់ខ្លួនថា យឹម ទិត្យ មិនពាក់ព័ន្ធនៅក្នុងការរៀបចំផ្ទេរកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ"[1434] (iv) ផ្តល់ទម្ងន់លើការសន្និដ្ឋានថា "ការបោសសម្អាតបានចាប់ផ្តើមអនុវត្តផ្នែកខ្លះនិងទីតាំងខ្លះមុនការមកដល់របស់ យឹម ទិត្យ នៅភូមិភាគពាយ័ព្យ"[1435] (v) ផ្អែកការសន្និដ្ឋានរបស់ខ្លួនលើយុត្តាធិការបុគ្គលលើអង្គហេតុដែលថា កម្មាភិបាលចំនួនប្រមាណ ១០០ រូប "បម្រើការនៅកម្រិតតំបន់និងភូមិភាគក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" ដែលមានសេចក្តីថា យឹម ទិត្យ ពុំមានតួនាទីសំខាន់ឡើយ[1436] និង(vi) ការពឹងផ្អែកខ្លាំងពេកទៅលើសាក្សីដែល "មិនដែលឮអំពី យឹម ទិត្យ"[1437]។

## G. អំណះអំណាងពាក់ព័ន្ធនឹងដីកាដំណោះស្រាយផ្ទុយគ្នា[1438]

507. ពាក់ព័ន្ធនឹងអត្ថិភាពនៃដីកាដំណោះស្រាយផ្ទុយគ្នា សហព្រះរាជអាជ្ញាអន្តរជាតិពិចារណាថា ដីកាសម្រេចលើកលែងចោទប្រកាន់គួរតែត្រូវបានបដិសេធ និងបញ្ជូនសំណុំរឿងទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំង យឹម ទិត្យ[1439]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ក្នុងករណីដែលចៅក្រមអន្តរជាតិពុំអាចរកសំឡេងភាគច្រើនលើសលុបតាមការតម្រូវសម្រាប់ការចេញសេចក្តីសម្រេចមួយ ឬក្នុងករណីដែលអង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍ទាំងអស់ ដោយសន្និដ្ឋានថា ដីកាដំណោះស្រាយទាំងពីរ

---

1432 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៥៣-១៥៤។

1433 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៥៦។

1434 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៥៧។

1435 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៥៨។

1436 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៥៩។

1437 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៦០-១៦៣។

1438 អំណះអំណាងទាំងនេះមិនមែនជាមូលដ្ឋានបណ្តឹងឧទ្ធរណ៍ជាផ្លូវការទេ ប៉ុន្តែ លើកឡើងពី "លទ្ធភាពសេណារីយ៉ូ" ដែលអាចកើតមានឡើង ក្រោយពេលចៅក្រមអន្តរជាតិសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងអស់ក្នុងរឿងក្តីនេះ។ សូមមើល បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៦៤។ ចៅក្រមអន្តរជាតិពិភាក្សាលម្អិតអំពីបញ្ហានៃដីកាដំណោះស្រាយចំនួនពីរ នៅក្នុងផ្នែកដាច់ដោយឡែក។ សូមមើលខាងលើ ដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ២៩-៤២។

1439 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៦៤។

ដែលរងការជំទាស់ត្រូវបានចេញ នៅក្នុងអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត សំណុំរឿងនេះត្រូវបញ្ជូនទៅជំនុំជម្រះ[1440]។ ដោយផ្អែកលើក្របខ័ណ្ឌគតិយុត្តិ និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក[1441] សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា វិធាន ១(២) នៃវិធានផ្ទៃក្នុង រួមជាមួយ វិធាន ៧៧(១៣)(ខ) ដែលជាច្បាប់ពិសេសមានអានុភាពលើលក្ខខណ្ឌទូទៅដែលមានចែងក្នុងវិធាន ៧៧(១៣)(ក) បញ្ជាក់ច្បាស់ថា ប្រសិនបើដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបាន បដិសេធនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ទេនោះ រឿងក្តីនេះនឹងត្រូវបញ្ជូនទៅជំនុំជម្រះ[1442]។

508. ក្នុងចម្លើយតប សហមេធាវីមិនបានលើកឡើងបញ្ហាណាមួយដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងមូលដ្ឋាន ក-ច[1443] ឡើយ។ ផ្ទុយទៅវិញ សហមេធាវីធ្វើសេចក្តីសន្និដ្ឋានអំពីការចេញដីកាដំណោះស្រាយចំនួន២[1444]។

509. ក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិរក្សាជំហរដដែលថា សំណុំរឿង ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1445]។

---

[1440] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៦៤។

[1441] សូមមើល ឧទាហរណ៍ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៦៥-១៧១ ដកស្រង់ វិធានផ្ទៃក្នុង វិធាន ៧៧(១៣), ១(២), ៧៩(១), សាលដីកាសំណុំរឿង ០០១ (F28) កថាខណ្ឌ ៦៥, សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (អៀង សារី) (D427/1/30) កថាខណ្ឌ ២៧២, ២៧៥។

[1442] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/19) កថាខណ្ឌ ១៦៦។

[1443] ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/26)។

[1444] ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D381/26) កថាខណ្ឌ ៧-៣៤។ តាមពិត សហមេធាវីអះអាងថា បណ្តឹងឧទ្ធរណ៍មិនអាចយកជាបានការ ដោយសារ (i) អ.ប.ជ បានសម្រេចជាឯកច្ឆន្ទថា សហចៅក្រមស៊ើបអង្កេតគ្មានមូលដ្ឋានច្បាប់ក្នុងការចេញដីកាដំណោះស្រាយពីរនោះទេ (ii) ដីកាដំណោះស្រាយទាំងពីរនៅក្នុងសំណុំរឿង ០០៤ ត្រូវចាត់ទុកជាមោឃៈ ហើយជាលទ្ធផល (iii) មូលដ្ឋានបណ្តឹងឧទ្ធរណ៍ទាំងអស់អំពីអង្គសេចក្តីនៃដីកាដំណោះស្រាយពុំពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន។

[1445] ការឆ្លើយតបរបស់ហព្រះរាជអាជ្ញាអន្តរជាតិ (D381/28) កថាខណ្ឌ ១, ៩។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា (i) សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ មិនបង្ហាញថា ដីកាដំណោះស្រាយ *ទាំងពីរ* គ្មានសុពលភាពទេ (ii) វិធាន ៦៧(២) នៃវិធានផ្ទៃក្នុង មិនអនុវត្តចំពោះវិបាកនៃការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាទេ និង (iii) សហមេធាវីខកខានមិនបានបង្ហាញថាតើ*ការចេញ*ដីកាដំណោះស្រាយពីរខ្វែងគ្នា រំលោភលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌យ៉ាងដូចម្តេចនោះទេ។ សូមមើល ការឆ្លើយតបរបស់ហព្រះរាជអាជ្ញាអន្តរជាតិ (D381/28) កថាខណ្ឌ ១-៥។

## ២. ការពិភាក្សា

510. ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាទាំងអស់ដែលចេញដោយសហចៅក្រមស៊ើបអង្កេត[1446]។ ចៅក្រមអន្តរជាតិរម្លឹកថា ទោះបីជាមានកិច្ចមិនស្របច្បាប់ពីសំណាក់សហចៅក្រមស៊ើបអង្កេត ដើម្បីគេចវេសនីតិវិធីដោះស្រាយការខ្វែងគំនិតគ្នា និងចេញដីកាដំណោះស្រាយចំនួនពីរដំណាលគ្នាក៏ដោយ ក៏ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ដោយហេតុថាដីកានេះមានអនុលោមភាពទៅនឹងក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក[1447]។ ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិបញ្ជាក់សាជាថ្មីថា ផ្អែកលើសំអាងហេតុមុនៗ ការចេញដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានចាត់ទុកថា ជាការប៉ុនប៉ងធ្វើឱ្យបរាជ័យដល់គោលជំហរស្វ័យប្រវត្តិដែលមានចែងនៅក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក ដូច្នេះវាជាការហួសដែនកំណត់[1448]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះប្រកាសថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលែងជាការចាំបាច់ទៀតហើយ ដោយសារតែបណ្តឹងនេះពាក់ព័ន្ធនឹងដីកាសម្រេចលើកលែងចោទប្រកាន់ដែលទុកជាមោឃៈ[1449]។

---

[1446] វិធាន ៧៤(២) នៃវិធានផ្ទៃក្នុង។

[1447] សូមមើលខាងលើ កថាខណ្ឌ ១៧៦; កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤) ("សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នាដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថាត្រូវបន្តការស៊ើបអង្កេតណាមួយ *ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត* លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧") (គូសបញ្ជាក់បន្ថែម)។ សូមមើល ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣*ថ្មី* កថាខណ្ឌ ៣។

[1448] សូមមើលខាងលើ កថាខណ្ឌ ១៧៥-១៧៦។ សូមមើលផងដែរ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ កថាខណ្ឌ ២៦២ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 & D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣២៤-៣២៦។

[1449] សូមមើលខាងលើ កថាខណ្ឌ ១៧៦ សូមមើលផងដែរ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 & D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៦៨២ យោងទៅក្នុងចំណោមនោះ តុលាការ ICC ស្ថានភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាលក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Jean-Pierre Bemba Gombo* ចៅក្រមអន្តរជាតិតុលាការកំពូល សំណុំរឿងលេខ ICC-01/05-01/08 A2 A3 សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា និងលោក Jean-Pierre Bemba Gombo ប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមអន្តរជាតិសាលាដំបូង III ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ដែលមានចំណងជើងថា "ដីកាសម្រេចលើការផ្តន្ទាទោស អនុលោមតាមមាត្រា ៧៦ នៃលក្ខន្តិកៈ" ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៨។ សំណុំរឿង ០០២ (អបជ៧០) សាលដីកាលើបណ្តឹងឧទ្ធរណ៍

# បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

## ១. អំណះអំណាង

511. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ដោយបានអះអាងថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសអង្គហេតុ និងអង្គច្បាប់ក្នុងការសន្និដ្ឋានថា យឹម ទិត្យ មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[1450]។

512. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសក្នុងការសន្និដ្ឋានថា យឹម ទិត្យ មិនស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម[1451]។
ដោយរម្លឹកអំពីលក្ខខណ្ឌវិនិច្ឆ័យពីរប្រភេទដែលយុត្តិសាស្ត្ររបស់ អ.វ.ត.ក បានកំណត់ក្នុងការវិនិច្ឆ័យទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ[1452] សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ការសម្រេចនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ផ្ទាល់នោះ បង្ហាញថា ឧក្រិដ្ឋកម្មរបស់ យឹម ទិត្យ គឺធ្ងន់ធ្ងរគ្រប់គ្រាន់ហើយ[1453]។ ជាពិសេស ទីតាំងឧក្រិដ្ឋកម្មទាំង ៣៩ ដែលស្ថិតក្រោមកិច្ចស៊ើបសួរ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ ហើយទីតាំងឧក្រិដ្ឋកម្មចំនួន ២៤ ក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មទាំងនេះ មានជនរងគ្រោះចំនួនប្រហែល ៥៣.០៥០ នាក់ ត្រូវបាន

---

របស់លោក អៀង សារី ប្រឆាំងទៅនឹងការបដិសេធតាមការសន្មតរបស់ ស.ច.ស លើសំណើទាំងពីររបស់គាត់ឱ្យចៅក្រមអន្តរជាតិទទួលយកសំណើសុំធ្វើមោឃភាព ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D381/1/2 កថាខណ្ឌ ២។

[1450] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ៥។

[1451] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ៧-១២។

[1452] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ៨ ដែលយោងទៅសាលដីកា សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៨០។ សាលក្រម សំណុំរឿង ០០១ (ឯកសារ E188) កថាខណ្ឌ ២២។ដីកាដំណោះស្រាយ សំណុំរឿង ០០៤/១ (សំអាងហេតុ) (ឯកសារ D308/3) កថាខណ្ឌ ៣៧-៤១។

[1453] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ៩។

សម្លាប់ ឬបានស្លាប់[1454]។ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អះអាងបន្ថែមទៀតថា កម្រិតនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ខ្ពស់គ្រប់គ្រាន់ ពីព្រោះតួនាទីតាមឋានានុក្រមរបស់គាត់ខ្ពស់ជាង ឌុច[1455]។ ដោយយោងទៅការសម្រេចនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គួសបញ្ជាក់អំពីការចូលរួមដោយផ្ទាល់របស់ យឹម ទិត្យ នៅក្នុងអំពើប្រល័យពូជសាសន៍ខ្មែរក្រោម ការដាក់ក្នុងមន្ទីរឃុំឃាំងជាទ្រង់ទ្រាយធំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[1456] និងសិទ្ធិអំណាចរបស់គាត់ជាមេបញ្ជាការ តាមព្រឹត្តិន័យទីពីររបស់តាម៉ុក នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ[1457]។

513. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំឱ្យចៅក្រមអន្តរជាតិច្រានចោលការសន្និដ្ឋានដែលថា យឹម ទិត្យ មិនស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[1458]។ ជាជម្រើសម្យ៉ាងទៀត ប្រសិនបើចៅក្រមអន្តរជាតិមិនអាចរកបានសំឡេងភាគច្រើនលើសលុបបានទេនោះ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើឡើងថា សំណុំរឿងនេះគួរបន្តទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង យឹម ទិត្យ[1459]។

## ២. ការពិភាក្សា

---

[1454] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ៩ ដែលយោងទៅ ដីកាសម្រេចលើកលែងចោទប្រកាន់ (ឯកសារ D381) កថាខណ្ឌ ៦៧៣, ៦៧៥, ៥៨៩-៥៩០។

[1455] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ដែលយោងទៅ សាលក្រម សំណុំរឿង ០០១(ឯកសារ E188) កថាខណ្ឌ ២០៨។

[1456] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ១០ យោងទៅ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៩៩១-៩៩៨។

[1457] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ១០ យោងទៅ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឯកសារ D382) កថាខណ្ឌ ៩៩៤-៩៩៥។

[1458] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ១១។

[1459] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ១២-៣៨។ ការអះអាងនេះលើកឡើងនូវ "លទ្ធភាពនៃសេណារីយ៉ូ" ដែលអាចកើតមានឡើង បន្ទាប់ពីចៅក្រមអន្តរជាតិសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាដំណោះស្រាយផ្ទុយគ្នា នៅក្នុងរឿងក្ដីនេះ។ ចៅក្រមអន្តរជាតិបានពិភាក្សាលម្អិតទៅលើបញ្ហាដីកាដំណោះស្រាយចំនួនពីរ នៅក្នុងផ្នែកដាច់ដោយឡែកមួយ។ សូមមើល ខាងលើ ដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ២៩-៤២។

514. អនុលោមតាមវិធាន ៧៤(៤)(ច) នៃវិធានផ្ទៃក្នុង សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អាច ជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ក្នុងករណីដែលសហព្រះរាជអាជ្ញាប្ដឹងឧទ្ធរណ៍[1460]។ ចៅក្រមអន្តរជាតិកត់សម្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់នៅក្នុងរឿងក្ដីនេះ[1461] ដែលអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងឧទ្ធរណ៍នៅចំពោះមុខចៅក្រមអន្តរជាតិ ប្រឆាំងនឹងដីកាដែលរងការជំទាស់នេះ។

515. ចៅក្រមអន្តរជាតិអះអាងជាថ្មីថា ខណៈដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានសុពលភាព ដោយសារតែដីកានេះនៅតែមានអនុលោមភាពជាមួយនឹងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក នោះ ដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិគឺជាការអនុវត្តហួសសិទ្ធិអំណាចគតិយុត្តិ និងត្រូវទុកជាមោឃៈ[1462]។ យោងតាមសំអាងហេតុខាងលើ ចៅក្រមអន្តរជាតិសូមប្រកាសថា បណ្ដឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់លែងជាការចាំបាច់ទៀតហើយ[1463]។

---

[1460] វិធាន ៧៤(៤)(ច) នៃវិធានផ្ទៃក្នុង។ សូមមើល ផងដែរ វិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង។

[1461] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D381/19)។

[1462] សូមមើល *ខាងលើ* កថាខណ្ឌ 175-176។ សូមមើលផងដែរ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ 262។ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & ឯកសារ D360/33) យោបល់របស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៣២៤-៣២៦។

[1463] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ៧-១២។ សូមមើលផងដែ សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & ឯកសារ D360/33) មតិយោបល់របស់ចៅក្រម BAIK និង BEAUVALLET កថាខណ្ឌ ៦៨២។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ 252។

# សេចក្តីសន្និដ្ឋាន

516. ចំណុចខាងក្រោម នឹងពិភាក្សាអំពីការយល់ឃើញរបស់ចៅក្រមអន្តរជាតិ លើបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន និងអានុភាពនៃសេចក្តីពិចារណានេះ។ បន្ថែមលើនេះ ដោយប្រឈមជាមួយនឹងការជំទាស់តវ៉ាផ្នែកនីតិវិធីយ៉ាងធ្ងន់ធ្ងរ ដែលបានរារាំងដល់យន្តការនៃច្បាប់នៅ អ.វ.ត.ក នោះ ចៅក្រមអន្តរជាតិ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ក្នុងនាមជាចៅក្រមដែលទទួលបានការតែងតាំងត្រឹមត្រូវដោយអង្គការសហប្រជាជាតិ និងព្រះមហាក្សត្រនរោត្តម សីហមុនី នឹងធ្វើការកត់សម្គាល់ចុងក្រោយ ដែលរួមមានការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិទាំងមូល ពាក់ព័ន្ធនឹងអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍។

## ១. ការយល់ឃើញនានាលើបណ្តឹងឧទ្ធរណ៍ និងអានុភាពនៃសេចក្តីពិចារណានេះ

517. យោងទៅលើសំអាងហេតុខាងលើ ចៅក្រមអន្តរជាតិសូមច្រានចោលភ្លាមៗនូវបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ដោយសារតែសហព្រះរាជអាជ្ញាជាតិ មិនបានបង្ហាញអំពីកំហុសដែលអាចបញ្ជាក់បាន ឬមានសំអាងហេតុគាំទ្រ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ ចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបណ្តឹងឧទ្ធរណ៍នីមួយៗ លើកឡើងអំពីដីកាសម្រេចលើកលែងចោទប្រកាន់នោះ ចៅក្រមអន្តរជាតិសូមប្រកាសថា បណ្តឹងឧទ្ធរណ៍ទាំងនោះទុកជាអសារឥតការ ដោយសារតែដីកាសម្រេចលើកលែងចោទប្រកាន់ គឺហួសដែនសមត្ថកិច្ច ដូច្នេះហើយគឺទុកជាមោឃៈ និងមិនមានអានុភាពគតិយុត្តិឡើយ។

518. ចំពោះបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី យឹម ទិត្យ (ដីកាដំណោះស្រាយពីរ) ចៅក្រមអន្តរជាតិសូមច្រានចោលបណ្តឹងឧទ្ធរណ៍នេះ[1464]។ ទោះបីជាការឯកភាពគ្នារបស់សហចៅក្រមស៊ើបអង្កេត ក្នុងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា រំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិជាសារវន្តរបស់អង្គជំនុំជម្រះនេះក្តី[1465] តែចៅក្រមអន្តរជាតិសន្និដ្ឋានថា ដីកា

[1464] សូមមើលខាងលើ កថាខណ្ឌ ១៧៦-១៧៧។

[1465] សូមមើលខាងលើ កថាខណ្ឌ ៩៥-១១៥។

បញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព រីឯដីកាសម្រេចលើកលែងចោទប្រកាន់ពុំមានសុពលភាពឡើយ[1466]។

519. ចំពោះបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដោយផ្អែកទៅតាមសំអាងហេតុខាងលើ ចៅក្រមអន្តរជាតិសូមច្រានចោលមូលដ្ឋានទី ២.២, ៣, ៤ និង ៥។

520. នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាថា ការឃុំខ្លួន យឹម ទិត្យ បណ្តោះអាសន្នរង់ចាំការជំនុំជម្រះមិនមែនជាវិធានការចាំបាច់ ដើម្បីបញ្ចៀសនូវកត្តាហានិភ័យនានា អនុលោមតាមវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង[1467] ឡើយ ហើយថា "ភាពមិនច្បាស់លាស់ផ្នែកនីតិវិធី ដោយសារមានដីកាដំណោះស្រាយផ្ទុយគ្នា" គឺជាសំអាងហេតុមួយទៀតដែលជំទាស់ទៅនឹងការបង្គាប់ឱ្យឃុំខ្លួន[1468]។ អនុលោមតាមវិធាន ៤៤ នៃវិធានផ្ទៃក្នុង និងអង្គហេតុនៅក្នុងសំណុំរឿង ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយសារការខកខានមិនបានពិចារណាឱ្យបានត្រឹមត្រូវក្នុងការចេញដីកាបង្គាប់ឱ្យឃុំខ្លួន[1469]។

521. ដោយងាកទៅមើលផលវិបាកគតិយុត្តិនៃសេចក្តីពិចារណាបច្ចុប្បន្ន ចៅក្រមអន្តរជាតិបានពិចារណាថា ដីកាសម្រេចលើកលែងចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ ដូចដែលបានពិភាក្សាខាងលើ[1470] គឺមោឃៈ ដោយសារតែគេចវេសពីក្របខណ្ឌគតិយុត្តិសំខាន់ៗ និងចាំបាច់នានារបស់ អ.វ.ត.ក។ ហេតុដូច្នេះ ដីកាសម្រេចនេះមិនអាចត្រូវចាត់ទុកថាមានអានុភាពគតិយុត្តិណាមួយឡើយ។

---

[1466] សូមមើលខាងលើ កថាខណ្ឌ ១៧៦។

[1467] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០៤១។

[1468] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (D382) កថាខណ្ឌ ១០៤២។

[1469] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៣៥៥-៣៥៦, ៣៥៨។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៦៨០-៦៨៣។

[1470] សូមមើលខាងលើ កថាខណ្ឌ ១៦១-១៧៧។

522. ហេតុដូច្នេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ដោយសារមិនអាចស្វែងរកសម្លេងគាំទ្រពីចៅក្រម ៤ (បួន) រូបយ៉ាងតិចតាមការតម្រូវ ក្នុងការបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្រគ្រប់គ្រាន់របស់អង្គជំនុំជម្រះគឺថា ចៅក្រមអន្តរជាតិសាលាដំបូងត្រូវទទួលយកសំណុំរឿងមកពិនិត្យ ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត"[1471]។

523. ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលយកសំណុំរឿងមកពិនិត្យ ផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ចៅក្រមអន្តរជាតិបញ្ជាក់បំភ្លឺថា តាមរយៈខ្លឹមសារនៃវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង សេចក្តីពិចារណាបច្ចុប្បន្ន ដែលមានភ្ជាប់ជាមួយនឹងមតិយោបល់នេះ ត្រូវជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា សហមេធាវីការពារក្តី យឹម ទិត្យ និងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេត ត្រូវបន្តកិច្ចដំណើរការនីតិវិធីជាបន្ទាន់ ស្របតាមសេចក្តីពិចារណានេះ[1472]។

## ២. សេចក្តីពិចារណាចុងក្រោយ

524. នៅផ្នែកចុងក្រោយនៃមតិរបស់ពួកគាត់ ចៅក្រមអន្តរជាតិនឹងធ្វើសេចក្តីសន្និដ្ឋានអំពីផលវិបាកនៃការណ៍ដែល អ.វ.ត.ក និងអាជ្ញាធរកម្ពុជា មិនអាចជំនុំជម្រះប្រកបដោយប្រសិទ្ធិភាព នូវសំណុំរឿងចុងក្រោយរបស់ អ.វ.ត.ក ដែលឆ្លុះបញ្ចាំងនូវឧក្រិដ្ឋកម្មយ៉ាងធ្ងន់ធ្ងរមួយចំនួន នៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម នៃប្រវត្តិសាស្ត្រទំនើប។

### *ក. កាតព្វកិច្ចក្នុងការជំនុំជម្រះ តាមអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍*

525. ដោយគោរពតាមយុត្តិសាស្ត្រ ដែលបានកំណត់យ៉ាងច្បាស់ របស់អង្គបុរេជំនុំជម្រះ[1473] ចៅក្រមអន្តរជាតិសូមបញ្ជាក់ឡើងវិញថា ច្បាប់ជាធរមានរបស់ អ.វ.ត.ក មិនបានរារាំងយុត្តាធិការជាតិ

[1471] សូមមើល វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ("ចៅក្រមអន្តរជាតិសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬតាមសេចក្តីសម្រេចរបស់ចៅក្រមអន្តរជាតិ")។

[1472] សូមមើល វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង។

[1473] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ៥៩។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ

*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*

01677383



ឡើយ និងថា តុលាការកម្ពុជា មានយុត្តាធិការពេញលេញជាមូលដ្ឋានទៅលើបញ្ហាយុត្តិធម៌ព្រហ្មទណ្ឌ។ អង្គបុរេជំនុំជម្រះបានពិចារណារួចហើយថា "នៅមុនពេលបង្កើត អ.វ.ត.ក រាជរដ្ឋាភិបាលកម្ពុជា មិនត្រឹមតែមានជម្រើសប៉ុណ្ណោះទេ ប៉ុន្តែ *ថែមទាំងមានកាតព្វកិច្ចផងដែរ តាមច្បាប់អន្តរជាតិ* ក្នុងការចោទប្រកាន់មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬអ្នកទាំងឡាយដែលត្រូវបានចោទប្រកាន់ថាទទួលខុសត្រូវខ្ពស់បំផុត ចំពោះបទល្មើសអន្តរជាតិ ដែលនេះគឺជាការអនុវត្តយុត្តាធិការមូលដ្ឋានរបស់ខ្លួន"[1474]។

526. ចៅក្រមអន្តរជាតិបានកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាដែលជារដ្ឋភាគី នៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍[1475] មានកាតព្វកិច្ចតាមមាត្រា VI នៃអនុសញ្ញានោះ ក្នុងការធានាថា បុគ្គលដែលត្រូវបានចោទប្រកាន់ ពីបទអំពើប្រល័យពូជសាសន៍ ត្រូវបានជំនុំជម្រះដោយតុលាការមានសមត្ថកិច្ចជាតិ ឬតុលាការព្រហ្មទណ្ឌអន្តរជាតិ[1476]។

527. ដោយស្របជាមួយមាត្រា VI នៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍[1477] និងយុត្តិសាស្ត្រដែលមិនប្រែប្រួលរបស់អង្គបុរេជំនុំជម្រះ[1478]នោះ ចៅក្រមអន្តរជាតិសម្រេចថា នៅពេលសំណុំ

---

D308/3/1/20) កថាខណ្ឌ ៧៥, ៧៩។ សូមមើលផងដែរ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៧០។

[1474] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ៥៧ (គូសបញ្ជាក់បន្ថែម)។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៧៥។

[1475] រាជរដ្ឋាភិបាលកម្ពុជាបានចូលជាសមាជិកនៃលិខិតូបករណ៍នេះ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥០។ យោងទៅអនុសញ្ញាពហុភាគីនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគូសបញ្ជាក់ថា ប្រភពច្បាប់អន្តរជាតិចងកាតព្វកិច្ចចំពោះប្រទេសកម្ពុជា ដោយតម្រូវឱ្យរដ្ឋធ្វើការកាត់សេចក្តីចារីនៃបទល្មើសធ្ងន់ធ្ងរ។ ពួកគេអះអាងបន្ថែមទៀតថា ការជំរុញឱ្យបញ្ជូន យឹម ទិត្យ ទៅចៅក្រមអន្តរជាតិសាលាដំបូងដើម្បីជំនុំជម្រះ គឺស្របតាមការបកស្រាយកិច្ចព្រមព្រៀង អ.វ.ត.ក ដោយផ្អែកតាមច្បាប់អន្តរជាតិ។ សូមមើលបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D381/20) កថាខណ្ឌ ៣៤-៣៥។

[1476] សូមមើល អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា ៦ (គូសបញ្ជាក់បន្ថែម) ("ជនជាប់ចោទពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋដទៃទៀត ដែលមានចែងក្នុងមាត្រា ៣ ត្រូវបាន*កាត់សេចក្តី*ដោយតុលាការមានសមត្ថកិច្ចរបស់រដ្ឋដែលបទល្មើសបានកើតឡើងលើទឹកដីខ្លួន ឬដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដែលអាចមានយុត្តាធិការ ដោយសាររដ្ឋភាគីទាំងនោះទទួលស្គាល់សមត្ថកិច្ចរបស់តុលាការនេះ")។

[1477] *ការអនុវត្តអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ (រឿងក្តីប្រទេសបូស្នីនិងហ៊ឺហ្សេហ្គូវីន ទល់នឹង ប្រទេសស៊ែបនិងម៉ុងតេណេហ្គ្រូ) (ICJ)*") កថាខណ្ឌ ៤៤២ ៦ មាត្រា)[...] តម្រូវឱ្យរដ្ឋកិច្ចសន្យាបង្កើត និងអនុវត្តយុត្តាធិការដែនដីផ្នែកព្រហ្មទណ្ឌ")។

01677384



រឿងរបបខ្មែរក្រហម ដែលគ្របដណ្ដប់ទៅលើអំពើប្រល័យពូជសាសន៍ ស្ថិតនៅក្នុងបណ្ដឹង ឬ យុត្តាធិការរបស់ អ.វ.ត.ក រួមទាំងចំពោះសំណុំរឿង ដែលស្ថិតក្រៅយុត្តាធិការបុគ្គលរបស់ខ្លួន[1479] ឬសំណុំរឿងដែលអះអាងថា មិនអាចបញ្ជូនទៅជំនុំជម្រះ ដោយមូលហេតុរដ្ឋបាលនោះ[1480] វាគឺជាការទទួលខុសត្រូវរបស់ តុលាការជាតិក្នុងការបន្តស្វែងរកយុត្តិធម៌ព្រហ្មទណ្ឌ តាមរយៈការសម្រេចប្រើប្រាស់យុត្តាធិការជំនុំជម្រះពេញលេញរបស់ខ្លួន[1481] នៅក្នុងលក្ខណៈដូចគ្នានឹងការជំនុំ

---

[1478] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ៥៩។ សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៧៥, ៧៩។ សូមមើលផងដែរ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៧០។

[1479] ជាពិសេស ដីកាសម្រេចលើកលែងការចោទប្រកាន់ដែលត្រូវបានចេញដោយផ្អែកលើការដែល អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គល មិនបានសម្រេចទៅលើករណីថាតើ មាន ឬមិនមានភ័ស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ទៅតាមអត្ថន័យនៃវិធាន ៦៧(៣)(គ) នៃវិធានផ្ទៃក្នុងនោះទេ។ សូមមើល សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៧១។ ម៉្យាងវិញទៀត វាមិនមែនជាការកំណត់តាមផ្លូវច្បាប់ពីបទចោទប្រកាន់ព្រហ្មទណ្ឌទេ និងត្រូវញែកឲ្យដាច់ពីការសម្រេចរបស់តុលាការឲ្យជនត្រូវចោទរួចទោស ដោយផ្អែកលើការសន្និដ្ឋានវិជ្ជមានទាក់ទងនឹងបទចោទពាក់ព័ន្ធ។ សូមមើលឧទាហរណ៍ សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៣៤០។

[1480] ចៅក្រមអន្តរជាតិបានសន្និដ្ឋាននាពេលកន្លងមកថា បុរេលក្ខខណ្ឌតម្រូវរដ្ឋបាលអំពីការជូនដំណឹង និងការបញ្ជូន ត្រូវបានតាក់តែងដើម្បីជាលេសដ៏ល្អក្នុងការធ្វើឲ្យកិច្ចដំណើរការនីតិវិធីឈានដល់ការបញ្ចប់ ដោយកត់សម្គាល់ថា សំអាងហេតុរបស់ចៅក្រមអន្តរជាតិតុលាការកំពូលពាក់ព័ន្ធនឹងអសមត្ថភាពរបស់ចៅក្រមអន្តរជាតិសាលាដំបូងក្នុងការបន្តនីតិវិធីទៅមុខទៀត គឺផ្អែកលើកំហុសអង្គច្បាប់ធ្ងន់ធ្ងរដែលអាចចាត់ជា និងធ្វើឲ្យច្របូកច្របល់ភាពផ្លូវការផ្នែករដ្ឋបាលក្នុងការបញ្ជូនសំណុំរឿងដែលមានការរារាំងយុត្តាធិការ ដែលហាមឃាត់ចៅក្រមអន្តរជាតិសាលដំបូងមិនឲ្យបំពេញកិច្ចបាន។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK ជើងទំព័រ ៥៩៤។ *ផ្ទុយពី* សំណុំរឿង ០០៤/២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ (ឯកសារ E004/2/1/1/2) កថាខណ្ឌ ៤៩-៥០, ៥៧។

[1481] សំណុំរឿង ០០៤/២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 & D360/33) កថាខណ្ឌ ៥៩។ សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) កថាខណ្ឌ ៧៩ ("កត់សម្គាល់ថា នៅក្នុងច្បាប់ជាធរមានរបស់ អ.វ.ត.ក មិនបានហាមឃាត់មិនឲ្យមានការបញ្ជូនប្រភេទនៃរឿងក្ដីដែលស្ថិតក្រោមយុត្តាធិការមានកម្រិតរបស់ខ្លួន ត្រឡប់ទៅឲ្យស្ថិតក្រោមយុត្តាធិការរបស់តុលាការកម្ពុជាធម្មតា នៅពេលដែល អ.វ.ត.ក លែងមានអត្ថិភាព")។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា

ជម្រះទៅលើបទល្មើសដែលត្រូវចោទប្រកាន់ដែលមានលក្ខណៈធ្ងន់ធ្ងរ តាមច្បាប់ជាតិ[1482]។ ហេតុដូច្នេះ ច្បាស់ណាស់ថា ការលើកលែងចោទប្រកាន់ ឬការបិទបញ្ចប់សំណុំរឿងប្រល័យពូជសាសន៍ ដោយ អ.វ.ត.ក ផ្អែកទៅលើមូលដ្ឋានយុត្តាធិការ ដោយមិនទាក់ទងជាមួយធាតុផ្សំ នៃបទចោទព្រហ្មទណ្ឌដែលពាក់ព័ន្ធនោះ គឺមិនបានធ្វើឲ្យយុត្តាធិការជាតិ រួចផុតពីការអនុវត្តភារកិច្ចតាមផ្លូវតុលាការរបស់ខ្លួននោះឡើយ[1483]។

528. ចៅក្រមអន្តរជាតិកត់សម្គាល់ដោយក្ដីសោកស្ដាយថា បន្ទាប់ពីមានការលើកលែងចោទប្រកាន់ ឬការបិទបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំង អោ អាន នៅក្នុងសំណុំរឿង ០០៤/២ (ដែលត្រូវបានចោទប្រកាន់ ពីបទប្រល័យពូជសាសន៍ជនជាតិចាម) និង មាស មុត ក្នុងសំណុំរឿង ០០៣ (ដែលត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ជនជាតិវៀតណាម)[1484] ស្ថាប័នអយ្យការជាតិកម្ពុ

---

ដំណោះស្រាយ (ឯកសារ D266/27 & D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៧០។

[1482] ទំព័រ ៤២២ និង ៤៥៦ កថាខណ្ឌ ៩០, ៩៤។

[1483] ស្រដៀងគ្នាដែរ នៅក្នុង *កាតព្វកិច្ចជំនុំជម្រះ ឬធ្វើបត្យាប័ន (រឿងក្ដីប្រទេសប៊ែលហ្ស៊ិក តទល់នឹងប្រទេសសេណេហ្គាល់)* នៅពេលប្រឈមនឹងអំណះអំណាងរបស់ប្រទេសសេណេហ្គាល់ថា វាជា "កម្មវត្ថុនៃសិទ្ធិអំណាច" របស់តុលាការយុត្តិធម៌ ECOWAS ទាក់ទងនឹងករណីរបស់ Hissène Habré តុលាការ ICJ "បានពិចារណាថា កាតព្វកិច្ចរបស់ប្រទេសសេណេហ្គាល់ក្នុងការអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនស្របតាមអនុសញ្ញា [ប្រឆាំងការធ្វើទារុណកម្ម] មិនអាចរងផលប៉ះពាល់ដោយសេចក្ដីសម្រេចរបស់តុលាការយុត្តិធម៌ ECOWAS ទេ" *កាតព្វកិច្ចជំនុំជម្រះ ឬធ្វើបត្យាប័ន (រឿងក្ដីប្រទេសប៊ែលហ្ស៊ិក តទល់នឹងប្រទេសសេណេហ្គាល់)* សាលក្រម តុលាការ ICJ របាយការណ៍ឆ្នាំ២០១២ (ថ្ងៃទី២០ ខែកក្កដា) ទំព័រ ៤២២ ("*កាតព្វកិច្ចជំនុំជម្រះ ឬធ្វើបត្យាប័ន (ICJ)*") កថាខណ្ឌ ១១០-១១១។

[1484] ស្រដៀងគ្នាដែរ ពុំមានចំណាត់ការណាមួយត្រូវបានអនុវត្តដោយអាជ្ញាធរកម្ពុជាប្រឆាំងនឹង អ៊ឹម ចែម នៅក្នុងសំណុំរឿង ០០៤/១ បន្ទាប់ពីអ្នកស្រីត្រូវបានលើកលែងការចោទប្រកាន់ ដោយមូលហេតុពុំមានយុត្តាធិការបុគ្គល។ ទោះបីជា អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ក៏ដោយ ក៏ចៅក្រមអន្តរជាតិបានកត់សម្គាល់ថា ការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងអ្នកស្រី រួមមាន ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម គួរត្រូវបានដោះស្រាយនៅចំពោះមុខតុលាការជាតិ។ សូមមើល សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET កថាខណ្ឌ ៣៤០។ សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៧៥។ សូមមើលផងដែរ សំណុំរឿង ០០៤/១ សំអាងហេតុនៃដីកាដំណោះស្រាយ (ឯកសារ D308/3) កថាខណ្ឌ ៣០៦-៣១១។

01677386



ជា មិនបានបំពេញកិច្ច ឬបង្ហាញពីចេតនាណាមួយក្នុងការបំពេញកិច្ច ដើម្បីចាប់ផ្តើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងបុគ្គលទាំងអស់នេះឡើយ។

529. ចៅក្រមអន្តរជាតិកត់សម្គាល់បន្ថែមថា ទោះបីជាការយល់ឃើញរបស់ខ្លួនថា ការិយាល័យសហព្រះរាជអាជ្ញារបស់ អ.វ.ត.ក មានលទ្ធភាព និង "មានការទទួលខុសត្រូវ" ក្នុងការចាប់ផ្តើមការជំនុំជម្រះ នៅក្នុងតុលាការជាតិ[1485]ក្តី តែសហព្រះរាជអាជ្ញាអន្តរជាតិ ចង្អុលបញ្ជាក់ថា គាត់មិនមានចេតនាបន្តការចោទប្រកាន់ជនត្រូវចោទនៅ អ.វ.ត.ក នៅក្នុងតុលាការធម្មតារបស់កម្ពុជាឡើយ ហើយគាត់ក៏មិនជឿថា សហការីជាតិរបស់គាត់ ឬអាជ្ញាធរកម្ពុជាដទៃទៀត មានចេតនាចោទប្រកាន់ដូច្នេះដែរ ដោយគាត់បានរៀបរាប់ថា សកម្មភាពបែបនេះគឺ "មិនប្រាកដប្រជា" និង "មានលក្ខណៈទាយស្មានខ្លាំង"[1486]។

530. ដោយសារតែមិនមានការខិតខំប្រឹងប្រែងពិតប្រាកដជាបន្តបន្ទាប់ក្នុងការជំនុំជម្រះ ដោយអាជ្ញាធរកម្ពុជា ទាំងនៅកម្រិតជាតិ និងកម្រិតអន្តរជាតិ[1487] ចៅក្រមអន្តរជាតិសូមរម្លឹកអំពីកាតព្វកិច្ចដែលអនុវត្ត*ចំពោះគ្រប់ភាគី (erga omnes partes)* របស់រាជរដ្ឋាភិបាលកម្ពុជា តាមអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍[1488] ដើម្បីធានាថា កម្មាភិបាលខ្មែរក្រហម ដែលត្រូវបានចោទប្រកាន់ពី

---

[1485] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 & D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៧៣-១៧៤។

[1486] សំណុំរឿង ០០៣ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់ចៅក្រមអន្តរជាតិសាលាដំបូង ឯកសារ D270 ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ កថាខណ្ឌ ១៧។

[1487] ដូចបានសង្កេតឃើញនៅក្នុងសំណុំរឿង ០០៤/១ សំណុំរឿង ០០៤/២ [និងសំណុំរឿង ០០៣] និងបច្ចុប្បន្ន ក៏អាចមាននៅក្នុងសំណុំរឿង ០០៤ ដែរ។

[1488] សូមមើល អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ បុព្វកថា ("ដើម្បីរំដោះមនុស្សជាតិឱ្យរួចផុតពីមហាភ័យដ៏គួរឱ្យស្អប់ខ្ពើមនេះ គឺ*តម្រូវឱ្យមាន*កិច្ចសហប្រតិបត្តិការអន្តរជាតិ") (គូសបញ្ជាក់បន្ថែម) និងមាត្រា ៩។ លើសពីនេះទៀត តុលាការយុត្តិធម៌អន្តរជាតិថ្មីៗនេះ បានពន្យល់នៅក្នុងករណីរបស់ Hissène Habré ក្នុងបរិបទនៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មថា រដ្ឋភាគីនៃអនុសញ្ញា "មានផលប្រយោជន៍រួមក្នុងការធានា យោងតាមគុណតម្លៃរួមរបស់ពួកគេ ថា ការធ្វើទារុណកម្មត្រូវបានបង្ការ ហើយប្រសិនបើមានការធ្វើទារុណកម្ម ជនដែលធ្វើទារុណកម្មមិនទទួលបាននូវនិទណ្ឌភាពទេ [...] រដ្ឋភាគីផ្សេងទៀតទាំងអស់មានផលប្រយោជន៍រួម ដោយអនុលោមតាម [...] រដ្ឋភាគីទាំងអស់មាន "ផលប្រយោជន៍ស្របច្បាប់" ក្នុងការការពារសិទ្ធិពាក់ព័ន្ធ។ កាតព្វកិច្ចទាំងនេះអាចត្រូវបានកំណត់ថាជា "*កាតព្វកិច្ចដែលអនុវត្តចំពោះគ្រប់ភាគី (erga omnes partes)*" ក្នុងន័យថារដ្ឋភាគីនីមួយៗមានផលប្រយោជន៍ អនុលោមតាមកាតព្វកិច្ចទាំងនេះ ក្នុងករណីណាមួយ។ ក្នុងន័យនេះ *បទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម គឺប្រហាក់ប្រហែលនឹងអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍*

បទប្រល័យពូជសាសន៍ ត្រូវបានចោទប្រកាន់ និងជំនុំជម្រះដោយតុលាការយុត្តិធម៌មានសមត្ថកិច្ច និងសូមអះអាងឡើងវិញថា ដោយផ្អែកលើភស្តុតាងដែលបានប្រមូល ក្នុងសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ នោះ អាជ្ញាធរកម្ពុជាមានកាតព្វកិច្ចត្រូវទទួលខុសត្រូវក្នុងការជំនុំជម្រះលើជនជាប់ចោទ ប្រសិនបើ អ.វ.ត.ក មិនអាចបន្តកិច្ចដំណើរការនីតិវិធីបានជាបន្តទៀតទេនោះ។

## *ខ. សេចក្តីសន្និដ្ឋានលើអានុភាពគតិយុត្តិនៃស្ថានភាពដែលបង្កដោយដីកាពីរផ្ទុយគ្នា របស់សហចៅក្រមស៊ើបអង្កេត*

531. អ.វ.ត.ក បានបង្ហាញសមត្ថភាពរបស់ខ្លួនក្នុងការដឹកនាំការស៊ើបអង្កេត។ ជាក់ស្តែងចាប់តាំងពីឆ្នាំ ២០០៩ ការស៊ើបអង្កេតចំនួនបួនត្រូវបានធ្វើចប់ទាំងលំបាកលំបិន ក្នុងលក្ខខណ្ឌយ៉ាងស្មុគស្មាញ[1489]។ ការស៊ើបអង្កេតនេះបានបង្ហាញអោយឃើញការជាប់ពាក់ព័ន្ធរបស់បុគ្គលបួនរូប[1490] ក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរដល់ថ្នាក់សហព្រះរាជអាជ្ញាអន្តរជាតិមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបើកការស៊ើបអង្កេត។ បើទោះជាមានភាពចម្រូងចម្រាស់ទាក់ទងនឹងយុត្តាធិការរបស់ អ.វ.ត.ក ក៏ដោយ ក៏ពុំមានចៅក្រមស៊ើបអង្កេត ឬចៅក្រមនៃអង្គបុរេជំនុំជម្រះណាម្នាក់ ជំទាស់នឹងអង្គហេតុជាក់ស្តែងក្នុងរឿងក្តីដែរ។ ជាក់ស្តែង ពុំមានការមន្ទិលសង្ស័យទាល់តែសោះថា បុគ្គលទាំងបួនរូបនេះ ជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ បំផុតដែលត្រូវបានស៊ើបអង្កេត ក្នុងសំណុំរឿង ០០៣, ០០៤/១, ០០៤/២ និង០០៤[1491]។ អង្គបុរេជំនុំជម្រះទាំងមូលគ្មានការងឿងឆ្ងល់ទាល់តែ

---

[...] រដ្ឋភាគីណាមួយនៃអនុសញ្ញា [ប្រឆាំងការធ្វើទារុណកម្ម] *អាចអំពាវនាវឲ្យរដ្ឋភាគីមួយផ្សេងទៀតមានទំនួលខុសត្រូវ* ក្នុងមានគោលបំណងដើម្បីបញ្ជាក់អំពីការចោទប្រកាន់ពីការខកខានមិនអនុវត្តតាម*កាតព្វកិច្ចដែលអនុវត្តចំពោះគ្រប់ភាគី*របស់ខ្លួន [...] និងមិនបញ្ចប់ការបរាជ័យនោះ" *កាតព្វកិច្ចជំនុំជម្រះ ឬធ្វើបត្យាប័ន (ICJ)* កថាខណ្ឌ ៦៨-៦៩ (គូសបញ្ជាក់បន្ថែម)។

[1489] ឧទាហរណ៍ សូមមើល សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៣៨ និងកថាខណ្ឌ ២៤២ (ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងការបដិសេធមិនពិចារណាលើភស្តុតាងដែលដាក់បញ្ចូលក្នុងសំណុំរឿង ក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ និងការបដិសេធមិនទទួលស្គាល់កិច្ចការរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ទោះបីជាត្រូវបានតែងតាំងត្រឹមត្រូវក៏ដោយ)។

[1490] បុគ្គលម្នាក់ក្នុងចំណោមនោះ គឺ អោ អាន បានទទួលមរណភាពតាំងពីពេលនោះមក។

[1491] [1491] សូមមើល សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ឯកសារ D382) កថាខណ្ឌ ៣២៣-៩៤១, សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (ឯកសារ D381) កថាខណ្ឌ ១៨៨-៤២៣, សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ឯកសារ D267) កថាខណ្ឌ ១៤៩-៤៥៥, សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (ឯកសារ D266) កថាខណ្ឌ ៥៥-៣៥៣, សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយ (ឯកសារ D360) កថាខណ្ឌ ១៥៧-៦៩៦, សំណុំរឿង ០០៤/

01677388



សោះថាបុគ្គលទាំងបួនរូបត្រូវតែមកបំភ្លឺអំពីអង្គហេតុទាំងនេះ ចំពោះមុខតុលាការមានសមត្ថកិច្ច[1492]។ ប្រសិនបើ អ.វ.ត.ក ពុំមានយុត្តាធិការ វាជារឿងធម្មតាដែលតុលាការជាតិមានសមត្ថកិច្ចចំពោះអង្គហេតុទាំងនេះ[1493]។

532. សួរថាតើរឿងក្តីបែបនេះនឹងត្រូវប្រព្រឹត្តទៅចំពោះមុខតុលាការជាតិឬយ៉ាងណា? វាមិនមែនជាកាតព្វកិច្ចរបស់ចៅក្រមនៃអង្គបុរេជំនុំជម្រះនោះទេ តែជាទំនួលខុសត្រូវរបស់តុលាការកម្ពុជាក្រោមការសង្កេតមើលពីសំណាក់សហគមអន្តរជាតិ[1494]។

---

២ ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (ឯកសារ D359) កថាខណ្ឌ ៧៧-៤២០, សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) (ឯកសារ D308/3) កថាខណ្ឌ ១៩០-២៤៣។

[1492] នៅពេលផ្តល់សុពលភាពដល់ដីកាសម្រេចលើកលែងការចោទប្រកាន់ ក្នុងសំណុំរឿង ០០៤/២ ព្រមទាំងដីកាសម្រេចលើកលែងការចោទប្រកាន់ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០៣ (សំណុំរឿង ០០៤) ចៅក្រមជាតិនៃចៅក្រមអន្តរជាតិទទួលយកគោលជំហរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ នៅក្នុងសំណុំរឿងទាំងនេះ ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើជនជាប់ចោទ ប៉ុន្តែ ជាទូទៅ មិនជំទាស់នឹងអត្ថិភាពនៃអង្គហេតុដែលបានស៊ើបសួរ និងតួនាទីរបស់ជនជាតិចោទទេ។ ចៅក្រមជាតិគ្រាន់តែបដិសេធមិនកំណត់អត្តសញ្ញាណជនជាប់ចោទទាំងនេះថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមប៉ុណ្ណោះ។ ឧទាហរណ៍ សូមមើល សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ធុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ២៩២ ("[...] ក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានលើកឡើងអំពីលទ្ធផលនៃការស៊ើបអង្កេតលើយុត្តាធិការបុគ្គលទេ ហើយផ្តោតតែទៅលើអង្គហេតុ។ ហើយបើធ្វើការស៊ើបអង្កេតតាមរបៀបនេះ រាល់មន្ត្រីខ្មែរក្រហមទាំងអស់នឹងក្លាយជាកម្មវត្ថុនៃការយកមកកាត់ទោស នៅ អ.វ.ត.ក។ [...] សកម្មភាពរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្ទុយទៅនឹងកម្មវត្ថុនៃការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីរ ត្រង់ថាកម្មវត្ថុនៃការខ្វែងនោះ គឺយុត្តាធិការបុគ្គល មិនមែនអង្គហេតុនោះឡើយ")។

[1493] សំណុំរឿង ០០៤/១ (អបជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 ("សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20)") កថាខណ្ឌ ៧៩។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) កថាខណ្ឌ ៥៧។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ១៧០ និងកថាខណ្ឌ ១៧២។

[1494] សូមមើលខាងលើ កថាខណ្ឌ ៥៣០។

533. អ.វ.ត.ក បានបង្ហាញសមត្ថភាពខ្លួនក្នុងការស៊ើបអង្កេតលើអង្គហេតុឧក្រិដ្ឋធ្ងន់ធ្ងរមិនធ្លាប់មានបន្ទាប់ពីអង្គហេតុពិនិត្យនៅក្នុងការជំនុំជម្រះក្តីនៅតុលាការ Nuremberg ហើយកិច្ចការនេះអាចធ្វើទៅបាន ដោយសារការអនុវត្តយ៉ាងម៉ត់ចត់នូវលិខិតបទដ្ឋានគតិយុត្តិជាធរមានចំពោះមុខ អ.វ.ត.ក រួមបញ្ចូលទាំងបទដ្ឋានមួយចំនួនដែលអនុម័តដោយចៅក្រមខ្លួនឯងផ្ទាល់ ក្រោមទម្រង់ជាវិធានផ្ទៃក្នុង។ ការគោរពដ៏ម៉ត់ចត់ចំពោះលិខិតបទដ្ឋានគតិយុត្តិទាំងនេះបង្ហាញពីសុច្ចរិតភាពនៃនីតិវិធី និងការប្រើប្រាស់គោលការណ៍បន្តការស៊ើបអង្កេត និងការចោទប្រកាន់។ យន្តការនេះជាស្នូលរបស់ អ.វ.ត.ក និងមានគុណតម្លៃជាអន្តរជាតិចំពោះហត្ថលេខីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក[1495]។ វាមានតម្លៃគតិយុត្តិដ៏ឧត្តុង្គឧត្តមចំពោះចៅក្រម និងសហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិដែលបានអញ្ជើញឲ្យមកបម្រើការក្នុងតុលាការនេះ[1496]។

534. ដោយឡែក ពិតមែនតែ អ.វ.ត.ក បានបង្ហាញពីសមត្ថភាពរបស់ខ្លួនក្នុងការស៊ើបអង្កេតលើអង្គហេតុទាំងនេះ ក៏ប៉ុន្តែ ចាប់ពីពេលនេះតទៅ អ.វ.ត.ក បង្ហាញថាខ្លួនអសមត្ថភាពក្នុងការជំនុំជម្រះជនជាប់ចោទ។ វាទៅជាដូច្នេះពីព្រោះគោលការណ៍ជាមូលដ្ឋានស្តីពីការបន្តកិច្ចស៊ើបសួរ និងចោទប្រកាន់ លែងដំណើរការហើយ។ វាមិនដំណើរការ ពីព្រោះផ្នែកមួយចំនួននៃ អ.វ.ត.ក បានប្រាសចាកយ៉ាងឆ្ងាយពីលិខិតបទដ្ឋានគតិយុត្តិ ដោយជ្រើសរើសយកការបកស្រាយ តាមទំនើង ចិត្ត និងការប្រើប្រាស់ឆន្ទានុសិទ្ធិក្លែងក្លាយ។ ការចុះសម្រុងគ្នារវាងសហចៅក្រម ស៊ើបអង្កេត បណ្តាលឱ្យមានការយល់ច្រឡូកច្រឡំរហូតដល់មានការយល់ខុសដោយចេតនានិងមិនអាចកែ បាន អំពីយន្តការច្បាប់សំខាន់ៗនៅ អ.វ.ត.ក ដែលក្នុងចំណោមនោះមាន គោលការណ៍បន្ត ការស៊ើបអង្កេត និងចោទប្រកាន់។

---

[1495] សូមមើល កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក បុព្វកថា។

[1496] ឧទាហរណ៍ សូមមើល ករណីខ្វែងយោបល់គ្នា លេខ ០០១/១៨-១១-២០០៨-អវតក/អបជ សេចក្តីពិចារណារបស់ចៅក្រមអន្តរជាតិពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 (ចៅក្រមជាតិនៃចៅក្រមអន្តរជាតិបានសម្តែងការមិនយល់ស្របនឹងការចាប់ផ្តើមការចោទប្រកាន់ ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ប៉ុន្តែ បានទទួលយកយ៉ាងត្រឹមត្រូវនូវឧត្តមភាពនៃគោលការណ៍បន្តកិច្ចស៊ើបសួរ និងចោទប្រកាន់)។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ធុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ២៧៤ ("ស.ព.ជ បានប្តឹងជំទាស់ឲ្យពិចារណាលើបញ្ហានៃការខ្វែងយោបល់ ដែលជាកម្មវត្ថុនឹងត្រូវបានបញ្ជូនទៅ អ.ប.ជ។ ជាលទ្ធផល អ.ប.ជ រកសំឡេងមិនបាន ដែលការនេះជាផលវិបាកផ្នែកគតិយុត្តិ ក្នុងបរិបទ អ.វ.ត.ក ដែលនាំឲ្យដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានអានុភាពគតិយុត្តិកើតឡើង")។

535. ទាក់ទងនឹងសំណុំរឿង ០០៤/២ ចៅក្រមអន្តរជាតិបានរំលឹកជាច្រើនលើកមកហើយថា នីតិវិធីត្រូវបានបញ្ជូនដោយក្រឡាបញ្ជីពីររូបនៃចៅក្រមអន្តរជាតិ[1497] ទៅសាលាជំនុំជម្រះក្តី។ បន្ទាប់មក ក៏មានទង្វើមួយចំនួនផ្ទុះបញ្ចាំងពីភាពតានតឹងក្នុងអារម្មណ៍ ដែលក្នុងចំណោមទង្វើទាំងនោះ មានសារអេឡិកត្រូនិកមួយរបស់ប្រធានចៅក្រមអន្តរជាតិ គ្មានមូលដ្ឋានច្បាប់[1498] ការបកស្រាយ បំពេញចិត្តរដ្ឋបាលតុលាការទាំងមូលមួយ[1499] និងការចុះផ្សាយសេចក្តីប្រកាសសារព័ត៌មាន មួយដ៏

[1497] ទោះបីជាក្រឡាបញ្ជីតែម្នាក់របស់ចៅក្រមអន្តរជាតិជាអ្នកស្នើសុំផ្ទេរសំណុំរឿងជាផ្លូវការក៏ដោយ ក៏ក្រឡាបញ្ជីម្នាក់ទៀតរបស់ចៅក្រមអន្តរជាតិមានវត្តមាន នៅពេលប្រគល់ឯកសារជូនការិយាល័យរដ្ឋបាល ដើម្បីដាក់ និងជូនដំណឹង។ ទោះជាយ៉ាងនេះក្តី ចៅក្រមអន្តរជាតិបានបញ្ជាក់អះអាងជាថ្មីថា មានការចាត់វិធានការចាំបាច់ និងតម្រូវ សម្រាប់ការផ្ទេរសំណុំរឿង ០០៤/២ ជូនចៅក្រមអន្តរជាតិសាលាដំបូង យ៉ាងត្រឹមត្រូវហើយ។ សូមមើល សំណុំរឿង ០០៤/០២ ទម្រង់បែបបទដាក់ និងជូនដំណឹងអំពីសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33), ឧបសម្ព័ន្ធក នៃអនុស្សរណៈអន្តរការិយាល័យរបស់ចៅក្រមអន្តរជាតិ ស្តីពីការការផ្ទេរសំណុំរឿង ០០៤/២ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/36.4 និង D360/45.4។ សំណុំរឿង ០០៤/២ ទម្រង់បែបបទណែនាំសម្រាប់ការជូនដំណឹង ដែលក្រឡាបញ្ជីរបស់ចៅក្រមអន្តរជាតិបានប្រគល់ដោយផ្ទាល់ដៃ ដល់មន្ត្រីគ្រប់គ្រងសំណុំរឿង ដើម្បីជូនដំណឹងអំពីសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) ដល់ចៅក្រមអន្តរជាតិសាលាដំបូង, ឧបសម្ព័ន្ធទី ៤ នៃអនុស្សរណៈអន្តរការិយាល័យរបស់ចៅក្រមអន្តរជាតិ ស្តីពីការផ្ទេរសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ឯកសារ D359/36.4 និង D360/45.4។

[1498] សូមមើលសំណុំរឿង ០០៤/២ អ៊ីមែលរបស់ក្រឡាបញ្ជីអន្តរជាតិនៃអង្គបុរជំនុំជម្រះ ជម្រាបជូនចៅក្រមអន្តរជាតិ អំពីសេចក្តីណែនាំរបស់ក្រឡាបញ្ជីជាតិដល់មន្ត្រីគ្រប់គ្រងសំណុំរឿង ពាក់ព័ន្ធនឹងការជូនដំណឹងអំពីសេចក្តីពិចារណា ក្នុងសំណុំរឿង ០០៤/២, ឧបសម្ព័ន្ធទី ៣ នៃអនុស្សរណៈអន្តរការិយាល័យរបស់ចៅក្រមអន្តរជាតិ ស្តីពីការផ្ទេរសំណុំរឿង ០០៤/២ ឯកសារ D359/36.3 និង D360/45.3។ ដោយរំលោភលើគោលការណ៍បន្តកិច្ចចោទប្រកាន់ និងសំឡេងភាគច្រើនលើបលុប ដែលមានតម្លៃជាអន្តរជាតិ អ៊ីមែលនេះទាមទារឲ្យមានឯកច្ឆន្ទភាពពីចៅក្រម ដើម្បីផ្ទេរសំណុំរឿងទៅចៅក្រមអន្តរជាតិ ។

[1499] សូមមើល សំណុំរឿង ០០៤/២ អនុស្សរណៈអន្តរការិយាល័យរបស់ការិយាល័យរដ្ឋបាល ស្នើសុំការបំភ្លឺ អនុលោមតាមវិធាន ១០(២) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការជូនដំណឹងអំពីសេចក្តីពិចារណា ក្នុងសំណុំរឿង ០០៤/២, ឧបសម្ព័ន្ធទី ៧ នៃអនុស្សរណៈផ្ទៃក្នុងរបស់ចៅក្រមអន្តរជាតិ ស្តីពីការផ្ទេរសំណុំរឿង ០០៤/២ ឯកសារ D359/36.7 និង D360/45.7 ។

សាមញ្ញរបស់សាលាជំនុំជម្រះក្តី[1500] បដិសេធសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំឱ្យខ្លួនពិនិត្យដីកាបញ្ជូនរឿងឱ្យស៊ើបសួរ[1501]។

536. នៅក្នុងសំណុំរឿង ០០៣ ដែលត្រូវបានយកមកគិតស្មើរតែតាមទំនើងចិត្ត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានចេញដីការចោទប្រកាន់បុគ្គលម្នាក់ពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មតាមច្បាប់ជាតិដទៃទៀត បែរជាប្រកាសថាខ្លួនត្រៀមខ្លួនរួចរាល់ក្នុងការបញ្ចប់សំណុំរឿង[1502]។

537. ក្នុងចំណោមឧបសគ្គរបស់ អ.វ.ត.ក ភាពវឹកវរដែលកើតចេញពីការចេញដីកាដំណោះស្រាយផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ មានលក្ខណៈពិសេសយ៉ាងសំខាន់ដែលនឹងអាចសម្លាប់កិច្ចដំណើរការនីតិវិធីកន្លងមក។

538. ចៅក្រមអន្តរជាតិធ្លាប់បានបង្ហាញថា ខ្លួនមានសមត្ថភាពសម្រេចអំពីភាពមិនស្របច្បាប់នៃការអនុវត្តមិនត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេត។ អង្គបុរេមិនមានសមត្ថភាពសម្រេចជាឯកច្ឆ័ន្ទទាំងប្រាំសម្លេងលើដីកាណាមួយនោះឡើយ។ ប៉ុន្តែ នេះមិនមែនជាកាតព្វកិច្ចរបស់ចៅក្រមឡើយ។

---

សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីថ្លែងការណ៍របស់ចៅក្រមចៅក្រមអន្តរជាតិសាលាដំបូងនៃ អ.វ.ត.ក ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០៖ https://www.eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao (ចូលមើលលើកចុងក្រោយ៖ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១។

[1501] សំណុំរឿង ០០៤/២ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើដល់ចៅក្រមអន្តរជាតិសាលាដំបូងចាត់វិធានការ ដើម្បីទទួលបានសិទ្ធិចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង នៃសំណុំរឿង ០០៤/២ (អោ អាន) ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D363/1.1.8។

[1502] សូមមើលសំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅចៅក្រមអន្តរជាតិសាលាដំបូង ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឯកសារ D270/7 ("សេចក្តីសម្រេចបដិសេធសំណើសុំបញ្ជូនសំណុំរឿង ០០៣ (ឯកសារ D270/7)" កថាខណ្ឌ ១៩ ("ប្រសិនបើពួកយើងបានទទួលការជូនដំណឹងបែបនេះអំពីមតិរួមគ្នារបស់ចៅក្រមអន្តរជាតិ ក្នុងលក្ខណៈលឿនជាងនេះនោះ សំណុំរឿងដែលនៅសល់ទាំងអស់អាចនឹងត្រូវបានដោះស្រាយឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន តាមរយៈសេចក្តីសម្រេចរួមដែលអាចត្រឹមតែជាការបញ្ចប់ភ្លាមៗនូវសំណុំរឿងទាំងអស់ដែលនៅសេសសល់ បន្ទាប់ពីការលើកលែងចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤/១ ដូចដែលយើងពន្យល់លម្អិតបន្ថែមទៀតខាងក្រោមនេះ។ ជាចុងក្រោយ ប៉ុន្តែ សំខាន់ដូចគ្នានោះ ការនេះនឹងជួយធ្វើឱ្យពួកយើងចំណេញពេលវេលា និងកម្លាំងយ៉ាងច្រើន និងនិយាយឱ្យចំទៅ ក៏ជួយសន្សំមួយផ្នែកធំដល់អ្នកផ្តល់ជំនួយអន្តរជាតិ និងរាជរដ្ឋាភិបាលកម្ពុជា លើការចូលរួមចំណែកផ្នែកហិរញ្ញវត្ថុរបស់ពួកគេ សម្រាប់ថវិការបស់ អ.វ.ត.ក")។

ផ្ទុយទៅវិញ កាតព្វកិច្ចរបស់ចៅក្រម គឺសម្រេចជាឯកជន និងជាសាធារណៈលើបញ្ហាដែលដាក់ជូនចំពោះមុខខ្លួន[1503]។ ការតម្រូវឱ្យចៅក្រមអន្តរជាតិផ្តល់ដំណោះស្រាយជាឯកច្ឆ័ន្ទ ស្របតាមគោលការណ៍បន្តការស៊ើបអង្កេត និងចោទប្រកាន់ មិនមែនជាការត្រឹមត្រូវនោះទេ។

539. ក្នុងដំណាក់កាលនេះ ពុំមានការមន្ទិលសង្ស័យណាមួយលើសុពលភាពនៃដីកាចោទប្រកាន់នោះទេ[1504]។ ដោយគ្មានមន្ទិលសង្ស័យ ច្បាស់ណាស់ថាគោលការណ៍ស៊ើបអង្កេត និងចោទប្រកាន់ត្រូវយកមកអនុវត្តលើសំណុំរឿង ០០៤ និង ០០៣ ដែលកើតឡើងមុន[1505]។ វាច្បាស់ណាស់ថា អង្គហេតុឧក្រិដ្ឋដែលត្រូវបានបង្ហាញក្នុងសំណុំរឿង ០០៤ និងពីមុន នៅក្នុងសំណុំរឿង ០០៤/១ និង ០០៣ តម្រូវឱ្យមានការពិនិត្យយ៉ាងប្រញាប់ ទៅលើការចោទប្រកាន់ដ៏ធ្ងន់ធ្ងរជាច្រើនលើចារីនៃអង្គហេតុដែលមានរៀបរាប់ក្នុងដីកាដំណោះស្រាយ[1506]។

---

[1503] ឧទាហរណ៍ សូមមើល មាត្រា ២០ ថ្មី វាក្យខណ្ឌទី ៨ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងយ៉ាងច្បាស់ថា៖ ("[...] សេចក្តីសម្រេចរបស់ចៅក្រមអន្តរជាតិ [...] តម្រូវឱ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច" ដែលទាមទារជាចាំបាច់ឱ្យចៅក្រមនៃចៅក្រមអន្តរជាតិមានសេរីភាពក្នុងការសម្រេច តាមការជឿជាក់របស់ខ្លួន។ សំណុំរឿង ០០៣ សេចក្តីពិចារណារួមទៅលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D271/5 &D272/3 (កថាខណ្ឌ ៦៦, ៦៨)។

[1504] សូមមើលខាងលើ កថាខណ្ឌ ១៧៦ (សំណុំរឿង ០០៤ យោបល់របស់ចៅក្រមអន្តរជាតិ និងប្រហែលជាជាតិ លើសុពលភាពនៃដីកាសម្រេចចោទប្រកាន់), សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ធុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១១៥, សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ២៨៤ ផ្នែកសម្រេចសេចក្តី ទំព័រ ១៦១, សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៣២៦ ផ្នែកសម្រេចសេចក្តី ទំព័រ ១៤៧។

[1505] សូមមើលខាងលើ កថាខណ្ឌ ១៧៤ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D266/27 និង D267/35) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK ផ្នែកសម្រេចសេចក្តី ទំព័រ ១៦១។ សូមមើលផងដែរ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK កថាខណ្ឌ ៣១៥-៣២៨។

[1506] សូមមើលខាងលើ កថាខណ្ឌ ៥២៥-៥៣០ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D308/3/1/20) យោបល់របស់ចៅក្រម ចៅក្រម BAIK កថាខណ្ឌ ៣៤០។ សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ឯកសារ D359/24 និង D360/33) យោបល់របស់ចៅក្រម BAIK និងចៅក្រម BEAUVALLET ផ្នែកសម្រេចសេចក្តី ទំព័រ ១៤៧។ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹង

01677393

សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦១)

ឯកសារលេខ D381/45 & D382/43

# ផ្នែកសម្រេចសេចក្ដី

**អាស្រ័យដូចបានរៀបរាប់ពីខាងលើ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ÷**

**បដិសេធ** បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ

**ប្រកាសថា** បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទុកជាអសារឥតការ

**ប្រកាសថា** បណ្ដឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទុកជាអសារឥតការ

**បដិសេធ** បណ្ដឹងឧទ្ធរណ៍របស់ សហមេធាវីការពារក្ដី យឹម ទិត្យ (ដីកាដំណោះស្រាយពីរ)

**បដិសេធ** មូលដ្ឋានទី ២.២, ៣, ៤, ៥ នៃបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី យឹម ទិត្យ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)

**យល់ឃើញថា** ដីកាសម្រេចលើកលែងចោទប្រកាន់ ទុកជាមោឃៈ

**តម្កល់** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

**យល់ឃើញថា** អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលយកសំណុំរឿង ០០៤ មកពិនិត្យ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង។

ភ្នំពេញថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០២១

**ចៅក្រម** **Olivier BEAUVALLET**

**ចៅក្រម** **Kang Jin BAIK**